# ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិ
# ដោយមានការចូលរួមពីសហគមន៍
# នៅប្រទេសកម្ពុជា



## អត្ថបទជ្រើសរើសស្តីពី ទស្សនទាន និងបទពិសោធន៍

គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍
២០០៥

ទស្សនៈដែលមាននៅក្នុងអត្ថបទនីមួយៗនៃសៀវភៅនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ឬ បណ្តាដៃគូដែលគាំទ្រនោះទេ ។

សូមទាក់ទងអ្នកនិពន្ធដោយផ្ទាល់ ចំពោះព័ត៌មានបន្ថែម ។
ព័ត៌មានទំនាក់ទំនងអ្នកនិពន្ធមាននៅក្នុងផ្នែក "ប្រវត្តិអ្នកនិពន្ធ" ។


សៀវភៅនេះមាននៅ :

**អង្គការមូលនិធិពិភពលោកសម្រាប់**
**អភិរក្សធម្មជាតិនៅប្រទេសកម្ពុជា**
ផ្ទះលេខ២៨ ផ្លូវលេខ៩ សង្កាត់ទន្លេបាសាក់
ប្រអប់សំបុត្រ: ២៤៦៧ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ: (៨៥៥ ២៣ ២១១ ៩០៩

**វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិ**
**ដោយមានការចូលរួមពីសហគមន៍**
ផ្ទះលេខ៣០ ផ្លូវលេខ៩ សង្កាត់ទន្លេបាសាក់
ប្រអប់សំបុត្រ: ២៥០៩ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥ ២៣ ៩៩៤ ៩៣៥
ទូរសារ: (៨៥៥ ២៣ ២២៤ ១៧១

*បោះពុម្ពនៅខែមករា ឆ្នាំ២០០៥ ដោយគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍*
*រូបនៅលើគម្រប : ដោយលោក សុន បូរ៉ា ក្រុម Mosaic អង្គការ WWF កម្ពុជា ។*
*រៀបចំ និងរចនាដោយ :លោកស្រី Erika von Kaschke*


## បណ្តាដៃគូដែលគាំទ្រ


គម្រោងគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីសហគមន៍- CBNRM Learning Initiative
អង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ - WWF
មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា - IDRC
អង្គការអុកស្វាមអាមេរិក - Oxfam America
មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច - RECOFTC
អង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ - FAO
នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ - DFID
ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក - Danida

# ការគ្រប់គ្រងធនធានធម្មជាតិដោយមានការ
# ចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា

## អត្ថបទជ្រើសរើសស្ដីពី
## ទស្សនទាន  និងបទពិសោធន៍


គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍

២០០៥

# បញ្ជីរាយនាមអ្នកនិពន្ធ

លោក កែន សេរីរដ្ឋា
លោក Toby Carson
កញ្ញា ហ៊ូ កល្យាណ
លោក ស្រី ម៉ារ៉ូណា
លោក Robert B. Oberndorf
លោក ញ៉ែម សុវណ្ណ
លោក ស៊ឹម ប៊ុនធឿន
លោក ថាយ សុមុនី
អ្នកស្រី សូ ស្រីមុំ
លោក ជាន ថាយុទ្ធ
កញ្ញា អ៊ូ សុភារី
អ្នកស្រី កែន សុភាព
លោក ហ៊ុយ វង្សរស្មីតារា
កញ្ញា Amanda Bradley
លោក យិន សូរិយា
លោក មិន ប៊ុណ្ណារ៉ា
លោកបណ្ឌិត Harald Kirsch

លោក Ignas Dümmer
លោក មាស សុធនវឌ្ឍនៈ
កញ្ញា សាន្ត សុជាតិលក្ខិណា
កញ្ញា Rebecca Kinakin
លោក ស៊ី រ៉ាមុនី
លោក ផាន់ កំណាព្យ
លោក គឹម សារិន
លោក ជាម មុនី
លោកបណ្ឌិត Andrew L. Maxwell
លោក អ៊ុក លីឃីម
លោក Ashish John
លោក គឹម ណុង
លោក ឃី អាន
កញ្ញា Melissa J. Marschke
លោក Doug Henderson
លោក Frank van Acker
កញ្ញា Katrin Seidel

# ពិនិត្យ កែសម្រួល រៀបចំ និង រចនា

លោក កែន សេរីរដ្ឋា
លោក Toby Carson
លោក Kenneth Riebe
លោកស្រី Steph Cox
លោកស្រី Erika von Kaschke

កញ្ញា ឃឹម វីរិយា
លោក យ៉ង ភិរម្យ
លោក ម៉ម កុសល
លោក សំអឿន សុធីរ៉ូ

# តារាងមាតិកា


ទំព័រ

សាររបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា *iii*
បុព្វកថា *v*
បញ្ជីពាក្យបំព្រួញ *vii*
សេចក្តីសង្ខេប *x*

**ផ្នែក ក: ការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា : ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត**

**ជំពូក ១ : ស្វែងយល់ពីទស្សនទានសំខាន់ៗនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍** ៣
រៀបរៀងដោយ: លោក កែន សេរីរដ្ឋា

**ជំពូក ២ : ការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា** ១៥
រៀបរៀងដោយ: លោក Toby Carson កញ្ញា ហ៊ូ កល្យាណ និង លោក ស្រី ម៉ារ៉ូណា

**ផ្នែក ខ: ការរៀបចំច្បាប់ និង ការផ្លាស់ប្តូរគោលនយោបាយ : ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍**

**ជំពូក ៣ : សេចក្តីសង្ខេបនៃគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍** ៣៩
រៀបរៀងដោយ: លោក Robert B. Oberndorf, J.D

**ជំពូក ៤ : កម្មវិធីវិមជ្ឈការសិលា និងការបញ្រ្ជាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន** ៥៣
រៀបរៀងដោយ : លោក ញ៉ែម សុវណ្ណា

**ជំពូក ៥ : កំណែទម្រង់គោលនយោបាយវិស័យជលផល និងក្របខ័ណ្ឌច្បាប់សម្រាប់សហគមន៍នេសាទ** ៦៩
រៀបរៀងដោយ: លោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និង អ្នកស្រី សូ ស្រីមុំ

**ផ្នែក គ: ការរៀបចំបណ្តាញការងារ ក្រុមការងារ និងស្ថាប័ន : កសាងទំនាក់ទំនងក្នុងចំណោមអ្នកពាក់ពន្ធ័សំខាន់ៗ**

**ជំពូក ៦ : បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ** ៨៧
រៀបរៀងដោយ: លោក ជាន ថាយុទ្ធ និង កញ្ញា អ៊ូ សុភារី

**ជំពូក ៧ : ការអភិវឌ្ឍ និងការរៀបចំបណ្តាញសហគមន៍នេសាទ** ៩៩
រៀបរៀងដោយ: លោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និងអ្នកស្រី សូ ស្រីមុំ

**ជំពូក ៨ : សហគមន៍អេកូទេសចរណ៍នៅប្រទេសកម្ពុជា: ការរៀបចំបណ្តាញការងារ និងការបង្កើតទស្សនទាន** ១១៣
រៀបរៀងដោយ: អ្នកស្រី កែន សុភាព លោក ហ៊ុយ វង្សរស្មីតារា កញ្ញា Amanda Bradley និងលោក យិន សូរិយា

**ជំពូក ៩ : ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា** ១២៩
រៀបរៀងដោយ: លោក មិន ប៊ុណ្ណារ៉ា លោកបណ្ឌិត Harald Kirsch & លោក Ignas Dümmer

ជំពូក ១០ៈ ការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា ១៤១
រៀបរៀងដោយៈ លោក មាស សុធនវឌ្ឍនៈ និងកញ្ញា សាន្ត សុជាតិលក្ខិណា

ផ្នែក ឃៈ ការរៀនសូត្រពីបទពិសោធន៍នៅមូលដ្ឋាន

ជំពូក ១១ៈ បទពិសោធន៍ពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ផ្ដោតលើឧទាហរណ៍ពីករណីសិក្សា ១៥៥
រៀបរៀងដោយៈ លោក ស្រី ម៉ារ៉ូណា កញ្ញា ហ៊ូ កល្យាណ និង កញ្ញា Rebecca Kinakin

ជំពូក ១២ៈ បទពិសោធន៍នៅមូលដ្ឋានស្ដីពីការស្រាវជ្រាវដោយអនុវត្តន៍សហគមន៍ព្រៃឈើ ១៧៥
រៀបរៀងដោយៈ លោក ស៊ី វ៉ាមុនី លោក ផាន់ កំណាព្យ និង លោក គីម សារិន

ជំពូក ១៣ៈ ការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស ១៨៩
រៀបរៀងដោយៈ លោកបណ្ឌិត Andy Maxwell លោក ជាម មុនី និងក្រុម MOSAIC

ជំពូក ១៤ៈ ផ្សារភ្ជាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ទៅនឹងដំណើរការកសាងផែនការនៅមូលដ្ឋាន ២០៣
រៀបរៀងដោយៈ លោក Ashish John

ជំពូក ១៥ៈ សិក្សា និងធ្វើការជាមួយគណៈកម្មការសហគមន៍ ២២១
រៀបរៀងដោយៈ លោក គឹម ណុង លោក អ៊ុក លីឃីម និងលោក ឃី អាន

ជំពូក ១៦ៈ ផ្ដើមចេញពីការកសាងផែនការ ឈានទៅការអនុវត្តសកម្មភាព ៖ តើគណៈកម្មការគ្រប់គ្រងធនធានអាចធ្វើអ្វីបានខ្លះ "នៅថ្នាក់មូលដ្ឋាន"? ២៤៣
រៀបរៀងដោយៈ កញ្ញា Melissa Marschke

ផ្នែក ងៈ កាលានុវត្តន៍ភាព និងការប្រឈមសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ៖ ឆ្ពោះទៅរកអភិបាលកិច្ចល្អ ការធានាសិទ្ធិកាន់កាប់ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

ជំពូក ១៧ៈ ការលើកកំពស់អភិបាលកិច្ចលើវិស័យព្រៃឈើនៅប្រទេសកម្ពុជា ៖ តួនាទីរបស់សហគមន៍ព្រៃឈើ ២៥៥
រៀបរៀងដោយៈ លោក Dough Henderson

ជំពូក ១៨ៈ ចំណងទាក់ទងរវាងសិទ្ធិមនុស្ស និងការគ្រប់គ្រងបរិស្ថាននៅប្រទេសកម្ពុជា ៖ ទស្សនទាន និងការឆ្លុះបញ្ចាំង ២៧៥
រៀបរៀងដោយៈ លោក Frank van Acker

ជំពូក ១៩ៈ តួនាទីនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ក្នុងការទទួលស្គាល់សិទ្ធិគ្រប់គ្រងដីធ្លីរបស់ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា ២៨៥
រៀបរៀងដោយៈ កញ្ញា Katrin Seidel

ជំពូក ២០ៈ វិធីសាស្ត្រនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព និងចំណងទាក់ទងជាមួយការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ៣០៧
រៀបរៀងដោយៈ កញ្ញា Rebecca Kinakin

សន្ទានុក្រម ៣២១
បញ្ជីឈ្មោះអង្គការពាក់ព័ន្ធ ៣២៩
ប្រវត្តិអ្នកនិពន្ធ ៣៣៧

# សាររបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាក្នុងការអភិវឌ្ឍលើផ្នែកគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ រួមមាន សហគមន៍ព្រៃឈើ សហគមន៍នេសាទ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា ។ ខ្ញុំសូមស្វាគមន៍ចំពោះការបង្កើត " គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ " ដែលនឹងធ្វើការដើម្បីជម្រុញការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ អភិបាលកិច្ចល្អ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជា ។

ក្នុងន័យនេះ ខ្ញុំសូមអបអរសាទរចំពោះអ្នកនិពន្ធជាច្រើន ដែលមានវិជ្ជាជីវៈ និងបទពិសោធន៍នៅក្នុងកិច្ចប្រឹងប្រែងនេះ ។ អ្នកនិពន្ធ សាស្ត្រាចារ្យ អ្នកសម្របសម្រួល និងអ្នកអនុវត្តន៍ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ទាំងនេះ បានប្រើប្រាស់ស្មារតីក្រុមការងារប្រកបដោយជោគជ័យ ដែលជាវិធីសាស្ត្រមួយដើម្បីប្រមូលផ្តុំចំណេះដឹង ជំនាញ និងបទពិសោធន៍ជាក់ស្តែងក្នុងការនិពន្ធអត្ថបទប្រកបដោយគំនិតជ្រាលជ្រៅ ការវិភាគច្បាស់លាស់ និងគួរជាទីចាប់អារម្មណ៍ ស្តីពីការគ្រប់គ្រងធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា សូមកោតសរសើរដោយស្មោះ ចំពោះកិច្ចផ្តួចផ្តើមនៃស្មារតីក្រុមការងារ និងលទ្ធផលដ៏មានអត្ថប្រយោជន៍របស់លោក លោកស្រី ។

កិច្ចប្រឹងប្រែងនេះ គូសបញ្ជាក់ពីសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធជាច្រើននៅក្នុងការកសាងផែនការ និងដំណើរការធ្វើសេចក្តីសម្រេច ដើម្បីគ្រប់គ្រងធនធានធម្មជាតិនៃប្រទេសកម្ពុជាដោយនិរន្តរភាពសម្រាប់បច្ចុប្បន្ន និងនាពេលអនាគត។ សៀវភៅនេះបង្ហាញយ៉ាងច្បាស់ថា ការផ្លាស់ប្តូរពីវិធីសាស្ត្រនៃការគ្រប់គ្រងដែលផ្តោតលើវិស័យតែមួយ ឆ្ពោះទៅវិធីសាស្ត្រនៃការគ្រប់គ្រងដែលមានការចូលរួមពាក់ព័ន្ធនឹងវិស័យច្រើនគឺជា"យុទ្ធសាស្ត្រចាំបាច់"មួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចដោយរលូន ដែលគ្មានបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន ។

ការប្តេជ្ញារបស់ប្រទេសកម្ពុជាលើការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និងវិធីសាស្ត្រគ្រប់គ្រងថ្មីអាចឃើញមាននៅក្នុងគម្រោងមួយចំនួនរបស់រដ្ឋាភិបាល រាប់បញ្ចូលទាំងកំណែទម្រង់គោលនយោបាយ និងយុទ្ធសាស្ត្រសមាហរណកម្មរហូតដល់ការផ្តល់កិច្ចគាំទ្រ និងអនុម័តសកម្មភាពនានាជាច្រើននៅកម្រិតមូលដ្ឋាន ។

ទីមួយ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកំណែទម្រង់គោលនយោបាយជាបន្តបន្ទាប់ដែលមានសារៈសំខាន់ សម្រាប់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ វិមជ្ឈការ អភិបាលកិច្ចល្អ និងកំណើនសេដ្ឋកិច្ចយ៉ាងរលូនដែលមិនបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន ។

ទីពីរ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទទួលស្គាល់តម្រូវការដើម្បីបន្តកំណែទម្រង់លើវិស័យព្រៃឈើ ជលផល និងការគ្រប់គ្រងដីធ្លី ទន្ទឹមនឹងការបង្កើនផលិតផលកសិកម្ម ព្រោះថាប្រជាពលរដ្ឋកម្ពុជានៅជនបទពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ និងកសិកម្មសម្រាប់ជីវភាពរស់នៅ ។ ចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ ដែលយុទ្ធសាស្ត្រនេះរាប់បញ្ចូលធាតុសំខាន់ៗ

នៃគោលដៅសហសវត្សរ៍ កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់កម្ពុជាសម្រាប់ឆ្នាំ ២០០១-២០០៥ (SEDP II) យុទ្ធសាស្ត្រជាតិកម្ពុជាកាត់បន្ថយភាពក្រីក្រសម្រាប់ឆ្នាំ ២០០៣-២០០៥ (NPRS) និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ព្រមទាំងកម្មវិធីកំណែទម្រង់សំខាន់ៗ ដទៃទៀតជាច្រើន ។

ទីបី រាជរដ្ឋាភិបាលកម្ពុជា គាំទ្រកិច្ចផ្តួចផ្តើមទាំងអស់ដែលគូសបញ្ជាក់ពីសារៈសំខាន់នៃការពាក់ព័ន្ធរបស់ភាគីជាច្រើននៅក្នុងដំណើរការកសាងផែនការ និងការធ្វើសេចក្តីសម្រេច។ វិធីសាស្ត្រគ្រប់គ្រងដែលមានការចូលរួមនាំឱ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជានៅជំនាន់នេះ និងអនាគត ដូចនេះវាជាការរួមចំណែកចំពោះសុខុមាលភាពនៅក្នុងតំបន់ និងលើពិភពលោក ។

ទីបួន រាជរដ្ឋាភិបាលកម្ពុជា ឯកភាពចំពោះកិច្ចប្រឹងប្រែងដ៏មោះមុតរបស់អ្នកភូមិ និងអ្នកសម្របសម្រួល ក្នុងការលើកកំពស់ការគ្រប់គ្រង និងដំណើរការកសាងផែនការសម្រាប់ធនធានធម្មជាតិនៅមូលដ្ឋាន ។ រដ្ឋាភិបាលវាយតម្លៃខ្ពស់ ចំពោះការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ប្រកបដោយសប្បុរសរបស់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការជាដៃគូទាំងអស់ ។

ទីប្រាំ រាជរដ្ឋាភិបាលកម្ពុជា មានបំណងប្រែក្លាយកំណែទម្រង់គោលនយោបាយទៅជាសកម្មភាពជាក់លាក់ដើម្បីពង្រឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៃប្រជាជាតិរបស់យើង ទន្ទឹមនឹងការអភិរក្សបេតិកភណ្ឌធម្មជាតិ និងវប្បធម៌ដ៏រុងរឿងរបស់យើង ។

ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងការកោតសរសើរចំពោះអ្នកនិពន្ធ និងក្រុមប្រឹក្សាភិបាល ព្រមទាំងក្រុមការងារនៃវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ចំពោះភាពមោះមុតក្នុងការដឹកនាំដំណើរការរៀបចំចងក្រងសៀវភៅនេះឡើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ម្ចាស់ជំនួយ និងទីភ្នាក់ងារផ្តល់ជំនួយនានា ចំពោះការ គាំទ្រដោយសប្បុរស ។ ខ្ញុំសង្ឃឹមថា ពួកគេនឹងបន្តគាំទ្រតួនាទីដែលមានសារៈសំខាន់របស់គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ថាជារបស់ជាតិ និងជាអ្នកសម្របសម្រួលសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ព្រមទាំងផ្តល់ធនធានហិរញ្ញវត្ថុ និងបច្ចេកទេសដែលត្រូវការជាចាំបាច់សម្រាប់គាំទ្រវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ដើម្បីសម្រេចការងាររបស់ខ្លួន ។



សម្តេច **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី
រាជរដ្ឋាភិបាលកម្ពុជា

# បុព្វកថា

សៀវភៅនេះ បង្ហាញពីកិច្ចសហការដ៏សំខាន់រវាងដៃគូដោយប្រមូលផ្តុំ អង្គការមិនមែនរដ្ឋាភិបាល រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយដើម្បីធ្វើការរួមគ្នា ។ ដូចគ្នានេះដែរ សៀវភៅនេះដាក់បញ្ចូលនូវលក្ខណៈដើមដែលមានវិសាលភាពចម្រុះនៃការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិតរួមបញ្ចូលទាំងទិដ្ឋភាពច្បាប់ គោលនយោបាយ និងការអនុវត្តលើវិស័យដីធ្លី ជលផល និងព្រៃឈើ ។

ទន្ទឹមនឹងបំណងអភិរក្សធនធានព្រៃឈើ និងជលផល យើងក៏ត្រូវធ្វើឱ្យប្រសើរឡើងផងដែរនូវការយល់ដឹងអំពីទំនាក់ទំនង និងការពឹងអាស្រ័យរបស់ប្រជាពលរដ្ឋក្រីក្រទៅលើធនធានទ្រព្យសម្បត្តិរួមទាំងអស់នេះ ។ យើងចាំបាច់ត្រូវធ្វើឱ្យប្រាកដថាការអភិរក្សត្រូវធ្វើឡើងប្រកបដោយសមធម៌ ព្រោះមានប្រជាពលរដ្ឋច្រើនណាស់ដែលពឹងអាស្រ័យលើការងារនេះសម្រាប់ការរស់រានមានជីវិត ។ អ្នកទាំងនោះរួមមាន ប្រជាពលរដ្ឋមួយចំនួនដែលក្រីក្រជាងគេបំផុតនៅប្រទេសកម្ពុជា ហើយដែលបានទាញយកផលប្រយោជន៍ជាច្រើន (*Unseen and under reported benefits*) សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ ។ ធនធានធម្មជាតិទ្រទ្រង់ផ្នែកជាច្រើននៃការចិញ្ចឹមជីវិត របស់ប្រជាពលរដ្ឋរួមមាន ផ្នែករូបវ័ន្ត សង្គម សេដ្ឋកិច្ច ជំនឿ និងវប្បធម៌ ។

សៀវភៅនេះផ្តោតលើការចូលរួម និងការរៀនសូត្រ ។ មានតែតាមរយៈកិច្ចសហការ ការចែករំលែកបទពិសោធន៍ និងការពិភាក្សាលើបញ្ហាធម្មជាតិទេ ដែលយើងអាចនឹងពង្រឹងការយល់ដឹង និងរកឃើញវិធីសាស្ត្រថ្មីៗ ដើម្បីធ្វើសមាហរណកម្មភាពក្រីក្រ និងបញ្ហាបរិស្ថានដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមធម៌ ។

**Mogen Laumand Christensen**
**Minister Counsellor**
Head of Development Cooperation Section, Royal Danish Embassy

**Chris Price**
Rural Livelihoods Advisor
DFID Cambodia

# បុព្វកថា

គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM Learning Initiative) បានបង្ហាញពីផលប្រយោជន៍នៃការរៀបចំភាពជាដៃគូ និងការរៀនសូត្រដើម្បីធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធិភាព ដោយធ្វើការផ្លាស់ប្តូរ និងចែករំលែកចំណេះដឹងជាច្រើនចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់តំបន់ ។

ការរៀបចំសៀវភៅនេះ ជាកិច្ចខិតខំប្រឹងប្រែងជាក្រុម និងកិច្ចសហការដ៏សំខាន់ ដោយមានការចូលរួមពីអ្នកនិពន្ធស្ទាត់ជំនាញ ចំនួន ៣៥ រូបមកពីបណ្តាអង្គការ និងស្ថាប័នជាដៃគូជាច្រើន ។ អង្គការ WWF មានសេចក្តីរីករាយក្នុងការសម្របសម្រួលដំណើរការជាក្រុមដ៏មានសារៈសំខាន់នេះ ដោយរួបរួមផ្នែករដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និង គ្រឹះស្ថានសិក្សា ដើម្បីសំយោគចំណេះដឹង និងបទពិសោធន៍សំខាន់ៗ ស្តីពីCBNRM នៅក្នុងប្រទេសកម្ពុជា ។

ក្រុមអ្នកនិពន្ធដែលមានជំនាញចម្រុះបានចងក្រងជំនាញ និងបទពិសោធន៍របស់ពួកគាត់ក្នុងអត្ថបទនីមួយៗនៃសៀវភៅ CBNRMនេះ ។បន្ថែមពីនេះអង្គការ និងស្ថាប័នជាច្រើនដែលសហការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនេះបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់គម្រោង CBNRM ។ មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC បានជួយដឹកនាំដំណើរការស្រាវជ្រាវដោយបានផ្សារភ្ជាប់មេរៀនទទួលបានពីការស្រាវជ្រាវនៅមូលដ្ឋានដោយមានការចូលរួមទៅនឹងការអភិវឌ្ឍគោលនយោបាយ ។ អង្គការ អុកស្វាមអាមេរិក (Oxfam America បានផ្តល់ការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រសង្គម សម្រប-សម្រួលការរៀបចំបណ្តាញការងារ និងចែករំលែកបទពិសោធន៍លើវិស័យជលផល ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (RECOFTC បានផ្តល់វគ្គបណ្តុះបណ្តាលប្រកបដោយគុណភាពខ្ពស់ និងបទពិសោធន៍ប្រចាំតំបន់លើផ្នែកសហគមន៍ព្រៃឈើ ។ នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID បានផ្តល់ក្របខ័ណ្ឌនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព និងអភិបាលកិច្ចល្អ ។

អង្គការ WWF រីករាយក្នុងការដើរតួជាអ្នកជម្រុញ និងជាអ្នកសម្របសម្រួល ព្រមទាំងផ្តល់នូវប្រវត្តិពីប្រពៃណីបុរាណនៃការអភិរក្សជីវៈចម្រុះ ។យើងទាំងអស់គ្នាជឿជាក់យ៉ាងខ្លាំងថា ប្រជាពលរដ្ឋគឺជាផ្នែកដ៏សំខាន់មួយរបស់ធម្មជាតិ ។ដូច្នេះ យើងទាំងអស់គ្នាដែលជាប្រជាពលរដ្ឋនៃសកលលោកនេះ ត្រូវតែរួបរួមគ្នាដើម្បីរកដំណោះស្រាយសម្រាប់បញ្ហាបរិស្ថាន ។ CBNRM គឺជាវិធីសាស្ត្រមួយដែលមានសក្តានុពលភាពពិតប្រាកដ និងជាផ្នែកមួយនៃដំណោះស្រាយទាំងអស់នេះ ។វិធីសាស្ត្រនេះមានសារៈ-សំខាន់ក្នុងការលើកទឹកចិត្តប្រជាពលរដ្ឋឱ្យស្វែងរកមធ្យោបាយដើម្បីធ្វើការរួមគ្នាជាសហគមន៍ ។

លោក **សេខ នៀក**

នាយកអង្គការ WWF កម្ពុជា

# បញ្ជីពាក្យបំព្រួញ

ADB: ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)
AFSC: អង្គការសេវាមិត្តភាពអាមេរិកកាំង (American Friend Service Committee)
AIT: វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (Asian Institute of Technology)
AP Team: ក្រុមវិភាគ និងកសាងផែនការ (Analysis and Planning Team)
APPA: ការកសាងផែនការ និងសកម្មភាពដោយមានការចូលរួមបែបវិជ្ជមាន (Appreciative participatory Planning and Action)
APRLP: គម្រោងចិញ្ចឹមជីវិតនៅជនបទនៅ អាន់ដ្រា ប្រាដេស (Andhra Pradesh Rural Livelihoods Project)
CARERE: គម្រោងបង្កើតឡើងវិញ និងស្តារវិស័យនានាក្នុងប្រទេសកម្ពុជា (Cambodia Area Regeneration and Rehabilitation Project)
CAT: អង្គការមូលនិធិអភិរក្សសត្វខ្លា (Cat Action Treasury)
CBET: សហគមន៍អេកូ-ទេសចរណ៍ (Community Based Eco-Tourism)
CBCRM: គម្រោងគ្រប់គ្រងធនធានតំបន់ឆ្នេរដោយមានការចូលរួមពីសហគមន៍ (Community Based Coastal Resource Management)
CBNRM: ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management)
CBNRM LI: គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management Learning Initiative)
CBO: អង្គការសហគមន៍ (Community Based Organization)
CC: ក្រុមប្រឹក្សាឃុំ-សង្កាត់ (Commune Council)
CCB: ក្រុមប្រឹក្សាឃុំ-សង្កាត់នៅមូលដ្ឋាន (Commune Council-Based)
CCBEN: បណ្តាញសហគមន៍អេកូ-ទេសចរណ៍នៅកម្ពុជា (Cambodia Community Based Eco-Tourism Network)
CDC: គណៈកម្មការអភិវឌ្ឍន៍ឃុំ-សង្កាត់ (Commune Development Committee)
CDF: មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ (Commune Development Funds)
CDP: ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ (Commune Development Plans)
CEMP: គម្រោងគ្រប់គ្រងបរិស្ថានកម្ពុជា (Cambodia Environmental Management Project)
CERD: អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ (International Convention on the Elimination of All Forms of Racial Discrimination)
CF: សហគមន៍ព្រៃឈើ (Community Forestry)
CFAC: គម្រោងសម្ព័ន្ធភាពសហគមន៍ព្រៃឈើសម្រាប់កម្ពុជា (Community Forestry Alliance for Cambodia)
CFDO: ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (Community Fisheries Development Office)
CFG: អភិបាលកិច្ចសហគមន៍ព្រៃឈើ (Community Forestry Governance)
CFI: អង្គការសហគមន៍ព្រៃឈើអន្តរជាតិ (Community Forestry International)
CFM: ការគ្រប់គ្រងសហគមន៍នេសាទ (Community Fisheries Management)
CFRP: គម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (Community Forestry Research Project)
CFU: ក្រុមសហគមន៍ព្រៃឈើ (Community Forestry Unit)
CG: ក្រុមពិគ្រោះយោបល់ (Consultative Group)
CGFP: គម្រោងស្រាវជ្រាវព្រៃឈើ កម្ពុជា-អាល្លឺម៉ង់ (Cambodian German Forestry Project)
CIDA: ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (Canadian International Development Agency)
CIDSE: អង្គភាពសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងសាមគ្គីភាព (Cooperation International Pour le Development et : la Solidarite)
CIP: កម្មវិធីវិនិយោគឃុំ-សង្កាត់ (Commune Investment Programme)
CO: ការរៀបចំសហគមន៍ (Community Organizing)
CPA: សហគមន៍តំបន់ការពារធម្មជាតិ (Community Protected Area)
CRF: អ្នកសម្របសម្រួលតំណាងឃុំ-សង្កាត់ (Commune Representative Facilitators)
CRIN: បណ្តាញព័ត៌មានសិទ្ធិកុមារ (Child Rights Information Network)
CWRP: គម្រោងសហគមន៍អ្នកអភិរក្សសត្វព្រៃ (Community Wildlife Ranger Project)
CZM: គម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ (Coastal Zone Management)
DED: សេវាអភិវឌ្ឍន៍អាល្លឺម៉ង់ (German Development Service)

# បញ្ជីពាក្យបំព្រួញ

DFID: នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (Department for International Development)
DFT: ក្រុមសម្របសម្រួលថ្នាក់ស្រុក (District Facilitation Team)
DFW: នាយកដ្ឋានរុក្ខា-ប្រមាញ់ (Department of Forestry and Wildlife)
DLMUPC: នាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Department of Land Management, Urban Planning and Construction)
DoE: មន្ទីរបរិស្ថានខេត្ត (Department of Environment)
DoF: នាយកដ្ឋានជលផល (Department of Fisheries)
DOLA: នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (Department of Local Administration)
DoP: នាយកដ្ឋានផែនការ (Department of Planning)
DNCP: នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ (Department of Nature Conservation and Protection)
DRIVE: គម្រោងអភិវឌ្ឍន៍ភូមិទេសចរណ៍ធម្មជាតិជនជាតិដើមនៅតំបន់ដាច់ស្រយាល (Developing Remote Indigenous Village Education Project)
EIA: ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (Environmental Impact Assessment)
ENTRI: សន្ធិសញ្ញាបរិស្ថាន និងសូចនាករណ៍ធនធាន (Environmental Treaties and Resource Indicators)
EPDO: អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (Environmental Protection and Development Organization)
FA: រដ្ឋបាលព្រៃឈើ (Forest Administration)
FACT: សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (Fisheries Action Coalition Team)
FAO: អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (United Nations Food and Agricultural Organization)
FFI: អង្គការសារពើសត្វ និងរុក្ខជាតិអន្តរជាតិ (Fauna and Flora International)
GTZ: ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (German Technical Co-operation)
ICCPR: អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និង សង្គមស៊ីវិល (International Convention on Civil and Political Rights)
IDRC: មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (International Development Research Centre, Canada)
IES: សមាគមទេសចរណ៍ធម្មជាតិអន្តរជាតិ (International Eco-tourism Society)
I/E-PP: ដំណើរការកសាងផែនការសមាហរណកម្ម (Integrated/Extended Planning Process)
IIRR: វិទ្យាស្ថានអន្តរជាតិសម្រាប់ស្តារតំបន់ជនបទនៅប្រទេសហ្វីលីពីន (The International Institute of Rural Reconstruction)
ILO: អង្គការពលកម្មអន្តរជាតិ (International Labour Organization)
IO: អង្គការអន្តរជាតិ (International Organization)
IPP: ដំណើរការកសាងផែនការសមាហរណកម្មសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ( Integrated Community and Natural Resource-based Planning Process)
IUCN: អង្គការសហភាពអភិរក្សពិភពលោក (IUCN)
JICA: ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency)
KYSD: អង្គការយុវជនខ្មែរ និងអភិវឌ្ឍន៍សង្គម (Khmer Youth and Social Development Organization)
LPP: ដំណើរការកសាងផែនការមូលដ្ឋាន (Local Planning Process)
LWF: អង្គការលូថេរ៉ាន បំរើពិភពលោក (The Lutheran World Federation)
MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries)
MCC: គណៈកម្មការកណ្តាលមេណូណៃ (Mennonite Central Committee)
MLI: គម្រោងសិក្សាស្រាវជ្រាវទន្លេមេគង្គ (Mekong Learning Initiative)
MLMUPC: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Ministry of Land Management, Urban Planning and Construction)
MOE: ក្រសួងបរិស្ថាន (Ministry of Environment)
MOSAIC EP: គម្រោងគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស (Management of Strategic Areas for Intergrated Conservation-Eastern Plains)
MOT: ក្រសួងទេសចរណ៍ (Ministry of Tourism)
MPF: ព្រៃការពារមណ្ឌលគីរី (Mondulkiri Protected Forest)
MRC: គណៈកម្មការទន្លេមេគង្គ (Mekong River Commission)
NEAP: ផែនការបរិស្ថានជាតិ (National Environmental Action Plan)
NGO: អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organization)

# បញ្ជីពាក្យបំព្រួញ

NPRS: យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (Notational Poverty Reduction Strategy)
NREM: ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ (Natural Resource and Environmental Management)
NRM: ការគ្រប់គ្រងធនធានធម្មជាតិ (Natural Resources Management)
NTDP: ផែនការជាតិអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ ២០០៣ (National Tourism Development plan 2003)
NTFP: ផល-អនុផលព្រៃឈើ (Non-Timber Forest Product)
OA: អង្គការអុកស្វាមអាមេរិក (Oxfam America)
OCAA: អង្គការអុកស្វាមដើម្បីជួយសហគមន៍ឯនាយសមុទ្រ (Oxfam Community Aid Abroad)
Oxfam GB: អង្គការអុកស្វាមចក្រភពអង់គ្លេស (Oxfam Great Britain)
PAR: ការស្រាវជ្រាវមូលដ្ឋានដោយមានការចូលរួម (Participatory Action Research)
PBA: ការវាយតម្លៃជីវៈចម្រុះដោយមានការចូលរួម (Participatory Biodiversity Assessments)
PDAFF: មន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ខេត្ត (Provincial Department of Agriculture, Forestry and Fisheries)
PDIME: មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត (Provincial Department of Industry, Mines and Energy)
PDLMUPC: មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្ត (Provincial Department of Land Management, Urban Planning and Construction)
PDRD: មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (Provincial Department of Rural Development)
PIF: មូលនិធិវិនិយោគថ្នាក់ខេត្ត (Provincial Investment Funds)
PKWS: ដែនជម្រកសត្វព្រៃ ពាមក្រសោប (Peam Krasaop Wildlife Sanctuary)
PLG: ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន (Partnership for Local Governance)
PLUP: ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (Participatory Land Use Planning)
PMMR: គម្រោងគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួម (Participatory Management of Mangrove Resources)
PPWS: ដែនជម្រកសត្វព្រៃភ្នំព្រេច (Phnom Prich Wildlife Sanctuary)
PRA: ការវាយតម្លៃជនបទដោយមានការចូលរួម (Participatory Rural Appraisal)
PRDC: គណៈកម្មការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្ត (Provincial Rural Development Committee)
PRSP: ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (Poverty Reduction Strategy Paper)
RECOFTC: មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើសហគមន៍ប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (Regional Community Forestry Training Centre)
RGC: រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia)
RUA: សាកលវិទ្យាល័យភូមិន្ទកសិកម្ម (Royal University of Agriculture)
SEDP II: ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំ លើកទី ២ (Second Five Year Socio-Economic Development Plan)
SFM: ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (Sustainable Forest Management)
SIDA: ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (Swedish International Development Agency)
SMRP: គម្រោងគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព (Sustainable Management of Resources Project)
SSP: អង្គការស្ត្រីដើម្បីសន្តិភាព និងបរិស្ថាន (Strey Daoembey Santepheap Nung Pakristhan)
SL: ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (Sustainable Livelihoods)
ToT: ការបណ្តុះបណ្តាលគ្រូបង្គោល (Training of Trainers)
UDHR: សេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights)
UNDP: កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme)
VDC: គណៈកម្មការអភិវឌ្ឍន៍ភូមិ (Village Development Committee)
VMC: គណៈកម្មការគ្រប់គ្រងភូមិ (Village Management Committee)
WCS: អង្គការសមាគមអភិរក្សសត្វព្រៃ (Wildlife Conservation Society)
WWF: អង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ (World Wide Fund for Nature)

# សេចក្តីសង្ខេប

**រៀបរៀងដោយ : លោក កែន សេរីរដ្ឋា លោក Toby Carson លោកស្រី Steph Cox និង លោកស្រី Erika von Kaschke**

ក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ អ្នករៀបចំគោលនយោបាយ អ្នកកសាងផែនការ និងអ្នកប្រាជ្ញជាច្រើន បានធ្វើការពិនិត្យ និងពិចារណាឡើងវិញពីតួនាទីសំខាន់របស់អ្នកពាក់ព័ន្ធ ជាពិសេស ក្រុមដែលសង្គមមិនសូវផ្តល់ឱកាសឱ្យ[១] នៅតាមសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ។

វិធីសាស្ត្រគ្រប់គ្រងថ្មីមួយឆ្ពោះទៅរកការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពនោះ គឺការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM) ។ នេះជាពាក្យមួយមានន័យទូលំទូលាយ ដែលត្រូវបានប្រើប្រាស់សម្រាប់គម្រោងជាច្រើនមានជាអាទិ៍ សហគមន៍ព្រៃឈើ សហគមន៍នេសាទ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី សហគមន៍តំបន់ការពារធម្មជាតិ និងការគ្រប់គ្រងព្រៃឈើរួមគ្នា ។

សិក្ខាសាលាថ្នាក់ជាតិមួយស្តីពី CBNRM ដែលបានរៀបចំឡើងនៅទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០០២ បានបង្ហាញពីតម្រូវការចាំបាច់ ដើម្បីចងក្រងបទពិសោធន៍ទទួលបានពីមូលដ្ឋានតាមរយៈគម្រោង និងអង្គការពាក់ព័ន្ធជាច្រើន ។ សៀវភៅនេះគឺជាការឆ្លើយតបដោយផ្ទាល់ទៅនឹងសេចក្តីត្រូវការរបស់អង្គសិក្ខាសាលា ។ សិក្ខាសាលានេះរៀបចំឡើងដោយគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM LI) ក្រោមការឧបត្ថម្ភពីសំណាក់ដៃគូសំខាន់ៗ ដូចជា អង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ (WWF) មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិ(IDRC) អង្គការអុកស្វាមអាមេរិក (Oxfam America) និង មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (RECOFTC) ។ ការគាំទ្រថវិកាបន្ថែមត្រូវបានផ្តល់ដោយអង្គការ DFID និងអង្គការ FAO ។

***ការអភិវឌ្ឍនៃ CBNRM នៅប្រទេសកម្ពុជា*** គឺជាលទ្ធផលដែលទទួលបានពីការពិគ្រោះយោបល់ជាក្រុម និងជាមួយបុគ្គលជាច្រើន ការប្រជុំ សិក្ខាសាលា និងការពិគ្រោះយោបល់តាមក្រុមដែលមានជំនាញប្រហាក់ប្រហែលគ្នាក្នុងអំឡុងពីរឆ្នាំមុន រួមជាមួយអ្នកអនុវត្តន៍ និងគ្រឹះស្ថានសិក្សាក្នុងស្រុក និងអន្តរជាតិជាច្រើនដែលធ្វើការលើផ្នែកនេះ ។ កិច្ចខិតខំប្រឹងប្រែងសហការគ្នានេះបាននាំឱ្យមានការរៀបរៀងជាសៀវភៅមួយមាន ២០ ជំពូក ហើយមានអ្នកនិពន្ធចំនួន ៣៥ រូប ( ចំពោះព័ត៌មានលំអិតសូមអានផ្នែកប្រវត្តិអ្នកនិពន្ធ ដែលបានចែករំលែកជំនាញ និងលះបង់ពេលវេលា ព្រមទាំងកម្លាំងកាយចិត្តដើម្បីចូលរួមក្នុងដំណើរការនេះ ។

ការចងក្រងឯកសារនេះចែកជា ៥ផ្នែក និង ២០ជំពូក ។ ផ្នែក ក រៀបរាប់ពីការអភិវឌ្ឍ ***CBNRM នៅប្រទេសកម្ពុជា*** ដោយផ្តល់នូវសេចក្តីសង្ខេបពី***ប្រវត្តិនៃទ្រឹស្តី*** និង***ស្ថានភាពជាក់ស្តែង***សម្រាប់ CBNRM នៅប្រទេសកម្ពុជា ។

លោក កែន សេរីរដ្ឋា ចាប់ផ្តើមពីជំពូកទីមួយនៃសៀវភៅនេះ ដោយធ្វើការរៀបរាប់ការយល់ដឹងពី***ទស្សនទានសំខាន់ៗ***នៃ CBNRM និងការយល់ដឹងពីទស្សនទាននេះនៅប្រទេសកម្ពុជា ។

---

[១] តាមរយៈសិក្ខាសាលា CBNRM Volume Peer Review នាថ្ងៃ ១៥-១៧ធ្នូ ឆ្នាំ២០០៥ ក្រុមអ្នកនិពន្ធសៀវភៅនេះបកប្រែពាក្យ Marginalized Group ថាជាក្រុមដែលសង្គមមិនសូវផ្តល់ឱកាសឱ្យ ។

ជំពូកនេះពិភាក្សាពីការផ្លាស់ប្តូរពីវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិតាមបែបសាមញ្ញ ទៅជាវិធីសាស្ត្រគ្រប់គ្រងមួយដោយធ្វើឱ្យមានអ្នកពាក់ព័ន្ធចូលរួម រួមទាំងក្រុមដែលមិនទទួលបានប្រយោជន៍ផងដែរ ។ ជំពូកនេះជជែកវែកញែកពីលក្ខខណ្ឌចាំបាច់ ដើម្បីជម្រុញ CBNRM ទៅជាការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ដែលឆ្លើយតបទៅនឹងគោលបំណងនៃការអភិរក្សជីវៈចម្រុះ និងការរក្សាសន្តិសុខនៃការចិញ្ចឹមជីវិតនៅមូលដ្ឋាន ។

ជំពូកទីពីរ ដែលរៀបរៀងដោយ លោក Toby Carson កញ្ញា ហ៊ូ កល្យាណ និង លោក ស្រី ម៉ារ៉ូណា សង្ខេបពី**បរិបទ និងបទពិសោធ៍នៃ** CBNRM នៅប្រទេសកម្ពុជា ។ ជំពូកនេះធ្វើការសំយោគព័ត៌មានសំខាន់ៗ ដែលបានបង្ហាញនៅក្នុងជំពូកផ្សេងៗទៀតនៃសៀវភៅនេះ ។

ផ្នែក **ខ** ផ្តោតទៅលើការ**រៀបចំច្បាប់ និងការផ្លាស់ប្តូរគោលនយោបាយ**នៅប្រទេសកម្ពុជា ។ នៅក្នុងជំពូកទីបី លោក Robert B. Oberndorf បានផ្តល់នូវសេចក្តីសង្ខេបនៃ**គោលនយោបាយ និងក្របខ័ណ្ឌច្បាប់** ដែលទាក់ទងនឹង CBNRM ។ ក្នុងជំពូកនេះ រួមបញ្ចូលទាំងច្បាប់ អនុក្រឹត្យ និង "ប្រកាស" ។ អ្នករៀបរៀងបានបង្ហាញផងដែរនូវភាពខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជា ។

ជំពូកទីបួន បង្ហាញពីឥទ្ធិពលនៃយុទ្ធសាស្ត្រ CBNRM ទៅលើកម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាល គឺ **កម្មវិធីសិលា** ដែលស្ថិតក្រោមការពិនិត្យពិច័យរបស់ លោក ញ៉ែម សុវណ្ណា ។ អត្ថបទនេះ បង្ហាញពីបទពិសោធន៍ថ្មីៗនៃបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM) ទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ឃុំរបស់កម្មវិធីសិលា ។

លោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និង អ្នកស្រី សូ ស្រីមុំ ដែលជាអ្នកនិពន្ធជំពូកទីប្រាំ ពិភាក្សាពី**កំណែទម្រង់គោលនយោបាយវិស័យជលផល** និង**ក្របខ័ណ្ឌច្បាប់សម្រាប់សហគមន៍នេសាទ** ។ អត្ថបទនេះផ្តល់នូវបរិបទជាប្រវត្តិសាស្ត្រនៃការគ្រប់គ្រងធនធានជលផល និងធ្វើការកត់សម្គាល់ពីសារៈសំខាន់នៃការរួមវិភាគទាននៃធនធានជលផលក្នុងការផ្តល់អាហារូបត្ថម្ភប្រចាំគ្រួសារ និងសម្រាប់វិស័យសេដ្ឋកិច្ចជាតិ ។

ផ្នែក គ ពិនិត្យមើលលើការរៀបចំ**បណ្តាញការងារ ក្រុមការងារ និងស្ថាប័ន ។**

ជំពូកទីប្រាំមួយ រៀបរៀងដោយ លោក ដាន ថាយុទ្ធ និង កញ្ញា អ៊ូ សុភារី ដោយមានការចូលរួមពីគណៈកម្មការរៀបចំបណ្តាញ**សហគមន៍ព្រៃឈើ (CF) និងបណ្តាញសហគមន៍តំបន់ការពារធម្មជាតិ ។** បណ្តាញនេះ គឺជាវេទិកាដ៏មានសារៈសំខាន់មួយសម្រាប់អ្នកអនុវត្តន៍គ្រប់កម្រិតទាំងអស់ ដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍រវាងគ្នា ទាំងខាងក្នុង និងខាងក្រៅតំបន់ការពារធម្មជាតិ តាមរយៈការប្រជុំបណ្តាញប្រចាំត្រីមាស និងតាមរយៈព្រឹត្តិប័ត្រព័ត៌មាន ។

ជំពូកនេះ បង្ហាញពីសេចក្តីសង្ខេបនៃការវិវឌ្ឍ ផលប្រយោជន៍ និងបញ្ហារបស់បណ្តាញ ព្រមទាំងការផ្តល់អនុសាសន៍របស់អ្នកនិពន្ធសម្រាប់កែលំអបណ្តាញទៅថ្ងៃអនាគត ។

ជំពូកទីប្រាំពីរ រៀបរៀងដោយលោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និង អ្នកស្រី សូ ស្រីមុំ ព្រមទាំងមានការចូលរួមពី លោក លី វុឌ្ឍី អ្នកស្រី ង៉ិន ណារីរ: និងសមាជិកដទៃទៀតនៃក្រុមការងារសម្របសម្រួលជលផល ដោយធ្វើការបង្ហាញពីសេចក្តីសង្ខេបស្តីពីទស្សនទាននៃ**ការអភិវឌ្ឍសហគមន៍នេសាទ និងការបង្កើតបណ្តាញ** នៅប្រទេសកម្ពុជា ។

អ្នកស្រី កែន សុភាព លោក ហ៊ុយ វង្សរស្មីតារា កញ្ញា *Amanda Bradley* និង លោក យិន សូរិយា ព្រមទាំងសមាជិកនៃបណ្តាញសហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា គឺជាអ្នកនិពន្ធនៃជំពូកទីប្រាំបី ។ ជំពូកនេះ ពិភាក្សាពី**សហគមន៍អេកូ-ទេសចរណ៍ (CBET)** ក្នុងបរិបទនៃប្រទេសកម្ពុជា ដែលធនធានធម្មជាតិត្រូវបានចាត់ទុកជាធនធានសម្រាប់វិស័យទេសចរណ៍ ។ ក្របខ័ណ្ឌគោលនយោបាយដែលទាក់ទងត្រូវបានធ្វើការវិភាគ ហើយបទពិសោធន៍ និងករណីសិក្សាត្រូវបានចែករំលែក ក្នុងគោលបំណងរៀនសូត្រ និង ធ្វើការពិចារណាដើម្បីផ្តល់ជាអនុសាសន៍សម្រាប់ការអភិវឌ្ឍទៅថ្ងៃអនាគត ។

ជំពូកទីប្រាំបួន រៀបរៀងដោយ លោក មិន ប៊ុណ្ណារ៉ា លោកបណ្ឌិត *Harald Kirsch* និងលោក *Ignas Dümmer* ដោយបង្ហាញពី **វិធីសាស្ត្រនៃការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP)** នៅប្រទេសកម្ពុជា និងទំនាក់ទំនងរបស់វិធីសាស្ត្រនេះជាមួយ *CBNRM* ។

ការអភិវឌ្ឍសហគមន៍**តំបន់ការពារធម្មជាតិ**នៅប្រទេសកម្ពុជា ត្រូវបានបង្ហាញក្នុងជំពូកទីដប់ ។ អត្ថបទនេះបានរៀបរៀងដោយលោក មាស សុធនវឌ្ឍនៈ និងកញ្ញា សាន្ត សុជាតិលក្ខិណា ដោយមានការចូលរួមពី លោក *Stefan Janssens* លោក កែន សេរីរដ្ឋា និងបុគ្គលិកនៃការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ *(CPAD)* នៃក្រសួងបរិស្ថាន ។

ផ្នែកបន្ទាប់ទៀត បង្ហាញយ៉ាងស៊ីជម្រៅពី**មេរៀនដែលទទួលបានពីបទពិសោធន៍នៅមូលដ្ឋាន** ដែលរួមបញ្ចូលជំពូកគួរឱ្យចាប់អារម្មណ៍ចំនួនប្រាំមួយ ។

ជំពូកទីដប់មួយ ផ្តោតទៅលើមេរៀនទទួលបានពី**ការសិក្សាស្រាវជ្រាវ និងចងក្រងករណីសិក្សា ។** នៅជំពូកនេះ អ្នកនិពន្ធ ( លោក ស្រី ម៉ារ៉ូណា កញ្ញា ហ៊ូ កល្យាណ និង កញ្ញា *Rebecca Kinakin* ប្រើប្រាស់ឧទាហរណ៍ពីករណីសិក្សាដែលសម្របសម្រួលដោយគម្រោង *CBNRM LI* ដើម្បីបង្ហាញពីមេរៀនសំខាន់ៗដែលទទួលបានពីបទពិសោធន៍នេះ ។

ជំពូកទីដប់ពីរ រៀបរៀងដោយ លោក ស៊ី រ៉ាមុនី លោក ផាន់ កំណាព្យ និង គីម សារិន បង្ហាញពីសេចក្តីសង្ខេបនៃ**ការស្រាវជ្រាវនៅមូលដ្ឋានដោយមានការចូលរួម (PAR)** នៅក្នុងសហគមន៍ព្រៃឈើ *(CF)* ដោយផ្អែកលើបទពិសោធន៍នៃសហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ *(CBNRM)* នៅប្រទេសកម្ពុជា ។

ជំពូកទីដប់បី ពិភាក្សាពីធនធានព្រៃឈើ និងវិវាទដីធ្លីនៅខេត្តមណ្ឌលគិរី និងវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីដោះស្រាយវិវាទទាំងនោះតាមរយៈ ***គម្រោងគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស (MOSAIC)*** ។ ជំពូកនេះរៀបរៀងដោយ លោក ជាម មុនី និងលោកបណ្ឌិត Andy Maxwell ដោយមានការចូលរួមពីសំណាក់ក្រុមការងារ ***MOSAIC*** ផងដែរ ។

លោក Ashish John គឺជាអ្នកនិពន្ធជំពូកទីដប់បួន ដែលសង្ខេបពីការសាកល្បងបញ្ចូលគ្នានូវវិធីសាស្ត្រ CBNRM ជាមួយ***ដំណើរកសាងផែនការមូលដ្ឋាន (LPP)*** នៅខេត្តរតនគិរី ដែលជាគំនិតផ្តួចផ្តើមរបស់កម្មវិធីសិលា ។

ជំពូកទីដប់ប្រាំ ត្រូវបានរៀបរៀងដោយលោក គឹម ណុង លោកអ៊ុក លីឃីម និងលោក ឃី អាន ។ ជំពូកនេះឆ្លុះបញ្ចាំងពីបទពិសោធន៍នៃ***ការរៀបចំសហគមន៍*** ដែលជាមធ្យោបាយមួយក្នុងការងារគ្រប់គ្រងធនធាន ជាមួយគណៈកម្មការគ្រប់គ្រងភូមិ (VMCs) ។ ជំពូកនេះ ធ្វើការវិភាគពីសកម្មភាពដែល VMCs អាចមានលទ្ធភាពអនុវត្តនៅថ្នាក់ភូមិ និងការលើកឡើងនូវបទពិសោធន៍ទាំងនេះសម្រាប់ CBNRM នៅប្រទេសកម្ពុជា ។

កញ្ញា Melissa Marschke អធិប្បាយនៅក្នុងជំពូកទីដប់ប្រាំមួយ ដោយផ្តោតទៅលើទំនាក់ទំនងរវាង ***ការកសាងផែនការ និងការអនុវត្តសកម្មភាព*** ព្រមទាំងបង្ហាញពីការពិនិត្យមើលលើការគ្រប់គ្រងធនធានដោយគណៈកម្មការពីរដោយបញ្ជាក់ពីការអនុវត្តនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅមូលដ្ឋាន និងហេតុផលដែលអ្នកភូមិចូលរួមក្នុងសកម្មភាពនេះ ។

ផ្នែកចុងក្រោយ ***បញ្ជាក់ពីកាលានុវត្តន៍ភាពសំខាន់ៗ និងការប្រឈមសម្រាប់ CBNRM*** ដោយមានរួមបញ្ចូលជំពូកចុងក្រោយចំនួនបួន ដែលពិភាក្សាពីដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ ការធានាសន្តិសុខ និងសិទ្ធិកាន់កាប់ដីធ្លី ព្រមទាំងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ។

ជំពូកទីដប់ប្រាំពីរ រៀបរៀងដោយលោក Doug Henderson ដោយធ្វើការវិភាគតួនាទីរបស់សហគមន៍ព្រៃឈើក្នុង ***ការលើកកំពស់អភិបាលកិច្ចលើវិស័យព្រៃឈើ***នៅប្រទេសកម្ពុជា ។ អ្នកនិពន្ធធ្វើការពិភាក្សាដោយលើកឡើងថា អភិបាលកិច្ចលើវិស័យព្រៃឈើ គឺជាផ្នែកសំខាន់មួយនៃដំណើរការនយោបាយដែលជាទូទៅ ពាក់ព័ន្ធនឹងការពិភាក្សាពីអំណាច និងសិទ្ធិសំរេចរវាងអ្នកពាក់ព័ន្ធនានា ។

លោក Frank van Acker ពិនិត្យមើលពីចំណងទាក់ទងរវាង ***សិទ្ធិមនុស្ស និងការគ្រប់គ្រងបរិស្ថាន*** នៅប្រទេសកម្ពុជា ។ ក្នុងជំពូកទីដប់ប្រាំបី លោកបង្ហាញពីទស្សនទាន និងការឆ្លុះបញ្ចាំងពីវិធីសាស្ត្រអាស្រ័យសិទ្ធិមនុស្ស ។

កញ្ញា Katrin Seidel ផ្តល់ជូននូវទស្សនទានលើបញ្ហានៃ***ការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច*** និងតួនាទីរបស់ CBNRM នៅក្នុងជំពូកទីដប់ប្រាំបួន ។ ដោយសិក្សាវាយតម្លៃពីសក្តានុពលភាព និងការអនុវត្តពិតប្រាកដរបស់ CBNRM នៅក្នុងដំណើរការរៀបចំច្បាប់ជាប្រពៃណីរបស់ជនជាតិដើមភាគតិច អ្នកនិពន្ធបានផ្តោតការយកចិត្តទុកដាក់ទៅលើកាលានុវត្តនីភាព និងហានិភ័យនៃវិធីសាស្ត្រ CBNRM ផងដែរ ។

នៅជំពូកទីម្ភៃ កញ្ញា Rebecca Kinakin ណែនាំពីទស្សនទាន ក្របខ័ណ្ឌការងារ ការអនុវត្តវិធីសាស្ត្រនៃ***ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SL)*** និងធ្វើការពិចារណាពីទំនាក់ទំនងនៃការប្រើប្រាស់វិធីសាស្ត្រ SL និងវិធីសាស្ត្រ CBNRM នៅប្រទេសកម្ពុជា ។ ក្របខ័ណ្ឌការងារ SL ត្រូវបានផ្តល់ជាវិធីសម្រាប់ពង្រឹងការយល់ដឹងពីបញ្ហាប្រឈមចំពោះនិរន្តរភាពនៃការចិញ្ចឹមជីវិតតាមជនបទ ។

***ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា*** គឺជាសៀវភៅកម្ពុជាដំបូងដែលពិភាក្សាលើផ្នែកគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ដោយមានអ្នកជំនាញជាច្រើនបានធ្វើការរួមគ្នាដើម្បីចងក្រងបទពិសោធន៍ផ្ទាល់តាមមូលដ្ឋានរបស់ពួកគេ ។ សៀវភៅនេះ ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរ និង ភាសាអង់គ្លេស ដោយរួមបញ្ចូលនូវវិស័យជាច្រើន រួមមានវិស័យជលផល ព្រៃឈើ និងជីវៈចម្រុះ ( តំបន់ការពារធម្មជាតិ និងផែនការប្រើប្រាស់ដីធ្លី ។

សៀវភៅនេះ ផ្តល់ព័ត៌មានមូលដ្ឋានយ៉ាងសំខាន់សម្រាប់ CBNRM ដែលមាននៅក្នុងប្រទេសកម្ពុជារហូតដល់ចុងឆ្នាំ២០០៤ កន្លងមកនេះ ។ ជំពូកភាគច្រើន មានលក្ខណៈជាការបរិយាយតែប៉ុណ្ណោះ ដោយពុំទាន់បានធ្វើការវិភាគឱ្យហ្មត់ចត់នៅឡើយទេ ។ ដោយ CBNRM កំពុងបន្តអនុវត្តនៅប្រទេសកម្ពុជា ហើយបទពិសោធន៍ថ្មីៗទៀតនឹងត្រូវបង្កើតឡើង ហេតុនេះយើងសង្ឃឹមថា សៀវភៅនេះនឹងត្រូវកែលំអជាបន្តបន្ទាប់ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរស្ថានភាពជាក់ស្តែង ។ យើងក៏សង្ឃឹមផងដែរថា អ្នកនិពន្ធនឹងបន្តកិច្ចសហការគ្នាដើម្បីចេញផ្សាយសៀវភៅនេះជាលើកទីពីរ ដែលអាចផ្តល់នូវការវិភាគបន្ថែមពីការអភិវឌ្ឍនៃ CBNRM នៅប្រទេសកម្ពុជា ។ តាមរយៈការពិភាក្សាជាបន្តបន្ទាប់បានផ្តល់អនុសាសន៍ថា គួរមានកិច្ចប្រឹងប្រែងរួមគ្នាបន្ថែមទៀត ដើម្បីធ្វើការចងក្រងព័ត៌មាន និងមេរៀនថ្មីៗដើម្បីឆ្លុះបញ្ចាំងពីភាពចម្រុះគ្នានៃការអនុវត្តគម្រោង និងបទពិសោធន៍ដែលមានសារៈសំខាន់សម្រាប់អ្នកអនុវត្តនី CBNRM ជំនាន់ក្រោយ ។

# ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិ
# ដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា



## ផ្នែក ក

## ការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិដោយមាន
## ការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា :
## ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត

# ផ្នែក ទី

# ការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា : ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត

ជំពូក ១

ស្វែងយល់ពីទស្សនទានសំខាន់ៗនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍

រៀបរៀងដោយ : លោក កែន សេរីរដ្ឋា

ជំពូក ២

ការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា

រៀបរៀងដោយដោយ : លោក Toby Carson កញ្ញា ហ៊ូ កល្យាណ និង លោក ស្រី ម៉ារ៉ូណា

---

រូបថត : ស្រី មុំ / WWF-CBNRM 2002

# ជំពូក ១

# ស្វែងយល់ពីទស្សនទានសំខាន់ៗនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍[១]

រៀបរៀងដោយ លោក កែន សេរីរដ្ឋា[២]

## សេចក្តីផ្តើម

អត្ថបទនេះផ្តល់ជូននូវការពន្យល់ណែនាំដោយសង្ខេបពីទស្សនទានសំខាន់ៗ នៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management-CBNRM ។ អត្ថបទនេះ ពិភាក្សាពីទំនាក់ទំនងរវាងមនុស្ស និងធនធានធម្មជាតិសម្រាប់ការអភិរក្សជីវៈចម្រុះផង និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពផង ។ លើសពីនេះទៀត អត្ថបទនេះបញ្ជាក់ពីសេចក្តីត្រូវការឱ្យមាន CBNRM និងការកំណត់និយមន័យនៃពាក្យនេះទៅតាមការយល់ឃើញ និងបទពិសោធន៍របស់អង្គការ និងស្ថាប័ននានា ដែលកំពុងធ្វើការងារក្នុងវិស័យនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

ជាទូទៅ ធនធានធម្មជាតិរួមមានដើមឈើ ដីធ្លី ត្រី និងអនុផលព្រៃឈើ ដែលមានសារៈសំខាន់ចំពោះមនុស្សគ្រប់រូប ។ ព្រៃឈើទ្រទ្រង់ជីវិតរស់នៅរបស់មនុស្សលោកនៅច្រើនលំដាប់ថ្នាក់ : នៅថ្នាក់មូលដ្ឋាន ព្រៃឈើផ្តល់នូវអាហារ ជម្រក ភាពកក់ក្តៅ និងប្រាក់ចំណូល ។ នៅលំដាប់សកលវិញព្រៃឈើរួមវិភាគទានយ៉ាងធំធេងនៅលើផ្នែកជាច្រើនដូចជា ព្រៃឈើមានតួនាទីជាអាងស្រូបកាបូន ដើម្បីជួយធ្វើឱ្យអាកាសធាតុនៅលើភពផែនដីមានតុល្យភាព ។ ព្រៃឈើមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាពិសេសចំពោះប្រជាពលរដ្ឋក្រីក្រដែលច្រើនតែពឹងអាស្រ័យយ៉ាងខ្លាំងលើធនធានព្រៃឈើ ។ ដើម្បីគ្រប់គ្រងព្រៃឈើ និងធនធានធម្មជាតិឱ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយទៀត ប្រការសំខាន់គឺត្រូវយល់ដឹងពីទំនាក់ទំនងនេះ ហើយត្រូវបញ្ចូលការចាប់អារម្មណ៍របស់ក្រុមមនុស្សផ្សេងៗគ្នាទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

បទពិសោធន៍ និងមេរៀនជាច្រើនទទួលបានពីបណ្តារដ្ឋាភិបាលនៅក្នុងទ្វីបអាស៊ី អាហ្វ្រិក និងតំបន់ផ្សេងៗទៀតនៅលើពិភពលោក បានទទួលស្គាល់ភាពបរាជ័យនៃការគ្រប់គ្រងព្រៃឈើឱ្យមានប្រសិទ្ធិភាព ។ ភាគច្រើននៃការអនុវត្តការងារនៅសតវត្សរ៍ទី២០ ការគ្រប់គ្រងព្រៃឈើមួយចំនួនធំបានផ្តោតតែលើផលិតកម្មឈើ សម្រាប់ឧស្សាហកម្ម ដែលអនុវត្តដោយនាយកដ្ឋានព្រៃឈើរបស់រដ្ឋាភិបាល ។ បច្ចុប្បន្ន នាយកដ្ឋានដដែលនេះរបស់រដ្ឋាភិបាលបានមើលឃើញតម្រូវការក្នុងការផ្លាស់ប្តូរវិធីសាស្ត្រ លើការគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើទាំងនេះរបស់ខ្លួនឱ្យមានប្រសិទ្ធិភាពសម្រាប់ពេលអនាគត ។

---

[១] ឯកសារនេះជាលទ្ធផលនៃការខិតខំប្រឹងប្រែងរួមគ្នាតាមរយៈការប្រជុំ ការពិភាក្សា និងការពិគ្រោះយោបល់ផ្សេងៗ ជាមួយអ្នកជំនាញជាច្រើនតាមរយៈបណ្តាញរបស់អ្នកនិពន្ធ ដែលមាននៅក្នុងប្រទេសកម្ពុជា និងនៅបរទេស ។ អ្នកនិពន្ធ សូមសំដែងអំណរគុណ ចំពោះការចូលរួមវិភាគទាន និងការគាំទ្រជាច្រើនរបស់លោក លោកស្រី ក្នុងការចងក្រងឯកសារនេះឡើង ។ សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក Toby Carson លោក ស្រី ម៉ារ៉ូណា និងកញ្ញា ហ៊ូ កល្យាណ ដែលបានផ្តល់ការគាំទ្រ និងការលើកទឹកចិត្តជាបន្តបន្ទាប់ ចាប់តាំងពីការរៀបចំសេចក្តីព្រាងនៃឯកសារនេះ រហូតដល់សម្រេចជាឯកសារចុងក្រោយ ។ សូមថ្លែងអំណរគុណផងដែរចំពោះអង្គការ IDRC WWF និង Oxfam America ចំពោះការគាំទ្រ ក្នុងការជម្រុញឱ្យមានការចូលរួម របស់សហគមន៍ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅប្រទេសកម្ពុជា ។ ទស្សនៈដែលមានក្នុងឯកសារនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធទាំងស្រុង ។

[២] ថ្មីៗនេះ លោក កែន សេរីរដ្ឋា ត្រូវបានតម្លើងឋានៈពីប្រធានការិយាល័យគ្រប់គ្រងសហគមន៍ព្រៃឈើ និងតំបន់ទ្រនាប់ ទៅជាអនុប្រធាននាយកដ្ឋានអភិរក្ស និងការពារធម្មជាតិ (DNCP) នៃក្រសួងបរិស្ថាន (MoE) និងជាទីប្រឹក្សាគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ដែលមានការិយាល័យនៅអង្គការ WWF ប្រទេសកម្ពុជា ។

ពីរទសវត្សរ៍កន្លងមកបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវការកើតឡើងចលនាថ្មីមួយ ក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការគ្រប់គ្រងដោយមានការចូលរួម ដែលអាចហៅម្យ៉ាងទៀតថា ការគ្រប់គ្រងតាមបែបវិមជ្ឈការ និងដោយសហគមន៍។ ចលនានេះបានអនុវត្តស្ទើរតែពាសពេញពិភពលោក រួមទាំងក្នុងតំបន់ជាច្រើននៅទ្វីបអាស៊ី និងអាហ្វ្រិក ព្រមទាំងនៅប្រទេសឧស្សាហកម្មផងដែរ ។ នៅប្រទេសអូស្ត្រាលី ការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសការគ្រប់គ្រងព្រៃឈើ និងតំបន់ការពារធម្មជាតិបានផ្លាស់ប្តូរពីវិធីសាស្ត្រធ្វើផែនការដែលច្រើនតែតាមបែបមជ្ឈការ ទៅជាដំណើរការបែបវិមជ្ឈការវិញ ។ វិធីសាស្ត្រថ្មីក្នុងការគ្រប់គ្រងធនធានធម្មជាតិនេះបានអនុម័តឱ្យប្រើប្រាស់ដោយអង្គការជាច្រើន ដែលធ្វើការខាងផ្នែកអភិរក្ស និងអង្គការអន្តរជាតិ ព្រមទាំងទីភ្នាក់ងារផ្តល់ជំនួយជាច្រើនដូចជាធនាគារពិភពលោក មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) អង្គការស្បៀង និង កសិកម្មនៃសហប្រជាជាតិ (FAO នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (DANIDA ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (CIDA) និងមូលនិធិ Ford ។



វ៉ែន សេរីវុឌ្ឍ/ CBNRM LI ២០០៤

***ការពិភាក្សាក្រៅផ្លូវការពីវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិនៅប្រទេសកម្ពុជា***

ការផ្លាស់ប្តូរវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ តម្រូវឱ្យមានកំណែទម្រង់រដ្ឋបាល និងការកំណត់តួនាទីភារៈកិច្ចថ្មីមួយសម្រាប់រដ្ឋាភិបាល ដែលកែសម្រួលតួនាទីពីការត្រួតត្រាលើព្រៃឈើ និងធនធានធម្មជាតិដោយផ្ទាល់ទៅជាតួនាទី ដែលផ្តោតទៅលើការសម្របសម្រួលឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ ដែលមានការចាប់អារម្មណ៍ទៅលើធនធានធម្មជាតិ និងព្រៃឈើក្នុងដំណើរការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចដោយមានការចូលរួម។ វិធីសាស្ត្រដែលមានការចូលរួមថ្មីនេះ បានកើតឡើងនៅពាសពេញពិភពលោក ហើយជាទូទៅត្រូវបានដឹកនាំដោយអ្នកផ្តួចផ្តើមគំនិតនៅតាមមូលដ្ឋានក្នុងប្រទេសផ្សេងៗគ្នា និងឆ្លុះបញ្ចាំងពីកាលៈទេសៈ ស្ថានភាពបរិស្ថាន និងនយោបាយនៅតាមមូលដ្ឋានរៀងៗខ្លួន ។ ថ្វីបើប្រទេសនីមួយៗ ប្រើបច្ចេកស័ព្ទផ្សេងៗគ្នាដើម្បី ពិពណ៌នាវិធីសាស្ត្រថ្មីៗរបស់ពួកគេក៏ដោយ អ្វីដែលសំខាន់នោះគឺការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម មានគោលដៅចម្បងគឺការអភិរក្ស ជីវៈចម្រុះ និងការធានាសន្តិសុខជីវភាពរស់នៅតាមមូលដ្ឋាន ។

ប្រទេសមួយចំនួនបានប្រើប្រាស់ពាក្យខ្លះៗដោយឱ្យអត្ថន័យផ្សេងៗពីគ្នា ឧទាហរណ៍ សហគមន៍ព្រៃឈើ ត្រូវបានហៅខុសៗគ្នារវាងប្រទេសឥណ្ឌា ណេប៉ាល់ និងប្រទេសផ្សេងៗទៀត នៅអាស៊ីអាគ្នេយ៍ ។ ដូចគ្នានេះដែរ វិធីសាស្ត្រចំពោះសហគមន៍ជលផលនៅប្រទេសកម្ពុជាអាចមិនដូចគ្នានៅក្នុងប្រទេសផ្សេងទៀតឡើយ ។ ជាទូទៅ វិធីសាស្ត្រ គ្រប់គ្រងដោយមានការចូលរួមទោះបីសម្រាប់តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ឬ សហគមន៍នេសាទក្តី សុទ្ធតែមានបំណង ធ្វើឱ្យអ្នកពាក់ពន្ធ័សំខាន់ៗចូលរួមក្នុងដំណើរការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេចចិត្តអំពីធនធានធម្មជាតិជាក់លាក់មួយចំនួន ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាការធានាសិទ្ធិកាន់កាប់ធនធានធម្មជាតិ ដោយធានាសុវត្ថិភាពខាងផលប្រយោជន៍ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការសំរាប់មនុស្សជំនាន់បច្ចុប្បន្ន និងទៅថ្ងៃអនាគត ។

## តើការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ជាអ្វី ?

លទ្ធផលនៅមានកម្រិតនៃការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិកាលពីប្រមាណទសវត្សរ៍កន្លងមកនេះ បានជម្រុញឱ្យអ្នករៀបចំគោលនយោបាយ អ្នករៀបចំផែនការ និងអ្នកប្រាជ្ញជាច្រើនធ្វើការពិគ្រោះយោបល់ និងពិចារណាឡើងវិញពីតួនាទីសំខាន់ៗរបស់អ្នកពាក់ព័ន្ធ ជាពិសេស សហគមន៍មូលដ្ឋាន រួមទាំងក្រុមដែលសង្គមមិនសូវផ្តល់ឱកាសអោយក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ[៣] ។

ទោះបីជាមានការគាំទ្រលើការគ្រប់គ្រងធនធានធម្មជាតិដែលមានការចូលរួមក៏ដោយ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីដោះស្រាយនូវបញ្ហាស្នូល ក្នុងគោលបំណងធ្វើសមាហរណកម្មគោលដៅនៃការអភិរក្សដោយផ្តោតលើកិច្ចការពារសត្វព្រៃដែលទទួលរងការគម្រាមកំហែង និងទីជម្រករបស់វា (ដូចជា ប្រភេទសត្វជិតផុតពូជ ព្រៃឈើ វាលស្មៅ ធនធានជលផល និងទឹក ជាមួយនឹងការចូលរួមរបស់សហគមន៍មូលដ្ឋានដែលពួកគាត់ចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ ម្ហូបអាហារ ឈើថាមពល ទីជម្រក និងទឹក ។

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ មានទំនាក់ទំនងជាមួយពាក្យដែលពាក់ព័ន្ធជាច្រើន ដូចជា ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរដោយសហគមន៍ សហគមន៍ព្រៃឈើ និងសហគ្រប់គ្រង ។ ការកំណត់និយមន័យ និងពាក្យនានាអាស្រ័យទៅលើបរិបទ និងទីកន្លែង ។

ពាក្យ " ដោយសហគមន៍ (Community-based) " បង្ហាញពីភាពខុសគ្នារវាងវិធីសាស្ត្រដែលកើតមានថ្មីៗ និងទស្សនៈនៃការគ្រប់គ្រងធនធានធម្មជាតិកាលពីអតីតកាល ដោយសំដៅលើសហគមន៍ដែលមានការទទួលខុសត្រូវពេញលេញ និងជាទូទៅ

---

[៣] Agrawal, A. 1999. Enchantment and disenchantment: តួនាទីរបស់សហគមន៍ ក្នុងការអភិរក្សធនធានធម្មជាតិ ។ ការបង្កើតពាក្យ 27 (4): 629-49.

មានលក្ខណៈស្វយ័តចំពោះកិច្ចការពារ និងការប្រើប្រាស់ធនធានធម្មជាតិ ។ វិធីសាស្ត្រនេះកើតចេញពីប្រព័ន្ធនៃការគ្រប់គ្រងធន-ធានធម្មជាតិតាមបែបបុរាណ ដែលចំណេះដឹងមូលដ្ឋាន និងស្ថាប័នបានវិវត្តរួមគ្នាជាមួយស្ថានប្រព័ន្ធធម្មជាតិ ។

CBNRM បានកំណត់ថាសហគមន៍មូលដ្ឋានគឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការកំណត់ធនធាន កំណត់អាទិភាពនៃការអភិវឌ្ឍ កែសម្រួល បច្ចេកវិទ្យា និងអនុវត្តការគ្រប់គ្រង ។ លើសពីនេះ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ គឺជាជម្រើសនៃការអភិវឌ្ឍ ដែលមានសក្តានុពលសម្រាប់ប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ ដើម្បីដោះស្រាយបញ្ហាភាពក្រីក្រតាមមូលដ្ឋាន និងភាពរេចរឹលនៃបរិស្ថាន ។ វិធីសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ជាច្រើន បានសាកល្បងនៅតាមប្រទេសនានានៅក្នុងតំបន់ ហើយគំរូអនុវត្តការងារមួយចំនួនបានរៀបចំឡើងដោយប្រើប្រាស់បទពិសោធន៍ជាក់ស្តែង ទទួលបានមកពីប្រទេសឥណ្ឌា ណេប៉ាល់ ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃឡង់ និងប្រទេសផ្សេងៗទៀត (Carson, 1999: 353-4) ។

វិធីសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធគ្រប់គ្រងដោយរដ្ឋាភិបាល ឬ ប្រព័ន្ធគ្រប់គ្រងពីលើចុះក្រោម ។ របៀបគ្រប់គ្រងធនធានធម្មជាតិតាមទម្លាប់ចាស់ ដែលមានមន្ត្រីនៅតាមស្ថាប័នរដ្ឋាភិបាលពាក់ពន្ធ័ ជាអ្នកដឹកនាំក្នុងការអភិវឌ្ឍ និងរៀបចំគោលនយោបាយទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ ។ មន្ត្រីថ្នាក់លើធ្វើសេចក្តីសម្រេចអំពីការប្រើប្រាស់ធនធានធម្មជាតិ និងការបែងចែកផលពីធនធានទាំងអស់ ។

បទពិសោធន៍ទូលំទូលាយនៃវិធីសាស្ត្រនេះបានបង្ហាញឱ្យឃើញថា សន្និធិធនធានធម្មជាតិ (Stock) និងគុណភាពបរិស្ថាន បានទទួលការរេចរឹលដោយសារតែប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ ដែលមានការគ្រប់គ្រងផែនការ និងការសម្រេចចិត្តនៅតែការិយាល័យរបស់រដ្ឋាភិបាលប៉ុណ្ណោះ និងពុំផ្តល់ឱកាសដល់សហគមន៍មូលដ្ឋាន ដែលច្រើនតែជាអ្នកប្រើប្រាស់ធនធានដោយផ្ទាល់ក្នុងការផ្តល់គំនិត និងចែករំលែកក្តីបារម្ភរបស់ពួកគាត់នៅក្នុងដំណើររៀបចំផែនការ និងការធ្វើសេចក្តីសម្រេចឡើយ (Kosal, 1996) ។

ការកំណត់និយមន័យនៃពាក្យ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ដោយគ្រាន់តែសរសេរមួយ ឬ ពីរប្រយោគនោះស្ទើរតែមិនអាចឆ្លុះបញ្ចាំងខ្លឹមសារបានពេញលេញឡើយ ព្រោះថាវាជាការផ្សំបញ្ចូលគ្នានូវគោលដៅ និងវិធីសាស្ត្រអភិវឌ្ឍន៍នានា ។ អង្គការ ស្ថាប័ន និងប្រទេសផ្សេងៗ មានរបៀបផ្ទាល់ខ្លួនក្នុងការបកស្រាយ និងបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ថាតើពាក្យ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មានន័យដូចម្តេច ។ ប្រអប់ទី១ ខាងក្រោមបង្ហាញពីនិយមន័យជាច្រើន ថ្វីបើការកំណត់និយមន័យនេះមិនមានភាពល្អិតល្អន់ក៏ពិតមែនប៉ុន្តែបានផ្តល់នូវសេចក្តីសង្ខេបពីអត្ថន័យនៃពាក្យ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។

## ប្រអប់ទី១ : ការកំណត់និយមន័យ CBNRM

'**CBNRM** គឺជាយុទ្ធសាស្ត្រអភិរក្សផង និងអភិវឌ្ឍន៍ជនបទផង ដោយរួមបញ្ចូលការប្រមូលផ្តុំ និងការរៀបចំបង្កើតសហគមន៍ ការអភិវឌ្ឍស្ថាប័នការបណ្តុះបណ្តាលទូលំទូលាយ ការអភិវឌ្ឍសហគ្រាស និងការពិនិត្យមើលមូលដ្ឋានគ្រឹះនៃធនធានធម្មជាតិ'[៤] ។
( កម្មវិធីគាំទ្រ **CBNRM** ក្នុងប្រទេស Botswana ; **IUCN** )

'ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ គឺជាវិធីសាស្ត្រនៃការចាត់ចែងពីក្រោមទៅលើដើម្បីធ្វើសមាហរណកម្មនៃការអភិរក្ស និងការអភិវឌ្ឍ '[៥] ។
(វិទ្យាស្ថានអន្តរជាតិ Cornell សម្រាប់ស្បៀងអាហារ កសិកម្ម និងការអភិវឌ្ឍ ។

**CBNRM** គឺជាលទ្ធផលនៃដំណើរការពីរផ្សេងគ្នាដែលទីមួយ ជាដំណើរការគ្រប់គ្រងពីក្រោមទៅលើដែលមានការជម្រុញពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអភិរក្សជីវៈចម្រុះ ។ បន្ថែមពីនេះ **CBNRM** បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើផ្នែកសង្គម ។ ទីពីរ ជាដំណើរការគ្រប់គ្រងពីលើចុះក្រោមដែលភ្នាក់ងារផ្តល់មូលនិធិ ម្ចាស់ជំនួយទ្វេភាគី អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការពាក់ព័ន្ធនានាបានផ្តោតការយកចិត្តទុកដាក់ដើម្បីធ្វើការអនុវត្ត និងស្រាវជ្រាវពីប្រសិទ្ធិភាពនៃវិធីសាស្ត្រនេះ ។ លើសពីនេះទៅទៀតអ្នកពាក់ព័ន្ធខាងលើបានបញ្ចូលវិធីសាស្ត្រទាំងពីរនេះដោយយល់ឃើញថា ថ្វីបើមានភាពផ្សេងគ្នានៃវិធីសាស្ត្រទាំងពីរ ប៉ុន្តែវាមានគោលដៅដូចគ្នា ។ ការរួមបញ្ចូលនៃវិធីសាស្ត្រទាំងពីរនេះធ្វើអោយការគ្រប់គ្រងធនធានធម្មជាតិមានភាពប្រសើរឡើងតាមរយៈការប្រើប្រាស់មធ្យោបាយ និងធនធានរបស់អ្នកពាក់ព័ន្ធនីមួយៗ[៦] ។
(**CBNRM** – ធនាគារពិភពលោក

' **CBNRM** គឺជាការគ្រប់គ្រងធនធានធម្មជាតិដែលមានផែនការច្បាស់លាស់ដែលផែនការនោះ រៀបចំ និងមានការយល់ព្រមពីសំណាក់អ្នកពាក់ព័ន្ធ ។ តាមរយៈវិធីសាស្ត្រនេះ សហគមន៍ជាអ្នកគ្រប់គ្រងធនធានធម្មជាតិដោយទទួលបាននូវសិទ្ធិស្របច្បាប់មានរចនាសម្ព័ន្ធគ្រប់គ្រងនៅមូលដ្ឋាន និងមានកត្តាលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចដើម្បីទទួលខុសត្រូវលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ តាមរយៈផែនការគ្រប់គ្រងធនធានធម្មជាតិ សហគមន៍មានតួនាទីជាអ្នកអនុវត្តន៍ការងារផ្ទាល់ដែលមានការគាំទ្រ និងការត្រួតពិនិត្យពីភ្នាក់ងារបច្ចេកទេស[៧] ' (**USAID**) ។

' **CBNRM** ធ្វើការវិភាគពីទំនាក់ទំនងនៃកត្តាផ្សេងៗដែលមានឥទ្ធិពលលើការប្រើប្រាស់ធនធានធម្មជាតិ និងជម្រើសនៃការគ្រប់គ្រង ។ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់សហគមន៍មូលដ្ឋានមានសារៈសំខាន់ណាស់ក្នុងការលើកកំពស់វិធីសាស្ត្រ **CBNRM** ដែលវិធីសាស្ត្រនេះរៀបចំឡើងដោយឈរលើគោលការណ៍ស្ម័គ្រចិត្តនៃការលើកកំពស់ចំណេះដឹង និងការអនុវត្តនៅមូលដ្ឋានជាជាងការកំណត់គោលការណ៍គ្រប់គ្រងពីខាងក្រៅ ។ វិធីសាស្ត្រនេះតម្រូវអោយមានការទទួលស្គាល់ពីភាពផ្សេងគ្នា និងចំណាប់អារម្មណ៍របស់សមាជិកសហគមន៍ និងអ្នកប្រើប្រាស់ធនធានមកពីខាងក្រៅសហគមន៍ ។'[៨]
( មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា - IDRC

*ផ្អែកលើ IDRC (2002)*

4 http://www.cbnrm.bw/pages_sub_dir/Main.htm
5 Cornell International Institute for Food, Agriculture and Development Annual Report, 1999-20000.
6 http://.www.cbnrm.net/about/overview/introduction.html
7 http://www.usaid.gov/procurement_bus_opp/procurement/announce/cbd/1010720-83426.27164.shtml
8 IDRC CBNRM programme initiative phase II prospectus, 2000-2003.

តាមបរិបទនៃប្រទេសកម្ពុជា ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍អាចត្រូវបានកំណត់ថា :

> *'ភាពចម្រុះគ្នានៃវិធីសាស្ត្រសហគ្រប់គ្រង ដែលព្យាយាមផ្តល់អំណាចឱ្យសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកយ៉ាងសកម្មក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តភាពតាមរយៈយុទ្ធសាស្ត្រផ្សេងៗគ្នា រួមទាំងសហគមន៍ព្រៃឈើ សហគមន៍នេសាទ ការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម និងសហគមន៍តំបន់ការពារធម្មជាតិ[៩]' ។*

*(គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា*

និយមន័យនេះ បានអនុម័តក្នុងពេលធ្វើសិក្ខាសាលាថ្នាក់ជាតិមួយ ស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ នៅទីក្រុងភ្នំពេញកាលពីខែវិច្ឆិកា ឆ្នាំ២០០២ ។ សិក្ខាសាលានេះចូលរួមដោយសិក្ខាកាមចំនួន ១១៥រូប តំណាងអោយស្ថាប័នរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងគម្រោងនានាដែលធ្វើការងារលើផ្នែក CBNRM ។

លើសពីនេះ ទស្សនទាននៃ CBNRM ត្រូវបានប្រើប្រាស់ដើម្បីសំដៅទៅលើការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ។ ការពិពណ៌នាអំពីពាក្យទាំងនេះមានបកស្រាយក្នុងប្រអប់ទី ២ ខាងក្រោម ។

---

[៩] របាយការណ៍នៃសិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ២០០៣ ភ្នំពេញ កម្ពុជា ។

## ប្រអប់២: ពាក្យដែលប្រើជាទូទៅ ឬ ទាក់ទងនឹង CBNRM

**កិច្ចសហការគ្រប់គ្រងព្រៃឈើ / កិច្ចសហការគ្រប់គ្រងធនធានធម្មជាតិ/សហគ្រប់គ្រង (Collaborative forest management / collaborative natural resource management/ co-management) :** សំដៅលើភាពជាដៃគូ ដែលក្នុងនោះ អ្នកពាក់ព័ន្ធជាច្រើនឯកភាពលើការចែករំលែកមុខងារគ្រប់គ្រង សិទ្ធិ និងកម្មសិទ្ធិ ផលចំណេញ និងការទទួលខុសត្រូវលើតំបន់ព្រៃឈើ ។ ជាធម្មតាអ្នកពាក់ព័ន្ធទាំងនោះមានជាអាទិ៍ ភ្នាក់ងារដែលចាប់អារម្មណ៍លើធនធាន និងសមាគមរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចតាមបែបប្រពៃណី ម្ចាស់ឧស្សាហកម្ម អ្នកជំនួញ វិទ្យាស្ថានស្រាវជ្រាវ និងភ្នាក់ងារផ្សេងទៀត ។

**ព្រៃឈើសង្គម (Social forestry) :** មានការប្រើប្រាស់ពាក្យនេះជាលើកដំបូងដោយរដ្ឋាភិបាលនៃប្រទេសឥណ្ឌា សំដៅលើកម្មសិទ្ធិ ដីព្រៃឈើ ជាចំណែកមួយ នៃដីធ្លីរបស់ភូមិ (មិនមែនជាព្រៃឈើបម្រុងទុកនោះទេ ។ បច្ចុប្បន្ន ពាក្យនេះមានន័យថា ជាការគ្រប់គ្រងព្រៃឈើប្រកបដោយគោលបំណងខាង សង្គម ដែលសំដៅផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន ។

**សហគមន៍ព្រៃឈើ (Community forestry) :** ជាពាក្យដែលមានន័យទូលំទូលាយដោយរួមបញ្ចូលប្រព័ន្ធនានា នៃការគ្រប់គ្រងព្រៃឈើដោយសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាកម្មវិធីនានា ដែលផ្តួចផ្តើមដោយសហគមន៍ ឬ រដ្ឋាភិបាល ។ បច្ចុប្បន្នពាក្យ សហគមន៍ព្រៃឈើបានប្រើប្រាស់យ៉ាងទូលំទូលាយដោយសំដៅលើប្រភេទផ្សេងៗនៃការគ្រប់គ្រងព្រៃឈើដោយប្រជាពលរដ្ឋ ។

**ការគ្រប់គ្រងព្រៃឈើរួមគ្នា (Joint forest management) :** ការចែករំលែកផលិតផល និងការទទួលខុសត្រូវរួមគ្នារវាងនាយកដ្ឋានរុក្ខា-ប្រមាញ់ និងក្រុមអ្នកប្រើប្រាស់ ។ កិច្ចការនេះអាចពាក់ព័ន្ធនឹងកិច្ចសន្យាកំណត់ពីសមត្ថកិច្ចការទទួលខុសត្រូវ និងការបែងចែកផលរវាងអ្នកភូមិ និងអង្គភាពគ្រប់គ្រងព្រៃឈើរបស់រដ្ឋ ។ គោលគំនិតដើមនៃការប្រើប្រាស់ព្រៃឈើរួមគ្នា ផ្តើមពីការដាំព្រៃឈើជាចំការនៅលើចំណែកដីរបស់រដ្ឋក្នុងប្រទេសឥណ្ឌា ប៉ុន្តែបច្ចុប្បន្នពាក្យនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ។

**ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម (Participatory forestry) :** ជាពាក្យ ដែលមានន័យរួមបញ្ចូលទាំងអត្ថន័យ និងទម្រង់នៃការគ្រប់គ្រងព្រៃឈើនីមួយៗ ដែលបានបកស្រាយនៅក្នុងប្រអប់ខាងលើ ។

**ការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន (Local forest management) សំដៅលើ**បណ្តាសកម្មភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្បែរព្រៃឈើមួយកន្លែងធ្វើការថែរក្សា ឬ លើកស្ទួយគុណភាពព្រៃឈើ និងកែលំអសុខុមាលភាពរបស់ខ្លួន ។ ជាការយល់ឃើញថា ប្រជាពលរដ្ឋមូលដ្ឋានជួយបង្កើននិរន្តរភាពព្រៃឈើ បង្កើតឱ្យមានការបែងចែកផល រក្សាអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងធនធាន និងចូលរួមក្នុងការដោះស្រាយតម្រូវការដែលមានលក្ខណៈប្រកួតប្រជែងតាមរយៈវិធីសាស្ត្រកាត់បន្ថយទំនាស់ និងបង្កើនប្រសិទ្ធភាព ។ ពាក្យនេះ បញ្ជាក់ពីការគ្រប់គ្រងដែលធ្វើឡើងជាចម្បងដោយអ្នកនៅមូលដ្ឋានដោយមានអន្តរាគមន៍អប្បបរមាពីខាងក្រៅ ។

**ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (Community forest based management) :** សំដៅលើការគ្រប់គ្រងព្រៃឈើជាមួយសហគមន៍មូលដ្ឋានដែលរួមមានការគ្រប់គ្រងព្រៃឈើ តាមបែបប្រពៃណី ។ ថ្មីៗនេះពាក្យនេះបានយកមកប្រើចំពោះ គម្រោងសហគមន៍ព្រៃឈើដែលគ្រប់គ្រងដោយសហគមន៍នៅ តាមឃុំ ឬទីក្រុងដោយមានការបែងចែកកម្មសិទ្ធជាមួយរដ្ឋ និងរៀបចំនូវការគ្រប់គ្រងរួមគ្នារវាងរដ្ឋ និងសហគមន៍ ។

**ព្រៃឈើកសិដ្ឋាន (Farm forestry) :** សំដៅលើការដាំព្រៃឈើដោយកសិករលើដីឯកជន ដែលច្រើនតែធ្វើឡើងដោយក្រុមសហគមន៍សំដៅរួបរួមគ្នា ក្នុងបំណងសម្របសម្រួលការលក់ផលព្រៃឈើ កែច្នៃ និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

**ការចូលរួមជាសាធារណៈក្នុងវិស័យព្រៃឈើ (Public participation in forestry):** គឺជាពាក្យមួយមានន័យទូលំទូលាយ ប្រើសំដៅដល់វិធីសាស្ត្រ ជាច្រើនដែលប្រជាពលរដ្ឋអាចមានឥទ្ធិពលលើវិស័យព្រៃឈើ ប៉ុន្តែមិនចាំបាច់ចូលរួមក្នុងការធ្វើសេចក្តីសម្រេចរួមគ្នា (ប្រកបដោយកិច្ចសហការ នោះឡើយ ។

**សហគមន៍តំបន់ការពារធម្មជាតិ (Community protected area management) :** ត្រូវបានស្គាល់ថា ជាការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម ដែលជា ដំណើរការមួយសំដៅសម្រេចឱ្យបាននូវស្ថានភាពឈ្នះ-ឈ្នះ ដែលផ្តល់ការអនុគ្រោះដល់អ្នកគ្រប់គ្រងធនធានធម្មជាតិក្នុងការសម្រេចគោលបំណងអភិរក្សជីវៈចម្រុះ និងផ្តល់អនុគ្រោះដល់អ្នកប្រើប្រាស់ធនធានក្នុងការធានាជីវភាពរស់នៅ និងរក្សាតម្លៃខាងវប្បធម៌ និងជំនឿ ។[១០]

[១០] ទទួលបានពីការសិក្សាវាយតម្លៃដោយរហ័ស ស្តីពីការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ DNCP/MoE 2004 ។ CPA មានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងការកសាងផែនការ ការអនុវត្ត ការតាមដាន និងវាយតម្លៃលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

សកម្មភាពការងារឆ្ពោះទៅរកការគ្រប់គ្រងធនធានធម្មជាតិ (NRM) ដោយមានការចូលរួមចាំបាច់ត្រូវមានការយល់ដឹងយ៉ាងច្បាស់ពីសហគមន៍ដែលដើរតួយ៉ាងសំខាន់ក្នុងដំណើរការនេះ ។ ជាទូទៅ ដោយសារតែពាក្យ "សហគមន៍" ត្រូវបានកំណត់ថាជាក្រុម ឬ អង្គការចាត់តាំងឯកភាពមួយនៃសង្គមមនុស្ស ដូច្នេះចាំបាច់ត្រូវស្វែងយល់ពីទស្សនៈ និងផលប្រយោជន៍ផ្សេងៗគ្នា និងថាតើភាពខុសគ្នាទាំងអស់នេះអាចប៉ះពាល់ដល់លទ្ធផលនៃការគ្រប់គ្រងធនធានធម្មជាតិ និងគោលនយោបាយនៅមូលដ្ឋាន និងទំនាក់ទំនងជាយុទ្ធសាស្ត្រនៅក្នុងសហគមន៍ ព្រមទាំងនយោបាយនៅតាមលំដាប់ជាច្រើននៃសហគមន៍នីមួយៗ ។ តាមរយៈបទពិសោធន៍ទទួលបានពីការងារ CBNRM បង្ហាញថា មានភាពចាំបាច់ក្នុងការស្វែងយល់ថាសហគមន៍ត្រូវបានរាប់បញ្ចូលចាប់ពីក្រុមតូចៗរហូតដល់ក្រុមធំដែលមានរចនាសម្ព័ន្ធសង្គមដូចគ្នា និងក្រុមដែលមានចំណាប់អារម្មណ៍រួម និងរស់នៅក្នុងបរិបទរួមគ្នា ។

**នៅពេលដែលសហគមន៍ត្រូវបានទទួលស្គាល់ថាជាក្រុមតូចៗនៃសង្គមមនុស្ស** នេះជាការទទួលស្គាល់ថាធនធានធម្មជាតិដែលប្រជាពលរដ្ឋ ប្រើប្រាស់ គ្រប់គ្រង និងការពារ ជាធម្មតាមានទីតាំងស្ថិតនៅជិតផ្ទះ និងកន្លែងតាំងទីលំនៅអចិន្ត្រៃយ៍នៅមូលដ្ឋាន ។ ក្នុងករណីនេះ ប្រសិនបើវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិបែបវិមជ្ឈការមិនអាចដំណើរការបានល្អដោយសារអ្នកគ្រប់គ្រងធនធានក្នុងស្ថាប័នរដ្ឋាភិបាលមិនមានសមត្ថភាពគ្រប់គ្រងពីចំងាយ ដូច្នេះការផ្ទេរអំណាចទៅឱ្យក្រុមសង្គមដែលមានទីតាំងនៅក្បែរ ធនធានអាចដំណើរការទៅបាន ល្អប្រសើរជាង ។

ការផ្តល់អំណាចទៅដល់សហគមន៍មូលដ្ឋានដែលរឹងមាំអាចដំណើរការទៅបានល្អសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ព្រោះជាញឹកញាប់ សមាជិករបស់ក្រុមតូចៗដែលរស់នៅក្នុងកន្លែងតែមួយ ហាក់ដូចជាមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកច្រើន ។ ការប្រាស្រ័យទាក់ទងគ្នាជិតស្និទ្ធរវាងសមាជិកក្រុមតូចៗ អាចកាត់បន្ថយការចំណាយក្នុងការធ្វើសេចក្តីសម្រេចរួមគ្នា ។ ទស្សនៈទាំងពីរបែបអំពីសហគមន៍គឺ : ត្រូវការបុគ្គលិកតិច កន្លែងធ្វើការតូច ក្រុមនានាមានលក្ខណៈខុសប្លែកពីគ្នា ។ នៅពេលខាងមុខ ការប្រាស្រ័យទាក់ទងគ្នាក្នុងចំណោមសមាជិកក្រុមតូចៗនៅក្នុងតំបន់មួយអាចនឹងរួមចំណែកដល់ការរៀបចំបង្កើតយុទ្ធសាស្ត្រដើម្បីគ្រប់-គ្រងធនធានធម្មជាតិដែលមាននៅក្បែរសហគមន៍របស់ពួកគាត់ ។

**នៅពេលដែលសហគមន៍មានលក្ខណៈជារចនាសម្ព័ន្ធសង្គមមនុស្សដែលមានលក្ខណៈសម្គាល់មួយចំនួនដូចគ្នា** នេះប្រហែលមកពីពួកគេមានលក្ខណៈសម្បត្តិរួម ដែលទាក់ទងទៅនឹងជនជាតិ សាសនា វណ្ណៈ ឬ ភាសា ។ ភាពដូចគ្នាបែបនេះ អាចនាំឱ្យមានដំណោះស្រាយរួមគ្នា ដែលកាត់បន្ថយគម្លាតរវាងឋានៈ និងទំនាស់នៅក្នុងការប្រាស្រ័យទាក់ទងគ្នា និងជម្រុញឱ្យការគ្រប់គ្រងធនធានធម្មជាតិបានប្រសើរឡើង ។ ក្រុមគ្រួសារនៅក្នុងសហគមន៍អាចមានទ្រព្យសម្បត្តិ ឬ ប្រាក់ចំណូលប្រហាក់ប្រហែលគ្នា ។ នៅតំបន់ជនបទ ប្រជាពលរដ្ឋដែលរស់នៅក្នុងទីតាំងជាមួយគ្នាអាចមានមុខរបរស្រដៀងគ្នា ហើយពឹងអាស្រ័យលើធនធានធម្មជាតិដូចគ្នា ។ ភាពដូចគ្នាទាំងអស់នេះអាចសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នាជាប្រក្រតីក្នុងចំណោមសមាជិកក្រុម ។

សហគមន៍ដែលត្រូវបានកំណត់ថាជាក្រុមដែលមានចំណង់ចំណូលចិត្តរួម និងទម្លាប់រស់នៅរួមគ្នា ជាសំខាន់នោះគឺ សហគមន៍ទាំងឡាយដែលមានឈ្មោះ ដែលជាញឹកញាប់អាស្រ័យទៅលើទស្សនៈយល់ដឹងរបស់អ្នកខាងក្រៅ។ បទបញ្ជាផ្ទៃក្នុង ឬ លក្ខន្តិកៈរបស់សមាជិកនៅក្នុងសហគមន៍ទាំងអស់នេះអាចតំរង់ទិសដៅនៃការគ្រប់គ្រងឆ្ពោះទៅរកលទ្ធផលដែលពួកគាត់ចង់បាន ហើយសហគមន៍អាចទទួលស្គាល់ខ្លួនឯងជាផ្លូវការ បន្ទាប់ពីមានការប្រាស្រ័យទាក់ទងគ្នា និងដំណើរការស្វែងរកផលប្រយោជន៍រួម។

## ហេតុអ្វីតម្រូវឱ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍?

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ត្រូវបានអភិវឌ្ឍ និងបង្កើតឡើងដោយកត្តាសំខាន់២គឺ ការសម្រេចមិនដល់គោលដៅ និងភាពជឿជាក់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ ការសម្រេចមិនដល់គោលដៅនេះកើតឡើងដោយសារ ការមិនយកចិត្តទុកដាក់ពីតម្រូវការ និងចំណាប់អារម្មណ៍ក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ។ ស្របពេលជាមួយគ្នានេះ ការគ្រប់គ្រងធនធានធម្មជាតិនៅកន្លែងផ្សេង ត្រូវបានជម្រុញលើកទឹកចិត្តតាមរយៈការចូលរួមប្រកបដោយជោគជ័យរបស់សហគមន៍មួយចំនួន ក្នុងការកសាងផែនការសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

ដើម្បីគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើឱ្យមាននិរន្តរភាព CBNRM ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការអភិរក្សជីវៈចម្រុះ និង ការធានាសន្តិសុខជីវភាពរស់នៅរបស់អ្នកពាក់ព័ន្ធ រួមបញ្ចូលទាំងក្រុមជនក្រីក្រ និង ក្រុមដែលសង្គមមិនសូវផ្តល់ឱកាសអោយ។ ថ្វីបើក្រុមអ្នកពាក់ព័ន្ធគាំទ្រថាគោលបំណងទាំងពីរនេះមានភាពផ្ទុយគ្នា ប៉ុន្តែភាពផ្ទុយគ្នានេះមានសារៈ-សំខាន់ដោយហេតុផល៣យ៉ាងដូចខាងក្រោម:

ទី១ ការពារជីវៈចម្រុះដើម្បីរក្សាប្រភេទសត្វរុក្ខជាតិ និងស្ថេរភាពនៃប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការការពារជីវៈចម្រុះ (ប្រភេទទទួលរងការគំរាមកំហែង និងជិតផុតពូជ ក៏បានចូលរួមចំណែកក្នុងវិស័យសេដ្ឋកិច្ចផងដែរតាមរយៈផលប្រយោជន៍និងប្រាក់ចំណូលទទួលបានពីវិស័យអេកូ-ទេសចរណ៍។

ទី២ ថែរក្សាប្រព័ន្ធអេកូឡូស៊ី ដូចជា ទីជម្រាលសម្រាប់សេវានានា ដែលផ្តល់ប្រយោជន៍ដល់ថ្នាក់សហគមន៍ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់សកល។ សេវាទាំងនេះមានជាអាទិ៍ ការអភិរក្សដី និងជីជាតិ ការប្រើប្រាស់ទឹកប្រកបដោយនិរន្តរភាព រក្សាតុល្យភាព មីក្រូអាកាសធាតុ ដំណុះព្រៃឈើដែលផ្តល់ផល និងអនុផលព្រៃឈើ ផលនេសាទ និងប្រព្រឹត្តកម្មធនធានដី ខ្យល់អាកាស និងទឹក។

ផលប្រយោជន៍ទាំងអស់នេះមានតម្លៃសេដ្ឋកិច្ច ទោះបីជាទូទៅមិនសមស្របទៅនឹងការចំណាយទៅឱ្យបុគ្គល និងសហគមន៍នានា ដែលកិច្ចសហការរបស់ក្រុមទាំងនេះមានសារៈសំខាន់ដើម្បីថែរក្សាធនធានក៏ដោយ ។

ចុងក្រោយ CBNRM តែងតែមានទំនាក់ទំនងជាមួយវប្បធម៌ និងតម្លៃនៃសហគមន៍ ដែលវិធីសាស្ត្រនេះហាក់បីដូចជាទទួលបានជោគជ័យច្រើន បើប្រៀបធៀបនឹងវិធីសាស្ត្រផ្សេងៗទៀតនៃការគ្រប់គ្រងធនធានធម្មជាតិ ព្រោះថាវិធីសាស្ត្រនេះបានបង្កើនសមត្ថភាព និងផ្តល់ការលើកទឹកចិត្តច្រើនដល់សហគមន៍ដើម្បីថែរក្សាស្ថានប្រព័ន្ធ និងធនធានធម្មជាតិរបស់ពួកគេ ។

ជាការសំខាន់ត្រូវចងចាំថា សហគមន៍អាចមានហេតុផលរបស់ពួកគាត់ក្នុងការយល់ព្រម ឬ ជំទាស់ទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ ហេតុផលទាំងនេះមានជាអាទិ៍ ផលប៉ះពាល់អវិជ្ជមានរយៈពេលខ្លី ឬ រយៈពេលវែងទៅលើជីវភាពរស់នៅ ឬ ផលប៉ះពាល់វិជ្ជមានដែលជួយដល់ការពង្រឹងអត្តសញ្ញាណ និងនិរន្តរភាពរបស់សហគមន៍ ។ ការពិភាក្សា និងការប្រៀបធៀបគោលបំណងទាំងនេះ មានសារៈសំខាន់សម្រាប់ការពិចារណាដែលជាផ្នែកមួយនៃដំណើរការរៀបចំការគ្រប់គ្រងដោយសហគមន៍ ។ លើសពីនេះទៅទៀត ប្រសិនបើតម្រូវឱ្យអ្នកពាក់ព័ន្ធក្នុងសហគមន៍ជួយបំពេញគោលបំណង របស់អ្នកពីខាងក្រៅនោះ ប្រការចាំបាច់គឺត្រូវធ្វើសុខដុមនីយកម្មគោលបំណងរបស់អ្នកខាងក្នុង និងអ្នកខាងក្រៅសហគមន៍ជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតដែលនេះជាកត្តារួមវិភាគទានចំពោះការសម្រេចសេចក្តីប៉ងប្រាថ្នានៅមូលដ្ឋាន ។

បទពិសោធន៍ និងមេរៀនដែលទទួលបានបង្ហាញថា ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មានតួនាទីសំខាន់ក្នុងការដោះស្រាយទំនាក់ទំនងរវាងការព្រួយបារម្ភពីបញ្ហាយុត្តិធម៌សង្គម និងភាពរេចរឹលនៃបរិស្ថាន ។ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ក៏ផ្តល់ផងដែរនូវឱកាសដ៏ធំធេងសម្រាប់ការចូលរួមរបស់ក្រុមអ្នកពាក់ព័ន្ធ ជាពិសេសក្រុមដែលសង្គមមិនសូវផ្តល់ឱកាសអោយ នៅក្នុងដំណើរការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេច ដែលមានឥទ្ធិពលចំពោះសុខុមាលភាព និងបរិស្ថានរស់នៅរបស់ពួកគាត់ ។ ប្រសិនបើមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នោះការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ផ្តល់ឱកាស និងវេទិកាសម្រាប់អ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់ពួកគាត់ ដោយមិនធ្វើឱ្យខូចខាតគុណភាពបរិស្ថានឡើយ ។

វិធីសាស្ត្រភាពជាដៃគូខាងលើនេះតម្រូវឱ្យមានការពង្រឹងសមត្ថភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសនៅក្នុងសហគមន៍ ។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក មានការផ្លាស់ប្តូរឆ្ពោះទៅរកការទទួលខុសត្រូវរួមគ្នាលើការគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើដែលអំពាវនាវឱ្យមានការកំណត់ឡើងវិញនូវទំនាក់ទំនង ក្នុងចំណោមអ្នកពាក់ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ពន្ធ័ និង វិធីសាស្ត្រគ្រប់គ្រង ។ នៅក្នុងការផ្លាស់ប្តូរនេះ គំរូនៃការគ្រប់គ្រងធនធានធម្មជាតិបានផ្លាស់ប្តូរពីវិធីសាស្ត្ររៀបចំផែនការតាមបែបមជ្ឈការ ទៅជាដំណើរការបែបវិមជ្ឈការ និងអាចបត់បែនបាន ។ ប្រអប់ទី៣សង្ខេបពីភាពខុសគ្នារវាងវិធីសាស្ត្រទាំងពីរនេះ និងលទ្ធផលដែលកើតចេញពីដំណើរការនេះសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ។

## ប្រអប់ទី ៣ : គំរូពីរបែបនៃការគ្រប់គ្រង

| គំរូធម្មតា (SIMPLE MODELS) | ដំណើរការស្មុគស្មាញ (COMPLEX PROCESS) |
|---|---|
| មានលក្ខណៈ (were) | គឺជា (are also) |
| មជ្ឈការ (centralized) | វិមជ្ឈការ (decentralized) |
| ពីលើចុះក្រោម (top down) | ពីក្រោមទៅលើ (bottom up) |
| ចំណូល (revenue) | ធនធាន (resource) |
| ដាំជាចំការ (plantation) | ដំណុះឡើងវិញ (regeneration) |
| ការប្រើប្រាស់ (use) | ការគ្រប់គ្រង (management) |
| ការផលិត (production) | និរន្តរភាព (sustainability) |
| គម្រោងការ (blueprints) | ផែនការដែលអាចបត់បែនបាន (flexible plans) |
| ទម្រង់ការ (procedures) | ការធ្វើពិសោធន៍ (experimentation) |
| ការត្រួតត្រា (controlling) | ការគាំទ្រ (supporting) |
| ធ្វើសេចក្ដីសម្រេច (decided) | មានការព្រមព្រៀង (agreed) |
| ទីកន្លែង (area) | ទីតាំង (site) |
| មានហានិភ័យតិច (low risk) | មានហានិយភ័យខ្ពស់ (risk taking) |
| មានភាពលាក់កំបាំង (opaque) | តម្លាភាព (transparent) |
| ធ្វើបានយ៉ាងឆាប់រហ័ស (quick fix) | ដំណើរការយឺតយ៉ាវ (slower process) |
| មានតែមួយ ហើយកំណត់ជាមុន (single and pre-set) | ច្រើនបែប និងអាស្រ័យលើតម្រូវការ (multiple and needs-based) |
| ប្រភេទ (species) | ជីវៈចម្រុះ (biodiversity) |
| ឈើពាណិជ្ជកម្ម (timber) | ផលិតផល (products) |
| ទិសដៅ (target) | គោលដៅជាច្រើន (aims) |
| អតិថិជន (client) | អ្នកពាក់ព័ន្ធ (stakeholders) |
| ដំណោះស្រាយ (solution) | ដំណើរការ (processes) |

*ប្រភព: ដកស្រង់ចេញពី Hobley (1996)*

## សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍អាចជាមធ្យោបាយមានប្រសិទ្ធិភាព សម្រាប់គ្រប់គ្រងធនធានធម្មជាតិ នៅពេលដែលសហគមន៍មួយផ្លាស់ប្តូរគោលជំហរពីការប្រើប្រាស់ធនធាន ទៅជាការគ្រប់គ្រងធនធានក្នុងភាពជាដៃគូ ជាមួយអ្នកគ្រប់គ្រងធនធានខាងរដ្ឋាភិបាល ។ វិធីសាស្ត្រវិមជ្ឈការដែលបើកចំហរ និងអាចបត់បែនបាននេះ កំពុងត្រូវបានប្រើប្រាស់ប្រកបដោយជោគជ័យសម្រាប់ជាដំណោះស្រាយមួយដើម្បីបំលែងការបំផ្លិចបំផ្លាញអោយទៅជាការកែលំអធនធានធម្មជាតិវិញ ។ ទោះបីជា ត្រូវបានទទួលស្គាល់ថា CBNRM ជាជំហានសំខាន់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើក៏ដោយអ្នកគ្រប់គ្រង និងអ្នកធ្វើសេចក្តីសម្រេចខាងរដ្ឋាភិបាលជាច្រើនមានការស្ទាក់ស្ទើរក្នុងការប្រកាន់យកវិធីសាស្ត្រគ្រប់គ្រងនេះ ។ ពេលវេលា ការស្វែងយល់ពីបរិយាកាសមូលដ្ឋាន ការទទួលស្គាល់ផលប្រយោជន៍របស់អ្នកពាក់ព័ន្ធផ្សេងៗ និងក្របខ័ណ្ឌច្បាប់ដែលគាំទ្រ មានសារៈសំខាន់ណាស់ក្នុងការចាត់ចែងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ឱ្យឆ្លើយតបទៅនឹងគោលបំណង នៃការអភិរក្សជីវៈចម្រុះ របស់សហគមន៍មូលដ្ឋាន ។

## REFERENCES

Agrawal, A. 1999. Enchantment and disenchantment: the role fo community in natural resource conservation. *World Development* 27 (4): 629-49.

Carson, T. 1999. *community based Natural Resource Management.* Phnom Penh, Cambodia. http://www.cbnrm.bw/pages _ sub _ dir/Main.htm

*Cornell International Institute for Food, Agriculture and Development Annual Report,* 1999-2000. http://www.cbnrm.net/about/overview/introduction.html

Http://www.usaid.gov/procurement _ bus _ opp/procurement/announce/cbd/1010720-83426.27164.shtml

Hobley, M. 1996. *Presentation of Synthesis of Findings. ODA Review Workshop.* 22 - 23 July 1996. Wye, UK.

International Development Research Centre. 2000. *community based Natural Resources Management Programme Initiative Phase II Prospectus,* 2000-2003.

Mam, Kosal, 1996. *Community Based Resource Management: General Concept and Implications for Cambodia.* Phnom Penh, Cambodia.

Meas, S.V.T., San, S.L., Ouk, S., Mao, K., Ma, C.S. 2004. *A Rapid Assessment on Community Protected Areas Development,* Department of Nature Conservation and Protection, Ministry of Environment, Phnom Penh, Cambodia.

*Proceedings Report of National Workshop on Community Based Natural Resources Management in Cambodia,* 2003, Phnom Penh, Cambodia.

# ជំពូក ២ ការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ នៅប្រទេសកម្ពុជា

រៀបចំដោយ លោក ថូប៊ី ខាស្សិន[១] កញ្ញា ហ៊ូ កល្យាណ[២] និងលោក ស្រី ម៉ារ៉ូណា[៣ និង ៤]

## សេចក្តីផ្តើម

ជំពូកនេះសង្ខេបនូវបរិបទ និងបទពិសោធន៍នៃការការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management - CBNRM នៅប្រទេសកម្ពុជា។ ជំពូកនេះចាប់ផ្តើម ដោយបង្ហាញពីស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេស ហើយបន្ទាប់មកពិពណ៌នាពីភាពផ្សេងគ្នានៃវិធីសាស្ត្រសហគ្រប់គ្រងដែលបង្ហាញឱ្យឃើញនូវក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍគោលនយោបាយ ច្បាប់ និងស្ថាប័ន ក៏ដូចជាតួនាទីនៃបណ្តាញការងារ ក្រុមការងារចម្រុះ និងការអភិវឌ្ឍស្ថាប័ន ដើម្បីការកសាងទំនាក់ទំនង ក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ ។ ជំពូកនេះក៏ផ្តល់ជូនផងដែរ នូវសេចក្តីសង្ខេបនៃមេរៀនទទួលបានពីបទពិសោធន៍តាមរយៈការស្រាវជ្រាវ និងវេទិការៀនសូត្រផ្សេងៗ ដែលនឹងត្រូវធ្វើការពិភាក្សាលម្អិតនៅក្នុងជំពូកក្រោយៗជាបន្តបន្ទាប់ ។ យើងអាចនិយាយថា ជំពូកនេះបញ្ចប់ដោយធ្វើការពិនិត្យមើលជាសង្ខេបលើឱកាស និងការប្រឈម សម្រាប់ការអនុវត្តវិធីសាស្ត្រ CBNRM នៅក្នុងប្រទេសកម្ពុជា ។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥ គម² មានឆ្នេរសមុទ្រប្រវែង ៤៣៥ គ.ម និងព្រំប្រទល់ដីគោកប្រវែង ២.៤៣៨ គ.ម ។ ធនធានទឹក ធនធានជលផល និងព្រៃឈើគឺជាធនធានសំខាន់ជាងគេរបស់ប្រទេសកម្ពុជា ។ ទីជម្រាលតំបន់ទន្លេមេគង្គ គ្របដណ្តប់លើ ៨៦ភាគរយនៃផ្ទៃដីគោករបស់ប្រទេស រួមបញ្ចូលទាំងបឹងទន្លេសាបផងដែរ ដែលជាបឹងទំនាបលិចទឹកធំបំផុតមួយ និងជាដែននេសាទទឹកសាបមួយក្នុងចំណោមដែននេសាទនានា ដែលផ្តល់ផលិតផលច្រើនជាងគេបំផុតនៅលើពិភពលោក ។




---

[១] លោក ថូប៊ី ខាស្សិនជាទីប្រឹក្សាគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (WWF, IDRC, Oxfam America, RECOFTC) ដែលធ្វើការងារផ្តោតលើការបង្កើនសមត្ថភាព ការធ្វើការងារ ការរៀនសូត្រពីបទពិសោធន៍ និងការគាំទ្រគោលនយោបាយសម្រាប់ CBNRM ។

[២] កញ្ញា ហ៊ូ កល្យាណ គឺជាទីប្រឹក្សាគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និងជាអនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារនៃនាយកដ្ឋានការពារ អភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ។

[៣] លោក ស្រី ម៉ារ៉ូណា គឺជាប្រធានក្រុមគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និងជាទីប្រឹក្សាថ្នាក់ជាតិរបស់គម្រោងគ្រប់គ្រងតំបន់យុទ្ធសាស្ត្រ ដើម្បីបញ្ចូលទៅក្នុងការអភិរក្សដែលមានការិយាល័យនៅអង្គការ WWF ។ ថ្មីៗនេះ លោក ស្រី ម៉ារ៉ូណា ត្រូវបានតម្លើងឋានៈជាប្រធានការិយាល័យសហគមន៍ តំបន់ការពារនៃក្រសួងបរិស្ថាន ។

[៤] ជាមួយនឹងការចូលរួមចំណែកពីក្រុមការងារគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។

ផលនេសាទទឹកសាបប្រចាំឆ្នាំមានបរិមាណច្រើនជាងគេចំណាត់ថ្នាក់ទី៤ នៅលើពិភពលោក និងត្រូវបានប៉ាន់ប្រមាណរវាងពី ២៣០ ០០០ ទៅ ៤០០ ០០០តោន ក្នុងមួយឆ្នាំ ។ ផលនេសាទនេះផ្តល់ប្រូតេអ៊ីនសរុបរហូតដល់ ៧៥ភាគរយនៃបរិមាណប្រូតេអ៊ីនសរុបក្នុងរបបអាហាររបស់ប្រជាពលរដ្ឋកម្ពុជាគឺ ៦៧គ.ក្រ/ម្នាក់ក្នុងមួយឆ្នាំ ។ ការប៉ាន់ប្រមាណបង្ហាញឱ្យឃើញថាមានប្រជាពលរដ្ឋពី ១-៣លាននាក់ ពឹងផ្អែកលើធនធានជលផលទឹកសាបសម្រាប់ចិញ្ចឹមជីវិត ។ ទំហំបឹងទន្លេសាបកើនឡើងបួនដងពី ២៥០ ០០០ ហិកតា ទៅ១លាន ហិកតា នារដូវវស្សាដោយបង្កើតជាបណ្តាញតំបន់ដីសើមដែលលាតសន្ធឹងរហូតដល់ ៣០ភាគរយនៃផ្ទៃដីប្រទេស និងមានតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចសង្គម និងវប្បធម៌របស់ប្រជាពលរដ្ឋកម្ពុជា ។ ទោះបីមានតួនាទីសំខាន់បែបនេះក៏ដោយ ប្រជាពលរដ្ឋកម្ពុជាប្រមាណ ៧លាននាក់ រស់នៅដោយពុំមានទឹកស្អាតសម្រាប់ បរិភោគឡើយ ។

តំបន់ឆ្នេរប្រទេសកម្ពុជា មានទីជម្រកធម្មជាតិច្រើនប្រភេទ រួមមាន ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ហើយដែនទឹកសមុទ្រ គឺជាជម្រកដែលមានត្រីសមុទ្រច្រើនជាង ៤៣៥ ប្រភេទ ព្រមទាំងថនិកសត្វនៅក្នុងទឹកដែលរងការគំរាមកំហែងជាសកលផងដែរ ដូចជា សត្វជ្រូកទឹក និងផ្សោត ។

ក្នុងចន្លោះទសវត្សរ៍ឆ្នាំ ១៩៦០ និងឆ្នាំ១៩៩២ វិសាលភាពគម្របព្រៃឈើក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាបានថយចុះពី ១៣.២ លានហិកតា (៧៣ភាគរយ មកត្រឹម ១១.២លានហិកតា (៦២ភាគរយ ។ គម្របព្រៃនៅតែមានវិសាលភាពធំធេងនៅឡើយដោយមានលក្ខណៈចម្រុះគ្នា ជាអាទិ៍ ព្រៃកោងកាង ព្រៃលិចទឹក ព្រៃឫស្សី ព្រៃស្រល់ ព្រៃល្បោះស្ងួត និងព្រៃល្បោះសើម ព្រៃបៃតងសើម ព្រៃភ្នំសើម និងព្រៃចុល្លព្រឹក្ស ។ ព្រៃឈើផ្តល់អនុផលជាច្រើនយ៉ាងដូចជា អុសដុត រុក្ខជាតិឱសថ សត្វព្រៃ និងសម្ភារៈសំណង់ ។ ឈើត្រូវបានប្រើប្រាស់ជាថាមពលចំអិនអាហារសម្រាប់ ៩២ភាគរយ នៃគ្រួសារនៅទូទាំងប្រទេស ។

ធនធានធម្មជាតិដ៏សម្បូរបែបនៃប្រទេសកម្ពុជា ទទួលរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសង្គ្រាមក្នុងស្រុក អស់រយៈពេល ២០ឆ្នាំ ព្រមទាំងការអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីនៅទសវត្សរ៍ឆ្នាំ ១៩៩០ ។ កត្តាសំខាន់ៗដែលមានឥទ្ធិពលចំពោះការបំផ្លិចបំផ្លាញធនធានមានជាអាទិ៍ កំណើនចំនួនប្រជាពលរដ្ឋ ភាពទន់ខ្សោយនៃការគ្រប់គ្រងធនធាន និងការប្រើប្រាស់ធនធានធម្មជាតិតាមបែបអនាធិបតេយ្យ ។ ប្រទេសកម្ពុជាមានប្រជាពលរដ្ឋ ១៣លាននាក់ (ហើយកើនឡើងយ៉ាងឆាប់រហ័ស ដែលក្នុងនោះ ប្រជា-ពលរដ្ឋ ៨៤ភាគរយ រស់នៅតាមជនបទ ហើយជាង ៨៥ភាគរយ នៃប្រជាពលរដ្ឋទាំងអស់រស់នៅតាមជនបទពឹងអាស្រ័យដោយផ្ទាល់លើធនធានធម្មជាតិ (ព្រៃឈើ និងជលផល ដែលកំពុងហិនហោចទាំងនេះសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត (McKenney និង Tola ២០០២ ។

ដើម្បីឆ្លើយតបនឹងបញ្ហានៃការថយចុះនូវធនធាន និងការពឹងអាស្រ័យលើធនធានទាំងអស់នេះ ពីសំណាក់ប្រជាពលរដ្ឋក្រីក្រនៅជនបទ កិច្ចប្រឹងប្រែងជាច្រើនត្រូវបានបង្កើតឡើងដើម្បីជួយរៀបចំសហគមន៍ និងអភិវឌ្ឍន៍សហគមន៍ ។ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវបានផ្តួចផ្តើមនាំបញ្ចូលមកក្នុងប្រទេសតាមរយៈអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលកំពុង

ធ្វើការជាមួយអ្នកភូមិលើបញ្ហាចិញ្ចឹមជីវិតរបស់សហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ។ ដោយមានការគាំទ្រពីម្ចាស់ជំនួយ និងដៃគូដែលជាអង្គការមិនមែនរដ្ឋាភិបាលនានា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយវិមជ្ឈការសម្រាប់ការគ្រប់គ្រង រួមបញ្ចូលទាំងការបង្កើនការគាំទ្រលើវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម (CBNRM) ផងដែរ ។

## តើ CBNRM នៅក្នុងប្រទេសកម្ពុជាគឺជាអ្វី ?

### វិធីសាស្ត្រសហគ្រប់គ្រង

ពាក្យ CBNRM ត្រូវបានសំដៅលើ "ទិដ្ឋភាពច្រើនបែបនៃវិធីសាស្ត្រសហគ្រប់គ្រង ដែលផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព"(Carson, Srey et al, ២០០២) ។ នៅប្រទេសកម្ពុជាមានយុទ្ធសាស្ត្រជាច្រើនទាក់ទងនឹង CBNRM រួមមាន សហគមន៍ព្រៃឈើ សហ-គ្រប់គ្រងសហគមន៍នេសាទ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម ។ ដោយសារស្ថានភាពប្រវត្តិសាស្ត្រ និងនយោបាយរបស់កម្ពុជា ភាគច្រើននៃគម្រោង CBNRM ហាក់បីដូចជាលំអៀងទៅខាងសហគ្រប់គ្រងដែលត្រួតត្រាដោយរដ្ឋាភិបាល ។ នៅប្រទេសកម្ពុជា មានឧទាហរណ៍ពីសកម្មភាព CBNRM មួយចំនួនតូចប៉ុណ្ណោះ ដែលនិយាយពីសហគ្រប់គ្រងធនធានធម្មជាតិដែលមាន "ទំនោរផ្អែកលើសហគមន៍" ។

គោលដៅនៃវិធីសាស្ត្រ CBNRM អាចចែកជាពីរផ្នែក គឺការពង្រឹងអំណាចសហគមន៍ និងការអភិរក្សប្រព័ន្ធអេកូឡូស៊ី ។ រហូតមកដល់បច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជា គោលដៅទាំងពីរនេះបានជាប់ទាក់ទងយ៉ាងសំខាន់ ជាមួយគោលបំណងអភិរក្សការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ និងការប្រើប្រាស់តាមគ្រួសារ ។ ទោះជាយ៉ាងណាក៏ដោយ មានកំណើននៃការទទួលស្គាល់ថា CBNRM អាចទទួលជោគជ័យប្រសិនបើវិធីសាស្ត្រនេះជួយកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅតាមជនបទ និងគោលដៅផ្សេងទៀតក្នុងការផ្តល់អំណាចសហគមន៍ ដើម្បីបង្កើនលទ្ធភាពផ្នែកសេដ្ឋកិច្ចសង្គម (សូមមើលដ្យាក្រាមខាងក្រោម ។

**គោលដៅពង្រឹងអំណាចសហគមន៍**

កាត់បន្ថយភាពក្រីក្រ

យុត្តិធម៌/សមធម៌សង្គម

លើកកំពស់ជីវភាពរស់នៅ

ចំណូលសេដ្ឋកិច្ចកម្រិតសមស្រប

សិទ្ធិលើធនធាន និងសុវត្ថិភាពកម្មសិទ្ធិដីធ្លី

ការគោរពចំណេះដឹងពីស្ថានប្រព័ន្ធនៅ

មូលដ្ឋាន រឺជាលក្ខណៈប្រពៃណី

ការរៀបចំបង្កើតសហគមន៍

និងបណ្តាញការងារមូលដ្ឋាន

**CBNRM**

**គោលដៅអភិរក្សប្រព័ន្ធអេកូឡូស៊ី**

ការអភិរក្សសេវាកម្មប្រព័ន្ធអេកូឡូស៊ី

វដ្តជលសាស្ត្រ

គុណភាពទឹក

ដី

ព្រៃឈើ

សត្វព្រៃ

សារព័ន្ធសត្វ និងសារព័ន្ធរុក្ខជាតិ

ភាពចម្រុះនៃប្រភេទ

ទីជម្រក

និរន្តរភាព

*យកតាមឯកសាររបស់អង្គការ Oxfam America : គោលដៅទាំងនេះផ្តោតលើការបង្កើនសមត្ថភាពនៅមូលដ្ឋាន ការឱ្យនិយមន័យអំពីការអភិវឌ្ឍសហគមន៍ក្នុងក្របខ័ណ្ឌទូលំទូលាយ ដោយរាប់បញ្ចូលមិនត្រឹមតែទិដ្ឋភាពសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទិដ្ឋភាពវប្បធម៌ នយោបាយ និងសង្គមផងដែរ ដោយសង្កត់ធ្ងន់លើនិរន្តរភាព ។*

នៅក្នុងរបាយការណ៍នេះ CBNRM ត្រូវបានប្រើប្រាស់ជាពាក្យគន្លឹះមួយ ដែលមានន័យរួមបញ្ចូលនូវការគ្រប់គ្រងធនធានតាមវិធីសាស្ត្រជាច្រើននៅមូលដ្ឋាន ជាអាទិ៍ ការរៀបចំសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ទេសចរណ៍ធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ និងទទួលស្គាល់វិធីសាស្ត្រជាច្រើនទៀតដែលបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវ និងការធ្វើផែនការសម្រាប់ CBNRM ជាអាទិ៍ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងការស្រាវជ្រាវដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ។

## សហគមន៍ព្រៃឈើ

នៅប្រទេសកម្ពុជា សហគមន៍ព្រៃឈើ (CF) មានន័យថាជាប្រព័ន្ធគ្រប់គ្រងបែបថ្មីមួយដែលធ្វើឱ្យការចូលរួមរបស់ ប្រជា-ពលរដ្ឋ និង សហគមន៍មូលដ្ឋានមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងធនធានព្រៃឈើដោយផ្តោតលើធនធានព្រៃឈើដែលពួកគេពឹងអាស្រ័យ ។ សហគមន៍ព្រៃឈើត្រូវបានចាត់ទុកថាជា "ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានដោយចាត់ទុកគោលបំណងរបស់ប្រជាពលរដ្ឋមូលដ្ឋានជាស្នូលនៃការគ្រប់គ្រងព្រៃឈើ និងធានាធ្វើឱ្យពួកគេទទួលផលប្រយោជន៍សមរម្យពីការគ្រប់គ្រងព្រៃឈើ "(Patrick Evans, FAOSiem Reap, 2003 ។ ការខកខានមិនបានឱ្យប្រជាពលរដ្ឋមូលដ្ឋានចូលរួមនៅក្នុងការគ្រប់គ្រងព្រៃឈើ ជាហេតុនាំឱ្យមានការបំផ្លាញព្រៃឈើ បរាជ័យនៃការគ្រប់គ្រងព្រៃឈើ និងភាពយឺតយ៉ាវក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងអភិបាលកិច្ច (Henderson, 2004 ។ (សូមអានជំពូកទី៦ ១២ និង ១៧ ។

## សហគមន៍នេសាទ

នៅប្រទេសកម្ពុជា សហគមន៍នេសាទសំដៅលើ "ប្រជាពលរដ្ឋមួយក្រុមដែលសហការគ្នាដោយស្ម័គ្រចិត្តដើម្បីគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព "។ លទ្ធផលរំពឹងទុកចម្បងនៃសហគ្រប់គ្រងជលផលនោះគឺ ពង្រឹងការធ្វើអោយមាន និរន្តរភាព ប្រសិទ្ធភាព សមភាព និងការមានឡើងវិញ (Berkes et al, 2001) ដែលអាចទទួលបានតាមរយៈ ការចាត់ចែងសម្របសម្រួល អព្យាក្រិត និងការជម្រុញអោយមានការពិភាក្សាគ្នារវាងអ្នកពាក់ព័ន្ធ (Gum, 2000) ។ សហគ្រប់គ្រងជលផលនៅប្រទេសកម្ពុជាមិនទាន់បានឈានដល់សក្តានុពលពេញលេញដើម្បីអាចប្រើប្រាស់ជាវិធានដែលមានប្រយោជន៍ក្នុង គោលបំណង លើកកម្ពស់អភិបាលកិច្ច និងធានាឱ្យមានការចាត់ចែងធនធានធម្មជាតិកាន់តែមានសមធម៌ និងនិរន្តរភាពដោយធ្វើឱ្យ អ្នកពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការធ្វើសេចក្តីសម្រេចនោះទេ ។ (សូមអានជំពូកទី ៥ និង ៧ ។

## ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី

ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) គឺជាដំណើរការរៀបចំផែនការដែលបានផ្តួចផ្តើមឡើងនៅថ្នាក់ភូមិ ក្នុងនោះអ្នកភូមិ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតរៀបចំផែនការប្រើប្រាស់ ការពារ និងបែងចែកដីធ្លី ព្រៃឈើ តំបន់កសិកម្ម និងដែនទឹកទាំងអស់រួមគ្នានៅក្នុងព្រំប្រទល់ភូមិរបស់ខ្លួន (ROCK,2004) ។ ក្នុងបរិបទនៃប្រទេសកម្ពុជា ដំណើរការនេះត្រូវបានជួយដោយអ្នកសម្របសម្រួលមក ពីក្រៅភូមិ ដែលមានលក្ខណៈអព្យាក្រិត ប៉ុន្តែភាគច្រើននៃអ្នកសម្របសម្រួលទាំងនោះគឺជាបុគ្គលិករបស់នាយកដ្ឋាននានារបស់រដ្ឋាភិបាល ។ យុទ្ធសាស្ត្រចម្បងរបស់ PLUP ផ្តោតលើសមត្ថភាព និងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ដីធ្លីនៅមូលដ្ឋាន។ ដំណើរការនេះត្រូវបានអនុវត្តឡើងតាមជំហានជាបន្តបន្ទាប់គ្នាហើយត្រូវផ្អែកលើការពិភាក្សាអំពីបញ្ហានានា និងធ្វើឱ្យមានតុល្យភាពរវាងផលប្រយោជន៍ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ (សូមអានជំពូកទី ៩ និង ១៣ ។

## ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

នៅប្រទេសកម្ពុជា ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិគឺជាដំណើរការមួយដែលរដ្ឋាភិបាលព្យាយាមបញ្ចូលប្រជាពលរដ្ឋមូលដ្ឋានទៅក្នុងកិច្ចការពារធនធានធម្មជាតិដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ។ នៅក្រោមកិច្ចគ្រប់គ្រងរបស់តំបន់ការពារធម្មជាតិនេះ រដ្ឋាភិបាលចែករំលែកការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានធម្មជាតិជាមួយសហគមន៍នៅមូលដ្ឋានដែលបានកំណត់ ហើយបន្ទាប់មកសហគមន៍ទាំងនោះនឹងទទួលបានសិទ្ធិក្នុងការការពារ និងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាព ។ ដោយទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់សហគមន៍មូលដ្ឋានក្នុងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានបានចេញសេចក្តីប្រកាសមួយស្តីពីការរៀបចំបង្កើតសហគមន៍ក្នុងតំបន់ការពារធម្មជាតិ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ ដែលចុះហត្ថលេខាដោយ ឯកឧត្តម បណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។ សេចក្តីប្រកាសនេះធ្វើឡើងក្នុងគោលបំណងណែនាំ និងសម្របសម្រួលមន្ទីរបរិស្ថានខេត្ត អង្គការមិនមែនរដ្ឋាភិបាល គម្រោង និងដៃគូដទៃទៀតដើម្បីឆ្ពោះទៅរកការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយសហគមន៍អោយមានប្រសិទ្ធិភាព ដែលស្របទៅតាម ប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ។ (សូមអានជំពូកទី ១០) ។

### សហគមន៍អេកូ-ទេសចរណ៍

អេកូ-ទេសចរណ៍សំដៅលើការធ្វើដំណើរប្រកបដោយភាពទទួលខុសត្រូវទៅក្នុងតំបន់ធម្មជាតិ ដែលមានលក្ខណៈអភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។ សហគមន៍ទេសចរណ៍ធម្មជាតិ (CBET) នៅប្រទេសកម្ពុជាមិនបានឈានដល់ដំណាក់កាលដែលប្រជាពលរដ្ឋមូលដ្ឋានមានការត្រួតត្រា និងមានការចូលរួមយ៉ាងសកម្ម នៅក្នុងគម្រោងទេសចរណ៍ធម្មជាតិ ដើម្បីធ្វើឱ្យមានចំណូលជាប្រយោជន៍សម្រាប់សហគមន៍នៅឡើយទេ ។ តែទោះបីជាយ៉ាងនេះក៏ដោយក្រុមមួយរបស់អង្គការជាច្រើនបានបង្កើតបណ្តាញមួយឡើងដោយធ្វើការរួមគ្នា ដើម្បីធ្វើឱ្យប្រសើរឡើង នូវការយល់ដឹងនិងការអនុវត្តCBET នៅក្នុងប្រទេសកម្ពុជា ។(សូមអានជំពូក ៨ ។

## ការរៀបចំច្បាប់ និងការផ្លាស់ប្តូរគោលនយោបាយ : ការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ CBNRM

ក្នុងទសវត្សន៍កន្លងមក មានគោលនយោបាយ ផែនការ កម្មវិធី និងយុទ្ធសាស្ត្ររដ្ឋាភិបាលសំខាន់ៗមួយចំនួន ត្រូវបានរៀបចំឡើង និងអនុវត្តទៅតាមកម្រិតសារៈសំខាន់នៃបរិធានទាំងនោះ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍។ ប្រការទាំងនេះមានជាអាទិ៍ គោលនយោបាយ និងកម្មវិធីវិមជ្ឈការ សេចក្តីថ្លែងការណ៍នយោបាយដីធ្លី ផែនការ បរិស្ថានជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ កំណែទម្រង់គោលនយោបាយ វិស័យជលផល គោលនយោបាយព្រៃឈើថ្នាក់ជាតិ និងយុទ្ធសាស្ត្រចតុកោណ ។ (ព័ត៌មានលម្អិតបន្ថែម សូមអានអត្ថបទក្នុងប្រអប់ខាងក្រោម និងជំពូកទី ៣ ។

### គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល

កម្មវិធីសិលារបស់រដ្ឋាភិបាល បានចាប់ផ្តើមនៅឆ្នាំ ១៩៩៦ ដែលជួយអភិវឌ្ឍសមត្ថភាពកសាងផែនការអភិវឌ្ឍន៍បែបវិមជ្ឈការ។ កម្មវិធីនេះមានបំណងឱ្យសេចក្តីសម្រេចភាគច្រើនធ្វើឡើងនៅថ្នាក់ឃុំ-សង្កាត់ ដែលគណៈ-កម្មការអភិវឌ្ឍន៍ឃុំ-សង្កាត់ (CDCs) សម្រេចលើសកម្ម-ភាពការងារនៅមូលដ្ឋាន និងបែងចែកថវិកា ។ ដោយមានកម្មវិធីគំរូនៅខេត្តរតនគិរី ឥឡូវក្រុមការងារគម្រោងសិលាថ្នាក់ជាតិបានចាប់ផ្តើមកម្មវិធីមួយដើម្បីជម្រុញអោយមានការបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងផែនការអភិវឌ្ឍន៍រៀបចំដោយក្រុមប្រឹក្សាឃុំ-សង្កាត់។ (សូមអានជំពូកទី ៤ និង ១៤ ។

### យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ - NPRS (២០០៣_២០០៥)

ត្រូវបានចេញផ្សាយនៅខែធ្នូ ឆ្នាំ២០០២ ដោយក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍសង្គម ។ យុទ្ធសាស្ត្រនេះគូសបញ្ជាក់ពីសកម្មភាពកាត់បន្ថយភាពក្រីក្រជាអាទិភាពមួយ ដើម្បីពង្រឹងស្ថាប័ន និងលើកកំពស់អភិបាលកិច្ច រួមទាំងកំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ (ដីធ្លី កសិកម្ម ព្រៃឈើ និងជលផល ។ ឱកាសរបស់ប្រជាពលរដ្ឋក្រីក្រចំពោះដីធ្លី និងធនធានក៏បានពិពណ៌នាដោយ NPRS ថាជាបញ្ហាចម្បងមួយដែលត្រូវដោះស្រាយផងដែរ ។

**យុទ្ធសាស្រ្ត និងផែនការសកម្មភាពជីវៈចម្រុះជាតិ (២០០០)**

ត្រូវបានរៀបចំដើម្បីផ្តល់ការណែនាំសម្រាប់ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីជីវៈចម្រុះ ដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅឆ្នាំ១៩៩៥ ។ គោលបំណងសំខាន់៣ រួមមាន : ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជីវសាស្ត្រ និងការបែងចែកដោយត្រឹមត្រូវ និងសមធម៌នូវផលប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់ធនធានសេនេទិច ។ គោលបំណងជាយុទ្ធសាស្ត្រ ១៤.១ លើកឡើងពីតម្រូវការរៀបចំបង្កើតកម្មវិធី CBNRM សម្រាប់វិស័យព្រៃឈើ ជលផល ការប្រើប្រាស់ដីធ្លី តំបន់ការពារធម្មជាតិ កិច្ចការពារប្រភេទសត្វ ការគ្រប់គ្រងសត្វព្រៃ និងកសិកម្ម ។

**សេចក្តីថ្លែងការណ៍ពីគោលនយោបាយដីធ្លី (២០០១)**
**និងយុទ្ធសាស្ត្រនៃក្របខ័ណ្ឌគោលនយោបាយដីធ្លី (២០០២)**

លើកឡើងពីគោលនយោបាយរដ្ឋាភិបាលស្តីពី ការគ្រប់គ្រងរដ្ឋបាលនិងការបែងចែកដីធ្លី ។ គោលនយោបាយនេះចែងថា "ប្រជាពលរដ្ឋដែលប្រើប្រាស់ដីធ្លី គឺជាអ្នកគ្រប់គ្រងដីធ្លី ប្រចាំថ្ងៃដោយការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការកសាងផែនការប្រើប្រាស់ដីធ្លីមានសារៈសំខាន់ណាស់ និងបន្តថា "ទស្សនទាននៃសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ.... បញ្ជាក់ថា ការកសាងផែនការប្រើប្រាស់ដីធ្លី សហគមន៍ និងការគ្រប់គ្រងដីធ្លី ត្រូវបានរំពឹងថានឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស" ។

(សូមអាន ជំពូក១៩

**កំណែទម្រង់គោលនយោបាយជលផល (២០០០)**

រួមបញ្ចូលការផ្តល់តំបន់ឡូតិ៍នេសាទទំហំជាង ៥៦ភាគរយ នៃដែននេសាទសរុបដែលស្ថិតនៅក្រោមការនេសាទពាណិជ្ជកម្មអោយទៅជាដែននេសាទរបស់សហគមន៍នេសាទ ។ នេះគឺជាវិធានការ របស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះ ភាពតានតឹងដែលកើនឡើងរវាង ម្ចាស់ឡូតិ៍នេសាទ និងសហគមន៍នេសាទ ក្រីក្រនៅជនបទ ។

(សូមអានជំពូកទី ៥ ។

**គោលនយោបាយព្រៃឈើថ្នាក់ជាតិ (២០០២)**

រួមបញ្ចូលគោលដៅថ្នាក់ជាតិ អំពីកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច និងអភិបាលកិច្ចល្អ ។ គោលនយោបាយនេះ ទទួលស្គាល់កិច្ចការពារស្របច្បាប់នូវ "សិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានព្រៃឈើ..." និងព្យាយាម "បង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋានលើការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើតាមរយៈការអភិរក្សសត្វព្រៃ និងព្រៃឈើតាមសហគមន៍" ។ (សូមអានជំពូកទី ១៧ ។

**ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម - SEDP (២០០១-២០០៥)**

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំ លើកទីពីរ (SEDPII - កក្កដា ឆ្នាំ ២០០២ រួមបញ្ចូលការជម្រុញឱ្យមានការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាពដែលជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ទាំងបួនរបស់ខ្លួន និងបង្កើនល្បឿននៃការលូតលាស់នៅក្នុងវិស័យសេដ្ឋកិច្ចជនបទ ដែលមានសក្តានុពលខ្ពស់បំផុតសម្រាប់កាត់បន្ថយភាពក្រីក្រ ។

**ផែនការបរិស្ថានជាតិ (១៩៩៨-២០០២)**

ការផ្តោតសំខាន់របស់ផែនការនេះ គឺទៅលើតំបន់អាទិភាពចំនួន៦ និងបានទទួលស្គាល់គោលការណ៍សំខាន់ ៤ : ទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងបរិស្ថាន សារៈសំខាន់របស់សហគមន៍នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ សេចក្តីត្រូវការឱ្យមានការពង្រឹងសមត្ថភាពតាមស្ថាប័ន និងសារៈសំខាន់នូវវិធីសាស្ត្រចម្រុះមួយសម្រាប់កសាងផែនការបរិស្ថាន (MOE, 1998 ។

### គោលដៅអភិវឌ្ឍន៍សហសវត្សន៍

គោលដៅដែលពាក់ព័ន្ធភាគច្រើនសម្រាប់ CBNRM រួមមានការលុបបំបាត់ចោលនូវភាពក្រីក្រ និងភាពអត់ឃ្លានបំផុត និងធានាឱ្យមាននិរន្តរភាពខាងបរិស្ថាន ។ចំណុច ៧.១ ចែងពីការថែរក្សាគម្របព្រៃឱ្យនៅត្រឹមអត្រា៦០ភាគរយនៃផ្ទៃដីសរុបទាំងអស់ក្នុងឆ្នាំ ២០០០ រហូតដល់ឆ្នាំ ២០១៥ ចំណែកឯចំណុច ៧.៧ អំពាវនាវឱ្យបង្កើនចំនួនដែននេសាទសហគមន៍ពី ២៦៤ នៅឆ្នាំ ២០០០ ទៅ ៥៨៩ នៅឆ្នាំ ២០១៥ ។

### យុទ្ធសាស្ត្រចតុកោណ (២០០៤-២០០៨)

បានបង្ហាញជូនដោយរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៤។ យុទ្ធសាស្ត្រនេះមានគោលបំណងជម្រុញកំណើនសេដ្ឋកិច្ច ភាពមានការងារធ្វើ សមភាព និងប្រសិទ្ធភាពតាមរយៈការអនុវត្ត SEDPII និង NPRS ។ នៅចំណុចស្នូលនៃយុទ្ធសាស្ត្រនេះ គឺអភិបាលកិច្ចល្អ ដោយផ្តោតលើផ្នែក៤ ជាអាទិ៍ ការប្រឆាំងអំពើពុករលួយ ច្បាប់ និងតុលាការ រដ្ឋបាលសាធារណៈ និងវិមជ្ឈការ ។ ប្រការសំខាន់នៃការអនុវត្ត CBNRM នោះគឺចតុកោណនៃការរីកចម្រើនជាយុទ្ធសាស្ត្រដោយផ្តោតលើ "ផលិតកម្មកសិកម្ម ភាពចម្រុះគ្នា និងភាពប្រកួតប្រជែង"។ ផ្នែកជាយុទ្ធសាស្ត្រនេះរួមបញ្ចូលទាំងការសង្កត់ធ្ងន់លើកំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងកំណែទម្រង់វិស័យព្រៃឈើ ។




ដ្យាក្រាមទី១ : យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុម័តឯកសារច្បាប់សំខាន់ៗមួយចំនួនរួមមាន ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ និងអនុក្រឹត្យសហគមន៍ព្រៃឈើ ។ (សូមអានតារាងខាងក្រោម និងជំពូកទី ៣ ។

| ឯកសារច្បាប់ | កាលបរិច្ឆេទអនុម័ត | ខ្លឹមសារពាក់ព័ន្ធសំខាន់ៗនឹង CBNRM |
|---|---|---|
| រដ្ឋធម្មនុញ្ញ | ២៤ កញ្ញា ១៩៩៣ | ច្បាប់កំពូលនៃប្រទេសកម្ពុជា ដែលកំណត់សិទ្ធិ រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ។ល។ លិខិតបទដ្ឋានផ្សេងៗ ទៀតទាំងអស់ត្រូវស្របតាមច្បាប់នេះ ។ |
| ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ | ១ វិច្ឆិកា ១៩៩៣ | កំណត់តំបន់ការពារ ២៣ កន្លែងដែលមានផ្ទៃដី ៣ ២៧៣ ២០០ហិកតា ដែលត្រូវជា ៣០ភាគរយ នៃផ្ទៃដីព្រៃសរុប ឬ ១៨ភាគរយនៃផ្ទៃប្រទេសទាំងមូល ។ ព្រះរាជក្រឹត្យនេះបង្ហាញពីការប្តេជ្ញាចិត្តចំពោះការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះរបស់ប្រទេសកម្ពុជា ។ |
| កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ | ២៤ ធ្នូ ១៩៩៦ | លើកឡើងនូវបញ្ញត្តិ និងទម្រង់ការសម្រាប់កសាងផែនការជាតិ និងតំបន់ដោយផ្អែកលើអាទិភាពបរិស្ថានដែលបានកំណត់ កិច្ចការពារធនធានធម្មជាតិ និងតាមរយៈការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។ |
| ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ | ១៩ មីនា ២០០១ | រដ្ឋាភិបាលពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការ ។ បានបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំដែលជារចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមបំផុត ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ទទួល ខុសត្រូវគ្រប់គ្រងធនធានធម្មជាតិ និងការពារបរិស្ថាន នៅក្នុងតំបន់នៃដែនសមត្ថកិច្ចរបស់ខ្លួន ។ |
| ច្បាប់ភូមិបាល | កញ្ញា ២០០១ | បែងចែកឱ្យខុសគ្នារវាងទ្រព្យសម្បត្តិឯកជន ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ប្រជាពលរដ្ឋកាន់កាប់ដីធ្លីមុនមានការអនុម័តច្បាប់នៅឆ្នាំ ២០០១ត្រូវបានផ្តល់នូវកម្មសិទ្ធិពេញលេញ។អនុញ្ញាតឱ្យជនជាតិដើមភាគតិចមានកម្មសិទ្ធិសមូហភាពអចលនទ្រព្យ |
| ច្បាប់ស្តីពីព្រៃឈើ | សីហា ២០០២ | បញ្ជាក់ពីភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើ ដាក់ក្របខ័ណ្ឌការងារសម្រាប់ចំណាត់ថ្នាក់ព្រៃឈើ អនុញ្ញាតឱ្យមានសហគមន៍ព្រៃឈើ ។ |
| អនុក្រឹត្យសហគមន៍ព្រៃឈើ | ធ្នូ ២០០៣ | ការបែងចែកដីព្រៃសម្រាប់ការគ្រប់គ្រងដោយសហគមន៍តាមកិច្ចសន្យាធ្វើឡើងរៀងរាល់ ១៥ឆ្នាំម្តង ។ |

*តារាង២ : ឯកសារច្បាប់បច្ចុប្បន្ន និងប្រការពាក់ព័ន្ធសម្រាប់ CBNRM នៅក្នុងប្រទេសកម្ពុជា ។*

ជាងនេះទៅទៀត ទស្សនទានវិមជ្ឈការនៅប្រទេសកម្ពុជាក៏មានចែងពីការផ្ទេរអំណាចពីថ្នាក់កណ្តាលមករដ្ឋាភិបាលមូលដ្ឋានដើម្បីធ្វើឱ្យរចនាសម្ព័ន្ធអភិបាលកិច្ចបានល្អប្រសើរថែមទៀត ។ គោលនយោបាយ និងឯកសារច្បាប់ទាំងអស់នេះ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដែលបានបង្ហាញនាពេលថ្មីៗនេះ សុទ្ធតែជួយបង្កើតក្របខ័ណ្ឌការងារសម្រាប់ការអនុវត្តវិធីសាស្ត្រ CBNRM ។

ឯកសារ ច្បាប់បច្ចុប្បន្នដែលពាក់ពន្ធ័នឹង CBNRM ព្រមទាំងភាពខ្វះចន្លោះនៅក្នុងក្របខ័ណ្ឌច្បាប់ មានសង្ខេបនៅក្នុងតារាងខាងក្រោម ។

| ឯកសារច្បាប់ | កាលបរិច្ឆេទអនុម័ត | ខ្លឹមសារសំខាន់ និងការពាក់ពន្ធ័សម្រាប់ CBNRM |
|---|---|---|
| ច្បាប់ជលផល | សេចក្តីព្រាងដាក់ជូន សភាឆ្នាំ ២០០៤ | ផ្តល់នូវក្របខ័ណ្ឌច្បាប់ សម្រាប់រចនាសម្ព័ន្ធថ្មីនៃការគ្រប់គ្រងវិស័យជលផល តាមរយៈលទ្ធផលនៃកំណែទម្រង់គោលនយោបាយវិស័យជលផល ។ |
| អនុក្រឹត្យសហគមន៍ នេសាទ | សេចក្តីព្រាងនៅឯគណៈ រដ្ឋមន្ត្រី ឆ្នាំ ២០០៤ | អនុក្រឹត្យនេះមានវិសាលភាព និងគោលដៅកំណត់អំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ |
| ច្បាប់ស្តីពីការគ្រប់គ្រង តំបន់ការពារធម្មជាតិ | សេចក្តីព្រាងនៅ ឯគណៈរដ្ឋមន្ត្រី | សេចក្តីព្រាងនេះ ផ្តល់ការណែនាំដើម្បីគ្រប់គ្រងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ នៃប្រទេសកម្ពុជា ។ |
| ច្បាប់គ្រប់គ្រងធនធានទឹក | សេចក្តីព្រាង ខែមីនា ឆ្នាំ ២០០២ | សេចក្តីព្រាងច្បាប់នេះ មានគោលបំណង "ជម្រុញឱ្យមានការគ្រប់គ្រងដោយប្រសិទ្ធិភាពនូវធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។ |
| គោលការណ៍ណែនាំ (ប្រកាស សម្រាប់សហគមន៍ព្រៃឈើ និង សហគមន៍តំបន់ការពារធម្មជាតិ | ស្ថិតនៅក្នុងដំណើការ ធ្វើសេចក្តីព្រាង | ប្រកាសនេះនឹងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត CBNRM និងសេចក្តីលំអិតសម្រាប់ការអនុម័តអនុក្រឹត្យសហគមន៍ព្រៃឈើ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀង បទបញ្ជាផ្ទៃក្នុងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈ ការតាមដាន និងការវាយតម្លៃ ។ |
| សិទ្ធិដីធ្លីជនជាតិដើមភាគតិច | ស្ថិតនៅក្នុងដំណើរការ ធ្វើសេចក្តីព្រាង | ឯកសារច្បាប់នេះនឹងជួយក្នុងការអនុវត្ត ផ្នែកមួយចំនួននៃច្បាប់ភូមិបាល ទាក់ទងនឹងការផ្តល់កម្មសិទ្ធិដីសមូហភាពសម្រាប់ជនជាតិដើមភាគតិច ។ |

*តារាង ៣ : ភាពខ្វះចន្លោះនៃក្របខ័ណ្ឌច្បាប់សម្រាប់ CBNRM នៅក្នុងប្រទេសកម្ពុជា ។*

## តួនាទី និងការទទួលខុសត្រូវតាមស្ថាប័ន

ការផ្លាស់ប្តូរគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នៅក្នុងប្រទេសកម្ពុជាបាននាំអោយមានការប្តូរតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារពាក់ព័ន្ធនានាក្នុងរដ្ឋាភិបាលជាអាទិ៍ រដ្ឋបាលព្រៃឈើ នាយកដ្ឋានគ្រប់គ្រងដែនដី ក្រសួងបរិស្ថាន នាយកដ្ឋានកសិកម្ម និង គណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត ។ ឧទាហរណ៍ បច្ចុប្បន្នក្រុមប្រឹក្សាឃុំ-សង្កាត់ មានការទទួលខុសត្រូវក្នុងការចូលរួមគ្រប់គ្រង ធនធានធម្មជាតិ និងការរៀបចំអភិវឌ្ឍន៍ឃុំរបស់ពួកគេផ្ទាល់ តាមរយៈការធ្វើឱ្យសហគមន៍មូលដ្ឋានបានចូលរួម ។

បញ្ហាមួយនៃបញ្ហាសំខាន់ជាច្រើននៅក្នុងប្រទេសកម្ពុជា គឺភាពពុំច្បាស់លាស់ ភាពត្រួតគ្នា និងភាពប្រកួតប្រជែងគ្នាក្នុងការទទួលខុសត្រូវលើការគ្រប់គ្រងធនធានធម្មជាតិ។ ដ្យាក្រាមខាងក្រោមសង្ខេបពីអាណត្តិ និងការទទួលខុសត្រូវរបស់ស្ថាប័នសំខាន់ៗ និងអង្គការដែលមានការពាក់ពន្ធ័ទៅនឹង CBNRM ។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)**

*ទទួលខុសត្រូវលើវិស័យជលផល និងព្រៃឈើ ជាអាទិ៍ ព្រៃបម្រុងទុក ព្រៃការពារ ព្រៃសម្បទាន ការរៀបចំបង្កើតសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ ។*

**ការិយាល័យសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ**

*ទទួលខុសត្រូវចំពោះការរៀបចំបង្កើតសហគមន៍ព្រៃឈើនៅក្នុងតំបន់ព្រៃ ។*

**ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នៃនាយកដ្ឋានជលផល**

*ទទួលខុសត្រូវចំពោះការរៀបចំបង្កើតសហគមន៍នេសាទនៅក្នុងតំបន់ដែននេសាទ ព្រៃលិចទឹក និងព្រៃកោងកាង ។*

**ក្រសួងបរិស្ថាន (MoE**

*ទទួលខុសត្រូវចំពោះតំបន់ការពារធម្មជាតិ ២៣ កន្លែង ដោយធ្វើការអភិរក្សធម្មជាតិ និងកិច្ចការពារបរិស្ថាន ។*

**ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ DNCP/ MoE**

*ទទួលខុសត្រូវរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិជាតិ ២៣ កន្លែង ដែលបានកំណត់ ។*

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC**

*ទទួលខុសត្រូវក្នុងការបង្កើតផែនការប្រើប្រាស់ ការបែងចែក និងការគ្រប់គ្រងដីធ្លី ។*

**ផ្នែកកសាងផែនការប្រើប្រាស់ដីធ្លី ដោយមានការចូលរួម , (MLMUPC)**

*លេខាធិការដ្ឋានសម្រាប់ក្រុមបណ្តុះបណ្តាល PLUP ។*

**ក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាជាតិគាំទ្រឃុំ**

*ទទួលបន្ទុកការងាររដ្ឋការ និងគ្រប់គ្រងក្រុមប្រឹក្សាឃុំ-សង្កាត់ ។*

**ក្រុមប្រឹក្សាឃុំ-សង្កាត់**

*ថ្នាក់រដ្ឋបាលទាបបំផុតកើតចេញពីការបោះឆ្នោតជ្រើសរើស មានអំណាចរៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ តួនាទីពិតប្រាកដទាក់ទងនឹងតំបន់ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានេះ មិនទាន់បានបញ្ជាក់ឱ្យច្បាស់លាស់នៅឡើយទេ ។*

**ក្រសួងធនធានទឹក និងឧតុនិយម**

*ទទួលខុសត្រូវគ្រប់គ្រងធនធានទឹក ជាអាទិ៍ ការផ្តល់សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ទឹក ដូចជា ក្រុមកសិករប្រើប្រាស់ទឹក ។*

**ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងក្រុមការងារគម្រោងសិលា**

*កម្មវិធីគាំទ្រលេខាធិការដ្ឋានរដ្ឋការ របស់រាជរដ្ឋាភិបាលកម្ពុជា ។*

*ដ្យាក្រាម : ស្ថាប័នរដ្ឋាភិបាល ដែលចូលរួមក្នុង CBNRM នៅកម្ពុជា : តួនាទី និងការទទួលខុសត្រូវ*

## ក្រុមបណ្តាញការងារ និងអ្នកពាក់ព័ន្ធនានា

បណ្តាញ និងក្រុមការងារនានាត្រូវបានបង្កើតឡើង នៅក្នុងការខិតខំបង្កើតទំនាក់ទំនងឱ្យបានល្អប្រសើរក្នុងចំណោមអ្នកពាក់ព័ន្ធ និងធ្វើឱ្យប្រសើរឡើងនូវលំហូរនៃការចែករំលែកព័ត៌មាន ។

| ឈ្មោះរបស់បណ្តាញ និង ក្រុមការងារ | គោលបំណង និងតួនាទី | សមាជិកភាព |
|---|---|---|
| សហគមន៍ព្រៃឈើ និង សហគមន៍តំបន់ការពារធម្មជាតិ (សូមអានជំពូកទី ៦ និង ១០ ។ | បណ្តាញថ្នាក់ជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីកំណត់ អាទិភាពនៃការចែករំលែកព័ត៌មាន និងបទពិសោធន៍អំពីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា ដោយរៀបចំកិច្ចប្រជុំគ្នារៀងរាល់បីខែម្តងនៅតាមបណ្តាខេត្តផ្សេងៗ ។ | មានសមាជិកសកម្មជាង ២០០នាក់ មកពីសហគមន៍ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំចាត់ចែងដោយគណៈកម្មការនាយក (សហប្រធានពីរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន គាំទ្រ ពី អង្គការ Concern, CBNRM/WWF, Oxfam GB CFI និង GTZ ។ |
| បណ្តាញសហគមន៍ទេសចរណ៍ធម្មជាតិ (CCBEN) | បង្កើនការយល់ដឹងអំពីទស្សនទាន និងសក្តានុពលរបស់សហគមន៍អេកូ-ទេសចរណ៍ (Community Based Eco-tourism -CBET) | ផ្តួចផ្តើមបង្កើតឡើងដោយក្រុមមួយដែលមានអង្គការមិនមែនរដ្ឋាភិបាលចំនួន១៥ ដោយសហការជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗ ។ |
| វេទិកាអង្គការមិនមែនរដ្ឋាភិបាល NGO អំពីបរិស្ថាន | ការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល និងការធ្វើបណ្តាញ ដើម្បីពិភាក និងតស៊ូមតិលើបញ្ហាអភិវឌ្ឍន៍ និង បម្រើជាមជ្ឈមណ្ឌលធនធានមួយ | រួមបញ្ចូលអង្គការ NGOs ក្នុងស្រុក និងអន្តរជាតិច្រើនជាង ១០០ អង្គការ ។ |
| សម្ព័ន្ធភាពអភិរក្សការងារជលផល (ជំពូកទី ៥ និង ៧ | ប្រមូល និងចងក្រងព័ត៌មានដើម្បីធ្វើការតស៊ូមតិ ក្នុងនាមសហគមន៍មូលដ្ឋានដោយធ្វើការទាក់ទងនឹងបញ្ហាជលផល | ក្រុមអង្គការ NGO និងសហគមន៍នៅជុំវិញបឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ ។ |
| ក្រុមការងារសហគមន៍ព្រៃឈើ | ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ (ឈប់ដំណើរការ តាំងពីឆ្នាំ២០០៣ ដើម្បីផ្តល់ជាវេទិកាមួយសម្រាប់ឱ្យអង្គការ និងស្ថាប័ននានាធ្វើការងាររួមគ្នាលើបញ្ហាសហគមន៍ព្រៃឈើ និងដើម្បីសម្របសម្រួលឱ្យមានការពង្រឹងស្ថាប័ន ។ | រួមបញ្ចូលសមាជិកមកពីរដ្ឋបាលព្រៃឈើ នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ (DNCP) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) និង អង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលរួមយ៉ាងសកម្មក្នុងការងារសហគមន៍ព្រៃឈើ ។ |
| ក្រុមផ្សព្វផ្សាយច្បាប់ ស្តីពីព្រៃឈើ (Foresty Law Extension Team - FLET) | មានបំណងផលិតសៀវភៅណែនាំអំពី ច្បាប់ព្រៃឈើ និងសម្ភារៈផ្សេងៗដើម្បីបង្កើនការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងព្រៃឈើ ។ | ដឹកនាំដោយរដ្ឋបាលព្រៃឈើ និងគាំទ្រដោយអង្គការ GTZ, Concern worldwide, CBNRM/WWF, JICA, Oxfam GB,CFI/CFAC ។ |
| ក្រុមការងារអ្នកសម្របសម្រួលការងារជលផល (សូមអានជំពូកទី៥ និង៧) | គាំទ្រ និងសម្របសម្រួលការរៀបចំបង្កើតឯកសារច្បាប់ជលផល និងផ្តល់វគ្គបណ្តុះបណ្តាលទាក់ទងនឹងការរៀបចំបង្កើតសហគមន៍នេសាទ ។ | អង្គការ Oxfam America, OGB, CBNRM LI, CFDO/DoF, CEPA, Star Cambodia, NGO Forum និងអង្គការផ្សេងៗទៀត ។ |
| ក្រុមបណ្តុះបណ្តាលការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) (សូមអានជំពូកទី៩ | សម្របសម្រួលវគ្គបណ្តុះបណ្តាល PLUP ដើម្បីបង្កើនសមត្ថភាព ក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងអង្គការ NGOs ដើម្បីផ្តួចផ្តើមបង្កើត និងគាំទ្រដំណើរការបង្កើតផែនការមូលដ្ឋាននៅថ្នាក់ភូមិ និង ឃុំដោយធ្វើការជាក្រុមដែលមានអ្នកសម្របសម្រួលពី ៣-៥នាក់ ។ | ក្រុមដែលមានជំនាញចម្រុះ ដែលមានទីភ្នាក់ងារនានានៃរដ្ឋាភិបាល រួមមាន MLMUPC (លេខាធិការដ្ឋាន រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន នាយកដ្ឋានជលផល និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ |
| បណ្តាញគ្រប់គ្រងធនធានធម្មជាតិថ្នាក់ខេត្ត (នៅតាមខេត្តនានា | ធ្វើឱ្យប្រសើរឡើងនូវលំហូរព័ត៌មាន និងគំនិត ហើយជាវេទិកាមួយសម្រាប់ពិភាក្សា និងធ្វើសកម្មភាពលើបញ្ហាគ្រប់គ្រងធនធានធម្មជាតិ ដែលទាក់ទងនឹងសហគមន៍មូលដ្ឋាន ។ | អង្គការសហគមន៍មូលដ្ឋាននានា អង្គការ NGOs, PLG/Seila ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ទីរនានានៅមូលដ្ឋាន (អាស្រ័យទៅតាមខេត្តនីមួយៗ ។ |
| ក្រុមការងារម្ចាស់ជំនួយអំពីការគ្រប់គ្រងធនធានធម្មជាតិ | សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ម្ចាស់ជំនួយជាមួយរាជ រដ្ឋាភិបាលកម្ពុជា និងរួមបញ្ចូលនូវក្រុមការងារបច្ចេកទេស ស្តីពីបញ្ហាព្រៃឈើ ជលផល និងដីធ្លី ។ | ក្រុមម្ចាស់ជំនួយរួមមាន Danida, DFiD, FAO, Sida, JICA, USAID, GTZ, WB, ADB និង UNDP ។ |
| ក្រុមការងារវេទិកា វិមជ្ឈការ | វេទិកានេះរៀបចំឡើងពីរដងក្នុងមួយឆ្នាំ នៅទីក្រុងភ្នំពេញ ដោយ ផ្តល់ឱកាសដើម្បីចែករំលែកព័ត៌មានលើកឡើង និងស្វែងរកបញ្ហា វិមជ្ឈការ និងជម្រុញកិច្ចសហការ និងការសម្របសម្រួល ។ | មានអ្នកពាក់ព័ន្ធជាច្រើន រួមមានអង្គការ NGOs ជាតិ និងអន្តរជាតិ ម្ចាស់ជំនួយ ផ្នែកឯកជន រដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ-សង្កាត់ ។ |

វេទិកានេះ ក៏ផ្តល់ផងដែរនូវសក្តានុពលដ៏ប្រសើរសម្រាប់ដោះស្រាយបញ្ហា រៀបចំវិធានការណ៍ និងពង្រីកការងារទៅកាន់តំបន់ផ្សេងៗទៀតដោយផ្អែកលើបទពិសោធន៍ល្អៗ (បង្កើតឱ្យច្រើនឡើង និងពង្រីកឱ្យធំ ។ បណ្តាញ និងក្រុមការងារទាំងនេះនៅតែប្រតិបត្តិការដាច់ដោយឡែកពីគ្នា ដោយពុំមានយន្តការសម្របសម្រួលរវាងផ្នែកខុសៗគ្នា និងរវាងថ្នាក់ជាតិទៅថ្នាក់ខេត្តឡើយ ។ ដ្យាក្រាមខាងក្រោមបង្ហាញពីទំនាក់ទំនងមួយចំនួនដែលអាចកើតមានឡើង ។ សហព័ន្ធនៃអង្គការ សហគមន៍មិនទាន់បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ប៉ុន្តែអាចជាជំហានបន្ទាប់នៃការអភិវឌ្ឍ បណ្តាញការងារ នៅក្នុង CBNRM ។



## ឱកាស និងការប្រឈម : ការរៀនសូត្រពីបទពិសោធន៍ និងការបង្កើតយុទ្ធសាស្ត្រដើម្បីធ្វើឱ្យ CBNRM មានដំណើរការទៅមុខ

មានមេរៀនជាច្រើនដែលអាចប្រើប្រាស់សម្រាប់ដកស្រង់បទពិសោធន៍ CBNRM តាមមូលដ្ឋាននៅប្រទេសកម្ពុជា។ ឧទាហរណ៍ ករណីសិក្សា និងគំនិតផ្តួចផ្តើមធ្វើការស្រាវជ្រាវចុះផ្ទាល់ជាច្រើន បានលើកឡើងឱ្យឃើញនូវឱកាស និងការប្រឈមចម្បង៧សម្រាប់ CBNRM ដូចតទៅនេះ :

- ភាពខ្វះចន្លោះនៃគោលនយោបាយ និង ក្របខ័ណ្ឌច្បាប់
- អភិបាលកិច្ចល្អ និងវិមជ្ឈការ
- យន្តការដោះស្រាយទំនាស់
- បញ្ហាយេនឌ័រ និង សមធម៌
- ការគ្រប់គ្រងលំហូរព័ត៌មាន (កិច្ចសហការ ការធ្វើបណ្តាញការងារ និងការចែករំលែកចំណេះដឹង
- ការតាមដាន និង ការវាយតម្លៃផលប៉ះពាល់
- ការបង្កើនសមត្ថភាព ការបណ្តុះបណ្តាល ការរៀនសូត្របន្ត
- សិទ្ធិលើដីធ្លី និង ធនធាន
- ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

វិធីសាស្ត្រចម្រុះរបស់ CBNRM នៅប្រទេសកម្ពុជាត្រូវបានអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មានវិធីសាស្ត្រដែលមានការចូលរួមពីសហគមន៍មួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ ។ នៅត្រឹមឆ្នាំ ២00២ យោងតាមរបាយការណ៍ស្រាវជ្រាវដែលបានផ្តល់ឱ្យ ដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាមានតំបន់សហគមន៍ព្រៃឈើជាង ២៣៧ កន្លែង និងសហគមន៍នេសាទចំនួន ១៦២ កន្លែង (សូមអាន តារាងខាងក្រោម ។

| **ប្រភេទសហគមន៍ ដែលបានរៀបចំ** | **ចំនួនសហគមន៍ ដែលបានរៀបចំ** | **ចំនួនភូមិ** | **ចំនួនគ្រួសារ** | **ទំហំតំបន់សហគមន៍ គ្រប់គ្រង ( ហិកតា** | **ប្រភពពត៌មាន** |
|---|---|---|---|---|---|
| សហគម៍ព្រៃឈើ | ២៣៧ | ៤១៦ | ៤១១ ៤៤០ នាក់ | ៧១ ៧២៤ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI, 2002) |
| សហគមន៍នេសាទ | ១៦២ | ៣៥១ | ៣០២ ៧០៥ នាក់ | ២២៧ ៧៨៥ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI, 2002) |
| | ៣៦៥ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | ការិយាល័យអភិវឌ្ឍន៏សហគមន៏នេសាទ (CFDO, 2004) |
| សហគមន៏តំបន់ការពារ | ៦៩ សហគមន៏តំបន់ការពារធម្មជាតិ | ១៦៧ | ១៨ ១២១ គ្រួសារ | ៥៦ ៨១៧ | ការិយាល័យអភិវឌ្ឍន៏សហគមន៏តំបន់ការពារ DNCP/MoE, ២០០៤ |
| ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី | ២០ ឃុំ ( រតនគីរី | ៩៦ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | Ashish John, PLG: 2004 |

*តារាង ៤ : ទិន្នន័យតំបន់ដែលគ្រប់គ្រងដោយសហគមន៏នៅក្នុងប្រទេសកម្ពុជា*

ទោះជាបានទទួលជោគជ័យក៏ដោយ ការអនុវត្ត CBNRM បានធ្វើឡើងតែនៅក្នុងតំបន់មួយចំនួនតែប៉ុណ្ណោះក្នុងផ្ទៃប្រទេស ចំណែកឯចំនួនប្រជាពលរដ្ឋដែលចូលរួមនៅមានកម្រិតទាប និងមានទៅតាមតំបន់មួយចំនួនតែប៉ុណ្ណោះ ។ ឧទាហរណ៏សហគមន៏ព្រៃឈើភាគច្រើនមាននៅតាមតំបន់ព្រៃរេចរឹល ហើយមិនសូវមាននៅតំបន់ដែលសម្បូរព្រៃឡើយ ។ មានការកើនឡើងនូវការគាំទ្ររបស់រដ្ឋាភិបាល សម្រាប់ទស្សនទាន និងវិធីសាស្ត្រ CBNRM ដូចដែលបានចង្អុលបង្ហាញឱ្យឃើញតាមរយៈគោលនយោបាយ និងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ ។ ទោះបីជាយ៉ាងនេះក៏ដោយ រដ្ឋាភិបាលនៅតែមានភាពស្ទាក់ស្ទើរក្នុងការផ្តល់ផលប្រយោជន៏និងអំណាចត្រួតត្រាពិតប្រាកដលើការគ្រប់គ្រងឱ្យដល់សហគមន៏មូលដ្ឋាន ។

គម្រោងព្រៃឈើកម្ពុជា-អាឡឺម៉ង់ ( នាយកដ្ឋានរុក្ខា-ប្រមាញ់ និងអង្គការ GTZ, 2002 បានធ្វើការសិក្សាវាយតម្លៃមួយអំពីគម្រោងបង្កើតសហគមន៏ព្រៃឈើទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា ដោយប្រើព័ត៌មានដែលបានប្រមូលដោយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI). គម្រោង CBNRM LI និងទិន្នន័យតាមមូលដ្ឋាន ។ ការសិក្សានេះបានរកឃើញថា គិតត្រឹមឆ្នាំ២០០២ មានផ្ទៃដីប្រមាណ ៨៣ ០០០ហិកតា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៏ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ( រួមទាំងព្រៃកោងកាង និងមាន ៤០៤ភូមិ បានចូលរួម ។ ទោះបីជាមានការកើនឡើងយ៉ាងឆាប់រហ័សនូវតំបន់សហគមន៏ព្រៃឈើនៅទូទាំងព្រះរាជាណាចក្រកម្ពុជាក៏ដោយ ផ្ទៃដីសរុបដែលស្ថិតនៅក្រោមការគ្រប់គ្រងសហគមន៏ព្រៃឈើមានត្រឹម ០,៧ភាគរយប៉ុណ្ណោះ នៃផ្ទៃដីព្រៃឈើសរុបក្នុងប្រទេសកម្ពុជា ចំណែកឯចំនួនភូមិដែលចូលរួមសរុបមានតែ ៣,៦ភាគរយ (៤១៥ ០០០នាក់ នៃចំនួនភូមិសរុបក្នុងប្រទេសកម្ពុជា ដែលទទួលផលពីសកម្មភាពការងារសហគមន៏ព្រៃឈើ ។

សហគមន៍ព្រៃឈើនៅមានទំហំតូចនៅឡើយបើប្រៀបធៀបទៅនឹងព្រៃសំរាប់ធ្វើអាជីវកម្ម/សម្បទាន ឬព្រៃការពារ តែបានផ្តល់សក្តានុពលជាច្រើនសម្រាប់សហគមន៍ព្រៃឈើ ជាពិសេសតាមរយៈការអនុម័តអនុក្រឹត្យសហគមន៍ ព្រៃឈើនាពេលថ្មីៗនេះ។ សហគមន៍ព្រៃឈើបានទទួលការយកចិត្តទុកដាក់ថា ជាជម្រើសប្រកបដោយសក្តានុពលមួយក្រៅពីការគ្រប់គ្រងព្រៃសម្បទាន ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅជនបទ ទន្ទឹមនឹងការទប់ស្កាត់បញ្ហាបរិស្ថាន ( CGFP, នាយកដ្ឋានរុក្ខា-ប្រមាញ់ និងអង្គការ GTZ, 2002 ។ របាយការណ៍នៃការសិក្សាវាយតម្លៃនេះបានបញ្ចប់ ដោយសន្និដ្ឋានថា ដីព្រៃរបស់ព្រះរាជាណាចក្រកម្ពុជារហូតដល់ ៨,៤ លានហិកតា អាចមានសក្តានុពលសមរម្យសម្រាប់បង្កើតសហគមន៍ព្រៃឈើ ( CGFP, នាយកដ្ឋានរុក្ខា-ប្រមាញ់ និងអង្គការ GTZ.២០០២ ។

ការបង្កើតសហគមន៍នេសាទក៏បានផ្តល់ឱកាស និងការប្រឈមមុខមួយចំនួនផងដែរ ។ នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត កំណែទម្រង់គោលនយោបាយជលផល ហើយប្រគល់តំបន់ឡូតិ៍នេសាទជាង ៥៦ភាគរយ ទៅឱ្យសហគមន៍គ្រប់គ្រង ជាការឆ្លើយតបនឹងភាពតានតឹងដែលកើនឡើងរវាងម្ចាស់ឡូតិ៍នេសាទ និងសហគមន៍នេសាទក្រីក្រនៅមូលដ្ឋាន។ លទ្ធផលដែលទទួលបាន មានទាំងវិជ្ជមាន និងអវិជ្ជមាន។ អ្វីដែលមនុស្សជាច្រើនអះអាងថា ជាការជម្រុញឱ្យមានការគ្រប់គ្រងដោយសហគមន៍នោះ ការពិតបានក្លាយជាបញ្ហានៃការបំផ្លិចបំផ្លាញធនធានដោយបើកចំហទៅវិញ (សូមអានជំពូក៥ និង១១ ។ ជាលទ្ធផល គោលនយោបាយនេះត្រូវបានអនុវត្តឆាប់រហ័សពេកដែលធ្វើឱ្យនាយកដ្ឋានជលផល និងអ្នកពាក់ព័ន្ធផ្សេងៗទៀតបានជួបប្រទះបញ្ហាលំបាកជាច្រើនក្នុងការដើរឱ្យទាន់ការផ្លាស់ប្តូរទាំងនេះ ។ កំណែទម្រង់បែបនេះបានបង្កើតឱ្យមានភាពខ្វះចន្លោះលើការគ្រប់គ្រងដែលទាមទារឱ្យមានការបំពេញបន្ថែម ។

ផ្នែកមួយនៃកំណែទម្រង់គោលនយោបាយវិស័យជលផល គឺជាសេចក្តីព្រាងច្បាប់ដែលធ្វើឡើងដោយនាយកដ្ឋានជលផល និងដោយមានការចូលរួមវិភាគទានពីអង្គការ Oxfam GB, WWF / CBNRMLI, Oxfam America និងអង្គការផ្សេងៗទៀត នាយកដ្ឋានជលផលនៅក្នុងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ បានកសាងសេចក្តីព្រាងច្បាប់ជលផលថ្មី។ ទោះជាយ៉ាងនេះក៏ដោយមានបញ្ហា និងឧបសគ្គជាច្រើនទាក់ទងនឹងការអនុវត្តន៍កំណែទម្រង់នេះ។ កំណែទម្រង់គោលនយោបាយមិនបានធានាអំពីការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងដោយគ្មានការកែលំអខាងផ្នែកតម្លាភាព សេរីភាពនៃពត៌មាន និងការអនុវត្ត ប្រកបដោយប្រសិទ្ធភាពតាមរយៈការផ្តល់ប្រាក់បៀវត្សរ៍សមរម្យដល់មន្ត្រីរាជការ និងសេវាកម្មបណ្តុះបណ្តាលដ៏ល្អនោះទេ (Somony Butthoeun and Mom ២០០៣ ។ អនុក្រឹត្យអំពីសហគមន៍នេសាទ ត្រូវបានអនុម័តនៅឯកិច្ចប្រជុំបច្ចេកទេសអន្តរក្រសួងក្នុងទីស្តីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃ ទី៣ ខែមីនា ឆ្នាំ២០០៤។

ក្នុងករណីកំណែទម្រង់វិស័យព្រៃឈើ ច្បាប់ស្តីពីព្រៃឈើចាស់ត្រូវបានទទួលស្គាល់ថា មិនមានលក្ខណៈគ្រប់គ្រាន់ និងមិនច្បាស់លាស់ ហើយច្បាប់ព្រៃឈើថ្មីត្រូវបានអនុម័តនៅ ខែសីហា ឆ្នាំ២០០២ ។ ទោះបីច្បាប់នេះមានចែងពីគោលការណ៍ឱ្យ

បង្កើតសហគមន៍ព្រៃឈើក៏ដោយ ច្បាប់ព្រៃឈើនេះក៏មិនបានរាប់បញ្ចូលបញ្ហាសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយផងដែរ ដូចជា ការបញ្ជាក់ឱ្យច្បាស់ពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់បែងចែកអោយច្បាស់រវាងតំបន់ព្រៃឈើ និងតំបន់មិនមែនព្រៃឈើ ។

អនុក្រឹត្យសហគមន៍ព្រៃឈើត្រូវបានអនុម័តជាចុងក្រោយនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៣ បន្ទាប់ពីបានពិនិត្យពី សេចក្ដីព្រាងជាច្រើនលើកច្រើនសារតាមរយៈការពិភាក្សា និងការពិគ្រោះយោបល់ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើនកម្មវិធី ។ សហគមន៍ព្រៃឈើជាតិ (NCFP) កំពុងត្រូវបានរៀបចំដើម្បីជួយណែនាំដល់ការអនុវត្តអនុក្រឹត្យសហគមន៍ព្រៃឈើ ។ យន្តការច្បាប់ដូចជា ប្រកាស ស្តីពីការកសាងផែនការគ្រប់គ្រង សារពើភ័ណ្ឌ ការបែងចែកផល ការតាមដាន និងការវាយតម្លៃកំពុងត្រូវបានរៀបចំឡើងជាផ្នែកមួយរបស់ NCFP ព្រមទាំងកំណត់ជំហាន និងយន្តការច្បាប់ផ្សេងៗទៀត ដែលចាំបាច់ដើម្បីធ្វើឱ្យការងារសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជាឈានទៅមុខ ។ សហគមន៍កាន់តែសកម្មឡើងទាំងលើការស្នើសុំឱ្យធ្វើការគូសបញ្ជាក់ពីព្រៃសហគមន៍ និងក្នុងការប្តឹងតវ៉ាពីការរំលោភច្បាប់ពីសំណាក់ម្ចាស់ព្រៃសម្បទាន ។

ជាងនេះទៅទៀត ផ្នែកត្រួតពិនិត្យវិស័យព្រៃឈើដោយឯករាជ្យ (២០០៤ បានផ្តល់អនុសាសន៍ថា ត្រូវបញ្ឈប់ប្រព័ន្ធសម្បទាន និងបន្តហាមឃាត់ការកាប់ឈើ ។ ក្រុមឯករាជ្យនេះក៏បានលើកឡើងផងដែរថា ប្រការសំខាន់គឺត្រូវលៃយ៉ាងណាឱ្យសហគមន៍ព្រៃឈើមានលទ្ធភាពរកចំណូលដោយខ្លួនឯង និងរក្សានិរន្តរភាពដំណើរការដោយខ្លួនឯងបាន។ ដូចនេះត្រូវបង្កើតឱ្យមានការលើកទឹកចិត្ត និងការធានាសិទ្ធិទទួលផលសំរាប់សហគមន៍ព្រៃឈើ (Independent Forest Sector Review, 2004) ។

ប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ណាស់ក្នុងការអនុវត្តសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារ និងវិធីសាស្ត្រ CBNRM ផ្សេងៗទៀត។ បញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះគឺជាការកែលំអរចនាសម្ព័ន្ធ និងដំណើរការអភិបាលកិច្ចជួយដល់ប្រជាពលរដ្ឋក្រីក្រនៅជនបទដើម្បីធានាសន្តិសុខធនធាន និងសិទ្ធិលើកម្មសិទ្ធិ ព្រមទាំងជួយធ្វើឱ្យការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋានបានល្អប្រសើរឡើង តាមរយៈការធ្វើឱ្យមានតុល្យភាពរវាងការកាត់បន្ថយភាពក្រីក្រជាមួយការអភិរក្ស និងការព្រួយបារម្ភផ្សេងៗទៀត។

យុទ្ធសាស្ត្រចតុកោណ (២០០៤-០៨ ជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលនយោបាយអភិបាលកិច្ចល្អ វិមជ្ឈការ ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងដោយថ្នាក់មូលដ្ឋាន ។ ឧទាហរណ៍ យុទ្ធសាស្ត្រនេះចែងពីការពង្រីកតំបន់សហគមន៍នេសាទនៅក្នុងកំណែទម្រង់ជលផល ចំណែកការកែទម្រង់វិស័យព្រៃឈើត្រូវមានផ្នែកសំខាន់ៗចំនួនបីមានជាអាទិ៍ គោលនយោបាយគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ប្រព័ន្ធតំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលជាកម្មវិធីត្រឹមត្រូវមានតម្លាភាពហើយអាចគ្រប់គ្រងបាននៅថ្នាក់មូលដ្ឋាន ។

## ការផ្តល់សេវាផ្អែកលើអភិបាលកិច្ច និងវិមជ្ឈការ

ការកែលំអជាច្រើនបានធ្វើឡើង ទាក់ទងទៅនឹងក្របខ័ណ្ឌច្បាប់ និងរចនាសម្ព័ន្ធវិមជ្ឈការនៅប្រទេសកម្ពុជា ។ ប៉ុន្តែភាពមិនអាចចែកដាច់ពីគ្នានៃរចនាសម្ព័ន្ធអភិបាលកិច្ច និងភាពមិនច្បាស់លាស់ជុំវិញការអនុវត្តជាក់ស្តែង នូវវិធានការណ៍ថ្មីៗ

បង្កការលំបាកក្នុងការព្យាករណ៍អំពីផលប៉ះពាល់នៃកំណែទម្រង់ទៅលើសហគមន៍ក្រីក្រ ។ ប្រការចាំបាច់គឺត្រូវយល់ឱ្យច្បាស់ និងតាមដានដំណើរការនេះ ហើយសហគមន៍ដែលពឹងផ្អែកលើធនធាន ត្រូវផ្តល់ការគាំទ្រដើម្បីឆ្លើយតបចំពោះការផ្លាស់ប្តូរនេះ (សូមអានជំពូក ៤ និង ១៤ ។

ការកែលំអអភិបាលកិច្ច ទាមទារឱ្យមានការត្រួតពិនិត្យមធ្យោបាយ "ដើម្បីកែទម្រង់រចនាសម្ព័ន្ធ និងដំណើរការ" ដែលមានឥទ្ធិពលលើរបៀបដែលប្រជាពលរដ្ឋមូលដ្ឋានប្រើប្រាស់ធនធានព្រៃឈើ និងប្រភពនៃការចិញ្ចឹមជីវិតរបស់ពួកគាត់ដោយផ្តោតលើការកែប្រែទំនាក់ទំនងរវាងអ្នកប្រើប្រាស់ ជាជាងការផ្តោតលើអ្នកអនុវត្តន៍ផ្ទាល់ (Hobley និង shields, 2000; Henderson, 2003- ចំពោះព័ត៌មានលំអិត សូមអានក្របខ័ណ្ឌទស្សនទានខាងក្រោម និងជំពូក ១៧ ។




*រូបទី ២ : ក្របខ័ណ្ឌអភិបាលកិច្ច (Henderson, 2003; Hobley and Shields 2000)*

## ការធានាសិទ្ធិលើកម្មសិទ្ធិ និងសិទ្ធិ និងការទទួលខុសត្រូវលើធនធាន

ការផ្លាស់ប្តូរខាងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នាពេលថ្មីៗនេះ ជាជំហានសំខាន់មួយឆ្ពោះទៅរកការទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋនៅជនបទក្នុងការគ្រប់គ្រងធនធានធម្មជាតិ ប៉ុន្តែគេនៅពុំទាន់យល់ច្បាស់នៅឡើយទេថា តើគោលនយោបាយ ទាំងនេះនឹងត្រូវអនុវត្តបែបណានោះ នៅពុំទាន់បានបញ្ជាក់ច្បាស់នៅឡើយទេ។ ហេតុដូច្នេះ ចាំបាច់ត្រូវបង្កើនការយល់ដឹងពីការ ប្រើប្រាស់ដីធ្លី និងប្រព័ន្ធកម្មសិទ្ធិធនធាន ។ សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយដីធ្លី (២០០១ ពន្យល់ថា "វិធីសាស្ត្រដែល ចង់បានសម្រាប់អនុវត្តការធ្វើផែនការប្រើប្រាស់ដីធ្លីតាមបែបវិមជ្ឈការត្រូវបានសំដៅទៅលើការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP)"។ ចាំបាច់ត្រូវធ្វើការសាកល្បងដើម្បីបង្ហាញឱ្យឃើញថា វិធីសាស្ត្រនេះគឺជាឧបករណ៍មានប្រសិទ្ធភាពសម្រាប់គ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព ។ អង្គការមិនមែនរដ្ឋាភិបាល និងគម្រោងទ្វេភាគីមួយចំនួនបានធ្វើការពិសោធន៍វិធីសាស្ត្រនេះ នៅតាមមូលដ្ឋានជាច្រើន ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្ត ចំពោះកម្មសិទ្ធិដីធ្លីតាមរយៈការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីសម្ហូហភាពសម្រាប់សហគមន៍ជនជាតិដើម (សូមអានជំពូក ១៤, ១៨ និង ១៩ ។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវដាក់បញ្ចូល PLUP ទៅក្នុងដំណើរការនេះដើម្បីធានាថាសិទ្ធិរបស់សហគមន៍ ត្រូវបានធានា (ក្រុមបណ្តុះបណ្តាល PLUP, ២០០៣ ។ កិច្ចប្រឹងប្រែងនឹងត្រូវធ្វើឡើងដើម្បីអោយមានការរៀបចំបង្កើត ការផ្សព្វផ្សាយ មធ្យោបាយបណ្តុះបណ្តាល និងយន្តការដើម្បីធានាថាសិទ្ធិ និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋានត្រូវបានគោរព និងដើម្បីបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់តាមរយៈការចែករម្លែកពតិមាន ។

## ឆ្ពោះទៅរកជីវភាពរស់នៅប្រកបដោយនិរន្តរភាព

ក្របខ័ណ្ឌ SL បង្ហាញពីសារៈសំខាន់របស់ CBNRM ដើម្បីធ្វើឱ្យជីវភាពរស់នៅបានប្រសើរឡើង ដោយគូសបញ្ជាក់ពីសារៈសំខាន់នៃធនធានមនុស្ស ធនធានរូបវន្ត ធនធានហិរញ្ញវត្ថុ ធនធានធម្មជាតិ (ឧទាហរណ៍ ព្រៃឈើ ដីកសិកម្ម ជលផល និងធនធានសង្គមដែលជាធាតុសំខាន់នៃយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន (សូមអានជំពូក ២០ ។ ក្របខ័ណ្ឌនេះសង្កត់ធ្ងន់លើរចនាសម្ព័ន្ធ និងដំណើរការដែលសម្រុះសម្រួលលទ្ធភាពរបស់ប្រជាពលរដ្ឋក្រីក្រក្នុងការប្រើប្រាស់ធនធានទាំងនេះ (Kinakin, 2003 ។ វិធីសាស្ត្រ CBNRM នៅប្រទេសកម្ពុជា គួរតែព្យាយាមស្វែងរកគោលការណ៍ស្នូលរបស់វិធីសាស្ត្រនៃការចិញ្ចឹមជីវិតផងដែរ មានជាអាទិ៍ : ការដាក់មនុស្សជាកត្តាចម្បង ទូលំទូលាយ បង្កើតចំណុចខ្លាំង ប្រកបដោយថាមភាព រួមទាំងចំណងទាក់ទងរវាង កម្រិតម៉ាក្រូ-មីក្រូ និង និរន្តរភាព (បរិស្ថាន សេដ្ឋកិច្ច សង្គម និងស្ថាប័ន ។

ប្រជាពលរដ្ឋកម្ពុជាភាគច្រើនរស់នៅតំបន់ជនបទ ពឹងអាស្រ័យទៅលើធនធានធម្មជាតិ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពរស់នៅដែលភាគច្រើនរស់នៅដោយសារការដាំដំណាំ និងផលិតផលត្រី និងធនធានដទៃទៀតក្នុងទឹក ព្រមទាំងផលិតផលព្រៃឈើជាច្រើនបែប ។ ធនធានធម្មជាតិរបស់ប្រទេសកម្ពុជាផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខស្បៀង ប្រាក់ចំណូល និងការងារដល់ប្រជាពលរដ្ឋនៅតាមជនបទជាង ៨៥% (McKenney និង Prom Tola, 2002 ។ នៅពេលធនធានកាន់តែខ្សត់ទៅសហគមន៍មូលដ្ឋានត្រូវធ្វើការរួមគ្នា ដើម្បីធានាអោយបានថាធនធានធម្មជាតិត្រូវបានប្រើប្រាស់ប្រកបដោយនិរន្តរភាព ។ ឱកាសសម្រាប់វិធីសាស្ត្រ CBNRM គឺការបន្សាំចំពោះរាល់ការលំបាកដែលជួបប្រទះនាបច្ចុប្បន្ន និងត្រូវដើរតួយ៉ាងសំខាន់ក្នុងការ ចាត់ចែងស្ថានភាពសុខុមាលភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ចរបសប្រជាពលរដ្ឋកម្ពុជាទៅថ្ងៃអនាគត ។

## REFERENCES


Cambodia National Environmental Plan. 1998

Community Fisheries Development Office, Department of Fisheries,. 2004. *Policy Reform Impact Assessment, Cambodia.* Impact of the fisheries policy reforms in Kampong Cham, Pusat and Takeo Province. 1st Round assessment report.

Council for Social Development. 2002. *National Poverty Reduction Strategy 2003-2005.* Kingdom of Cambodia

Fichtenau, J., C. B., Ly., N, Sothea., Dy., Sophy. 2002. *Assessment of ongoing Community Forestry Initiaives in Cambodia. Implications for the Development of a Forestry Extension Strategy.* Phnom Penh, Cambodia.

Gum, W. 2000. *Inland Aquatic Resource and Livelihoods in Cambodia: A Guide to the Literature, Legislation, Institutional Framework and Recommentdations.* Oxfam GB and NGO Forum on Cambodia.

Hou, K, and Carson, T. 2001. *Community Based Natural Resource Management (CBNRM) in Cambodia: Case Study and Networking Initiative.* Proposal for WWF, Oxfam America, and IDRC. (February 28, 2001).

Kinakin, T. 2004. *Learning the Livelihoods Way: Understanding Rural Livelihood Sustainability in Northeastem Cambodia.* Masters Degree major paper. Toronto: Faculty of Environmental Studies.

McKenney, B. and Tola, P. 2002. *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment.* Phnom Penh: Cambodia Development Resource Institute. Working Paper No. 23.

Ministry of Environment and National Biodiversity Steering Committee. 2002. *Cambodia's National Biodiversity Strategy and Action Plan: To Use, Protect and Manage Biodiversity for Sustainable Development in Cambodia.* Royal Government of Cambodia.

*NGO Sectoral and Issue papers on poverty reduction and development in Cambodia 2003. 2004*

Rock, F. 2004. Working paper 05: *Comparative Study on Practices and Lessons in Land Use Planning and Land Allocation.* Watershed management Component of the MRC-GTZ Cooperation Programme.

Royal Government of Cambodia. 2002. *National Poverty Reduction Strategy 2003-2005.* December 2002

Shields, D. et al. 2004. independent Forest Sector Review.

Sigaty, T. 2001. *Resource Rights and Responsibilities of Local Communities Regarding Natural Resource Management and Conservation.*

Thay, S. 2002. *Fisheries Policy Reforms and the current perceptions about community fisheries and Co-management of fisheries.*

Torell, M. A. Salamanca and B. Ratner. 2004. *Wetlands Management in Cambodia: Socio-economic, Ecological, and Policy Perspectives.* Sida and World Fish Center.

# ការអភិវឌ្ឍការគ្រប់គ្រងធនធានធម្មជាតិ
# ដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា







## ផ្នែក ខ

## ការរៀបចំច្បាប់ និងការផ្លាស់ប្តូរគោលនយោបាយ ៈ
## ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងធនធាន
## ធម្មជាតិដោយមានការចូលរួមពីសហគមន៍

# ផ្នែក ២

## ការរៀបចំច្បាប់ និងការផ្លាស់ប្តូរគោលនយោបាយ: ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍

ជំពូក ៣

សេចក្តីសង្ខេបនៃគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍

រៀបរៀងដោយ : លោក Roberf B. Oberndorf, J.D

ជំពូក ៤

កម្មវិធីវិមជ្ឈការសិលា និងការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

រៀបរៀងដោយ : លោក ព្រៀម សុវណ្ណា

ជំពូក ៥

កំណែទម្រង់គោលនយោបាយជលផល និងក្របខ័ណ្ឌច្បាប់សម្រាប់សហគមន៍នេសាទ

រៀបរៀងដោយ : លោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និង អ្នកស្រី សូ ស្រីមុំ

---

រូបថត : WWF-CBNRM 2002 និងក្រុម MOSAIC 2004

# ជំពូក ៣ សេចក្តីសង្ខេបនៃគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ទាក់ទងទៅនឹង ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍

រៀបរៀងដោយលោក Robert B. Oberndorf, J.D[១]

## សេចក្តីផ្តើម

គោលបំណងចម្បងនៃជំពូកនេះ គឺសំដៅផ្តល់ជូនអ្នកអាននូវសេចក្តីសង្ខេបពីគោលនយោបាយ និងឯកសារច្បាប់ដែលមានស្រាប់នាពេលបច្ចុប្បន្ន (ច្បាប់ អនុក្រឹត្យ និងប្រកាស ដែលមានទំនាក់ទំនងជាមួយការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ។ ដើម្បីជាជំនួយដល់អ្នកអាន យើងបានផ្តល់ជូននូវការពន្យល់ពីអ្វីជាគោលនយោបាយ (គោលនយោបាយធៀបនឹងច្បាប់ និងសេចក្តីសង្ខេបពីប្រព័ន្ធនីតិបញ្ញត្តិនៅប្រទេសកម្ពុជា ។ លើសពីនេះទៀត ជំពូកនេះនឹងធ្វើការកំណត់ភាពខ្វះចន្លោះ ដែលមាននៅក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិក្នុងប្រទេសកម្ពុជា ។

## ស្វែងយល់ពីគោលនយោបាយ

ភាពខុសគ្នារវាងគោលនយោបាយ និងច្បាប់តែងតែមានភាពច្របូកច្របល់ ។ ក្នុងករណីជាច្រើន អ្នកធ្វើអត្ថាធិប្បាយយោងទៅរកច្បាប់ថាជាគោលនយោបាយ ទោះបីជាបរិធានទាំងពីរនេះគួរតែជាឯកសារដាច់ដោយឡែក និងផ្សេងពីគ្នានៅក្នុងវិស័យអភិបាលកិច្ចក៏ដោយ ។ ឯកសារគោលនយោបាយតំណាងឱ្យទិសដៅមួយនៃសកម្មភាព ឬទស្សនៈមួយដែលរដ្ឋាភិបាលបានអនុម័ត ដោយសរសេរចងក្រងជាទម្រង់របាយការណ៍គំរូមួយ ចំណែកច្បាប់ដាក់ចេញនូវអណត្តិ សិទ្ធិ ការទទួលខុសត្រូវ និងការហាមឃាត់ជាក់លាក់លើកម្មវត្ថុមួយនៅក្នុងទម្រង់តឹងរឹងនៃជំពូក និងមាត្រា។ ឯកសារគោលនយោបាយបានចងក្រងនិងអនុម័តដោយស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាល ។ ច្បាប់អនុម័តដោយស្ថាប័ននីតិបញ្ញត្តិផង និងស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាលផង ដែលក្នុងនោះច្បាប់អនុម័តដោយស្ថាប័ននីតិបញ្ញត្តិ ចំណែកឯវិធានអនុវត្ត និងបទប្បញ្ញត្តិអនុម័ត អនុវត្ត និងពង្រឹងដោយស្ថាប័ននីតិប្រតិបត្តិ[៣] ។

ឯកសារច្បាប់ល្អគួរតែសរសេរចងក្រងឡើង យ៉ាងច្បាស់លាស់ដោយផ្តល់ឱ្យរដ្ឋាភិបាល និងភ្នាក់ងាររដ្ឋបាលរបស់រដ្ឋាភិបាលនោះ នូវទិសដៅច្បាស់លាស់ពីសកម្មភាពការងារដែលត្រូវប្រកាន់យក ។ ឯកសារគោលនយោបាយតែងតែអនុម័តដើម្បីផ្តល់ទិសដៅសម្រាប់ការធ្វើសេចក្តីព្រាងការអនុម័ត និងការអនុវត្តនូវលិខិតបទដ្ឋាននានា ។ ឯកសារគោលនយោបាយ ក៏អាចរៀបចំ

---

[១] លោក Robert បច្ចុប្បន្នជាទីប្រឹក្សាច្បាប់ និងគោលនយោបាយសម្រាប់គម្រោងសម្ព័ន្ធភាពសហគមន៍ព្រៃឈើសំរាប់កម្ពុជារបស់អង្គការ សហគមន៍ព្រៃឈើអន្តរជាតិ ។ គាត់ជាប់កិច្ចសន្យាជាអ្នកជំនាញបច្ចេកទេសច្បាប់សម្រាប់គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំនៅកម្ពុជាផងដែរ ។

[២] (ពុំមានកំណត់សម្គាល់នេះទេ ដកស្រង់ចេញពីរបាយការណ៍មួយរបស់អង្គការសហគមន៍ព្រៃឈើអន្តរជាតិ/គម្រោងសម្ព័ន្ធភាពសហគមន៍ព្រៃឈើ សម្រាប់កម្ពុជា២០០៤ ។

[៣] ចំពោះសេចក្តីពន្យល់លំអិតអំពីក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជា សូមអានផ្នែក ឃ នៃសៀវភៅនេះ ។

ឡើងដើម្បីជួយក្នុងការបកស្រាយពីលិខិតបទដ្ឋានដោយអង្គភាពទាំងនោះ ដែលទទួលខុសត្រូវចំពោះការអនុវត្ត និងការពង្រឹងច្បាប់ ។ ឯកសារច្បាប់ដែលបានចងក្រងឡើងដោយត្រឹមត្រូវអាចបំពេញបន្ថែម និងយោងទៅលើឯកសារច្បាប់នានា។ ក្នុងករណីដែលមិនមានចងក្រងគោលនយោបាយពីបញ្ហាអ្វីមួយទេនោះ ពេលនោះជាញឹកញាប់ ឯកសារច្បាប់ត្រូវបានយោងជាឯកសារគោលនយោបាយរបស់រដ្ឋាភិបាល ដែលការធ្វើបែបនេះចាត់ទុកថាជាទម្រង់នៃការអភិវឌ្ឍ គោលនយោបាយទន់ខ្សោយបំផុតមួយ ហើយក្នុងករណីនេះរដ្ឋាភិបាលគួររៀបចំ និងអនុម័តគោលនយោបាយឱ្យបានច្បាស់លាស់ ។

ដើម្បីឱ្យគោលនយោបាយរដ្ឋាភិបាលមានប្រសិទ្ធិភាពពិតប្រាកដនោះ ត្រូវមានចែងពីសេចក្តីថ្លែងការណ៍ច្បាស់លាស់អំពីសកម្មភាពការងារដែលត្រូវយកមកអនុវត្ត ដែលអាចវាស់វែង និងតាមដានប្រកបដោយប្រសិទ្ធិភាពនៅពេលវេលាខាងមុខ ។ ជាញឹកញាប់ ឯកសារគោលនយោបាយមានតែសេចក្តីថ្លែងការណ៍ទូលំទូលាយ ដោយក្រសោបយកទស្សនទានទូទៅមួយ និងមិនសម្តែងឱ្យឃើញនូវសកម្មភាពច្បាស់លាស់ឡើយ ។

## ឯកសារគោលនយោបាយ

ព័ត៌មានខាងក្រោមនេះ គឺជាសេចក្តីសង្ខេបស្តីពីឯកសារគោលនយោបាយដែលមានចំណុចមួយចំនួនទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅក្នុងប្រទេសកម្ពុជា[៤] ។

### ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំ ២០០១-២០០៥ លើកទី២ របស់រាជរដ្ឋាភិបាលកម្ពុជា

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំ ២០០១-២០០៥ លើកទី២ (SEDPII) របស់រាជរដ្ឋាភិបាលកម្ពុជា (RGC) គឺជាឯកសារគោលនយោបាយដែលដាក់ទិសដៅសម្រាប់រដ្ឋាភិបាល ឱ្យផ្តោតទៅលើបញ្ហាអភិវឌ្ឍន៍ជាច្រើនប្រភេទ ដោយមានការយកចិត្តទុកដាក់លើសកម្មភាពដែលត្រូវអនុវត្តន៍ ដើម្បីជម្រុញការរីកចម្រើនខាងសេដ្ឋកិច្ច និងការអភិវឌ្ឍផ្នែកឯកជន។ លើសពីនេះ គោលនយោបាយ (SEDPII) និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិដែលទើបតែអនុម័តនាពេលថ្មីៗនេះ (National Poverty Reduction Strategy II - NPRS) នឹងត្រូវដាក់បញ្ចូលគ្នានៅឆ្នាំ ២០០៦ នេះ ។

គោលដៅនៃគោលនយោបាយនេះ គឺធានាអោយបាននូវការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព និងពិភាក្សាពីកំណែទម្រង់វិស័យកសិកម្ម ព្រៃឈើ ជលផល និងការគ្រប់គ្រងដីធ្លី តែសេចក្តីថ្លែងការណ៍ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយ CBNRM នៅមានតិចតួចនៅឡើយ។ ឯកសារនេះ អំពាវនាវឱ្យមាន "ការប្រើប្រាស់ផលចំណេញខ្ពស់ពីធនធានព្រៃឈើសម្រាប់ជាផលប្រយោជន៍ដល់សហគមន៍មូលដ្ឋានតាមរយៈការគ្រប់គ្រងព្រៃឈើដោយសហគមន៍ "ការរៀបចំ និងការអនុវត្តក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តសម្រាប់ការគ្រប់គ្រងសហគមន៍នេសាទ" ការរៀបចំរចនាសម្ព័ន្ធដើម្បីផ្តល់ជំនាញដល់សហគមន៍

[៤] ឯកសារគោលនយោបាយហួសសុពលភាព ដូចជា ផែនការសកម្មភាពអភិបាលកិច្ច (២០០១-២០០៤) ឬផែនការបរិស្ថានជាតិ (១៩៩៨-២០០២) មិនរាប់បញ្ចូលក្នុងការវិភាគនោះទេ ។ គោលនយោបាយរដ្ឋាភិបាលទាំងនេះត្រូវការឱ្យផ្លាស់ប្តូរ ឬរួមបញ្ចូលគ្នាទៅក្នុងយន្តការគោលនយោបាយផ្សេងៗទៀត ជាអាទិ៍ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។

មូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិដែលជាមូលដ្ឋាននៃការទ្រទ្រង់ជីវភាពរស់នៅ ។ នេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍធនធានទាំងអស់នេះប្រកបដោយនិរន្តរភាព " ។

## ក្រុមខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលកម្ពុជា (២០០២

ឯកសារគោលនយោបាយនេះបានរៀបចំឡើងដោយផ្អែកលើសេចក្តីថ្លែងការណ៍ឆ្នាំ២០០១ ស្តីពីគោលនយោបាយ ដីធ្លី ហើយបានដាក់ចេញនូវគោលការណ៍ និងផែនការនានាដែលត្រូវអនុវត្តន៍ ដើម្បីបំពេញគោលដៅរបស់រដ្ឋាភិបាលពាក់ព័ន្ធ នឹងដីធ្លី និងផែនការជម្រុញឱ្យមានការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងបំណងសម្រេចគោលដៅទូលំទូលាយរបស់ជាតិ ។ ឯកសារនេះតំណាងឱ្យ ដំណើរការដែលកំពុងអនុវត្តដើម្បីកសាងគោលនយោបាយលំអិតអំពីដីធ្លីសម្រាប់ប្រទេសកម្ពុជា ។

មានការអនុម័តគោលការណ៍ល្អៗមួយចំនួនដែលទាក់ទងជាមួយ CBNRM ។ឯកសារច្បាប់នេះចែងថា " *ប្រជាពលរដ្ឋដែលប្រើប្រាស់ដីធ្លី គឺជាអ្នកគ្រប់គ្រងដីធ្លីប្រចាំថ្ងៃ ហើយការចូលរួមរបស់ពួកគាត់នៅក្នុង ការកសាងផែនការប្រើប្រាស់ដីធ្លីមានសារៈសំខាន់ខ្លាំងណាស់* "។ គោលនយោបាយនេះចែងបន្តទៀតថា "ទស្សនទានស្តីពីសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ ... មានន័យថា ការកសាងផែនការប្រើប្រាស់ដីធ្លីសហគមន៍ និងការគ្រប់គ្រងដីធ្លីនឹងត្រូវអនុវត្តនៅទូទាំងប្រទេស " ។

គោលនយោបាយនេះចែងថា "*វិធីសាស្ត្រដែលជាជម្រើសសម្រាប់អនុវត្តការកសាងផែនការប្រើប្រាស់ដីធ្លីបែបវិមជ្ឈការ គឺការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី* (*PLUP* " ។ នេះជាវិធីសាស្ត្រមួយ ក្នុងការរៀបចំបង្កើតឱ្យមានការព្រមព្រៀងនៅមូលដ្ឋានលើការប្រើប្រាស់ដីធ្លីនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគតឱ្យស្របគ្នាជាមួយនឹងគោលដៅអភិវឌ្ឍន៍ និងធនធានធម្មជាតិដែលមាន ហើយផ្អែកលើគោលការណ៍នៃម្ចាស់កម្មសិទ្ធិជាមូលដ្ឋាន និងតាមដានលើដំណើរការរៀបចំផែនការនៅមូលដ្ឋាន ។ ពាក់ព័ន្ធនឹងសិទ្ធិដីធ្លីជនជាតិដើមភាគតិច ឯកសារនេះចែងថា គោលការណ៍នៃ" *ការកសាងផែនការប្រើប្រាស់ដីធ្លីនៅមូលដ្ឋាន និងការពង្រីកភាពជាដៃគូរវាងសហគមន៍ជនជាតិដើមភាគតិច អង្គការ NGO និងរដ្ឋាភិបាល ក្នុងការគ្រប់គ្រងនៅក្នុង និងនៅជុំវិញតំបន់កម្មសិទ្ធិសហគមន៍ នឹងផ្តល់ការណែនាំ និងគោលការណ៍ដើម្បីអនុវត្តន៍ការផ្តល់កម្មសិទ្ធិដីធ្លីដល់សហគមន៍* " ។

## យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា (២០០៣

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រាំឆ្នាំដែរ គឺបានចែងពីបញ្ហាដ៏ទូលំទូលាយជាច្រើនទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ។ គោលនយោបាយនេះបានចែងច្បាស់លាស់អំពីគោលបំណង វិធានការណ៍ដែលអាចអនុវត្តសកម្មភាពបាន សូចនាករណ៍ដែលអាចវាស់វែងបាន និងចំណុចគោលដៅកំណត់ទៅតាមពេលវេលាជាក់លាក់ និងភ្នាក់ងារដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពនេះ ។ អាស្រ័យហេតុនេះ ឯកសារនេះជាគោលនយោបាយដែលបានចងក្រងឡើងយ៉ាងល្អមួយដូចបានពិពណ៌នាខាងលើនោះ ។

នៅឆ្នាំ២០០៦ ឯកសារគោលនយោបាយនេះ និង SEDP II នឹងត្រូវដាក់បញ្ចូលគ្នាទៅជាឯកសារគោលនយោបាយទូលំទូលាយតែមួយសម្រាប់ណែនាំការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ។

ជាអកុសល គោលនយោបាយនេះមានចែងតិចតួចប៉ុណ្ណោះដែលអាចពាក់ព័ន្ធទៅនឹងសកម្មភាព CBNRM ។ គោលនយាបាយនេះពិតជាអំពាវនាវឱ្យមាន " *ការកសាងផែនការប្រើប្រាស់ដីធ្លី ដោយរួមបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ និងការកសាងផែនការ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លីតាមបែបវិមជ្ឈការ* " ដែលគួរមានដាក់បញ្ចូលទៅក្នុងអនុក្រឹត្យស្តីពីការកសាងផែនការប្រើប្រាស់ដីធ្លីដូចមានចែងនៅក្នុងច្បាប់ភូមិបាល ។ គោលនយោបាយនេះក៏អំពាវនាវឱ្យបង្កើត និងពង្រឹងសហគមន៍ព្រៃឈើផងដែរតាមរយៈការបង្កើនការយល់ដឹង និង "*ជួយក្រុមអ្នកប្រើប្រាស់ព្រៃឈើក្នុងការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ* " និង បន្ត " *កិច្ចប្រឹងប្រែងលើការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយនិរន្តរភាព* " ។

នៅក្នុងផែនការគ្រប់គ្រងធនធានទឹក គោលនយោបាយនេះចែងថា រដ្ឋាភិបាលចាំបាច់ត្រូវអនុម័តគោលការណ៍ណែនាំ និងបទបញ្ជាទូលំទូលាយមួយ ដែលទាក់ទងទៅនឹងការចូលរួមរបស់កសិករនៅក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងការស្រោចស្រពតាមរយៈ ការដាក់ចេញឱ្យប្រើប្រាស់នូវច្បាប់ស្តីពីធនធានទឹក និងអនុក្រឹត្យស្តីពីសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ។

## គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់វិស័យព្រៃឈើ (២០០២

ឯកសារនេះមិនមានទម្រង់ជាឯកសារគោលនយោបាយទេ តែជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល ដែលបានបង្ហាញពីការតាំងចិត្ត ក្នុងការបើកទូលាយនៃគោលការណ៍គ្រប់គ្រង ។ សម្រាប់ប្រទេសកម្ពុជា ចាំបាច់ត្រូវរៀបចំឯកសារគោលនយោបាយវិស័យព្រៃឈើទូលំទូលាយមួយ ហើយនេះគឺជាលក្ខខណ្ឌចាំបាច់ដែលមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ។ នៅក្នុងសេចក្តីថ្លែងការណ៍នេះមានចំណុចតិចតួចណាស់ ដែលមានទំនាកទំនងជាមួយ CBNRM ។

ឯកសារនេះចែងថា រដ្ឋាភិបាលត្រូវ " *ធានាការចូលរួមយ៉ាងពេញលេញពីផ្នែកឯកជន និងសហគមន៍មូលដ្ឋានក្រោមរូបភាព នៃការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព...* ទទួលស្គាល់ និង " *ការពារតាមផ្លូវច្បាប់នូវសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានព្រៃឈើ...* " និង "*បង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋានពីការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើតាមរយៈទស្សនទាននៃការអភិរក្សព្រៃឈើ និងសត្វព្រៃដោយសហគមន៍* " ។

[៥] អនុក្រឹត្យនេះបានអនុម័តរួចហើយ សូមអានផ្នែកស្តីភាពខ្វះចន្លោះនៅក្នុងច្បាប់

## គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីធនធានទឹក (២០០៤

នៅខែមករា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិលើកទី ១ស្តីពីធនធានទឹករបស់ប្រទេស ។ ឯកសារគោលនយោបាយនេះ ទទួលស្គាល់ពីសារៈសំខាន់នៃធនធានទឹកនៅក្នុងប្រទេសកម្ពុជា និងអំពាវនាវឱ្យមានការអភិវឌ្ឍ ការប្រើប្រាស់ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅទូទាំងប្រទេស ។ ចំណុចខ្វះខាតនៅក្នុងឯកសារនេះគឺពុំបានចែងពីសកម្មភាព ជាក់លាក់ដែលត្រូវយកមកអនុវត្ត ពេលវេលាដែលត្រូវអនុវត្ត ស្ថាប័នឬនាយកដ្ឋានដែលទទួលខុសត្រូវ ។ ក្រសួងតែមួយគត់ដែលបានលើកយកមកពិពណ៌នានោះគឺ ក្រសួងធនធានទឹក និងឧតុនិយម ។

ចំនុចដែលទាក់ទងនឹងការងារ CBNRM នៅក្នុងគោលនយោបាយនេះ គឺសេចក្តីថ្លែងការណ៍ទាំងឡាយ ដែលទាក់ទងនឹងការលើកកំពស់ការចូលរួមពីអ្នកទទួលផល និងសហគមន៍កសិករអ្នកប្រើប្រាស់ទឹក នៅក្នុងការគ្រប់គ្រងធនធានទឹក ។

## សេចក្តីសង្ខេបនៃប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា

ប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាបានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃរចនាសម្ព័ន្ធអភិបាលកិច្ចរួម ក្រោមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស ។ រដ្ឋាភិបាលបង្កើតឡើងដោយប្រព័ន្ធមួយ ដែលមានបំណងបែងចែកអំណាចច្បាស់លាស់ រវាងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ។

*"ការបែងចែកអំណាចជាការធានាឱ្យបានថា គ្មានផ្នែក ឬ ស្ថាប័នណាមួយរបស់រដ្ឋាភិបាលអាចកាន់កាប់អំណាចដាច់ខាត ឬផ្តាច់ការបានឡើយ ហើយការធ្វើបែបនេះជាកិច្ចការពារប្រជាពលរដ្ឋ ប្រឆាំងនឹងការរំលោភដោយអំណាចរបស់រដ្ឋ"។[៦] (មើលដ្យាក្រាម ១*

ដោយសារតែភាពទន់ខ្សោយ និងកង្វះខាតសមត្ថភាពនៅក្នុងប្រព័ន្ធនីតិបញ្ញត្តិ និងប្រព័ន្ធតុលាការ ប្រពន្ធ័នៃការបែងចែកអំណាចនេះមិនអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាពទៅតាមលទ្ធភាពបានឡើយ ។ ប្រព័ន្ធតុលាការត្រូវបានមើលឃើញថា ជាប្រព័ន្ធមួយទន់ខ្សោយជាងគេបំផុតក្នុងចំណោមប្រព័ន្ធទាំងបីនេះ ទោះបីជាមានការខិតខំប្រឹងប្រែង ដើម្បីកែទម្រង់ស្ថានភាពនេះក៏ដោយ ដូចជាការអនុម័តនានាពេលថ្មីៗនេះនូវច្បាប់ និងសេចក្តីព្រាងកំណែទម្រង់គោលនយោបាយតុលាការ រៀបចំដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ។

ផ្នែកនីតិបញ្ញត្តិបានបែងចែកជាសភាជាតិ និងព្រឹទ្ធសភា ដោយមានអំណាចផ្តល់ការអនុម័តឯកភាព និងធ្វើ វិសោធនកម្មច្បាប់ដែលតាក់តែងឡើងដោយខ្លួនឯង ឬដោយរាជរដ្ឋាភិបាលកម្ពុជា[៦] ។ ផ្នែកនីតិប្រតិបត្តិរួមមាន នាយករដ្ឋមន្ត្រី

[៦] កំណែទម្រង់គោលនយោបាយច្បាប់ និងតុលាការ ដែលបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅក្នុងទំព័រទី៨

គណៈរដ្ឋមន្ត្រី និងក្រសួងនានា ។ ផ្នែកតុលាការ រួមមានតុលាការខេត្តចំនួន ១៩ តុលាក្រុង ២ តុលាការយោធា១ និងសាលាឧទ្ធរណ៍ និងតុលាការកំពូល១ នៅទីក្រុងភ្នំពេញ ។ ក្រសួងយុត្តិធម៌ និងប្រធានព្រះរាជអាជ្ញា អនុវត្តច្បាប់ និងទម្រង់ការព្រហ្មទណ្ឌ ហើយត្រួតពិនិត្យកិច្ចការរបស់ប៉ូលីសយុត្តិធម៌នៅក្នុងការពង្រឹងការអនុវត្តច្បាប់ទាំងអស់តាមរយៈសាលាក្តី[៧] ។

ច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា មានលំដាប់ឋានានុក្រម ហើយច្បាប់ និងបទបញ្ញត្តិនីមួយៗ មានសុពលភាព និងអំណាច ផ្អែកលើបទបញ្ញាទៅតាមលំដាប់នៃឋានានុក្រមនេះ។ ប្រអប់ ១ បង្ហាញពីឋានានុក្រមច្បាប់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា៖




*ដ្យាក្រាម ១ : ការបែងចែកអំណាចនៅប្រទេសកម្ពុជា*[៨]

នៅក្នុងឋានានុក្រមច្បាប់នេះ យើងអាចធ្វើការសង្កេតជាទូទៅមួយអំពីពេលវេលា និងវិសាលភាពផងដែរ ។ ចំពោះឯកសារ ច្បាប់ដែលបានអនុម័តដោយស្ថាប័នជាន់ខ្ពស់ ការអនុម័តឯកសារទាំងនោះត្រូវទាមទារពេលវេលាកាន់តែច្រើន ដោយសារត្រូវឆ្លងកាត់ការពិនិត្យនៅច្រើនលំដាប់ថ្នាក់ ។ឧទាហរណ៍ សេចក្តីព្រាងច្បាប់មួយដែលរៀបចំដោយរាជរដ្ឋាភិបាល

---

[៧] រាជរដ្ឋាភិបាលកម្ពុជារួមទាំងទីស្តីការគណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រី
[៨] រដ្ឋធម្មនុញ្ញ : ជំពូក ៧-១១

កម្ពុជា ត្រូវឆ្លងកាត់ដំណើរការពិនិត្យដោយគណៈរដ្ឋមន្ត្រី រដ្ឋសភាជាតិ និងទីបំផុតដោយព្រឹទ្ធសភា ចំណែកប្រកាសទាមទារឱ្យមានការពិនិត្យត្រឹមក្រសួងដែលរៀបចំឯកសារនោះឱ្យប្រើប្រាស់ប៉ុណ្ណោះ[៩] ។

ទិដ្ឋភាពមួយទៀតដែលគួរតែពិចារណា គឺវិសាលភាពនៃឯកសារច្បាប់ ។ ច្បាប់មានវិសាលភាពទូលំទូលាយហើយអនុវត្តចំពោះគ្រប់អង្គភាពរបស់រដ្ឋាភិបាលនៅទូទាំងប្រទេស លើកលែងតែមានចែងច្បាស់លាស់នៅក្នុងអត្ថបទច្បាប់នោះ ។ ប្រកាស មានអំណាចប្រតិបត្តិតែនៅក្នុងក្រសួងដែលចេញ សេចក្តីប្រកាសនោះប៉ុណ្ណោះ ចំណែកដីកាអនុវត្តបានចំពោះតែតំបន់ ភូមិសាស្រ្តនៃខេត្ត ឬឃុំដែលអនុម័តដីកានោះតែប៉ុណ្ណោះ ។

**ប្រអប់១ : ឋានានុក្រមច្បាប់នៅប្រទេសកម្ពុជា**

១ រដ្ឋធម្មនុញ្ញ
២ ច្បាប់ (chhbab)
៣ ព្រះរាជក្រឹត្យ (ReachKret)
៤ អនុក្រឹត្យ (Anu-Kret)
៥ ប្រកាស (Prakas)
៦ សារាចរ (sarachor)
៧ ដីកា (Deika)

**ច្បាប់** គឺជាប្រភពចម្បងនៃអត្ថបទច្បាប់នៅប្រទេសកម្ពុជា ។ ច្បាប់គឺជាអត្ថបទដែលអនុម័តដោយសភាជាតិ ( សភាជាន់ទាប និងព្រឹទ្ធសភា ( សភាជាន់ខ្ពស់ ។ មនុស្សជាច្រើនមានការយល់ច្រឡំរវាងច្បាប់ និងក្រម ដែលជាគំរូមួយបែបនៃព្រះរាជក្រឹត្យដែលព្រះមហាក្សត្រ ឬ ប្រមុខរដ្ឋ ប្រកាសឱ្យប្រើប្រាស់ច្បាប់មួយ ។ ដូចបានរៀបរាប់មកហើយ ដំណើរការនៃការប្រកាសអោយប្រើប្រាស់ច្បាប់មួយដែលបានស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាទំនងជាត្រូវចំណាយពេលវេលាច្រើន ហើយជាទូទៅអនុវត្តតាមលំដាប់លំដោយ[១០] ដូចតទៅ :

[៩] បន្ទាប់ពីប្រកាសឱ្យប្រើប្រាស់ ច្បាប់អាចនឹងត្រូវពិនិត្យឡើងវិញឱ្យត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ប៉ុន្តែអាស្រ័យលើសំណើរបស់ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ឬរដ្ឋសភា នាយករដ្ឋមន្ត្រី ១/៤នៃសមាជិកព្រឹទ្ធសភា ១/១០នៃសមាជិករដ្ឋសភា ឬតុលាការតែប៉ុណ្ណោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញគ្មានសិទ្ធិពិនិត្យឡើងវិញលើច្បាប់ ស្តីពីបញ្ហាដែលមិនមានចែងក្នុងរដ្ឋធម្មនុញ្ញ ហើយមិនមានសិទ្ធិពិនិត្យឡើងវិញលើឧបករណ៍ច្បាប់ផ្សេងៗទៀត ជាអាទិ៍ អនុក្រឹត្យ ឬប្រកាសឡើយ ។

[១០] នីតិវិធីនេះនឹងដាក់ស្នើឱ្យមានការធ្វើវិសោធនកម្មច្បាប់ផងដែរ ។

១ ការរៀបចំសេចក្តីព្រាងច្បាប់ដោយក្រសួងជំនាញ ដូចជាក្រសួងមហាផ្ទៃ ។

២ ការពិភាក្សាពីសេចក្តីព្រាងច្បាប់នៅក្នុងកិច្ចប្រជុំអន្តរក្រសួង (ឬប្រសិនបើចាំបាច់ នៅក្នុងក្រសួងពាក់ព័ន្ធផ្ទាល់តែម្តង ។ ជាញឹកញាប់មានការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ពន្ធ័ផងដែរ (ម្ចាស់ជំនួយ សង្គមស៊ីវិល ផ្នែក ឯកជន ។ល ។ ។

៣ ការសិក្សាអំពីសេចក្តីព្រាងច្បាប់ដោយក្រុមប្រឹក្សាអ្នកច្បាប់ចំណុះអោយគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យមើលភាពស្របគ្នាជាមួយរដ្ឋធម្មនុញ្ញ ភាពទាក់ទងគ្នាជាមួយច្បាប់ដែលមានស្រាប់ ។ល ។

៤ ការពិភាក្សាលើសេចក្តីព្រាងច្បាប់នៅថ្នាក់អន្តរក្រសួងស្ថិតនៅចំណុះអោយគណៈរដ្ឋមន្ត្រី ។

៥ ការត្រួតពិនិត្យមើល និងការអនុម័តសេចក្តីព្រាងច្បាប់ដោយគណៈរដ្ឋមន្ត្រី ។

៦ ការដាក់ឆ្លងសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជាជូនទៅរដ្ឋសភាជាតិ ។ សេចក្តីព្រាងច្បាប់ត្រូវដាក់ឆ្លងជាទម្រង់លាយល័ក្ខអក្សរដោយអមជាមួយនូវ "សេចក្តីថ្លែងការណ៍ពីគោលបំណង" ជូនទៅគណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិដើម្បីចែកចាយទៅឱ្យតំណាងរាស្ត្រ ។ គណៈកម្មការអចិន្ត្រៃយ៍បញ្ជូនសេចក្តីព្រាងច្បាប់នេះ បន្តទៅគណៈកម្មការជំនាញដើម្បីធ្វើការពិនិត្យ ។ បន្ទាប់ពីការពិនិត្យរួចហើយ ប្រធានគណៈកម្មការនេះផ្តល់មតិរបស់គណៈកម្មការ ជូនទៅ រដ្ឋសភាជាតិ ។

៧ ការពិនិត្យ និងជជែកវែកញែកពីសេចក្តីព្រាងច្បាប់នៅឯសម័យប្រជុំពេញអង្គរួមទាំងការកែសម្រួលដោយរដ្ឋសភាជាតិ ។

៨ ការបោះឆ្នោតលើសេចក្តីព្រាងច្បាប់ដោយសភាជាតិ (មតិភាគច្រើន ។

៩ ការដាក់ឆ្លងសេចក្តីព្រាងច្បាប់ជូនព្រឹទ្ធសភា ដែលត្រូវពិនិត្យ និងផ្តល់អនុសាសន៍ មិនលើសពីរយៈពេលមួយខែឡើយ ។ ចំពោះបញ្ហាបន្ទាន់រយៈពេលនេះត្រូវកាត់បន្ថយមកនៅត្រឹម៧ថ្ងៃប៉ុណ្ណោះ ។ ប្រសិនបើព្រឹទ្ធសភាមិនផ្តល់អនុសាសន៍ក្នុងរយៈពេលកំណត់ដែលបានចែងទេនោះ ច្បាប់នេះនឹងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។ ប្រសិនបើ ព្រឹទ្ធសភាសុំឱ្យធ្វើការ កែប្រែ រដ្ឋសភាជាតិត្រូវយកចំណុចនោះមកពិភាក្សាភ្លាម ។ នៅក្នុងការពិនិត្យលើកទីពីរនៃសេចក្តីព្រាងច្បាប់នេះ រដ្ឋសភាជាតិត្រូវអនុម័តដោយ សំឡេងភាគច្រើនដាច់ខាត ។

១០ ការប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ ឬ ប្រមុខរដ្ឋ (ក្រម ។

**ព្រះរាជក្រឹត្យ :** រដ្ឋធម្មនុញ្ញចែងថា " *តាមការស្នើសុំរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រ (ប្រមុខរដ្ឋ ត្រូវចុះហត្ថលេខាលើក្រឹត្យតែងតាំង ផ្ទេរ ឬបញ្ចប់បេសកកម្មរបស់មន្ត្រីស៊ីវិល ឬមន្ត្រីយោធាជាន់ខ្ពស់..*[១១] ។ រាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់បទប្បញ្ញត្តិនេះ ដើម្បីបង្កើតអង្គភាពអន្តរក្រសួងជាន់ខ្ពស់ដូចជា គណៈកម្មការជាតិគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។ ពេលខ្លះមានការប្រើប្រាស់ព្រះរាជក្រឹត្យជាឯកសារបទបញ្ជា ដូចជាករណី ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងទីជម្រាលជាដើម ។

---

[១១] មាត្រា២១ នៃរដ្ឋធម្មនុញ្ញ

តាមលក្ខណៈបច្ចេកទេសព្រះរាជក្រឹត្យ និង ក្រឹត្យបែបនេះមិនស្របតាមរដ្ឋធម្មនុញ្ញទេ ព្រោះថា ព្រះមហាក្សត្រមានអំណាចត្រឹមតែ គ្រងរាជ្យសម្បត្តិតែមិនកាន់អំណាចឡើយ ។

**អនុក្រឹត្យ** ៖ ជាឯកសារច្បាប់ជាទូទៅបានប្រើប្រាស់សម្រាប់អនុវត្តន៍ និងពន្យល់បំភ្លឺបន្ថែមពីប្រការជាក់លាក់ដែលមាននៅក្នុងច្បាប់។ ជួនកាលបទប្បញ្ញត្តិទាំងនោះត្រូវបានប្រើប្រាស់ផងដែរ ដើម្បីធ្វើការរៀបរាប់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពរដ្ឋាភិបាល ដូចជាក្រសួង ឬសម្រាប់ការតែងតាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ជាដើម ។ សេចក្ដីព្រាងអនុក្រឹត្យ ត្រូវបានរៀបចំឡើងដោយក្រសួងមួយ ឬក្នុងចំណោមក្រសួងនានាជាច្រើនដែលមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងការបង្កើតអនុក្រឹត្យនោះ ។ នៅពេលបានសេចក្ដីព្រាងហើយ អនុក្រឹត្យនោះត្រូវដាក់ឆ្លងទៅគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការពិនិត្យ និងអនុម័ត[១២] ។ ក្រោយពេលគណៈរដ្ឋមន្ត្រីបានអនុម័តរួចហើយ នាយករដ្ឋមន្ត្រីនឹងចុះហត្ថលេខាលើអនុក្រឹត្យនោះ និងត្រូវចុះហត្ថលេខាទទួលយកមកវិញដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូបដែលទទួលបន្ទុកអនុវត្តន៍។ ការផ្ដល់អំណាចសម្រាប់អនុក្រឹត្យនេះទោះជាផ្ទាល់ ឬ ដោយប្រយោលក្ដី ត្រូវយោងទៅលើឯកសារច្បាប់ដែលមានឋានានុក្រមខ្ពស់ជាង ។ ដោយសារតែអនុក្រឹត្យបានអនុម័តនៅថ្នាក់គណៈរដ្ឋមន្ត្រី ដូច្នេះវិសាលភាពនៃអំណាចរបស់វាមានលក្ខណៈទូលំទូលាយ ។

**ប្រកាស** ៖ ជាបទបញ្ជាថ្នាក់ក្រសួង ឬអន្តរក្រសួងដែលមានការប្រើប្រាស់ដូចអនុក្រឹត្យដែរ សម្រាប់អនុវត្តន៍ និងបំភ្លឺបន្ថែមពីបទប្បញ្ញត្តិនានា ដែលមាននៅក្នុងឯកសារច្បាប់ទាំងឡាយ ។ ជាញឹកញាប់ ប្រកាសត្រូវបានប្រើប្រាស់សម្រាប់បង្កើតគោលការណ៍ណែនាំដែលចាំបាច់សំរាប់អនុវត្តច្បាប់ ឬ អនុក្រឹត្យ ។ ជាធម្មតា សេចក្ដីព្រាងប្រកាសត្រូវបានធ្វើឡើងដោយនាយកដ្ឋានជំនាញ បន្ទាប់មកត្រូវបានចុះហត្ថលេខា ឯកភាព ដោយរដ្ឋមន្ត្រីមួយរូប (ឬរដ្ឋមន្ត្រីច្រើនរូប ទទួលបន្ទុកតាមក្រសួងដែលត្រូវអនុវត្តបទបញ្ជា ឬគោលការណ៍ណែនាំក្នុងសេចក្ដីប្រកាសនោះ ។ គួរកត់សម្គាល់ថា ប្រកាសត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីអនុវត្តច្បាប់នៅប្រទេសកម្ពុជា ហើយមេរៀនទទួលបានអាចត្រូវបានដាក់បញ្ចូលគ្នាបានយ៉ាងឆាប់រហ័សដោយសារតែដំណើរការសម្រាប់អនុម័តប្រកាសហាក់បី ដូចជាធម្មតា និងឆាប់រហ័ស ។ ចំនុចខ្សោយរបស់ប្រកាស គឺមានវិសាលភាពតូចសម្រាប់តែក្រសួងនានាដែលជាអ្នកអនុម័ត និងខ្សែបណ្ដោយរបស់ខ្លួន ចំណែកក្រសួងឬអង្គភាពដទៃទៀតពុំមានកាតព្វកិច្ចអនុវត្តតាមប្រកាសទាំងនោះឡើយ ។

**សារាចរ** ៖ ជាបរិធានច្បាប់ចេញដោយនាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី សម្រាប់ធ្វើការពន្យល់ ឬ បំភ្លឺវិធានការណ៍ច្បាប់បទប្បញ្ញត្តិ ជាក់លាក់ ឬជាការចេញបញ្ជា ។ ដូចប្រកាសដែរ សារាចរមានអំណាចតិចតួចតែងាយអនុម័ត ។

[១២] ជំហាននានាសម្រាប់អនុម័តអនុក្រឹត្យមានលក្ខណៈដូចគ្នា នឹងការអនុម័តច្បាប់ពីជំហាន ១-៥ ។

**ដីកា** ៖ ជាបទបញ្ជាចេញដោយអភិបាលខេត្ត ឬក្រុមប្រឹក្សាឃុំ ដែលមានអំណាចច្បាប់នៅក្នុងព្រំប្រទល់រដ្ឋបាលនៃដែនដីរបស់ខ្លួន ។ ដីកាមិនអាចមានអត្ថន័យផ្ទុយនឹងបទបញ្ជាផ្សេងៗទៀតនៅថ្នាក់ជាតិឡើយ ។

## ឯកសារច្បាប់

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃឯកសារច្បាប់ជាមូលដ្ឋាន ដែលមានទំនាក់ទំនងតាមរូបភាពមួយចំនួនជាមួយការគ្រប់គ្រងធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅក្នុងប្រទេស ។

### ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)

ច្បាប់នេះរួមមានបទប្បញ្ញត្តិសម្រាប់ការពារធនធានធម្មជាតិ និងបរិស្ថានរបស់ប្រទេសដែលគ្របដណ្តប់តំបន់ការពារធម្មជាតិ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន សកម្មភាពត្រួតពិនិត្យការបំពុលទឹក ការរៀបចំផែនការសកម្មភាពការងារបរិស្ថានតាមតំបន់ និងថ្នាក់ជាតិ និងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោង អភិវឌ្ឍន៍ ឬសកម្មភាពផ្សេងៗទៀតដែលមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះបរិស្ថាន ។

គោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើននៃច្បាប់នេះ គឺ *"លើកទឹកចិត្ត និងផ្តល់លទ្ធភាពដល់សាធារណៈជនឱ្យចូលរួមនៅក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ "* ។ ទោះបីជាចំណុចនេះទាក់ទងទៅនឹងទស្សនទានរបស់ CBNRM ប៉ុន្តែច្បាប់នេះពុំមានចែងច្បាស់លាស់ពីវិធីសាស្រ្តដើម្បីសម្រេចកិច្ចការនេះឡើយ ។ ច្បាប់នេះផ្តល់សិទ្ធិអំណាចឱ្យមានការតាក់តែងសេចក្តីព្រាង និងការអនុម័តអនុក្រឹត្យស្តីពីបែបបទនៃការចូលរួមរបស់សាធារណៈជននៅក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ តែការងារនេះមិនទាន់បានធ្វើនៅឡើយទេ ។

### ច្បាប់ភូមិបាល (២០០១)

ច្បាប់ភូមិបាលលើកឡើងនូវទស្សនទានសំខាន់ៗនៃការចាត់ថ្នាក់ដីធ្លី (ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និងដីឯកជន និងកម្មសិទ្ធិនៅក្នុងប្រទេសកម្ពុជា[១៣] ។ ច្បាប់នេះរួមបញ្ចូលបទបញ្ញត្តិសំខាន់ៗ អំពីសិទ្ធិស្តីពីកម្មសិទ្ធិសមូហភាពរស់ក្រុមជនជាតិដើមភាគតិចនៅក្នុងប្រទេស ។ ច្បាប់នេះមិនបានចែងពីយន្តការណាមួយសម្រាប់ការកសាងផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងទាក់ទងនឹងសកម្មភាព CBNRM ទេ តែច្បាប់នេះក៏បានស្នើឱ្យមានការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលអាចចែងអំពីប្រការនេះតាមរយៈបទប្បញ្ញត្តិស្តីពីការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី ។ ច្បាប់ភូមិបាលបានផ្តល់យន្តការដោះស្រាយទំនាស់មួយចំនួនដែលអាចប្រើប្រាស់នៅពេលជួបបញ្ហាកម្មសិទ្ធិក្នុងពេលធ្វើការងារ CBNRM នេះ ។

---

[១៣] ចំពោះសេចក្តីសង្ខេបនៃចំណងទាក់ទង រវាងប្រព័ន្ធចំណាត់ថ្នាក់នៅក្នុងច្បាប់ ភូមិបាល ច្បាប់ព្រៃឈើ សូមអានដ្យាក្រាម ២ ខាងក្រោម ។




*ដ្យាក្រាម ២ :ប្រព័ន្ធចាត់ថ្នាក់អចលនៈទ្រព្យ ស្របតាមច្បាប់ភូមិបាល (២០០១*

**ច្បាប់ស្តីពីរដ្ឋបាល និងការគ្រប់គ្រងឃុំ (២០០១)**

ឯកសារច្បាប់សំខាន់នេះ ផ្តល់អំណាចពាក់កណ្តាលស្វយ័ត ទាំងខាងនីតិប្រតិបត្តិ និងនីតិបញ្ញត្តិឱ្យដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលកើតឡើងពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសម្រាប់ការងារគ្រប់គ្រងនៅថ្នាក់ក្រោមបំផុត ។ ក្រុមប្រឹក្សាឃុំ-សង្កាត់មានសមត្ថកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិស្ថិតនៅក្នុងព្រំប្រទល់ដែនសមត្ថកិច្ចរបស់ពួកគេ ប៉ុន្តែត្រូវបានហាមឃាត់ជាពិសេសមិនឱ្យធ្វើសេចក្តីសម្រេចអំពីបញ្ហាព្រៃឈើ លើកលែងតែមានការផ្តល់អំណាចជាក់លាក់ពីរាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវកសាងផែនការអភិវឌ្ឍន៍ឃុំ ដែលអាច រួមបញ្ចូលការគ្រប់គ្រងធនធានធម្មជាតិ ។ លើសពីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់អាចបង្កើតអនុគណៈកម្មការដើម្បីជួយដោះស្រាយបញ្ហាគ្រប់គ្រងជាក់លាក់ជាច្រើន ដូចជាបញ្ហាដែលអាចនឹងមានទំនាក់ទំនងជាមួយសកម្មភាព CBNRM [១៤] ។ មិនមានបទប្បញ្ញត្តិជាក់លាក់នៅក្នុង ច្បាប់នេះ ឬលិខិតបទដ្ឋានពាក់ព័ន្ធដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ឡើយ ។

**ច្បាប់ស្តីពីព្រៃឈើ (២០០២)**

ច្បាប់ស្តីពីព្រៃឈើចែងពីវិធាន និងបទបញ្ញាទូទៅដែលទាក់ទងនឹងរដ្ឋបាល និងការគ្រប់គ្រងព្រៃឈើនៅក្នុងប្រទេសកម្ពុជា [១៥] ។ ទោះបីច្បាប់ព្រៃឈើផ្តល់សមត្ថកិច្ចចម្បងទៅឱ្យរដ្ឋបាលព្រៃឈើ (FA) ក្នុងការគ្រប់គ្រងព្រៃបំរុងទុកអចិន្ត្រៃយ៍ក្តី តែរដ្ឋបាលព្រៃឈើក៏មានសមត្ថកិច្ចគ្រប់គ្រងតំបន់ផ្សេងទៀតក្នុងដែនព្រៃឈើផងដែរ ដូចជាឧក្រិដ្ឋកម្មព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិដែលគ្រប់គ្រង ដោយក្រសួងបរិស្ថាន និងបទបញ្ញាលើការដាំឈើលើដីឯកជន (ព្រៃឯកជន ។ ច្បាប់ស្តីពីព្រៃឈើចែងអំពីរចនាសម្ព័ន្ធគ្រឹះ តួនាទីនិង ការទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើ ។

ច្បាប់ស្តីពីព្រៃឈើ គឺជាបរិធានច្បាប់មួយដ៏សំខាន់ដែលទាក់ទងជាមួយ CBNRM ។ ច្បាប់នេះរួមមានមាត្រាសំខាន់ៗ ស្តីពីការ

[១៤] គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាឃុំ-សង្កាត់មួយចំនួនក្នុងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃកម្មវិធី NREM ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ។

[១៥] ចំពោះសេចក្តីសង្ខេបនៃរបៀបដែលច្បាប់ព្រៃឈើចាត់ថ្នាក់ប្រភេទព្រៃឈើផ្សេងៗគ្នា និងទំនាក់ទំនងជាមួយច្បាប់ភូមិបាល សូមអានដ្យាក្រាម ៣ ខាងក្រោម

**ច្បាប់ស្តីពីព្រៃឈើ (២០០២) បន្ត**

ប្រើប្រាស់ជាលក្ខណៈប្រពៃណី និងសិទ្ធិចំពោះធនធានព្រៃឈើ តែពុំមានចែងពីសិទ្ធិក្នុងការគ្រប់គ្រងឡើយ ។ សំខាន់ជាងនេះទៅទៀត គឺបទប្បញ្ញត្តិដែលអនុញ្ញាតឱ្យមានការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍ ដែលតាមរយៈនេះ សហគមន៍ត្រូវបានផ្តល់ឱ្យនូវតំបន់ព្រៃបំរុងទុកអចិន្ត្រៃយ៍ដើម្បីគ្រប់គ្រង និងទាញយកផល ។ បទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុញ្ញាតឱ្យមានតែសកម្មភាពសហគមន៍ព្រៃឈើ តែនៅក្នុងតំបន់ដែលបានចាត់ថ្នាក់ជាព្រៃផ្តល់ផល ហេតុនេះមិនរាប់បញ្ចូលតំបន់ព្រៃការពារឱ្យនៅក្រោមការគ្រប់គ្រងនៃសហគមន៍ព្រៃឈើឡើយ ។




*ដ្យាក្រាម ៣ : ប្រព័ន្ធចំណាត់ថ្នាក់ព្រៃឈើ ស្របតាមច្បាប់ភូមិបាល (២០០២*

**ព្រះរាជក្រឹត្យស្តីពីតំបន់ការពារធម្មជាតិ (១៩៩៣)**

ព្រះរាជក្រឹត្យនេះ បានបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិឱ្យស្ថិតនៅក្រោមក្រសួងបរិស្ថាន ប៉ុន្តែមានចែងតិចតួចអំពីការគ្រប់គ្រងតំបន់ទាំងអស់នេះ ។ ព្រះរាជក្រឹត្យនេះ បានទទួលការរិះគន់ពីឋានានុក្រមច្បាប់ ប៉ុន្តែបានដោះស្រាយតាមរយៈការអនុម័តច្បាប់ស្តីពីព្រៃឈើ ។ ច្បាប់ស្តីពីព្រៃឈើ គឺជាយន្តការដែលអនុម័តដោយរដ្ឋសភា និងបានផ្តល់អាណត្តិច្បាស់លាស់ដល់ក្រសួងបរិស្ថាននូវសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

**អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ (២០០៣)**

អនុក្រឹត្យនេះ បានទទួលអំណាចពីច្បាប់ស្តីពីព្រៃឈើ ដើម្បីចែងអំពីបទបញ្ជា និងបែបបទទូទៅសម្រាប់សហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ។ បែបបទ និងតម្រូវការលំអិតដែលចាំបាច់សម្រាប់ការអនុវត្តនឹងត្រូវលាតត្រដាងនៅក្នុងសេចក្តីប្រកាសដែលបច្ចុប្បន្នកំពុងរៀបចំជាសេចក្តីព្រាងនៅឡើយ ។ សេចក្តីប្រកាសនេះត្រូវបានរំពឹងថានឹងត្រូវអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឆ្នាំ២០០៥ ។

## ភាពខ្វះចន្លោះនៃច្បាប់

មានច្បាប់ អនុក្រឹត្យ និងប្រកាសជាច្រើនដែលនឹងត្រូវអនុម័តនៅពេលខាងមុខ និងដែលអាចមានឥទ្ធិពលលើសកម្មភាព CBNRMនៅក្នុងប្រទេស ។ ខាងក្រោមនេះ គឺជាឯកសារច្បាប់សំខាន់៧ ដែលនៅជាសេចក្តីព្រាងនៅឡើយ ។ បច្ចុប្បន្ន គេនៅពុំទាន់ដឹងច្បាស់នៅឡើយទេថា តើឯកសារច្បាប់ទាំងនេះ នឹងមានទម្រង់យ៉ាងណាឡើយ នៅពេលត្រូវអនុម័តរួច ។

**ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**

ដើម្បីគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានត្រូវរៀបចំច្បាប់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។ បច្ចុប្បន្ន នៅក្នុងសេចក្តីព្រាងច្បាប់នេះ មានចែងពីតំបន់សហគមន៍ប្រើប្រាស់ និងគ្រប់គ្រងដែលមានទំនាក់ទំនងជាមួយ CBNRM ។ ទោះបីជាការឯកសារច្បាប់នេះស្ថិតនៅជាសេចក្តីព្រាងក៏ដោយ ប៉ុន្តែសេចក្តីព្រាងនេះ នឹងត្រូវអនុម័តជាអនុក្រឹត្យស្តីពីតំបន់ការពារធម្មជាតិ ។

**ច្បាប់ជលផល**

ប្រទេសកម្ពុជាត្រូវការច្បាប់នេះសម្រាប់គ្រប់គ្រងវិស័យជលផលទាំងមូល រួមទាំងគ្រប់គ្រងបញ្ហានានានៅជុំវិញសកម្មភាពនេសាទតាមគ្រួសារ និងសហគមន៍នេសាទដែលមានទំនាក់ទំនងជាមួយ CBNRM ។ ច្បាប់នេះចាំបាច់ត្រូវអនុម័តដោយរដ្ឋសភាមុនការអនុម័តនូវអនុក្រឹត្យសហគមន៍នេសាទ ។ ច្បាប់នេះស្ថិតនៅជាសេចក្តីព្រាងអស់រយៈពេលជាងពីរឆ្នាំមកហើយ ។

**ច្បាប់គ្រប់គ្រងធនធានទឹក**

សេចក្តីព្រាងច្បាប់គ្រប់គ្រងធនធានទឹក(សេចក្តីព្រាងថ្មីបំផុតនៅខែមិនាឆ្នាំ២០០២ មានគោលបំណង "ជម្រុញឱ្យមានការគ្រប់គ្រងធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយប្រសិទ្ធិភាព ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពប្រជាពលរដ្ឋ" ។ គោលបំណងនេះនឹងត្រូវអនុវត្តតាមរយៈការកំណត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ទឹក

ទស្សនទានសំខាន់នៃការគ្រប់គ្រងធនធានទឹក ស្ថាប័នទទួលបន្ទុកអនុវត្តន៍ និងពង្រឹងការអនុវត្ត និងការចូលរួមរបស់ អ្នកប្រើប្រាស់ និងសហគមន៍នៅក្នុងការអភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តរភាព ។ ទន្ទឹមនឹងមាត្រាចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់ទឹក រួមទាំងក្រុមកសិករអ្នកប្រើប្រាស់ទឹក ច្បាប់នេះមានទំនាក់ទំនងល្អជាមួយបញ្ហា CBNRM នៅប្រទេសកម្ពុជា ។

## អនុក្រឹត្យស្តីពីសហគមន៍នេសាទ

អនុក្រឹត្យនេះ នឹងបង្កើតវិធានការណ៍លំអិតសម្រាប់ការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទនៅប្រទេសកម្ពុជា ។ ហេតុនេះ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបញ្ហា CBNRM ហើយមានលក្ខណៈស្រដៀងគ្នាទៅនឹងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើដោយផ្តល់ធនធាននៅក្នុងតំបន់មួយចំនួនទៅឱ្យសហគមន៍ ដើម្បីគ្រប់គ្រង និងទាញយកផល ។

## គោលការណ៍ណែនាំសហគមន៍ព្រៃឈើ (ប្រកាស

ប្រកាសទាំងអស់នេះ នឹងផ្តល់នូវសេចក្តីលំអិតសម្រាប់ការអនុវត្តអនុក្រឹត្យសហគមន៍ព្រៃឈើ ។ ប្រកាសនេះរួមបញ្ចូលឧបសម្ព័ន្ធដែលផ្តល់គំរូ និងខ្លឹមសារទូទៅអំពីកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ បទបញ្ជាផ្ទៃក្នុងសម្រាប់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ លក្ខន្តិកៈសហគមន៍ព្រៃឈើ និងការតាមដានលើការអប់រំពីសហគន៍ព្រៃឈើ ។ តំបន់សហគមន៍ព្រៃឈើដែលមានស្រាប់នាពេលបច្ចុប្បន្ន និងតំបន់ដែលកំពុងត្រូវបានស្នើឡើង សម្រាប់សកម្មភាពការងារជាប្រភេទសហគមន៍ព្រៃឈើ ទៅថ្ងៃអនាគត មិនទាន់អាចទទួលស្គាល់ជាផ្លូវការបានឡើយ រហូតដល់មានការអនុម័តគោលការណ៍ណែនាំនេះ ។

## សេចក្តីសន្និដ្ឋាន

ឯកសារ និងគោលនយោបាយ និងច្បាប់កម្ពុជាដែលគាំទ្រទស្សនទាន CBNRM នៅមានចំនួនតិចតួចនៅឡើយ ។ សញ្ញានៃជោគជ័យមួយនៅក្នុងការងារនេះ គឺការប្រើប្រាស់នាពេលបច្ចុប្បន្ននូវបច្ចេកទេសកសាងផែនការប្រើប្រាស់ដីធ្លីដែលអាចជាមូលដ្ឋានសម្រាប់រៀបចំជាច្បាប់ស្តីពីការគ្រប់គ្រងដីធ្លីទៅថ្ងៃអនាគត ការអនុម័តអនុក្រឹត្យ ស្តីពីសហគមន៍ព្រៃឈើ និងសេចក្តីព្រាងឯកសារច្បាប់នាពេលបច្ចុប្បន្ន ដែលមានមាត្រាទាក់ទងនឹងក្រុមកសិករអ្នកប្រើប្រាស់ទឹក និងការគ្រប់គ្រងសហគមន៍ជលផល ។

អ្វីដែលត្រូវចងចាំនោះគឺថា គោលនយោបាយ និងច្បាប់អាចកែប្រែទៅតាមពេលវេលា ។ នៅពេលមានបទពិសោធន៍ និងមានការផ្លាស់ប្តូរអាកប្បកិរិយា នៅពេលនោះអាចមានឱកាសយ៉ាងច្រើនដើម្បីអនុម័តទស្សនទានដែលទាក់ទងនឹង CBNRM នៅក្នុងគោលនយោបាយ និងច្បាប់នៅប្រទេសកម្ពុជា ។

# ជំពូក ៤ កម្មវិធីវិមជ្ឈការសិលា និងការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

**រៀបរៀងដោយ : លោក ញ៉ែម សុវណ្ណា**[១]

ឯកសារនេះពិភាក្សាពីទំនាក់ទំនងរបស់រដ្ឋាភិបាល នៅក្នុងការពិគ្រោះយោបល់អំពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM) តាមរយៈកម្មវិធីអភិបាលកិច្ចវិមជ្ឈការនៃកម្មវិធីសិលា ។ ឯកសារនេះកត់ត្រានូវបទពិសោធន៍ថ្មីៗ នៃការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់ឃុំ-សង្កាត់ ។ បទពិសោធន៍នៅមូលដ្ឋានពីខេត្តរតនគីរី ដែលបញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវបានចាត់ទុកថាជាបញ្ហាអភិបាលកិច្ចដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការកសាងយុទ្ធសាស្ត្របញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។ នៅក្នុងបរិបទនៃវិមជ្ឈការ យុទ្ធសាស្ត្របញ្ជ្រាបបានចាត់ទុកបញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ថាជាបញ្ហានៃអភិបាលកិច្ចហើយដែលនោះជាមូលហេតុនៃការដាក់បញ្ចូលបញ្ហា នៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ឃុំ-សង្កាត់ ។

ការវិភាគអំពីបទពិសោធន៍នៃការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៅក្នុងដំណាក់កាលពីរឆ្នាំដំបូងកន្លងមកនេះ បានបង្ហាញពីចំណុចលម្អិតជាច្រើន ទោះបីជានៅមានតម្រូវការដើម្បីធ្វើការពិសោធន៍បន្តទៅទៀតដើម្បីឱ្យអាចឆ្លុះបញ្ចាំងពីដំណើរការបញ្ជ្រាបនេះបានយ៉ាងពេញលេញក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍ពីឃុំ-សង្កាត់ដែលបានអនុវត្តដំណើរការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នេះជាច្រើនដង បានធ្វើឱ្យការយល់ដឹង និងការជឿជាក់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់កាន់តែមានភាពល្អប្រសើរឡើងសម្រាប់ធ្វើការគាំទ្រ និងចរចាជុំវិញបញ្ហាបរិស្ថាន ។ ការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានមានសារៈសំខាន់ណាស់ព្រោះបានបញ្ចូលនូវបញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងក្របខ័ណ្ឌវិមជ្ឈការដែលបានទទួលការគាំទ្រយ៉ាងពេញលេញពីបណ្តាប្រទេសអ្នកផ្តល់ជំនួយនានា និងរាជរដ្ឋាភិបាល ។

ទោះជាបែបនេះក្តី នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ។ បញ្ហាប្រឈមទីមួយ គឺថាតើយើងអាចដាក់បញ្ចូលបែបណានូវវិធីសាស្ត្រនៃការកសាងផែនការរយៈពេលវែង " ដោយផ្អែកលើដំណើរការជាមូលដ្ឋានគ្រឹះ " ( បញ្ជ្រាបការគ្រប់-គ្រងធនធានធម្មជាតិ និងបរិស្ថាន ទៅក្នុងដំណើរការដែលផ្អែកលើលទ្ធផល ( កម្មវិធីវិនិយោគឃុំ-សង្កាត់ ។ បញ្ហាប្រឈមទីពីរគឺតើត្រូវធ្វើបែបណាដើម្បីជម្រុញការអនុវត្តផែនការ និងលើកទឹកចិត្តឱ្យមានការប្តេជ្ញា ( នៅគ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តគម្រោងផែនការឱ្យបានសម្រេចជោគជ័យ ។

## ប្រវត្តិដើម

ភាគច្រើននៃប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា គឺជាកសិករដែលមានជីវភាពក្រីក្រ និងពឹងអាស្រ័យទាំងស្រុង ឬស្ទើរតែទាំងស្រុងលើធនធានធម្មជាតិសម្រាប់ការចិញ្ចឹមជីវិត ។ ភាគច្រើននៃមន្ត្រីរដ្ឋាភិបាលគិតថា ធនធានធម្មជាតិជាមធ្យោបាយ

[១] អត្ថបទនេះបានចងក្រងឡើងដោយដកស្រង់យកបទពិសោធន៍ និងទិន្នន័យនៃការអនុវត្តគំរោងក្នុងចន្លោះឆ្នាំ១៩៩៧-២០០៤ បទពិសោធន៍ និងទិន្នន័យដែលបានរៀបរាប់នៅក្នុងអត្ថបទនេះអាចមានការប្រែប្រួលច្រើន ។ លោក សុវណ្ណា គឺជាទីប្រឹក្សាគម្រោងបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៃកម្មវិធីសិលា ដែលផ្តោតសំខាន់លើការបង្កើតយុទ្ធសាស្ត្រ មធ្យោបាយ និងវិធីសាស្ត្រសម្រាប់បញ្ជ្រាបបញ្ហា NREM និងយេនឌ័រ ទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ច តាមរយៈកម្មវិធីវិមជ្ឈការសិលា ។

សម្រាប់ផ្គត់ផ្គង់បន្ថែមលើប្រាក់ចំណូលទាបរបស់ពួកគេ តាមរយៈការផ្តល់សម្បទានព្រៃឈើ និងកសិ-ពាណិជ្ជកម្ម ។ ធនធានទាំងនេះកំពុងត្រូវបានបាត់បង់នៅក្នុងកម្រិតមួយដ៏ធ្ងន់ធ្ងរដោយសារតែអំពើពុករលួយ និងការដកហូតប្រើប្រាស់ហួសកម្រិត ។

ចាប់តាំងពីមានការផ្តល់មូលនិធិពីប្រទេសអ្នកផ្តល់ជំនួយអោយប្រទេសកម្ពុជានាទសវត្សរ៍ឆ្នាំ ១៩៩០ មក ការចាប់អារម្មណ៍ពីសំណាក់សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលបានកើនឡើង ដែលនាំឱ្យមានការអនុវត្តសាកល្បងវិធីសាស្រ្តផ្សេងៗ និងការបើកចំហឱ្យមានការពិភាក្សាអំពីបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងឃុំ) ។ ភាគច្រើននៃកិច្ចខិតខំប្រឹងប្រែងនៅក្នុងដំណាក់កាលដំបូងនេះ គឺឆ្ពោះទៅរកការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់នៅថ្នាក់ភូមិ ឬឃុំ ដែលជានិច្ចកាល គឺជាកន្លែងដែលមានលក្ខណៈងាយស្រួលបំផុតសម្រាប់ NGO ចាប់ផ្តើម ។ ភាគច្រើននៃកិច្ចខិតខំប្រឹងប្រែងនៅដំណាក់កាលដំបូងទាំងនេះ ផ្តោតការយកចិត្តទុកដាក់តិចតួចបំផុតនៅថ្នាក់ស្រុក និងខេត្ត ដែលជួនកាលនៅមានបញ្ហាប្រឈមច្រើនសម្រាប់ NGO ក្នុងការចរចា ។ ដោយសារអាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ស្រុក និងខេត្ត មិនបានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាព NREM ជានិច្ចកាល ពួកគាត់តែងតែរារាំងគំនិតផ្តួចផ្តើមទាំងនេះ និងពុំមានឆន្ទៈទទួលស្គាល់ ព្រមទាំងគាំទ្រស្ថាប័ននានាដែលបានរៀបចំបង្កើតឡើងនៅថ្នាក់សហគមន៍ឡើយ ។ អាស្រ័យហេតុនេះ ប្រការនេះកាន់តែបង្ហាញអោយឃើញច្បាស់ថា ប្រសិនបើពុំមានការចូលរួមយ៉ាងពេញលេញពីរដ្ឋាភិបាលនោះទេ NREM ប្រកបដោយនិរន្តរភាពនឹងពុំអាចមានលទ្ធភាពប្រព្រឹត្តទៅបានឡើយ ។

## កម្មវិធីសិលា និងអភិបាលកិច្ចវិមជ្ឈការ

ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសកម្ពុជា ចែកចេញជា៤កំរិត : នៅថ្នាក់ជាតិមានក្រសួងពាក់ព័ន្ធនានា នៅថ្នាក់ខេត្តមានខេត្តចំនួន ២០ និងក្រុងចំនួន៤ ដែលបែងចែកចេញជា ១៨៥ស្រុក និង ១៦២១ឃុំ-សង្កាត់ ដែលជារដ្ឋបាលថ្នាក់ទាបបំផុត ។ ក្រសួងមហាផ្ទៃតែងតាំងអភិបាលដែលមាននាទីគ្រប់គ្រង ខេត្ត-ក្រុង និងស្រុក ។

រយៈពេលជាច្រើនឆ្នាំនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍បានបង្កើតអោយមានតម្រូវការក្នុងការកសាងសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាលលើការរៀបចំផែនការអភិវឌ្ឍន៍ចម្រុះ កៀងគរ និងគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងការកែលំអអោយកាន់តែប្រសើរឡើងនូវសុខុមាលភាពសេដ្ឋកិច្ច-សង្គមរបស់ប្រជាពលរដ្ឋ ។ កត្តាទាំងនេះ បានបង្កើតអោយមានកម្មវិធីអភិបាលកិច្ចវិមជ្ឈការដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ពោលគឺកម្មវិធីសិលា ។

នៅឆ្នាំ១៩៩៦ ដំណាក់កាលទីមួយនៃកម្មវិធីសិលា[២] បានប្រកាសចាប់ផ្តើមដោយរាជរដ្ឋាភិបាលកម្ពុជា ថាជាកម្មវិធីសាកល្បងលើគំរូនៃការពង្រឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ។ កម្មវិធីនេះ ផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើអភិបាលកិច្ច

---

[២] សិលា គឺជាកម្មវិធីដែលផ្តល់ការគាំទ្រដោយប្រទេសអ្នកផ្តល់ជំនួយពហុភាគី ដល់រាជរដ្ឋាភិបាលកម្ពុជា ។ មូលនិធិនានាត្រូវបានផ្តល់តាមរយៈ UNDP/UNOPS ។ គម្រោង CARERE គឺជាគម្រោងគាំទ្រកម្មវិធីសិលា និងឧបត្ថម្ភដោយ UNDP ។

វិមជ្ឈការសំដៅកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងដំណាក់កាលទីមួយរបស់ខ្លួន កម្មវិធីនេះបានទទួលការគាំទ្រពីគម្រោង CARERE[3] ក្រោមការឧបត្ថម្ភដោយ UNDP ។

កម្មវិធីសិលា កសាងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់មូលដ្ឋាន ដើម្បីគាំទ្រដល់ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៃការអភិវឌ្ឍនៅមូលដ្ឋាន ។ សហគមន៍[៤] ត្រូវបានផ្តល់អោយនូវទម្រង់ការនានា និងការកសាងសមត្ថភាពដើម្បីរៀបចំបង្កើតឡើងនូវផែនការអភិវឌ្ឍន៍ឃុំ (CDP) ។

នៅក្នុងពេលជាមួយគ្នានេះដែរ មូលនិធិវិនិយោគខេត្ត (PIF) ក៏ត្រូវបានបែងចែកទៅអោយខេត្តដើម្បីផ្តល់សេវាកម្មតាមរយៈមន្ទីរជំនាញនានា ទៅដល់សហគមន៍មូលដ្ឋានដើម្បីឆ្លើយតបនឹង CDP របស់ពួកគេ ។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (PRDC) ជាអ្នកគ្រប់គ្រងកម្មវិធីនេះនៅថ្នាក់ខេត្ត ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ត្រូវបានផ្តល់ផងដែរនូវមូលនិធិអភិវឌ្ឍន៍ឃុំ (CDF) ដើម្បី អនុវត្តគម្រោងការនានា ដោយផ្អែកទៅលើ CDP របស់ខ្លួនផងដែរ ។

កម្មវិធីសិលាគាំទ្រវិធីសាស្រ្តពហុវិស័យសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋានដែលមាន PRDC ដើរតួនាទីជាអ្នកសម្របសម្រួល ។ នេះជាកម្មវិធីពង្រឹងស្ថាប័នអភិបាលកិច្ចមូលដ្ឋាន នៅក្នុងបរិបទនៃការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ (គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឆ្នាំ២000 ទំព័រទី៩ ។

បទពិសោធន៍នៅថ្នាក់ខេត្ត និងឃុំត្រូវបានរាយការណ៍មកថ្នាក់ជាតិវិញ ដើម្បីជួយដល់ពួកគេកសាងគោលនយោបាយនានាស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។ គោលការណ៍គន្លឹះសំខាន់ៗចំនួន ៤ គឺ ការពិភាក្សា ភាពច្បាស់លាស់ កិច្ចព្រមព្រៀង និងការគោរពច្បាប់ ផ្តល់នូវក្របខ័ណ្ឌសម្រាប់ការប្រាស្រ័យទាក់ទងនេះ (សូមអានជំពូកទី ១៧ ។

ដំណាក់កាលទី២នៃកម្មវិធីសិលា (២00១-២00៥ បានកំណត់នូវបញ្ហាអន្តរវិស័យចំនួនបី[៥] ដែលតម្រូវឱ្យមានការកសាងផែនការយុទ្ធសាស្រ្ត ។ នៅឆ្នាំ២00៣ កម្មវិធីសិលាបានចាប់ផ្តើមអនុវត្តនូវយុទ្ធសាស្រ្តបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន (NREM) របស់ខ្លួន ដែលជាបញ្ហាមួយក្នុងចំណោមបញ្ហាអន្តរវិស័យទាំងបី សំដៅសម្របសម្រួលដល់ការបញ្ជ្រាប NREM ប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ជាតិ (គោលនយោបាយ ថ្នាក់ខេត្ត (កម្មវិធី និងថ្នាក់ឃុំ (គម្រោង ។

---

[៣] CARERE គម្រោងស្តាបនា និងស្តារប្រទេសកម្ពុជាឡើងវិញ ។

[៤] បន្ទាប់ពីការបោះឆ្នោតជ្រើសរើសជាប្រវត្តិសាស្រ្តនាខែកុម្ភៈ ឆ្នាំ២00២មក ក្រុមប្រឹក្សាឃុំ-សង្កាត់ដែលបានជាប់ឆ្នោត ត្រូវបានបង្កើតឡើងជាស្ថាប័នអភិបាលកិច្ចនៅមូលដ្ឋាន ។

[៥] ការកាត់បន្ថយភាពក្រីក្រ យេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។

យុទ្ធសាស្ត្របញ្ជ្រាប NREM មានសមាសភាពបីសំខាន់ៗ :

- **ទស្សនទាន** ដែលចាត់ទុកថា NREM គឺជាបញ្ហានៃអភិបាលកិច្ច
- **របនាសម្ព័ន្ធ** ដែលត្រូវតែជាម្ចាស់នៃទស្សនទាន និងបំលែងទស្សនទានទាំងនេះទៅក្នុងផែនការ និងកម្មវិធីនានា
- **ប្រព័ន្ធ** ដែលតាមរយៈនេះ ការអនុវត្តនីគម្រោងការនានាត្រូវបានគ្រប់គ្រង ។

ដើម្បីសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រនៅថ្នាក់រដ្ឋបាលទាំងបីកម្រិតនេះរបស់រដ្ឋាភិបាល គម្រោងកំពុងផ្តោតការយកចិត្តទុកដាក់ដើម្បីបង្កើនការយល់ដឹង ការកសាងសមត្ថភាព ការទទួលយោបល់ និងការកៀងគរធនធាន ដើម្បីបញ្ជ្រាប NREM នៅក្នុងកម្មវិធីសិលា ។

នៅថ្នាក់មូលដ្ឋាន គម្រោងធ្វើការជាពិសេសជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយធ្វើការកសាងសមត្ថភាពរបស់ពួកគាត់ដើម្បីធ្វើការពិចារណា និងដាក់បញ្ចូលបញ្ហានៃ NREM ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ ។

នៅថ្នាក់ជាតិ គម្រោងនៅខេត្តរតនគីរី គឺជាគម្រោងនាំមុខគេក្នុងការអនុវត្តការងារ ស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (CBNRM ដែលបានដំណើរការនៅក្នុងក្របខ័ណ្ឌការងារនៃកម្មវិធីសិលា ដោយផ្តោតការយកចិត្តទុកដាក់លើ NREM និងវិមជ្ឈការ ។ បទពិសោធន៍ពីខេត្តរតនគីរី ត្រូវបានចែករំលែក និងប្រើប្រាស់ជាមូលដ្ឋានដើម្បីពង្រីកការសាកល្បងអំពីការបញ្ជ្រាប NREM ទៅខេត្តបីផ្សេងទៀត ។ មេរៀនដែលទទួលបានពីការសាកល្បងនេះ នឹងត្រូវដាក់បញ្ចូលក្នុងការពិគ្រោះយោបល់អំពីគោលនយោបាយនៅថ្នាក់ជាតិ ស្តីពី NREM នៅក្នុងកម្មវិធីសិលា ។

### ឧទាហរណ៍ស្តីពីការងារនៅក្នុងខេត្តរតនគីរី

នៅខេត្តរតនគីរី ម្ចាស់ដីសម្បទាន និងអ្នកកាន់កាប់ដីជាលក្ខណៈឯកជន ដែលមិនមែនជាជនជាតិដើមភាគតិចបានធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិច ដែលមានជីវិតរស់នៅពឹងផ្អែកទៅលើធនធានធម្មជាតិត្រូវទទួលរងនូវផលលំបាកធ្ងន់ធ្ងរ ។ មន្ត្រីរដ្ឋាភិបាល ចាត់ទុកខ្លួនឯងថា ជាអ្នកធានានូវតុល្យភាពរវាងផលចំណេញបុគ្គល តម្រូវការសហគមន៍ គោលនយោបាយ និងច្បាប់ជាតិ ដែលផ្តល់អំណាចដល់រដ្ឋាភិបាល ក្នុងការត្រួតពិនិត្យធនធានធម្មជាតិទាំងអស់នេះ ។ កន្លងមក តម្រូវការរបស់សហគមន៍មិនត្រូវបានទទួលដឹងឮ ឬមានការពិចារណាត្រឹមតិចតួចបំផុត ។ ប្រវត្តិនៃទំនាស់នានាអំពីធនធានមានលក្ខណៈវែងឆ្ងាយណាស់ ។ រូបភាពទី១ បង្ហាញពីបញ្ហាស្នូលមួយចំនួន ដែលបានកំណត់ដោយភាគីពាក់ព័ន្ធសំខាន់ៗនៅថ្នាក់មូលដ្ឋាន ខេត្ត និង NGO/IO នៅក្នុងសិក្ខាសាលាមួយ ។




*រូបភាពទី ១ : បញ្ហាទាក់ទងទៅនឹងទំនាស់នានាលើធនធាន*

ក្រោមកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានា កម្មវិធីសិលាគាំទ្រដោយ CARERE នៅក្នុងខេត្តរតនគិរី បានបង្កើតគម្រោងដែលផ្អែកលើបញ្ហាធនធានធម្មជាតិដែលមាននៅក្នុងខេត្ត ។ គម្រោងថ្មីស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ត្រូវបានដឹកនាំអនុវត្តដោយមន្ទីរបរិស្ថានខេត្ត ដែលទទួលមូលនិធិគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ (IDRC) តាមរយៈកម្មវិធីសិលា ។ គោលបំណងជាក់លាក់របស់គម្រោង CBNRM មានសង្ខេបនៅក្នុងរូបភាពទី ២ ។




*រូបភាពទី ២ : ទិដ្ឋភាពរួមនៃគម្រោង CBNRM ខេត្តរតនគិរី*

នៅក្នុងអំឡុងពេលនៃដំណើរការរបស់គម្រោង CBNRM សហគមន៍អាចមានលទ្ធភាពបង្ហាញនូវប្រព័ន្ធនៃការប្រើប្រាស់ដី និងការគ្រប់គ្រងធនធានធម្មជាតិតាមបែបប្រពៃណី ។ វិធីសាស្ត្រកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមត្រូវបានយកមកអនុវត្តក្នុងការធ្វើផែនទីកំនត់តំបន់ប្រើប្រាស់របស់សហគមន៍ ។

ដើម្បីអោយសហគមន៍នៅក្នុងតំបន់គោលដៅគម្រោង CBNRM ឈានទៅដល់ការគ្រប់គ្រងធនធានធម្មជាតិមានប្រសិទ្ធិភាព ប្រការសំខាន់គឺត្រូវតែមានការឯកភាពគ្នាលើទស្សនៈដែលថាសហគមន៍ជាម្ចាស់នៃការគ្រប់គ្រងធនធានតាមរយៈ

- ការមានការយល់ដឹងស្របគ្នា អំពីរបៀបប្រើប្រាស់ និងគ្រប់គ្រងធនធាន
- ការយល់ដឹងស្របគ្នា អំពីរបៀបប្រើប្រាស់ និងការចែកផលបានអំពីធនធានទាំងនេះ
- សន្តិសុខរយៈពេលយូរអង្វែងខាងសិទ្ធិលើកម្មសិទ្ធិ
- ការគាំទ្រពីអាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីជម្រុញការអនុវត្តលក្ខន្តិកៈ និងបទបញ្ជារបស់សហគមន៍

ដើម្បីឱ្យប្រការនេះអាចកើតឡើងបាន គម្រោងនេះត្រូវតែមានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ហើយត្រូវធ្វើការងារជាមួយរដ្ឋាភិបាល ។ វិធីសាស្ត្រនៅមូលដ្ឋានបែបនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើយុទ្ធសាស្ត្របញ្ជ្រាប NREM នៅក្នុងកម្មវិធីសិលា ។

## ខេត្តរតនគិរី : វិធីសាស្ត្រអភិបាលកិច្ចនៅថ្នាក់រដ្ឋបាលទាំងបីកម្រិត

ដើម្បីអាចធ្វើការងារ CBNRM បានប្រកបដោយជោគជ័យ គម្រោងនៅខេត្តរតនគិរីចាំបាច់ត្រូវអនុវត្តគម្រោងនៅថ្នាក់រដ្ឋបាលទាំងបីកម្រិត : ថ្នាក់ជាតិមាននាទីផ្តល់ការអនុម័តយល់ព្រមសំរាប់អនុវត្តសកម្មភាពគំរោង ថ្នាក់ខេត្តជាអ្នកអនុវត្តគម្រោង និងថ្នាក់ឃុំ ( សហគមន៍ ដែលជាក្រុមគោលដៅក្នុងការទទួលផលប្រយោជន៍ពីគម្រោង ។

**នៅថ្នាក់ជាតិ:** មានការប្រើប្រាស់វិធីសាស្ត្រពីរ ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាទាក់ទងទៅនឹង NREM ។ វិធីសាស្ត្រទី១: គឺការចូលរួមនៅក្នុងការគាំពារមតិដោយបង្កើតឡើងនូវបណ្តាញប្រាស្រ័យទាក់ទងជាមួយស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាល និងគណៈកម្មការនានា ក៏ដូចជាសង្គមស៊ីវិលផ្សេងៗផងដែរ ដែលជាប់ពាក់ព័ន្ធទៅនឹងការចរចាអំពីគោលនយោបាយ ។ វិធីសាស្ត្រទី២ : គឺការបង្កើនការយល់ដឹងសម្រាប់អ្នកធ្វើសេចក្តីសម្រេចអំពីគោលនយោបាយ ដោយនាំសមាជិកសហគមន៍ទៅជួបជាមួយអ្នកនយោបាយ ឬនាំអ្នកនយោបាយមកជួបសហគមន៍ដោយផ្ទាល់ ដើម្បីពិភាក្សាអំពីបញ្ហាកំពុងប្រឈម ។ គម្រោងនេះរួមជាមួយគម្រោងដទៃទៀត បានចាត់ចែងឱ្យមានវេទិកាពិភាក្សានេះឡើង ។

**នៅថ្នាក់ខេត្ត** : គម្រោងនេះបានជួយដល់ខេត្តក្នុងការរៀបចំគម្រោង ដោយមានការចូលរួមពី NGOs / IOs និងសហគមន៍និងបានផ្តល់ធនធានសម្រាប់ធ្វើការសិក្សានានា ។ គម្រោងបានធ្វើការងារក្នុងភាពជាដៃគូជាមួយគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត (PRDC) ដែលមានអភិបាលខេត្តជាប្រធាន និងប្រធានមន្ទីរពាក់ព័ន្ធជាសមាជិក ។ PRDC គឺជាតួអង្គសម្របសម្រួលថ្នាក់ខ្ពស់ជាងគេបង្អស់នៅក្នុងខេត្ត និងជាអ្នកសម្របសម្រួលរវាងអន្តរមន្ទីរ ដើរតួនាទីជាវេទិកាដែលមន្ទីរនានា ជុំវិញខេត្តអាចជួបប្រជុំគ្នា និងពិភាក្សាអំពីបញ្ហានៅក្នុងលក្ខខណ្ឌបើកចំហ និងស្មើភាពគ្នា និងធ្វើការសម្រេចរួមគ្នាផ្អែកលើគោលការណ៍ កម្មវិធីសិលា ។គម្រោងបានជួយដល់ខេត្តដោះស្រាយបញ្ហា NREM នានាដែលបានកើតឡើង ព្រមទាំងធ្វើការកែសម្រួលគម្រោងឱ្យស្របទៅតាមស្ថានភាព និងក្របខ័ណ្ឌច្បាប់ដែលបានផ្លាស់ប្តូរ ។

**នៅថ្នាក់សហគមន៍** : គម្រោងបានយល់អំពីសារៈសំខាន់ដែលសហគមន៍អាចបង្ហាញពីស្ថានភាពរបស់គេដោយខ្លួនឯងផ្ទាល់ និងចរចាអំពីសិទ្ធិទាំងឡាយរបស់ខ្លួន ។ ជាលទ្ធផលតាមរយៈដៃគូការងាររបស់ខ្លួន គម្រោងបានជួយដល់សហគមន៍រៀបចំផែនទី កំណត់តំបន់ប្រើប្រាស់តាមប្រពៃណី និងបង្កើតលក្ខន្តិកៈប្រើប្រាស់និងគ្រប់គ្រងតំបន់ទាំងនេះ ។ ការកសាងសមត្ថភាពបច្ចេកទេស និងការគាំទ្រ ត្រូវបានចាត់ចែងឱ្យមានជាប្រចាំ ដើម្បីឱ្យសហគមន៍អាចបង្ហាញព័ត៌មានទាំងនេះដល់អាជ្ញាធរខេត្តធ្វើការអនុម័ត និងជួយជម្រុញការអនុវត្តលក្ខន្តិកៈ ។ ទំនាក់ទំនងរវាងសហគមន៍ និងខេត្ត ក៏ត្រូវបានបង្កើតឡើងផងដែរ ។

## មេរៀនសំខាន់ៗស្តីពីអភិបាលកិច្ច និង CBNRM ពីខេត្តរតនគិរី

នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ឃុំ និងភូមិបានឆ្លងកាត់នូវដំណើរការកសាងផែនការពីរបែបខុសគ្នា ។ ដំណើរការទីមួយមានលក្ខណៈលំអៀងទៅរកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដំណើរការមួយផ្សេងទៀតផ្តោតជាសំខាន់ទៅលើបញ្ហារយៈពេលវែង ។

ដំណើរការទីមួយនៃការកសាងផែនការ ត្រូវបានស្គាល់ថា ជាដំណើរការកសាងផែនការ CDP/CIP (ពិភាក្សាខាងក្រោម មាននិន្នាការផ្តោតទៅលើគម្រោងវិនិយោគ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍សម្រាប់រយៈពេលខ្លី ឬមធ្យម ។ ដំណើរការ CBNRM ដែលផ្តោតលើដំណើរការជាមូលដ្ឋានគ្រឹះនោះ ជាវិធីសាស្ត្រដែលមានចក្ខុវិស័យរយៈពេលវែង មាននិន្នាការជួយអោយអ្នកភូមិឱ្យចេះដោះស្រាយបញ្ហាជាឫសគល់របស់ពួកគេ (ការទន្ទ្រានយកដីធ្លី ការវិវាទលើធនធាននានា បញ្ហានៃការចិញ្ចឹមជីវិត ។ នៅក្នុងដំណើរការ CBNRM ចំណងទាក់ទងរវាងប្រជាពលរដ្ឋជាមួយធនធានដីធ្លី ជលផល និងព្រៃឈើមានលក្ខណៈច្បាស់លាស់ណាស់ ក៏ប៉ុន្តែនៅក្នុងដំណើរកសាងផែនការផ្លូវការនៃ CDP/CIP តម្រូវការទាំងនេះមិនត្រូវបានដាក់បញ្ចូលឡើយ ។ នេះគឺជាមូលហេតុដែលកម្មវិធីសិលានៅក្នុងខេត្តរតនគីរី ផ្តោតការយកចិត្តទុកដាក់លើតម្រូវការពិចារណាអំពីការគ្រប់គ្រងធនធានធម្មជាតិថា ជាបញ្ហានៃអភិបាលកិច្ច ហើយធ្វើការគិតគូរដាក់បញ្ចូលនូវបញ្ហាបរិស្ថាន ទៅក្នុងដំណើរការកសាងផែនការ CDP/CIP (សូមអានជំពូកទី ១៤ ។ ផ្អែកតាមការសម្រេចបែបនេះ ក្រុមក៏បានធ្វើការពិសោធន៍រកវិធីច្របាច់បញ្ចូលគ្នានូវដំណើរការកសាងផែនការទាំងពីរ នេះហើយវិធីសាស្ត្របញ្ជ្រាប NREM បច្ចុប្បន្ននេះបានដកស្រង់យកមេរៀននានាទទួលបានពីអភិបាលកិច្ចនេះ ។

គម្រោងនៅខេត្តរតនគីរី នឹងមិនអាចមានឥទ្ធិពលនៅថ្នាក់ខេត្តបានទេ ប្រសិនបើគំរោងនេះមិនមែនជាផ្នែកមួយនៃរចនាសម្ព័ន្ធដែលទទួលស្គាល់ដោយរដ្ឋាភិបាល ។ ទោះបីជាការធ្វើការងារជាមួយរដ្ឋាភិបាលអាចយឺតយ៉ាវ និងមានការរំខានច្រើនក៏ដោយ តែការធ្វើបែបនេះអាចផ្តល់នូវលទ្ធផលដែលមាននិរន្តរភាពជាង ព្រមទាំងមានអានុភាពសម្រាប់រយៈពេលយូរអង្វែងផងដែរ ។

## អ្វីទៅជាការបញ្ជ្រាប NREM ?

ការចាប់ផ្តើមអនុវត្តការបញ្ជ្រាប NREM ត្រូវប្រើប្រាស់ឧបករណ៍មួយចំនួនជាមធ្យោបាយ ដើម្បីវិភាគដាក់បញ្ចូលបញ្ហាមូលហេតុ និងសំណើដំណោះស្រាយនានាទាក់ទងនឹង NREM ទៅក្នុងផែនការឃុំ-សង្កាត់ដែលមានស្រាប់ (CDP ។ ដំណើរការនេះត្រូវបានរៀបចំឡើង ដើម្បីអាចបញ្ចូលបញ្ហាបរិស្ថានជាអាទិភាពទៅក្នុង CDP ប្រសិនបើឃុំមានការចាប់អារម្មណ៍នៅក្នុងការដោះស្រាយបញ្ហាទាំងនេះ ។ គោលបំណងអភិវឌ្ឍន៍ទូទៅនៃគម្រោងបញ្ជ្រាប NREM គឺ :

*សម្រេចបាននូវការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព ធានាសន្តិសុខ និងសមធម៌នៃសិទ្ធិក្នុងការបន្តមានលទ្ធភាពប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ព្រមទាំងបង្កើតឱកាសនានា សម្រាប់សកម្មភាពសេដ្ឋកិច្ចទាំងឡាយ ទាក់ទងនឹងធនធានធម្មជាតិ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ ។*

ក្រុមប្រឹក្សាឃុំ ទទួលខុសត្រូវក្នុងការរៀបចំផែនការនៅក្នុងតំបន់រដ្ឋបាលរបស់ខ្លួន : ក្រុមប្រឹក្សាឃុំនីមួយៗរៀបចំ CDP ក្នុងរយៈពេលប្រាំឆ្នាំម្តង និងកម្មវិធីវិនិយោគឃុំបីឆ្នាំរំកិល (CIP ។ ទម្រង់ការនានាសម្រាប់ការបញ្ជ្រាប NREM នៅក្នុងក្រុមប្រឹក្សាឃុំកំពុងត្រូវបានអនុវត្តសាកល្បងនៅក្នុងឃុំចំនួន ៤០ នៅក្នុងខេត្តបី (ពោធិ៍សាត់ សៀមរាប និងក្រចេះ តាមរយៈកម្មវិធីសិលា ។ ដោយសារឃុំបានរៀបចំ CDP របស់ខ្លួនរួចហើយ ការសាកល្បងបាននឹងកំពុងប្រព្រឹត្តទៅជាមួយក្រុមប្រឹក្សា

ឃុំ-សង្កាត់ ចំនួន ៤០ ដើម្បីដាក់បញ្ចូលបញ្ហានៃ NREM នៅក្នុងដំណើរការ CIP របស់ពួកគាត់ ដែលអាចឱ្យអ្នកដែលមានលទ្ធភាពផ្តល់ជំនួយគាំទ្រ និងភ្នាក់ងាររដ្ឋាភិបាល ផ្តល់ការគាំទ្រដល់សកម្មភាពបរិស្ថានធម្មជាតិនានា ដូចជាការដាំដើមឈើ និងការរៀបចំសហគមន៍ជលផល ។ល។ តាមរយៈការចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក (DIW និងតាមរយៈការផ្តល់មូលនិធិវិនិយោគខេត្ត (PIF ។

ដើម្បីបញ្ជ្រាប NREM ក្រុមសម្របសម្រួលបច្ចេកទេស (TFT រួមមានសមាជិកជាមន្ត្រីមកពីមន្ទីរពាក់ព័ន្ធនានា នៅថ្នាក់ខេត្តធ្វើការងារជាមួយក្រុមសម្របសម្រួលថ្នាក់ខេត្ត និងស្រុក (PFT និង DFT ដែលមានតួនាទីទទួលខុសត្រូវជួយគណៈ-កម្មការផែនការ និងថវិកា (PBC នៃក្រុមប្រឹក្សាឃុំ-សង្កាត់រៀបចំផែនការ CIP ប្រចាំឆ្នាំ ។ ជួនកាល TFTs ធ្វើការដោយផ្ទាល់ជាមួយ PBCs បន្ទាប់មកធ្វើការជាមួយ PFTs ដើម្បីដាក់បញ្ចូល NREM ទៅក្នុងដំណើរការ CIP ហើយនៅពេលខ្លះទៀតផែនការទាំងពីរនេះអាចធ្វើឡើងនៅក្នុងពេលតែមួយ[៦] ។ រូបទី ៣ បង្ហាញពីរចនាសម្ព័ន្ធនៃការអនុវត្តការបញ្ជ្រាប NREM ។




*រូបទី៣ : ការបញ្ជ្រាប NREM និងរចនាសម្ព័ន្ធអភិបាលកិច្ចដែលមានស្រាប់*

[៦] វាក្យខ័ណ្ឌទាំងពីរខាងលើនេះដកស្រង់ចេញពី Marschke 2004 ។

ឃុំ និងភូមិ អាចធ្វើការងារស្តីពី NREM ហើយនៅក្នុងពេលជាមួយគ្នានេះដែរ ដោយច្របាច់បញ្ចូលការងារនេះទៅក្នុងវចនាសម្ព័ន្ធអភិបាលកិច្ច ។ យន្តការគាំទ្រផ្លូវច្បាប់ និងដំណើរការលម្អិតពន្យល់ពីការរៀបចំគណៈកម្មការ NREM និងគណៈ-កម្មការពាក់ព័ន្ធផ្សេងទៀត ព្រមទាំងថាតើគណៈកម្មការ NREM ឃុំទាក់ទងនានាដែលមានស្រាប់ (ភាគច្រើននៃគណៈកម្មការទាំងនេះ បានបង្កើតឡើងរួចមកហើយនៅក្នុងប្រទេសកម្ពុជា ដូចជាគណៈកម្មការសហគមន៍ព្រៃឈើ និងនេសាទ ។ល។ អាចសម្របសម្រួលឱ្យស៊ីសង្វាក់គ្នាបែបណាជាមួយដំណើរការនេះ ។ គម្រោង ឬសកម្មភាពនានា ដែលបានកំនត់ជាអាទិភាពនៅក្នុង CDP ឬ CIP តាមរយៈដំណើរការបញ្ជ្រាបនេះ បានអនុវត្តជាបន្តបន្ទាប់ដោយគណៈកម្មការ NREM ឃុំ ដោយប្រើប្រាស់មូលនិធិ NREM ឃុំ-សង្កាត់បន្ថែម ។ សិក្ខាសាលាសមាហរណកម្មស្រុក ផ្តល់នូវការគាំទ្របន្ថែមទៀតពីមន្ទីរជំនាញពាក់ព័ន្ធ NGOs/IOs និងវិស័យឯកជន ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តគម្រោង ឬសកម្មភាពទាំងនេះផងដែរ ។

តាមរយៈ CC/PBC គំនិតនានាត្រូវបានបំផុសឡើង ស្តីពីការប្រើប្រាស់មូលនិធិនេះ (តារាងទី ១ បង្ហាញពីឧទាហរណ៍ជ្រើសរើសមួយចំនួន ។

| NREM US$ ១០០០ | ផែនការបែងចែក ឬអនុវត្ត |
| --- | --- |
| ឃុំមួយបានណែនាំពីប្រព័ន្ធឥណទាន សម្រាប់គ្រួសារជ្រើសរើសមួយចំនួន ដើម្បីប្រមូលដើមល្ពាក់ដែលដុះនៅក្នុង និងតាមភ្លឺស្រែមកត្បាញជាកន្ទេល ។ ការប្រមូល និងការកែឆ្នៃដើមល្ពាក់ គឺជាជម្រើសមួយនៅក្នុងការជំនួសឱ្យការដុតចោល និងដើម្បីកាត់បន្ថយការពឹងផ្អែកទាំងស្រុងលើការធ្វើស្រែអាស្រ័យលើទឹកភ្លៀង ។ បច្ចុប្បន្នក្រុមនេះកំពុងស្វែងរកទីផ្សារ ។ | បានអនុវត្តរួចហើយ |
| ដាំឈើហូបផ្លែ ជាមធ្យោបាយមួយជំនួសឱ្យការកាប់ដើមឈើហូបផ្លែព្រៃនៅក្នុងព្រៃឈើ | បានអនុវត្តរួចហើយ |
| ពង្រឹងកិច្ចការបង្កើនការយល់ដឹងនៅថ្នាក់ភូមិ ជុំវិញបញ្ហា NREM | បានអនុវត្តរួចហើយ |
| បង្កើតថ្មីនូវសហគមន៍ព្រៃឈើ និងនេសាទ និងពង្រឹងសហគមន៍ដែលមានស្រាប់ | កំពុងបន្តអនុវត្ត |
| កសិរុក្ខកម្ម ការធ្វើជីកំប៉ុស្ត ដើម្បីកែលំអជីជាតិដី | កំពុងបន្តអនុវត្ត |

យើងមានសុទិដ្ឋិនិយម ក្នុងការរង់ចាំមើលនូវលទ្ធផលជាវិជ្ជមានពីសហគមន៍រៀបចំគ្រោងការ និងអនុវត្តនូវយុទ្ធសាស្ត្ររបស់ពួកគេដោយខ្លួនឯងផ្ទាល់ជុំវិញសកម្មភាព NREM និងការបង្កើនការយល់ដឹង ។ ដូច្នេះប្រការសំខាន់បំផុតគឺ អ្នកសម្របសម្រួលទាំងអស់គ្នាត្រូវផ្តល់ការគាំទ្រដល់ដំណើរការនេះប្រកបដោយវិចារណញ្ញាណ ។ បទពិសោធន៍ពីខេត្តរតនគីរីបានបង្ហាញថាសហគមន៍ខ្លួនឯងត្រូវការឱ្យមានការជួយជ្រោមជ្រែងបន្ថែម ដើម្បីកែលំអនូវសមត្ថភាពរបស់ពួកគេឱ្យមានលទ្ធភាពអាចធ្វើការចរចាបាន ។ គម្រោងបញ្ជ្រាប NREM កំពុងតែធ្វើការងារនេះ ដើម្បីផ្តល់ការគាំទ្រអោយបានគ្រប់គ្រាន់ដល់ឃុំ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែទំហំ និងវិសាលភាពនៃតំបន់គម្រោងមានលក្ខណៈធំធេង ការប្រើប្រាស់នូវវិធីសាស្ត្រដែលមានលក្ខណៈដូចគ្នានឹងវិធីសាស្ត្រដែលប្រើប្រាស់នៅខេត្តរតនគីរី ពុំអាចធ្វើបានឡើយ ។ គម្រោងនេះកំពុងធ្វើការងារ ដើម្បីពង្រឹងការសម្របសម្រួលឱ្យកាន់តែមានលក្ខណៈប្រសើរឡើង និងប្រកបដោយនិរន្តរភាព ។

## ការឆ្លុះបញ្ចាំងអំពីការអនុវត្តដំណើរការ NREM

ការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាប NREM នៅក្នុងកម្មវិធីសិលា បានដំណើរការជាផ្លូវការអស់រយៈពេលជិតពីរឆ្នាំហើយ ។ ការបញ្ជ្រាប NREM តម្រូវឱ្យមានអភិបាលកិច្ចល្អនៅគ្រប់កម្រិតទាំងអស់ ព្រោះថាបញ្ហា NREM ជាបញ្ហាអន្តរវិស័យ ដែលតម្រូវឱ្យមានកិច្ចសហការល្អរវាងវិស័យនានា ដើម្បីធានាដល់ការអនុវត្តដោយក្រុមចម្រុះមកពីស្ថាប័នពាក់ព័ន្ធ ។ នៅក្នុងអំឡុងពេលនៃការអនុវត្ត វិធីសាស្ត្រចម្រុះវិស័យត្រូវបានយកមកប្រើប្រាស់ដែលមានបុគ្គលិកមកពីក្រសួង និងមន្ទីរពាក់ព័ន្ធចូលរួមបង្កើតជាក្រុមស្នូលមួយ ដើម្បីអនុវត្តយុទ្ធសាស្ត្រ NREM ។ ក្រៅពីនេះមានបញ្ហាសំខាន់ៗមួយចំនួនដែលកើតឡើងនៅក្នុងរយៈពេលកន្លងមកនេះ និងមានពិពណ៌នាលម្អិតដូចខាងក្រោម ៖

### បញ្ហានៃការកសាងសមត្ថភាពជុំវិញការបញ្ជ្រាប NREM នៅក្នុងអភិបាលកិច្ច

- ការកសាងសមត្ថភាពសម្រាប់មន្ទីរ ដែលមិនមានអាណត្តិទាក់ទងដោយផ្ទាល់ទៅនឹង NREM គឺជាការលំបាក ។
- ការបញ្ជ្រាប NREM ទៅក្នុងផែនការនៅទូទាំងគ្រប់វិស័យទាំងអស់ ដោយគ្រាន់តែធ្វើទៅតាមដំណើរការរៀបចំផែនការដែលមានបទដ្ឋានជាក់លាក់ណាមួយមិនមែនជាការងាយស្រួលឡើយ ។
- ការសម្របសម្រួលសកម្មភាពនានានៅគ្រប់វិស័យ និងការជម្រុញលើកទឹកចិត្តអោយមានការពិគ្រោះយោបល់តាមរយៈខ្សែទទឹងរវាងវិស័យ និងវិស័យមានលក្ខណៈស្មុគស្មាញ ដែលចាំបាច់តម្រូវអោយមានតួអង្គសម្របសម្រួលមួយ ( ដើម្បីសម្រុះសម្រួលការលំបាក ឬបញ្ហានានា ។
- ជាទូទៅរចនាសម្ព័ន្ធរដ្ឋាភិបាលមានលក្ខណៈជាការចាត់ចែងតាមបែបបញ្ជាពីលើចុះក្រោម ដូច្នេះត្រូវការពេលវេលាសមស្របដើម្បីកសាងសមត្ថភាពឱ្យចេះស្តាប់យោបល់របស់សហគមន៍ ។
- ជាទូទៅទម្រង់បែបបទនានារបស់រដ្ឋាភិបាលក្នុងការប្រាស្រ័យទាក់ទងគ្នាតែងតម្រូវអោយមានការគូសជាសញ្ញាក្នុងប្រអប់ ឬក៏បំពេញទិន្នន័យទៅក្នុងទម្រង់បែបបទដែលមានលក្ខណៈងាយ ប៉ុន្តែNREM ត្រូវការចាំបាច់អោយអ្នកសម្របសម្រួលវិភាគពីស្ថានភាព និងជួយដល់សហគមន៍ឱ្យឈានទៅរកការធ្វើសេចក្តីសម្រេចមួយដែលមានការពិចារណាហ្មត់ចត់ ដែលប្រការនេះតម្រូវអោយបុគ្គលិកខិតខំប្រឹងប្រែងបន្ថែមទៀត ។
- ការបញ្ជ្រាប NREM ទៅក្នុងអភិបាលកិច្ច ត្រូវការចាំបាច់នូវគោលនយោបាយ និងច្បាប់ដែលពិចារណាពីតម្រូវការរបស់សហគមន៍ ។

### ការកសាងសមត្ថភាពជាមួយក្រុម NREM-TFT

- អ្នកសម្របសម្រួលពុំទាន់មានការប៉ិនប្រសប់ក្នុងការអនុវត្តវិធីសាស្ត្រដែលមានការចូលរួមនៅឡើយ ។
- មានការខ្វែងគំនិតគ្នានៅក្នុងក្រុម TFTs រវាងសមាជិកដែលចង់អនុវត្តទាំងស្រុងតាមគោលការណ៍ណែនាំ ( ឯកសារបណ្តុះបណ្តាល និងដំណើរការ CIP និងសមាជិកដែលចង់ធ្វើការពិសោធន៍ និងពិចារណាលើអ្វីដែលគួរធ្វើ ។
- ជារឿយៗប្រធានក្រុមមិនបានផ្តល់នូវការជួយគាំទ្រអ្នកធ្វើការងារនៅមូលដ្ឋានឱ្យបានគ្រប់គ្រាន់នៅឡើយទេ ដោយសារតែតែមានការចាប់អារម្មណ៍ច្រើន ( ឬកិច្ចការច្រើន ពាក់ព័ន្ធនឹងការសរសេរឯកសារទាក់ទងនឹងដំណើរការបែបនេះ ។

- អ្នកសម្របសម្រួលទំនងជាត្រូវប្រឈមនឹងការលំបាកក្នុងការជម្រុញលើកទឹកចិត្តអោយមានការគាំទ្រគម្រោងប្លែកៗ សម្រាប់ឃុំ ។ ជាទូទៅ អ្វីដែលឃុំមួយបានលើកឡើងច្រើនតែចម្លងយកតាមអ្វីដែលអនុវត្តក្នុងឃុំផ្សេងៗទៀត ។ តើនេះដោយសារតម្រូវការនៅក្នុងឃុំនោះមានលក្ខណៈដូចគ្នា ឬមួយក៏ដោយសារតែអ្នកសម្របសម្រួល មិនបានធ្វើការសាកសួរដេញដោលឱ្យបានគ្រប់គ្រាន់ដើម្បីឈានទៅបង្ហាញពីតម្រូវការពិតប្រាកដរបស់ឃុំនីមួយៗឬយ៉ាងណា ?
- នៅមានចំណងទាក់ទងជាច្រើនជាមួយបញ្ហាផលប្រយោជន៍បុគ្គល ។ អ្នកបណ្តុះបណ្តាលអាចធ្វើលំៗអោយរួចតែពីដៃ ជាជាងធានាឱ្យដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព ។
- ការបណ្តុះបណ្តាលគឺមិនមែនស្តីអំពីការផ្តល់នូវដំណោះស្រាយនោះទេ ក៏ប៉ុន្តែគឺស្តីអំពីការផ្តល់នូវបរិយាកាសសម្រាប់ការរៀនសូត្រដែលគំនិតនានា ត្រូវបានលើកយកមកពិភាក្សា ។ នេះគឺជាវិធីសាស្ត្រថ្មី ហើយត្រូវការពេលវេលាសមស្របដើម្បីឱ្យទាំងអ្នកសម្របសម្រួល និងឃុំមើលឃើញនូវតម្លៃពិតៗនៃវិធីសាស្ត្រនោះ ។
- ភាគច្រើននៃបញ្ហាទាំងនេះ មានការទាក់ទងទៅនឹងកង្វះភាពទន់ភ្លន់ ក្របខ័ណ្ឌពេលវេលាកំណត់នៃដំណើរការ CIP មានន័យថា អ្នកសម្របសម្រួលមិនមានអារម្មណ៍ថាពួកគេត្រូវមានការបត់បែនទៅតាមស្ថានភាព ដើម្បីធ្វើអោយប្រាកដថា មានការពិភាក្សាអំពីការចិញ្ចឹមជីវិតនោះឡើយ ។
- ដំណើរការ និងក្រុមប្រឈមនឹងការលំបាកពីរបែប ពោលគឺ ប្រសិនបើពួកគេបំពេញការងារនៅក្នុងក្របខ័ណ្ឌដែលកំនត់ឱ្យនោះ ការច្នៃប្រឌិតប្រកបដោយវិចារណញាណមួយចំនួននឹងត្រូវបាត់បង់ ប៉ុន្តែប្រសិនបើគេធ្វើការងារនៅក្រៅក្របខ័ណ្ឌនេះវិញ ភាពមិនចុះសម្រុងគ្នារវាងក្រុមអាចនឹងកើតឡើង ហើយការបញ្ជ្រាបបញ្ហានៃ NREM ទៅក្នុងផែនការ CIP អាចត្រូវប្រឈមនឹងការលំបាកកាន់តែខ្លាំងឡើង ។

**បញ្ហាប្រឈមនៅក្នុងការកសាងសមត្ថភាពជុំវិញការបញ្ជ្រាប NREM នៅក្នុងសហគមន៍**

- តំណាងសហគមន៍ត្រូវមានចំណាប់អារម្មណ៍ទទួលខុសត្រូវ ចំពោះអ្នកដែលបានបោះឆ្នោតឱ្យ ។
- ការបញ្ជ្រាប NREM ទៅក្នុងផែនការនៅទូទាំងគ្រប់វិស័យទាំងអស់ ដោយគ្រាន់តែធ្វើតាមបទដ្ឋាននៃដំណើរការកសាងផែនការជាក់លាក់ណាមួយមិនមែនជាការងាយស្រួលនោះឡើយ ។
- សមាជិកសហគមន៍ភាគច្រើនខ្វះការជឿទុកចិត្ត ក្នុងការពិភាក្សាបញ្ហាជាមួយអាជ្ញាធរ ដោយសារតែពួកគេខ្វះនូវចំណេះដឹងអំពីសិទ្ធិ ច្បាប់ យន្តការច្បាប់ ។ល។ នេះគឺជាបញ្ហាប្រឈមពិសេសមួយ នៅពេលដែលដៃគូការងាររបស់ខ្លួនមិនចេះអក្សរ ។
- សហគមន៍មូលដ្ឋានពិបាកយល់អំពីការបញ្ជ្រាប NREM ពាក្យគន្លឹះក្នុងច្បាប់/ទស្សនទានរបស់ច្បាប់ ដោយសារតែបញ្ហាខាងផ្នែកភាសា ។ ជារឿយៗប្រជាពលរដ្ឋមូលដ្ឋានចង់ឃើញនូវផលប្រយោជន៍ភ្លាមៗ ដោយមិនទទួលស្គាល់ថា ផលប្រយោជន៍ទាំងនេះត្រូវការពេលវេលាសមស្របគ្រប់គ្រាន់ដើម្បីអនុវត្តសំណើដំណោះស្រាយនានានោះឡើយជាពិសេសចំពោះ NREM ។ ការពិភាក្សាអំពីទ្រឹស្តី ធ្វើអោយសហគមន៍មានការធុញទ្រាន់ ក៏ប៉ុន្តែវាមានសារៈសំខាន់សំរាប់ការយល់ដឹងរបស់ពួកគាត់ ។

**បទពិសោធន៍អំពីការអនុវត្តន៍ការបញ្ជ្រាប NREM រយៈពេលពីរឆ្នាំ**

ដោយសារតែការបញ្ជ្រាប NREM នៅក្នុងកម្មវិធីសិលាទើបតែបានអនុវត្តអស់រយៈពេលជិតពីរឆ្នាំប៉ុណ្ណោះ ការធ្វើសំយោគអំពីបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍បែបនេះ ដូចជាប្រញាប់ប្រញាល់បន្តិចហើយ ។ ទោះជាយ៉ាងណា ក៏ដោយ បទពិសោធន៍ និងបញ្ហាប្រឈមនានាអាចមានដូចខាងក្រោមនេះ :

**ការគាំទ្រអន្តរវិស័យ**

ការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ត្រូវតែបានបញ្ចូលទៅក្នុងគ្រប់ស្ថាប័នទាំងអស់ រួមទាំងស្ថាប័នដែល មានអាណត្តិពុំទាក់ទងដោយផ្ទាល់ជាមួយ NREM ក៏ដោយ ។

**គោលនយោបាយថ្មី**

ការបង្កើតគោលនយោបាយជាតិ ដែលទទួលស្គាល់តម្រូវការផ្នែកច្បាប់សម្រាប់អភិបាលកិច្ចមូលដ្ឋាន គឺជាជំហានដ៏មានសារៈសំខាន់នៅក្នុងការធ្វើវិមជ្ឈការ និងការគ្រប់គ្រងធនធានធម្មជាតិផងដែរ ។

**វិធីសាស្ត្របត់បែនទៅតាមកាលៈទេសៈ**

ការបញ្ជ្រាប NREM/CCB-NREM ទៅក្នុងដំណើរការកសាងផែនការរដ្ឋាភិបាល ( ទាំងនៅថ្នាក់ជាតិ ខេត្ត និងផែនការអភិវឌ្ឍន៍ឃុំ មិនគួរអនុវត្តដូចជាយន្តការរឹងស្ទូក ដោយគ្រាន់តែអនុវត្តដោយគ្មានការច្នៃប្រឌិត និងធ្វើតាមតែរចនាសម្ព័ន្ធដែលបានបង្កើតមកនោះឡើយ ។

**មធ្យោបាយថ្មីនៅក្នុងការធ្វើការងារត្រូវការពេលវេលា**

របៀបធ្វើការតាមបែបបទថ្មីដែលត្រូវការពេលវេលាដើម្បីស្វែងយល់អំពីការផ្លាស់ប្តូរអាកប្បកិរិយាពិតជាលំបាកជាពិសេស នៅក្នុងបរិបទវប្បធម៌នៃប្រទេសកម្ពុជា ដែលការសួរដេញដោលចំពោះប្រធានរបស់ខ្លួនមិនត្រូវបានលើកទឹកចិត្តឡើយ ។ អាស្រ័យទៅតាមពេលវេលា និងវិធីសាស្ត្រសមស្រប អ្នកដែលមានអំណាចអាចទទួលស្គាល់ពីផលប្រយោជន៍ នៃការចែករំលែក "អំណាច" ក៏ប៉ុន្តែការផ្លាស់ប្តូរនូវអាកប្បកិរិយាបែបនេះ អាចកើតមានទៅបាន លុះណាតែដៃគូការងាររបស់យើងយល់ និងឱ្យតម្លៃទៅលើវិធីសាស្ត្រនោះ ។

ការបញ្ជ្រាប NREM ទៅក្នុងដំណើរការកសាងផែនការនៅថ្នាក់មូលដ្ឋាន (ដំណើរការ CDP/CIP) គឺជាជំហានដ៏ធំធេងទីមួយ ។ វិធីសាស្ត្រដែលបានប្រើគឺជាវិធីសាស្ត្រធ្វើសំយោគ ហើយដែលនៅក្នុងករណីនេះ នៅជុំវិញបញ្ហានៃ NREM ដែលជាវិធីសាស្ត្រមួយធ្វើអោយប្រាកដថាបញ្ហានៃNREM ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការមូលដ្ឋាន ។

ការជ្រើសរើសយកមកប្រើនូវវិធីសាស្ត្រ PRA បានជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការវិភាគស្ថានភាព NRM របស់ពួកគេ ។ ក្របខ័ណ្ឌដែលប្រើប្រាស់បច្ចុប្បន្ននេះមានការដាក់កំហិតចំពោះជម្រើសនានា ដោយសារតែមិនមានភាពបត់បែន និងផ្តោតសំខាន់តែលើហេដ្ឋារចនាសម្ព័ន្ធ ប្រើប្រាស់ពេលវេលាតិចតួច ជាដំណើរការដែលផ្តោតលើលទ្ធផល ហើយដែលមានការយកចិត្តទុកដាក់តិចតួចទៅលើដំណើរការ ។ ផ្ទុយទៅវិញ CBNRM មានគោលដៅជាវិធីសាស្ត្រ ដែលផ្អែកជាចំបងទៅលើដំណើរការជាសំខាន់ ដែលនេះអាចជាបញ្ហាប្រឈមនៅក្នុងការធ្វើឱ្យវិធីសាស្ត្រទាំងពីរនេះមានតុល្យភាព ។ ការពិចារណាមួយសម្រាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺការគិតគូរថាតើពួកគាត់អាចចាប់ផ្តើមដោះស្រាយបញ្ហា NREM ដោយខ្លួនពួកគាត់ផ្ទាល់តាមរបៀបណា ហើយដែលលទ្ធភាពមួយក្នុងចំណោមលទ្ធភាពជាច្រើនផ្សេងទៀតប្រហែលជាអាចត្រូវធ្វើតាមរយៈការផ្តល់នូវការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុ ។ ការផ្តល់នូវការលើកទឹកចិត្តបែបនេះអាចឱ្យសហគមន៍មានលទ្ធភាពធ្វើជាម្ចាស់លើដំណើរការបានច្រើនជាងហើយអាចជាសក្តានុពលដែលនឹងនាំឱ្យការគ្រប់គ្រងដោយសហគមន៍អាចកើតមានឡើងបាន ។ គម្រោង CBNRM ភាគច្រើនជា

គម្រោងតូចៗមានតំបន់គោលដៅគ្របដណ្តប់តិចតួច ដែលអាចមានលទ្ធភាពឱ្យពួកគេផ្តោតការយកចិត្តទុកដាក់លើការ ប្រើប្រាស់នូវវិធីសាស្ត្រដែលផ្អែកសំខាន់លើដំណើរការបាន ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្របញ្ជ្រាប NREM មានតំបន់គោលដៅក្នុងឃុំជាច្រើន ហើយដែលនេះគឺជាបញ្ហាប្រឈមមួយនៅក្នុងការសម្របសម្រួល ។ បញ្ហាគន្លឹះស្ថិតនៅត្រង់ថា តើត្រូវធ្វើការបញ្ជ្រាប NREM ដូចម្តេចនៅក្នុងក្របខ័ណ្ឌធំទូលាយ ( ឃុំគោលដៅច្រើន ដោយធានាឱ្យដំណើរការឆ្លុះបញ្ចាំងអាចកើតឡើងបាន ។

## ការគ្រប់គ្រងមូលនិធិ

គម្រោងភាគច្រើន ត្រូវបញ្ចប់នៅពេលដែលវដ្តនៃការផ្តល់មូលនិធិបានបញ្ចប់ទៅដែរ ។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីសិលាកំពុងបង្កើនការយល់ដឹងពី NREM ក្នុងគោលបំណងរំពឹងទុកថាក្រុមប្រឹក្សាឃុំ នឹងយកចិត្តទុកដាក់ធ្វើការពិចារណាបញ្ហាបរិស្ថាននៅក្នុងរយៈពេលយូរអង្វែង ។ ទោះបីជាគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាគម្រោងសាងសង់ផ្លូវ និងសាលារៀនអាចធ្វើការចាត់អាទិភាពជាតម្រូវការបន្ទាន់ក៏ដោយ នាពេលអនាគត គម្រោង NREM ក៏អាចត្រូវបានពិចារណាផងដែរ ។

ការចំណាយថវិកាមិនត្រឹមត្រូវ ឬក៏មិនសមស្រប ក៏អាចជាគ្រោះថ្នាក់មួយផងដែរ ពិសេសនៅពេលបែងចែកថវិកាទៅឱ្យមន្ទីរពាក់ព័ន្ធ ដែលជាអ្នកផ្តល់សេវាកម្មឆ្លើយតបចំពោះគម្រោងនានារបស់ឃុំ ។ នៅក្នុងខេត្តរតនគីរី ក្រុមអ្នកសម្របសម្រួលធ្វើការងារយ៉ាងជិតស្និទ្ធជាមួយមន្ទីរនានា ដើម្បីធានាថាដំណើរការនេះអាចប្រព្រឹត្តទៅបាន ដោយផ្តល់នូវការគាំទ្រដល់ការអនុវត្តន៍គម្រោង និងការគ្រប់គ្រងថវិកាបានល្អ ។ ជាទូទៅមន្ទីរនានា ដែលផ្តល់ការគាំទ្រដល់គំនិត និងគម្រោងថ្មីៗទាំងឡាយ ជារឿយៗអាចមានគំនិតតិចតួចក្នុងការសម្របសម្រួល និងអនុវត្តគម្រោងទាំងនោះ ដែលអាចជាហេតុបណ្តាលឱ្យបាត់បង់ថវិកាដ៏មានតម្លៃទាំងនេះ ។ សំនួរគន្លឹះ ដែលកើតមានឡើងគឺ តើ PIF បានធ្វើការបែងចែកប្រកបដោយប្រសិទ្ធភាពដែរឬទេ ដើម្បីធ្វើការបញ្ជ្រាប NREM ប្រសិនបើមិនមានការតាមដានគាំទ្រឱ្យបានជិតដល់គ្រប់គ្រាន់ ថាតើមូលនិធិទាំងនេះបាននឹងកំពុងចំណាយបែបណា ?

## ការកសាងផែនការដើម្បីអោយមាននិរន្តរភាព

ការដែលគ្រាន់តែកសាងផែនការឃុំនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ ។ ដំណើរការតស៊ូមតិ និងដំណើរការដោះស្រាយវិវាទនានា ត្រូវតែដាក់បញ្ចូលទៅក្នុងគ្រប់វិធីសាស្ត្រអភិបាលកិច្ច ហើយដែលនេះគឺជាចំណុចខ្វះខាតចំពោះគម្រោងបញ្ជ្រាប NREM នៅក្នុងកម្មវិធីសិលា ។ ដំណើរការ ដូចដែលបានចាត់ចែងពេលបច្ចុប្បន្ននេះ គាំទ្រដល់ការកសាងផែនការនៅថ្នាក់ឃុំ និងអនុវត្តតម្រូវការជាអាទិភាពនានា ដោយមិនបានផ្តល់នូវយន្តការផ្សេងៗសម្រាប់ដោះស្រាយវិវាទនានា ដែលអាចកើតមានឡើងនោះឡើយ ។ ការរួមបញ្ចូលគ្នានូវវិធីសាស្ត្រទាំងពីរនេះ អាចជាតម្រូវការចាំបាច់ដើម្បីដោះស្រាយនូវការវិវាទទាំងឡាយដែលអាចកើតមានឡើង ។ នៅខេត្តរតនគីរី ផែនទីត្រូវបានប្រើប្រាស់ជាភស្តុតាងសម្រាប់ដោះស្រាយការវិវាទលើបញ្ហាដីធ្លី ឬ NREM ដើម្បីធ្វើការចរចាជាមួយអាជ្ញាធរខេត្ត ។ ប៉ុន្តែដើម្បីឱ្យការចរចាបានទទួលជោគជ័យ ចាំបាច់ត្រូវឱ្យមានការរៀបចំបណ្តាញជាច្រើនដើម្បីពាំនាំព័ត៌មានពីថ្នាក់ភូមិ ឬ ឃុំទៅឱ្យដល់អ្នកធ្វើគោលនយោបាយ ។ អាស្រ័យហេតុនេះ បញ្ហាប្រឈមសំខាន់គឺតើត្រូវដាក់បញ្ចូលការតស៊ូមតិទៅក្នុងការបញ្ជ្រាប NREM តាមរបៀបណា ។

នៅកម្រិតថ្នាក់អនុវត្តន៍ មន្ត្រីរដ្ឋាភិបាលមិនមានការប្តេជ្ញាចិត្តដើម្បីផ្តល់ការគាំទ្រ ដូចដែលមានចែងនៅក្នុងអាណត្តិរបស់ខ្លួននោះឡើយ ។ ប្រការនេះតំរូវឱ្យមានការចរចា និងសម្របសម្រួលជាប្រចាំ ។ ដូចនេះបញ្ហាប្រឈមចំពោះអភិបាលកិច្ចមូលដ្ឋានគឺ តើត្រូវធ្វើយ៉ាងណាដើម្បីធានាថាមន្ទីរនានាថែរក្សាធនធាននៅមូលដ្ឋានយ៉ាងពិតប្រាកដ ។

ជាងនេះទៅទៀត ប្រការចាំបាច់គឺត្រូវបង្កើតលទ្ធភាពដកស្រង់បទពិសោធន៍ ហើយជៀសវាងនូវភាពតឹងរ៉ឹងហួសហេតុដែលគ្មានភាពទន់ភ្លន់ អំពីអ្វីដែលគួរចែង ឬ ពុំគួរចែងនៅក្នុងច្បាប់នោះឡើយ ។ ទំនាស់នេះបានគូសបញ្ជាក់រវាងគោលនយោបាយឃុំ-សង្កាត់ និងគោលនយោបាយរដ្ឋបាលព្រៃឈើ (FA ។ ផ្អែកទៅតាមច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំមានសិទ្ធិក្នុងការឃាត់ឈើល្មើសច្បាប់ ប្រសិនបើពួកគេរាយការណ៍ជាបន្ទាន់ទៅដល់ FA ។ ទោះជាយ៉ាងណាក៏ដោយ FA បានបកស្រាយថាការធ្វើបែបនេះ គឺល្មើសច្បាប់ ។ ប្រការនេះតម្រូវអោយមានការបណ្តុះបណ្តាល និងបង្កើនការយល់ដឹងអោយបានច្រើនថែមទៀតរវាងមន្ត្រីរដ្ឋាភិបាល ដោយឆ្លុះបញ្ចាំងទៅលើអ្វីដែលច្បាប់បានចែង ហើយថាតើសហគមន៍មូលដ្ឋានមានសិទ្ធិអ្វីខ្លះ ។ ប្រការនេះមានន័យថាមិនមែនគ្រប់ច្បាប់ទាំងអស់សុទ្ធតែមានភាពស៊ីសង្វាក់គ្នានោះទេ។ ប្រការសំខាន់គឺ បុគ្គលិកត្រូវមានការយល់ដឹងផងដែរថាសហគមន៍មូលដ្ឋានមានសិទ្ធិដែរ ។ ជាងនេះទៅទៀត ចាំបាច់ត្រូវធ្វើការប្រៀបធៀបរវាងអ្វីដែលមានចែងក្នុងច្បាប់ និងអ្វីដែលកើតមានឡើងជាក់ស្តែងនៅមូលដ្ឋាន ។

## ទំនាក់ទំនងរវាងការបញ្ជ្រាប NREM និង CBNRM

ការបញ្ជ្រាប NREM គឺជាឱកាសសម្រាប់ធ្វើអោយសកម្មភាព CBNRM មានការទទួលស្គាល់ តាមរយៈរចនាសម្ព័ន្ធអភិបាលកិច្ច ។ នៅក្នុងប្រទេសកម្ពុជា ការផ្តល់ការគាំទ្រទៅដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអ្នកនៅក្នុងជួររដ្ឋអំណាចផ្សេងៗទៀតមានសារៈសំខាន់ជាទីបំផុតនៅក្នុងការអនុវត្ត CBNRM នៅមូលដ្ឋាន ។ អាស្រ័យហេតុនេះ ការប្រើប្រាស់ដំណើរការកសាងផែនការ CIP/CDP គឺជាជំហានយុទ្ធសាស្រ្តសំខាន់ជាទីបំផុត សម្រាប់គ្រប់ដំណើរការ CBNRM នានានៅមូលដ្ឋាន ។

នៅពេលដែលការគាំទ្រចលនាសង្គមស៊ីវិលនានាមានសារៈសំខាន់ រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន ក៏មិនអាចមិនអើពើបានដែរ ។ ជារឿយៗ វិធីសាស្រ្តបច្ចុប្បន្ន នៃការធ្វើការងារដោយផ្ទាល់ជាមួយសហគមន៍ ដែល NGOs ភាគច្រើន និងគម្រោងផ្សេងៗបានអនុវត្ត តែងតែមិនឆ្លងកាត់រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះ ។ គម្រោងទាំងនេះត្រូវតែធ្វើការជាមួយសហគមន៍ដើម្បីបង្កើនការយល់ដឹងអំពីអ្វីដែលគេរំពឹងថាទទួលបានពីក្រុមប្រឹក្សាឃុំ-សង្កាត់របស់គេ ដូចជាក្នុងវិស័យ NREM ព្រមទាំងផ្តល់ការគាំទ្រដល់ឃុំ-សង្កាត់ផងដែរ ក្នុងការរៀនសូត្រអំពីការសម្របសម្រួល និងគាំទ្រអោយបានកាន់តែប្រសើរឡើងនូវដំណើរការ CBNRM នានានៅមូលដ្ឋាន ។

## REFERENCES

Ashish, J. 2001. *Local planning process in* Ratanakiri*, Cambodia. The challenge to meet people's strategic needs.*

*Ashish, J, Ingty, J and Nhem, S. 2003. Participatory Land Use Planning and Governance in Ratanakiri, Cambodia* (Paper Prepared for publication in Potato magazine).

Marschke, M. 2004. *Mainstreaming NREM with Commune Councils and PLUP tools. Phnom Penh: Seila/PLG.*

Nhem, S and Min, M. 2000. *CBNRM as a tool to obtain recognition over natural resource management and its influence on policy making (Paper prepared for the 2nd International CBNRM workshop, 16-20 October 2000 in Guizhou, China).*

Nhem, S. 2001. *CBNRM and it influence on governance at different levels (Paper prepared for CBNRM workshop in Chiang Mai, Thailand).*

Seila Task Force March. 2002. *Seila Natural Resource and Environment Management Mainstreaming Strategy 2002-2005.*

# ជំពូក ៥ កំណែទម្រង់គោលនយោបាយវិស័យជលផល និងក្របខ័ណ្ឌច្បាប់សម្រាប់សហគមន៍នេសាទ

រៀបរៀងដោយលោក ថាយ សុមុនី[១] លោក ស៊ីម ប៊ុនធឿន[២] និង អ្នកស្រី សូ ស្រីមុំ[៣ និង ៤]

## សេចក្ដីផ្ដើម

វិស័យជលផល និងតំបន់ដីសើមនៅប្រទេសកម្ពុជា មានសារៈសំខាន់ជាអាយុជីវិតក្នុងការទ្រទ្រង់ស្បៀងអាហារ ប្រាក់ចំណូល និងជីវភាពរស់នៅនៃប្រជាពលរដ្ឋជាច្រើនលាននាក់ ។ បន្ទាប់ពីស្រូវ ជលផលគឺជាឆ្អឹងខ្នងនៃសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជា ដោយរួមចំណែករហូតដល់ ៧៥% នៃសារជាតិប្រូតេអ៊ីនដែលបានពីជាតិសាច់ ក៏ដូចជាផ្ដល់ប្រាក់ចំណូល ព្រមទាំងការងារពេញម៉ោង និងការងារក្រៅម៉ោងសម្រាប់ប្រជាពលរដ្ឋប្រមាណ ២លាននាក់ ជាពិសេសបណ្ដាគ្រួសាររស់នៅតាមជនបទ ដែលមានប្រមាណជិត ៩០% នៃប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេស ។ ជាក់ស្ដែង ការរួមវិភាគទាននៃ "ផលនេសាទទឹកសាប" ចំពោះសន្តិសុខស្បៀង និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាត្រូវបានចាត់ទុកថា មានកម្រិតខ្ពស់ជាងនៅក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ប៉ុន្តែ ទោះបីធនធានធម្មជាតិដ៏សម្បូរបែបនេះ មាននៅក្នុងដែននេសាទទឹកសាបទំហំ ១.៨ លានហិកតា មានជាអាទិ៍ ទន្លេ និងបឹង ព្រៃលិចទឹក វាលស្មៅ វាលស្រែ និងវាលភក់ក៏ដោយ ភូមិភាគនេះនៅតែជាតំបន់មួយក្រីក្រជាងគេនៅប្រទេសកម្ពុជា។ ប្រជាពលរដ្ឋប្រមាណ ៣៨% នៅក្នុងសហគមន៍នៃតំបន់បឹងទន្លេសាប រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ។

ប៉ុន្តែ កំណើននៃចំនួនឧបករណ៍នេសាទ និងការនេសាទហួសកម្រិត បានបង្កឱ្យមានកំណើនសម្ពាធលើធនធានជលផល ។ ប្រការនេះបាននាំឱ្យមានការធ្វើអាជីវកម្មធនធានជលផលហួសកម្រិត ។ លើសពីនេះ ការរានព្រៃលិចទឹកបានបំផ្លាញ និងធ្វើអោយខូចខាតទីជម្រកសំខាន់ៗនៃមច្ឆាជាតិ ។

ឯកសារនេះពិភាក្សាទៅលើទិដ្ឋភាពមួយចំនួន នៃការគ្រប់គ្រងជលផលក្នុងប្រទេសកម្ពុជា មានជាអាទិ៍ :

- ការរួមវិភាគទានដ៏សំខាន់ នៃធនធានជលផលនៅប្រទេសកម្ពុជា
- ការគំរាមកំហែងចំពោះនិរន្តរភាពនៃធនធានជលផលនៅប្រទេសកម្ពុជា
- សេចក្ដីសង្ខេបអំពីបរិបទជាប្រវត្តិសាស្ត្រនៃការគ្រប់គ្រងជលផលនៅប្រទេសកម្ពុជា និងកំណែទម្រង់គោលនយោបាយវិស័យជលផលនៅប្រទេសកម្ពុជា ។

---

[១] បច្ចុប្បន្ន លោក សុមុនី គឺជានាយកស្ដីទីប្រចាំប្រទេសកម្ពុជា របស់អង្គការមូលនិធិអន្តរជាតិសម្រាប់សត្វក្រៀល ហើយដែលកន្លងទៅថ្មីៗនេះធ្លាប់ជាប្រធានស្ដីទីនៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៅចំណុះនាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

[២] លោក ប៊ុនធឿន គឺជាមន្ត្រីតស៊ូមតិខាងផ្នែកជលផលរបស់អង្គការអុកស្វាមអាមេរិក ប្រចាំការិយាល័យតំបន់អាស៊ីបូពា៌ និងមានការិយាល័យនៅភ្នំពេញ។

[៣] អ្នកស្រី សូ ស្រីមុំ គឺជាប្រធានក្រុមគម្រោង "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍" (WWF, IDRC, Oxfam, RECOFTC) ដែលផ្ដោតលើការកសាងសមត្ថភាព ការបង្កើតបណ្ដាញទំនាក់ទំនង ការស្វែងយល់ពីបទពិសោធន៍ និងការគាំទ្រគោលនយោបាយ ។

[៤] ការរួមចំណែកពីអ្នកស្រី ងិន ណាវីរៈ មន្ត្រីកម្មវិធីសម្រាប់គម្រោងសិក្សាអំពីជីវភាពរស់នៅ របស់អង្គការអុកស្វាមអង់គ្លេស និងលោក លី វុឌ្ឍី ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ។

## សារៈសំខាន់នៃធនធានជលផលនៅប្រទេសកម្ពុជា

ធនធានជលផលមានជាអាទិ៍ ត្រី ក្តាម កង្កែប វារីរុក្ខជាតិ វារីសត្វ ព្រៃលិចទឹក ។ល។ មានសារៈសំខាន់ជាច្រើនបែបយ៉ាងណាស់ (ក្នុងការទ្រទ្រង់ សន្តិសុខស្បៀង ប្រាក់ចំណូលប្រចាំគ្រួសារ និងសេដ្ឋកិច្ចជាតិ ចំពោះប្រជាពលរដ្ឋកម្ពុជា ដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមប្លែកៗគ្នា ។ ធនធានទាំងនេះ ដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ី និងមានតម្លៃខ្ពស់សម្រាប់ទេសចរណ៍ធម្មជាតិ និងវប្បធម៌។ បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបង្អស់ នៅអាស៊ីអាគ្នេយ៍ ដែលតភ្ជាប់ទៅទន្លេមេគង្គតាមរយៈដងទន្លេសាបដែលមានប្រវែង ១២០គ.ម។ នៅរដូវប្រាំង បឹងទន្លេសាបមានវិសាលភាពប្រមាណ ២៥០,០០០ ហិកតា ចំណែកនៅរដូវវស្សាវិសាលភាពនេះបានកើនឡើងដល់ធំជាង ១លានហិកតា ដោយមានជម្រៅទឹក ៨-៩ ម ។ ផលនេសាទប្រចាំឆ្នាំរវាង ២៥០,០០០-៤៣០,០០០តោន ដែលបានពីបឹងនេះ និងមានតម្លៃប្រមាណ ១៥០-២០០ លានដុល្លារអាមេរិក ។ ផលិតផលនេសាទទឹកសាបពីបឹងទន្លេសាប ស្ថិតក្នុងលំដាប់ទី ៤ លើពិភពលោក បន្ទាប់ពីប្រទេសឥណ្ឌា ចិន និងបង់ក្លាដេស ។

## សន្តិសុខស្បៀង

ត្រីគឺជាប្រភពអាហារដ៏សំខាន់បន្ទាប់ពីស្រូវ និងជាទូទៅមានតម្លៃថោកសមល្មម ព្រមទាំងបានរួមចំណែកច្រើនជាង ៧៥% នៃសារជាតិប្រូតេអ៊ីនដែលបានពីសាច់សត្វនៅក្នុងរបបអាហាររបស់ប្រជាពលរដ្ឋមនុស្សម្នាក់ៗក្នុងសហគមន៍ ដែលពឹងផ្អែកលើផលនេសាទបានបរិភោគត្រីជាមធ្យម ៦៧គ.ក្រ នៅក្នុងមួយឆ្នាំ (ធៀបនឹងបរិមាណជាមធ្យមទូទាំងប្រទេសនៃការបរិភោគអង្ករអស់១៥១គ.ក្រ ក្នុងមួយឆ្នាំ ។ ការរួមវិភាគទាននៃផលនេសាទទឹកសាបចំពោះសន្តិសុខស្បៀង និងសេដ្ឋកិច្ចជាតិក្នុងប្រទេសកម្ពុជាមានអត្រាខ្ពស់ជាងនៅក្នុងប្រទេសនានាក្នុងតំបន់ ។ បច្ចុប្បន្ន ការធានាថាឱ្យមានសារជាតិប្រូតេអ៊ីនពីសាច់សត្វនៅក្នុងរបបអាហាររហូតដល់ ៦៧គ.ក្រ ក្នុងមួយឆ្នាំ គឺជាការលំបាក ។ ប្រជាពលរដ្ឋត្រូវចំណាយពេលវេលាកាន់តែច្រើន



ស៊ុម ប៊ុនធឿន/OA ២០០១



ស៊ុម ប៊ុនធឿន/OA ២០០១

*ត្រីជាប្រភពអាហារដែលអាចរកបាននៅឡើយ ។ ក្នុងប្រទេសកម្ពុជា ច្រើនជាង ៧៥% នៃសារជាតិប្រូតេអ៊ីនដែលមានប្រភពពីសាច់សត្វ បានមកពីការបរិភោគត្រី ។*

ដើម្បីនេសាទត្រីសម្រាប់ការបរិភោគប្រចាំថ្ងៃដោយខ្លួនឯង ឬចាំបាច់ត្រូវមានប្រាក់ដើម្បីទិញត្រីសម្រាប់ការបរិភោគប្រចាំថ្ងៃ ។ ជួនកាល និងក្នុងករណីខ្លះ ប្រជាពលរដ្ឋត្រូវបង្ខំចិត្តប្រើប្រាស់ឧបករណ៍ប្លែកៗ និងវិធីនេសាទទំនើបៗ ដើម្បីរកត្រីឱ្យបានគ្រប់គ្រាន់ ។ អ្នកភូមិជាច្រើននៅតំបន់ខ្ពង់រាបបានបញ្ឈប់ការនេសាទត្រីទៅហើយ ដោយសារការថយចុះនៃធនធានជលផលនៅក្នុងតំបន់របស់ពួកគេ និងដោយសារកំណើនប្រជាពលរដ្ឋនៅតំបន់នោះ ។ ប៉ុន្តែប្រជាពលរដ្ឋនៅទីជនបទនៅតែបន្តត្រូវការត្រីសម្រាប់បរិភោគ ដើម្បីទ្រទ្រង់ជាតិសាច់ជាបន្ថែមនៅក្នុងរបបអាហារ ទោះបីបរិមាណត្រីដែលគេបរិភោគកាន់តែតិចជាងធម្មតាក៏ដោយ ។



ស៊ិន ប៊ុនធឿន/OA ២០០១

***ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋច្រើនជាង ២លាននាក់ពឹងផ្អែកលើវិស័យជលផលតាមវិធីផ្សេងៗ ។***

## ប្រាក់ចំណូល និងជីវភាពរស់នៅ

មានប្រជាពលរដ្ឋច្រើនជាង ២លាននាក់ប្រកបការងារក្នុងវិស័យជលផល និងសកម្មភាពពាក់ព័ន្ធជាមួយវិស័យនេះ ។ ការនេសាទគឺជាមុខរបរមូលដ្ឋានបន្ថែម ដើម្បីទំនុកបំរុងសេដ្ឋកិច្ចគ្រួសារ ឬដើម្បីបង្ការពេលមានគ្រោះអាសន្ន (ដូចជា ភាពរាំងស្ងួត ការរាតត្បាតពីសត្វចង្រៃ ឬទឹកជំនន់ ។ បឹងទន្លេសាប និងទំនាបលិចទឹកនៃបឹងនេះ គឺជាកន្លែងរស់នៅរបស់ប្រជាពលរដ្ឋប្រមាណ ១.២លាននាក់ ដែលក្នុងនោះប្រមាណ ២៥% រស់នៅតាមភូមិបណ្តែតទឹក ឬសង់ផ្ទះលើជន្ទល់ខ្ពស់ផុតពីដី ដោយពុំមាន ឬមានដីតិចតួចតែប៉ុណ្ណោះសម្រាប់ដាំដំណាំ ។ ការពឹងផ្អែកលើធនធានជលផលយ៉ាងខ្លាំងបែបនេះ បានឆ្លុះបញ្ចាំងពីតម្រូវការចាំបាច់ក្នុងការធានាឱ្យមានសមធម៌លើការប្រើប្រាស់ និងការការពារធនធាននេះ ។

## សេដ្ឋកិច្ចជាតិ

ដែននេសាទដែលសម្បូរត្រី (ឡូតិ៍នេសាទ ដែលបានកំណត់ឡើងដោយអាជ្ញាធរអាណានិគមបារាំង ក្នុងឆ្នាំ ១៨៦៤ ត្រូវបានដាក់ឱ្យដេញថ្លៃសម្រាប់រយៈពេល២ឆ្នាំម្តង ដើម្បីប្រមូលប្រាក់ឈ្នួលឡូតិ៍នេសាទសម្រាប់ជាចំណូលថវិកាជាតិ ។ ការប៉ាន់ប្រមាណថ្មីៗនេះ ដោយគម្រោងនេសាទទឹកសាបនៃគណៈកម្មការទន្លេមេគង្គ ដែលមានទីតាំងនៅនាយកដ្ឋានជលផល បង្ហាញថាដែននេសាទទឹកសាបអាចផ្តល់ផលត្រី ២៣០,០០០-៤៣០,០០០តោន ជារៀងរាល់ឆ្នាំ ដែលមានតម្លៃប្រមាណ ១៥០-២០០លានដុល្លារអាមេរិក ដែលជាប្រាក់ចំណូលយ៉ាងក្រាស់ក្រែលសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ។ ការប៉ាន់ប្រមាណថ្មីៗនេះដោយក្រសួងផែនការបង្ហាញថា ប្រាក់ចំណូលពីការនេសាទរួមវិភាគទានរហូតដល់ ១៦ភាគរយ នៃផលទុនក្នុងស្រុកសរុប

(Gross Domestic Products - GDP) នៃប្រទេសកម្ពុជា ។ រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាទាំងមូលគួរតែបានទទួលអត្ថប្រយោជន៍ពីសក្តានុពលនៃប្រាក់ចំណូលដ៏ច្រើននេះដែលទទួលបានពីវិស័យជលផល ។

## ការអភិរក្សអេកូឡូស៊ី និងទីជម្រក

ប្រភពដ៏សំខាន់នៃផលនេសាទច្រើនសន្ធឹកសន្ធាប់ក្នុងប្រទេសកម្ពុជា គឺទំនាបលិចទឹក ជាពិសេសព្រៃលិចទឹកដែលមានវិសាលភាពធំទូលាយ និងដែលលិចទឹកនៅរដូវវស្សា បង្កើតបានជាបឹងដែលមានព្រៃព័ទ្ធជុំវិញ និងដែលលិចទឹករហូតដល់ជម្រៅ ១០ម៉ែត្រ។ ព្រៃលិចទឹកទាំងនេះ គឺជាទីជម្រកដ៏ស្មុគស្មាញ និងប្រកបដោយជីជាតិ ស្ថិតលើវិសាលភាពផ្ទៃដីធំធេងសម្បូរទៅដោយចំណីអាហារ និងមាននាទីជាជម្រកសម្រាប់ត្រី សត្វស្លាប អណ្តើក និងសត្វដទៃទៀតជាច្រើនប្រភេទដែលរស់នៅក្នុងតំបន់ដីសើម។ ព្រៃលិចទឹកទាំងនេះគឺជាគោលដៅសម្រាប់ត្រីជាច្រើនប្រភេទ ធ្វើចរាចរផ្លាស់ទីឆ្លងកាត់អាងទន្លេមេគង្គខាងក្រោម ដើម្បីស្វែងរកកន្លែងពងកូននៅដើមរដូវវស្សាដែលជាការបន្សាំតាមពេលវេលាសម្រាប់ឱ្យកូនត្រីតូចៗ ដែលទើបញាស់អាចចូលទៅក្នុងតំបន់ទំនាបលិចទឹកនៅរដូវទឹកឡើង ។ ប្រការសំខាន់ដែរនោះគឺថា ឡូតិ៍ដាយជាច្រើននៅតាមដងទន្លេសាបធ្វើអាជីវកម្មនេសាទ ប្រភេទត្រីបំលាស់ទី នៅពេលដែលត្រីនេះបំលាស់ទីចាកចេញពីបឹងទន្លេសាបទៅទន្លេមេគង្គវិញនៅចុងរដូវវស្សា ។ ក្រៅពីនេះក៏មានត្រីជាច្រើនប្រភេទផ្សេងទៀតដែលពុំធ្វើចរាចរឆ្ងាយបែបនេះទេ ប៉ុន្តែវាផ្លាស់ទីជិតៗពីព្រៃលិចទឹកទៅក្នុងលំហទឹកបឹងនៅរដូវទឹកស្រក ។

## អេកូ-ទេសចរណ៍

បឹងទន្លេសាប ព្រៃលិចទឹក ព្រមទាំងហ្វូងសត្វស្លាបដ៏ច្រើនដែលជាប្រភេទមានដោយកំរ (ជាពិសេសនៅព្រែកទាល់ និងលក្ខណៈដោយឡែកនៃភូមិបណ្តែតទឹក ដែលមានទីតាំងមិនឆ្ងាយពីអង្គរវត្ត បានផ្តល់នូវសក្តានុពលដ៏ធំធេងសម្រាប់ទេសចរណ៍ និងជាប្រភពដ៏សំខាន់នៃរូបិយប័ណ្ណបរទេស ជាប្រយោជន៍សេដ្ឋកិច្ចនៃប្រជាពលរដ្ឋកម្ពុជា ។ អេកូ-ទេសចរណ៍បែបនេះ បានចាប់ផ្តើមផ្តល់នូវការទាក់ទាញដល់ភ្ញៀវទេសចរណ៍ក្នុងការស្វែងយល់អំពីភាពសម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប និងសហគមន៍នានា ក្នុងភូមិបណ្តែតទឹក ។

## វប្បធម៌

តំបន់ដីសើម បឹង ទន្លេ និងព្រៃនៅក្នុងប្រទេសកម្ពុជា បានបង្កើតជាមូលដ្ឋានគ្រឹះនៃអរិយធម៌ខ្មែរជាច្រើនសតវត្សរ៍មកហើយ ។ បឹងទន្លេសាប និងដែននេសាទទឹកសាបដ៏ធំទូលាយ បានជួយបង្កើតអត្តសញ្ញាណជាតិកម្ពុជា និងបន្តរក្សាអត្តសញ្ញាណបែបនេះរហូតមកដល់សព្វថ្ងៃ ។ សារៈសំខាន់នៃត្រីចំពោះប្រជាពលរដ្ឋខ្មែរ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសុភាសិតមួយដែលចែងថា *"ទីណាមានទឹក ទីនោះមានត្រី"* ។ វិស័យជលផលក៏មានអត្ថប្រយោជន៍ចំពោះកសិករផងដែរ ដែលមកធ្វើនេសាទក្នុងដែន

នេសាទសាធារណៈពីខែធ្នូ ដល់ខែមីនា មុនការប្រមូលផលស្រូវ ដើម្បីរកផលនេសាទបន្ថែមសម្រាប់បរិភោគក្នុងគ្រួសារ ។ ជាទូទៅកសិករប្រើឧបករណ៍នេសាទខ្នាតតូច ឬឧបករណ៍ជាលក្ខណៈប្រពៃណី ហើយផលនេសាទត្រូវបានកែច្នៃជាប្រហុក ត្រីងៀត និង ត្រីឆ្អើរ ។ កសិករខ្លះលក់ ឬដោះដូរផលនេសាទជាមួយអ្នកនេសាទនៅក្នុងមូលដ្ឋាន ។ ទម្លាប់ជាលក្ខណៈប្រពៃណីបែបនេះនៅមានបន្តរហូតដល់សព្វថ្ងៃ និងជួយពង្រឹងទំនាក់ទំនងរវាងប្រជាពលរដ្ឋពីតំបន់ខ្ពង់រាប និងអ្នកនេសាទនៅក្នុងមូលដ្ឋាន ។ ជួនកាលទំនាក់ទំនងមនោសញ្ចេតនាបានកើតឡើងនៅក្នុងពេលមានការដោះដូរផលត្រី និងស្រូវ ហើយស្វាមីភរិយាពីប្រភពខុសគ្នាមួយគូអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បន្ទាប់ពីមានការឯកភាពពីគ្រួសារទាំងសងខាង ។

## ស្ត្រី និង កុមារក្នុងការនេសាទ

ស្ត្រីទំនងជាធ្វើសកម្មភាពច្រើនជាងបុរសក្នុងអត្រា១២%នៅក្នុងការងារកសិកម្ម ការនេសាទ និងមុខរបរពាក់ព័ន្ធសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ ។ គ្រួសារជាច្រើនមានសមាជិកស្ទើរតែទាំងអស់ចូលរួមនៅគ្រប់រដូវ ក្នុងការនេសាទ លក់ផលនេសាទ កែច្នៃផលត្រី និងធ្វើឧបករណ៍នេសាទត្រី ព្រមទាំងសកម្មភាពនានាជាច្រើនផ្សេងទៀតពាក់ព័ន្ធនឹងការនេសាទ ។ ស្ត្រីច្រើនតែចូលរួមគ្រប់សកម្មជាងបុរសនៅក្នុងការងារលើគោក ជាអាទិ៍ ជួសជុលឧបករណ៍នេសាទ ជួសជុលមង លប និងចាត់ថែងផលនេសាទទៅតាមទំហំ និងប្រភេទ។ កុមារក៏ជួយគ្រួសារនៅក្នុងសកម្មភាពនេសាទមួយចំនួនផងដែរ ។ ស្ត្រីខ្លះ ជាពិសេសស្ត្រីមេម៉ាយដែលជាមេគ្រួសារធ្វើការធ្ងន់ធ្ងរក្រៃលែង ។ ស្ត្រីមេម៉ាយតែងតែមានកូនជាជំនួយនៅក្នុងសកម្មភាពនេសាទ ជាហេតុនាំឱ្យមានឥទ្ធិពលអវិជ្ជមានក្នុងសង្គម ដោយសារក្មេងទាំងនោះពុំអាចទៅសាលារៀនបាន ។ ក្នុងភូមិបណ្តែតទឹក ជិត ៩៥% នៃកុមារបានបោះបង់ចោលសាលារៀនត្រឹមថ្នាក់ទី៣ ឬថ្នាក់ទី៥ ដើម្បីជួយការងារគ្រួសាររបស់ខ្លួន រួមទាំងជួយក្នុងការនេសាទ ។ តួនាទីរបស់ស្ត្រីក្នុង សកម្មភាពនេសាទកាន់តែថយចុះ ដោយសារពីមួយថ្ងៃទៅមួយថ្ងៃ ធនធានជលផលកាន់តែខ្សត់ទៅ ។



ស៊ុន ប៊ុនធឿន /OA ២០០១

*សមាជិកទាំងអស់ប្រឡូកនៅគ្រប់រដូវក្នុងការនេសាទ លក់ផលនេសាទ កែច្នៃផលត្រី និង សកម្មភាពនានាជាច្រើនផ្សេងទៀត ពាក់ព័ន្ធនឹងការនេសាទ*

## ការគម្រាមកំហែងចំពោះធនធានជលផលនៅប្រទេសកម្ពុជា

ធនធានជលផលនៃប្រទេសកម្ពុជាបានរងឥទ្ធិពលពីការធ្វើអាជីវកម្មហួសកម្រិត ការធ្វើនេសាទយ៉ាងខ្លាំងក្លា ស្ថាប័នទន់ខ្សោយ កំណើនចំនួនប្រជាពលរដ្ឋ និងកត្តាផ្សេងទៀតជាច្រើន ។ ចាប់តាំងពីឆ្នាំ ២០០០-២០០១ បឹងទន្លេសាប និងការនេសាទទឹកសាបបានរងការគម្រាមកំហែងដោយសារ វិធីនេសាទល្មើសច្បាប់ ដែលកើតមានជាទូទៅពាសពេញដែននេសាទសាធារណៈ និងដែននេសាទដែលបានកាត់ឱ្យសហគមន៍គ្រប់គ្រង ។ ប៉ុន្តែអ្នកនេសាទសប្បាយរីករាយណាស់ ដោយសារពួកគេអាចធ្វើនេសាទបានដោយសេរីក្រោយពេលដែលឡូតិ៍នេសាទ ៥៦.២៣% ត្រូវបានកាត់ និងលប់ចេញ សម្រាប់ដាក់ឱ្យធ្វើការនេសាទជាសាធារណៈ ដែលជាហេតុនាំឱ្យអ្នកនេសាទមានដែននេសាទធំទូលាយជាងមុន ។ ប្រជាពលរដ្ឋរស់នៅក្នុងភូមិបណ្តែតទឹក នៅពុំទាន់យល់ច្បាស់អំពីការគ្រប់គ្រងដែននេសាទសហគមន៍នៅឡើយទេ ដោយសារដំណើរការនៃការគ្រប់គ្រងស្ថាប័ននៅទន់ខ្សោយ ។

ការគម្រាមកំហែងចំពោះធនធានជលផលនៅក្នុងប្រទេសកម្ពុជា អាចពិពណ៌នាដូចខាងក្រោម[៤]ៈ

### សកម្មភាពនេសាទល្មើសច្បាប់



ស៊ុន ប៊ុនធឿន /OA ២០០១

***សកម្មភាពល្មើសច្បាប់ជាច្រើន កើតឡើងពីការប្រើប្រាស់ឧបករណ៍នេសាទខ្នាតធំដែលហាមឃាត់ក្នុងការវាតទីទ្រង់ទ្រាយធំ***

សកម្មភាពល្មើសច្បាប់ជាច្រើនកើតឡើងពីការប្រើប្រាស់ឧបករណ៍នេសាទខ្នាតខូចដែលហាមឃាត់ និងការប្រើឧបករណ៍ឆក់ត្រី ថ្នាំពុល គ្រឿងផ្ទុះ និងការបូមបាចពង្រីង រួមទាំងការវាតទីទ្រង់ទ្រាយធំនៃអ្នកកាន់កាប់ឡូតិ៍នេសាទទៅក្នុងដែននេសាទសាធារណៈ ។ ចំពោះអ្នកនេសាទខ្នាតតូច និងមធ្យមវិញ តម្រូវការជាមូលដ្ឋានគឺសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ និងប្រាក់ចំណូល អាចជាកម្លាំងជម្រុញឱ្យមានការប្រើវិធីនេសាទល្មើសច្បាប់ ចំណែកអ្នកនេសាទទ្រង់ទ្រាយធំ អាចត្រូវបង្ខំចិត្តប្រើវិធីនេសាទល្មើសច្បាប់ដោយសារថ្លៃឈ្នួលឡូតិ៍នេសាទ និងឧបករណ៍នេសាទទ្រង់ទ្រាយធំមានតម្លៃខ្ពស់ ហើយការកំណត់រយៈពេល២ឆ្នាំ ក្នុងការកាន់កាប់ឡូតិ៍នេសាទ ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងជាទីបំផុត ។ ជាញឹកញាប់ កងកម្លាំងប្រដាប់អាវុធ និងនគរបាលក៏មានការពាក់ព័ន្ធនឹងបទល្មើសនេសាទផងដែរ ។

មូលហេតុចម្បងមួយ ដែលនាំឱ្យមានការនេសាទច្រើនហួសកម្រិត គឺកំណើនចំនួនប្រជាពលរដ្ឋ ។ នៅឆ្នាំ១៩៩២ ចំនួនប្រជាពលរដ្ឋត្រូវបានប៉ាន់ប្រមាណត្រឹម ៧លាននាក់ តែប៉ុណ្ណោះ តែបច្ចុប្បន្នចំនួនប្រជាពលរដ្ឋបានត្រូវប៉ាន់ប្រមាណរហូតដល់

---

[៤] Feast or Famine? and Cambodia's Essential Fisheries Resources Under Threat

១៣លាននាក់។ ចំនួនអ្នកនេសាទនៅជុំវិញបឹងទន្លេសាបបានកើនឡើងពី ០,៥លាននាក់ ដល់ ១,២ លាននាក់។ នៅពេលមានកំណើនចំនួនប្រជាពលរដ្ឋ ការធ្វើនេសាទហួសកម្រិតនៅតែជាបញ្ហាគម្រាមកំហែងនៅក្នុងបឹងទន្លេសាប តាមដងទន្លេមេគង្គ និងតំបន់ឆ្នេរ ។ ប្រជាពលរដ្ឋព្យាយាមលើកកំពស់លក្ខខណ្ឌជីវភាពរស់នៅនៃគ្រួសាររបស់ខ្លួន ជាចំណែកមួយនៃដំណើរការទំនើបកម្ម និងសាកលភាវូបនីយកម្ម ហើយប្រការនេះកំពុងបន្តគម្រាមកំហែងដល់ធនធានជលផល ។

ក្រៅពីកំណើនចំនួនប្រជាពលរដ្ឋ កសិករមួយចំនួនបានផ្លាស់ប្តូរមុខរបររបស់ខ្លួនទៅធ្វើនេសាទ ដោយសារលក្ខខណ្ឌអាកាសធាតុមិនអំណោយផល ដូចជាទឹកជំនន់ និងភាពរាំងស្ងួត ដែលបានបំផ្លាញដំណាំនៅក្នុងអំឡុងពេល ៣ឆ្នាំចុងក្រោយនេះ ។ ការប្រកួតប្រជែងដើម្បីនេសាទធនធានជលផល ដែលកាន់តែខ្សត់ខ្សោយនេះ បង្ខំឱ្យប្រជាពលរដ្ឋព្យាយាមរិះរកវិធីគ្រប់យ៉ាង ដើម្បីពួកគេអាចនេសាទបានត្រីច្រើនជាងអ្នកជិតខាងរបស់ខ្លួន។ ប្រភពនៃកំណើនចំនួនប្រជាពលរដ្ឋមានពីរបែប : កំណើនប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេស និងកំណើនចំនួនអ្នកនេសាទដែលពីមុនធ្លាប់តែប្រកបមុខរបរជាកសិករ ។ តម្រូវការរបស់សហគមន៍មូលដ្ឋានមានកម្រិតខ្ពស់ ហើយប្រជាពលរដ្ឋនៅទីក្រុងក៏ត្រូវការធនធាននេះផងដែរ ។

## ការបាត់បង់ជីវៈចម្រុះ និងទីជម្រក

ទីជម្រកធម្មជាតិ ពិសេសព្រៃលិចទឹកមានផលិតភាពខ្ពស់បំផុត ធៀបនឹងដែននេសាទផ្សេងទៀត ហេតុនេះការបាត់បង់ព្រៃលិចទឹក ឬការបំលែងទៅជាដីកសិកម្មនាំឱ្យមានឥទ្ធិពលអវិជ្ជមានគួរឱ្យកត់សំគាល់ ចំពោះសន្និធិផលនេសាទ ។ ការបន្តពូជនៃប្រភេទត្រីដែលបំលាស់ទី និងមិនបំលាស់ទី និងអនាគតនៃផលនេសាទ ពឹងផ្អែកលើទំនាបលិចទឹកដែលមាននាទីជាកន្លែងពងកូន កន្លែងរកចំណី និងការលូតលាស់របស់ត្រី ។ ការបំផ្លាញព្រៃលិចទឹកនឹងនាំឱ្យមានឥទ្ធិពលដោយផ្ទាល់ចំពោះសត្វស្លាបច្រើនប្រភេទ រួមទាំង សត្វត្រដក់ និងត្រយ៉ង ដែលជាសត្វរងការគម្រាមកំហែងកម្រិតពិភពលោក និងដែលជាអ្នកប្រើប្រាស់ដើមឈើខ្ពស់ៗ សម្រាប់ធ្វើសំបុក។

## ការបំពុល

នៅឆ្នាំ២០០០ មានការប្រើប្រាស់ថ្នាំគីមីកសិកម្មប្រមាណ ១.៣លានលីត្រ (Oxfam America, EJF 2002) នៅក្នុងទីជម្រាលនៃអាងបឹងទន្លេសាប ហើយភាគច្រើននៃថ្នាំគីមីកសិកម្មទាំងនោះ គឺជាសារធាតុគីមីពុលកម្រិតខ្ពស់ (ជាអាទិ៍ ដេដេតេ ដែលត្រូវបាននាំចូលដោយល្មើសច្បាប់ពីប្រទេសជិតខាង ។ សំណាកត្រីចាប់ពីក្នុងអាងទន្លេមេគង្គខាងក្រោម បង្ហាញថា មានកំហាប់សំណល់ថ្នាំគីមីកសិកម្មកម្រិតខ្ពស់ ក្នុងនោះប្រភេទត្រីប្រាដែលជាពពួកត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់ក្នុងអាងទន្លេមេគង្គក៏ត្រូវបានរកឃើញថា មានកំហាប់ថ្នាំគីមីកសិកម្មខ្ពស់ជាងគេផងដែរ ។ ការប្រើប្រាស់ជីគីមី ជាទូទៅលើដំណាំនៅរដូវប្រាំងក៏នាំឱ្យមានឥទ្ធិពលចំពោះអេកូឡូស៊ីបឹងទន្លេសាបផងដែរ ដែលម្តងម្កាលវាអាចធ្វើឱ្យបាត់បង់អុកស៊ីសែន ដែលចាំបាច់សម្រាប់រុក្ខជាតិ និងត្រី និងជួនកាលធ្វើឱ្យត្រីងាប់ផងក៏មាន ។

## ទំនាស់ឡូតិ៍នេសាទ

ទំនាស់ក្នុងការនេសាទបានកើតឡើងជាទូទៅក្នុងប្រទេសកម្ពុជា ដោយសារការប្រកួតប្រជែងក្នុងការនេសាទរវាងការនេសាទជាលក្ខណៈពាណិជ្ជកម្ម កំណើនចំនួនអ្នកនេសាទគ្រួសារ ការនេសាទល្មើសច្បាប់ និងតម្រូវការដី កសិកម្ម ទឹក និងអុស ។ ទំនាស់បានកើតឡើងរវាងកម្មករឡូតិ៍នេសាទ អាជ្ញាធរមូលដ្ឋាន ទាហាន នគរបាល និងសហគមន៍មូលដ្ឋាន ដែលនាំឱ្យមានការធ្វើបាតុកម្ម ការធ្វើញត្តិប្រឆាំង ការឃាត់ខ្លួន និងការចាប់បង្ខំឱ្យធ្វើពលកម្ម ការរឹបអូសឧបករណ៍នេសាទ និងសត្វចិញ្ចឹម ការបង្កស្នាមរបួស ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងសេចក្តីរាយការណ៍អំពីការសម្លាប់អ្នកនេសាទ និងមន្ត្រីជលផល ។

ក្នុងករណីជាច្រើន ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានហាមឃាត់មិនឱ្យចូលក្នុងដែននេសាទដែលជាកន្លែងត្រូវបានកំណត់សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ដោយស្របច្បាប់ និងដែលពួកគេធ្លាប់បាននេសាទជាច្រើនជំនាន់មកហើយ ។ ក្រៅពីនេះ មានសេចក្តីរាយការណ៍ផងដែរអំពីទំនាស់ក្នុងការប្រើប្រាស់ទឹក និងការនេសាទក្នុងអាងជលសាស្ត្រ ។ នៅពេលទឹកស្រក ជួនកាលអ្នកកាន់កាប់ឡូតិ៍នេសាទបានបូមពង្រីងបឹងតូចៗនានា ដែលមានទឹកនៅសេសសល់ ដើម្បីចាប់ត្រីដែលជាប្រការល្មើសច្បាប់ ។ ប្រការនេះធ្វើអោយខ្វះទឹកសម្រាប់ស្រោចស្រពនៅរដូវប្រាំង ជាហេតុនាំឱ្យសហគមន៍មូលដ្ឋានក្លាយជាអ្នករងគ្រោះ ។

ការកំណត់ពុំបានច្បាស់អំពីព្រំប្រទល់ឡូតិ៍នេសាទ ជាហេតុនាំឱ្យមានការចោទប្រកាន់ថា អ្នកនេសាទក្នុងមូលដ្ឋានបានលួចចូលនេសាទត្រី ទោះបីជួនកាលពួកគាត់ធ្វើនេសាទនៅត្រឹមតែក្នុងដែននេសាទសាធារណៈក៏ដោយ ។ ជាញឹកញាប់ដែននេសាទសាធារណៈត្រូវបានប្រើប្រាស់សម្រាប់ផលប្រយោជន៍ឯកជន ដែលជួនកាលមានទាំងការបំភិតបំភ័យ ការប្រើអាវុធព្រមទាំងការពាក់ព័ន្ធពីសំណាក់ទាហាន និងនគរបាលផងដែរ ។ គេកម្រឃើញមានការដោះស្រាយទំនាស់នៅក្នុងតុលាការណាស់ ហើយភស្តុតាងនានាមិនត្រូវបានយកមកពិនិត្យឡើយ ។

## គម្រោងកសាងទំនប់ និងធនធានទឹក

គម្រោងកសាងទំនប់ និងគម្រោងអំពីធនធានទឹកអាចមានឥទ្ធិពលធ្ងន់ធ្ងរ ចំពោះវិសាលភាពនៃទឹកជំនន់ គុណភាពទឹក ការធ្វើនាវាចរណ៍ និងផលិតកម្មស្បៀងក្នុងប្រទេសនៅខ្សែទឹកខាងក្រោម និងអាចមានឥទ្ធិពលលើការនេសាទនៅក្នុងតំបន់ខ្សែទឹកខាងលើនៃទំនប់ ដោយសារត្រីពុំអាចចរាចរឆ្លងកាត់ទំនប់ទៅភាគខាងលើបាន ។ ការធ្លាក់ចុះនៃផលិតផលត្រី នៅក្នុងបឹងនិងទន្លេនានានៃប្រទេសកម្ពុជា នឹងនាំឱ្យមានឥទ្ធិពលនៅទូទាំងអាងទន្លេមេគង្គទាំងមូល ព្រោះថាប្រភេទត្រីមួយចំនួនត្រូវចរាចរយ៉ាងឆ្ងាយរវាងប្រទេសកម្ពុជា វៀតណាម លាវ និងរហូតដល់ប្រទេសចិន ។ ការកាប់ឈើ ការជីកយករ៉ែ និងការធ្វើកសិកម្មដោយគ្មាននិរន្តរភាពនៅទូទាំងអាងទន្លេមេគង្គ ពិសេសនៅតំបន់ខ្ពង់រាប បង្កឱ្យមានភាពរេចរិលនៅក្នុងទីជម្រាល កំណើន ការហូរច្រោះ និងប្រែប្រួលរបបជលសាស្ត្រ ។

## បរិបទជាប្រវត្តិសាស្ត្រនៃការគ្រប់គ្រងជលផល

ជាទូទៅការគ្រប់គ្រងជលផលនៅប្រទេសកម្ពុជាបានទទួលឥទ្ធិពល និងចាត់ចែងដោយរបបគ្រប់គ្រង និងរបបនយោបាយខុសៗគ្នាពីអតីតកាល និងបច្ចុប្បន្នកាល ។ ប្រព័ន្ធគ្រប់គ្រងនីមួយៗ មានឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាន ចំពោះជីវភាពរស់នៅ និងស្ថានភាពនៃធនធានជលផល[5] ។

ការគ្រប់គ្រងជលផលក្នុងប្រទេសកម្ពុជា រួមមានការចាត់ចែងជាទម្រង់ផ្លូវការ និងក្រៅផ្លូវការ លើការនេសាទ សិទ្ធិ និងទម្លាប់ក្នុងការប្រើប្រាស់ដែននេសាទ ។ ប្រព័ន្ធគ្រប់គ្រងបែបនេះ ឃើញមានតាំងពីសម័យព្រះមហាក្សត្រ "នរោត្តម" (១៨៥៩-១៨៩៧) និងព្រះមហាក្សត្រមុនៗ ។ នៅក្នុងរជ្ជកាលនីមួយៗ ប្រាក់ចំណូលពីវិស័យនេសាទត្រូវបានប្រមូលក្រោមរូបភាពជាការលក់អាជ្ញាប័ណ្ណចូលធ្វើនេសាទ ។ លើសពីនេះ ព្រះមហាក្សត្រអាចអនុញ្ញាតឱ្យអ្នកវិនិយោគ និងពាណិជ្ជករគ្រប់គ្រងឡូតិ៍នេសាទ ហើយអ្នកទាំងនោះអាចជួលបន្តចំណែកនានានៃដែននេសាទទៅឱ្យអ្នកនេសាទ ។



ស៊ុំ ប៊ុនធឿន /OA ២០០១

ដូចដែលចារឹកលើប្រាង្គប្រាសាទអង្គរវត្ត ហើយការនេសាទជាផ្នែកដ៏សំខាន់សម្រាប់ជីវភាពរស់នៅក្នុងប្រទេសកម្ពុជា

ច្បាប់ និងបទប្បញ្ញត្តិដំបូងបំផុតអំពីការនេសាទត្រូវបានបង្កើតឡើង និងចុះផ្សាយក្នុងឆ្នាំ ១៩០៨ នៅក្រោមរដ្ឋបាលអាណានិគមបារាំង ។ ប៉ុន្តែ គោលបំណងនៃច្បាប់នោះ គឺការប្រមូលប្រាក់ចំណូលសម្រាប់រដ្ឋបាលអាណានិគម ដោយពុំពាក់ព័ន្ធនឹងការផ្លាស់ប្តូររបៀបនៃការធ្វើអាជីវកម្មនេសាទដែលមានស្រាប់នោះឡើយ[6] ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សកម្មភាពនេសាទមានតិចតួចតែប៉ុណ្ណោះ ។ មានការបង្កើត "អង្គភាពនេសាទ" មួយចំនួនតូច ដើម្បីធ្វើការនេសាទ និងកែច្នៃផលនេសាទសម្រាប់ផ្គត់ផ្គង់ដល់សហករណ៍ និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមនៅទីក្រុងភ្នំពេញ[7] ។ កំណើនសម្ពាធចំពោះធនធានជលផលកើតឡើងពីការពង្រីកការអភិវឌ្ឍកសិកម្ម ដែលនាំឱ្យមានការរានឆ្ការព្រៃលិចទឹក[8] ។

---

[5] Bruce *et al.,* 2002:54.
[6] Degen and Nao, 2000 in Bruce *et al.,* 2002:54
[7] Bruce and Prom, 2002:54 and FACT 2002:40
[8] FACT 2002:40

ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩ មានការលើកទឹកចិត្តឱ្យធ្វើនេសាទរួមគ្នា រហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៨០ នៅក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩) និងរដ្ឋកម្ពុជា (១៩៨៩-១៩៩៣) ដែលនៅក្នុងអំឡុងពេលនោះ ការគ្រប់គ្រងជលផលនៅក្នុងប្រទេសកម្ពុជាបានធ្វើឡើងតាមរយៈប្រព័ន្ធក្រុមសាមគ្គី ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ មានការដាក់ឱ្យប្រើឡើងវិញនូវប្រព័ន្ធឡូតិ៍នេសាទជាបរិធានគ្រប់គ្រងមួយ និងដើម្បីបង្កើនប្រាក់ចំណូល ។ ប្រព័ន្ធនេះមានលក្ខណៈដូចគ្នានឹងប្រព័ន្ធពីអតីតកាលដែលធ្លាប់បានប្រើប្រាស់ជាងមួយសតវត្សរ៍មកហើយ មុនការឡើងកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត ។ នៅឆ្នាំ១៩៨៧ ក្រឹត្យច្បាប់ជលផលលេខ៣៣ ត្រូវបានអនុម័តដោយកំណត់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងជលផល[៩] ។

ឆ្នាំ១៩៩៣-២០០០ គឺជាអន្តរសម័យរវាងសម័យមានសង្គ្រាម និងសន្តិភាពដែលមានការផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការទៅជា សេដ្ឋកិច្ចទីផ្សារសេរី និងជម្រុញការនាំចេញ ។ ក្នុងអំឡុងពេលនេះ នាយកដ្ឋានជលផលនៃក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ មានសមត្ថកិច្ចខាងផ្លូវច្បាប់ក្នុងការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍធនធានជលផល ។ លើសពីនេះបច្ចុប្បន្ននាយកដ្ឋានជលផលមានភារៈទទួលខុសត្រូវពង្រឹងការអនុវត្តបទបញ្ញត្តិ ការជួលឡូតិ៍នេសាទ និងការចេញអាជ្ញាប័ណ្ណ ការប្រមូលប្រាក់ឈ្នួលពីសកម្មភាពទាំងនេះ និងគ្រប់គ្រងការកែច្នៃផលនេសាទ ការធ្វើពាណិជ្ជកម្ម ព្រមទាំងសកម្មភាពនាំចេញ ។

ក្នុងអំឡុងឆ្នាំ១៩៩៨-២០០០ ក្រោយពីបានឈ្នះក្នុងការដេញថ្លៃ អ្នកកាន់កាប់ឡូតិ៍នេសាទភាគច្រើនបានជួលបន្តឡូតិ៍នេសាទដែលខ្លួនកាន់កាប់ដោយបែងចែកដែននេសាទជាផ្នែកតូចៗសម្រាប់ការជួលបន្ត ។ អនុលោមតាមច្បាប់ជលផល ទោះបីនេះជាសកម្មភាពល្មើសច្បាប់ក្តី តែពុំឃើញមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពឡើយ ។ នៅអំឡុងពេលនោះដែរ មានការដាក់ឡូតិ៍នេសាទមួយចំនួនសម្រាប់ការស្រាវជ្រាវ ដែលផ្តល់លទ្ធភាពដល់អ្នកកាន់កាប់ឡូតិ៍នេសាទនូវការចាត់ចែងពាក់ព័ន្ធនឹងប្រាក់កំរៃជើងសារ ។ នេះជាហេតុផលចម្បងមួយដែលនាំឱ្យមានកំណែទម្រង់គោលនយោបាយ វិស័យជលផលក្នុងថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០។ ទំនាស់បានកើតឡើងរវាងអ្នកកាន់កាប់ឡូតិ៍នេសាទ និងអ្នកនេសាទ ដោយសារកំណើនចំនួនប្រជាពលរដ្ឋនេសាទ ការលួចទន្ទ្រានចូលក្នុងដែននេសាទសាធារណៈ និងការចាប់យកឧបករណ៍នេសាទដោយឥតរើសមុខពីសំណាក់អ្នកកាន់កាប់ឡូតិ៍នេសាទ ។

## កំណែទម្រង់គោលនយោបាយវិស័យជលផល

ការគ្រប់គ្រងវិស័យជលផលក្នុងប្រទេសកម្ពុជា បានជួបប្រទះបញ្ហាជាច្រើនឆ្នាំមកហើយ ដោយសារការគាំទ្រឱ្យមានការធ្វើអាជីវកម្មទ្រង់ទ្រាយធំជាលក្ខណៈពាណិជ្ជកម្ម និងការប្រមូលប្រាក់ចំណូលជាហេតុនាំឱ្យមានទំនាស់លើការប្រើប្រាស់ធនធានក្នុងខេត្តជាច្រើននៅជុំវិញបឹងទន្លេសាប និងទន្លេមេគង្គ ។ ភាគច្រើននៃបញ្ហាក្នុងការគ្រប់គ្រងជាប់ពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ចជាអាទិ៍ អំពើពុករលួយក្នុងចំណោមមន្ត្រីពង្រឹងការអនុវត្តច្បាប់ និងមន្ត្រីមូលដ្ឋាន ការប្រមូលប្រាក់ចំណូលបានតិចតួចសម្រាប់

[៩] Thay, 2002.

រដ្ឋាភិបាល ព្រមទាំងអសមធម៌លើការចែកផលប្រយោជន៍ខាងសេដ្ឋកិច្ចពីធនធានទាំងនោះ ។ ទោះបីបញ្ហាទាំងនេះនៅបន្តគម្រាមកំហែងចំពោះសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជាក្តី ផលប៉ះពាល់អេកូឡូស៊ីបានស្តែងឡើងកាន់តែច្បាស់ ដូចជាមានភស្តុតាងនៃការធ្លាក់ចុះផលិតផលត្រីប្រភេទខ្លះ បណ្តាលពីទម្លាប់នៃការនេសាទច្រើនហួសហេតុ ។

នៅខែតុលា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រីបានធ្វើសេចក្តីសម្រេចដោយពុំមានការរំពឹងទុកជាមុនក្នុងការកាត់ និងលប់ឡូតិ៍នេសាទឱ្យទៅសហគមន៍មូលដ្ឋាន ។ កំណែទម្រង់គោលនយោបាយជលផលអាចពាក់ព័ន្ធនឹងកំណើននៃភាពតានតឹង និងទំនាស់រវាងអ្នកកាន់កាប់ឡូតិ៍នេសាទជាមួយអ្នកនេសាទក្នុងមូលដ្ឋានក្នុងអំឡុងពេល៣ឆ្នាំមុន ព្រមទាំងចេតនារបស់រដ្ឋាភិបាល ដើម្បីរៀបចំខ្លួនឱ្យបានល្អសម្រាប់ការបោះឆ្នោត ឃុំ-សង្កាត់នៅឆ្នាំ២០០២ ក៏ដូចជាសម្រាប់ការបោះឆ្នោតជាតិ ខែកក្កដា ឆ្នាំ២០០៣ផងដែរ ។

បច្ចុប្បន្នមានកិច្ចការថ្មី និងប្រកបដោយការប្រកួតប្រជែងសម្រាប់នាយកដ្ឋានជលផល ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ រដ្ឋាភិបាលទាំងមូល និងអ្នកនេសាទ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការអនុវត្តទស្សនវិស័យថ្មីនៃសហគមន៍នេសាទ ឬសហគ្រប់គ្រងជលផល ។ ការប្រឹងប្រែងធ្វើឱ្យមានច្បាប់ជលផលថ្មីបានសំដែងឱ្យឃើញពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែទម្លាប់បច្ចុប្បន្ន និងប្រកាន់យកវិធីគ្រប់គ្រងធនធានដោយផ្អែកលើសហគមន៍[១០] ។

## បញ្ហា និង ការលំបាក

សហគមន៍មូលដ្ឋាន ម្ចាស់អំណោយ ភាគីពាក់ព័ន្ធផ្សេងទៀតបានចាត់ទុកគោលនយោបាយវិស័យជលផលជាដំណើរការល្អ និងមានប្រជាប្រិយភាព។ ប៉ុន្តែនៅមានបញ្ហា និងឧបសគ្គជាច្រើនដែលត្រូវប្រឈមដើម្បីអនុវត្តកំណែទម្រង់នេះឱ្យមានប្រសិទ្ធិភាព ។ ករណីសិក្សាមួយធ្វើឡើយដោយ Thay (2002) និងការស្រាវជ្រាវបឋមមួយធ្វើដោយគម្រោងវាយតម្លៃផលប៉ះពាល់នៃកំណែទម្រង់គោលនយោបាយជលផល (DFID - DoF) បង្ហាញថា ការខកខានមិនបានផ្តល់ការគាំទ្រ និងធនធានដើម្បីអនុវត្តកំណែទម្រង់អាចធ្វើឱ្យខូចរាល់ផលប្រយោជន៍ដែលទទួលបានរួចមកហើយ ។ ប្រការនេះកើតឡើងដោយសារ ការខ្វះចន្លោះនៅក្នុងច្បាប់ ស្ថាប័ន និងរដ្ឋបាលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា ជាហេតុធ្វើឱ្យក្រុមអ្នកមានធនធាន អ្នកមានអំណាច និងអ្នកមានឥទ្ធិពលធ្វើវិទ្ធង្សនាប្រឆាំងនឹងបំណងល្អនៃកំណែទម្រង់នេះ ។

យោងតាមសេចក្តីថ្លែងការណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាល គោលបំណងមួយក្នុងចំណោមគោលបំណងចម្បងជាច្រើននៃកំណែទម្រង់វិស័យជលផល គឺការលើកកម្ពស់សន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ក្នុងចំណោមអ្នកនេសាទនៅមូលដ្ឋាន ។ ប៉ុន្តែ ការកែលំអជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រតាមរយៈកំណែទម្រង់ជលផល ប្រហែលពុំអាចធ្វើទៅបាន

[១០] ព្រឹត្តិបត្រសិក្សាប្រចាំតំបន់ស្តីពី CBNRM ខែ កក្កដា ឆ្នាំ ២០០២

ឡើយព្រោះថា អ្នកនេសាទក្រីក្រពុំមានប្រាក់គ្រប់គ្រាន់ដើម្បីទិញឧបករណ៍នេសាទទំនើប ដែលអាចប្រើប្រាស់ក្នុងការនេសាទត្រីឱ្យបានច្រើនឡើយ ផ្ទុយទៅវិញអ្នកនេសាទដែលមានធនធានអាចចាប់យកកាលានុវត្តនភាពនេះ ដើម្បីបង្កើនការធ្វើអាជីវកម្មដោយទិញសម្ភារៈថ្មីៗ និងបង្កើនការនេសាទដើម្បីប្រមូលផលនេសាទឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន[១១] ។

លើសពីនេះ កំណែទម្រង់គោលនយោបាយពុំមែនជាការធានាកែលំអប្រព័ន្ធគ្រប់គ្រង ដោយពុំត្រូវការឱ្យមានការកែលំអតម្លាភាព សេរីភាពខាងព័ត៌មាន និងប្រសិទ្ធភាពនៃការអនុវត្តតាមរយៈការប្រើប្រាស់មន្ត្រីដែលទទួលប្រាក់បៀវត្សរ៍សមស្រប និងបានទទួលការបណ្តុះបណ្តាលសមរម្យនោះឡើយ ។ ជាង ៥៦% នៃឡូតិ៍នេសាទត្រូវបានកាត់និងលប់ជាអចិន្ត្រៃយ៍ដើម្បីបង្វិលទៅឱ្យសហគមន៍ ប៉ុន្តែពុំមានរចនាសម្ព័ន្ធច្បាប់ ការផ្តល់មូលនិធិ ឬ ការបណ្តុះបណ្តាលដើម្បីគាំទ្រការបង្កើតសហគមន៍នេសាទនៅក្នុងតំបន់ទាំងនោះឡើយ ដែលបានក្លាយទៅដែននេសាទសាធារណៈ និងបង្កឱ្យមានភាពច្របូកច្របល់អំពីសិទ្ធិក្នុងការប្រើប្រាស់ និងពីការកើតឡើងនូវការធ្វើអាជីវកម្មអនាធិបតេយ្យ និងការនេសាទល្មើសច្បាប់ ។

មានការលើកឡើងនូវកង្វល់អំពីការបង្កើតសហគមន៍នេសាទដោយប្រញាប់ប្រញាល់ ដើម្បីបំពេញភាពខ្វះចន្លោះក្រោយពីការកាត់ និងលុបដែននេសាទពីឡូតិ៍នេសាទ ។ នៅពេលខ្វះវិធានការបន្ទាន់ ការធ្វើបែបនេះអាចនាំឱ្យមានបញ្ហាជាច្រើនដោយសារការយល់មិនបានច្បាស់អំពីទស្សនវិស័យ ការខ្វះព័ត៌មានសំខាន់ៗដូចជាផែនទី ផលនេសាទ និងកម្រិតស្តុកក្នុងធម្មជាតិ សេចក្តីត្រូវការរបស់អ្នកនេសាទ និងការពិចារណាទិដ្ឋភាពបរិស្ថាន ទន្ទឹមនឹងការខកខានមិនបានបង្កើត និងអនុវត្តបទប្បញ្ញត្តិព្រមទាំងរចនាសម្ព័ន្ធឱ្យមានប្រសិទ្ធិភាព ។ បច្ចុប្បន្ន មានតម្រូវការចាំបាច់ដើម្បីពង្រឹងសមត្ថភាពជួយខ្លួនឯង ដូចជាការកសាងសមត្ថភាពសម្រាប់វិភាគបញ្ហាទំនាក់ទំនងព័ត៌មាន ការចាត់ចែងការចរចា និងការកសាងផែនការ ។ ការលំបាកទាំងនេះត្រូវធ្លាក់លើការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ដែលទទួលខុសត្រូវសម្របសម្រួលជាមួយផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន ជាពិសេសជាមួយអ្នកភូមិនៅក្នុងមូលដ្ឋាន ដើម្បីអនុវត្តយន្តការសហគមន៍នេសាទឱ្យមានប្រសិទ្ធភាព និងប្រកបដោយជោគជ័យ ។

## ដំណើរការពិគ្រោះយោបល់

ក្រោយមានការពិគ្រោះយោបល់ជាមួយសហគមន៍អ្នកនេសាទ អង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាកិច្ចប្រឹងប្រែងនានា បានចាប់ផ្តើមផ្តោតជាសំខាន់លើការកែលំអគោលនយោបាយ ឈានទៅបង្កើតក្របខ័ណ្ឌច្បាប់ច្បាស់លាស់ និងដែលអាចអនុវត្តបាន ដោយអនុញ្ញាតឱ្យបង្កើតសហគមន៍នេសាទក្នុងតំបន់ដែលបានកំណត់ ។

[១១] Thay, 2002

សេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ បានធ្វើឡើងនៅក្នុងដំណាក់កាលដំបូងនៃកំណែទម្រង់វិស័យជលផល ដើម្បីគាំទ្រការបង្កើតសហគមន៍នេសាទ ហើយបច្ចុប្បន្នកំពុងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី ។ សេចក្តីព្រាងច្បាប់ជលផលថ្មីក៏កំពុងស្ថិតក្នុងស្ថានភាពដូចគ្នានេះដែរ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ប្រាក់កំចីដល់ប្រទេសកម្ពុជា សម្រាប់កសាងសហគមន៍នេសាទនៅតំបន់ជុំវិញបឹងទន្លេសាប ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងផ្តល់ជំនួយបច្ចេកទេសសម្រាប់ការពិនិត្យឡើងវិញ និងអនុវត្តក្របខ័ណ្ឌច្បាប់ ព្រមទាំងគោលនយោបាយសម្រាប់គ្រប់គ្រងជលផលនៅបឹងទន្លេសាប ។

អនុលោមតាមអនុសាសន៍យ៉ាងហ្មត់ចត់របស់ក្រុមពិគ្រោះយោបល់ដែលជួបប្រជុំ២ឆ្នាំម្តង នៅទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ នាយកដ្ឋានជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសហការជាមួយអង្គការអុកស្វាមអង់គ្លេស អុកស្វាមអាមេរិកកាំង និងអង្គការ WWF ដើម្បីធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទនៅមូលដ្ឋាន មន្ទីរកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទខេត្ត អាជ្ញាធរមូលដ្ឋាន មន្ត្រីជលផល និងអ្នកពាក់ព័ន្ធដទៃទៀតលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ។

សេចក្តីព្រាងបច្ចុប្បន្ននៃច្បាប់ជលផលត្រូវបានចាត់ទុកថាគ្រប់គ្រាន់ និងអាចអនុវត្តបានដោយផ្អែកលើសេចក្តីកែតម្រូវលើច្បាប់ជលផលចាស់ ដែលធ្វើឡើងដោយនាយកដ្ឋានជលផល អង្គការអុកស្វាមអង់គ្លេស អុកស្វាមអាមេរិកកាំង និងអង្គការ WWF ជាមួយនឹងការគាំទ្រដោយប្រាក់កម្ចីពីធនាគារពិភពលោកដល់នាយកដ្ឋានជលផល ។ បច្ចុប្បន្ន សេចក្តីព្រាងច្បាប់ជលផលនេះបានរៀបចំរួចស្រេចបាច់ហើយ និងបានប្រគល់ជូនទៅឱ្យនាយកដ្ឋានជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយដែរ ។

## ការពង្រឹងការអនុវត្តច្បាប់ និងការតាមដាន

ការពង្រឹងការអនុវត្តច្បាប់ នឹងត្រូវធ្វើឡើងខុសៗគ្នានៅក្នុងសហគមន៍ខុសគ្នា ដោយផ្អែកលើភាពជិតស្និទ្ធរវាងសហគមន៍ អាជ្ញាធរ និងអ្នកពាក់ព័ន្ធដទៃទៀត ។ ការគ្រប់គ្រងសហគមន៍ពុំមែនមានន័យថា តំបន់ទាំងនោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដោយសហគមន៍តែឯងមិនពាក់ព័ន្ធជាមួយរដ្ឋាភិបាលនោះឡើយ ។ ការចូលរួមរបស់អាជ្ញាធរនានា គឺជាប្រការចាំបាច់ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ។

អនុក្រឹត្យស្តីពីសហគមន៍នេសាទ អំពាវនាវឱ្យសហគមន៍ធ្វើសេចក្តីរាយការណ៍ និងធ្វើសហប្រតិបត្តិការជាមួយអ្នកនេសាទ និងអាជ្ញាធរមូលដ្ឋាន ដើម្បីលុបបំបាត់ និងរឹបអូសឧបករណ៍ល្មើសច្បាប់ ។ ប្រការនេះនឹងផ្តល់ឱ្យសហគមន៍នូវការទទួលខុសត្រូវ ដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិនេសាទ ប៉ុន្តែ ពុំសុទ្ធតែផ្តល់អំណាចឱ្យសហគមន៍ចាត់វិធានការណ៍គ្រប់ករណីនោះឡើយ ជាពិសេសក្នុងពេលប្រឈមជាមួយអ្នកនេសាទល្មើសច្បាប់ ដែលប្រើអំពើហិង្សា និងករណីដទៃទៀត ។

សហគមន៍ខ្លះបានសង្កត់ធ្ងន់ពីតម្រូវការឱ្យមានអំណាចច្រើន ដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិរបស់ពួកគេ ដោយអះអាងថា តម្រូវការពេលវេលាវែងដើម្បីទទួលដំណឹង និងការចាត់វិធានការណ៍ពីសំណាក់អាជ្ញាធរពាក់ព័ន្ធប្រឆាំងអ្នកប្រព្រឹត្តបទល្មើសមានន័យថា ជាញឹកញាប់ជនល្មើសមិនត្រូវបានឃាត់ខ្លួនឡើយ ។ ប្រការនេះអាចផ្តល់លទ្ធភាពឱ្យសហគមន៍ធ្វើការផាកពិន័យអ្នកប្រព្រឹត្តបទល្មើស និងប្រមូលប្រាក់ចំណូលជាប្រយោជន៍សហគមន៍ទាំងមូល ។

ការចូលរួមរបស់សហគមន៍ដើម្បីពង្រឹងការអនុវត្តច្បាប់ គឺជាមធ្យោបាយច្បាស់លាស់មួយដើម្បីកែលម្អអភិបាលកិច្ច និងជម្រុញឱ្យមានអ្នកពាក់ព័ន្ធកាន់តែច្រើនក្នុងកិច្ចការពារធនធានធម្មជាតិ ។ ប៉ុន្តែ គួរចាត់វិធានការណ៍នេះដោយប្រុងប្រយ័ត្ន ដើម្បីធានាថាការអភិវឌ្ឍ និងការអនុវត្តវិន័យប្រកបដោយតម្លាភាព នឹងនាំមកនូវផលប្រយោជន៍ប្រកបដោយផ្លែផ្កាសម្រាប់សហគមន៍ទាំងមូល ។

ទន្ទឹងនឹងពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធតាមដាន ត្រូវបង្កើតប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព យុត្តិធម៌ និងឯករាជ្យសម្រាប់ការលើកទឹកចិត្ត និងដោះស្រាយក្នុងការរម្លោកទុក្ខរបស់អ្នកពាក់ព័ន្ធនានា ទាំងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ ត្រូវមានការយកចិត្តទុកដាក់ ដើម្បីធានាថា ច្បាប់ត្រូវបានអនុវត្តប្រកបដោយលក្ខណៈទៀងទាត់ និងហ្មត់ចត់ ។

## សេចក្តីសន្និដ្ឋាន

ក្នុងនាមជាចំណែកមួយនៃធនធានធម្មជាតិដ៏សម្បូរបែបក្នុងប្រទេសកម្ពុជា ធនធានជលផលមានសារៈសំខាន់ជាអាយុជីវិតសម្រាប់ប្រជាពលរដ្ឋកម្ពុជាច្រើនលាននាក់ រួមទាំងសម្រាប់ជីវភាពរស់នៅ ប្រភពប្រាក់ចំណូល ប្រព័ន្ធអេកូឡូស៊ី និងជីវៈ-ចម្រុះ ។ ប៉ុន្តែ ការគម្រាមកំហែងនានាដែលអាចកើតមានឡើងចំពោះធនធានជលផល ដែលមិនអាចកាត់ថ្លៃបានទាំងនេះមានច្រើនណាស់រួមទាំង : ភាពពុំច្បាស់លាស់នៃក្របខ័ណ្ឌច្បាប់ ភាពទន់ខ្សោយនៃស្ថាប័ន កំណើនចំនួនប្រជាពលរដ្ឋ និងការធ្វើអាជីវកម្មធនធានទាំងនេះ ដោយគ្មាននិរន្តរភាពបណ្តាលពីភាពក្រីក្រ ។ កំណែទម្រង់គោលនយោបាយ វិស័យជលផលក្នុងពេលថ្មីៗនេះ ស្របជាមួយដំណើរវិមជ្ឈការរបស់រដ្ឋាភិបាលដែលនាំឱ្យមានការកាត់ និងលុបឡូតិ៍នេសាទ ៥៦% ទៅឱ្យសហគមន៍មូលដ្ឋានគ្រប់គ្រង អភិរក្ស ប្រើប្រាស់ និងអភិវឌ្ឍក្រោមរូបភាពសហគ្រប់គ្រង អាចជាជម្រើសមួយសម្រាប់ធានានិរន្តរភាពជីវភាពរស់នៅ និងកែលំអធនធានជលផល ។ ប៉ុន្តែមានការលំបាកជាច្រើននៅខាងមុខ ដែលអាចជាឧបសគ្គក្នុងការសម្រេចគោលដៅនេះ ។ ការប្តេជ្ញា និងកិច្ចប្រឹងប្រែងជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជាមានសារៈសំខាន់ណាស់ ។ ដូចគ្នានេះដែរសហគមន៍អ្នកផ្តល់ជំនួយរួមទាំងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបន្តផ្តល់ជំនួយ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីអាចចាត់វិធានការណ៍សម្រេចឱ្យបាននូវគោលដៅចុងក្រោយនៃការកាត់បន្ថយភាពក្រីក្រ ។

## REFERENCES


Degen and Nao. 2000 in Bruce et al,2002:54.

Fisheries Action Coalition Team and Environmental Justice Foundation, 2002. *Feast or Famine? Solutions to Cambodia's Fisheries Conflicts.*

Fisheries Action Coalition Team, Community Based Natural Resource Management and Environmental Justice Foundation. 2002. *Making Community Fisheries Work in Cambodia.* (Poster Presentation)

Fisheries Action Coalition Team, Community Based Natural Resource Management and Environmental Justice Foundation. 2002. *Feast or Famine? Cambodia's Essential Fisheries Resource Under Threat.* (Poster Presentation)

McKenney, B and Prom T. July 2002. *Natural Resource and Rural Livelihood in Cambodia: a Baseline Assessment.* Working Paper 23 of Cambodia Development Research Institute.

Thay, S. 2002. *Concept of Fisheries Co-Management in Cambodia* (Masters thesis paper).

Thay, S. 2002. *A Case Study on Fisheries Policy Reforms and the Current Perception about Community fisheries.*

Touch, ST and Todd, BH. 2002. *The Inland and Marine Fisheries Trade of Cambodia.*

# ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិ
# ដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា



## ផ្នែក គ

## ការរៀបចំបណ្តាញការងារ ក្រុមការងារ និងស្ថាប័ន :
## កសាងទំនាក់ទំនងក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ

# ផ្នែក គ

# ការរៀបចំបណ្ដាញការងារ ក្រុមការងារ និងស្ថាប័ន : កសាងទំនាក់ទំនងក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ

ជំពូក ៦

បណ្ដាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ

រៀបរៀងដោយ : លោក ជាន ថាយុទ្ធ និង កញ្ញា អ៊ូ សុភារី

ជំពូក ៧

ការអភិវឌ្ឍ និងការរៀបចំបណ្ដាញសហគមន៍នេសាទ

រៀបរៀងដោយ : លោក ថាយ សុមុនី លោក ស៊ឹម ប៊ុនធឿន និងអ្នកស្រី សូ ស្រីមុំ

ជំពូក ៨

សហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា : ការរៀបចំបណ្ដាញការងារ និងការបង្កើតទស្សនទាន

រៀបរៀងដោយ : អ្នកស្រី កែន សុភាព កញ្ញា Amanda Bradley លោក ហ៊ុយ វង្សរស្មីតារា និង លោក យិន សូរិយា

ជំពូក ៩

ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា

រៀបរៀងដោយ : លោក មិន ប៊ុណ្ណារ៉ា លោកបណ្ឌិត Harald Kirsch និង លោក Ignas Dümmer

ជំពូក ១០

ការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា

រៀបរៀងដោយ : លោក មាស សុធនវឌ្ឍនៈ និង កញ្ញា សាន្ត សុជាតិលក្ខិណា

---

រូបថត : បូរ៉ា សុន / WWF-CBNRM LI 2003

# ជំពូក ៦ បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ

រៀបរៀងដោយ លោក ជាន ថាយុទ្ធ[១] និង កញ្ញា អ៊ូ សុភារី[២និង៣]

## សេចក្តីផ្តើម

បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិជាបណ្តាញការងារមួយក្នុងចំណោមបណ្តាញការងារសហគមន៍ធនធានធម្មជាតិនៅកម្ពុជា ។ តាមរយៈកិច្ចប្រជុំ និងព្រឹត្តិប័ត្រប្រចាំត្រីមាស បណ្តាញនេះគឺជាវេទិកាមួយសម្រាប់អ្នកអនុវត្តនៅគ្រប់លំដាប់ថ្នាក់ក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍ជុំវិញការចូលរួមរបស់សហគមន៍ពាក់ព័ន្ធនឹងការចូលរួមគ្រប់គ្រងព្រៃឈើទាំងនៅក្នុងនិងក្រៅតំបន់ការពារធម្មជាតិ ។ ជំពូកនេះបង្ហាញពីស្ថានភាពទូទៅនៃការវិវឌ្ឍផលប្រយោជន៍ ព្រមទាំងបញ្ហាមួយចំនួនដែលបណ្តាញជួបប្រទះ និងអនុសាសន៍ដើម្បីកែលំអបណ្តាញនេះ នាពេលអនាគត ។

## ហេតុអ្វីតម្រូវឱ្យមានបណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ? តើបណ្តាញការងារជាអ្វី ?

មានការយល់ឃើញខុសៗគ្នាជាច្រើនអំពីនិយមន័យនៃពាក្យ "បណ្តាញការងារ"។ Starkey (១៩៩៧) បានឱ្យនិយមន័យបណ្តាញការងារថា ជាក្រុមមនុស្ស ឬស្ថាប័នដែលស្ម័គ្រចិត្ត ផ្លាស់ប្តូរព័ត៌មាន ឬធ្វើសកម្មភាពនានារួមគ្នា ដោយចាត់ចែងបង្កើតជាបណ្តាញការងារនេះដោយខ្លួនឯង តែរក្សាឯករាជ្យភាពរៀងៗខ្លួន។ ដោយមិនគិតពី "មធ្យោបាយក្នុងការប្រាស្រ័យទាក់ទង រចនាសម្ព័ន្ធ និងការចាត់ចែងរបស់បណ្តាញ ប្រការសំខាន់ គឺធ្វើយ៉ាងណាឱ្យបណ្តាញការងារមានសកម្មភាពរស់រវើក"។

នៅក្នុងជំពូកនេះ បណ្តាញការងារសំដៅលើចំណងទាក់ទងរួមរវាងបណ្តាអ្នកដែលមានគោលបំណងដូចគ្នាដើម្បី អភិវឌ្ឍនិងចែករំលែកព័ត៌មាន ព្រមទាំងបទពិសោធន៍រវាងគ្នា ។

## ហេតុអ្វីបានជាមានបណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ?

ធនធានធម្មជាតិ ជាពិសេសព្រៃឈើមានសារៈសំខាន់ចំពោះអាយុជីវិតមនុស្សគ្រប់រូប ។ ព្រៃឈើជាជម្រកសម្រាប់រុក្ខជាតិ និងសត្វរាប់លានប្រភេទ ព្រៃឈើជួយការពារដីទល់នឹងការហូរច្រោះ ផលិតអុកស៊ីសែន និងស្រូបយកនូវឧស្ម័នកាបូនិច ព្រមទាំងជួយរក្សាតុល្យភាពអាកាសធាតុក្នុងតំបន់ និងពិភពលោកទាំងមូល ។ នៅកម្ពុជា ព្រៃឈើក៏មានសារៈប្រយោជន៍ណាស់ដែរសម្រាប់មនុស្ស ជាពិសេសសហគមន៍ដែលរស់នៅតាមទីជនបទក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ មានជាអាទិ៍

---

[១] លោក ថាយុទ្ធ ជាជំនួយការបច្ចេកទេស និងជាទីប្រឹក្សាគម្រោង CBNRM LI ។ មុននេះលោកធ្លាប់ធ្វើការជាមួយអង្គការConcern Worldwide និង PRASAC/EU

[២] កញ្ញា សុភារី ធ្វើការជាមួយអង្គការConcern Worldwide

[៣] ការចូលរួមចំណែកពីលោកស្រី Vaneska Litz និងសមាជិកគណៈកម្មការរៀបចំបណ្តាញសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ

ផ្តល់អាហារ អុស ឱសថបុរាណ និងសម្ភារៈសំណង់ ។ ក៏ប៉ុន្តែ ការគម្រាមកំហែងនានា ដូចជាការកាប់ឈើល្មើសច្បាប់ និងដោយអាណាធិបតេយ្យ ព្រមទាំងការរានដីសម្រាប់ធ្វើកសិកម្ម និងសម្រាប់គោលបំណងអភិវឌ្ឍនានា បាននាំឱ្យធនធានធម្មជាតិរងការរេចរឹល ជាខ្លាំង ។

នៅឆ្នាំ ១៩៩១ នាយកដ្ឋានរុក្ខា-ប្រមាញ់ ( បច្ចុប្បន្នរដ្ឋបាលព្រៃឈើ បានផ្តើមលើកទឹកចិត្តសហគមន៍មូលដ្ឋានឱ្យចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ ។ នាយកដ្ឋាននេះទទួលស្គាល់ថា ដើម្បីគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ចាំបាច់ត្រូវឱ្យមានការចូលរួមពីសំណាក់អ្នកដែលរស់នៅជិតព្រៃ ដែលការចិញ្ចឹមជីវិតរបស់ពួកគាត់ពឹងផ្អែកជាចម្បងលើធនធានព្រៃឈើ ។ ក្នុងពេលនោះ សហគមន៍ព្រៃឈើចំនួន២ ត្រូវបានបង្កើតឡើង : នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ( គាំទ្រថវិកាដោយអង្គការខុនសឺនកម្ពុជា និងនៅស្រុកត្រាំកក់ ខេត្តតាកែវ (គាំទ្រថវិកាដោយអង្គការ MCC) ។

ទោះបីនៅពេលនោះ សហគមន៍ព្រៃឈើគឺជាទស្សនទានថ្មីមួយសម្រាប់ប្រជាពលរដ្ឋកម្ពុជាក៏ដោយ ការរៀបចំសហគមន៍ ព្រៃឈើបានរីកសាយភាយដល់ខេត្តផ្សេងៗ នៅទូទាំងប្រទេស រួមមានខេត្តស្វាយរៀង ខេត្តរតនគិរី ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តពោធិ៍សាត់ ។ ដើមឡើយ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលមានជំនាញសហគមន៍ព្រៃឈើ បន្ទាប់ពីពួកគេបានចូលរួមវគ្គបណ្តុះបណ្តាលនៅតាមប្រទេសមួយចំនួននៅក្នុងតំបន់ ។ ប៉ុន្តែអ្នកទាំងនោះខ្វះបទពិសោធន៍ ការងារជាក់ស្តែងនៅមូលដ្ឋាន ហើយទោះបីសហគមន៍ព្រៃឈើបានទទួលការគាំទ្រយ៉ាងពេញទំហឹងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្តក៏ដោយចម្ងល់ ជាច្រើនតែងតែមាននៅឡើយនៅថ្នាក់ជាតិពីអត្ថន័យនៃ "សហគមន៍ព្រៃឈើ " និងពីការអនុវត្តទស្សនទាននេះ ។

ដើម្បីលើកកំពស់ការយល់ដឹងពីទស្សនទានសហគមន៍ព្រៃឈើនៅថ្នាក់ជាតិ និងដើម្បីផ្តល់ឱកាសឱ្យអ្នកអនុវត្តការងារសហគមន៍ព្រៃឈើ បានចែករំលែកបទពិសោធន៍រវាងគ្នា បណ្តាញការងារសហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ។

## ការអំពាវនាវរបស់សហគមន៍

នៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ បណ្តាញការងារផ្សេងៗត្រូវបានរៀបចំឡើងដើម្បីចែករំលែកបទពិសោធន៍រវាងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងដើម្បីពិភាក្សា និងដោះស្រាយបញ្ហាមួយចំនួន ដែលកើតឡើងនៅក្នុងមូលដ្ឋាន ។ សមាជិកសំខាន់ៗ នៃបណ្តាញនេះមានជាអាទិ៍ តំណាងមកពីសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន តំណាងអង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ។ ជាទូទៅបណ្តាញការងារទាំងនេះ រៀបចំឡើងរៀងរាល់ពីរ ឬបីខែម្តង ។

បណ្តាញការងារដែលមានក្នុងពេលបច្ចុប្បន្នមានជាអាទិ៍ ៖

- បណ្តាញការងារគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ខេត្តពោធិ៍សាត់
- បណ្តាញការងារសហគមន៍ព្រៃឈើ ខេត្តកំពង់ឆ្នាំង
- បណ្តាញការងារសហគមន៍ព្រៃឈើ ស្រុកដំបែរ ខេត្តកំពង់ចាម
- បណ្តាញការងារព្រៃឈើ ខេត្តក្រចេះ

## ការអំពាវនាវរបស់អង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងគាំទ្រការរៀបចំសហគមន៍ព្រៃឈើនិងសហគមន៍តំបន់ការពារធម្មជាតិ បានចាប់ផ្តើមសហការលើសកម្មភាពការងារមួយចំនួន ដើម្បីជៀសវាងនូវការធ្វើការងារជ្ជួនគ្នា។ អង្គការទាំងនោះមានជាអាទិ៍ អង្គការខុនសឺន អង្គការអុកស្វាមអង់គ្លេស គម្រោង CBNRM Learning Initiative/WWF គម្រោង CFI/CFAC គម្រោង MRC/GTZ អង្គការម្លប់បៃតង អង្គការ FAO កម្មវិធី NREM/PLG/SEILA គម្រោង CFRP គម្រោង JICA អង្គការ LWF និងអង្គការ FFI ។

## ការអំពាវនាវរបស់ម្ចាស់ជំនួយ

អង្គការដានីដា និងម្ចាស់ជំនួយដទៃទៀតបានចូលរួមនៅក្នុងកិច្ចប្រជុំបណ្តាញការងារនេះ និងថែមទាំងបានផ្តល់ជាថវិកាគាំទ្រដល់ដំណើរការនៃបណ្តាញការងារនេះតាមរយៈអង្គការខុនសឺនទៀតផង ។ អង្គការដានីដាក៏ជាសហប្រធាននៃគណៈកម្មការរួមរវាងរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយផងដែរ ដែលធ្វើការសម្របសម្រួលការងារខាងវិស័យព្រៃឈើ ហេតុដូច្នេះ អង្គការនេះ អាចប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយម្ចាស់ជំនួយផ្សេងទៀត និងជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋបាលព្រៃឈើផងដែរ ។ ប្រការនេះសំខាន់ណាស់ព្រោះថា បណ្តាញការងារនេះផ្តោតការយកចិត្តទុកដាក់លើបញ្ហាជំនួយអភិវឌ្ឍន៍ រួមមានកំណែទម្រង់របស់រដ្ឋាភិបាល និងការផ្លាស់ប្តូរគោលនយោបាយផ្សេងៗផងដែរ ។ លោកនាយក និងនាយករង តំណាងនៃរដ្ឋបាលព្រៃឈើក៏មានសមាសភាពក្នុងគណៈកម្មការនេះផងដែរ ហើយម្ចាស់ជំនួយដទៃទៀត ដែលជាសមាជិកគណៈកម្មការនេះដែរ រួមមានគម្រោង JICA ធនាគារពិភពលោក និងអង្គការ DFID ។

## សមាជិកភាព

បណ្តាញការងារនេះបើកទូលាយសម្រាប់ការចូលជាសមាជិកពីសំណាក់អ្នកអនុវត្តការងារ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ អ្នកសម្របសម្រួលផ្ទាល់នៅមូលដ្ឋាន អ្នករៀបចំគោលនយោបាយ សហគមន៍មូលដ្ឋាន អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងបុគ្គលដទៃទៀតដែលមានចំណាប់អារម្មណ៍ ។ ការពង្រីកសមាជិកភាពធ្វើឡើងតាមរយៈអ៊ីមែល ។ សមាជិកចាស់ៗត្រូវចែករំលែកព័ត៌មានអំពីបណ្តាញការងារនេះឱ្យទៅអ្នកដែលមានចំណាប់អារម្មណ៍ដទៃទៀតដែលជាសមាជិកថ្មី ។ មានសមាជិកមួយចំនួនទៀតត្រូវបានកំណត់ និងអញ្ជើញឱ្យចូលរួមទៅតាមតម្រូវការជាក់ស្តែង ។ ឧទាហរណ៍ មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ត្រីយោធាត្រូវបានអញ្ជើញឱ្យ

ចូលរួមដោយសារចាំបាច់ឱ្យមន្ត្រីទាំងនោះចែករំលែកព័ត៌មានជាមួយអ្នកចូលរួមដទៃទៀត និងដើម្បីឱ្យពួកគាត់បានជ្រាបពីបញ្ហាដែលបានកើតឡើង ព្រមទាំងដើម្បីសហការដោះស្រាយ ឬដើម្បីជៀសវាងទំនាស់នានា ។ តាមរយៈបណ្តាញការងារនេះ អាជ្ញាធរមូលដ្ឋានមានឱកាសរៀនសូត្រពីរបៀបអនុវត្តសកម្មភាពសហគមន៍ព្រៃឈើអោយសមស្របទៅតាមផ្លូវច្បាប់ ។ ដោយឡែកអ្នករៀបចំគោលនយោបាយអាចរៀនសូត្រពីបញ្ហានានា ដែលកើតមាននៅមូលដ្ឋាន និងអាចរៀបចំឱ្យមានការគាំទ្រតាមផ្លូវច្បាប់បានសមស្រប ដើម្បីការពារសិទ្ធិរបស់សហគមន៍ជនបទក្រីក្រ ។ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានបានរៀនសូត្រពីរបៀបផ្តល់ការគាំទ្រ ដែលឆ្លើយតបនឹងតម្រូវការរបស់សហគមន៍មូលដ្ឋាន ។ បណ្តាញការងារនេះត្រូវបានបង្កើតឡើងដើម្បីស្តាប់សម្លេងរបស់សហគមន៍មូលដ្ឋាន។

## បទពិសោធន៍របស់បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ

បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជាជាក្រុមអន្តរស្ថាប័នដែលមានការប្តេជ្ញា ដើម្បីកសាងការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ និងដើម្បីធានាឱ្យមានការពិភាក្សា និងផ្សព្វផ្សាយបានទូលំទូលាយពីបញ្ហាដែលពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ។ បណ្តាញការងារនេះមានការប្តេជ្ញាក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍នានា ។ ជាពិសេស បណ្តាញការងារនេះលើកទឹកចិត្តអ្នកពាក់ព័ន្ធទាំងអស់ឱ្យលើកឡើងអំពីបញ្ហាដែលពាក់ព័ន្ធ និងផ្តល់ជាវេទិកាសម្រាប់ពិភាក្សាដោយចំហ ដែលអាចរៀនសូត្រពីគ្នាដោយសេរី ។ ផ្អែកលើមូលដ្ឋាននៃបញ្ហាទាំងនេះ បណ្តាញការងារនេះសង្ឃឹមថានឹងបង្កើនលទ្ធផលក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងបុគ្គលនានា ទាំងនៅក្នុងពេលប្រជុំ និងពេលធ្វើទស្សនកិច្ចសិក្សា ដើម្បីបន្តរៀបចំគំរូសហគមន៍ព្រៃឈើនៅកម្ពុជា ។ បញ្ហាដែលជាកង្វល់ចម្បង៧ រួមមាន និរន្តរភាពនៃការចិញ្ចឹមជីវិត ការគ្រប់គ្រងព្រៃឈើ ការចូលរួមរបស់សហគមន៍ សកម្មភាពពាក់ព័ន្ធនឹងគោលនយោបាយ និងបញ្ហាបច្ចេកទេសដទៃទៀតជុំវិញការគ្រប់គ្រងព្រៃឈើ ។

បណ្តាញការងារនេះបានធ្វើការពិភាក្សាជាញឹកញាប់ ពីមធ្យោបាយសម្រាប់គ្រប់គ្រងសហគមន៍ព្រៃឈើប្រកបដោយនិរន្តរភាព វិធីដើម្បីបញ្ឈប់សមាជិកសហគមន៍ អ្នកមកពីក្រៅសហគមន៍ និងអ្នកភូមិជិតខាងដើរកាប់បំផ្លាញព្រៃទាំងនៅក្នុង និងក្រៅតំបន់ព្រៃសហគមន៍ ។ បទពិសោធន៍ពីសមាជិកនានា បានរួមចំណែកក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ ។ ថ្មីៗនេះ សហគមន៍មូលដ្ឋានបានធ្វើការបង្កើតគំរូស្តីពីការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍សម្រាប់ការប្រើប្រាស់ឱ្យឯកភាពគ្នានៅទូទាំងប្រទេស ជាគំរូរួមមួយ ដែលអាចអនុវត្តបាននៅមូលដ្ឋាន ។

បណ្តាញការងារនេះមិនពាក់ព័ន្ធនឹងបញ្ហានយោបាយទេ ម្យ៉ាងទៀតគោលបំណង និងទិសដៅរបស់បណ្តាញមិនអនុញ្ញាតឱ្យមានសកម្មភាពតស៊ូមតិជាលក្ខណៈប្រឈមមុខដាក់គ្នាឡើយ ។ ដោយសារបណ្តាញនេះមានគោលដៅលើកកំពស់ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ បណ្តាញការងារនេះបានផ្តោតតែលើការបង្កើតចំណងទាក់ទងរវាង និងក្នុងចំណោមសហគមន៍ អ្នកអនុវត្តការងារសហគមន៍ព្រៃឈើ និងម្ចាស់ជំនួយ ក៏ដូចជាអ្នករៀបចំគោលនយោបាយផងដែរ តាមរយៈការចែករម្លែកព័ត៌មាន និងការពិគ្រោះយោបល់ ។

## ការវិវឌ្ឍរបស់បណ្តាញការងារ

តាំងពីបណ្តាញការងារនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៨ បណ្តាញនេះបានវិវឌ្ឍជាបីដំណាក់កាលចម្បងៗ ដូចមានបង្ហាញនៅក្នុងប្រអប់ទី១ ខាងក្រោម ។

**ប្រអប់ទី ១ៈ អតីតភាព និងបច្ចុប្បន្នភាពនៃបណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ**

**ឆ្នាំ ១៩៩៧**

បណ្តាញការងារសហគមន៍ព្រៃឈើត្រូវបានបង្កើតឡើងក្រោមកិច្ចសហការរវាងផ្នែកសហគមន៍ព្រៃឈើនៃនាយកដ្ឋានរុក្ខា-ប្រមាញ់ និងផ្នែកសហគមន៍ព្រៃឈើនៃនាយកដ្ឋានការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន និងក្រោមជំនួយថវិកាពីគម្រោងគ្រប់គ្រងបរិស្ថានកម្ពុជា(CEMP) ។ បណ្តាញនេះតែងបានជួបប្រជុំនៅនាយកដ្ឋានរុក្ខា-ប្រមាញ់ ឬនៅក្រសួងបរិស្ថាន ។

**ឆ្នាំ ១៩៩៨_២០០១**

នៅពេលគម្រោង CEMP ត្រូវបានបញ្ចប់នៅខែកក្កដា ឆ្នាំ១៩៩៧ បណ្តាញការងារនេះត្រូវបានផ្អាកសកម្មភាពរបស់ខ្លួនអស់ជិតមួយឆ្នាំ ។ នៅឆ្នាំ១៩៩៨ អង្គការខុនសឺនកម្ពុជាបានចាប់ផ្តើមអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ និងមានចំណាប់អារម្មណ៍ក្នុងការគាំទ្របណ្តាញការងារនេះឱ្យដំណើរការឡើងវិញ ។ អង្គការខុនសឺនក៏ឯកភាពផ្តល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាដល់ផ្នែកសហគមន៍ព្រៃឈើនៃនាយកដ្ឋានរុក្ខា-ប្រមាញ់ និងផ្នែកសហគមន៍ព្រៃឈើនៃក្រសួងបរិស្ថានដើម្បីចាប់ដំណើរការបណ្តាញការងារនេះ បន្តទៅទៀត ។

**ឆ្នាំ២០០២ មកទល់បច្ចុប្បន្ន**

គំនិតដែលបង្កើតអោយមានគណៈកម្មការអចិន្ត្រៃយ៍ដើម្បីរៀបចំបណ្តាញសហគមន៍ព្រៃឈើ បានកើតចេញពីលទ្ធផលនៃការវាយតម្លៃអំពីតម្រូវការដែលបានធ្វើឡើងដោយសមាជិកបណ្តាញការងារនេះកាលពីឆ្នាំ ២០០០ ។ សំណើសុំនេះបានរៀបចំឡើងដោយអង្គការ ខុនសឺន និងបានដាក់ជូនទៅក្នុងកិច្ចប្រជុំបណ្តាញការងារនេះនៅខែមីនា ឆ្នាំ២០០២ ។ គំនិតនេះបានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់សមាជិកជាច្រើននៃបណ្តាញការងារនេះ ។

គណៈកម្មការអចិន្ត្រៃយ៍បច្ចុប្បន្ន រួមមានសមាជិកមកពីការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ (ពីមុនជាផ្នែកសហគមន៍ព្រៃឈើនៃនាយកដ្ឋានរុក្ខា-ប្រមាញ់ ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន (ពីមុនជាផ្នែកសហគមន៍ព្រៃឈើ អង្គការខុនសឺន អង្គការអុកស្វាមអង់គ្លេស គម្រោង CBNRM LI/WWF អង្គការម្លប់បៃតង គម្រោង CFI/CFAC និងគម្រោង MRC/GTZ ។ តួនាទីចម្បងរបស់គណៈកម្មការនេះ គឺចាត់ចែងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសសម្រាប់កំណត់យុទ្ធសាស្រ្ត កែលំអបណ្តាញការងារនេះ និងបោះពុម្ពព្រឹត្តិប័ត្របណ្តាញប្រចាំត្រីមាស ។

ស្ថាប័នទាំងពីរនៃរដ្ឋាភិបាល គឺការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ និងការិយាល័យអភិវឌ្ឍន៍សហគមន៍ តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថានបានម្ចាស់ការលើបណ្តាញការងារនេះ ។ នេះមានន័យថា រដ្ឋាភិបាលដើរតួយ៉ាងសំខាន់ក្នុងការដឹកនាំ ហើយកាលណារដ្ឋាភិបាលមាននាទីជាស្ថាប័នទទួលខុសត្រូវផ្ទាល់ បណ្តាញការងារនេះទំនងជាអាចដំណើរការប្រកបដោយនិរន្តរភាពបាន ។ តំណែងប្រធានគណៈកម្មការ បណ្តាញនេះនឹងត្រូវផ្លាស់ប្តូររៀងរាល់ ៦ខែម្តង ។ ឧបសម្ព័ន្ធ១ បង្ហាញជូនពីរចនាសម្ព័ន្ធនៃគណៈកម្មការបណ្តាញការងារនេះ ។

គណៈកម្មការនេះតែងរៀបចំសំណើថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនទៅម្ចាស់ជំនួយ ។ ម្ចាស់ជំនួយបច្ចុប្បន្នមានជាអាទិ៍ អង្គការខុនសឺនកម្ពុជា អង្គការអុកស្វាមអង់គ្លេសគម្រោង WWF/CBNRMLI គម្រោង CFI/CFAC និងគម្រោងMRC/GTZ ។ បន្ថែមលើជំនួយថវិកា អង្គការខុនសឺនបានគាំទ្រផ្នែករដ្ឋបាលផងដែរ ។

ការវាយតម្លៃពីតម្រូវការដែលបានធ្វើឡើងកាលពីឆ្នាំ ២០០០ បានស្នើឱ្យមានការប្រជុំបណ្តាញនេះប្រចាំត្រីមាស ហើយការប្រជុំគួរធ្វើឡើងនៅតាមខេត្តផ្សេងៗ ដើម្បីអោយអ្នកចូលរួមមានឱកាសបានទៅទស្សនកិច្ច និងសិក្សាបទពិសោធន៍ផ្ទាល់នៅមូលដ្ឋាន ។ ប្រធានបទដែលបានលើកយកមកពិភាក្សាកន្លងមក ផ្តោតលើបញ្ហាសង្គម និងបច្ចេកទេសជាងបញ្ហាគោលនយោបាយ ហើយក្នុងនោះក៏មានការផ្តល់នូវព័ត៌មានថ្មីៗស្តីពីសហគមន៍ព្រៃឈើនៅកម្ពុជាផងដែរ ។ សមាជិកក៏បានស្នើឱ្យអ្នកជំនាញផ្នែកសហគមន៍ព្រៃឈើធ្វើបទបង្ហាញលើប្រធានបទជាក់លាក់ណាមួយនៅក្នុងកិច្ចប្រជុំនីមួយៗនៃបណ្តាញនេះ ហើយរាល់កិច្ចប្រជុំ បណ្តាញនីមួយៗ បានពិភាក្សាលើប្រធានបទ ឬបញ្ហាត្រឹមមួយ ឬពីរប៉ុណ្ណោះ ។



*"នេះជាលើកទី១ហើយដែលខ្ញុំបានចូលរួមក្នុងការប្រជុំបណ្តាញសហគមន៍ផ្សេងៗគ្នាជាច្រើន ។ ខ្ញុំគិតថា ការប្រជុំនេះមានប្រយោជន៍ណាស់សម្រាប់ខ្ញុំ ។ ខ្ញុំទទួលបានបទពិសោធន៍ និងមេរៀនជាច្រើនពីទស្សនកិច្ចសិក្សានេះ តាមរយៈការបង្ហាញ ការជជែកពិភាក្សា និងការផ្តល់អនុសាសន៍ "។*

*លោក គ្រួច សូថុន អភិបាលរងស្រុក រលាប្អៀរ ខេត្តកំពង់ឆ្នាំង ។*
*ថ្ងៃ២៤ ខែធ្នូ ឆ្នាំ២០០២*

នៅដើមឆ្នាំ ២០០៣ បណ្តាញនេះបានប្តូរឈ្មោះពី "បណ្តាញការងារសហគមន៍ព្រៃឈើនៅកម្ពុជា" ទៅជា "បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា" ។ នៅក្រោមច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ រាល់សកម្មភាពគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ ត្រូវបានហៅថា "សហគមន៍ព្រៃឈើ" ដោយឡែកនៅក្រោមសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ការគ្រប់គ្រងព្រៃឈើដោយសហគមន៍នៅក្នុងតំបន់ការពារធម្មជាតិ ត្រូវបានហៅថា "សហគមន៍តំបន់ការពារធម្មជាតិ" ។ ដោយសារបណ្តាញការងារនេះ ពាក់ព័ន្ធទាំងក្នុង និងក្រៅតំបន់ការពារធម្មជាតិ ដូចនេះបណ្តាញត្រូវបានប្តូរឈ្មោះថ្មី ដើម្បីអោយស្របទៅនឹងទំហំការងារនេះ ។

## ជោគជ័យ

ចំនួនសមាជិកបណ្តាញការងារនេះបានកើនឡើងពី ២០នាក់ (ឆ្នាំ១៩៩៨) រហូតដល់ ១៥០នាក់ (ឆ្នាំ២០០៤) ។ ដោយឡែក សមាសភាពជាតំណាងសហគមន៍បានកើនពី ១៥% (ឆ្នាំ១៩៩៨) រហូតដល់ ៤៧% (ឆ្នាំ២០០៤) ។ លើសពីនេះចំនួនសមាជិកដែលជាតំណាងអង្គការមិនមែនរដ្ឋាភិបាល និងគម្រោងពាក់ព័ន្ធក៏មានការកើនឡើងច្រើនដែរ ។ ឧបសម្ព័ន្ធ ២ សង្ខេបជូនពីកិច្ចប្រជុំបណ្តាញការងារនេះ ដោយបង្ហាញលម្អិតពីទីកន្លែង និងប្រភេទអ្នកចូលរួមតាំងពីឆ្នាំ ១៩៩៨ មក ។

នៅឆ្នាំ ១៩៩៨ មានអង្គការមិនមែនរដ្ឋាភិបាល និងគម្រោងមួយចំនួនតូចប៉ុណ្ណោះដែលបានចូលរួម ជាអាទិ៍ អង្គការខុនសឺនកម្ពុជា អង្គការ LWS អង្គការ AFSC អង្គការ MCC អង្គការម្លប់បៃតង គម្រោង CFRP និងគម្រោង SMRP តែបច្ចុប្បន្ន មានតំណាងអង្គការមិនមែនរដ្ឋាភិបាលចូលរួមជាច្រើនបន្ថែមទៀត ជាអាទិ៍ អង្គការអុកស្វាមអង់គ្លេស គម្រោង WWF/CBNRMLI អង្គការ FAO គម្រោង SEILA/PLG/NREM គម្រោង JICA អង្គការ LWF អង្គការ FFI អង្គការ NGO Forum អង្គការ BPS អង្គការ SSP អង្គការ PNKA អង្គការ EPDO អង្គការ BFDK អង្គការ KAFDOC អង្គការ CBO អង្គការគុណធម៌ និងអង្គការ KYSD ជាដើម ។

បណ្ដាញការងារបានទទួលការចាប់អារម្មណ៍មិនត្រឹមតែពីសមាជិករបស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែពីសំណាក់ម្ចាស់ជំនួយផងដែរ ។ ទាំងគម្រោង CFI/CFAC និងគម្រោង MRC/GTZ បានចូលរួមជាសមាជិកគណៈកម្មការនេះ ព្រមទាំងបានផ្ដល់ថវិកាគាំទ្រដល់ដំណើរការនៃបណ្ដាញនេះផងដែរ ។

ស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវរៀបចំបណ្ដាញនេះ ។ តួនាទីនោះគឺការធានាអោយមានការចូលរួម និងការរៀនសូត្ររវាងសមាជិកនៅគ្រប់កម្រិត និងអង្គភាពនានា ។

បច្ចុប្បន្ន បណ្ដាញការងារនេះត្រូវបានទទួលស្គាល់ជាបណ្ដាញថ្នាក់ជាតិ ដែលផ្ដល់ការគាំទ្រ និងជាស្ពានផ្សារភ្ជាប់ទំនាក់ទំនងអំពីការគ្រប់គ្រងព្រៃឈើដោយសហគមន៍សម្រាប់បណ្ដាញនានានៅថ្នាក់មូលដ្ឋាន ។ ទំនាក់ទំនងនេះធ្វើឡើងតាមរយៈកិច្ចប្រជុំបណ្ដាញប្រចាំត្រីមាសនៅតាមខេត្តនានា ។

បណ្ដាញការងារនេះផ្ដល់ឱកាសជាច្រើនដល់សមាជិកនានាក្នុងការចែករំលែកបទពិសោធន៍ និងសម្រាប់កិច្ចសហការលើសកម្មភាពការងារជាក់លាក់ ។ ការធ្វើបែបនេះអាចជួយកាត់បន្ថយភាពស្ទួនគ្នានៃការងាររបស់គម្រោងពាក់ព័ន្ធ ។

តាមរយៈ សមាជិករបស់បណ្ដាញការងារនេះសហគមន៍មូលដ្ឋានអាចកសាងជំនាញ ចំណេះដឹង បទពិសោធន៍ និងជំនឿទុកចិត្តលើការគ្រប់គ្រងព្រៃឈើ ដោយមានការចូលរួមពីសហគមន៍ ។ ទន្ទឹមនឹងនេះ សមាជិកនានាអាចរៀនសូត្រអំពីវិធីសាស្ត្រផ្សេងៗ ក្នុងការគ្រប់គ្រង និងដោះស្រាយទំនាស់ ។

បណ្ដាញការងារនេះក៏បានផ្ដល់ឱកាសផងដែរសម្រាប់ការចែករម្លែកព័ត៌មាន និងការផ្លាស់ប្តូរបទពិសោធន៍រវាងអ្នក

**បណ្ដាញការងារ. . .**

. . . គឺជាធាតុសំខាន់នៅក្នុងកិច្ចប្រឹងប្រែងលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ និងដើរតួជាស្នូល និងជាមូលដ្ឋានគ្រឹះសម្រាប់កសាងគោលនយោបាយចាំបាច់សម្រាប់វិស័យព្រៃឈើ ។

**បណ្ដាញការងារ. . .**

. . . មូលដ្ឋាននៅថ្នាក់ខេត្ត ក៏ដូចជាថ្នាក់តំបន់មានសារៈសំខាន់ដូចគ្នានឹងបណ្ដាញនៅថ្នាក់ជាតិដែរ ដែលមាននាទីផ្លាស់ប្តូរគំនិត និងបទពិសោធន៍ពីមូលដ្ឋាន ។

**បណ្ដាញការងារ. . .**

. . . ជួយកំណត់នូវយុទ្ធសាស្ត្រដែលល្អបំផុតក្នុងការលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ក៏ដូចជាយុទ្ធសាស្ត្រសម្រាប់ធានា អោយបាននូវការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

(Fichtenau 2002)

រៀបចំគោលនយោបាយ និងអ្នកអនុវត្តការងារផ្ទាល់នៅមូលដ្ឋាន ដើម្បីឱ្យមានការពាំនាំយកបញ្ហា និងបទពិសោធន៍ទាំងនោះ សម្រាប់ការពិភាក្សាស្តីពីកំណែទម្រង់គោលនយោបាយនៅថ្នាក់ជាតិ ។ ទន្ទឹមនឹងនេះ មានការចែករំលែកព័ត៌មានថ្មីៗស្តីពីគោលនយោបាយបច្ចុប្បន្ន ជាមួយអ្នកដែលធ្វើការនៅមូលដ្ឋាន ដើម្បីពួកគេអាចអនុវត្តគោលនយោបាយទាំងនោះ និងធ្វើការផ្លាស់ប្តូរបានទាន់សភាពការណ៍ ។

## បញ្ហា និងការប្រឈម

ពេលខ្លះការប្រជុំបណ្តាញត្រូវបានរៀបចំដោយបុគ្គលម្នាក់ ឬស្ថាប័នមួយ។ ដូចគ្នានេះដែរ សមាជិកមួយក្រុមហាក់ដូចជាមានការយល់ដឹងច្រើន និងមានភាពសកម្មជាងសមាជិកដទៃទៀត ។ ក្រុមនេះគួរតែមានតួនាទីដើម្បីចែករំលែកបទពិសោធន៍ ក៏ដូចជាដើម្បីរៀនសូត្របន្ថែមពីគ្នាផងដែរ ។ គោលបំណងរបស់បណ្តាញគឺដើម្បីផ្តល់ជាវេទិកាសម្រាប់គ្រប់សមាជិកទាំងអស់ ចែករំលែកព័ត៌មានបទពិសោធន៍ និងការរៀនសូត្រ ។ ប្រសិនបើបណ្តាញនេះមិនផ្តល់នូវឱកាសបែបនេះទេ បណ្តាញការងារនេះនឹងក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ដែលមនុស្សមួយក្រុមដើរតួជាអ្នកបង្រៀន និងមនុស្សមួយក្រុមទៀតជាអ្នករៀន។

តាមទ្រឹស្តី បណ្តាញនេះជាកម្មសិទ្ធិរបស់សមាជិកទាំងអស់ ហើយសមាជិកម្នាក់ៗមានសិទ្ធិចូលរួមយោបល់ថាតើត្រូវធ្វើរបៀបណាដើម្បីកែលំអបណ្តាញនេះឱ្យរឹតតែមានសារៈប្រយោជន៍បន្ថែមទៀត ។ ប៉ុន្តែដោយឡែក សមាជិកមួយចំនួនបានសម្តែងពីអារម្មណ៍របស់ពួកគាត់ ដែលពឹងផ្អែកទាំងស្រុងទៅលើគណៈកម្មការនៃបណ្តាញនេះ និងក៏មិនដែលគិតដែរថា បណ្តាញនេះជារបស់ពួកគាត់ឡើយ ។ គោលបំណងរបស់គណៈកម្មការនៃបណ្តាញនេះគឺដើម្បីរៀបចំ និងធានាឱ្យបណ្តាញនេះមានដំណើរការដោយរលូនទៅអនាគត ។ នេះមិនមែនមានន័យថាបណ្តាញជារបស់ក្រុមគណៈកម្មការទាំងនេះទេ ។ នៅពេលដែលរាល់សមាជិកមិនយល់ថា បណ្តាញគឺជារបស់ពួកគាត់ម្នាក់ៗទេនោះ គេពិតជាលំបាកក្នុងការទាក់ទាញឱ្យពួកគាត់ចូលរួមនៅក្នុងរាល់សកម្មភាពរបស់បណ្តាញនេះ ដូចជាការធ្វើបទបង្ហាញពីអ្វីដែលពួកគាត់បានរៀនសូត្រនៅក្នុងអង្គប្រជុំនៃបណ្តាញនេះ ឬចូលរួមសរសេរអត្ថបទសម្រាប់ព្រឹត្តិប័ត្រនៃបណ្តាញនេះ។

ទោះបីបណ្តាញនេះផ្តោតជាចម្បងតែលើបទពិសោធន៍ជាក់ស្តែងនៅមូលដ្ឋានក្តី រាល់ប្រធានបទ និងកិច្ចពិភាក្សានានានៅក្នុងបណ្តាញការងារនេះ ក៏អាចជ្រួតជ្រាបដល់សហគមន៍មូលដ្ឋានផងដែរ ។

ទោះបីចំនួនសមាជិកមានការកើនឡើងច្រើនក៏ដោយ ក៏ចំនួនសមាជិកជាស្ត្រីនៅតែមានចំនួនតិចដដែល។ ក្នុងចំណោមសមាជិកសរុប ២០នាក់ ក្នុងនោះមានសមាជិកស្ត្រីចំនួន៣នាក់ (ឬត្រូវនឹង ១៥% នៃចំនួនសមាជិកសរុប) ។ ដោយឡែកបច្ចុប្បន្ន ក្នុងចំណោមសមាជិកសរុប150នាក់ មានសមាជិកស្ត្រីត្រឹមចំនួន២០នាក់ (១៣%)។ ដូចនេះពិតជាមានការពិបាកដែលចង់អោយមានសម្លេងស្ត្រីច្រើននៅក្នុងបណ្តាញដោយសារនៅក្នុងកិច្ចប្រជុំនីមួយៗមានតំណាងជាស្ត្រីតិច ។នៅថ្នាក់មូលដ្ឋាន ការជម្រុញ

ឱ្យស្ត្រីចូលរួមរឹតតែលំបាកជាងនេះទៅទៀត ដោយសារបញ្ហារបាំងវប្បធម៌ និងសុវត្ថិភាពសម្រាប់ស្ត្រី ។ ជាក់ស្តែង គណៈកម្មការរៀបចំបណ្តាញដែលមានសមាជិកភាពសរុបចំនួន ៨ នាក់ មានស្ត្រីជាតំណាងតែមួយរូបប៉ុណ្ណោះ ។

## សេចក្តីសន្និដ្ឋាន

តាំងពីឆ្នាំ ១៩៩៨មក បណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិបានផ្តល់នូវវេទិកាដ៏មានសារៈប្រយោជន៍សម្រាប់ផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍នៅកម្ពុជា ។ ចំណង ទាក់ទងរវាងស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គម្រោង និងសហគមន៍មូលដ្ឋានមានភាពរីកចម្រើនឡើង ។ បណ្តាញ សម្រេចបាននូវដំណោះស្រាយជាច្រើនតាមរយៈកិច្ចប្រជុំ ការធ្វើបទបង្ហាញ ការពិភាក្សា និងទស្សនកិច្ចសិក្សានៅតាមតំបន់សហគមន៍ផ្សេងៗគ្នា ។ ផលប្រយោជន៍ និងប្រសិទ្ធភាពរបស់បណ្តាញត្រូវបានស្តែងឡើងយ៉ាងច្បាស់ ។ ជោគជ័យរបស់បណ្តាញជាបន្តទៅទៀត ពឹងផ្អែកទាំងស្រុងលើឆន្ទៈរបស់គណៈកម្មការរៀបចំបណ្តាញ ការបើកទូលាយសម្រាប់សមាជិកភាព មធ្យោបាយប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព និងការគាំទ្ររបស់ម្ចាស់ជំនួយ ។ ចំនួនសមាជិកបណ្តាញបានកើនឡើង ច្រើនបើប្រៀបធៀបទៅនឹងពេលដែលបណ្តាញនេះទើបនឹងបង្កើតឡើង ។ សមាជិកថ្មីមកពីគ្រប់លំដាប់ថ្នាក់ ដែលរួមបញ្ចូលទាំងសហគមន៍ផ្តល់ជំនួយផងដែរ ។

ទោះជាបែបនេះក្តី បណ្តាញនេះគួរជម្រុញឱ្យមានការចូលរួមបានទូលំទូលាយ និងអនុវត្តតាមវិធីវិមជ្ឈការ ។ គណៈកម្មការបណ្តាញ គួរបង្កើនចំណងទាក់ទងក្នុងចំណោមសមាជិក និងបង្កើតអោយមានដំណើរការជាបណ្តាញការងារសកម្មជាមួយបណ្តាញការងារគ្រប់គ្រងធនធានធម្មជាតិដទៃទៀត ។ បណ្តាញនេះគួរមានសកម្មភាពសំខាន់ៗដទៃទៀតដើម្បីបង្កើនចំណាប់អារម្មណ៍បន្ថែមទៀត និងគួរមានការឯកភាពលើយន្តការដ៏មានប្រសិទ្ធភាពក្នុងការផ្តោះប្តូរព័ត៌មានរវាងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ ការវាយតម្លៃពីតម្រូវការកាលពីឆ្នាំ២000 គឺជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការកែលំអប្រសិទ្ធភាពរបស់បណ្តាញនេះ ។ ការវាយតម្លៃបែបនេះគួរធ្វើឡើងជាទៀងទាត់ដើម្បីធានានូវភាពរីកចម្រើនរបស់បណ្តាញ ។

## យុទ្ធសាស្ត្រសម្រាប់អនាគត

- តួនាទីអ្នកសម្របសម្រួល អ្នកធ្វើបទបង្ហាញ និងអ្នកចូលរួមគួរកំណត់អោយបានច្បាស់ និងអនុវត្តតាមឱ្យបានខ្ជាប់ខ្ជួន ។
- គួរបង្កើតអោយមានវិន័យជាមូលដ្ឋានសម្រាប់ប្រើនៅពេលប្រជុំបណ្តាញ ។
- ប្រធានបទដែលនឹងលើកយកមកចែករំលែក និងពិភាក្សាក្នុងប្រជុំបណ្តាញត្រូវជាប្រធានបទដែលពាក់ព័ន្ធ ខ្លី សាមញ្ញ និងជាទីចាប់អារម្មណ៍សម្រាប់អ្នកចូលរួមភាគច្រើន ។
- អត្ថបទសម្រាប់ព្រឹត្តិប័ត្រគួរពាក់ព័ន្ធទៅនឹងតម្រូវការសម្រាប់អ្នកអានដែលជាសហគមន៍មូលដ្ឋាន ។

- គណៈកម្មការគួរជួយអ្នកធ្វើបទបង្ហាញរៀបចំបទបង្ហាញឱ្យមានភាពទាក់ទាញ និងមានប្រសិទ្ធិភាព ។
- ដោយសារចំនួនអ្នកចូលរួមកើនឡើងច្រើន គណៈកម្មការគួរត្រួតពិនិត្យឡើងវិញលើបច្ចេកទេសសម្របសម្រួលរបស់ខ្លួនដើម្បីអោយការប្រជុំប្រព្រឹត្តទៅដោយរលូន ។
- គួរលើកកម្ពស់ភាពម្ចាស់ការក្នុងចំណោមសមាជិកបណ្តាញទាំងអស់ និងជម្រុញអោយមានការចូលរួមយ៉ាងសកម្មពីសមាជិកនានា ។
- បណ្តាញការងារនេះគួរបន្តការផ្សារភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញដទៃទៀតទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ។
- បណ្តាញគួរប្រមូលទុកនូវរាល់ឯកសារ និងព័ត៌មានសំខាន់ៗទុកដើម្បីចែកជូនសមាជិក ហើយឯកសារទាំងនេះគួរតែមានជាភាសាខ្មែរ ។
- គណៈកម្មការគួររៀបចំផែនការ និងយុទ្ធសាស្ត្រឱ្យបានច្បាស់លាស់ដើម្បីកែលំអទាំងការប្រជុំបណ្តាញ និងព្រឹត្តិប័ត្រ ។

## ឯកសារយោង :


-Edwards K. 2001: ការសម្របសម្រួល គាំទ្របណ្តាញការងារអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

-Fichtenau F, Ly CB, Nup S, and Dy S, 2002³ ការសិក្សាពីការបន្តផ្តួចផ្តើមសហគមន៍ព្រៃឈើនៅកម្ពុជា: សំណើរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព្រៃឈើ

-Hussein Z. ករណីសិក្សាស្តីពីបណ្តាញការងារ និងការសម្របសម្រួល, IUCN

-Starkey P. 1997. បណ្តាញការងារដើម្បីការអភិវឌ្ឍន៍, វេទិកាអន្តរជាតិសម្រាប់គមនាគមន៍នៅមូលដ្ឋាន និងការអភិវឌ្ឍ, London, UK.

-កំណត់ហេតុប្រជុំបណ្តាញការងារសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ និងកំណត់ហេតុប្រជុំគណៈកម្មការបណ្តាញ ។

## ឧបសម្ព័ន្ធ ១ : រចនាសម្ព័ន្ធគណៈកម្មការរៀបចំបណ្តាញ




[៤] ប្រធាន និងអនុប្រធាននៃគណៈកម្មការរៀបចំបណ្តាញត្រូវតែជាអ្នកតំណាងមកពី រដ្ឋបាលព្រៃឈើ និង ក្រសួងបរិស្ថាន ហើយត្រូវផ្លាស់ប្តូរវេនគ្នារៀងរាល់៦ខែម្តង ។

# ឧបសម្ព័ន្ធ ២ : ទីកន្លែងប្រជុំ និង កាលបរិច្ឆេទ

| កាលបរិច្ឆេទនៃការប្រជុំបណ្តាញការងារ | ការចូលរួម | | | | | | | ទីកន្លែងនៃការប្រជុំបណ្តាញការងារ |
|---|---|---|---|---|---|---|---|---|
| | NGOs& គម្រោង | FA | MoE | សហគមន៍មូលដ្ឋាន | ផ្សេងៗ | ចំនួនសរុប | ការចូលរួមរបស់ស្ត្រី | |
| ១៩៩៧ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ភ្នំពេញ |
| ៣-មេសា-៩៨ | ១៣ | ១ | ១ | ៣ | ២ | ២០ | ៣ | ភ្នំពេញ |
| ១២-មិថុនា-៩៨ | ២០ | ១ | ២ | ៥ | 0 | ២៨ | គ្មាន | ភ្នំពេញ |
| ៧-សីហា-៩៨ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ភ្នំពេញ |
| ៩-តុលា-៩៨ | ២៧ | ២ | ២ | ៤ | 0 | ៣៥ | គ្មាន | ភ្នំពេញ |
| ១១-ធ្នូ-៩៨ | ២៤ | ១ | ១ | ៣ | ២ | ៣២ | គ្មាន | ភ្នំពេញ |
| ១២-កុម្ភៈ-៩៩ | ៣៨ | ១ | ១ | ៣ | ២ | ៤៦ | គ្មាន | ភ្នំពេញ |
| ២-មេសា-៩៩ | ២៩ | ៤ | ៦ | ១ | 0 | ៤0 | គ្មាន | ភ្នំពេញ |
| ៤-មិថុនា-៩៩ | ១៣ | ២ | ៥ | 0 | ១ | ២១ | គ្មាន | ភ្នំពេញ |
| ៦-សីហា-៩៩ | ១៧ | ២ | ៤ | 0 | 0 | ២៣ | គ្មាន | ភ្នំពេញ |
| ១-តុលា-៩៩ | ១៦ | ២ | ១ | ១ | 0 | ២0 | គ្មាន | ភ្នំពេញ |
| ៣-ធ្នូ-៩៩ | ១៦ | ៤ | ៤ | 0 | 0 | ២៤ | គ្មាន | ភ្នំពេញ |
| ៣១-មីនា-00 | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣៨ | គ្មាន | ភ្នំពេញ |
| ៩-មិថុនា-00 | ២៣ | ៥ | ៧ | ៣ | 0 | ២៨ | គ្មាន | ភ្នំពេញ |
| ១-កញ្ញា-00 | ១៦ | ៣ | ៣ | ៤ | ២ | គ្មាន | គ្មាន | ភ្នំពេញ |
| ១៥-ធ្នូ-00 | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៤២ | គ្មាន | ភ្នំពេញ |
| ៨-សីហា-0១ | ២៨ | ៣ | ៤ | ៧ | 0 | ៤0 | គ្មាន | ភ្នំពេញ |
| ២១-ធ្នូ-0១ | ២៨ | ៥ | ៤ | ៣ | 0 | ៥0 | គ្មាន | ភ្នំពេញ |
| ១៥-មីនា-0២ | ២៥ | ៦ | ៥ | ៤ | 0 | ៧៤ | គ្មាន | ភ្នំពេញ |
| ១៣-១៤-មិថុនា-0២ | ២៤ | ១២ | ៦ | ៥ | ៣ | ៨៤ | គ្មាន | កំពង់ធំ |
| ១១-១២-កញ្ញា-0២ | ៤៧ | ៩ | ៥ | ១0 | ៣ | ៨៤ | គ្មាន | សៀមរាប |
| ២៣-២៤-ធ្នូ-0២ | ៤0 | ១៧ | ៨ | ១១ | ៨ | ៧៥ | ៥ | បាត់ដំបង |
| ២0-២១-មីនា-0៣ | ២៦ | ១១ | ៥ | ៣២ | ១ | ៨៨ | ១៧ | ក្រចេះ |
| ១៩-២0-មិថុនា-0៣ | ៣១ | ១១ | ៣ | ៣៧ | ៦ | ១៤៣ | ១៣ | ពោធិសាត់ |
| ៧-៨-តុលា-0៣ | ៤៩ | ១៥ | ៦ | ៧0 | ៣ | ៦៧ | ២៤ | កំពង់ឆ្នាំង |
| ២២-២៣-ធ្នូ-0៣ | ២៣ | ១១ | ៥ | ២៨ | 0 | ៦៧ | ៧ | កំពង់ធំ |
| 0១-0២-មេសា-0៤ | ៣៤ | ១១ | ៩ | ៤៦ | 0 | ១00 | ១៥ | សៀមរាប |
| ៣0មិថុនា- ១កក្កដា-0៤ | ៥៩ | ១៦ | ៦ | ៥១ | ២ | ១៣៤ | ២៥ | កំពត |
| ២២-២៣-កញ្ញា-0៤ | ៥១ | ១៧ | ១0 | ៦៨ | ២ | ១៤៨ | ១0 | បន្ទាយមានជ័យ |
| 0១-0២-ធ្នូ-0៤ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១00 | គ្មាន | កំពង់សោម |

# ជំពូក ៧ ការអភិវឌ្ឍ និងការរៀបចំបណ្តាញសហគមន៍នេសាទ

រៀបរៀងដោយ លោក ថាយ សុមុនី[១] លោក ស៊ឹម ប៊ុនធឿន[២] និងអ្នកស្រី សូ ស្រីមុំ[៣]

## សេចក្តីផ្តើម

ឯកសារនេះបង្ហាញជូននូវទស្សនទានពីសហគមន៍នេសាទ ដែលបានបង្កើតឡើងនៅប្រទេសកម្ពុជានាឆ្នាំ២០០០ ហើយជាទស្សនទានមួយថ្មីបំផុតសម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសសម្រាប់អ្នកនេសាទ និងកសិករដែលពឹងផ្អែកលើធនធានជលផល ។ ឯកសារនេះផ្តល់ជូនពីសេចក្តីសង្ខេបនៃការអភិវឌ្ឍសហគមន៍នេសាទនៅប្រទេសកម្ពុជា ។

សហគមន៍នេសាទសំដៅលើស្ថានភាពមួយដែលរដ្ឋបានឯកភាពផ្តល់សិទ្ធិដល់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬ ជិតដែននេសាទ និងដែលមានប្រពៃណីប្រើប្រាស់ ព្រមទាំងមានជីវភាពរស់នៅពឹងផ្អែកលើធនធានជលផលទាំងនោះ។ ការផ្តល់សិទ្ធិនេះ ស្ថិតក្នុងលក្ខខណ្ឌដែលដែននេសាទត្រូវគ្រប់គ្រង និងប្រើប្រាស់ក្រោមរូបភាពប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងនេសាទដោយសហគមន៍ (Community Fisheries Management - CFM) មានមូលដ្ឋានលើការប្តេជ្ញារបស់សមាជិកទាំងអស់របស់សហគមន៍ដែលមានភារៈទទួលខុសត្រូវអនុវត្ត និងកិច្ចសហការពីសំណាក់ភាគីពាក់ព័ន្ធ ស្ថាប័នជលផល និងស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដែលច្រើនតែទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ។

នៅពេលដែលទស្សនទានពីសហគមន៍នេសាទបានអនុវត្តជាលើកដំបូង ប្រជាពលរដ្ឋជាច្រើនមានការយល់ច្រឡំជាមួយនឹងប្រព័ន្ធសហករណ៍ដែលបានដាក់ឱ្យប្រើប្រាស់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ក្រោយរយៈពេលនោះ ប្រព័ន្ធក្រុមសាមគ្គីត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងការនេសាទនៅទូទាំងប្រទេសពីឆ្នាំ១៩៨២-១៩៨៩ ។ ក្រុមសាមគ្គីបានបង្កើតឡើង ដើម្បីគ្រប់គ្រងធនធានជលផលក្នុងបឹងនានា និងមានលក្ខណៈជាការគ្រប់គ្រង

**សហគមន៍** សំដៅលើប្រជាពលរដ្ឋមួយក្រុមដែលរស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា និង ដែលមាន ស្ថានភាពសង្គម បរិស្ថាន វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចរួមគ្នា ព្រមទាំងប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់តែមួយ (នៅក្នុងកន្លែង ឬក្បែរកន្លែងដែលពួកគេរស់នៅ តាមវិធីប្រកបដោយនិរន្តរភាព សម្រាប់គោលដៅទ្រទ្រង់ និងកែលំអជីវភាពរស់នៅ ។

**សហគមន៍នេសាទ** សំដៅលើប្រជាពលរដ្ឋកម្ពុជាមួយក្រុម ដែលសហការគ្នាដោយស្ម័គ្រចិត្ត ដើម្បីគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ ធនធានជលផលដោយនិរន្តរភាព ។ សហគមន៍នេសាទការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងសហគមន៍ខ្លួនអនុលោមតាមបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យជលផល ។

---

[១] បច្ចុប្បន្ន លោក សុមុនី គឺជានាយកស្តីទីប្រចាំប្រទេសកម្ពុជា របស់អង្គការមូលនិធិអន្តរជាតិសម្រាប់សត្វក្រៀល ហើយដែលកន្លងទៅថ្មីៗនេះធ្លាប់ជាប្រធានស្តីទី នៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទក្នុងនាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

[២] លោក ប៊ុនធឿន គឺជាមន្ត្រីតស៊ូមតិខាងផ្នែកជលផលរបស់អង្គការអុកស្វាមអាមេរិក ប្រចាំការិយាល័យតំបន់អាស៊ីបូព៌ា និងមានមូលដ្ឋាននៅភ្នំពេញ។

[៣] អ្នកស្រី សូ ស្រីមុំ គឺជាប្រធានក្រុមគម្រោង "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍" (WWF, IDRC, Oxfam, RECOFTC) ដែលផ្តោតលើការកសាងសមត្ថភាព ការបង្កើតបណ្តាញទំនាក់ទំនង ការស្វែងយល់ពីបទពិសោធន៍ និងការគាំទ្រគោលនយោបាយ ។

ដែននេសាទសាធារណៈ និងការប្រើប្រាស់សិទ្ធិនេសាទរួម ។ ប៉ុន្តែប្រព័ន្ធគ្រប់គ្រងធនធានតាមបែបក្រុមសាមគ្គីមិនបានទទួលជោគជ័យទេ ដោយសារភាពទន់ខ្សោយនៃការគ្រប់គ្រង និងខ្វះការប្តេជ្ញាពីសំណាក់ប្រធានសហគមន៍ក្នុងការដឹកនាំ និងការទទួលខុសត្រូវចំពោះមុខសហគមន៍ ។ បទពិសោធន៍មិនល្អក្នុងរយៈកាលនៃការគ្រប់គ្រងតាមបែបក្រុមសាមគ្គីបានធ្វើឱ្យសហគមន៍នានាអល់ឯកពុំចង់ចូលរួមនៅក្នុងសកម្មភាពសហគមន៍នេសាទបែបថ្មី ហើយប្រជាពលរដ្ឋជាច្រើន រួមទាំងអ្នកពាក់ព័ន្ធនានា អាជ្ញាធរមូលដ្ឋាន មន្ត្រីជលផល និងអង្គការមិនមែនរដ្ឋាភិបាល ពុំបានយល់ច្បាស់អំពីទស្សនទាននៃការគ្រប់គ្រងសហគមន៍នេសាទនៅឡើយដែរ ។

សហគមន៍នេសាទមួយបានបង្កើតជាលើកដំបូងនៅឆ្នាំ១៩៩៤ ក្នុងខេត្តស្វាយរៀងនៃប្រទេសកម្ពុជា ដែលផ្តួចផ្តើមឡើងដោយនាយកដ្ឋានជលផលនៃក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ។ គម្រោងនោះមានគោលដៅបង្កើតការគ្រប់គ្រងត្រពាំងដោយសហគមន៍ ។ គោលបំណងនៃសកម្មភាពនោះ គឺការលើកទឹកចិត្តឱ្យកសិករអភិរក្សត្រពាំងជាជម្រកត្រីដែលអាចប្រើប្រាស់ជាត្រីមេពូជ ជាជម្រកសម្រាប់ត្រីពងកូន និងជាកន្លែងត្រីលាក់ខ្លួននៅរដូវប្រាំង។ នៅឆ្នាំ១៩៩៥ សហគមន៍នេសាទមួយបានបង្កើតឡើង ដើម្បីការពារព្រៃលិចទឹក ដោយមានការគាំទ្រពីអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ។ នៅឆ្នាំបន្ទាប់ មានសហគមន៍នេសាទចំនួន ១១០ ត្រូវបានបង្កើតឡើងនៅក្នុងខេត្តក្រចេះ កំពង់ចាម កោះកុង បាត់ដំបង ស្ទឹងត្រែង កំពង់ឆ្នាំង រតនគិរី និងខេត្តបន្ទាយមានជ័យ ដោយបានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងស្រុក។

## ប្រវត្តិដើម

ការគ្រប់គ្រងវិស័យជលផលក្នុងប្រទេសកម្ពុជាបានជួបប្រទះបញ្ហាជាច្រើនអស់រយៈពេលច្រើនឆ្នាំមកហើយ ដោយសារនិន្នាការលំអៀងទៅរកការធ្វើអាជីវកម្មខ្នាតធំជាលក្ខណៈពាណិជ្ជកម្ម និងការប្រមូលប្រាក់ចំណូល ដែលនាំឱ្យមានទំនាស់លើការប្រើប្រាស់ធនធាននៅក្នុងខេត្តជាច្រើនជុំវិញបឹងទន្លេសាប និងទន្លេមេគង្គ ។ ភាគច្រើននៃបញ្ហាក្នុងការគ្រប់គ្រងពាក់ព័ន្ធនឹងអភិបាលកិច្ច រួមទាំងអំពើពុករលួយក្នុងចំណោមន្ត្រីពង្រឹងការអនុវត្តច្បាប់ និងមន្ត្រីនៅមូលដ្ឋាន ការប្រមូលប្រាក់ចំណូលបានតិចតួចសម្រាប់រដ្ឋាភិបាល ក៏ដូចជាកង្វះសមធម៌ក្នុងការទទួលផលប្រយោជន៍សេដ្ឋកិច្ចពីធនធាននេះ ។ នៅពេលដែលបញ្ហាទាំងនេះនៅតែបន្តគម្រាមកំហែងចំពោះសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជា ផលប៉ះពាល់ខាងផ្នែកអេកូឡូស៊ីកាន់តែបង្ហាញយ៉ាងច្បាស់តាមរយៈការថយចុះផលនេសាទ ដែលបណ្តាលមកពីកំណើននៃការនេសាទយ៉ាងខ្លាំងក្លា ។

## ហេតុអ្វីត្រូវឱ្យមានការគ្រប់គ្រងនេសាទដោយសហគមន៍នៅក្នុងប្រទេសកម្ពុជា ?

នៅថ្ងៃ២៣ខែតុលា ឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមអនុវត្តកំណែទម្រង់គោលនយោបាយវិស័យជលផលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រ។ ភាគច្រើននៃកម្លាំងជម្រុញឱ្យមានកំណែទម្រង់គឺកំណើនចំនួនករណីទំនាស់ពាក់ព័ន្ធនឹងការនេសាទរវាងអ្នកនេសាទតូចតាចក្រីក្រក្នុងមូលដ្ឋានជាមួយអ្នកកាន់កាប់ឡូតិ៍នេសាទដែលច្រើនតែមានការគាំទ្រដោយសមត្ថកិច្ចប្រដាប់អាវុធ ។ អ្នកនេសាទក្នុងមូលដ្ឋានទាំងនោះត្រូវបានគាបសង្កត់ឱ្យបោះបង់ចោលដែននេសាទជាប្រពៃណីរបស់ខ្លួន និងបង្ខំឱ្យធ្វើនេសាទនៅក្នុងកន្លែងគ្មានត្រី ដែលជាហេតុនាំឱ្យពួកគាត់នេសាទបានផលតិចតួច និងមានជីវភាពធ្លាក់ចុះ ។

ធាតុសំខាន់ៗនៃកំណែទម្រង់ រួមមានការកាត់ និងលុបឡូតិ៍នេសាទចំនួន៥៣ ដែលមានក្រឡាផ្ទៃសរុប ៥៣៦ ៣០២ ហិកតាត្រូវជា ៥៦.២៣% នៃផ្ទៃឡូតិ៍នេសាទសរុបនៅទូទាំងប្រទេស ។ បន្ទាប់មកតំបន់ដែលបានកាត់ចេញពីឡូតិ៍នេសាទត្រូវបានកំណត់សម្រាប់ការធ្វើនេសាទខ្នាតតូច និងជម្រុញឱ្យមានការបង្កើតសហគមន៍នេសាទ ។ លើសពីនេះការប្រមូលថ្លៃឈ្នួលលើសកម្មភាពនេសាទសិប្បកម្មក្នុងដែននេសាទទឹកសាប និងតំបន់ខ្លះៗនៅឆ្នេរសមុទ្រត្រូវបានលុបចោល ។ រដ្ឋាភិបាលបានផ្លាស់ប្តូរតំណែងប្រធាន និងអនុប្រធាននាយកដ្ឋានជលផល និងបានចាប់ផ្តើមព្យួរការងាររបស់ អង្គភាព-សង្កាត់ត្រួតពិនិត្យ ជលផលថ្នាក់ខេត្តនៅតាមឡូតិ៍នេសាទទាំងអស់នៅក្នុងប្រទេសជាបណ្តោះអាសន្ន ។កំណែទម្រង់គោលនយោបាយ វិស័យជលផល បានតម្រូវឱ្យមានកិច្ចប្រឹងប្រែងយ៉ាងខ្លាំង និងជាបន្ទាន់ក្នុងកិច្ចផ្តួចផ្តើមលើការគ្រប់គ្រងការនេសាទដោយសហគមន៍ និងសហគ្រប់គ្រងធនធានជលផលដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍ម្ចាស់ជំនួយ ។ នៅក្នុងនាយកដ្ឋានជលផល ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (Community Fisheries Development Office - CFDO) ត្រូវបានបង្កើតឡើងដើម្បីគាំទ្រការបង្កើតសហគមន៍នេសាទ ផ្តួចផ្តើមការងារ និងរៀបចំគោលការណ៍ណែនាំសម្រាប់បង្កើតសហគមន៍នេសាទនៅក្នុងតំបន់ដែលកាត់ និងលុបចេញពីឡូតិ៍នេសាទ ។

មុនពេលមានកំណែទម្រង់គោលនយោបាយវិស័យជលផល វត្តមាននៃសហគមន៍នេសាទក្នុងប្រទេសកម្ពុជា គ្រាន់តែជាយន្តការមួយសម្រាប់គ្រប់គ្រងធនធានតែប៉ុណ្ណោះ ។ទោះបីគំរូសហគមន៍នេសាទថ្មី ផ្តោតចំណាប់អារម្មណ៍លើការគ្រប់គ្រងធនធានជលផលក៏ដោយ គំរូទាំងនេះអាចឱ្យប្រជាពលរដ្ឋស្វែងយល់អំពីទស្សនវិស័យនៃកំណែទម្រង់ និងថាតើប្រជាពលរដ្ឋអាចចែករំលែក និងប្រើប្រាស់ធនធានដោយនិរន្តរភាពនិងដោយសមធម៌ដោយវិធីណា ។ ការគ្រប់គ្រងសហគមន៍នេសាទព្យាយាមដើម្បីកាត់បន្ថយទំនាស់នានា និងកែលំអជីវភាពរស់នៅរបស់អ្នកនេសាទ និងកសិករនៅក្នុងមូលដ្ឋានដែលជាអ្នកប្រើប្រាស់ធនធានជលផល។ ប៉ុន្តែដំណើរការបែបនេះត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមអ្នកនេសាទទាំងនោះ និងដើម្បីចាត់ចែងបង្កើតក្រុមប្រជាពលរដ្ឋសម្រាប់គ្រប់គ្រងធនធានដោយខ្លួនឯង ។

## ទស្សនទានអំពីសហគ្រប់គ្រង

មាននិយមន័យជាច្រើនបកស្រាយខុសៗគ្នា ពីសហគ្រប់គ្រង ។ Hartmann (2000) កំណត់និយមន័យ សហគ្រប់គ្រង ថាជា " *ដំណើរការដែលមានការទទួលស្គាល់ជាផ្លូវការ និងអាចយកទៅអនុវត្តកន្លែងផ្សេងបាន នៃការចែករំលែក សមត្ថកិច្ច និងការទទួលខុសត្រូវរវាង រដ្ឋាភិបាល និងក្រុមអ្នកប្រើប្រាស់ដែលបានចងក្រងឡើង នៅក្នុងសេចក្តីសម្រេចតាមបែបវិមជ្ឈការ ដែលធ្វើឡើងសំដៅឱ្យមានការកែលំអធនធាន* " ចំណែក Gum (2000) អធិប្បាយថាជា "ការផ្តល់នូវការសម្របសម្រួលត្រឹមត្រូវ និងការជម្រុញឱ្យមានការពិភាក្សា សន្ទនារវាងអ្នកពាក់ព័ន្ធ " លទ្ធផលរំពឹងទុកចម្បងនៃសហគ្រប់គ្រងនេសាទ គឺបង្កើតឱ្យមានការកែលំអនិរន្តរភាពប្រសិទ្ធភាព សមធម៌ និងភាពរស់រវើក (Berkes *et al.*, 2001) ។

សហគ្រប់គ្រងនេសាទ គឺជាការចាត់ចែងឱ្យមានភាពជាដៃគូ ដែលនៅក្នុងនោះរដ្ឋាភិបាល សហគមន៍អ្នកប្រើប្រាស់នៅក្នុងមូលដ្ឋាន ទីភ្នាក់ងារមកពីខាងក្រៅ ( អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានបណ្តុះបណ្តាល និងវិទ្យាស្ថានស្រាវជ្រាវ ព្រមទាំងអ្នកពាក់ព័ន្ធនានាផ្សេងទៀត ក្នុងវិស័យជលផល និងវិស័យធនធានផ្សេងទៀត ចែករំលែកការទទួលខុសត្រូវ និង សមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចអំពីការគ្រប់គ្រងធនធានជលផល (Pomeroy Williams, 1994; Pomeroy, 1998; and Berkes *et al.*, 2001) ។ សហគ្រប់គ្រងសហគមន៍នេសាទនៅប្រទេសកម្ពុជា អាចបកស្រាយបាន តាមរូបភាពដូចខាងក្រោម :-




**លំដាប់ថ្នាក់នៃសហគ្រប់គ្រង**

កែសម្រួលពី *Nielson et al, 1997*

## ការរៀបចំសហគមន៍នេសាទ

សហគមន៍នេសាទត្រូវបានបង្កើតឡើងដោយប្រជាពលរដ្ឋមួយក្រុម ដែលមានបំណងចាត់ចែង និងបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងធនធាននានាដែលពួកគេពឹងផ្អែកសម្រាប់ការរស់នៅ ។ នៅដំណាក់កាលដំបូងនៃដំណើរការគ្រប់គ្រងសហគមន៍តែងតែត្រូវការជំនួយគាំទ្រខាងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីនាយកដ្ឋានបច្ចេកទេសរបស់រដ្ឋាភិបាល និងពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។ តាំងពីឆ្នាំ ១៩៩៨មក អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផ្ដល់ការគាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ទោះបីកិច្ចផ្ដួចផ្ដើមទាំងនោះ ច្រើនតែផ្ដោតលើធនធាន ព្រៃឈើជាងធនធានជលផលក៏ដោយ ។ ក្រោយកំណែទម្រង់វិស័យជលផលក្នុងឆ្នាំ២០០១ ចំនួនគម្រោងក្នុងផ្នែកសហគមន៍នេសាទបានកើនឡើង ហើយប្រជាពលរដ្ឋបានចាប់ផ្ដើមស្វែងយល់ពីវិធីការពារ និងអភិរក្សធនធានជលផល ។

សហគមន៍ជាច្រើនបានបង្កើតឡើងដោយពុំមានការយល់ដឹងពិតប្រាកដពីទស្សនទាន និងដំណើរនៃការចាត់ចែង ព្រមទាំងមូលហេតុនៃការបង្កើតសហគមន៍នេសាទឡើយ ។ ទស្សនទានពីសហគមន៍នេសាទនៅថ្មីខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសសម្រាប់អ្នករស់នៅតាមជនបទដែលពុំសូវមានលទ្ធភាព ឬ ពុំបានទទួលព័ត៌មានពីបញ្ហានេះ។ ឯកសារសហគមន៍នេសាទចំនួន៣៦០ ត្រូវបានបង្កើតឡើង ហើយនឹងត្រូវបានពិភាក្សានៅក្នុងឯកសារនេះ (រូបនានាបានពី CFDO/DoF) ។

## ការរៀបចំសហគមន៍

ប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ មានទម្លាប់រស់នៅជាក្រុម និងមានការការពារទាំងអភិរក្សធនធានធម្មជាតិជារបស់សហគមន៍ខ្លួន ។ ជាប្រពៃណី ជាពិសេសមុនរបបខ្មែរក្រហម ប្រជាពលរដ្ឋនៅជនបទចូលចិត្តរស់នៅជាក្រុម ដើម្បីជួយគ្នាទៅវិញទៅមក និងចែករំលែកព័ត៌មានរវាងគ្នានិងគ្នា ។ ទោះបីប្រជាពលរដ្ឋទាំងនោះមិនបានដឹងពីទ្រឹស្ដីនៃ "សហគមន៍" ក៏ដោយ តែពួកគេបានអនុវត្តទៅតាមដំណើរការសហគមន៍ ។ កាលពីអតីតកាល សម្ពាធលើធនធានធម្មជាតិមានកម្រិតទាបជាងបច្ចុប្បន្ននេះឆ្ងាយណាស់ ដោយមានចំនួនប្រជាពលរដ្ឋតិចតួច ការប្រើប្រាស់ធនធានធម្មជាតិមានកម្រិតទាប ហើយការប្រកួតប្រជែងនៅទីផ្សារក៏មានកម្រិតទាបផងដែរ ។ សហគមន៍ដែលបានគ្រប់គ្រងធនធានរបស់ខ្លួនដោយជោគជ័យ គឺដោយសារមានការប្ដេជ្ញាក្នុងចំណោមប្រជាពលរដ្ឋ ការផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ដំណើរគ្រប់គ្រង ធ្វើការជាមួយគ្នានៅក្នុងវប្បធម៌តែមួយ មានអ្នកដឹកនាំស្វាហាប់នៅក្នុងសហគមន៍ដែលច្រើនតែជាមនុស្សចាស់ជាងគេនៅក្នុងសង្គម ក៏ដូចជាមានការយល់ដឹងបានប្រសើរអំពីធនធានដែលត្រូវគ្រប់គ្រង ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ សហគមន៍បានគ្រប់គ្រងធនធានទាំងនោះដោយខ្លួនឯងដោយគ្មានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងពីនាយកដ្ឋានជំនាញនានារបស់រដ្ឋាភិបាលឡើយ ។

សហគមន៍ជាច្រើននៅជនបទមានទម្លាប់ប្រកាន់អបិ្បយជំនឿ ។ ឧទាហរណ៍នៅកន្លែងដែលមានដើមឈើធំ ប្រជាពលរដ្ឋជឿថាមានខ្មោច ឬមានត្រីធំ ឬមានអ្នកតានៅទីនោះ ។ ប្រជាពលរដ្ឋនឹងមិនសម្លាប់ត្រីធំទាំងនោះទេ ព្រោះគេជឿថានឹងនាំឱ្យមានសំណាងអាក្រក់ ។ ដោយសារអបិ្បយជំនឿទាំងនេះហើយទើបធនធានទាំងឡាយត្រូវបានថែរក្សា និងការពារឱ្យនៅគង់វង្ស ហើយសហគមន៍ទាំងនេះអាចជួយការពារ និងគ្រប់គ្រងធនធានធម្មជាតិ ។ ប៉ុន្តែសហគមន៍នានាអាចទទួលផលចំណេញពីការគាំទ្របច្ចេកទេស ដើម្បីគ្រប់គ្រងដំណើរការសហគមន៍ឱ្យបានប្រសើរឡើង និងដើម្បីធ្វើការដោះស្រាយបញ្ហាដែលសាំញ៉ាំជាងមុន ដូចជាការប្រើប្រាស់ធនធានដោយល្មើសច្បាប់ និងដោយស្របច្បាប់ពីសំណាក់ប្រជាពលរដ្ឋមកពីក្រៅសហគមន៍របស់ខ្លួន ។

នៅខេត្តកោះកុង គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ បានទទួលការសម្របសម្រួលដោយគម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង/ក្រសួងបរិស្ថាន ។ កាលពីដំបូង ប្រជាពលរដ្ឋក្នុងមូលដ្ឋានមួយក្រុមបានរួបរួមគ្នាដើម្បីចាត់វិធានការឆ្លើយតបនឹងកំណើនការនេសាទ និងការកាប់ឈើល្មើសច្បាប់នៅក្នុងតំបន់នោះ ។ នៅឆ្នាំ១៩៩៥ គម្រោងសហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ឆ្នេរ និងខេត្តជាច្រើននៅភាគឦសាននៃប្រទេសកម្ពុជា និងបានឆ្លុះបញ្ចាំងពីការទទួលស្គាល់ថា ការចាត់ចែងបង្កើតសហគមន៍ពិតជាមានសារៈសំខាន់ ដើម្បីការពារធនធានធម្មជាតិ ។

នៅក្នុងសម័យអន្តរកាល អ្នកនេសាទមួយចំនួនបានឆ្លៀតឱកាសដើម្បីធ្វើការនេសាទ ដោយប្រើវិធីល្មើសច្បាប់ និងទ្រង់ទ្រាយធំនៅក្នុងឡូតិ៍នេសាទបម្រុងទុកជុំវិញបឹងទន្លេសាប ។ ទម្លាប់បានកើតឡើងរវាងអ្នកទាំងឡាយ ដែលមានលទ្ធភាពទិញឧបករណ៍នេសាទទំនើបខ្នាតធំ និងអ្នកនេសាទក្រីក្រដែលពុំមានថវិកាគ្រប់គ្រាន់សម្រាប់ទិញឧបករណ៍នេសាទដែលមានប្រសិទ្ធភាពខ្ពស់ជាងមុន ។ ប្រការនេះនាំឱ្យការប្រើប្រាស់ធនធានពុំមានសមធម៌ ។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានតម្រូវឱ្យក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទតាមរយៈនាយកដ្ឋានជលផល ចុះសហការជាមួយ ការិយាល័យជលផលខេត្ត-ក្រុង បង្ក្រាបសកម្មភាព ល្មើសច្បាប់ និងជម្រុញការបង្កើតសហគមន៍ នេសាទនៅទូទាំងប្រទេស ។

សមត្ថកិច្ចជំនាញរបស់រដ្ឋាភិបាលបានរៀបចំធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងប្រទេស ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។ សេចក្តីព្រាងអនុក្រឹត្យនេះអាចត្រូវបានចាត់ទុកថាជាគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីការគ្រប់គ្រងធនធានជលផលដោយនិរន្តរភាពសម្រាប់ការអនុវត្តជាក់ស្តែង និងផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់រៀបចំសហគមន៍នេសាទ ។

នៅក្នុងការពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យនេះ មានបញ្ហាចម្រូងចម្រាស់មួយចំនួនដូចតទៅ :

- ១ ការតម្រូវឱ្យសហគមន៍អ្នកនេសាទប្រើប្រាស់តែឧបករណ៍នេសាទខ្នាតតូច ។ (សហគមន៍នេសាទជាច្រើនពុំមាន ឬ មានប្រភពធនធានហិរញ្ញវត្ថុតិចតួចសម្រាប់គាំទ្រការនេសាទរបស់ពួកគេ ។

⊙ ការទាមទារដោយសហគមន៍នេសាទមានសិទ្ធិឃាត់ខ្លួន ឬផាកពិន័យអ្នកនេសាទល្មើសច្បាប់ ឬជនប្រព្រឹត្តបទល្មើសដោយខ្លួនឯង ដោយពុំមានក្របខ័ណ្ឌច្បាប់គាំទ្រ ។

⊙ ការដាក់កំហិតនូវសិទ្ធិរបស់អ្នកដែលមិនមែនជាសមាជិករបស់សហគមន៍នេសាទ ធ្វើនេសាទនៅក្នុងដែននេសាទរបស់សហគមន៍ ។

នាយកដ្ឋានជលផលបានទទួលយកអនុសាសន៍ទាំងអស់ និងធ្វើវិសោធនកម្មសេចក្តីព្រាងអនុក្រឹត្យនេះមុនដាក់ចូលសម្រាប់ការពិគ្រោះយោបល់ចុងក្រោយបង្អស់នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ។ ការពិគ្រោះយោបល់នោះបានប្រព្រឹត្តទៅ និងមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនៅទូទាំងប្រទេស ។

បច្ចុប្បន្នទោះបីគ្មានច្បាប់ជាផ្លូវការស្តីពីការបង្កើតសហគមន៍នេសាទក្តី ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ/នាយកដ្ឋានជលផល បានបញ្ជូនមន្ត្រីរបស់ខ្លួនដើម្បីសហការជាមួយមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទខេត្ត/ក្រុង អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល/អង្គការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដើម្បីសម្រួលឱ្យមានការបង្កើតសហគមន៍នេសាទតាមគោលការណ៍ណែនាំដែលកំណត់ដោយគណៈរដ្ឋមន្ត្រី ។ ជាលទ្ធផលថ្មីៗនេះការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទបានបង្ហាញថាមានសហគមន៍នេសាទចំនួន ៤០៤[១] ត្រូវបានបង្កើតឡើងនៅក្នុងដែននេសាទទឹកសាប និងនៅក្នុងតំបន់ឆ្នេរ ។

ដំណើរការបង្កើតសហគមន៍នេសាទ មានជាអាទិ៍ ៖

— ការចែកផ្សាយគោលការណ៍ណែនាំសម្រាប់បង្កើតសហគមន៍នេសាទ

— ដំណើរការបោះឆ្នោត និង

— បង្កើតលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងផែនទីព្រំប្រទល់សហគមន៍នេសាទ ។

ដំណើរការនេះបាននឹងកំពុងអនុវត្តយ៉ាងសកម្មនៅទូទាំងប្រទេស ។ នាយកដ្ឋានជលផលបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដើម្បីរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីជលផល និងគណៈកម្មការ សហគមន៍នេសាទ ។ បន្ទាប់ពីអង្គការ និងក្រុមនានាត្រូវបានបង្កើតឡើង គេបានធ្វើការតាមដាន និងវាយតម្លៃ នៅថ្នាក់ខេត្ត-ក្រុង ដើម្បីពិនិត្យមើលឱ្យច្បាស់ថាពិតជា មានការតាមដានញឹកញាប់លើទស្សនទានថ្មីនេះ ។



ស៊ុង ប៊ុនធឿន /OA ២០០១

***រហូតមកដល់ឥឡូវ សហគមន៍នេសាទចំនួន៤០៤ ត្រូវបានបង្កើតឡើងនៅដែននេសាទទឹកសាប និងសមុទ្រ ។***

[១] លោកឈួន គឹមឈា អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ខែធ្នូ ២០០៥

របាយការណ៍ពីការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តរបស់សហគមន៍នេសាទបានបង្ហាញថា :

— ករណីនេសាទល្មើសច្បាប់ និងទំនាស់ក្នុងដែនសហគមន៍នេសាទបានកាត់បន្ថយ

— អ្នកនេសាទបានយល់ពីទស្សនទាននៃការគ្រប់គ្រងធនធានជលផលដោយមានការចូលរួម តាមរយៈការអនុវត្តសកម្មភាពសហគមន៍នេសាទ ។ ប្រការគួរឱ្យកត់សម្គាល់គឺពួកគេមានឆន្ទៈប្រឹងប្រែង និងសហការដោយស្ម័គ្រចិត្តជាមួយអាជ្ញាធរមូលដ្ឋានក្នុងការបង្កើត និងអនុវត្តន៍ការងារសហគមន៍នេសាទ ។

— អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធទាំងឡាយ អង្គការមិនមែនរដ្ឋាភិបាល បានគាំទ្រដំណើរការរបស់សហគមន៍នេសាទ ។

លើសពីនេះ ផលនេសាទបានកើនឡើងនៅក្នុងដែននេសាទសហគមន៍ ដែលមានកំណត់កន្លែងបម្រុងទុកសម្រាប់ការពារមច្ឆាជាតិ ។

## បញ្ហាលំបាកក្នុងការអភិវឌ្ឍសហគមន៍នេសាទ

ទោះបីមានការគាំទ្រក្នុងកម្រិតមួយពីសំណាក់អ្នកពាក់ព័ន្ធនានាក្តី ការអនុវត្ត កំណែទម្រង់គោលនយោបាយវិស័យជលផលនៅពុំទាន់មានដំណើរការរលូនតាមអ្វីដែលគេចង់បាននៅឡើយទេ ដោយសារបទពិសោធន៍ និងសមត្ថភាពចាត់ចែងព្រមទាំងចំណេះដឹងអំពីការគ្រប់គ្រងសហគមន៍នេសាទ ក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានជលផលនៅមានកម្រិតទាបនៅឡើយ ព្រោះថា នេះជាទស្សនទានថ្មីមួយសម្រាប់ប្រទេសកម្ពុជា ។

**ការលំបាកក្នុងការអនុវត្តសហគមន៍នេសាទឱ្យបានពេញលេញនៅកម្ពុជា មានជាអាទិ៍ :**

- ព្រំប្រទល់រវាងឡូតិ៍នេសាទពាណិជ្ជកម្ម និងដែននេសាទសហគមន៍ នៅពុំទាន់បានកំណត់ទាំងស្រុងនៅឡើយ ។
- ការរាំងស្កាត់ និងបង្ក្រាបឧបករណ៍នេសាទល្មើសច្បាប់ ដូចជាការឆក់ត្រី ការប្រើស្បៃមុង ការប្រើឈិបយន្ត ។ល។ នៅពុំទាន់អនុវត្តបានប្រកប ដោយប្រសិទ្ធភាពនៅឡើយទេ ។
- ពុំទាន់មានក្របខ័ណ្ឌច្បាប់និងអនុក្រឹត្យច្បាស់លាស់ក្នុងការគ្រប់គ្រងសហគមន៍នេសាទ ។ ពុំទាន់មានគំរូលក្ខន្តិកៈ និងប្រការផ្សេងទៀតដែលចែងពីការគ្រប់គ្រងសហគមន៍នេសាទនៅឡើយទេ ។ ជាលទ្ធផល មានបញ្ហាចំរូងចំរាស់ខ្លះៗ ដែលត្រូវដោះស្រាយក្នុងចំណោមអ្នកពាក់ព័ន្ធ ។
- ការយល់ដឹងអំពីសហគមន៍នេសាទក្នុងចំណោមសមាជិកសហគមន៍អ្នកនេសាទ មន្ត្រីជលផល និងអាជ្ញាធរមូលដ្ឋាន នៅមានកម្រិតទាប ។
- សហគមន៍នេសាទមិនទាន់ទទួលបានសុំឱ្យផ្តល់សិទ្ធិបង្ក្រាប និងធ្វើការផាកពិន័យដោយខ្លួនឯង ចំពោះសកម្មភាពនេសាទល្មើសច្បាប់ ។

- សហគមន៍នេសាទមួយចំនួនបានសុំឱ្យផ្តល់សិទ្ធិធ្វើនេសាទជាលក្ខណៈពាណិជ្ជកម្ម នៅក្នុងដែននេសាទសហគមន៍របស់ខ្លួន ដែលជាប្រការផ្ទុយទៅនឹងមាត្រាដែលមានចែងនៅក្នុងអនុក្រឹត្យស្តីពីការកាត់ និងលុបឡូតិ៍នេសាទសម្រាប់ការធ្វើនេសាទខ្នាតតូច ជាលក្ខណៈគ្រួសារ ។
- អាជ្ញាធរមូលដ្ឋានខ្លះ ( ក្រុមប្រឹក្សាឃុំ-សង្កាត់ ពុំទាន់គាំទ្រសហគមន៍នេសាទទាំងស្រុងនៅឡើយទេ ហើយក្នុងករណីខ្លះអ្នកទាំងនោះបានលក់ដែននេសាទសហគមន៍ទៅឱ្យឈ្មួញ ដោយប្រើប្រាស់ឈ្មោះសហគមន៍នេសាទ ។
- មានអ្នកនេសាទល្មើសច្បាប់នៅឡើយ នៅក្នុងដែននេសាទរបស់សហគមន៍ ដែលប្រការនេះត្រូវតែបញ្ឈប់ជាបន្ទាន់ ។
- ភាពក្រីក្រក្នុងចំណោមអ្នកនេសាទ គឺជាឧបសគ្គមួយផ្សេងទៀត ចំពោះការចាត់ចែងបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ
- កង្វះសម្ភារៈ ថវិកា និងមធ្យោបាយផ្សេងទៀត សម្រាប់ផ្សព្វផ្សាយ និងពង្រីកសកម្មភាព ការចាត់ចែង ការពង្រឹង ការត្រួតពិនិត្យ និងវាយតម្លៃ ដំណើរការរបស់សហគមន៍នេសាទ ។
- ភាគច្រើននៃសហគមន៍នេសាទដែលបានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ និងមានកិច្ច-សហការល្អជាមួយមន្ត្រីបច្ចេកទេសជលផលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ទំនងជាមានដំណើរការប្រព្រឹត្តទៅបានល្អ ។ ប៉ុន្តែសហគមន៍នេសាទដែលរៀបចំឡើងដោយនាយកដ្ឋានជលផល និងការិយាល័យជលផលនៅថ្នាក់ខេត្តតែឯងពុំដំណើរការបានល្អឡើយ ដោយសារបញ្ហាថវិកា និងកង្វះខាតការគាំទ្រផ្នែកបច្ចេកទេស ។

## ការលំបាកសម្រាប់សហគ្រប់គ្រងសហគមន៍នេសាទ

ក្រោយមានកំណែទម្រង់គោលនយោបាយវិស័យជលផល ចំណោទគន្លឹះមួយនៅពុំទាន់ឆ្លើយរួចគឺ តើសហគមន៍មូលដ្ឋានអាចគ្រប់គ្រងការធ្វើអាជីវកម្ម និងអភិរក្សធនធានជលផលឱ្យមាននិរន្តរភាពតាមរបៀបណា? ទស្សនវិស័យអំពីសហគ្រប់គ្រងនេសាទដោយសហគមន៍ ត្រូវបានប្រើប្រាស់ជាវិធីមួយ ដើម្បីសម្រេចទិសដៅនេះ ។

ដើម្បីឱ្យសហគ្រប់គ្រងការនេសាទដោយសហគមន៍ប្រព្រឹត្តទៅបានជោគជ័យ ទាមទារឱ្យមានៈ

១. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់សមស្រប
២. ការយល់ដឹងអំពីទស្សនវិស័យសហគមន៍
៣. តម្លាភាពក្នុងការគ្រប់គ្រង
៤. កិច្ចសហការ បណ្តាញការងារ និងការចែករំលែកព័ត៌មាន
៥. យន្តការដោះស្រាយទំនាស់
៦. ការពង្រឹងការអនុវត្តច្បាប់
៧. ការត្រួតពិនិត្យតាមដាន វាយតម្លៃ និងវិភាគអំពីបទពិសោធន៍ ដែលទទួលបាន
៨. ការប្តេជ្ញារយៈពេលយូរអង្វែង ។

នាយកដ្ឋានជលផលបានព្យាយាមដោះស្រាយបញ្ហា និងឧបសគ្គទាំងនេះដោយយកចិត្តទុកដាក់ ព្រមទាំងត្រូវបង្ខំចិត្តប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីដោះស្រាយប្រការទាំងនោះ ។ ជាក់ស្តែងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និងរាជរដ្ឋាភិបាលកម្ពុជាបានទទួលប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់អនុវត្តគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ។ ចំណុចចាប់អារម្មណ៍ចម្បងមួយក្នុងចំណោមប្រការនានា គឺការគាំទ្រ និងសម្របសម្រួលការអភិវឌ្ឍសហគមន៍នេសាទនៅក្នុងខេត្តទាំង៥ នៅជុំវិញបឹងទន្លេសាប ។ លើសពីនេះប្រាក់ជំនួយឥតសំណងផ្តល់ដោយកម្មវិធីអភិវឌ្ឍសហប្រជាជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងក្របខ័ណ្ឌនៃគម្រោងនេះ នឹងត្រូវប្រើប្រាស់សម្រាប់កសាងសមត្ថភាពមន្ត្រីនាយកដ្ឋានជលផល និងការិយាល័យជលផលខេត្ត-ក្រុង ព្រមទាំងសម្រាប់កសាងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់បឹងទន្លេសាប ។

អនុសាសន៍ដូចខាងក្រោមនេះ បានធ្វើឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្មីៗនេះ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលនៅពេលនោះ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និងនាយកដ្ឋានជលផលបានស្នើសុំមូលនិធិ និងកិច្ចសហប្រតិបត្តិការ ពីសំណាក់អង្គការអុកស្វាមអង់គ្លេស អុកស្វាមអាមេរិក និងអង្គការ WWF ដើម្បីចាត់ចែងអនុវត្តរួមគ្នាពីការពិគ្រោះយោបល់នូវសេចក្តីព្រាងច្បាប់ជលផល និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទជាមួយសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន ពីខែមីនា ដល់ខែមេសា ឆ្នាំ២០០៣ ។ ដោយមានការគាំទ្រពីអង្គការអុកស្វាមអង់គ្លេស អុកស្វាមអាមេរិក និងអង្គការ WWF នាយកដ្ឋានជលផល បានចាត់ចែងឱ្យមានសិក្ខាសាលាឆ្លុះបញ្ចាំងអំពីសហគមន៍នេសាទ ដើម្បីចែករំលែកបទពិសោធន៍នៃការអនុវត្តទស្សនវិស័យនេះ ។

## កត្តាគន្លឹះសម្រាប់អនុវត្តន៍សហគមន៍នេសាទប្រកបដោយជោគជ័យ

### កិច្ចសហការរវាងអង្គការមិនមែនរដ្ឋាភិបាល និងការិយាល័យជលផលខេត្តក្រុង នៅដំណាក់កាលដំបូង

អង្គការមិនមែនរដ្ឋាភិបាល និងការិយាល័យជលផលខេត្ត-ក្រុងបានរៀបចំការប្រជុំមួយចំនួន ដើម្បីបង្កើតកិច្ចព្រមព្រៀងរវាងភាគីទាំងពីរនេះ ។ មន្ត្រីជលផលខេត្ត-ក្រុងខ្លះ បានសំណូមពរឱ្យមានបុគ្គលិករបស់ខ្លួនកាន់តែច្រើនពាក់ព័ន្ធនៅក្នុងកម្មវិធីសហគមន៍នេសាទដើម្បីអាចទទួលបានប្រាក់កំរៃបន្ថែម ។ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាលអាចទទួលបុគ្គលិកជលផលត្រឹមតែ ១រូប ឬ ២រូប តែប៉ុណ្ណោះ ដើម្បីធ្វើការក្នុងគម្រោងទាំងនោះ ពោលគឺអ្នកទាំងនោះ ត្រូវតែមានសមត្ថភាពសម្របសម្រួល និងផ្តល់យោបល់បច្ចេកទេស ដល់ដំណើរការគ្រប់គ្រងសហគមន៍នេសាទ ។

កិច្ចសហការរវាងអង្គការមិនមែនរដ្ឋាភិបាល និងការិយាល័យជលផលខេត្តក្រុង មិនមែនជាការងាយស្រួលនោះទេ ដោយសារមន្ត្រីការិយាល័យជលផលខេត្តក្រុងបានដាក់លក្ខខណ្ឌជាច្រើន ហើយអង្គការមិនមែនរដ្ឋាភិបាលមានការប្តេជ្ញា និងសមត្ថភាពផ្តល់ហិរញ្ញវត្ថុក្នុងកម្រិតកំណត់ ។ ទោះបីទំនាក់ទំនងនេះមានលក្ខណៈសាំញ៉ាំក្តី ហើយច្រើនតែជួបប្រទះការលំបាក

ក៏ដោយ មន្ត្រីជលផល និងអង្គការមិនមែនរដ្ឋាភិបាល នៅតែពឹងពាក់គ្នាទៅវិញទៅមក ដើម្បីឱ្យការគ្រប់គ្រងសហគមន៍នេសាទបានទទួលជោគជ័យ ដោយសារភាគីមួយមានជំនាញក្នុងការបង្កើតគម្រោងសហគមន៍ ហើយភាគីមួយផ្សេងទៀតមានជំនាញបច្ចេកទេសក្នុងវិស័យជលផល ។

## អាជ្ញាធរមូលដ្ឋានបានពាក់ព័ន្ធក្នុងការបង្កើតសហគមន៍នេសាទ

កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន មិនមែនជាការងាយស្រួលឡើយ ដោយសារមន្ត្រីជាច្រើនមិនបានដឹងអំពីកំណែទម្រង់ក្នុងវិស័យជលផល ។ ក្នុងខេត្តខ្លះ អាជ្ញាធរមូលដ្ឋានមិនបានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលឡើយ ដោយសារពួកគេនិយាយថា ពួកគេត្រូវបាត់បង់ផលប្រយោជន៍ ប្រសិនបើផ្តល់កិច្ចសហការ ហើយពួកគេមានការព្រួយបារម្ភអំពីជំហរនយោបាយនៃអង្គការមិនមែនរដ្ឋាភិបាលខ្លះ។ អាជ្ញាធរមូលដ្ឋានខ្លះបានឯកភាពផ្តល់កិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែមានការបារម្ភថា សហគមន៍នេសាទអាចក្លាយជាចលនារឹងមាំ របស់ប្រជាពលរដ្ឋ ដែលអាចមានសមត្ថភាពរឹងមាំក្នុងកិច្ចការពារសកម្មភាពល្មើសច្បាប់ទៅវិញ។ ចាប់ពីពេលនោះមក អង្គការមិនមែនរដ្ឋាភិបាលបានចាត់ចែងឱ្យមានការបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនស្តីពីអនុក្រឹត្យ និងអំពីការគ្រប់គ្រងធនធានធម្មជាតិ ។សកម្មភាពបង្កើនការយល់ដឹងបានធ្វើឡើងតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាដើម្បីឱ្យអាជ្ញាធរយល់ពីតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយអាជ្ញាធរមូលដ្ឋានខ្លះក៏មានឆន្ទៈកាន់តែខ្ពស់ ក្នុងការផ្តល់កិច្ចសហការដោយចំហចំពោះសហគមន៍នេសាទ។

ប្រធានឃុំមួយចំនួនបានចូលរួមក្នុងការចាត់ចែងបង្កើតសហគមន៍ ដូចជាក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ សៀមរាប ពោធិសាត់ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង។ នៅឆ្នាំ ២០០៣ ប្រធានឃុំមួយរូបក្នុងខេត្តបាត់ដំបងបានចាប់អារម្មណ៍តិចតួច ប៉ុណ្ណោះអំពីដំណើររៀបចំសហគមន៍នេសាទ និងបានអះអាងថា សហគមន៍នេសាទពុំមានសិទ្ធិការពារធនធានជលផលឡើយ ។ សហគមន៍នេសាទពុំមានបទពិសោធន៍ ឬជំនាញក្នុងការគ្រប់គ្រងធនធានជលផលឡើយ ។ មួយឆ្នាំក្រោយមក ប្រធានឃុំដដែលនោះបានផ្លាស់ប្តូរឥរិយាបទ ដោយគាត់បានសហការណ៍ចូលរួមផ្តួចផ្តើមសហគមន៍នេសាទ ហើយបច្ចុប្បន្នគាត់បានចំណាយពេលរបស់ខ្លួនប្រមាណ ៣០% ដើម្បីធ្វើការឱ្យសហគមន៍នេសាទ ។ ទោះបីនេះជាគំរូនៃកិច្ចសហការ និងការគាំទ្រដ៏ល្អប្រសើរនៅថ្នាក់មូលដ្ឋានក្តី មេដឹកនាំនៅមូលដ្ឋានដទៃទៀត នៅតែកំពុងបន្តផ្តល់ការគាំទ្រចំពោះការនេសាទល្មើសច្បាប់ ឬ មានសាច់ញាតិធ្វើនេសាទល្មើសច្បាប់នៅក្នុងដែននេសាទសហគមន៍នៅឡើយ ។

## អ្នកពាក់ព័ន្ធនានាបានចូលរួមក្នុងដំណើរការរៀបចំសហគមន៍នេសាទ

តាំងពីឆ្នាំ ២០០០មក ទស្សនទានអំពីសហគមន៍នេសាទ ត្រូវបានអនុវត្តទូលំទូលាយក្នុងតំបន់បឹងទន្លេសាប។ ក្រសួងបរិស្ថាន និងអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ការគាំទ្រលើការអនុវត្ត និងសម្រួលដំណើរការរៀបចំសហគមន៍នេសាទ ។

នៅឆ្នាំ២០០០ គម្រោងគ្រប់គ្រងធនធានដោយសហគមន៍ ត្រូវបានបង្កើតឡើងនៅខេត្តកោះកុង ដែលគាំទ្រដោយកម្មវិធីរបស់អង្គការ IDRC និងសម្របសម្រួលដោយគម្រោងចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង ដែលមានបុគ្គលិកជាសមភាគីមកពីក្រសួងបរិស្ថាន និងមន្ទីរពាក់ព័ន្ធក្នុងខេត្ត ដូចជាទាហាន និងនគរបាល ។


ស៊ុម ប៊ុនធឿន /OA ២០០១

***ទស្សនទានរបស់សហគមន៍នេសាទត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ នៅតំបន់បឹងទន្លេសាប***

បទពិសោធន៍នានា ក្នុងអំឡុងពេលស្រាវជ្រាវនេះបានបង្ហាញថា ការចាត់ចែងឱ្យមានអ្នកពាក់ព័ន្ធចូលរួមជាប្រការលំបាក ព្រោះថាសហគមន៍នេសាទ គឺជា"ការងារសាធារណៈ"ដែលគ្មានប្រាក់ចំណូលសម្រាប់សមាជិកនោះឡើយ ។ ការបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនដែលបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងនាយកដ្ឋានជលផលបានផ្តល់ព័ត៌មាន និងបទពិសោធន៍ដ៏មានតម្លៃ ប៉ុន្តែពុំអាចស្តែងចេញជាការប្តេជ្ញាពីសំណាក់ពួកគេបានឡើយ ។ ក្នុងស្ថានភាពជាក់ស្តែងបែបនេះ អ្នកពាក់ព័ន្ធទាំងនោះកំពុងធ្វើការគាំទ្រចំពោះការនេសាទល្មើសច្បាប់ ។ មានមូលហេតុពីរយ៉ាងដែលនាំឱ្យពួកគេគាំទ្រការនេសាទល្មើសច្បាប់ ។ ទីមួយ ពួកគេត្រូវការប្រាក់ចំណូលដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលដែលមានកម្រិតទាប និងទីពីរ គឺការរកប្រាក់ចំណូលបន្ថែមឱ្យបានច្រើន សម្រាប់គាំទ្រក្រុមរបស់ខ្លួនដើម្បីអនុវត្តការងារនៅក្នុងតំបន់ទំនាបលិចទឹក ។

## អង្គការមិនមែនរដ្ឋាភិបាលសម្របសម្រួលការរៀបចំសហគមន៍នេសាទ

ដំណើរការបង្កើតសហគមន៍នេសាទដែលរៀបចំ និងសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាលមានភាពស្រដៀងគ្នានឹងដំណើរការដែលចាត់ចែងឡើងដោយនាយកដ្ឋានជំនាញនានារបស់រដ្ឋាភិបាលដែរ ប៉ុន្តែមានប្រជាពលរដ្ឋចូលរួមច្រើនជាងដំណើរការរបស់នាយកដ្ឋានជំនាញទាំងនោះ ។ មានសិក្ខាសាលាផ្តល់យោបល់ជាច្រើន ដែលបានរៀបចំនៅថ្នាក់ខេត្ត ។ ភាគច្រើននៃសិក្ខាសាលាទាំងនោះត្រូវបានរៀបចំឡើង និងទទួលការគាំទ្រពីមូលនិធិរបស់អង្គការមិនមែនរដ្ឋាភិបាល ។ បុគ្គលិកបច្ចេកទេសបានផ្តល់ជំនួយបច្ចេកទេស និងធ្វើការឆ្លើយតបចំពោះសំណួរនានារបស់សិក្ខាកាម ។ ក្រុមសម្ព័ន្ធភាព ដើម្បីអភិរក្សធនធានជលផល (FACT) បានដឹកនាំសិក្ខាសាលានៅមុនការពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទដើម្បីបង្កើនចំណេះដឹងរបស់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់អ្នកដែលបានទទួលការអញ្ជើញចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ និងថ្នាក់ជាតិ ។

ដោយសារអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់អ្នកពាក់ព័ន្ធ អ្នកនេសាទ និងអង្គការសង្គមស៊ីវិលបានយល់កាន់តែច្រើនអំពីសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ។ អាជ្ញាធរមូលដ្ឋានក៏បានដឹងអំពីប្រការនេះ

ផងដែរ។ ថ្មីៗនេះ អ្នកពាក់ព័ន្ធ អ្នកនេសាទក្នុងមូលដ្ឋាន និងអង្គការសង្គមស៊ីវិលជាច្រើន បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នានា ដើម្បីផ្តល់យោបល់ និងអនុសាសន៍លើសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ។ លើសពីនេះអ្នកចូលរួមទាំងនោះអាចផ្តល់ព័ត៌មានអំពីស្ថានភាពក្នុងតំបន់ជិតខាងរបស់ខ្លួន ដើម្បីកែលំអសេចក្តីព្រាងអនុក្រិត្យនោះ។ បច្ចុប្បន្នប្រជាពលរដ្ឋជាច្រើនបានយល់អំពីសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ អាស្រ័យហេតុនេះសហគមន៍នេសាទបានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងមុន ។

នៅក្នុងការអនុវត្តសហគ្រប់គ្រងឱ្យបានជោគជ័យ មានសមាសភាគចម្បងបួន ដែលជាកត្តាកំណត់ភាពជោគជ័យនៃសហគមន៍នេសាទ។ កត្តាទាំងនោះមានជាអាទិ៍ ការគ្រប់គ្រងធនធាន ការអភិវឌ្ឍសហគមន៍និងសេដ្ឋកិច្ច ការកសាងសមត្ថភាព និងការគាំទ្រស្ថាប័ន (Pomeroy, Katon and Harkes, 2001 in Thay 2002: 23-4) ។

១. **ការគ្រប់គ្រងធនធាន** សំដៅលើសកម្មភាពនានាដើម្បីគ្រប់គ្រង ការពារ អភិរក្ស ស្តារឡើងវិញ ការដាក់កំហិត និងការ**កែលំអ**ធនធានជលផល ។

២. **ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ច** សំដៅលើការបង្កើនប្រាក់ចំណូល លើកកំពស់កម្រិតជីវភាពរស់នៅ និងបង្កើតការងារតាមរយៈការបង្កើតជម្រើសថ្មី និងមុខរបរបន្ថែម សេវាសង្គមសម្រាប់សហគមន៍ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍សហគ្រាស និងអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ រួមទាំងឧស្សាហូបនីយកម្ម ។

៣. **ការកសាងសមត្ថភាព** សំដៅលើបុគ្គល និងក្រុមនានា ព្រមទាំងពាក់ព័ន្ធជាមួយការផ្តល់អំណាចក្នុងចំណោមប្រជាពលរដ្ឋ ការចូលរួម ការអប់រំការបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ និងការរៀបចំអង្គការចាត់តាំង ។

៤. **ការគាំទ្រស្ថាប័ន** ពាក់ព័ន្ធនឹងយន្តការគ្រប់គ្រងទំនាស់ ចំណងទាក់ទងរវាងបុគ្គល និងស្ថាប័ន ការរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក ការគាំទ្រខាងផ្នែកច្បាប់ ការកសាងគោលនយោបាយ ការតស៊ូមតិ និងបណ្តាញការងារ វេទិកានានាសម្រាប់ចែករំលែកបទពិសោធន៍ ការចែករំលែកអំណាច ការធ្វើសេចក្តីសម្រេច និងការកសាងស្ថាប័ន។ ការពង្រឹងយេនឌ័រ បញ្ហាវប្បធម៌ និងជនជាតិ ត្រូវបានក្លាយជាគោលដៅនៅគ្រប់ដំណាក់កាលនៃការអនុវត្ត ។

## សេចក្តីសន្និដ្ឋាន

ទោះបីទិដ្ឋភាពខ្លះៗ នៃសហគ្រប់គ្រងជលផលបានដំណើរការយ៉ាងសកម្មនៅក្នុងខេត្តស្វាយរៀង ក្រចេះ ស្ទឹងត្រែង និងខេត្តសៀមរាប តាំងពីឆ្នាំ ១៩៩៤ មកហើយក្តី កំណែទម្រង់គោលនយោបាយក្នុងវិស័យជលផលនាពេលថ្មីៗនេះ បានផ្តល់ជាកម្លាំងជម្រុញសម្រាប់ការអភិវឌ្ឍសហគមន៍នេសាទនៅទូទាំងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយបានធ្វើការពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីការអភិវឌ្ឍសហគមន៍នេសាទ។ បច្ចុប្បន្នមានសហគមន៍នេសាទប្រមាណ ៤០៤[១] បាន

[១] លោកឈួន គឹមឈា អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ខែធ្នូ ២០០៥

បង្កើតឡើងនៅក្នុងតំបន់បឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរ ដែលបានរៀបចំឡើងដោយ នាយកដ្ឋានជលផល ក្រសួងបរិស្ថាន (ក្នុងតំបន់ការពារធម្មជាតិសមុទ្រ ក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ប៉ុន្តែសហគមន៍នេសាទដែលបានរៀបចំឡើងដោយនាយកដ្ឋានជលផលតែឯង បានប្រឈមនឹងឧបសគ្គខាងផ្នែកថវិកា និងកង្វះបច្ចេកទេស។ លើសពីនេះការអនុវត្តដំណើរការសហគមន៍នេសាទបានប្រឈមនឹងបញ្ហាជាច្រើន ដោយសារនេះជាទស្សនទានថ្មីសម្រាប់ប្រទេសកម្ពុជា។ ទស្សនទាននេះតម្រូវឱ្យមានពេលវេលាគ្រប់គ្រាន់ កិច្ចប្រឹងប្រែង ក្របខ័ណ្ឌច្បាប់ច្បាស់លាស់ និងការ ប្តេជ្ញារយៈពេលយូរអង្វែងពីសំណាក់រដ្ឋាភិបាល (អ្នកកសាងគោលនយោបាយ មន្ត្រីបច្ចេកទេស អាជ្ញាធរមូលដ្ឋាន អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសហគមន៍នេសាទខ្លួនឯង មុនពេលអនុវត្តទស្សនទាននេះ និងមុនពេលធានាអោយបាននូវភាពជោគជ័យនៃការអភិវឌ្ឍ និងគ្រប់គ្រងសហគមន៍នេសាទនៅប្រទេសកម្ពុជា ។

## REFERENCES

Fisheries Action Coalition Team and Environmental Justice Foundation, 2002. *Feast or Famine? Solutions to Cambodia's Fisheries Conflicts.*

Fisheries Action Coalition Team, Community Based Natural Resource Management and Environmental Justice Foundation, 2002. *Making Community Fisheries Work in Cambodia.* (Poster Presentation)

Fisheries Action Coalition Team, Community Based Natural Resource Management and Environmental Justice Foundation, 2002. *Feast or Famine? Cambodia's essential fisheries resource under threat. (Poster Presentation)*

McKenney, B and Prom, T. July 2002. *Natural resource and rural livelihood in Cambodia: a Baseline Assessment.* Working Paper 23 of the Cambodia Development Research Institute.

Thay, S. January 2002. *Concept of fisheries co-management in Cambodia* (Masters thesis paper).

Thay, S. 2002. *A case study on fisheries policy reforms and the current perception about Community fisheries.*

Touch S.T., And Todd, B.H. 2002. *The inland and marine fisheries trade of Cambodia.*

# ជំពូក ៨ សហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា : ការរៀបចំបណ្តាញការងារ និងការបង្កើតទស្សនទាន

រៀបរៀងដោយ អ្នកស្រី កែន សុភាព[១] លោក ហ៊ុយ វង្ស រស្មីតារា[២] កញ្ញា អាមេនដា ប្រេដលី[៣] និងលោក យិន សូរិយា[៤ និង ៥]

## សេចក្តីផ្តើម

ជំពូកនេះអធិប្បាយអំពីសហគមន៍អេកូ-ទេសចរណ៍ នៅក្នុងប្រទេសកម្ពុជាដោយផ្តោតទៅលើការពិភាក្សាអំពីធនធានធម្មជាតិដែលជាធនធានទេសចរណ៍ ការឱ្យនិយមន័យសហគមន៍អេកូ-ទេសចរណ៍ក្នុងបរិបទនៃប្រទេសកម្ពុជា និងការវិភាគរចនាសម្ព័ន្ធគោលនយោបាយ រួមទាំងបង្ហាញអំពីបទពិសោធន៍មួយចំនួន ដែលទាក់ទងនឹងសហគមន៍អេកូ-ទេសចរណ៍មេរៀនដែលបានសិក្សា និងការផ្តល់អនុសាសន៍មួយចំនួនសម្រាប់ការអភិវឌ្ឍទៅអនាគត ។

## ធនធានធម្មជាតិ និងធនធានទេសចរណ៍

សក្តានុពលនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ផ្អែកជាសំខាន់លើមូលដ្ឋាននៃធនធានវប្បធម៌ និងធម្មជាតិ ។ ប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ជាសម្បត្តិវប្បធម៌យ៉ាងសំខាន់របស់ប្រទេសកម្ពុជាដែលទាក់ទាញទេសចរណ៍ ។ លើសពីនេះ រាជធានីភ្នំពេញក៏មានភាពទាក់ទាញទេសចរណ៍ផងដែរ ដោយសារស្ថាបត្យកម្ម វប្បធម៌ និងសោភ័ណភាព ។ នៅភាគខាងត្បូងក្រុងព្រះសីហនុ គឺជាតំបន់រមណីយដ្ឋានទេសចរណ៍លំហែកាយដ៏ល្បីល្បាញ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ។ ចំណែកបណ្តាខេត្តមួយចំនួននៅភាគខាងជើង និងភាគឦសានវិញសុទ្ធតែជាខេត្តដែលផ្តល់ឱកាសច្រើនដល់ការអភិវឌ្ឍអេកូ-ទេសចរណ៍ និងទេសចរណ៍វប្បធម៌ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ ពុំទាន់មានការអភិវឌ្ឍនៅឡើយទេ ។



Amanda Bradley/ ម្លូប់បៃតង ២០០៤

*ជីដូន និង ចៅ ជនជាតិគ្រឹងនៅក្នុងភូមិក្រឡ ខេត្តរតនគិរី*

---

[១] អ្នកស្រី កែន សុភាព ជាជំនួយការគម្រោងចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពដែលជាផ្នែកមួយនៃគម្រោងផ្តួចផ្តើមការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM Learning Initiative) ស្ថិតក្នុងអង្គការ WWF ។

[២] លោក ហ៊ុយ វង្ស រស្មីតារា ជានិស្សិតអនុបណ្ឌិត នៃសាកលវិទ្យាល័យន័រតុន កម្ពុជា ។

[៣] កញ្ញា អាមេនដា ប្រេដលី ជាទីប្រឹក្សាគម្រោងនៃអង្គការបរិស្ថានក្នុងស្រុកឈ្មោះម្លូប់បៃតង និងជាអ្នកសម្របសម្រួលកម្មវិធីនៃ គម្រោងសម្ព័ន្ធភាពសហគមន៍ព្រៃឈើសម្រាប់កម្ពុជា ។

[៤] លោក យិន សូរិយា ជាសាស្ត្រាចារ្យផ្នែកទេសចរណ៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ RUPP ។

[៥] ការចូលរួមចំណែកពីគណៈកម្មការបណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជា CCBEN ។

នាពេលថ្មីៗនេះ មាននិន្នាការបង្ហាញពីការចាប់អារម្មណ៍កាន់តែច្រើនឡើងអំពីធម្មជាតិក្នុងប្រទេសកម្ពុជា ពីសំណាក់ភ្ញៀវទេសចរណ៍។ ប្រទេសកម្ពុជាមានប្រភេទសត្វ និងរុក្ខជាតិកម្រមួយចំនួន ។ ទោះបីចំនួនសត្វ និងរុក្ខជាតិទាំងនេះមានការថយចុះនៅទូទាំងទ្វីបអាស៊ីដោយសារការបរបាញ់ និងការធ្វើអាជីវកម្មល្មើសច្បាប់យ៉ាងណាក៏ដោយ ក៏សត្វព្រៃ និងរុក្ខជាតិទាំងនេះនៅមានច្រើនបង្គួរនៅឡើយក្នុងប្រទេសកម្ពុជា ។ ប្រទេសកម្ពុជាសម្បូណ៌ទៅដោយធនធានធម្មជាតិល្អស្រស់ត្រកាល ឧទ្យានជាតិ និងតំបន់ការពារដែនសមុទ្រជាច្រើនកន្លែង ដែលនឹងផ្តល់សក្តានុពលដ៏ធំធេងដល់ការអភិវឌ្ឍទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ ប្រសិនបើត្រូវបានការពារ និងគ្រប់គ្រងបានល្អ ។

ខេត្តរតនគីរីដែលស្ថិតនៅភូមិភាគឦសាន មានសក្តានុពលខ្ពស់ខាងផ្នែកទេសចរណ៍ធម្មជាតិ ។ ខេត្តនេះត្រូវបានចាត់ទុកជាតំបន់គោលដៅចម្បងសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលមានបំណងបង្កើតប្រភេទផលិតផល និងរៀបចំតំបន់គោលដៅអេកូ-ទេសចរណ៍ ទន្ទឹមនឹងការប្រឹងប្រែងពង្រីក សេវាកម្មទេសចរណ៍តាមវិជ្ជាជីវៈ និងបំពេញ តាមតម្រូវការនៃកំណើនទីផ្សារអន្តរជាតិផ្នែកអេកូ-ទេសចរណ៍ ។ ការគ្រប់គ្រងធនធានធម្មជាតិអោយបានល្អ គឺជាមូលដ្ឋានគ្រឹះ សំខាន់ណាស់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ។ ការគ្រប់គ្រងទេសចរណ៍អោយមានចីរភាពបានលុះត្រាតែការអភិវឌ្ឍតំបន់គោលដៅទេសចរណ៍ ត្រូវបានចាត់ចែងប្រកបដោយទស្សនវិស័យសម្រាប់រយៈពេលយូរអង្វែង ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅជនបទ (Yin, ២០០៣) ។

## ភាពរីកចម្រើននៃវិស័យទេសចរណ៍

អាស្រ័យដោយមានធនធានសម្បូណ៌បែប ស្ថេរភាពនយោបាយ កំណើនគុណភាព និងវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទេសចរណ៍ បានធ្វើអោយចំនួនភ្ញៀវទេសចរអន្តរជាតិចូលមកកម្ពុជាមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលពីរ-បីឆ្នាំចុងក្រោយនេះ ។ ទោះបីចំនួនភ្ញៀវទេសចរណ៍តែងមិនមែនជា សូចនាករណ៍បង្ហាញពីភាពរីកចម្រើននៃវិស័យទេសចរណ៍ក៏ដោយ ក៏ចំនួនសរុបនៃភ្ញៀវអន្តរជាតិបានកើនឡើងពី១១៨.១៨៣នាក់ ក្នុងឆ្នាំ១៩៩៣ រហូតដល់៧០១.០១៤នាក់ ក្នុងឆ្នាំ២០០៣ ដែលភាគច្រើននៃភ្ញៀវទាំងនេះមកពីបណ្តាប្រទេសអាស៊ី ប្រទេសបារាំង សហរដ្ឋអាមេរិក អូស្ត្រាលី និងចក្រភពអង់គ្លេស (MoT, ២០០៣) ។

**ចំនួនភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៣**[៦]




*ប្រភព : របាយការណ៍ស្ថិតិប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍ ឆ្នាំ២០០៣*

[៦] តារាងខាងលើបង្ហាញពីកំណើនយ៉ាងឆាប់រហ័សនៃចំនួនភ្ញៀវទេសចរលើកលែងតែឆ្នាំ ១៩៩៧ និង២០០៣។ ឆ្នាំ១៩៩៧ ចំនួនភ្ញៀវទេសចរថយចុះបណ្តាលមកពីទំនាស់នយោបាយរវាងគណបក្សនយោបាយក្នុងរដ្ឋាភិបាលចម្រុះ និងវិបត្តិហិរញ្ញវត្ថុអាស៊ី និងក្នុងឆ្នាំ២០០៣ បណ្តាលមកពីជំងឺសារស៍ សង្គ្រាមនៅអ៊ីរ៉ាក់ និងកុបកម្មប្រឆាំងថៃ។ ទោះជាបែបនេះក្តី ក្រសួងទេសចរណ៍នៅតែមានសុទិដ្ឋិនិយមថាវិស័យទេសចរណ៍កម្ពុជានឹងនៅតែបន្តរីកចម្រើន។

## តួនាទីនៃវិស័យទេសចរណ៍ ក្នុងការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ

វិស័យទេសចរណ៍មានសក្តានុពលក្នុងការកាត់បន្ថយភាពក្រីក្រ ដោយសារវិស័យនេះអាចនាំមកនូវប្រាក់ចំណូល និងស្រូបយកកម្លាំងពលកម្មបានច្រើន ។ វិស័យទេសចរណ៍នៅប្រទេសកម្ពុជាបានផ្តល់ការងារសម្រាប់ប្រជាពលរដ្ឋកម្ពុជាប្រមាណ ១០០,០០០នាក់ (MoT, ២០០៣)។ លើសពីនេះវិស័យទេសចរណ៍ ត្រូវបានប្រមាណថាបានផ្តល់រូបិយប័ណ្ណអន្តរជាតិសរុបប្រហែល១០០ លានដុល្លា ក្នុងឆ្នាំ១៩៩៥ រហូតដល់៣៨៦ លានដុល្លា ក្នុងឆ្នាំ២០០៣ (MoT, ២០០៣) ។ ថ្មីៗនេះប្រាក់ចំណូលពីវិស័យទេសចរណ៍មានចំនួន ១២.៥% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា។

មិនមែនគ្រប់ប្រភេទទេសចរណ៍ទាំងអស់អាចកាត់បន្ថយភាពក្រីក្របានទេ។ ឧទាហរណ៍ ការអភិវឌ្ឍវិស័យទេសចរណ៍ខ្នាតធំ និងការលេចធ្លាយផ្នែកសេដ្ឋកិច្ច អាចធ្វើឱ្យចំណូលភាគច្រើនពីវិស័យទេសចរណ៍ហូរចេញពីប្រទេស ។ ផែនការជាតិអភិវឌ្ឍន៍ទេសចរណ៍ (២០០៣) និង Schellhorn និង Simmons (២០០៣)បានផ្តល់អនុសាសន៍ថាត្រូវជម្រុញទេសចរណ៍ក្នុងស្រុក និងអ្នកទេសចរណ៍ពនេចរ ជាមធ្យោបាយរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ Schellhorn & Simmons បានអះអាងថាទេសចរណ៍ប្រភេទនេះភាគច្រើនប្រើប្រាស់ធនធានក្នុងមូលដ្ឋានដែលសហគមន៍ក្រីក្រអាចផ្តល់ឱ្យបាន ។ បន្ថែមពីនេះទៀត ភាពក្រីក្រអាចត្រូវបានកាត់បន្ថយបាន លុះត្រាតែសហគមន៍មូលដ្ឋានត្រូវបានគេផ្តល់សិទ្ធិ ការទទួលខុសត្រូវផ្នែកគ្រប់គ្រង ពោលគឺសិទ្ធិ និងអំណាចពេញលេញក្នុងការចាត់ចែងធនធានធម្មជាតិ និងអនាគតរបស់ពួកគេ (Yin, ២០០៣)។

## តើសហគមន៍អេកូ-ទេសចរណ៍ជាអ្វី ?

សហគមន៍អេកូ-ទេសចរណ៍អន្តរជាតិ (IES) បានឱ្យនិយមន័យអេកូ-ទេសចរណ៍ថាជា " *ការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវទៅក្នុងតំបន់ធម្មជាតិ ដែលមានលក្ខណៈអភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពរបស់សហគមន៍មូលដ្ឋាន* "។ នៅតាមសហគមន៍អេកូ-ទេសចរណ៍ (CBET) សហគមន៍មូលដ្ឋានមានអំណាចគ្រប់គ្រងយ៉ាងសកម្មក្នុងគម្រោងអេកូ-ទេសចរណ៍ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ក្រោសក្រែលពីសកម្មភាពទាំងនោះ។ សហគមន៍អេកូ-ទេសចរណ៍ គឺជាផ្នែកមួយនៃទេសចរណ៍ដើម្បីកាត់បន្ថយភាពក្រីក្រ។ ចរិកលក្ខណៈនៃ



Amanda Bradley/ ២០០៤

***នេះជាការបង្ហាញពីផ្ទះរបស់កូនក្រមុំ និងកូនកំលោះដែលជាប្រពៃណីរបស់ប្រជាជនទំពួន នៅយក្សឡោម ។***

សហគមន៍អេកូ-ទេសចរណ៍មានជាអាទិ៍ ផ្តល់នូវជម្រើសផ្សេងៗក្នុងការបង្កើនប្រាក់ចំណូល និងផ្តល់ជម្រើសការងារដល់សហគមន៍មូលដ្ឋាន បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ពីការអភិរក្ស ផ្តល់ការអប់រំ និងការបកស្រាយអំពីធម្មជាតិ ដែលជាផ្នែកមួយនៃផលិតផលទេសចរណ៍ ហើយក៏ដូចជាការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះធនធានធម្មជាតិ និងបរិស្ថានសង្គមវប្បធម៌ ។ សហគមន៍អេកូ-ទេសចរណ៍ (CBET) ផ្តល់ការគាំទ្រដល់កិច្ចការពារតំបន់ធម្មជាតិ ដោយបង្កើតនូវអត្ថប្រយោជន៍សេដ្ឋកិច្ចដល់សហគមន៍ តាមរយៈការរៀបចំជាក្រុមតូចៗ។ ក្នុងករណីប្រទេសកម្ពុជាសហគមន៍អេកូ-ទេសចរណ៍ មិនត្រឹមតែរួមចំណែកការពារធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកស្ទួយវប្បធម៌ជនជាតិភាគតិចទៀតផង ។ សហគមន៍អេកូ-ទេសចរណ៍ (CBET) គួរតែបង្កើនការអភិរក្សជីវៈចម្រុះផងដែរ (Ngece, ២០០២)។

## ការចូលរួមរបស់សហគមន៍

ក្នុងសហគមន៍អេកូ-ទេសចរណ៍ (CBET) សហគមន៍ដើរតួនាទីយ៉ាងសំខាន់ធ្វើជាម្ចាស់ ជាអ្នកគ្រប់គ្រង ជាអ្នកធ្វើសេចក្តីសម្រេច និងជាអ្នកថែរក្សា។ ជោគជ័យរបស់សហគមន៍អេកូ-ទេសចរណ៍ តម្រូវអោយមានការចូលរួមយ៉ាងខ្លាំងក្លាពីមនុស្សក្នុងសហគមន៍ ប៉ុន្តែត្រូវមានកិច្ចសហការល្អជាមួយអ្នកពាក់ព័ន្ធ ដូចជាក្រុមហ៊ុនទេសចរណ៍ និងអាជ្ញាធរមូលដ្ឋាន។ ដើម្បីបង្កើនឱ្យការចូលរួមមានប្រសិទ្ធភាព សហគមន៍មូលដ្ឋានត្រូវចូលរួមក្នុងការបង្កើតផែនការយុទ្ធសាស្ត្រទេសចរណ៍ និងក្នុងការអនុវត្ត ព្រមទាំងវាយតម្លៃសកម្មភាពពាក់ព័ន្ធ។ ប្រការសំខាន់ផងដែរគឺការពង្រឹងផ្នែកច្បាប់ និងការទទួលខុសត្រូវរបស់សហគមន៍ លើការកាន់កាប់ដីធ្លី ធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍។ សហគមន៍មូលដ្ឋានអាចរកប្រាក់ចំណូលបន្ថែមដោយការចូលរួមក្នុងសកម្មភាពសហគមន៍អេកូ-ទេសចរណ៍ (CBET) ដូចជាសេវានាំភ្ញៀវទេសចរណ៍ លក់សិប្បកម្មធ្វើដោយដៃ លក់ម្ហូបអាហារ ផ្តល់កន្លែងស្នាក់នៅ ។

ការចូលរួមរបស់សហគមន៍មិនត្រឹមតែផ្តោតលើផលប្រយោជន៍ខាងសម្ភារៈសម្រាប់មនុស្សក្នុងសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតផងដែរអំពីគោលបំណងនៃការអភិរក្សជីវៈចម្រុះ ។ សហគមន៍មូលដ្ឋានត្រូវធ្វើឱ្យប្រាកដថាអ្នកពាក់ព័ន្ធទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពសហគមន៍ទេសចរណ៍ធម្មជាតិ (CBET)។ សកម្មភាពភ្ញៀវទេសចរណ៍មិនត្រូវធ្វើឱ្យខូចតម្លៃ ឬបំផ្លិចបំផ្លាញធនធានធម្មជាតិឡើយ ។ ប្រាក់ចំណូលពីសេវាភ្ញៀវទេសចរណ៍ត្រូវរួមចំណែកដើម្បីការអភិវឌ្ឍអោយមាននិរន្តរភាព និងបង្កើនមុខរបរសម្រាប់ទ្រទ្រង់ជីវភាពរបស់សហគមន៍មូលដ្ឋាន ហើយអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែគាំទ្រយ៉ាងសកម្មចំពោះការអភិរក្សធម្មជាតិ និងបេតិកភ័ណ្ឌវប្បធម៌។

## អត្ថប្រយោជន៍ និងការប្រឈមនៃសហគមន៍ទេសចរណ៍ធម្មជាតិ (CBET)

សហគមន៍អេកូ-ទេសចរណ៍ (CBET) អាចផ្តល់អត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋានជាសម្ភារៈ និងអត្ថប្រយោជន៍អរូបិយ ផ្សេងទៀត ដូចជាអត្ថប្រយោជន៍សេដ្ឋកិច្ចសង្គម អត្ថប្រយោជន៍បរិស្ថាន និងអត្ថប្រយោជន៍វប្បធម៌ ។

ស្របពេលជាមួយគ្នានេះដែរ សហគមន៍មូលដ្ឋានត្រូវប្រឈមនឹងបញ្ហាជាច្រើន ។ គោលដៅចម្បងរបស់សហគមន៍អេកូ-ទេសចរណ៍ (CBET) គឺផ្តល់ប្រាក់ចំណូលដល់សហគមន៍មូលដ្ឋាន ប៉ុន្តែប្រសិនបើប្រាក់ចំណូលមិនត្រូវបានចែករំលែកអោយមានសមភាពនៅក្នុងសហគមន៍ទេ នោះគម្លាតរវាងអ្នកមាន និងអ្នកក្រ នឹងកើនឡើងដោយសារប្រជាពលរដ្ឋក្រីក្រភាគច្រើននឹងទទួលផលប្រយោជន៍តិចតួចតែប៉ុណ្ណោះ ។ អ្នកទាំងនេះនឹងមិនបានទទួលនូវការលើកទឹកចិត្ត ដើម្បីការពារធនធានធម្មជាតិឡើយ ដូច្នេះ ធនធានបរិស្ថាននៅតែបន្តរងការបំផ្លិចបំផ្លាញ ដែលនេះជាឧបសគ្គចំពោះគោលដៅធានានិរន្តរភាពនៃការចិញ្ចឹមជីវិត ។

ដើម្បីអោយទទួលបាននូវអត្ថប្រយោជន៍យូរអង្វែងពីសហគមន៍អេកូ-ទេសចរណ៍ (CBET) សហគមន៍មូលដ្ឋានត្រូវតែបង្កើតយន្តការដែលផ្តល់ការបែងចែកផលឱ្យបានប្រសើរប្រកបដោយសមធម៌ ។ លើសពីនេះ ប្រការចាំបាច់គឺត្រូវបង្កើត និងអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងគោលការណ៍ណែនាំសម្រាប់អនុវត្តន៍ក្នុងសហគមន៍ផងដែរ ។

| **អត្ថប្រយោជន៍** | **ការប្រឈមមុខ** |
|---|---|
| • ឱកាសការងារប្រសើរឡើង<br>• ប្រាក់ចំណូលបន្ថែមដល់សហគមន៍មូលដ្ឋាន<br>• ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធថែទាំសុខភាព<br>• បង្កើនសមត្ថភាពធនធានមនុស្ស (ការអប់រំ គុណភាពគ្រូនៅសាលារៀនជាដើម ។<br>• ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន<br>• បង្កើនការយល់ដឹងអំពីសកម្មភាពសហគមន៍ទេសចរណ៍ធម្មជាតិ (CBET) បញ្ហាបរិស្ថាន និងគាំទ្រដល់ការអភិរក្សធម្មជាតិ ។<br>• ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ កន្លែងស្នាក់អាស្រ័យជាដើម ។<br>• ការគាំទ្រការអភិវឌ្ឍន៍អេកូ-ទេសចរណ៍ពីអ្នកពាក់ព័ន្ធ<br>• កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន និងឱកាសក្នុងកិច្ចការពារធនធានធម្មជាតិយូរអង្វែង ។ | • កំណើនប្រជាពលរដ្ឋ<br>• ធ្វើអោយខូចខាតប្រព័ន្ធអេកូឡូស៊ី<br>• បំពុលបរិស្ថាន ការចោលសំណល់រឹង<br>• បង្កើនការប្រើប្រាស់ធនធាន និងបង្កអោយមានជម្លោះចំពោះការប្រើប្រាស់ធនធានធម្មជាតិ ។<br>• បង្កផលប៉ះពាល់ដល់វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិច និងតម្លៃនៃជំនឿ ។<br>• បង្កើនការកៀបសង្កត់ពីលើសិទ្ធិកាន់កាប់ដីធ្លី |

*តារាងទី២: អត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃសហគមន៍អេកូ-ទេសចរណ៍ (CBET)*

## គោលនយោបាយសម្រាប់សហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា

ទោះបីពុំទាន់មានគោលនយោបាយច្បាស់លាស់ស្តីពីសហគមន៍ទេសចរណ៍ធម្មជាតិក្នុងប្រទេសកម្ពុជាក៏ដោយ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមឆ្នាំ២០០១-០៥ (SEDPII) (មើលជំពូកទី៣) ផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍ជាតិឆ្នាំ២០០៣ (NTDP) ផែនការបរិស្ថានជាតិ ១៩៩៨-២០០២ (NEAP) និងផែនការវិមជ្ឈការនៃកម្ពុជា (DP) បានផ្តល់គោលនយោបាយទាក់ទងនឹងសហគមន៍អេកូ-ទេសចរណ៍ (CBET) ។ ផែនការទាំងអស់បានផ្តោតទៅលើការអភិវឌ្ឍទេសចរណ៍ប្រកបដោយ

និរន្តរភាពដើម្បីជួយកាត់បន្ថយភាពក្រីក្រ ក្នុងចំណោមសហគមន៍ក្រីក្រ និងដើម្បីការពារបរិស្ថាន និងវប្បធម៌ដោយផ្តល់នូវស្វ័យភាពដល់សហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

ខាងក្រោមនេះជាគោលនយោបាយពាក់ព័ន្ធ :

- កាត់បន្ថយភាពក្រីក្រ និងសម្រេចបាននូវសមធម៌ក្នុងសង្គម និងយេនឌ័រក្នុងការរៀបចំផែនការសង្គម និងបរិបទនៃការអភិវឌ្ឍ (SEDPII)
- ការពារបេតិកភ័ណ្ឌគ្រប់ផ្នែក ( ធម្មជាតិ និងវប្បធម៌ ព្រមទាំងប្រពៃណី និងតម្លៃនៃប្រជាពលរដ្ឋកម្ពុជា (NTDP)
- ទាញយកប្រាក់ចំណូលដោយសហគមន៍មូលដ្ឋាន (SEDPII)
- ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាផែនការសហគមន៍ ព្រមទាំងគោលនយោបាយជាតិ ត្រូវបានអនុវត្តតាមគោលដៅ (NTDP)
- ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) ត្រូវអនុវត្តឱ្យបានត្រឹមត្រូវមុនអនុម័តឯកភាពលើគម្រោងអភិវឌ្ឍន៍ (NEAP)
- ត្រូវធានាឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ទាំងក្នុងការកសាងផែនការ និងក្នុងសកម្មភាពសេដ្ឋកិច្ច។ ត្រូវធ្វើការសិក្សាស្រាវជ្រាវអំពីការកសាងសមត្ថភាព និងការបង្កើតយន្តការសម្រាប់គាំទ្រសហគ្រាសខ្នាតតូច និងមធ្យមក្នុងពេលសមរម្យ (SEDPII)
- ផ្តោតការយកចិត្តទុកដាក់លើការកសាងយុទ្ធសាស្ត្រដែលនឹងផ្តល់ឱកាសដល់បណ្តាតំបន់ដែលពុំទាន់មានការផ្តល់សេវានានា និងហេដ្ឋារចនាសម្ព័ន្ធ (NTDP)
- ធានាថា គោលនយោបាយអភិវឌ្ឍន៍ ( រួមមានសាធារណៈការ និងដឹកជញ្ជូន រថយន្តក្រុង និងបណ្តាញផ្លូវថ្នល់ ផ្តល់ការគាំទ្រ ដល់កិច្ចការពារ និងជម្រុញភាពទាក់ទាញផ្សេងៗ (NTDP)
- រួមបញ្ចូលអ្នកពាក់ព័ន្ធកាន់តែច្រើននៅក្នុងរាល់ការធ្វើសេចក្តីសម្រេច និងការបែងចែកធនធាន (NTDP)

ផែនការទាំងនោះក៏បានបញ្ជាក់ថា ដើម្បីឱ្យមានការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើចំនួន និងស្ថិតិភ្ញៀវទេសចរណ៍ ទន្ទឹមគ្នានឹងការស្វែងយល់អំពីផលប៉ះពាល់ខាងគុណភាព និងសេដ្ឋកិច្ចនៃទេសចរណ៍ និងកំណើននៃផលចំណូលពីវិស័យទេសចរណ៍សម្រាប់ក្រុមជនក្រីក្រ និងក្រុមជនផ្សេងទៀតក្នុងសង្គម ។ លើសពីនេះការជ្រើសរើសយកគោលនយោបាយទេសចរណ៍ជួយជនក្រីក្រ ទាមទារមិនត្រឹមតែការដាក់បញ្ចូលភាពក្រីក្រទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវការឱ្យមានការផ្លាស់ប្តូរទម្រង់នៃការអភិវឌ្ឍទេសចរណ៍ ដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកក្រ ។

ដោយសារការអភិវឌ្ឍវិស័យទេសចរណ៍ពាក់ព័ន្ធនឹងស្ថាប័នច្រើន ប្រការសំខាន់គឺអ្នកកសាងផែនការ និងអ្នកគ្រប់គ្រង ដែលធ្វើការក្នុងវិស័យនានា ត្រូវស្វែងយល់អំពីសារៈសំខាន់នៃទេសចរណ៍ ថាជាប្រភពនៃសក្តានុពលដើម្បីកាត់បន្ថយភាពក្រីក្រ ។ គោលនយោបាយទេសចរណ៍កាត់បន្ថយភាពក្រីក្រនឹងធានាថា ទិដ្ឋភាពនានានៃទេសចរណ៍ត្រូវបានរួមបញ្ចូលទៅក្នុងផែនការសហគមន៍ទូទៅ និងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចប្រចាំតំបន់ ។

## បទពិសោធន៍សហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា

### ប្រវត្តិទូទៅ

ក្នុងប្រទេសកម្ពុជា តំបន់សហគមន៍អេកូ-ទេសចរណ៍មានតែមួយចំនួនតូចប៉ុណ្ណោះ ។ បឹងយក្សឡោមក្នុងខេត្តរតនគិរី គឺជាតំបន់អេកូ-ទេសចរណ៍ដំបូងបំផុតដែលបានបង្កើតនៅឆ្នាំ ១៩៩៥ ក៏ប៉ុន្តែគម្រោងថ្មីៗជាច្រើនកំពុងត្រូវបានរៀបចំឡើង ។ នៅឃុំចំបក់ ខេត្តកំពង់ស្ពឺ អ្នកភូមិបានបង្កើតតំបន់សហគមន៍អេកូ-ទេសចរណ៍មួយកន្លែងកាលពីខែមករា ឆ្នាំ២០០៣ ដោយមានការជួយសម្របសម្រួល ពីអង្គការម្លប់បៃតង ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ។ អង្គការ LWF អង្គការ Osmose អង្គការ WWF និងអង្គការផ្សេងៗទៀត ក៏កំពុងគាំទ្រការផ្តួចផ្តើមបង្កើតសហគមន៍អេកូ-ទេសចរណ៍ក្នុងខេត្តកំពង់ស្ពឺ សៀមរាប រតនគិរី និងមណ្ឌលគិរីផងដែរ ។



Amanda Bradley/ ម្លប់បៃតង ២០០៤

*ភ្ញៀវទេសចរណ៍នៅបឹងយក្សឡោម ខេត្តរតនគិរី*

## ករណីសិក្សានៅបឹងយក្សឡោម

បឹងយក្សឡោមជាបឹងធម្មជាតិមួយរាងស្ទើរការ៉េ ស្ថិតនៅចំកណ្តាលភ្នំក្នុងស្រុកបានលុងចម្ងាយ៥គីឡូម៉ែត្រពីទីរួមខេត្តរតនគីរី ។ បឹងនេះមានអង្កត់ផ្ចិតប្រហែល៨០០ម៉ែត្រ ជម្រៅ៤៨ម៉ែត្រនៅក្នុងរដូវប្រាំង បឹងនេះបានកើតឡើងដោយបន្ទុះភ្នំភ្លើងរាប់សតវត្សរ៍មកហើយ ។ បឹងយក្សឡោមមានទេសភាព តំបន់ភ្នំគួរអោយចាប់ចិត្តជាទីជម្រកសត្វស្លាបយ៉ាងប្រណិត ហើយផ្តល់ឱកាសដល់ទេសចរណ៍ក្នុងការស្វែងយល់ពីជីវិតប្រចាំថ្ងៃរបស់ជនជាតិភាគតិចតំបន់ភ្នំ ។

នៅឆ្នាំ១៩៩៥ ឆ្លើយតបទៅនឹងផែនការកំណត់ព្រៃសម្បទាននៅទូទាំងខេត្តរតនគីរី និងភាពរេចរិលនៃបរិស្ថាន មន្ត្រីខេត្តបានប្រកាសតំបន់ការពារធម្មជាតិចំនួន១១កន្លែងនៅក្នុងខេត្ត រួមមានឃុំយក្សឡោមផងដែរ ។ គោលបំណងនៃការអភិវឌ្ឍឃុំយក្សឡោមជាតំបន់ការពារធម្មជាតិ គឺដើម្បីការពារព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងទីជម្រាល ព្រមទាំងដើម្បីអភិវឌ្ឍន៍ឱ្យទៅជាកន្លែងសម្រាកលំហែកាយ កន្លែងផ្តល់ការអប់រំ និងតំបន់ទេសចរណ៍ ។

នៅឆ្នាំ១៩៩៦ មជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃប្រទេសកាណាដា (the International Development Research Centre of Canada) បានចុះកិច្ចសន្យារយៈពេលមួយឆ្នាំជាមួយអាជ្ញាធរខេត្តរតនគីរី ដើម្បីប្រើប្រាស់បឹងយក្សឡោម និងបរិស្ថានជុំវិញ និងចាត់ចែងមធ្យោបាយដើម្បីឱ្យសហគមន៍ក្នុងស្រុកគ្រប់គ្រងបន្ត (Barton, ១៩៩៦)។ ក្រោយមកនៅឆ្នាំ ១៩៩៨ សហគមន៍បានស្នើសុំ អាជ្ញាធរខេត្តឱ្យផ្តល់សិទ្ធិពិសេសដើម្បីកាន់កាប់បឹងនេះ ។ សំណើនោះបានទទួលការយល់ព្រម និងចុះកិច្ចសន្យារយៈពេល២៥ឆ្នាំ ។ សហគមន៍បឹងយក្សឡោមដែលមាន៥ភូមិក្នុងឃុំចូលរួម បានបង្កើតឡើងដើម្បីការពារតំបន់ស្នូលដែលគ្របដណ្តប់ផ្ទៃដីទំហំ ៣៦២ហិកតា។ គណៈកម្មការ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីគម្រោងសិលា/ភីអិលជី និងធ្វើរបាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ សម្រាប់រយៈពេលពីរឆ្នាំបន្ទាប់ គម្រោងសិលា/ភីអិលជី ធ្វើការផ្តោតទៅលើការកសាងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងបឹងនេះ និងបំផុសអោយសហគមន៍ចូលរួមក្នុងសកម្មភាពដូចជាអាជីវកម្មខ្នាតតូច ការចូលរួមពី សហគមន៍ឱ្យកាន់តែច្រើនឡើងក្នុងការគាំទ្រសកម្មភាពរបស់គណៈកម្មការនេះ ។

នៅដើមឆ្នាំ ២០០១ ក្រោមការគាំទ្រពីគម្រោងអភិវឌ្ឍន៍ការអប់រំតាមភូមិដាច់ស្រយាល (DRIVE) ដែលទទួលមូលនិធិពីប្រទេសអូស្ត្រាលី គម្រោងសហគមន៍អេកូ-ទេសចរណ៍យក្សឡោម (YLCBET) ត្រូវបានបង្កើតឡើង ហើយក្លាយជាតំបន់សហគមន៍ទេសចរណ៍ដំបូងគេបំផុតក្នុងប្រទេសកម្ពុជា ។ ទាំងគម្រោង DRIVE និងគម្រោងសិលា/ភីអិលជីបានព្យាយាមបង្កើតសហគមន៍អេកូ-ទេសចរណ៍នៅបឹងយក្សឡោម និងបង្ហាញពីការរួមបញ្ចូលសកម្មភាពនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ និងរក្សាការចូលរួមរបស់សហគមន៍ ទោះបីជាពួកយកគេទទួលថវិកាផ្សេងៗក៏ដោយ។ ក្នុងឆ្នាំ២០០២ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់បានផ្តល់នូវរចនាសម្ព័ន្ធថ្មី និងចាប់ផ្តើមសកម្មភាពដែលពាក់ព័ន្ធដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។ គម្រោងសហគមន៍អេកូ-ទេសចរណ៍យក្សឡោម (YLCBET) បានទទួលជោគជ័យជាច្រើនក្នុងការបង្កើនជីវភាពប្រចាំថ្ងៃការអភិរក្ស និងការចូលរួមពីសហគមន៍។ ប្រាក់ចំណូលសរុបប្រចាំឆ្នាំពីវិស័យទេសចរណ៍ សម្រាប់ឃុំយក្សឡោមកើនឡើងពី៦១០ ដុល្លា អាមេរិកក្នុងឆ្នាំ១៩៩៩ ដល់ ៣.៨៨៦ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០២ ។ នេះគឺអាស្រ័យដោយការកើនឡើងនៃចំនួនភ្ញៀវទេសចរណ៍ ព្រមទាំងការតំឡើងថ្លៃសំបុត្រចូល កំសាន្ត ពី០,៥០ ដល់ ១ដុល្លា អាមេរិកសម្រាប់ភ្ញៀវទេសចរណ៍បរទេស ។ បច្ចុប្បន្ននេះ ប្រាក់ចំណូលត្រូវបានយក មកផ្គត់ផ្គង់ការគ្រប់-គ្រងបឹង និងប្រាក់បៀវត្សរ៍បុគ្គលិក។ សហគមន៍បានរាយការណ៍អំពីមោទនភាពរបស់ពួកគេចំពោះវប្បធម៌ និងបរិស្ថាន។ ការងារនេះបាននាំឱ្យសហគមន៍ចូលរួមក្នុងការគ្រប់គ្រង រមណីយដ្ឋាន ការបម្រើសេវាកម្ម ការសម្តែងសិល្បៈ សិប្បកម្មធ្វើដោយដៃ និងវត្ថុប្រពៃណីជនជាតិដើមភាគតិចលក់ផលិតផល កសិកម្ម និងការពារធនធានវិស័យទេសចរណ៍ និងថែទាំរមណីយដ្ឋានសម្រាប់ភ្ញៀវទេសចរណ៍កំសាន្ត (Yin, ២០០៣) ។

ទោះបីបានទទួលជោគជ័យបែបនេះក៏ដោយ គម្រោងសហគមន៍ទេសចរណ៍ធម្មជាតិយក្សឡោម កំពុងជួបប្រទះបញ្ហាជាច្រើនដែលមានលក្ខណៈប្រហាក់ប្រហែលនឹងតំបន់ផ្សេងៗទៀតក្នុងខេត្តរតនគីរីដែរ។ បញ្ហាទាំងនោះមានជាអាទិ៍ កង្វះការយល់ដឹងពីទេសចរណ៍ក្នុងចំណោមសហគមន៍ កង្វះជំនាញក្នុងវិស័យទេសចរណ៍ ការលក់ និងទិញដី ការពង្រីកទីប្រជុំជនពីស្រុកបានលុង ការកៀបសង្កត់ពីសេដ្ឋកិច្ចទីផ្សារ កង្វះភាពជាម្ចាស់គម្រោង និងការពឹងផ្អែកខ្លាំងទៅលើអ្នកពីខាងក្រៅ និងការគ្រប់គ្រងពីលើចុះក្រោមពីសំណាក់អាជ្ញាធរថ្នាក់លើ។ លើសពីនេះ សាមគ្គីភាពក្នុងសហគមន៍ កំពុងត្រូវបានគម្រាមកំហែង ហើយធនធានធម្មជាតិដែលមានដោយកម្រកំពុងបណ្តាលឱ្យមានទំនាស់ក្នុងសហគមន៍ ។

បញ្ហាទាំងនេះអាចត្រូវបានដោះស្រាយបានលុះត្រាតែមានការធានាស្វ័យភាពរបស់សហគមន៍លើធនធានធម្មជាតិ និងគោរពច្បាប់ និងមានការផ្តល់អំណាចតាមរយៈការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍជំនាញ ជំនួយក្នុងការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ពួកគេ និងភ្ជាប់បណ្តាញទាក់ទង ជាមួយសហគមន៍អេកូ-ទេសចរណ៍ដទៃទៀតទាំងក្នុង និងក្រៅប្រទេស។

## ករណីសិក្សានៅចំបក់

សហគមន៍អេកូ-ទេសចរណ៍ចំបក់ ស្ថិតនៅក្នុងឃុំចំបក់ នៅជាយឧទ្យានជាតិគិរីរម្យក្នុងខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា ។

អង្គការម្លប់បៃតងដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើការខាងផ្នែកបរិស្ថាននៅក្នុងប្រទេសកម្ពុជា បាននិងកំពុងធ្វើការជាមួយសហគមន៍ក្នុងតំបន់នេះតាំងពីឆ្នាំ២០០០មក ដោយមានគោលដៅគាំទ្រការអភិរក្សជីវៈចម្រុះក្នុងឧទ្យានជាតិ ព្រមទាំងជួយផ្តល់ជម្រើសនៃការចិញ្ចឹមជីវិត សម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមព្រំប្រទល់ឧទ្យានជាតិ ។ ជាទូទៅអ្នកភូមិក្នុងឃុំចំបក់ទាំងមូលពឹងផ្អែកទាំងស្រុងលើធនធានព្រៃឈើ ជាពិសេសការផលិតធ្យូង និងអុស ។ ការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០០៣ បង្ហាញថាគ្រួសារ ៩៤% បានចូលរួមក្នុងសកម្មភាពទាញយកផលប្រយោជន៍ពីព្រៃឈើ ។ ការធ្វើស្រូវ និងដាំបន្លែផ្តល់ទិន្នផលទាប ជួនកាលបានតិចជាងមួយតោនក្នុងមួយហិកតា ដោយសារ ខ្វះប្រព័ន្ធស្រោចស្រព និងដីខ្សោះជីជាតិ ។ ជីវភាពអ្នកភូមិរងគ្រោះដោយសារការរេចរិលនៃធនធានធម្មជាតិ ហើយអ្នកភូមិភាគច្រើនជាប់ជំពាក់បំណុលគេ និងប្រឈមចំពោះការខ្វះស្បៀង ។

ចាប់តាំងពីការបើកសម្ពោធជាផ្លូវការនៃតំបន់ទេសចរណ៍ធម្មជាតិចំបក់នៅថ្ងៃទី ៤ ខែមករា ឆ្នាំ២០០៣ ផ្លូវលំធម្មជាតិ និងទិដ្ឋភាពទឹកធ្លាក់ដ៏ប្រណីតបានទាក់ទាញអ្នកទស្សនាប្រហែល ៨០០នាក់ ដោយក្នុងមួយខែផ្តល់ប្រាក់ចំណូល ៥០០-១០០០ ដុល្លា អាមេរិក រៀងរាល់ខែ។ ប្រាក់ចំណូលនេះមួយផ្នែកត្រូវបានចំណាយសម្រាប់អ្នកភូមិ ដែលធ្វើការក្នុងរមណីយដ្ឋាន ។ ប្រាក់ដែលនៅសល់ត្រូវបានរក្សាទុកក្នុងមូលនិធិសហគមន៍សម្រាប់ចំណាយពេលត្រូវការសំខាន់ៗ ដែលគណៈកម្មការបានលើកឡើង និងយល់ព្រមដោយអ្នកភូមិភាគច្រើន ។

ជាទូទៅ ខណៈពេលគម្រោងឈានទៅសម្រេចគោលបំណង អង្គការម្លប់បៃតងបានប្រឈមនឹងការលំបាកមួយចំនួនក្នុងការអនុវត្តសហគមន៍អេកូ-ទេសចរណ៍នៅចំបក់ ។ ការលំបាកធំបំផុតចំនួនពីរ គឺការធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងរម្មណីយដ្ឋាន ។ ប្រជាជនមួយចំនួនធំក្នុងសហគមន៍មិនសប្បាយចំពោះការដាក់កំហិតក្នុងតំបន់អេកូ-ទេសចរណ៍ ហើយចង់អោយមានភ្ញៀវទេសចរណ៍ចូលទស្សនាច្រើន ពីព្រោះពួកគាត់គិតថាប្រាក់ចំណូលនឹងកើនឡើង ។ ភ្ញៀវទេសចរណ៍កម្ពុជាជាច្រើនដែលមិនយល់ពីអេកូ-ទេសចរណ៍ បានគាំទ្រការប្រែក្លាយអោយទៅជា ទេសចរណ៍បែបពាណិជ្ជកម្ម ពីព្រោះអ្នកទេសចរណ៍ទាំងនោះត្អូញត្អែរអំពីការដើរឆ្ងាយ ឬ ការខ្វះធុងសំរាមជាដើម ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ អង្គការម្លប់បៃតងបានព្យាយាមបង្កើតទស្សនវិស័យរយៈពេលវែងក្នុងចំណោមសមាជិកគណៈកម្មការ និងអ្នកភូមិសំខាន់ៗផ្សេងទៀតតាមរយៈសិក្ខាសាលា ។

ក្រៅពីនេះមានការចាត់ចែងសមាជិកគណៈកម្មការធ្វើទស្សនកិច្ចសិក្សានៅប្រទេសថៃ ដើម្បីឱ្យបានឃើញពីភាពខុសគ្នារវាង រមណីយដ្ឋានទេសចរណ៍បែបពាណិជ្ជកម្ម ដែលវប្បធម៌ក្នុងស្រុក និងបរិស្ថានត្រូវបានទទួលរងនូវផលប៉ះពាល់ពីសំណាក់ភ្ញៀវទេសចរណ៍ ។

បញ្ហាមួយផ្សេងទៀតគឺការបែងចែកអត្ថប្រយោជន៍ឱ្យមានសមធម៌ ។ ទោះបីការអនុម័តតម្រូវឱ្យឯកភាពពីអ្នកភូមិទាំងអស់ក្នុងការចំណាយប្រាក់បានពីចំណូលទៅក្នុងមូលនិធិសហគមន៍ក្តី ក្នុងការអនុវត្តជាក់ស្តែង មានតែសមាជិកគណៈកម្មការចំនួន១២រូបតែប៉ុណ្ណោះ ដែលជាអ្នកធ្វើសេចក្តីសម្រេចលើប្រាក់បៀវត្សរ៍ និងការចំណាយផ្សេងៗ ។ ពួកគេក៏ជាអ្នកត្រួតពិនិត្យព័ត៌មានសម្រាប់ផ្សព្វផ្សាយដល់អ្នកភូមិផងដែរ ។ ដើម្បីដោះស្រាយបញ្ហានេះ អង្គការម្លប់បៃតងកំពុងជម្រុញក្រុមប្រឹក្សាឃុំ-សង្កាត់ឱ្យដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងចាត់ចែងគម្រោង ។ ទោះជា មានការលំបាកទាំងនេះក៏ដោយសហគមន៍អេកូ-ទេសចរណ៍ ចំបក់បានទទួលលទ្ធផលល្អមួយចំនួន ដូចជាការដាំដើមឈើឡើងវិញ ធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ព្រមទាំងបង្កើនមោទនភាព និងការលើកទឹកចិត្តក្នុងចំណោមអ្នកភូមិ ។ គម្រោងនេះមានសក្តានុពលភាពយ៉ាងល្អសម្រាប់ការពង្រីកសាមគ្គីភាពក្នុងសហគមន៍ធ្វើឱ្យជីវភាពប្រជាពលរដ្ឋប្រសើរឡើង ការពារធនធានធម្មជាតិ និងកាត់បន្ថយភាពក្រីក្រដោយសមធម៌ និងប្រកបដោយនិរន្តរភាព ។

## មេរៀនដែលទទួលបានពីករណីសិក្សា

ផ្នែកនេះបង្ហាញអំពីទិដ្ឋភាពទូទៅនៃបទពិសោធន៍បានពីករណីសិក្សាទាំងពីរ ។

◇ ភាពជាដៃគូដ៏ល្អជាមួយអាជ្ញាធរដែនដីគឺជាការចាំបាច់ ។ ឆ្លងតាមបទពិសោធន៍ករណីសិក្សានៅសហគមន៍ចំបក់ ក្រុមប្រឹក្សាឃុំមានតួនាទីសំខាន់ក្នុងការធានាសុវត្ថិភាពតំបន់ ព្រមទាំងទំនុកចិត្ត និងតម្លាភាព ក្នុងការអនុវត្តគម្រោង ។

◇ ការកាន់កាប់ដីធ្លី និងធនធានរបស់សហគមន៍ជាប្រការសំខាន់ទាក់ទងនឹងការវិនិយោគទុន ។ ទេសចរណ៍និងប្រាក់ចំណូលដែលទទួលបានអាចបង្កើនការគាបសង្កត់លើដីធ្លី ។ អ្នកមកពីក្រៅ អាចនឹងមកកាន់កាប់ដីដែលសហគមន៍ពុំមានប័ណ្ណកាន់កាប់ដីជាផ្លូវការ ឬសមាជិកសហគមន៍អាចព្យាយាមលក់ដីឱ្យអ្នកមកពីខាងក្រៅ ដូចជាករណីនៅបឹងយក្សឡោម ។ ដើម្បីធានាការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍ឱ្យបានជោគជ័យ ប្រការសំខាន់គឺត្រូវធ្វើឱ្យប្រាកដថា មានការកាន់កាប់ដីច្បាស់លាស់ហើយសហគមន៍យល់ដឹងពីផលវិបាកនៃការលក់ដីរបស់ពួកគាត់ ។

◇ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុបានល្អ និងបញ្ហាតម្លាភាព ព្រមទាំងទំនុកចិត្តគឺជាកត្តាគន្លឹះក្នុងភាពជោគជ័យនៃគម្រោង ។ បញ្ហាគ្រប់គ្រងហិរញ្ញវត្ថុមិនបានល្អអាចបំផ្លាញការទុកចិត្តគ្នា និងសាមគ្គីភាពក្នុងសហគមន៍ ។ ដើម្បីចៀសវាងបញ្ហាទាំងនេះ ជាចាំបាច់ត្រូវបង្កើត ជំនាញប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឱ្យបានល្អ ។

◇ ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍអេកូ-ទេសចរណ៍ ។ តាមរយៈបទពិសោធន៍នៅបឹងយក្សឡោម និងចំបក់បានបង្ហាញថាស្ត្រីមានជំនាញពិតប្រាកដ និងការចាប់អារម្មណ៍ច្រើនក្នុងការចូលរួមក្នុងអេកូ-ទេសចរណ៍ ។ ដូច្នេះស្ត្រីត្រូវតែចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំគម្រោង ។

◇ សាមគ្គីភាពក្នុងសហគមន៍ លើកទឹកចិត្តអោយមានការចូលរួមពីប្រជាជនក្នុងស្រុកក្នុងការអភិរក្សធនធានធម្មជាតិ និងសកម្មភាពគ្រប់គ្រងគម្រោងអេកូ-ទេសចរណ៍ ។ ក្នុងករណីមានការមិនចុះសម្រុងគ្នាក្នុងសហគមន៍ ការខិតខំប្រឹងប្រែងគួរធ្វើឡើងដើម្បីកសាងទំនុកចិត្ត និងសាមគ្គីភាព ។

◇ អេកូ-ទេសចរណ៍ ដែលមានការគ្រប់គ្រងបានល្អអាចទទួលផលជាវិជ្ជមាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ លើកកម្ពស់ជីវភាពនៅជនបទ និងសន្តិសុខស្បៀង ។

## បណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជា CCBEN

## ប្រវត្តិ និងគោលបំណង

បណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជា (CCBEN) បានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២០០២។ CCBEN គឺជាបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល គម្រោងវិទ្យាស្ថានអប់រំ និងសហគមន៍ក្នុងប្រទេសកម្ពុជា ដែលពាក់ព័ន្ធក្នុងការងារសហគមន៍អេកូ-ទេសចរណ៍ ។ CCBEN មានគោលបំណងបង្កើតភាពជាដៃគូជាមួយរដ្ឋាភិបាលក្នុងការព្យាយាមគាំទ្រសហគមន៍អេកូ-ទេសចរណ៍ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងការកាត់បន្ថយភាពក្រីក្រ និងការពារបរិស្ថាន វប្បធម៌ និង ធនធានសង្គមផងដែរ (សូមអានប្រអប់ទី១ ។

**ប្រអប់ទី១ : គោលបំណងរបស់បណ្តាញសហគមន៍ទេសចរណ៍ធម្មជាតិកម្ពុជា CCBEN**

១. លើកកំពស់កម្រិតយល់ដឹង ជំនាញរបស់សមាជិកបណ្តាញដែលពាក់ព័ន្ធ ដើម្បីធ្វើអោយសម្រេចនូវទស្សនវិស័យរបស់ CCBEN

២. ចែករំលែកបទពិសោធន៍ព័ត៌មាន និងធនធានឱ្យមានប្រសិទ្ធភាពរវាងសមាជិក CCBEN និងសហគមន៍មូលដ្ឋាន ដើម្បីឆ្ពោះទៅសម្រេចទស្សនវិស័យ បេសកកម្ម និងគោលបំណងរបស់ CCBEN ។

៣. បង្កើនការយល់ដឹង និងតស៊ូមតិស្តីអំពីតួនាទីសហគមន៍ទេសចរណ៍នៅក្នុងការអភិវឌ្ឍសហគមន៍ កាត់បន្ថយភាពក្រីក្រ និងការអភិរក្សធនធាន ។

៤. រៀបចំគោលការណ៍ណែនាំ និងមាគ៌ាអនុវត្តដែលកំណត់អំពីរាល់សកម្មភាព សំដៅឆ្ពោះទៅសម្រេចទស្សនវិស័យ របស់ CCBEN ។

៥. បង្កើតចំណងទាក់ទងរឹងមាំ និងប្រកបដោយផ្លែផ្កាជាមួយនឹងបណ្តាញសហគមន៍ដទៃផ្សេងទៀតដែលមានទស្សនវិស័យ បេសកកម្ម និងគោលបំណងប្រហាក់ប្រហែលគ្នា ។

## សកម្មភាពរបស់បណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជា

បណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជាកំពុងធ្វើការឆ្ពោះទៅរកគោលដៅរបស់ខ្លួន ក្នុងកិច្ចសហការជាមួយរដ្ឋាភិបាល និងស្ថាប័នដែលពាក់ព័ន្ធជាមួយសហគមន៍អេកូ-ទេសចរណ៍នៅក្នុងប្រទេសកម្ពុជា ដោយធ្វើការកសាងសមត្ថភាពសមាជិករបស់ខ្លួន និងបុគ្គលិករដ្ឋាភិបាល និងបង្កើនការយល់ដឹងដល់សហគមន៍មូលដ្ឋាន អំពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ បទពិសោធន៍នានា ដែលទទួលបានតាមរយៈការធ្វើទស្សនកិច្ចសិក្សាពីសំណាក់សមាជិកនៃបណ្តាញ ការងារនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ និងតាមរយៈការចែករំលែកព័ត៌មានក្នុងចំណោមសមាជិកនៅពេលមានកិច្ចប្រជុំពិភាក្សាអំពីកម្មវិធី និងផែនការសកម្មភាព ។ ភ្ញៀវពិសេស១ និងគ្រូបណ្តុះបណ្តាលត្រូវបានអញ្ជើញឱ្យចូលរួម ដើម្បីចែករំលែកចំណេះដឹង និងជំនាញជាមួយសមាជិកបណ្តាញការងារ ។ ក្នុងនោះក៏មានវគ្គបណ្តុះបណ្តាលមួយអំពី "សកម្មភាព និងការចូលរួមកសាងផែនការដោយការស្រុះស្រួល" (APPA) ផងដែរ ។

ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលក៏ដូចជាផ្នែកឯកជន និងដើម្បីឱ្យមានការទទួលស្គាល់តាមផ្លូវច្បាប់ ជាសមាគមមួយក្នុងការគាំទ្រការអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិក្នុងប្រទេសកម្ពុជា សមាជិកបណ្តាញមានបំណងចាត់ចែងស្នើសុំ

រដ្ឋាភិបាលចុះឈ្មោះ និងទទួលស្គាល់បណ្ដាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជាជាផ្លូវការ ។ ដើម្បីគាំទ្រគំនិតផ្ដួចផ្ដើមនេះ លក្ខន្តិកៈរបស់បណ្ដាញដែលមានចែងអំពីរចនាសម្ព័ន្ធ និងអភិបាលកិច្ចត្រូវបានរៀបចំរួចជាស្រេច ។ បណ្ដាញសហគមន៍ អេកូ-ទេសចរណ៍កម្ពុជាបានបង្កើតគេហទំព័រដើម្បីផ្សព្វផ្សាយអំពីសហគមន៍អេកូ-ទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាសយដ្ឋាន www.geocities.com\cambodiacben ។

## ការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍ទៅអនាគត

ការអនុវត្តសហគមន៍អេកូ-ទេសចរណ៍នៅកម្ពុជានៅមានកំរិតនៅឡើយ ប៉ុន្តែការងារនេះមាន សក្ដានុពលក្នុងការរួមចំណែកអភិរក្សជីវៈចម្រុះ ដូចជាការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ជីវភាពរស់នាពេលអនាគត ។ ផ្នែកនេះបង្ហាញពីជំហានមួយចំនួន ក្នុងការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍នៅកម្ពុជា ។



Amanda Bradley/ ២០០៨

***ទស្សនកិច្ចសិក្សារបស់សមាជិក CCBEN ទៅកាន់តំបន់ទេរទឹកពុះក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ សហគមន៍ជនជាតិដើមភាគតិចសួយ មានបំណងរៀបចំតំបន់នេះទៅជាតំបន់ CBET ដោយមានការគាំទ្រដោយ (LWF)***

## ការផ្ដល់អនុសាសន៍លើគោលនយោបាយ

ដូចដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយ និងផែនការអភិវឌ្ឍន៍ ដែលយ៉ាងហោចណាស់តាមទ្រឹស្ដីបានគាំទ្រដល់គំនិតផ្ដួចផ្ដើមក្នុងការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍ផងដែរ ។ អង្គការ ម្ចាស់ជំនួយអន្តរជាតិ ដូចជាធនាគារពិភពលោក កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី បានផ្ដោតជាសំខាន់ លើការកាត់បន្ថយភាពក្រីក្រ ដំណើរការវិមជ្ឈការ និងការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងផ្ដួចផ្ដើមដូចជាគម្រោងអភិវឌ្ឍន៍ទេសចរណ៍មហាអនុតំបន់ទន្លេមេគង្គ ។ ការផ្ដួចផ្ដើម និងការវិនិយោគលើសហគមន៍អេកូ-ទេសចរណ៍បែបនេះនៅមានកម្រិតទាបនៅឡើយ បើប្រៀបធៀបនឹងចំនួនទឹកប្រាក់សរុបដ៏ច្រើនសន្ធឹកសន្ធាប់នៃវិស័យឯកជនដែលបានវិនិយោគ ។

ច្បាប់ និងគោលនយោបាយអាចមានប្រសិទ្ធភាពនៅក្នុងកំរិតសហគមន៍មូលដ្ឋាន ប៉ុន្តែនយោបាយក្នុងការអនុវត្តគោលនយោបាយទាំងនោះរឹតតែសំខាន់ទៅទៀត ។ ដើម្បីឱ្យសហគមន៍អេកូ-ទេសចរណ៍រួមវិភាគទានយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រជាតិ

សម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា ជាដំបូងត្រូវបង្កើតច្បាប់ និងគោលនយោបាយសម្រាប់គាំទ្រដល់ការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍ ។ ទីពីរត្រូវបង្កើតផែនការសកម្មភាពសម្រាប់អនុវត្ត ។ ដោយសារសហគមន៍ អេកូ-ទេសចរណ៍ពាក់ព័ន្ធនឹងវិស័យ និងស្ថាប័នច្រើន ផែនការខាងលើគួរតម្រូវអោយមានកិច្ចសហប្រតិបត្តិការពីស្ថាប័ន រដ្ឋាភិបាល ដូចជាក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក រដ្ឋបាលព្រៃឈើ ក្រសួង ពាណិជ្ជកម្ម និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈផងដែរ ។ ក្រុមចម្រុះស្ថាប័នដែលមានសមាជិកពីក្រសួងនីមួយៗ ហើយដែលមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល អាចជាអ្នកដឹកនាំ និងផ្សព្វផ្សាយសហគមន៍អេកូ-ទេសចរណ៍តាមរយៈយន្តការទីផ្សារ និងគោលនយោបាយ វិនិយោគ-ទុន សិទ្ធិកាន់កាប់ដីធ្លី ច្បាប់គ្រប់គ្រងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីសម្រួលដល់ការ ចេញចូលងាយស្រួល ហើយនិងការអភិវឌ្ឍធនធានមនុស្ស ។ ចំណុចទាំងនេះគឺជាបញ្ហាប្រឈមយ៉ាងសំខាន់ និងដែលគួរទទួលការពិចារណាដោយយកចិត្តទុកដាក់ ។

## សុវត្ថិភាពផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស

បច្ចុប្បន្ននេះសហគមន៍អេកូ-ទេសចរណ៍ បានផ្តួចផ្តើមបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលជាមួយធនធាន និងហិរញ្ញវត្ថុនៅមានកម្រិត។ ជាសំណាងល្អ ការរៀបចំសហគមន៍អេកូ-ទេសចរណ៍ ពុំត្រូវការវិនិយោគទុនច្រើននោះទេដោយសារតែសហគមន៍អេកូ-ទេសចរណ៍អាចប្រើប្រាស់ធនធានដែលមានស្រាប់សម្រាប់ជាដើមទុនទេសចរណ៍របស់ខ្លួន ។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនអាចផ្តល់ការសម្របសម្រួលគ្រប់គ្រាន់ក្នុងការគាំទ្រ ការចូលរួមរបស់សហគមន៍ ប៉ុន្តែការយល់ដឹងពីទស្សនៈសហគមន៍អេកូ-ទេសចរណ៍នៅមានកម្រិតនៅឡើយក្នុងចំណោមអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានខ្លួនឯង។ ដើម្បីគាំទ្រការអភិវឌ្ឍ សហគមន៍អេកូ-ទេសចរណ៍ ប្រការចាំបាច់គឺត្រូវធ្វើការវាយតម្លៃធនធាន និងសមត្ថភាពដែលមានស្រាប់ហើយដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ ដូចជាជំនាញគ្រប់គ្រងធ្វើអាជីវកម្ម គណនេយ្យ ការគ្រប់គ្រងធនធាន ធម្មជាតិ ដោះស្រាយទំនាស់ ការបង្កើតតំរិយាបទប្រកបដោយភាពច្នៃប្រឌិត ។ បណ្តាញសហគមន៍អេកូ-ទេសចរណ៍កម្ពុជាមានគោល-បំណងបណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពសម្រាប់អ្នកសម្របសម្រួល ។ ប្រសិនមានការផ្តល់មូលនិធិគាំទ្រ ការខិតខំប្រឹងប្រែងបន្ថែមទៀត ត្រូវផ្តោតលើការពង្រឹងការយល់ដឹង និងជំនាញពាក់ព័ន្ធសហគមន៍អេកូ-ទេសចរណ៍។ កម្មវិធីបណ្តុះបណ្តាលនេះគួរផ្តល់សម្រាប់បុគ្គលិក មន្ត្រីរដ្ឋាភិបាល ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានក៏ដូចជាសហគមន៍ផងដែរ ។

## ការរៀបចំ និងការធ្វើអោយប្រសើរឡើងនូវភាពជាដៃគូ

គំនិតផ្តួចផ្តើមសហគមន៍អេកូ-ទេសចរណ៍អាចទទួលជោគជ័យ ទាមទារអោយមានភាពជាដៃគូរឹងមាំដែលគាំទ្រសហគមន៍ក្នុងការខិតខំអភិរក្សធនធាន និងលើកកំពស់ជីវភាពរស់នៅយូរអង្វែង ។ ដើម្បីគាំទ្រដល់ការគ្រប់គ្រងធនធានធម្ម-ជាតិនៅមូលដ្ឋានទាមទារឱ្យមានការចូលរួមសហប្រតិបត្តិការគ្នា ចាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់រហូតដល់ស្ថាប័នជាតិ។ ក្នុងករណី

អាចធ្វើបានរាល់កិច្ចផ្តួចផ្តើមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ដូចជាការកសាងផែនការប្រើប្រាស់ដីធ្លី សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ ត្រូវមានចំណងទាក់ទងជាមួយសហគមន៍អេកូ-ទេសចរណ៍នៅក្នុងក្របខ័ណ្ឌទូលំទូលាយមួយក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ។

ភាពជាដៃគូបែបយុទ្ធសាស្ត្ររវាងសមាគមទេសចរណ៍ និងជាពិសេសវិស័យឯកជនត្រូវតែបានបង្កើតឡើង។ ការទាក់ទាញទេសចរណ៍ដែលមានទំនោរទៅរកវប្បធម៌ក្នុងស្រុក និងការអភិរក្សធម្មជាតិតម្រូវឱ្យមានចំណងទាក់ទងជាមួយឧស្សាហកម្មទេសចរណ៍ និងទីផ្សារ ។

## ការស្រាវជ្រាវ និង ការចែករំលែកព័ត៌មាន

ការធ្វើឱ្យប្រសើរនៅអនាគតនៃការអនុវត្តសហគមន៍អេកូ-ទេសចរណ៍ អាស្រ័យលើការស្រាវជ្រាវ និងការចែកចាយព័ត៌មានក្នុងចំណោមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរដ្ឋាភិបាល។ បណ្តាញសហគមន៍អេកូ-ទេសចរណ៍ (CCBEN) ត្រូវបានបង្កើតឡើងជាវេទិកាសម្រាប់ផ្លាស់ប្តូរព័ត៌មានតាមរយៈការបង្កើតបណ្ណាល័យ ធនធានឯកសារ ការបង្កើតគោលការណ៍ជាតិ ការពង្រីកផ្សព្វផ្សាយរេបសាយ និងការពង្រីកសម្ភារៈពាក់ព័ន្ធអំពីអេកូ-ទេសចរណ៍ ។ មិនតែប៉ុណ្ណោះបណ្តាញសហគមន៍មានគោលបំណងបង្កើតទំនាក់ទំនងជាមួយក្រុមដៃគូនានាក្នុងតំបន់ ។ ករណីសិក្សា ការវាយតម្លៃគម្រោង ការសិក្សាស្រាវជ្រាវ និងឯកសារស្រាវជ្រាវធនធានស្តីអំពីបទពិសោធ៍សហគមន៍អេកូ-ទេសចរណ៍មានសារៈសំខាន់បង្កើតទ្រឹស្តី ផ្តល់ជាមេរៀន និងធ្វើឱ្យប្រសើរឡើងដល់ការអភិវឌ្ឍសហគមន៍អេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា។

## សេចក្តីសន្និដ្ឋាន

ជំពូកនេះបានបកស្រាយពីទស្សនទាន និងនិយមន័យសហគមន៍ទេសចរណ៍ធម្មជាតិ នៅក្នុងបរិបទធនធានធម្មជាតិនៃប្រទេសកម្ពុជា និងឧស្សាហកម្មទេសចរណ៍ដែលមានកំណើនយ៉ាងឆាប់រហ័ស។ ជំពូកនេះបានលើកបង្ហាញឧទាហរណ៍ជាក់ស្តែងអំពីគំនិតផ្តួចផ្តើមនៃការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិ ហើយបានស្នើឱ្យមានវិធីសាស្ត្រគាំទ្រតាមរយៈការបង្កើតគោលនយោបាយក្របខ័ណ្ឌច្បាប់ កិច្ចសហការជាមួយដៃគូពាក់ព័ន្ធ ការកសាងបណ្តាញ ការកសាងសមត្ថភាព ការស្រាវជ្រាវ និងចែករំលែកព័ត៌មាន។ ដោយសារសហគមន៍ទេសចរណ៍ធម្មជាតិជាទស្សនទានថ្មីនៅប្រទេសកម្ពុជា អ្នកអនុវត្តន៍គួរសិក្សាស្វែងយល់អំពីបទពិសោធន៍ សហគមន៍នៅក្នុងវិស័យមួយចំនួនដូចជា ព្រៃឈើ កសិកម្ម និងនេសាទ។

គួរចាត់ចែងឱ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីទស្សនទានសហគមន៍អេកូ-ទេសចរណ៍ សម្រាប់ជាយុទ្ធសាស្ត្របង្កើនការចិញ្ចឹមជីវិតប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ និងជាវិធីសាស្ត្រនៃការអភិរក្សធនធានធម្មជាតិ។ គួរចាត់ទុកថា សហគមន៍អេកូ-ទេសចរណ៍ ជាសក្តានុពលមួយក្នុងការជួយអោយសហគមន៍គ្រប់គ្រងធនធានរបស់គេបានល្អប្រសើរឡើង។ ការប្រើប្រាស់សហគមន៍អេកូ-ទេសចរណ៍ ជាយុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន តម្រូវឱ្យមានសាមគ្គីភាពនៅក្នុងសហគមន៍ ការប្តេជ្ញាយូរអង្វែងរបស់អង្គការម្ចាស់ជំនួយ និងអ្នកសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាលក៏ដូចជាការគាំទ្រគោលនយោបាយ និងក្របខ័ណ្ឌច្បាប់។ ប្រការសំខាន់ដែរនោះគឺត្រូវអភិរក្សធនធានធម្មជាតិ ដែលជាមូលដ្ឋានសម្រាប់សហគមន៍អេកូ-ទេសចរណ៍ និងត្រូវទទួលស្គាល់សិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងធនធានអោយមាននិរន្តរភាព។

## REFERENCES


Bradley, A. 2004. *Community Based Eco-Tourism in Cambodia: A case Study in Chambok Commune, Kompong Speu, Mlup Baitong, Cambodia.*

Inwent. 2003. *Training Manual for Community-based Tourism.* Authors: Nicole Háausler & Wolfgang Strasdas.

Ngece, K. 2002. *East African Eco-tourism Development and Conservation Consultants, Nairobi.*

Ministry of Tourism. 2003. *Annual Tourism Statistic Report. Phnom Penh, Cambodia.*

Ministry of Tourism. 2003.*National Tourism Development Plan 2003. Phnom Penh, Cambodia.*

Ministry of Planning. 2001. *Socio-Economic Development Plan 2001-2005.*Phnom Penh, Cambodia.

Schellhorn, M and Simmons, D. 2003. *Developing Wildlife Tourism in the Dry Forest Ecoregion of Northeastern Cambodia.* Feasibility Assessment Prepared for WWF-Cambodia Conservation Programme by Lincoln International (1995) Ltd. Phnom Penh: WWF.

WWF International. 2001.*Guidelines for Community Based Eco-Tourism Development.* Prepared by: Dr. R. Denman, The Tourism Campany, Ledbury/UK.

Yin, S. 2003. *Potential and Challenges for Community Based Eco-Tourism, a case study of Yeak Laom Community Based Eco*-tourism. Royal University of Phnom Penh.

Huy, V. 2004. *A Case Study: “Community Based Management of Eco-Tourism Project in Chambok Cammune, Kampong Speu Province”.* Norton University of Cambodia.

# ជំពូក ៩ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនៅប្រទេសកម្ពុជា

រៀបរៀងដោយ លោក មិន ប៊ុណ្ណារ៉ា[១] លោកបណ្ឌិត Harald Kirsch[២] និងលោក Ignas Dümmer[៣ និង៤]

## សេចក្តីផ្តើម

អត្ថបទនេះពិភាក្សាពីវិធីសាស្ត្រ និងបទពិសោធន៍នៃការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (Participatory Land Use Planning - PLUP) និងទំនាក់ទំនងជាមួយការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management - CBNRM) ។

PLUPគឺជាបទពិសោធន៍ថ្មីមួយនៅក្នុងប្រទេសកម្ពុជា ។ អង្គការអាល្លឺម៉ង់ GTZ និងស្ថាប័នរដ្ឋាភិបាលមួយចំនួនបានរៀបចំសិក្ខាសាលាជាច្រើនលើកនៅក្នុងកំឡុងឆ្នាំ ១៩៩៩ និង ២០០១ ។ សៀវភៅជំនួយស្មារតីពីការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) សម្រាប់ប្រទេសកម្ពុជាត្រូវបានរៀបរៀងឡើងជាផ្លូវការនៅឆ្នាំ ២០០២ ។ វគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP-ToT) ត្រូវបានរៀបចំឡើងនៅខែកុម្ភៈ ឆ្នាំ២០០២ នៅឯនាយកដ្ឋានគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ នាទីក្រុងភ្នំពេញ ។ វគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់សម្រាប់អ្នកសម្របសម្រួលថ្នាក់ខេត្ត (TPF) ត្រូវបានរៀបចំឡើងដោយគ្រូបង្គោលថ្នាក់ជាតិនៅតាមខេត្តក្រុងជាច្រើនក្នុងប្រទេសកម្ពុជា ។ គ្រូបង្គោលថ្នាក់ជាតិ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី បានសហការជាមួយទីប្រឹក្សាពីររូបមកពីអង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (DED) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត ។

## ប្រវត្តិដើម

ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងឡាយនៃការរេចរិលធនធានធម្មជាតិ និងទំនាស់ដីធ្លីដែលជះឥទ្ធិពល ទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ និងធនធានដទៃទៀតនៅក្នុងប្រទេសទាំងមូល ការប្រតិបត្តិ នូវវិធីសាស្ត្រថ្មីនៃការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី គឺជាកត្តាចាំបាច់ដែលបានផ្តោតទៅលើការអភិវឌ្ឍដ៏យូរអង្វែង ដើម្បីរៀបចំផែនការចម្រុះ ។ សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពី គោលនយោបាយដីធ្លី (ខែឧសភា ឆ្នាំ២០០១ និងក្របខ័ណ្ឌ យុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី (បច្ចុប្បន្នកំពុងរៀបចំ បានផ្តល់ជាមតិយោបល់ដល់អ្នកធ្វើផែនការប្រើប្រាស់ដីធ្លីតាមជនបទ : ពីប្រការចាំបាច់ក្នុងការរៀបចំអភិវឌ្ឍសម្រាប់តំបន់អាទិភាពដូចជា : (តំបន់ទេសចរណ៍ និងតំបន់វិនិយោគ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ

---

[១] បច្ចុប្បន្ន លោក មិន ប៊ុណ្ណារ៉ា គឺជាមន្ត្រីសម្របសម្រួលគម្រោងគ្រប់គ្រងទីជម្រាលនៃកម្មវិធី AIFP ដែលមានទីតាំងក្នុងរដ្ឋបាលព្រៃឈើ ។ ពីមុនគាត់គឺជាអ្នកសម្របសម្រួលគម្រោង MRC/GTZ-SMRP និងគម្រោងព្រៃឈើកម្ពុជាអាល្លឺម៉ង់ (GTZ-CGFP) ។

[២] លោកHaral គឺជាអ្នកគាំទ្រសកម្មភាពផ្តត់ផ្គង់ សម្របសម្រួល និងរៀបចំរួមគ្នា ស្តីពី ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) ក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ។

[៣] បច្ចុប្បន្ន លោក Ignas គឺជាទីប្រឹក្សាបច្ចេកទេស NREM សម្រាប់លេខាធិការដ្ឋាននៃក្រុមចំរុះក្នុងកម្មវិធីសិលា (ដែលទទួលមូលនិធិពីអង្គការ Danida ។ ពីមុនគាត់ធ្វើការជាមួយអង្គការសេវាកម្មអភិវឌ្ឍន៍អាឡឺម៉ង់ (DED) និងមានការិយាល័យនៅនាយកដ្ឋាន ព្រៃឈើនិងសត្វព្រៃ ក្នុងនាមជាអ្នកសម្របសម្រួល PLUP និងសហគមន៍ព្រៃឈើ ។

[៤] ការរួមចំណែកពីក្រុមបណ្តុះបណ្តាល PLUP និង លោក ប្រាក់អង្គារ៉ា ដែលជាជនបង្គោលខាងផ្នែក PLUP នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រកបដោយនិរន្តរភាព ។ នៅពេលជាមួយគ្នានោះដែរ អាជ្ញាធរជាតិគ្រប់គ្រងផែនការដីធ្លីដែលមានសិទ្ធិអំណាចនយោបាយដើម្បីគ្រប់គ្រងសកម្មភាពដីធ្លីគ្រប់ប្រភេទ នោះត្រូវបានធ្វើវិមជ្ឈការដល់អាជ្ញាធរខេត្ត និងមូលដ្ឋានដែលស្របទៅតាមគោលនយោបាយរបស់រដ្ឋាភិបាលបច្ចុប្បន្ន។

## តើការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) ជាអ្វី?

PLUP គឺជាឧបករណ៍ ឬវិធីសាស្ត្រដ៏ទំនើបមួយសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅតាមជនបទ ។ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីបានផ្តោតជាសំខាន់ទៅលើការបង្កើនសមត្ថភាព និងឆ្លើយតបទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់និងការបែងចែកដីធ្លីតាមជនបទដើម្បីការពារធនធានទាំងឡាយរួមមាន ព្រៃឈើ ដីកសិកម្ម និងផ្ទៃទឹក។ PLUP គឺជាអន្តរអំពើរវាងកត្តា សេដ្ឋកិច្ច-សង្គម ជីវរូបសាស្ត្រ ព្រៃឈើ ដីកសិកម្ម និងផ្ទៃទឹក ហើយ PLUP ក៏បានរួមបញ្ចូលផងដែរនូវកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធទាំងអស់ដែលជាល័ក្ខខ័ណ្ឌកំណត់មួយ ដើម្បីឈានទៅដល់ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ។

## ទស្សនទាននៃការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី

PLUP គឺជាដំណើរការរៀបចំផែនការចាប់ផ្តើមពីថ្នាក់ភូមិដែលមានអ្នកភូមិព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ រួមគ្នាធ្វើផែនការស្តីពីការប្រើប្រាស់ ការការពារ និងការបែងចែកដីធ្លី និងផ្ទៃទឹកនៅក្នុងភូមិរបស់ពួកគាត់ ។ តាមរយៈការអនុវត្តដំណើរការនេះ ពួកគាត់ទទួលបានការជួយណែនាំពីសំណាក់អ្នកសម្របសម្រួលអព្យាក្រឹតមកពីខាងក្រៅ ។

PLUP នឹងត្រូវពង្រីកបន្ថែមទៀត ដើម្បីគ្របដណ្តប់រាល់ប្រភេទដីធ្លី និងផ្ទៃទឹក ដូចជា: ដីកសិកម្ម តំបន់ព្រៃឈើ តំបន់តាំងទីលំនៅ ស្រះចិញ្ចឹមត្រី បឹង និងតំបន់ដែលមានធនធានរ៉ែ ។ល។ PLUP នឹងជួយអ្នកភូមិ ក្នុងការធ្វើកិច្ចសហការជាមួយស្ថាប័នរដ្ឋាភិបាល ហើយ PLUP ក៏អាចជួយអ្នកភូមិផងដែរ ដើម្បីកំណត់ឱ្យច្បាស់លាស់ថា: តើពួកគាត់អាចប្រើប្រាស់ ឬការពារតំបន់នីមួយៗទាំងនោះទៅពេលអនាគតយ៉ាងដូចម្តេច ។

### វិធីសាស្ត្រទូទៅរបស់ PLUP

- កំណត់ជម្រើសផ្សេងៗ នៃការប្រើប្រាស់ដីធ្លីដែលអាចទទួលយកបានពីអ្នកពាក់ព័ន្ធទាំងអស់។
- ពង្រឹងសមត្ថភាពរបស់ពួកគេ ដើម្បីគ្រប់គ្រងធនធានទាំងអស់នោះប្រកបដោយនិរន្តរភាព។
- បង្កើតក្របខ័ណ្ឌការងារមួយដែលសង្គមអាចទទួលស្គាល់ អាចទទួលយកបានពីមជ្ឈដ្ឋានជុំវិញ ដែលស្របទៅនឹងគោលនយោបាយ និងធ្វើឱ្យសេដ្ឋកិច្ចមានការលូតលាស់។
- ជំនះទៅលើទំលាប់របស់ស្ថាប័នរដ្ឋ និងមន្ត្រីរាជការមួយចំនួន តាមរយៈការត្រិះរិះពិចារណាក្នុងផ្នែកនីមួយៗ ។
- បង្កើន ឬ ប្រើប្រាស់រចនាសម្ព័ន្ធឃុំ ភូមិ និងគណៈកម្មការដែលមានស្រាប់ ដើម្បីរៀបចំដំណើរការនានានៃការចូលរួម ។

នៅក្នុងដំណើរការនេះ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងត្រូវបានបញ្ជាក់ច្បាស់លាស់ និងបានសម្រេចថា : តើអ្នកណាជាអ្នកមានសិទ្ធិប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិយ៉ាងណានោះ ។ PLUP នឹងជួយកំណត់អោយបានច្បាស់នូវតំបន់ដែលគ្មានការប្រើប្រាស់មួយចំនួន ដែលអាចផ្តល់លទ្ធភាពដ៏សមស្រប សម្រាប់ផលិតផលកសិកម្ម ហើយអាចបែងចែកតំបន់ នេះទៅឱ្យគ្រួសារក្រីក្រ និងគ្រួសារដែលគ្មានដីនៅក្នុងភូមិ ។ អ្នកភូមិទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យរៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទប្បញ្ញត្តិសម្រាប់សហគមន៍មូលដ្ឋាន ផ្អែកលើច្បាប់ និងអនុក្រឹត្យដែលពាក់ព័ន្ធ ហើយព្រមទាំងរៀបចំផែនការគ្រប់គ្រងលំអិតសម្រាប់តំបន់សហគមន៍ព្រៃឈើ ឬសហគមន៍នេសាទដែលមាននៅក្នុងតំបន់ទាំងនោះ ។

### PLUP និង CBNRM

CBNRM មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ PLUP ដោយសារតែវិធីសាស្រ្តទាំងពីរនេះ មានការជាប់ពាក់ព័ន្ធដូចគ្នាទៅនឹង ធនធានធម្មជាតិទាំងអស់ ។ PLUP អាចចាត់ទុកជាឧបករណ៍ ឬវិធីសាស្រ្តដើម្បីសម្រេចអោយបាននូវ CBNRM ។

### តើអ្វីដែលជាគោលការណ៏របស់ PLUP ?

PLUP ចាប់ផ្តើម ពីថ្នាក់ភូមិ ហើយនឹងបន្តពង្រីកពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំមួយ និងស្រុកមួយ ។ ការរៀបចំធ្វើផែនការបែបពីក្រោមទៅលើ មានលក្ខណៈស្របគ្នាជាមួយនឹងគោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល ។

PLUP ត្រូវបានគ្របដណ្តប់លើដី និងធនធានធម្មជាតិគ្រប់ប្រភេទ ។

PLUP គឺជាដំណើរការនៃការចូលរួម និងផ្តោតលើការពង្រឹងក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងពង្រឹងសមត្ថភាពដល់ការគ្រប់គ្រងតាមមូលដ្ឋាន ។

អ្នកខាងក្រៅគឺជាអ្នកសម្របសម្រួល មានភាពអព្យាក្រឹតក្នុងការដោះស្រាយទំនាស់នានា និងជាអ្នកគាំទ្រទូទៅ ដល់ដំណើរការ PLUP ។

PLUP គួរតែបានរៀបចំអោយមានមូលដ្ឋានច្បាស់លាស់សម្រាប់ជាគោលការណ៏ដើម្បីរៀបចំ កំណត់ បែងចែកដីធ្លីដោយក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។



ប្រភពរូបភាព PLUP 2004

| | **CBNRM** | **PLUP** |
|---|---|---|
| **ចំណុចសំខាន់ៗដែលត្រូវចាប់អារម្មណ៍** | ពង្រឹងសមត្ថភាពនៃការគ្រប់គ្រងដើម្បីការពារនិងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។ | ជាដំណើរការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លី ការកំណត់សិទ្ធិកាន់កាប់ដីធ្លីសម្រាប់ពេលអនាគត និងការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។ |
| **វិសាលភាព** | ជាការប្រើប្រាស់ធនធានសាធារណៈដោយចំហ ហើយការប្រើប្រាស់ទាំងនោះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍ ( មួយចំណែកជាព្រៃឈើ ជាដែននេសាទ ឬជាវាលស្មៅជាដើម ។ល ។ | មានវិសាលភាពធំធេង គ្រប់ប្រភេទដីធ្លីទាំងអស់ រួមមាន: ដីកសិកម្ម ដីលំនៅដ្ឋាន និងដីទាំងអស់ដែលមានកម្មសិទ្ធិច្បាស់លាស់ ។ |
| **ការពាក់ព័ន្ធរបស់ស្ថាប័ន ឧទា. មានតំណាងក្នុងក្រុមអ្នកសម្របសម្រួល** | មួយចំនួនធំគឺ ព្រៃឈើ ជលផល និងបរិស្ថាន | DLMUPC, PDAFF, DoE, និងអាចមាន PDRD, PDIME, DWRM, PDCT ។ល ។ |
| **អង្គការ និងស្ថាប័នសំខាន់ៗនៅថ្នាក់មូលដ្ឋាន** | គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ | គណៈកម្មការគ្រប់គ្រងធនធានធម្មជាតិឃុំ-សង្កាត់ ក្រុមប្រឹក្សា ឃុំ-សង្កាត់ និងគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ ។ |
| **ការធ្វើផែនទី** | ធនធានដែលជាកម្មសិទ្ធសាធារណៈ ជាពិសេសតំបន់ព្រៃឈើ ឬ ដែននេសាទដែលស្ថិតក្រោមការគ្រប់គ្រងដោយសហគមន៍ ត្រូវបានជ្រើសរើសដើម្បីរៀបចំធ្វើផែនទី ។ | ព្រំប្រទល់រដ្ឋបាល ការប្រើប្រាស់ដីធ្លីបច្ចុប្បន្ន និងទៅអនាគត ដីរដ្ឋ ដីឯកជន តំបន់សម្បទាននានា ឧបករណ៍ ដែលត្រូវប្រើប្រាស់ និងការរៀបចំធ្វើផែនទីតំបន់ទាំងមូល ។ |
| **ជំហាននៃការងារ** | ការវិភាគស្ថានភាព ការបោះឆ្នោតជ្រើសរើសគណៈកម្មការ ការធ្វើផែនទី ការរៀបចំបទបញ្ញត្តិ និងផែនការគ្រប់គ្រង ការរៀបចំផែនការសកម្មភាពដើម្បីគ្រប់គ្រងធនធានធម្មជាតិ ការអនុវត្ត ការត្រួតពិនិត្យ និងការប្រតិបត្តិ ។ | ជំហាន CBNRM ទាំងអស់រួមបន្ថែមប្រមាណ +២៥% ទៅលើបញ្ហាដីធ្លី ការគូសផែនទី និងរៀបចំផែនការសម្រាប់អនាគត ។ |

*តារាងទី ១ : ការប្រៀបធៀបទស្សនទានរវាង PLUP និង CBNRM*

## PLUP ក្នុងតំបន់ការពារធម្មជាតិ

នាយកដ្ឋានការពារអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន មានសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិ ។ ចាត់ចែងអោយមានការប្រើប្រាស់ PLUP ជាយន្តការកំណត់តំបន់គ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិទាំងអស់ ។ សេចក្តីព្រាងច្បាប់តំបន់ការពារធម្មជាតិ ( សូមអាន ជំពូក៣ បានបែងចែកតំបន់ការពារធម្មជាតិជាបួនតំបន់គ្រប់គ្រងតូចៗ គឺតំបន់ស្នូល តំបន់អភិរក្ស

តំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់សហគមន៍ ។ ការផ្តល់កម្មសិទ្ធិដីធ្លី ជាលក្ខណៈឯកជននៅក្នុងតំបន់ការពារធម្មជាតិត្រូវហាមឃាត់ដាច់ខាត ។

នេះមានន័យថា អ្នកភូមិមិនអាចពង្រីកភូមិ ឬពង្រីកតំបន់ប្រើប្រាស់របស់ខ្លួនបានឡើយ ហើយការប្រើប្រាស់ធនធានទៀតសោត ក៏ត្រូវតែស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង។ ទោះបីការការពារ មានសារៈសំខាន់យ៉ាងណាក្តី អ្នកភូមិទាំងអស់គួរត្រូវបានលើកទឹកចិត្ត ដើម្បីសហការគ្នាជាមួយបុគ្គលិកឧទ្យានលើផ្នែកការពារ និងគ្រប់គ្រង។ កិច្ចសហការត្រូវរួមបញ្ចូលផងដែរ អំពីការបែងចែកផលទេសចរណ៍ធម្មជាតិ ឬ ទេសចរណ៍ "សម្របសម្រួល" ដោយផ្តោតទៅលើការអភិរក្សជីវៈចម្រុះ វិធីប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយកំណើនប្រជាពលរដ្ឋ និងការតាំងទីលំនៅថ្មី ។

## PLUP នៅថ្នាក់ឃុំ-សង្កាត់

សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី (ខែឧសភា ឆ្នាំ២០០១ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី (បច្ចុប្បន្នកំពុងរៀបចំ បានស្នើឱ្យមានការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លីតាមតំបន់អាទិភាពមួយចំនួន (ដូចជា: តំបន់ទេសចរណ៍ និងតំបន់វិនិយោគ និងសំរាប់គ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព។ ទន្ទឹមនឹងនេះអាជ្ញាធរគ្រប់គ្រង និងរៀបចំផែនការដីធ្លី ចាំបាច់ត្រូវធ្វើវិមជ្ឈការដើម្បីផ្ទេរសមត្ថកិច្ចទៅឱ្យអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តស្របទៅតាមគោលនយោបាយអភិបាលកិច្ចរបស់រដ្ឋាភិបាល ដែលជម្រុញការអនុវត្តវិមជ្ឈការ និងសហវិមជ្ឈការ ។

## ហេតុអ្វីបានតម្រូវឱ្យមានការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី PLUP នៅថ្នាក់ឃុំ-សង្កាត់ ?

ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី PLUP រួមមាន: ការបញ្ជាក់ឱ្យច្បាស់នូវព្រំប្រទល់រដ្ឋបាល និងការវិភាគពីការប្រើប្រាស់ដីធ្លីគ្រប់ប្រភេទទាំងអស់នាពេលបច្ចុប្បន្ននៅក្នុងព្រំប្រទល់ ភូមិ ឬ ឃុំ ថាតើធនធានទាំងនោះ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ជាសម្បត្តិឯកជនរបស់រដ្ឋ ឬ ជាសម្បត្តិឯកជនស្របតាមច្បាប់ភូមិបាលដែរ ឬយ៉ាងណា?

PLUP មានអត្ថប្រយោជន៍សំខាន់ណាស់ ជាពិសេសនៅក្នុងតំបន់ដែលមានទំនាស់ច្រើនក្នុងការប្រើប្រាស់ដីធ្លី ឬតំបន់ដែលធនធានធម្មជាតិរេចរឹលធ្ងន់ធ្ងរ ។ PLUP ក៏បានជួយផងដែរដល់ការរៀបចំបង្កើតក្រុមសហគមន៍ព្រៃឈើ និង/ឬសហគមន៍នេសាទ អាស្រ័យតាមស្ថានភាពក្នុងភូមិនីមួយៗ ។

## ច្បាប់ និងអនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយ PLUP

មានច្បាប់ និងអនុក្រឹត្យសំខាន់ៗមួយចំនួនទាក់ទងនឹងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ដែលត្រូវបានអនុម័ត ឬកំពុងត្រូវបានរៀបចំជាសេចក្តីព្រាងដោយរាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីពិនិត្យមើលឱ្យកាន់តែស៊ីជំរៅជាងនេះ សូមអានជំពូក ៣ នៃរបាយការណ៍នេះ ។

ច្បាប់ទាំងនេះរួមមាន:

ច្បាប់ភូមិបាល

សេចក្តីថ្លែងការណ៍គោលនយោបាយដីធ្លី

ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់

ច្បាប់ស្តីពីព្រៃឈើ

សេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ

សេចក្តីព្រាងច្បាប់ស្តីពីការអភិរក្ស ការគ្រប់គ្រង និងការអភិវឌ្ឍជលផល

សេចក្តីព្រាងអនុក្រឹត្យសហគមន៍នេសាទ

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ

នៅពេលបច្ចុប្បន្ន គោលការណ៍ណែនាំថ្នាក់ជាតិជាក់លាក់មិនទាន់មាននៅឡើយទេ ។ គោលការណ៍ណែនាំនេះនឹងត្រូវរៀបចំធ្វើតឡើងនៅក្នុងអំឡុងពេល ពីរ ឬបីឆ្នាំ ខាងមុខ ដោយផ្អែកលើបទពិសោធន៍ដំបូងដែលមាននៅក្នុងប្រទេសកម្ពុជា ។

## ជំហាននៃការអនុវត្ត PLUP

ការអនុវត្ត PLUP ក្នុងភូមិ និងឃុំមានប្រាំបួនជំហានដូចខាងក្រោម :



### ជំហាន ០ : ការចាប់ផ្តើមដំបូង

- ជ្រើសរើស និងបណ្តុះបណ្តាលក្រុមសម្របសម្រួល PLUP ។
- វាយតម្លៃទិន្នន័យដែលមានស្រាប់ ។
- ទិញសម្ភារៈ និងគ្រឿងបរិក្ខារចាំបាច់ ។
- ជ្រើសរើសតំបន់ធ្វើការ ។

**ជំហានទី ១: ត្រៀមលក្ខណៈសម្រាប់ចុះធ្វើការនៅមូលដ្ឋាន**

- ផ្តល់ដំណឹងដល់អាជ្ញាធរមូលដ្ឋាន ។
- ប្រជុំភូមិគោលដៅដែលបានធ្វើការជ្រើសរើស ។

**ជំហានទី ២ : វិភាគស្ថានភាព**

- វិភាគទិដ្ឋភាពសេដ្ឋកិច្ច-សង្គម
- វិភាគទិដ្ឋភាពស្ថាប័ន
- វិភាគស្ថានភាពនៃការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ពីអតីតកាល និងបច្ចុប្បន្ន
- វិភាគអំពីការប្រើប្រាស់ដីធ្លី និងការប្រើប្រាស់ធនធានធម្មជាតិនាពេលបច្ចុប្បន្ន
- កំណត់ព្រំប្រទល់  ដើរកាត់ពំនុះទទឹងភូមិ( Transect walks) និងធ្វើផែនទី
- រៀបចំផែនទីស្តីពីការប្រើប្រាស់ដីធ្លីបច្ចុប្បន្ន

**ជំហានទី ៣: កំណត់ និងជ្រើសរើសនូវជម្រើសនៃការប្រើប្រាស់ដីធ្លី**

ជំហាននេះ ត្រូវអនុវត្តដោយអ្នកភូមិ និងមានការសម្របសម្រួលដោយបុគ្គលិកមកពីថ្នាក់ខេត្ត-ស្រុក

**ជំហានទី៤ : ការបង្កើតគណៈកម្មការ NRM ភូមិគណៈកម្មការ NRM**

ភូមិប្រតិបត្តិការងារជាអនុគណៈកម្មការនៃគណៈកម្មការអភិវឌ្ឍន៍ភូមិ ។

**ជំហានទី៥: រៀបចំធ្វើផែនទីប្រើប្រាស់ដីធ្លីអនាគត បទបញ្ញាផ្ទៃក្នុងភូមិ និងរៀបចំផែនការគ្រប់គ្រងលំអិត**

- ផែនទីប្រើប្រាស់ដីធ្លីអនាគត
- សម្របសម្រួលក្នុងការរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងភូមិ
- ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ

**ជំហានទី៦: ការដាក់ឆ្លងដើម្បីអនុម័ត និងឯកភាពជាផ្លូវការនូវផែនការប្រើប្រាស់ដីធ្លី បទបញ្ញាផ្ទៃក្នុងភូមិ និង ផែនការគ្រប់គ្រង ?**

- ការរៀបចំសរសេរបទបញ្ជាផ្ទៃក្នុងភូមិ
- ចុះហត្ថលេខា និងទទួលស្គាល់ដោយអាជ្ញាធរភូមិ ឃុំ ស្រុក និងខេត្ត

**ជំហានទី៧: បង្កើតទំនាក់ទំនងជាមួយសេវាកម្មផ្សព្វផ្សាយ និងការរៀបចំចុះបញ្ជីដីធ្លីដោយ PDLMUPC**

បង្កើតទំនាក់ទំនងជាមួយស្ថាប័នដែលមានស្រាប់ ដើម្បីផ្តល់ការគាំទ្រវាល់ការអនុវត្តសកម្មភាព NRM ក្នុងភូមិ ដូចជា: ការកំណត់ និងការចុះបញ្ជីដីធ្លីដែលអាចជួយកាត់បន្ថយ និងដោះស្រាយទំនាស់ផ្សេងៗ ។

**ជំហានទី ៨ : ការតាមដាន និងវាយតម្លៃ (Monitoring and Evaluation - M & E)**

ការតាមដាន និងវាយតម្លៃនៅក្នុងការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី PLUP គឺជាការប្រៀបធៀបរវាងស្ថានភាពបច្ចុប្បន្នជាមួយស្ថានភាពអតីតកាល រាល់ការអនុវត្តសកម្មភាពជាក់លាក់មួយចំនួន ដូចជាការកសាងផែនការ រៀបចំបទបញ្ញាផ្ទៃក្នុងភូមិ និងដំណើរការនានាដែលបានធ្វើ ។ M & E ផ្តល់នូវព័ត៌មានសំខាន់ៗ ដែលអាចយកមកប្រើប្រាស់សម្រាប់ធ្វើសេចក្តីសម្រេចថាតើសកម្មភាពទាំងអស់ដូចជា : ការធ្វើផែនការ ការអនុវត្តបទបញ្ញាផ្ទៃក្នុង និងដំណើរការនានាដែលបានធ្វើគួរតែបន្តទៅទៀត ឬក៏ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ ។ សេចក្តីសម្រេចទាំងនោះត្រូវធ្វើឡើងដោយមានការចូលរួម ។




*ដ្យាក្រាម ១: ជំហាន និងនីតិវិធីនៅក្នុង PULP*

រយៈពេលសមរម្យសម្រាប់អនុវត្តសកម្មភាពពីជំហាន ទី១ ដល់ជំហាន ទី៨ គឺត្រូវប្រើប្រាស់ពេលវេលាពី ៤-៦ ខែ ដោយអ្នកសម្របសម្រួលត្រូវធ្វើការប្រមាណ ១០ ថ្ងៃក្នុងមួយខែ ។

## បទពិសោធន៍



ប្រភពរូបភាព PLUP 2004

ក្នុងបំណងផ្តល់អំណាចដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាក់ទងនឹងការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនៅថ្នាក់មូលដ្ឋាន ។ កម្មវិធីបណ្តុះបណ្តាល មួយត្រូវបានរៀបចំឡើងសំរាប់អ្នកសម្របសម្រួលការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី PLUP ដោយមានការគាំទ្រពីម្ចាស់ជំនួយជាច្រើន ។ ក្នុងជំហានទីមួយ គ្រូបង្គោលPLUP ថ្នាក់ជាតិបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT) នៅក្នុងខែមីនា ឆ្នាំ២០០២ ។ បច្ចុប្បន្ន គ្រូបង្គោលទាំងនេះកំពុងធ្វើការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងកម្មវិធី ឬ គំរោងផ្តល់ជំនួយផ្សេងៗទៀត ។ គ្រូបង្គោល PLUP ធ្វើការងារជាក្រុមតូចៗ ដើម្បីបណ្តុះបណ្តាលអ្នកសម្របសម្រួលមកពី អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកតាម ខេត្ត ស្រុក ដែលមកពីស្ថាប័នផ្សេងៗទាក់ទងនឹងធនធានធម្មជាតិ (ក្សេត្រសាស្ត្រ រុក្ខកម្ម ជលផល រៀបចំដែនដី អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។ បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលសិក្ខាកាមជាមន្ត្រីរដ្ឋាភិបាលមកពីស្ថាប័នផ្សេងៗ និងបង្កើតជាក្រុមសម្របសម្រួល PLUP ថ្នាក់ខេត្ត ហើយក៏បានចាប់ផ្តើមគាំទ្រដល់សកម្មភាពរៀបចំផែនការប្រើប្រាស់ដីធ្លីនៅតាមមូលដ្ឋាន ។

វគ្គបណ្តុះបណ្តាល PLUP សម្រាប់អ្នកសម្របសម្រួលបានរៀបចំឡើងនៅតាមបណ្តាខេត្តជាច្រើនក្នុងប្រទេសកម្ពុជា ។ សកម្មភាព PLUP ក៏មាននៅតាមតំបន់ការពារធម្មជាតិ និងដែនជំរកសត្វព្រៃមួយចំនួនផងដែរដូចជា : តំបន់ការពារជម្រកសត្វព្រៃភ្នំសំកុស (សូមអានជំពូកទី ១៣ ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំ និងគាំទ្រថវិកាដោយអង្គការ FFI សហការជាមួយក្រសួងបរិស្ថាន ។

សកម្មភាពទៅថ្ងៃអនាគតត្រូវបានកំណត់ និងចាប់ផ្តើមរួចជាស្រេចនៅតាមតំបន់មួយចំនួន ។ អង្គការមិនមែនរដ្ឋាភិបាល (ដូចជា: LWF, WWF, PRASAC EU, FFI និង GTZ-PRO បានដើរតួជាអ្នកដឹកនាំការអនុវត្តសកម្មភាព PLUP តាមតំបន់គោលដៅរបស់ពួកគេ ។ សកម្មភាពនេះនឹងអាចត្រូវបានពង្រីកទៅខេត្តដទៃទៀតនៅពេលណា មានស្ថេរភាពផ្នែកថវិកា ។ ផែនទី១ បង្ហាញពីការពង្រីកសកម្មភាពរបស់ PLUP ចាប់ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៤ ។




ផែនទីទី ១: សកម្មភាព PLUPចាប់តាំងពីឆ្នាំ២០០២ ដល់ ឆ្នាំ ២០០៤

## បញ្ហា និងទស្សនវិស័យ

នាយកដ្ឋានរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ មានតួនាទីជាផ្លូវការក្នុងការរៀបចំធ្វើផែនការប្រើប្រាស់ ដីធ្លី ការធ្វើចំណាត់ថ្នាក់ដីធ្លី និងការបែងចែកដីធ្លី ។ ប៉ុន្តែបុគ្គលិកជាច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ខ្វះចំណេះដឹង មូលដ្ឋានស្ដីពីធនធានធម្មជាតិ ។ ការបង្កើនសមត្ថភាពនិងកិច្ចសហការយ៉ាងជិតស្និតជាមួយស្ថាប័នជំនាញនឹងជួយដល់មន្ត្រី ទាំងនោះដើម្បីសម្របសម្រួលការងារ ។

ការអនុវត្តPLUP អាចទទួលជោគជ័យនៅថ្នាក់ភូមិ-ឃុំ លុះត្រាតែ :

- អាជ្ញាធររដ្ឋាភិបាលបង្ហាញអំពីឆន្ទៈនយោបាយក្នុងការគាំទ្រវិមជ្ឈការ តម្លាភាព ហើយដំណើរការ PLUP ត្រូវអនុវត្តពីក្រោម ទៅលើ ដើម្បីឱ្យស្របតាមសេចក្ដីថ្លែងការណ៍ជាលាយល័ក្ខអក្សរ និងផ្ទាល់មាត់របស់ខ្លួន ។
- កម្មវិធីផ្សព្វផ្សាយកសិកម្មមានទំនាក់ទំនងជាមួយនឹងការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លី ចំណាត់ថ្នាក់ដីធ្លី និងបែងចែកដីធ្លី ។ កម្មវិធី នេះនឹងផ្តល់ឱកាសដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការបង្កើនស្បៀង និងប្រាក់ចំណូល និងកាត់បន្ថយការពឹងផ្អែកទាំងស្រុងលើវិស័យព្រៃឈើ និងការកាប់ទន្ទ្រានព្រៃឈើ ។

## សកម្មភាពនាពេលអនាគត

ដើម្បីធ្វើឱ្យសកម្មភាព PLUP នៅកម្ពុជាឈានដល់កម្រិតអតិបរមា និងបានល្អប្រសើរគួរតែរៀបចំធ្វើផែនការដូចបានរៀបរាប់ខាងក្រោម :-

តាមដាន និងវាយតម្លៃរាល់សកម្មភាព PLUP នៅតាមបណ្តាខេត្ត

រៀបចំសិក្ខាសាលាក្នុងចំណោមគ្រូបង្គោល ដើម្បីកែលំអមេរៀន និងវិធីសាស្ត្រនៃវគ្គបណ្តុះបណ្តាល

ធ្វើអោយមានសេវាកម្មផ្សព្វផ្សាយអំពី PLUP ក្នុងចំណោមក្រុមប្រឹក្សាឃុំ/សង្កាត់

បង្កើតបណ្តាញការងារ PLUP រវាងថ្នាក់ជាតិ និងថ្នាក់ខេត្តក្រោមការដឹកនាំរបស់នាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

រៀបចំធ្វើសិក្ខាសាលាមួយដែលមានផែនការច្បាស់លាស់ ដើម្បីកែលំអសៀវភៅជំនួយស្មារតី PLUP

បង្កើតប្រព័ន្ធទិន្នន័យស្ដីពី PLUP ដែលស្រដៀងគ្នានឹងប្រព័ន្ធទិន្នន័យស្ដីអំពីសហគមន៍ព្រៃឈើ ។

## REFERENCES

Christ, H [Ed.] 1999. *Participatory Land Use Planning in Cambodia.* Proceedings of the Introductory Workshop, 14 15 September 1999, Department of Forestry and Wildlife, Phnom Penh.

Rock, F [Ed.] 2001. *Participatory Land Use Planning PLUP in Rural Cambodia. Manual for Government Staff and Development Workers.* (English and Khmer Version) Ministry of Land Management, Urban Planning and Construction, Phom Penh.

# ជំពូក ១០ ការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា

រៀបរៀងដោយ លោក មាស សុធនវឌ្ឍនៈ[១] កញ្ញា សាន្ត សុជាតិលក្ខិណា[២ និង ៣]

គោលបំណងនៃជំពូកនេះគឺដើម្បីផ្តល់នូវចំណេះដឹងទូទៅពីវិធីសាស្ត្រនៃការគ្រប់គ្រងដោយមានការចូលរួម នៅក្នុងតំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា ។ ផ្នែកទីមួយសង្ខេបអំពីប្រវត្តិនៃការកើតឡើងនៃវិធីសាស្ត្រគ្រប់គ្រងដោយមានការចូលរួម។ ផ្នែកទីពីរ ពន្យល់អំពីប្រភេទខុសៗគ្នានៃសហគមន៍តំបន់ការពារធម្មជាតិ និងវិធីសាស្ត្រ ដែលបានប្រើប្រាស់ទៅតាមអង្គការ ឬស្ថាប័នផ្សេងៗ។ ផ្នែកទីបី បង្ហាញនូវបញ្ហាមួយចំនួន ព្រមទាំងវិធីសាស្ត្រថ្មីៗ ។ ផ្នែកចុងក្រោយ ជាការសន្និដ្ឋាន និងការងារដែលត្រូវធ្វើជាបន្តទៀត។

## ប្រវត្តិដើម

នៅឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការកំណត់ និងបង្កើតតំបន់ការពារធម្មជាតិ បានបង្កើតតំបន់ការពារធម្មជាតិចំនួន ២៣ កន្លែងនៅក្នុងប្រទេសកម្ពុជា (ឧបសម្ព័ន្ធទី១ ។ តំបន់ការពារធម្មជាតិទាំង ២៣កន្លែងនេះ មានផ្ទៃដីសរុប ៣,៣លាន ហិកតា ដែលត្រូវនឹង ១៨% នៃផ្ទៃដីប្រទេសកម្ពុជា ។ តំបន់ការពារធម្មជាតិទាំងនោះបានចែកជាឧទ្យានជាតិចំនួន៧កន្លែង ដែនជម្រកសត្វព្រៃចំនួន ១០កន្លែង តំបន់ការពារទេសភាពចំនួន ៣កន្លែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣កន្លែង ។

ដោយសារបញ្ហាសន្តិសុខនៅមូលដ្ឋានសម័យនោះនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានបានបង្កើតតំបន់ការពារធម្មជាតិទាំងនេះដោយមិនបានពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ជាមួយអ្នកពាក់ព័ន្ធឡើយ (Carew-Reid *et al*, 2002:7)។ នៅពេលនោះ តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងដោយវិធីសាស្ត្រគ្រប់គ្រងពីលើចុះក្រោម ដែលការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលកំពុងតែរស់នៅទីនោះមានកម្រិតនៅឡើយ (Ken, 2003)។

វិធីសាស្ត្រគ្រប់គ្រងពីលើចុះក្រោមមិនអាចដំណើរការទៅបានដោយសារហេតុផលសំខាន់ៗ ចំនួនបួន គឺ:

**កង្វះការយល់ដឹង** ពីទីកន្លែងដែលប្រជាពលរដ្ឋកំពុងរស់នៅ និងធនធានដែលពួកគាត់ប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិត (Ken, 2003)។ ទោះបីជាតំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងក៏ដោយ ក៏សហគមន៍មូលដ្ឋានបានបន្តប្រើប្រាស់ធនធានព្រៃឈើដូចដែលពួកគាត់បានធ្វើកន្លងមកដែរ។ អាស្រ័យហេតុនេះ ធនធានធម្មជាតិពុំបានទទួលកិច្ចការពារប្រកបដោយនិរន្តរភាពបានឡើយ។

**កង្វះក្របខ័ណ្ឌច្បាប់** បានន័យថាពុំមានការដោះស្រាយប្រកបដោយប្រសិទ្ធិភាពនូវបញ្ហានានាក្នុងការទាញយកផលពីធនធានធម្មជាតិដោយគ្មាននិរន្តរភាពពីសំណាក់អ្នកដែលរស់នៅតំបន់ផ្សេងៗទាំងអ្នករស់នៅក្នុង និងអ្នករស់នៅក្រៅ ។

---

[១] លោក មាស សុធនវឌ្ឍនៈ ជាមន្ត្រីបច្ចេកទេសនៅការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន

[២] កញ្ញា សាន្ត សុជាតិលក្ខិណា ជាមន្ត្រីបច្ចេកទេសនៅការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន

[៣] ការចូលរួមចំណែកលោកស្រី អ៊ុក សីហា លោក ម៉ៅ គន្ធា និងលោក ម៉ា សុផល ព្រមទាំងកែសម្រួលដោយលោក Stefan Janssens និងលោក កែន សេរីរដ្ឋា។

**កង្វះព័ត៌មានអំពីជីវៈចម្រុះ** ដែលនាំឱ្យរដ្ឋាភិបាលមិនអាចធ្វើសេចក្តីសម្រេចឱ្យបានត្រឹមត្រូវអំពីការបែងចែកតំបន់ការពារធម្មជាតិទៅជាតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់អភិវឌ្ឍន៍សហគមន៍ ។

**សមត្ថភាពធនធានមនុស្ស និងថវិកានៅមានកម្រិត** ដែលនាំឱ្យរដ្ឋាភិបាលកម្ពុជាលំបាកក្នុងការចាត់វិធានការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាព ។

ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រខុសៗគ្នានៃការគ្រប់គ្រងបានបង្កើតឡើងទៅតាមការនិយមរបស់អង្គការមិនមែនរដ្ឋាភិបាលនានា និងគម្រោងផ្សេងៗដែលកំពុងដំណើរការនៅក្នុងប្រទេស ។ វិធីសាស្ត្រនីមួយៗនេះបានគាំទ្រសហគមន៍មូលដ្ឋានឱ្យចូលរួមនៅក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។ សហគមន៍មូលដ្ឋានទាំងនោះបានទទួលការរៀនសូត្រ និងស្វែងយល់អំពីសារៈប្រយោជន៍នៃធនធានព្រៃឈើ ហើយក៏បានចូលរួមនៅក្នុងការគ្រប់គ្រង ការប្រើប្រាស់ឱ្យមាននិរន្តរភាព និងទប់ស្កាត់ការប្រើប្រាស់ធនធានធម្មជាតិល្មើសច្បាប់ ។

ការអនុវត្តជាក់ស្តែងបានបង្ហាញឱ្យឃើញថាវិធីសាស្ត្រនេះមានប្រសិទ្ធិភាព ។ បទពិសោធន៍បានបង្ហាញឱ្យឃើញផងដែរថាការចូលរួមរបស់សហគមន៍មូលដ្ឋានបានធ្វើឱ្យមានការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទន្ទឹមនឹងនោះក៏បានជួយអភិរក្សជីវៈចម្រុះផងដែរ ។ ប៉ុន្តែការប្រើប្រាស់វិធីសាស្ត្រនេះទាមទារពេលវេលាយូរព្រោះត្រូវ ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើន ។

បទពិសោធន៍ខាងលើ ក៏ដូចជាការលើកទឹកចិត្តពីអង្គការមិនមែនរដ្ឋាភិបាលនានា បានជម្រុញរដ្ឋាភិបាលឱ្យពិចារណាពីវិធីសាស្ត្ររបស់ខ្លួនឡើងវិញ ។ ការគ្រប់គ្រងដោយមានការចូលរួមនេះក៏ឆ្លើយតបផងដែរទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ ។ នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានបានទទួលបទពិសោធន៍នេះ និងបានចេញគោលការណែនាំចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ ស្តីពីកិច្ចដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ។ គោលការណ៍ណែនាំនេះ គឺជាកិច្ចប្រឹងប្រែងដំបូងមួយឈានទៅរៀបចំគោលនយោបាយផ្លូវការមួយ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួមនៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់ពីចេញគោលការណ៍ណែនាំមក យើងឃើញមានសហគមន៍តំបន់ការពារធម្មជាតិចំនួន៦៩ បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងនោះសហគមន៍ចំនួន២៤ ត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងបរិស្ថាន (សូមមើលឧបសម្ព័ន្ធ ២និង ៣) ។

ប៉ុន្តែ មកទល់ពេលនេះ នៅពុំទាន់មានការបង្កើតគោលការណ៍ណែនាំបច្ចេកទេស ឬបទដ្ឋានច្បាប់ច្បាស់លាស់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិនៅឡើយទេ ។ អង្គការមិនមែនរដ្ឋាភិបាល និងគម្រោងទ្វេភាគីនានា កំពុងអនុវត្តការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិតាមវិធីសាស្ត្រ ដោយឡែករៀងៗខ្លួន ។ ផ្នែកបន្ទាប់នឹងពិពណ៌នាអំពីវិធីសាស្ត្រសំខាន់ៗដែលបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ។

## ប្រភេទផ្សេងៗនៃសហគមន៍តំបន់ការពារធម្មជាតិ

សហគមន៍តំបន់ការពារធម្មជាតិជាវិធីសាស្ត្រមួយសំដៅសម្រេចគោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។ កន្លងមកមានវិធីសាស្ត្របួនបានប្រើប្រាស់សម្រាប់រៀបចំសហគមន៍តំបន់ការពារធម្មជាតិ រួមមាន ការរៀបចំដោយការកំណត់តំបន់ ការចូលរួមរៀបចំផែនការ សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ និងការកសាងជីវភាពរស់នៅដោយនិរន្តរភាព។ នៅពេលខ្លះ វិធីសាស្ត្រទាំងអស់ខាងលើនេះត្រូវបានអនុវត្តដោយរួមបញ្ចូលគ្នា ។ អង្គការនានាដែលកំពុងធ្វើការនៅតាមតំបន់ការពារធម្មជាតិនីមួយៗក្នុងប្រទេសកម្ពុជាបានជម្រុញ និងសម្របសម្រួលឱ្យមានការប្រើប្រាស់វិធីសាស្ត្រទាំងនេះ ។

តារាងទី១ : ពិពណ៌នាដោយសង្ខេបពីអង្គការមួយចំនួនដែលកំពុងធ្វើការនៅតាមតំបន់ការពារធម្មជាតិនានា និងវិធីសាស្ត្រចម្បងៗ ដែលបានប្រើប្រាស់ដែលមានពិពណ៌នាបន្ទាប់ពីតារាងនេះ ។

| អង្គការ/គម្រោង | តំបន់ការពារធម្មជាតិ | វិធីសាស្ត្រ |
|---|---|---|
| រុក្ខជាតិ និងសត្វព្រៃអន្តរជាតិ (FFI) | គម្រោងដែនជំរកសត្វព្រៃជួរភ្នំក្រវាញ | ការចូលរួមរៀបចំផែនការ |
| គម្រោងគ្រប់គ្រងជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ (BPAMP) ឧបត្ថម្ភដោយធនាគារពិភពលោក | ឧទ្យានជាតិ វីរៈជ័យ | ការកំណត់តំបន់ និងការចូលរួមកសាងផែនការ |
| គម្រោងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ (BPAMP)-ឧបត្ថម្ភ ដោយអង្គការ ដានីដា | ឧទ្យានជាតិព្រះសីហនុ "រាម" | សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ |
| អង្គការសមាគមន៍អភិរក្សសត្វព្រៃ (WCS) | ដែនជម្រកសត្វព្រៃគូលែន ព្រហ្មទេព | ការចូលរួមកសាងផែនការ |
| អង្គការម្លប់បៃតង (Mlup Baitong) | ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" | ការកសាងជីវភាពរស់នៅដោយនិរន្តរភាព |
| គម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) | ដែនជម្រកសត្វព្រៃបឹងពែរ | សហគមន៍ព្រៃឈើ |
| អង្គការសង្គ្រោះសត្វព្រៃកម្ពុជា (SCW) | ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" | សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ |
| គម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង (PMMR) | ដែនជម្រកសត្វព្រៃពាមក្រសោប | សហគមន៍នេសាទ សហគមន៍ព្រៃឈើ និងការកសាងជីវភាពរស់នៅដោយនិរន្តរភាព |
| អង្គការមូលនិធិពិភពលោកសម្រាប់ការអភិរក្សធម្មជាតិ (WWF) | ដែនជម្រកសត្វព្រៃភ្នំព្រេច | ការកំណត់តំបន់ និងការចូលរួមកសាងផែនការ សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ |

*តារាងទី ១: ឧទាហរណ៍ពីអង្គការដែលអនុវត្តការងារ និងវិធីសាស្ត្រដែលបានប្រើប្រាស់*

## ការកំណត់តំបន់

សហគមន៍តំបន់ការពារធម្មជាតិប្រភេទនេះបានបែងចែកទៅតាមតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ។ មានតែឧទ្យានុរក្ស និងអ្នកស្រាវជ្រាវតែប៉ុណ្ណោះដែលអាច ទទួលការអនុញ្ញាតឱ្យចូលធ្វើការស្រាវជ្រាវ និងការពារបរិស្ថាននៅក្នុងតំបន់ស្នូល ។ ការចូលទៅក្នុងតំបន់អភិរក្សតម្រូវឱ្យមានការអនុញ្ញាតពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

សហគមន៍មូលដ្ឋានអាចប្រើប្រាស់ធនធានធម្មជាតិដោយមានកម្រិតកំណត់ ។ ការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ ការប្រើប្រាស់តំបន់នេះអាចអនុញ្ញាតក្រោមរូបភាពជាអេកូ-ទេសចរណ៍ សហគមន៍តំបន់ការពារធម្មជាតិ កន្លែងអភិរក្សបេតិកភ័ណ្ឌ ឬកន្លែងប្រើប្រាស់ពិសេស ។ ក្នុងដែនសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍មូលដ្ឋានអាចមានដីជាកម្មសិទ្ធិ ។ ក្រសួងបរិស្ថាន និងធនាគារពិភពលោកប្រើប្រាស់វិធីសាស្ត្រកំណត់តំបន់ក្នុងការអនុវត្តគម្រោងនៅឧទ្យានជាតិវីរៈជ័យ ។

**តំបន់ស្នូល** ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។ ការចេញចូលតំបន់នេះ ត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែក វិទ្យាសាស្ត្រ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថានដែលត្រូវមានការអនុញ្ញាតជាមុន ពីក្រសួងបរិស្ថាន លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។

**តំបន់អភិរក្ស** ជាតំបន់គ្រប់គ្រងស្ថិតនៅ ជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ ។ ការចេញចូលតំបន់នេះត្រូវមាន ការអនុញ្ញាតពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែងលើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះសម្រាប់ជីវភាពសហគមន៍មូលដ្ឋានជនជាតិដើមភាគតិច ដែលមិន ប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

**តំបន់ប្រើប្រាស់ដោយចីរភាព** ជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្ស តំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះតាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនិតិវិធីជាធរមាន ។

**តំបន់សហគមន៍** ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់សហគមន៍ និងជនជាតិ ដើមភាគតិច ដែលមានសកម្មភាពស្រាប់រួមមានលំនៅដ្ឋាន ស្រែ និងចំការ ។ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យ ប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

## ការចូលរួមរៀបចំផែនការ

នៅក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម តំបន់នានាបានបែងចែកជា ដីកសិកម្ម ដីភូមិ សហគមន៍តំបន់ការពារធម្មជាតិ និងតំបន់អភិរក្ស ។ នៅក្នុងដំណើរការបែងចែកតំបន់បែបនេះ សហគមន៍មូលដ្ឋាន បានអញ្ជើញឱ្យចូលរួមដើម្បីស្វែងយល់អំពីសារៈសំខាន់នៃតំបន់ទាំងនោះ និងដើម្បីចូលរួមនៅក្នុងការគ្រប់គ្រង និងអភិរក្ស ។ អង្គការរុក្ខជាតិ និងសត្វព្រៃអន្តរជាតិ (FFI) បានប្រើប្រាស់វិធីសាស្ត្រនេះ ក្នុងការអនុវត្តគម្រោងដែនជម្រកសត្វព្រៃជួរភ្នំក្រវាញ ។

## ការរៀបចំជាសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ

ផ្នែកខ្លះនៃតំបន់ការពារធម្មជាតិបានដាក់នៅក្រោមការគ្រប់គ្រងរបស់សហគមន៍មូលដ្ឋាន និងរៀបចំជាសហគមន៍ តំបន់ការពារធម្មជាតិ សម្រាប់គ្រប់គ្រងព្រៃឈើ និងធនធានជលផល ។ ឧទាហរណ៍ សហគមន៍តំបន់ការពារធម្មជាតិនៅដែន ជម្រកសត្វព្រៃបឹងពែរ និងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ដែលអនុវត្តដោយគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើ និងអង្គការសង្គ្រោះសត្វព្រៃកម្ពុជា ចំណែកឯនៅឧទ្យានជាតិព្រះសីហនុ "រាម" ដែលអនុវត្តដោយគម្រោងគ្រប់គ្រងតំបន់ឆ្នេរ សមុទ្រ ។

## ការកសាងជីវភាពរស់នៅដោយនិរន្តរភាព

នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបែបនេះ សហគមន៍មូលដ្ឋានមានឱកាសរកប្រាក់ចំណូលពីមុខរបរថ្មីៗ ដូច្នេះ សហគមន៍មូលដ្ឋានមិនពឹងផ្អែកទាំងស្រុងទៅលើការប្រើប្រាស់ធនធានធម្មជាតិទេ។ កម្មវិធីចិញ្ចឹមជីវិតមានជាអាទិ៍ ការចិញ្ចឹមមាន់ ជ្រូក និងការចិញ្ចឹមត្រី ការដាំបន្លែ និងដំណាំហូបផ្លែជាលក្ខណៈគ្រួសារ និងការចាត់ចែងសេវាទេសចរណ៍ធម្មជាតិ។ ជាក់ស្តែង នៅឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" មានតំបន់ទេសចរណ៍ធម្មជាតិមួយបានបង្កើតឡើងជាប្រយោជន៍ក្នុងការ បង្កើនប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន។

## បញ្ហា និងឧបសគ្គ

សហគមន៍ក្នុងតំបន់ការពារធម្មជាតិនៅតែជួបប្រទះបញ្ហាជាច្រើនដែលទាក់ទងទៅនឹងការកំណត់ព្រំប្រទល់ ការអនុវត្ត សកម្មភាពនៅមានកម្រិតទាប ការចូលទន្ទ្រានពីសំណាក់អ្នកមានអំណាចមកពីខាងក្រៅ និងការពុំមានអំណាចគ្រប់គ្រាន់ដើម្បីចាត់ វិធានការបង្ក្រាបបទល្មើស ។ បញ្ហាចម្បងៗមានបង្ហាញជូនដូចខាងក្រោមនេះ :

**- បទពិសោធន៍របស់អ្នកសម្របសម្រួលនៅមានកម្រិត**

ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិគឺជាសកម្មភាព និងវិធីថ្មីមួយ ហើយការរៀបចំសហគមន៍បានចាត់ចែង ឡើងដោយអ្នកសម្របសម្រួល ដែលមានការយល់ដឹងទាប និងតាមការយល់ដឹងរៀងៗខ្លួន។ ឯកសារណែនាំរបស់ក្រសួង បរិស្ថានត្រូវបានចែកចាយដោយពុំមានការបកស្រាយ និងពន្យល់អំពីរបៀបអនុវត្តន៍តាមសេចក្តីណែនាំទាំងនោះឡើយ ។

**- ការចូលរួមរបស់សហគមន៍នៅមានកម្រិត**

សហគមន៍តំបន់ការពារធម្មជាតិភាគច្រើនស្ថិតនៅតំបន់ដាច់ស្រយាល ហើយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រឈម នឹងការលំបាកជាច្រើន ដូច្នេះសហគមន៍មានពេលវេលាតិចតួចដើម្បីចូលរួមយាមល្បាត។ លើសពីនេះ គណៈកម្មការសហគមន៍ពុំ ទាន់យល់ច្បាស់ពីច្បាប់ និងប្រឈមចំពោះការគម្រាមកំហែងពីសំណាក់ជនល្មើសថែមទៀតផង ។

សមាជិកសហគមន៍មួយចំនួននៅមានភាពស្ទាក់ស្ទើរក្នុងការចូលរួម ឬមានការយល់ច្រឡំពីដំណើរការនេះ។ ពួកគេ គិតថា សហគមន៍តំបន់ការពារធម្មជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានភូមិ និងគណៈកម្មការសហគមន៍តែប៉ុណ្ណោះ។ ការយល់ឃើញបែបនេះអាចបណ្តាលពីសកម្មភាពផ្សព្វផ្សាយធ្វើឡើងមិនបានទូលំទូលាយទៅដល់ស្រទាប់សមាជិកសហគមន៍ ហើយអ្នកសម្របសម្រួល ច្រើនតែធ្វើការជាមួយគណៈកម្មការសហគមន៍តែប៉ុណ្ណោះ។

**- កង្វះខាតថវិកា**

យោងតាមគោលនយោបាយវិមជ្ឈការឆ្នាំ២០០៣ ក្រសួងបរិស្ថានបានទទួលការលើកទឹកចិត្តឱ្យរៀបចំសហគមន៍ តំបន់ការពារធម្មជាតិមួយចំនួនដោយប្រើប្រាស់ថវិការដ្ឋ និងមានការសម្របសម្រួលពីសំណាក់នាយកតំបន់ការពារធម្មជាតិ។

ជាលទ្ធផល សហគមន៍តំបន់ការពារធម្មជាតិមួយចំនួនបានកំណត់ទីតាំងព្រំប្រទល់ព្រៃ និងជ្រើសរើសគណៈកម្មការរួចរាល់ហើយ តែពុំទាន់មានការទទួលស្គាល់តាមផ្លូវច្បាប់ឡើយ ។ ទន្ទឹមនឹងនោះ សហគមន៍ខ្លះមានការទទួលស្គាល់ជាផ្លូវការហើយនៅតែពុំទាន់ដឹងថាត្រូវចាត់ចែងការអនុវត្តដោយរបៀបណានៅពេលខ្វះអ្នកសម្របសម្រួល។ ដោយសារតែថវិការដ្ឋមានតិចតួច ក្រសួងពុំអាចបំពេញតាមសំណូមពររបស់សហគមន៍មូលដ្ឋានបានទាំងស្រុងឡើយ។

**- ភាពមិនច្បាស់លាស់ពីការរើបអូស និងការបែងចែកផល**

មិនត្រឹមតែសហគមន៍តំបន់ការពារធម្មជាតិប៉ុណ្ណោះទេ សូម្បីតែសហគមន៍ព្រៃឈើដែលនៅក្រៅតំបន់ការពារធម្មជាតិក៏នៅពុំទាន់មានភាពច្បាស់លាស់ពីតួនាទីរបស់សហគមន៍ ក្នុងការចូលរួមបង្ក្រាបបទល្មើស និងបែងចែកផលរវាងសហគមន៍ និងរដ្ឋាភិបាលដែរ ។ បញ្ហានេះធ្វើឱ្យមានការប៉ះពាល់ដល់ឆន្ទៈក្នុងការចូលរួមរបស់សមាជិកសហគមន៍។ លើសពីនេះ សហគមន៍តំបន់ការពារធម្មជាតិភាគច្រើនមានបំណង ដកហូតផលខ្លះៗពីព្រៃឈើសម្រាប់អភិវឌ្ឍន៍សហគមន៍របស់គាត់ ដែលផ្ទុយនឹងគោលបំណងចម្បងនៃការអភិរក្សតំបន់ការពារធម្មជាតិ ។

## សេចក្តីសន្និដ្ឋាន និងការងារដែលត្រូវធ្វើបន្ត

បច្ចុប្បន្ននេះ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ បានរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល ឬគម្រោងផ្សេងៗជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា និងពុំមានយុទ្ធសាស្ត្ររួមឡើយ។ បទពិសោធន៍បានបង្ហាញថាការរៀបចំសហគមន៍តំបន់ការពារធម្មជាតិតាមវិធីនេះទទួលបានលទ្ធផលវិជ្ជមានតែសហគមន៍ទាំងនេះនៅតែមានឧបសគ្គខ្លះៗ ក្នុងការអនុវត្តការងារ ។

ដើម្បីសម្រេចបានជោគជ័យ យើងចាំបាច់ត្រូវរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំបច្ចេកទេស។ បណ្តាញការងារមួយត្រូវបានបង្កើតឡើងរួចមកហើយ ដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងក្នុងការបង្កើនការប្រាស្រ័យទាក់ទងគ្នា។ចុងបញ្ចប់ ប្រការចាំបាច់គឺការកសាងសមត្ថភាពបន្ថែមទៀតសម្រាប់អ្នកអនុវត្តការងារនេះនៅមូលដ្ឋាន។

### រៀបចំគោលនយោបាយរួម

បច្ចុប្បន្នមានវិធីសាស្ត្រផ្សេងៗគ្នាជាច្រើនដែលបានប្រើប្រាស់ ដើម្បីឈានទៅធ្វើការអភិរក្សជីវៈចម្រុះ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ អង្គការ និងមន្ទីរជំនាញនានារបស់រដ្ឋាភិបាលបាននឹងកំពុងចាត់ចែងរៀបចំការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិតាមមធ្យោបាយរៀងៗខ្លួន។ នៅដំណាក់កាលនេះក្រសួងបរិស្ថានកំពុងតែព្យាយាមប្រមូលផ្តុំវិធីសាស្ត្រដែលបាននឹងកំពុងតែប្រើប្រាស់ជាមួយគ្នាដើម្បីរៀបចំជាគោលការណ៍រួមមួយ។

### រៀបចំផែនការយុទ្ធសាស្ត្រ

ដើម្បីរៀបចំគោលការណ៍ណែនាំបច្ចេកទេសអំពីរបៀបបង្កើតសហគមន៍តំបន់ការពារធម្មជាតិ តម្រូវការចាំបាច់គឺការរៀបចំផែនការយុទ្ធសាស្ត្រ។ នៅពេលនេះ ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិកំពុងរៀបចំកសាងផែនការយុទ្ធសាស្ត្រ ដោយមានការចូលរួមពីសំណាក់គណៈកម្មការតំបន់ការពារធម្មជាតិ។

## បង្កើនការប្រាស្រ័យទាក់ទង

ប្រការសំខាន់ ត្រូវបង្កើនការប្រាស្រ័យទាក់ទងរវាងអង្គការ ឬស្ថាប័នរដ្ឋាភិបាល នាយកតំបន់ការពារធម្មជាតិ និងសហគមន៍មូលដ្ឋាន ។ ការខិតខំប្រឹងប្រែងដំបូងមួយបានធ្វើឡើងនៅឆ្នាំ១៩៩៨ នៅពេលបង្កើតបណ្តាញការងារសហគមន៍ព្រៃឈើ និងតំបន់ការពារធម្មជាតិ ដើម្បីចែករំលែកព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធ ។ បណ្តាញការងារនេះផ្តោតលើតំបន់ទាំងអស់ ពោលគឺទាំងក្នុង និងក្រៅតំបន់ការពារធម្មជាតិ ។ កិច្ចប្រជុំប្រចាំត្រីមាសបានរៀបចំឡើង ដោយមានការចែកផ្សាយព្រឹត្តិបត្រព័ត៌មានផងដែរ ។

ក្រោយមានសេចក្តីប្រកាសឆ្នាំ២០០៣ បណ្តាញការងារនេះបានពង្រីក ដោយរួមបញ្ចូលតំណាងសហគមន៍តំបន់ការ-ពារធម្មជាតិផងដែរ ។ សមាសភាពក្នុងបណ្តាញនេះមានជាអាទិ៍ គណៈកម្មការសហគមន៍ នាយកតំបន់ការពារធម្មជាតិ ឧទ្យានុរក្សអង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តសកម្មភាពនៅមូលដ្ឋាន និងមន្ទីរជំនាញពាក់ព័ន្ធរបស់រដ្ឋាភិបាល ។ អ្នកចូលរួមក្នុងបណ្តាញការងារនេះបានផ្លាស់ប្តូរព័ត៌មាន ចែករំលែកបទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក ។ ក្រៅពីនេះក៏មានការជូនដំណឹងផងដែរពីការវិវឌ្ឍថ្មីៗ ទាក់ទងនឹងគោលនយោបាយដែលសមាជិកនានា អាចយកទៅអនុវត្តបន្ត ។

ទោះជាយ៉ាងណាក៏ដោយ កិច្ចប្រជុំនេះពុំទាន់បានអនុវត្តទូលំទូលាយនៅឡើយទេ ដោយសារតែពុំមានការផ្តល់ថវិកាគ្រប់គ្រាន់ពីក្រសួងបរិស្ថាន ដូច្នេះមានតែសមាជិកគណៈកម្មការសហគមន៍មួយចំនួនតូចប៉ុណ្ណោះ ដែលបានទទួលការអញ្ជើញចូលរួម ។ របៀបវារៈនៃកិច្ចប្រជុំនេះមានត្រឹមតែជាវេទិកាសម្រាប់ផ្លាស់ប្តូរគំនិត និងបទពិសោធន៍ ដែលមិនមែនជាវេទិកាសម្រាប់ដោះស្រាយ ឬធ្វើសេចក្តីសម្រេចនោះឡើយ ។

## ការកសាងសមត្ថភាព

មានតម្រូវការចាំបាច់បន្ថែមទៀតក្នុងការបង្កើនសមត្ថភាពសម្រាប់អ្នកសម្របសម្រួល និងសហគមន៍មូលដ្ឋាន ។ អ្នកសម្របសម្រួល ពុំសូវមានការយល់ដឹងពីតួនាទីរបស់ខ្លួនឡើយ ។ ពួកគេមិនបានចាត់ទុកការចូលរួម និងការចែករំលែកគំនិត ឬយោបល់ពីសំណាក់សមាជិកសហគមន៍គ្រប់រូបនោះឡើយ ។ ហេតុនេះ រាល់សេចក្តីសម្រេចមិនមែនសុទ្ធតែបានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីតម្រូវការពិតប្រាកដរបស់សហគមន៍មូលដ្ឋាននោះទេ ។

## REFERENCES

Carew-Reid, J., Kol, V. and Mao, K. 2002. *Lessons learned: the Cambodia experience of protected areas and development, http://www.mekong-protected-areas.org/cambodia/docs/* cambodia_lessons.pdf (23/03/03).

Meas, S. V. et al. 2004. *Report on Community Protected Areas in Cambodia,* Department of Nature Conservation and Protection, Ministry of Environment, Phnom Penh, Cambodia 2004.

Ministry of Environment, 1999. *Map of Protected Areas in Cambodia, Phnom Penh, Cambodia.*

Ken, S.R. 2003. *Research Thesis on Co-Management in Protected Areas Management in Cambodia,* The Australian National University, Canberra, Australia.

Ken, S.R. 2004. *Concept Paper on Strategies Concept Note, Department of Nature Conservation and Protection,* Ministry of Environment, Cambodia.


ឧបសម្ព័ន្ធ១: តំបន់ការពារធម្មជាតិ នៅកម្ពុជា
Cities
Rivers
Roads
Protected Aeas
Fish Sanctuary
Multiple Use Area
National Park
Protected Landscape
RAMSAR Wetland
Wildlife Sanctuary
Protected Forest
Marine Protected Area
Water
N
30 0 30 60 90 Kilometers
Sources:
Protected Areas: Ministry of Environment (2001)
Roads: Ministry of Planning (1999)
Cities: UNEP (1999)
Projection: UTM Zone 48
Spheroid: Everest 56
Stung Treng
Ban Lung
Siem Reap
Battambang
Kratie
Pursat
Sen Monorom
Kampong Cham
Koh Kong
Phnom Penh
Kampot
Sihanoukville
300000
400000
500000
600000
700000
1600000
1500000
1400000
1300000
1200000




***ឧបសម្ព័ន្ធ២: សហគមន៍តំបន់ការពារធម្មជាតិនៅប្រទេសកម្ពុជា***

| ល.រ | តំបន់ការពារធម្មជាតិ | ចំនួន CPAs | ចំនួនភូមិ | ចំនួនគ្រួសារ | ទំហំ CPA ហិកតា |
|---|---|---|---|---|---|
| *ឧទ្យានជាតិ* | | | | | |
| ១ | ព្រះមុនីវង្ស បូកគោ | ៣ | ១១ | ១៤៦២ | ២៨៣៦ |
| ២ | ព្រះសីហនុ-រាម | ៤ | ១៣ | ១៣០១ | ៥១៨៨ |
| ៣ | ព្រះសុរាម្រិត-កុសមៈ (គីរីរម្យ | ២ | ៤ | ២៥៩ | ៤៩៤ |
| ៤ | ព្រះជ័យវរ្ម័ន-នរោត្តម ភ្នំគូលែន | ៤ | ៤ | ៣២៦ | ១ ០៩៤ ២៥២ |
| ៥ | វីរៈជ័យ | ២ | ១៤ | ? | ១៦២៥ |
| ៦ | កែប | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ៧ | បុទមសាគរ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុបរង | | ១៥ | ៤៦ | ៣ ៣៤៨ | ៩ ៦២៨ ៧៧៥ |
| *ដែនជម្រកសត្វព្រៃ* | | | | | |
| ៨ | បឹង ពែរ | ៤ | ១៦ | ២ ០៥១ | ៦ ៧៤៥ |
| ៩ | ភ្នំសំកុស | ៤ | ៤ | ២៧៤ | ៦៩៥ |
| ១០ | រនាមដូនសំ | ១៣ | ១៣ | ៣ ១០៤ | ៥០០ |
| ១១ | ស្នួល | ១ | ៣ | ២៩៩ | ២ ៤៥៩ |
| ១២ | ឱរ៉ាល់ | ៣ | ១០ | ៧៨៨ | ៥ ៦៧១ |
| ១៣ | ពាមក្រសោប | ៣ | ៣ | ៦១៣ | ១០ ០៤២ |
| ១៤ | លំផាត់ | ៦ | ២៤ | ៣១១ | ៣ ៤០១ ៦៩៨ |
| ១៥ | គូលែន-ព្រហ្មទេព | ១ | ១ | ១៤៧ | ១ ៦៧៤ |
| ១៦ | ភ្នំណាមល្បើរ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ១៧ | ភ្នំព្រេច | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុបរង | | ៣៥ | ៧៤ | ៧ ២៧៦ | ៣១ ១៨៧ ៦៩៨ |
| *តំបន់ការពារទេសភាព* | | | | | |
| ១៨ | បន្ទាយឆ្មារ | ២ | ២ | ១៥៦ | ៩០៧ |
| ១៩ | អង្គរ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ២០ | ព្រះវិហារ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សរុបរង | | ២ | ២ | ១៥៦ | ៩០៧ |
| *តំបន់ប្រើប្រាស់ច្រើនយ៉ាង* | | | | | |
| ២១ | សំឡូត | ៤ | ១១ | ១ ១៦១ | ៦ ៨៩៣ |
| ២២ | ដងពែង | ១ | ៤ | ២៣៦ | ២ ១២០ |
| ២៣ | បឹងទន្លេសាប | ១២ | ៣០ | ៥ ៨១៥ | ៣ ៤៩០ |
| សរុបរង | | ១៧ | ៤៥ | ៧ ២១២ | ១២ ៥០៣ |
| *តំបន់រ៉ាមសា* | | | | | |
| ២៤ | ស្ទឹងត្រែង | ២ | ២ | ១៥៨ | |
| **សរុប** | | ៦៩ CPA | ១៦៧ ភូមិ | ១៨១ ៥០០គ្រួសារ | ៥៥ ២២៦ ៤៧៣ ហិកតា |

**ឧបសម្ព័ន្ធ ៧: តារាងសង្ខេបស្តីពីការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ**

ប្រភព : របាយការណ៍ស្តីពីការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា មេសា ២០០៤

# ការអភិវឌ្ឍន៍នៃការគ្រប់គ្រងធនធានធម្មជាតិ
# ដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា



## ផ្នែក ឃ

## ការរៀនសូត្រពីបទពិសោធន៍នៅមូលដ្ឋាន

# ផ្នែក ឃ ការរៀនសូត្រពីបទពិសោធន៍នៅមូលដ្ឋាន

ជំពូក ១១

បទពិសោធន៍ពីការគ្រប់គ្រងធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា
ផ្អែកលើឧទាហរណ៍ពីករណីសិក្សា
រៀបរៀងដោយ : លោក ស្រី ម៉ារ៉ូណា កញ្ញា ហ៊ូ កល្យាណ និងកញ្ញា Rebecca Kinakin

ជំពូក ១២

បទពិសោធន៍នៅមូលដ្ឋានស្តីពីការស្រាវជ្រាវដោយអនុវត្តន៍សហគមន៍ព្រៃឈើ
រៀបរៀងដោយ : លោក ស៊ុ រ៉ាមុនី លោក ផាន់ កំណាព្យ និង លោក គឹម សារិន

ជំពូក ១៣

ការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស
រៀបរៀងដោយ : លោកបណ្ឌិត Andy Maxwell លោក ជាម មុនី និងក្រុម MOSAIC

ជំពូក ១៤

ផ្សារភ្ជាប់ការគ្រប់គ្រងធម្មជាតិដោយមានការចូលរួមពីសហគមន៍ទៅនឹងដំណើរការកសាងផែនការនៅមូលដ្ឋាន
រៀបរៀងដោយ : លោក Ashish John

ជំពូក ១៥

សិក្សា និងធ្វើការជាមួយគណៈកម្មការសហគមន៍
រៀបរៀងដោយ : លោក គឹម ណុង លោក អ៊ុក លីឃីម និងលោក ឃី អាន

ជំពូក ១៦

ផ្តើមចេញពីការកសាងផែនការឈានទៅការអនុវត្តសកម្មភាព :
តើគណៈកម្មការគ្រប់គ្រងធនធានអាចធ្វើអ្វីបានខ្លះ "នៅថ្នាក់មូលដ្ឋាន" ?
រៀបរៀងដោយ : កញ្ញា Melissa Marschke

រូបថត : Matin von Kaschke / WWF-Cambodia 2004

# ជំពូក ១១ បទពិសោធន៍ពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជាផ្អែកលើឧទាហរណ៍ពីករណីសិក្សា

រៀបរៀងដោយ លោក ស្រី ម៉ារ៉ូណា[១] កញ្ញា ហ៊ូ កល្យាណ[២] និងកញ្ញា Rebecca Kinakin[៣]

## សេចក្តីផ្តើម

មេរៀនជាច្រើនអាចដកស្រង់ចេញពីបទពិសោធន៍ នៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ក្នុងប្រទេសកម្ពុជា ។ ជំពូកនេះប្រើប្រាស់ឧទាហរណ៍ដកស្រង់ចេញពីករណីសិក្សាជាច្រើន ដែលរៀបចំឡើងតាមរយៈកិច្ចសហការសម្របសម្រួលរវាងគម្រោង (Community Based Natural Resource Management Learning Initiative - CBNRM LI) និងដៃគូនានា ដើម្បីបង្ហាញឱ្យឃើញពីបទពិសោធន៍សំខាន់ៗ ដែលទាក់ទងទៅនឹងការចូលរួមការកសាងសមត្ថភាព ការលើកកម្ពស់ការអប់រំ និងការយល់ដឹង ការរៀបចំសហគមន៍ និងការពង្រឹងស្ថាប័ន ការរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ការដោះស្រាយទំនាស់ យេនឌ័រ និងសមធម៌ ការយល់ដឹង និងទម្លាប់អនុវត្តតាមបែបប្រពៃណី ការគាំទ្របណ្តាញសម្រាប់អ្នកអនុវត្តន៍ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management - CBNRM) ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ។ ប៉ុន្តែជាដំបូងយើងសូមផ្តល់ជូនពីប្រវត្តិនៃដំណើរការសរសេរករណីសិក្សារបស់គម្រោងCBNRM LI ជាមុនសិន ។

## ប្រវត្តិនៃដំណើរការ

### ហេតុអ្វីត្រូវឱ្យមានករណីសិក្សា ?

អស់រយៈពេលជាច្រើនឆ្នាំកន្លងមក មានកិច្ចខិតខំប្រឹងប្រែងជាច្រើនពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍បានអនុវត្តនៅក្នុងប្រទេសកម្ពុជា តែទោះជាយ៉ាងនេះក៏ដោយ ការចងក្រងឯកសារខាងផ្នែកនេះនៅមានកម្រិតនៅឡើយ ។ ទំហំការសិក្សាស្រាវជ្រាវអំពីគម្រោង និងការស្រាវជ្រាវផ្ទាល់នៅមូលដ្ឋាន ដែលរៀបចំដោយគម្រោង CBNRM LI រួមជាមួយអ្នកពាក់ព័ន្ធនានាបានបង្ហាញថា ករណីសិក្សាគឺជាប្រភេទនៃការចងក្រងឯកសារដែលមានប្រយោជន៍បំផុត ពីព្រោះករណីសិក្សាទាំងនោះទាក់ទងនឹងដំណើរការស្រាវជ្រាវតាមបែបវិភាគ ដែលជាមូលដ្ឋានសម្រាប់បង្កើនចំណេះដឹងទាំងខាងបច្ចេកទេស និងប្រពៃណី ។ ដូចគ្នាផងដែរ ផលិតផលទទួលបាន គឺជាព័ត៌មានដែលងាយស្រួលប្រើប្រាស់ ហើយមានលក្ខណៈជាទម្រង់ងាយ និងទាមទារការចំណាយធនធានតិចតួច ។ ទោះជាទម្រង់នៃការធ្វើទំនាក់ទំនងប្រភេទនេះមានគោលដៅ ចំពោះបុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ក៏ដោយ តែការអនុវត្តបែបនេះក៏បានផ្តល់ឱកាសសំរាប់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតផងដែរ (ឧទា. វិធានសម្រាប់ ធ្វើការងារ នៅមូលដ្ឋានវីដេអូ និងផ្ទាំងរូបភាព មានគោលដៅចំពោះអ្នកអានច្រើន ។

ចាប់តាំងពីឆ្នាំ ២០០១មក សកម្មភាពចម្បងរបស់គម្រោង CBNRM LI គឺពង្រឹងសមត្ថភាពស្រាវជ្រាវ វិភាគ ចងក្រងឯកសារ និងទទួលមតិយោបល់កែលំអពីក្រុមការងារ បណ្តាញអ្នកគាំទ្រ CBNRM ក្នុងប្រទេស និងតំបន់ ព្រមទាំងផ្តល់ការគាំទ្រដល់ ដំណើរការពិគ្រោះយោបល់សម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ ។

---

[១] លោក ស្រី ម៉ារ៉ូណា គឺជាប្រធានក្រុមគម្រោងCBNRM LI / WWF និងជាប្រធានការិយាល័យ CPAD, MoE

[២] កញ្ញា ហ៊ូ កល្យាណ គឺជាទីប្រឹក្សាគម្រោង CBNRM LI / WWF និងជាអនុប្រធានការិយាល័យ CPAD,MoE

[៣] កញ្ញា Rebecca Kinakin គឺជាអ្នកសម្របសម្រួលគម្រោង Mekong Learning Initiative ដែលមានការិយាល័យនៅ Oxfam America

## តើអ្នកណាចូលរួមក្នុងការសរសេរករណីសិក្សា ?

គម្រោង CBNRM LI ទទួលបានកិច្ចសហការឧបត្ថម្ភពីអង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិនៅកម្ពុជា (WWF) អុកស្វាមអាមេរិក (Oxfam America) មជ្ឈមណ្ឌលអភិវឌ្ឍន៍ និងស្រាវជ្រាវអន្តរជាតិនៃប្រទេសកាណាដា (IDRC) មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើក្នុងតំបន់អាស៊ី និងប៉ាស៊ីភិច (RECOFTC) គម្រោងសិក្សាស្រាវជ្រាវទន្លេមេគង្គ (MLI) និងបណ្តាញសិក្សាស្រាវជ្រាវ និងរៀនសូត្រសម្រាប់ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍ (LEARN/CBCRM) ។ គម្រោងនេះផ្តល់ការគាំទ្រក្នុងការបង្កើនទំនាក់ទំនងក្នុងចំណោមគម្រោងគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋានដែលពង្រឹងអំណាចសហគមន៍មូលដ្ឋានឱ្យចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពតាមរយៈសហគមន៍ព្រៃឈើ សហគ្រប់គ្រងជលផល ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម ។ គោលដៅរួមនៃគម្រោងនេះ គឺជម្រុញ CBNRM ឱ្យក្លាយទៅជាសមាសធាតុចម្បងនៃយុទ្ធសាស្ត្រ និងគោលនយោបាយវិមជ្ឈការ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ។

ករណីសិក្សា និងគម្រោងបង្កើតបណ្តាញការងារ CBNRM LI ត្រូវបានសម្របសម្រួលដោយស្ថាប័នពាក់ព័ន្ធ ក្រុមអ្នកស្រាវជ្រាវស្នូលដែលមានជំនាញផ្សេងៗគ្នាក្នុងប្រទេសកម្ពុជាជាមួយនឹងដៃគូមកពីស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល បណ្តាញការងារ គ្រឹះស្ថានសិក្សា សហគមន៍ និងក្រុមសង្គមស៊ីវិលនានា ដែលធ្វើការក្នុងតំបន់ខ្ពង់រាប ទំនាបកណ្តាល នៅក្នុងដែនទឹកសាប និងតំបន់ឆ្នេរ ។

## យុទ្ធសាស្ត្ររបស់គម្រោង CBNRM LI ក្នុងការពង្រីកការសរសេរករណីសិក្សា

ឧបសម្ព័ន្ធទី១ ផ្តល់ទិដ្ឋភាពទូទៅពីដំណើរការ និងសកម្មភាពសំខាន់ៗជាច្រើនក្នុងការសរសេរករណីសិក្សា ដែលក្នុងនោះសិក្ខាសាលាបណ្តុះបណ្តាលលើកទីមួយបានរៀបចំឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០១ នៅខេត្តសៀមរាប ។ វគ្គបណ្តុះបណ្តាលនេះបានធ្វើឱ្យអ្នកពាក់ព័ន្ធជាច្រើនជួបជុំគ្នា ដើម្បីធ្វើការពិភាក្សាពីបទពិសោធន៍ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ (NRM) ការវិភាគទស្សនទានស្តីពី CBNRM និង រៀនសូត្រពីរបៀបសរសេរករណីសិក្សាដោយប្រើប្រាស់ដំណើរការសរសេរករណីសិក្សាទាំងដប់ជំហាន (សូមអានឧបសម្ព័ន្ធទី២ ព្រោះថា អ្នកទាំងនោះមិនបានធ្វើការផ្ទាល់រួមគ្នាអស់រយៈពេលមួយទសវត្សរ៍មកហើយ ។ របាយការណ៍មួយមានចំណងជើងថា "ប្រវត្តិរឿងស្តីពីបឹងទន្លេសាប" និងវិធាននៃរបៀបសរសេរករណីសិក្សាដែលបានរៀបរៀងឡើង រួមជាមួយបទពិសោធន៍វិជ្ជមាននានា បានបង្ហាញឱ្យឃើញពីតម្រូវការឱ្យមានការរៀបចំសិក្ខាសាលាមួយផ្សេងទៀតនៅខេត្តរតនគិរីក្នុងខែវិច្ឆិកា ឆ្នាំ២០០១ ។ សិក្ខាសាលានេះបានផលិតរបាយការណ៍បណ្តុះបណ្តាលផ្អែកលើករណីសិក្សាពី "ប្រវត្តិរឿងស្តីពីតំបន់ខ្ពង់រាបរតនគិរី" និងសំណៅកែសម្រួលនៃក្បួនខ្នាតណែនាំអំពីរបៀបសរសេរករណីសិក្សា ។

បន្ទាប់ពីព្រឹត្តិការណ៍នេះ តំបន់ចំនួនដប់នៅក្នុងប្រទេសកម្ពុជាដែលតំណាងឱ្យតំបន់ខ្ពង់រាប តំបន់ទំនាបកណ្តាល តំបន់ដែនទឹកសាប និងតំបន់ឆ្នេរត្រូវបានជ្រើសរើសសម្រាប់ការសរសេរករណីសិក្សា (សូមអានឧបសម្ព័ន្ធទី៣ ។ បញ្ហាចម្បងជាច្រើនត្រូវបាន

ធ្វើឡើងដោយដៃគូនានា ដែលធ្វើការជិតស្និទ្ធជាមួយសហគមន៍ ។ ឧទាហរណ៍អំពីបញ្ហាទាំងនោះ មានជាអាទិ៍ សមធមិ យេនឌ័រ និងការគ្រប់គ្រងព្រៃឈើ ការដោះស្រាយទំនាស់និងសហគមន៍នេសាទ និងការធ្វើកសិកម្មពនេចរក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ។ ក្នុងអំឡុងខែឧសភា ឆ្នាំ២០០២ គម្រោង CBNRM LI ធ្វើកិច្ចសហការសម្របសម្រួលសិក្ខាសាលាសំយោគ និងឆ្លុះបញ្ចាំងមួយនៅក្នុងខេត្តកោះកុង ដើម្បីពិនិត្យឡើងវិញនូវសេចក្តីព្រាងករណីសិក្សា ជាមួយនឹងដៃគូនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ។ ចុងក្រោយបំផុតនៅខែវិច្ឆិកា ឆ្នាំ២០០២ សិក្ខាសាលា CBNRM ថ្នាក់ជាតិមួយត្រូវបានរៀបចំឡើងនៅទីក្រុងភ្នំពេញ ដើម្បីបង្ហាញនូវករណីសិក្សា និងបទពិសោធន៍នានា ដល់អ្នកចូលរួមជាច្រើន រួមទាំងអ្នករៀបចំគោលនយោបាយជាន់ខ្ពស់ផងដែរ ។

ក្នុងខែតុលា ឆ្នាំ២០០៣ ក្រោមកិច្ចសហការជាមួយគម្រោងចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង (PMMR) និងគម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) គម្រោង CBNRM LI បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលជាលើកទី៣ ។ សិក្ខាសាលានេះបានឆ្លើយតបនឹងតម្រូវការរបស់ដៃគូ និងមានបំណងពិនិត្យមើល ព្រមទាំងពិភាក្សាលើ "ប្រធានបទសំខាន់ៗ" ឬ បញ្ហាប្រឈមចំពោះការគ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេសកម្ពុជា ។ សិក្ខាសាលានោះបានផលិតចេញនូវករណីសិក្សាថ្មីមួយឈុតផ្សេងទៀត ។ អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ដែលចាត់ចែងឡើងដោយអ្នកតំណាងគម្រោង CBNRM LI បានបង្កើតករណីសិក្សាមួយផ្សេងទៀត ធ្វើឱ្យករណីសិក្សាសរុបដែលបានរៀបចំឡើងនៅក្នុងដំណាក់កាលថ្មីនេះមានចំនួនដល់ទៅប្រាំបី (សូមអានឧបសម្ព័ន្ធទី៤ ។ មកទល់បច្ចុប្បន្ន មានករណីសិក្សាចំនួនដប់ប្រាំបីត្រូវបានបោះពុម្ព (សូមអានឧបសម្ព័ន្ធទី៥ ។

នៅពេលនោះ RECOFTC បានដាក់បញ្ចូលគ្នានូវបទពិសោធន៍ដែលទទួលបានពីដំណើរការនេះ និងបានបោះពុម្ពផ្សាយសៀវភៅជំនួយស្មារតីអំពីការសរសេរករណីសិក្សា សម្រាប់ប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលកម្រិតតំបន់។ ដោយមានការលើកទឹកចិត្ត តាមរយៈជោគជ័យនៃ CBNRM ដៃគូផ្សេងៗទៀតក្នុងតំបន់ ដូចជាគម្រោង MLI ( Mekong Learning Initiative ) សិក្សាស្រាវជ្រាវតំបន់ទន្លេមេគង្គ បានចាប់ផ្តើមប្រើប្រាស់ករណីសិក្សា ជាវិធីសាស្ត្រ សម្រាប់ការចែករំលែកមេរៀន និងបទពិសោធន៍ ជាពិសេសទាក់ទងជាមួយការងារគម្រោងនៅភាគខាងត្បូងនៃប្រទេសឡាវ និងតំបន់ដីសណ្តនៃប្រទេសវៀតណាម[4] ។ ដំណើរការសរសេរករណីសិក្សាកំពុងទទួលបាននូវការចាប់អារម្មណ៍ពីសំណាក់អ្នកពាក់ព័ន្ធជាច្រើន។ ថ្មីៗនេះ និស្សិតពីសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមចូលរួមក្នុងការបណ្តុះបណ្តាលនេះផងដែរ ។

## មេរៀនទទួលបាន

### ការចូលរួម

មកទល់បច្ចុប្បន្ន វិធីសាស្ត្រដោយមានការចូលរួម ដែលអនុវត្តក្នុងគម្រោង CBNRM LI បានជួយឱ្យមានកិច្ចសហការ ដើម្បី កំណត់បញ្ហាសម្រាប់ការស្រាវជ្រាវ ការសាងទំនាក់ទំនងរវាងក្រុម និងបុគ្គលនានា ព្រមទាំងគាំទ្រក្នុងការអភិវឌ្ឍគោលនយោបាយឱ្យបានល្អប្រសើរផងដែរ ។

[4] ចំពោះព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួល MLI គឺកញ្ញា Recbecca Kinakin

គម្រោងចូលរួមគ្រប់គ្រងព្រៃកោងកាង (PMMR) គឺជាគម្រោងដែលផ្តួចផ្តើម និងគាំទ្រដោយក្រសួងបរិស្ថាន និងអង្គការ IDRC ។ PMMR ធ្វើការជាមួយសហគមន៍មូលដ្ឋាន ដើម្បីស្វែងយល់ប្រសើរឡើងអំពីបញ្ហាការចិញ្ចឹមជីវិត និងបញ្ហាគ្រប់គ្រង ក្នុងដែនជម្រកសត្វព្រៃពាមក្រសោម ដែលជាប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលលាតសន្ធឹង លើផ្ទៃដី ២៣ ៧៥០ ហិកតា និងស្ថិតនៅក្នុងស្រុកចំនួនបី (Marschke and Kim, ២០០១) ។ Marschke and Kim (២០០១) ពិពណ៌នាអំពីវិធីសាស្ត្រគ្រប់គ្រងដោយមានការចូលរួមតាមលក្ខណៈបន្សាំ ឬវិធីសាស្ត្រ "រៀនសូត្របណ្តើរ និងអនុវត្តបណ្តើរ" គឺជា ស្នូលនៃការងាររបស់គម្រោង PMMR ក្នុងការធ្វើឱ្យអ្នកអនុវត្តន៍នានាចូលរួមនៅក្នុងការគ្រប់គ្រងធនធាន ដោយឈរលើទស្សនៈទាំងពីររបស់អ្នកប្រើប្រាស់ធនធាន និងស្ថាប័ន ។

វិធីសាស្ត្រដោយមានការចូលរួម ផ្តល់ឱ្យនូវការធ្វើពិសោធន៍ ការសម្របសម្រួល និងកាកំណត់បញ្ហា ដែលមានឥទ្ធិពលចំពោះសហគមន៍តំបន់ឆ្នេរ និងបរិស្ថានរបស់សហគមន៍ទាំងនោះ (Ibid) ។ តាមវិធីសាស្ត្របែបនេះ ការចូលរួមដែលមានតម្លាភាព និងការចែករំលែកព័ត៌មានជាចំហ ត្រូវបានមើលឃើញថាជាវិធីមួយដើម្បីបង្កើនជំនឿទុកចិត្ត ដែលជួយសម្រេចអាណត្តិរបស់សហគមន៍ អង្គការ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ព្រមទាំងជួយជម្រុញការងារវិមជ្ឈការផងដែរ ។

ឧទាហរណ៍ដទៃទៀតពីករណីសិក្សា ក្នុងភូមិបឹងជន្លេន ខេត្តកណ្តាល បានបង្ហាញថា ទន្ទឹមនឹងការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងគម្រោងនេះ ពេលនេះឱកាសសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលយូរអង្វែងនៅក្នុងតំបន់ក៏កាន់តែកើនឡើងផងដែរ ។ លើសពីនេះ ការអនុវត្តផែនការដោយមានការចូលរួម បានកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាននៃការចូលរួម ពោលគឺការបាត់បង់ពេលវេលាសំរាប់សកម្មភាពរកប្រាក់ចំណូល ។

> ***តម្លាភាពគឺជាកត្តាសំខាន់សម្រាប់គ្រប់វិធីសាស្ត្រដោយមានការចូលរួម ។ បើពុំមានការចែករំលែកចំណេះដឹង ព័ត៌មាន និងបទពិសោធន៍ឱ្យបានទូលំទូលាយទេនោះ អ្នកពាក់ព័ន្ធពុំអាចកសាងការជឿទុកចិត្តបានឡើយ ហើយវិធីសាស្ត្រផ្អែកលើការចូលរួមនឹងទទួលបរាជ័យ ។***

## ការកសាងសមត្ថភាព

វគ្គបណ្តុះបណ្តាល សិក្ខាសាលា ការប្រជុំបណ្តាញ ទស្សនកិច្ចសិក្សា និងឱកាសនៃការរៀនសូត្រផ្សេងៗទៀតរបស់គម្រោង CBNRM LI ត្រូវបានទទួលស្គាល់ថាមានប្រជាប្រិយភាពខ្ពស់ និងទទួលបានលទ្ធផលល្អប្រសើរ ។ ព្រឹត្តិការណ៍ទាំងនេះ ត្រូវបានរៀបចំឡើង ដើម្បីប្រមូលអ្នកគាំទ្រ និងអ្នកអនុវត្តន៍ CBNRM មកជួបជុំគ្នា និងដើម្បីពង្រឹងជំនាញ និងចំណេះដឹងសម្រាប់ផ្នែកផ្សេងៗ ជាអាទិ៍ ការស្រាវជ្រាវ ការវិភាគ ការសរសេរករណីសិក្សា ការតាមដាន ច្បាប់ពាក់ព័ន្ធ និងអេកូឡូស៊ី ដែលអាចអនុវត្តដោយផ្ទាល់ ដែលអាចយកទៅប្រើប្រាស់បានភ្លាមៗ តម្រូវតាមស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន ។ ដូចនេះផងដែរ ការបណ្តុះបណ្តាលពីវិធីសាស្ត្រ "រៀនសូត្របណ្តើរ និងអនុវត្តបណ្តើរ" បានផ្តល់ឱកាសដល់បុគ្គលដែលមិនមានជំនាញខ្ពង់ខ្ពស់ឱ្យរៀនបានតាមលទ្ធភាពរបស់ខ្លួនដើម្បីអាចបន្តការពង្រឹងសម្ថភាពផ្អែកលើមូលដ្ឋាននៃចំណេះដឹង និងចែករំលែកបទពិសោធន៍រវាងគ្នា ។

ដូចដែល Marschke (២០០២) បានពិពណ៌នាអំពីបទពិសោធន៍ PMMR រួចមកហើយថា "អ្នកភូមិមានបំណងរៀនសូត្រ និងទទួលចំណេះដឹងបានច្រើនបំផុតតាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក ។ លើសពីនេះអ្នកភូមិរីករាយក្នុងការ "ធ្វើសកម្មភាពនានា" ពួកគាត់ចង់ឱ្យមានសកម្មភាពជាក់ស្តែង ដូចជាការល្បាត ការដាំដើមឈើឡើងវិញ និងសាកល្បងនូវ ជម្រើសសម្រាប់ការចិញ្ចឹមជីវិត " (Ibid) ។ ការផ្តល់សិទ្ធិអំណាច និងការបណ្តុះគំនិតអោយមានភាពជាម្ចាស់កម្មសិទ្ធិ អាចកើតឡើង តាមរយៈដំណើរការបែបនេះ និងតាមរយៈការចូលរួមដោយស្ម័គ្រចិត្តក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ដូចគ្នានេះដែរ ការបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងសហគមន៍នៅឧទ្យានជាតិ រាម និងដែនជម្រកសត្វព្រៃពាមក្រសោប បានពង្រឹងសមត្ថភាពសហគមន៍ ហើយតាមរយៈសិក្ខាសាលា នេះ សហគមន៍បានរៀនសូត្រពីការកសាងផែនការគ្រប់គ្រងដោយខ្លួនឯងផ្ទាល់ ។

ការពង្រឹងសមត្ថភាពមិនត្រឹមតែជាប្រការចាំបាច់នៅថ្នាក់សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រការចាំបាច់ផងដែរសម្រាប់ស្ថាប័នរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ និងសម្រាប់នាយកដ្ឋានបច្ចេកទេសផង ដើម្បីធ្វើការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបទ ។ ដូចដែលបានរៀនសូត្រតាមរយៈករណីសិក្សានៅភូមិបឹងជន្លេន ខេត្តកណ្តាល ការពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សានៅតាមកន្លែងផ្សេងៗទៀត អាចធ្វើឱ្យគណៈកម្មការគ្រប់គ្រងរៀនសូត្របានពីបទពិសោធន៍ថ្មីៗ ពីការគ្រប់គ្រងធនធានជលផល ដែលបន្ទាប់មកអ្នកទាំងនោះអាចយកមកអនុវត្តនៅភូមិបឹងជន្លេន ។ ទង្វើបែបនេះនាំឱ្យមានការចែករំលែកជំនាញផ្ទាល់ខ្លួនជាមួយអ្នកផ្សេងទៀត ។

***ការពង្រឹងសមត្ថភាពត្រូវធ្វើឡើងដើម្បីកែទម្រង់លើរបៀបធ្វើសេចក្តីសម្រេចដែលគ្មានប្រសិទ្ធិភាព លើកទឹកចិត្តឱ្យមានការប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួម និងវិមជ្ឈការ ដើម្បីសម្របសម្រួលឱ្យមានការពិភាក្សាជាមួយសហគមន៍ និងក្រុមដទៃទៀត ព្រមទាំងធ្វើការផ្លាស់ប្តូរអាកប្បកិរិយា ។***

## ការលើកកំពស់ការអប់រំ និងការយល់ដឹង

បទពិសោធន៍នានាបានបង្ហាញថា កំណើនការអប់រំ និងការយល់ដឹងអំពី CBNRM បានជួយកាត់បន្ថយសកម្មភាពល្មើសច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ។ ភស្តុតាងទាំងនេះ អាចកត់សំគាល់ឃើញមាននៅក្នុងករណីសិក្សាជាច្រើន ជាពិសេស ករណីសិក្សានៅក្នុងខេត្តស្ទឹងត្រែង (Khai and Thai, 2002) ករណីសិក្សាអំពីឆ្នេរភាគខាងត្បូងនៃឧទ្យានជាតិរាម និងដែនជម្រកសត្វព្រៃពាមក្រសោប (Chiy *et al*, 2002) និងក្នុងតំបន់ខ្ពង់រាបខេត្តរតនគិរី (Cheam *et al.*, 2001) ។

ករណីសិក្សាភាគច្រើន ចង្អុលបង្ហាញពីតម្រូវការឱ្យមានយុទ្ធនាការលើកកំពស់ការអប់រំ និងការយល់ដឹងបន្ថែមទៀត ព្រមទាំងការផ្សព្វផ្សាយព័ត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ។ សកម្មភាពលើកកំពស់ការអប់រំ និងការយល់ដឹងត្រូវតែប្រើប្រាស់ ភាសា និងវិធីសាស្ត្រដែលសមស្របសម្រាប់ក្រុមអ្នកពាក់ព័ន្ធគោលដៅ។ លើសពីនេះ តាមរយៈទស្សនកិច្ចសិក្សា និងការរៀនសូត្រ និងឱកាសចែករំលែក បានផ្តល់អនុសាសន៍ផងដែរឱ្យមានការបង្កើនការផ្សាយ និងការពង្រីកចំណេះដឹងបន្ថែមទៀត ។

***ដើម្បីឱ្យការលើកកម្ពស់ការអប់រំ និងការយល់ដឹងអនុវត្តប្រកបដោយប្រសិទ្ធិភាព ចាំបាច់ត្រូវផ្សព្វផ្សាយព័ត៌មានឱ្យដល់សហគមន៍ តាមរបៀបដែលពួកគាត់ងាយយល់ និងអាចប្រើប្រាស់បាន ។***

## ការរៀបចំសហគមន៍ និងស្ថាប័ន

ការរៀបចំសហគមន៍ និងស្ថាប័នសម្រាប់ CBNRM ក្នុងប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ជាផ្នែកសំខាន់ក្នុងដំណើរការនេះ ។ ឧទាហរណ៍មួយដែលដកស្រង់ចេញពីករណីសិក្សាស្តីពីការចូលរួមដោយសហគមន៍ក្នុងការគ្រប់គ្រងការនេសាទក្នុងខេត្តស្ទឹងត្រែង បានបង្ហាញអំពីរបៀបដែលប្រជាពលរដ្ឋមូលដ្ឋានបានរៀបចំបង្កើតគណៈកម្មការសហគមន៍នេសាទ ដើម្បីកាត់បន្ថយការនេសាទល្មើសច្បាប់ ដែលនាំឱ្យមានកំណើនការចូលរួមដែលមាននិរន្តរភាពជាងនេះរបស់ពួកគេក្នុងការគ្រប់គ្រងការនេសាទ និងដើម្បីដោះស្រាយជម្លោះរវាងអ្នកភូមិ និងអ្នកនេសាទមកពីខាងក្រៅ ។ ទោះបីជាយ៉ាងណាក៏ដោយ ឧបសគ្គចំពោះការរៀបចំសហគមន៍នៅខេត្តស្ទឹងត្រែង គឺថាមានការយល់ឃើញថា គណៈកម្មការ CBNRM នៅមូលដ្ឋាន គឺជាគណបក្សនយោបាយ ដូច្នេះប្រជាជនបដិសេធពុំចូលរួមសហការជាមួយគណៈកម្មការនេះទេ ។

***ទៅថ្ងៃអនាគត មានការងារជាច្រើនដែលចាំបាច់ត្រូវអនុវត្ត ដើម្បីបង្កើតស្ថាប័នមូលដ្ឋាន និងដោះស្រាយគម្លាតភាពបង្កើនការយល់ដឹង និងបញ្ជាក់អំពីតួនាទីរបស់ស្ថាប័នទាំងនេះ ក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពី CBNRM ។***

## ការដោះស្រាយទំនាស់

ការបង្កើតយន្តការប្រកបដោយប្រសិទ្ធិភាពនៅមូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិមានសារៈសំខាន់ណាស់ សម្រាប់ដោះស្រាយទំនាស់ ហើយការងារនេះជាប្រធានបទដែលលើកឡើងច្រើនជាងគេនៅក្នុងចំណោមករណីសិក្សាទាំងអស់ ។ នៅកន្លែងណាដែលមាន ធនធានធម្មជាតិ កន្លែងនោះគឺជាប្រភពនៃទំនាស់ទាក់ទងនឹងការប្រើប្រាស់ធនធាន កម្មសិទ្ធិលើធនធាន និងការគ្រប់គ្រងធនធានទាំងនោះ ។ ករណីសិក្សាមួយនៅឧទ្យានជាតិវាមស្តីពីការដោះស្រាយទំនាស់ ហើយសហគមន៍នេសាទបានបង្ហាញពីបទពិសោធន៍ គន្លឹះដែលអាចដោះស្រាយភាពមិនចុះសម្រុងគ្នាក្នុងការគ្រប់គ្រងព្រៃកោងកាង ដោយតម្រូវឱ្យមានការចូលរួមពីសំណាក់ សហគមន៍មូលដ្ឋាន និងការគាំទ្ររបស់អាជ្ញាធរមូលដ្ឋាន អ្នកជំនាញ និងស្ថាប័នពាក់ព័ន្ធនានា ។

ករណីសិក្សាផ្សេងទៀតពីស្រុកស្រែអំបិល ខេត្តកោះកុង (Tong et al, 2003) បានបង្ហាញពីកិច្ចប្រឹងប្រែងយ៉ាងខ្លាំងរបស់សមាជិកគណៈកម្មការសហគមន៍ផងដែរ ក្នុងការទប់ស្កាត់ទំនាស់ ជាពិសេសសកម្មភាពប្រព្រឹត្តបទល្មើសនានា ។ គណៈកម្ម-ការសហគមន៍ព្រៃឈើ និងសមាជិករបស់ខ្លួនជឿជាក់ថា ប្រសិនពួកគេពង្រឹងកិច្ចសហការរវាងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ ពួកគេអាចកាត់បន្ថយ ឬបញ្ឈប់រាល់សកម្មភាពអនាធិបតេយ្យនានាដែលកើតឡើងក្នុងតំបន់សហគមន៍ព្រៃឈើ ។

ទម្ងៃបែបនេះអាចជម្រុញឱ្យអ្នកភូមិចូលរួមកាន់តែពេញលេញក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ ហើយជឿជាក់ថាពួកគេអាចទទួលផលប្រយោជន៍ ក្នុងនាមជាសហគមន៍ផងដែរ ។

*ការបង្កើតយន្តការរលូនសម្រាប់ដោះស្រាយទំនាស់ ដែលជាផ្នែកមួយនៃការពង្រឹងស្ថាប័នប្រពៃណី/មូលដ្ឋាន និងទំលាប់ដែលមានស្រាប់សម្រាប់ដោះស្រាយទំនាស់ អាចបង្កើនឱ្យមានការបើកទូលាយ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពសហគមន៍ ដូចជា ការគ្រប់គ្រងសហគមន៍ព្រៃឈើជាដើម ។*

## ការរៀបចំក្របខ័ណ្ឌច្បាប់ និងគោលនយោបាយគាំទ្រ

ករណីសិក្សាមួយ ពីខេត្តរតនគិរី ដែលបកស្រាយអំពីការអនុវត្តបទបញ្ជាផ្ទៃក្នុងសហគមន៍ព្រៃឈើ (Kim and Real, 2002) បង្ហាញថា ដើម្បីអនុវត្តបទប្បញ្ញត្តិនានាឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវឱ្យមានការពាក់ព័ន្ធ និងការយល់ដឹងឱ្យបានច្បាស់អំពីសហគមន៍មូលដ្ឋាន ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ។ ចំណុចសំខាន់មួយទៀតគឺ លក្ខន្តិកៈទាំងនេះត្រូវតែស្របគ្នាជាមួយបញ្ញត្តិ ច្បាប់នានានៅក្នុងប្រទេស ។ ការលំបាកមួយដែលត្រូវប្រឈមគឺថា មិនទាន់មានការពង្រឹង លក្ខន្តិកៈសហគមន៍ព្រៃឈើ និងលក្ខន្តិកៈសហគមន៍នេសាទនៅថ្នាក់ជាតិនៅឡើយទេ ទោះបីអាជ្ញាធរខេត្តបាន ទទួលស្គាល់ហើយក៏ដោយ ។ ដូចគ្នានេះដែរ "ប្រការចាំបាច់គឺត្រូវឱ្យមានការផ្សព្វផ្សាយ និងការបកស្រាយឱ្យបានច្បាស់លាស់ និងទូលំទូលាយ អំពីលក្ខន្តិកៈសម្រាប់សហគមន៍មូលដ្ឋាន និងសម្រាប់អ្នកមកពីខាងក្រៅសហគមន៍ " (Ibid,:7) ។

អ្វីដែលត្រូវការផងដែរនោះគឺគោលនយោបាយ និងនីតិវិធីដែលគាំទ្រវិមជ្ឈការ ដែលជម្រុញឱ្យមានការចូលរួម និងកិច្ចសហការរបស់អ្នកពាក់ព័ន្ធនៅគ្រប់កម្រិត នៅក្នុងការរៀបចំផែនការការគ្រប់គ្រង ការអនុវត្ត ការតាមដាន និងការវាយតម្លៃ ។ លើសពីនេះក្នុងករណីខ្លះ ប្រការចាំបាច់គឺត្រូវផ្តល់សិទ្ធិកាន់កាប់ស្របច្បាប់ទៅឱ្យសហគមន៍នានា ផ្អែកលើទម្លាប់ប្រើប្រាស់ជាប្រពៃណី លទ្ធភាពប្រើប្រាស់ និងទីកន្លែងដែលពួកគេធ្លាប់ចូលទៅប្រើប្រាស់ ។

*ប្រការចាំបាច់គឺត្រូវថែងឱ្យច្បាស់លាស់អំពីអាណត្តិរបស់រដ្ឋាភិបាលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ក៏ដូចជាច្បាប់ "ប្រកបដោយអំណាច" ដើម្បីជួយគាំទ្រការគ្រប់គ្រង និងការពង្រឹងការអនុវត្តលក្ខន្តិកៈនៅមូលដ្ឋាន កាត់បន្ថយសកម្មភាពល្មើសច្បាប់ផ្តល់សិទ្ធិស្របច្បាប់ ( ជាពិសេសដល់សហគមន៍ជនជាតិដើម និងការលើកទឹកចិត្តឱ្យមានការធ្វើវិមជ្ឈការ ។*

## យេនឌ័រ និងសមធម៌

ទោះបីបញ្ហាយេនឌ័រគឺជាទស្សនទានថ្មីសម្រាប់ការស្រាវជ្រាវក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ករណីសិក្សាអំពីយេនឌ័រក្នុងសហគមន៍ព្រៃឈើ (Sun and Kouk, 2002) នៅខេត្តពោធិ៍សាត់បានបង្ហាញថា ការគ្រប់គ្រងសហគមន៍ព្រៃឈើ

ទទួលជោគជ័យចាំបាច់ត្រូវឱ្យមានការចូលរួមទាំងបុរស និងស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងក្នុងការអនុវត្ត ។ សេចក្តីសន្និដ្ឋាននេះបានដកស្រង់ចេញពីការទទួលស្គាល់ថា បុរស និងស្ត្រីបានប្រើប្រាស់ និងមានការយល់ដឹង អំពីធនធានព្រៃឈើខុសៗគ្នា ហើយមានចំណេះដឹង និងទំនាក់ទំនងខុសៗគ្នាជាមួយព្រៃឈើ ។ ករណីសិក្សានេះបានផ្តល់អនុសាសន៍ឱ្យធ្វើការអង្កេតបន្ថែមទៀតទៅលើតួនាទីយេនឌ័រ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងសមធម៌ក្នុងការបែងចែកផលប្រយោជន៍ និងទទួលខុសត្រូវចំពោះការងារ CBNRM ។

***ដើម្បីធ្វើឱ្យ CBNRM កាន់តែឆ្លុះបញ្ចាំងអំពីស្ថានភាពពិតនៅមូលដ្ឋាន ចាំបាច់ត្រូវយកចិត្តទុកដាក់កាន់តែច្រើនអំពីចំណងមិត្តភាព និងសន្ទុះការងារសង្គមក្នុងសហគមន៍ (ឧទាហរណ៍ រវាងក្រុមមនុស្សដែលមានភាពខុសគ្នាខាងសេដ្ឋកិច្ច យេនឌ័រ អាយុ ជនជាតិ វណ្ណៈ ឥទ្ធិពល និងលទ្ធភាព ។ ដើម្បីធ្វើឱ្យការងារ CBNRM កាន់តែមានលក្ខណៈសមរម្យទៅនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន ។***

## ចំណេះដឹង និងការអនុវត្តជាលក្ខណៈប្រពៃណី

ការប្រមូលពត៌មានក្នុងករណីសិក្សាជាច្រើនអំពី CBNRM បង្ហាញថា ចំណេះដឹង និងការអនុវត្តជាលក្ខណៈប្រពៃណីគឺជាប្រភពដ៏សំខាន់ និងមានប្រយោជន៍សម្រាប់ការយល់ដឹងស្តីពីការគ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេសកម្ពុជា។ ករណីសិក្សាមួយស្តីពីកសិកម្មពនេចរក្នុងខេត្តមណ្ឌលគីរីបានបង្ហាញអំពីដំណើរការនៃទម្លាប់ធ្វើកសិកម្មតាមប្រពៃណី និងបានបង្ហាញផងដែរថាអ្នកដទៃបានយល់ដឹងតិចតួចតែប៉ុណ្ណោះអំពីការរស់នៅ និងចំណេះដឹងរបស់ជនជាតិដើម ឬអំពីផលប៉ះពាល់នៃទម្លាប់ទាំងនេះ ។

***ជាទូទៅ អ្នកពាក់ព័ន្ធទាំងឡាយក្នុងប្រទេសកម្ពុជា បានយល់ដឹងត្រឹមតិចតួចប៉ុណ្ណោះអំពីចំណេះដឹង និងទម្លាប់ជាលក្ខណៈប្រពៃណី ហេតុនេះគេចាំបាច់ត្រូវធ្វើការស្វែងយល់បន្ថែមអំពីកត្តាទាំងនេះ ដើម្បីឱ្យឃើញថាតើចំណេះដឹង និងទម្លាប់ទាំងនោះអាចរួមចំណែកបែបណាក្នុងការថែរក្សា ឬកែលំអប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ ។***

## គាំទ្របណ្តាញការងារសម្រាប់អ្នកអនុវត្តន៍ CBNRM

ជាទូទៅ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងរដ្ឋាភិបាលនៅទន់ខ្សោយនៅឡើយ ហើយទាមទារអោយមានការពង្រឹងទំនាក់ទំនងនេះឱ្យបានល្អរវាង និងក្នុងចំណោមក្រុមនានាទាំងនេះ។

គ្រប់ករណីសិក្សាទាំងអស់បានស្នើអោយមានការបង្កើតនិងកែលំអចំណងទាក់ទង និងបណ្តាញការងារសម្រាប់អ្នកគាំទ្រ និងអ្នកអនុវត្ត CBNRM ទំនាក់ទំនងខ្សែបណ្តោយ(រវាង និងក្នុងចំណោមសហគមន៍ ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅមូលដ្ឋាន និងទំនាក់ទំនងខ្សែទទឹង (រវាងអង្គការនានា ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ ។ ការធ្វើបែបនេះមានសារៈសំខាន់សម្រាប់ការចែករម្លែកមេរៀន និងពង្រីកបទពិសោធន៍ដែលទទួលបានជោគជ័យឱ្យបានទូលំទូលាយ ។ ករណីសិក្សាមួយក៏បានស្នើផងដែរឱ្យបង្កើត បណ្តាញគាំទ្រដែលផ្តោតលើទំនាក់ទំនងរវាងស្ត្រី និងបរិស្ថាន (Sun and Kouk, 2002) ។

***ការគាំទ្រដល់សមត្ថភាពការងារត្រូវចាំបាច់ណាស់ក្នុងការធ្វើអោយការអនុវត្ត CBNRM មានប្រសិទ្ធិភាព អាចផ្សះបញ្ជាំងបាន អាចអនុវត្តនៅតំបន់ផ្សេងៗទៀត និងមាននិរន្តរភាពក្នុងប្រទេសកម្ពុជា ។***

### ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (Participation Land Use Planning - PLUP)

ដូចដែលបានបង្ហាញក្នុងករណីនៃភូមិ ទួលសម្បូណ៍ ដែលការអនុវត្តយុទ្ធសាស្ត្រ PLUP (សូមអានជំពូកទី៩ បានបង្កើនការចូលរួមរបស់អ្នកភូមិ និងនាយកដ្ឋានពាក់ព័ន្ធទៅក្នុងកិច្ចការពារព្រៃឈើ ហើយក៏បានទប់ស្កាត់សកម្មភាពល្មើសច្បាប់ជាច្រើនប្រភេទ ទាំងនៅក្នុង និងក្រៅតំបន់សហគមន៍ព្រៃឈើផងដែរ (Ouk and Ou, 2003 ។ ការប្រើប្រាស់វិធាន PLUP ក្នុងការដោះស្រាយបញ្ហាប្រើប្រាស់ដីធ្លីជាមួយអ្នកពាក់ព័ន្ធ មុនពេលដាក់ជូនផែនការទាំងនេះដើម្បីសុំការឯកភាពពីអ្នកនយោបាយ បានជួយដោះស្រាយបញ្ហាទន្ទ្រានដីព្រៃក្នុងតំបន់នេះ ។ លទ្ធផលចម្បងនៃករណីសិក្សានេះបានបង្ហាញថា ដើម្បីដោះស្រាយទំនាស់នេះ គេត្រូវការជាចាំបាច់នូវការទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបង្កើតការគ្រប់គ្រងធនធានធម្មជាតិ ។ ការទទួលស្គាល់បែបនេះក៏មានសារៈសំខាន់ដូចគ្នានឹងការជម្រុញ និងការលើកចិត្តឱ្យសហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានព្រៃឈើដែរ ។

***PLUP ជួយជម្រុញការងារ CBNRM ដោយរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ទៅក្នុងដំណើរការរៀបចំផែនការគ្រប់គ្រងធនធាននៅមូលដ្ឋាន និងដោះស្រាយទំនាស់នានាដែលអាចកើតមានឡើង ។ បន្ទាប់មក លទ្ធផលទាំងនេះអាចយកទៅបញ្ចូលទៅក្នុងផែនការ និងគោលនយោបាយជាតិ ។***

### ចំណងទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ (CC)

ករណីសិក្សាក្នុងស្រុក ជុំគីរី បានបង្ហាញថា ក្រុមប្រឹក្សាឃុំ-សង្កាត់គួរដើរតួជាអ្នកសម្របសម្រួលយ៉ាងសំខាន់ក្នុងដំណើរការរៀបចំ និងអនុវត្តន៍សហគមន៍ព្រៃឈើ ។ នេះដោយសារសហគមន៍ទាំងនោះបានកំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់សមាជិក នីមួយៗរួចមកហើយ (*Im, et al* 2003) ។ នៅពេលមានការអនុវត្តតួនាទីនេះបានត្រឹមត្រូវ គេអាចបង្កើនល្បឿននៃការរៀបចំសហគមន៍ព្រៃឈើ ដោយអាចទទួលផលវិជ្ជមាន ។ ដោយសារមានភាពសកម្មនឹងការងារ ក្រុមប្រឹក្សាឃុំ-សង្កាត់អាចទទួលការគាំទ្រកាន់តែច្រើនពីសមាជិកសហគមន៍ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើក្រុមប្រឹក្សាឃុំ-សង្កាត់ប្រើប្រាស់តួនាទី និងឋានៈរបស់ខ្លួន សម្រាប់ផលប្រយោជន៍បុគ្គលវិញនោះ ការជឿទុកចិត្ត និងការចូលរួមរបស់ប្រជាជននៅមូលដ្ឋានក្នុងដំណើរអភិវឌ្ឍសហគមន៍ នឹងមានត្រឹមកម្រិតទាបតែប៉ុណ្ណោះ ។

***ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការសម្រុះសម្រួលទំនាស់នានា ទន្ទឹមនឹងធ្វើការជម្រុញយ៉ាងសកម្ម និងសម្របសម្រួលយន្តការសម្រាប់ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន សង្គមស៊ីវិល អង្គការនានា និងក្រុមសហគមន៍ផងដែរ ។***

## ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

ក្នុងកិច្ចខិតខំប្រឹងប្រែងការពារ និងអភិរក្សធនធានធម្មជាតិនេះ អ្នកពាក់ព័ន្ធនានាមានការងឿងឆ្ងល់អំពីថាតើសហគមន៍នានាអាចរក្សាស្ថេរភាពនៃជីវភាពរស់នៅរបស់ពួកគាត់តាមរបៀបណា។ ករណីសិក្សានេះបានបង្ហាញឱ្យឃើញថា សហគមន៍មានចំណាប់អារម្មណ៍ក្នុងការស្វែងរកជម្រើសនានាសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។ ក្នុងគម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាងនៅដែនជម្រកសត្វព្រៃពាមក្រសោប មានកត្តាជាច្រើនត្រូវបានពិពណ៌នាថាមានឥទ្ធិពលចំពោះការរស់នៅរបស់ប្រជាជនពោលគឺ គោលនយោបាយរដ្ឋាភិបាល ភាពរេចរឹលនៃបរិស្ថាន ជំងឺ សកម្មភាពល្មើសច្បាប់នានា និងលក្ខខណ្ឌទីផ្សារ (PMMR, 2002)។ ករណីសិក្សានេះ បង្ហាញថាការគ្រប់គ្រងធនធានដោយមានការចូលរួម កំពុងជួយសម្របសម្រួលឱ្យមានការផ្លាស់ប្តូរទៅបង្កើតការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពជាងមុន។ ឧទាហរណ៍ ផ្លាស់ប្តូរពីការផលិតធ្យូងទៅជាការស្តារព្រៃកោងកាង និងការប្រមូលធនធានវារីជាតិជាលក្ខណៈតូចតាចឡើងវិញ ។ ការផ្លាស់ប្តូរថ្មីនេះបានលើកទឹកចិត្តផងដែរក្នុងការស្រាវជ្រាវអំពីជម្រើសនានាសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ។

ករណីសិក្សាផ្សេងទៀត ក្នុងតំបន់ពាមក្រសោប ពន្យល់បន្ថែមអំពីឥទ្ធិពលនៃរដូវកាល ទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទ ។ អ្នកភូមិម្នាក់ឱ្យដឹងថា "នៅរដូវវស្សា ខ្ញុំមិនអាចធ្វើការនេសាទដោយប្រើប្រាស់លបក្តាមបានទេ ខ្ញុំឱ្យកូនប្រុសរបស់ខ្ញុំទៅនេសាទនៅសមុទ្រខាងក្រៅជាមួយអ្នកជិតខាងរបស់ខ្ញុំ ។ ពួកគេចំណាយពេលពីរទៅបីយប់នៅលើទូក ដើម្បីនេសាទត្រី..." (Khim *et al.*, 2004)។ ការនេសាទបានផលតិចតួចនៅរដូវវស្សាបានធ្វើឱ្យជីវិត និងការរស់នៅប្រឈមនឹងការលំបាក និងងាយទទួលរងគ្រោះ ហេតុនេះប្រការចាំបាច់គឺត្រូវពិនិត្យមើលជម្រើសផ្សេងៗសម្រាប់ជីវភាពរស់នៅ (Ibid) ។

***ចាំបាច់ត្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីទស្សនទាន និងវិធីសាស្ត្រនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលអាចជួយលើកកម្ពស់ការងារ CBNRM តាមរយៈការដោះស្រាយបញ្ហានៃភាពងាយរងគ្រោះនៃការចិញ្ចឹមជីវិត ។***

## សេចក្តីសន្និដ្ឋាន

មេរៀនជាច្រើនអាចរៀនសូត្របានតាមរយៈដំណើរការសរសេរករណីសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ជំពូកនេះផ្តោតជាសំខាន់ទៅលើការធ្វើអត្ថសញ្ញាណកម្មមេរៀនដែលទទួលបានពីករណីសិក្សាទាំងនេះ។ ការរៀនសូត្រជាគន្លឹះមួយចំនួនត្រូវបានសង្ខេបដូចខាងក្រោម :

- ប្រការសំខាន់សម្រាប់រាល់វិធីសាស្ត្រចូលរួមគឺតម្លាភាព ។ បើគ្មានការចែករំលែកចំណេះដឹង ព័ត៌មាន និងបទពិសោធន៍អោយបានទូលំទូលាយទេនោះ នឹងពុំអាចកសាងជំនឿទុកចិត្តបានឡើយ ហើយវិធីសាស្ត្រដោយមានការចូលរួមក៏នឹងទទួលបរាជ័យដែរ ។

- ចាំបាច់ត្រូវឱ្យមានការពង្រឹងសមត្ថភាពដើម្បីប្តូរចេញនូវរបៀបនៃការធ្វើការសម្រេចចិត្តដែលគ្មានប្រសិទ្ធភាព លើកទឹកចិត្តឱ្យប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួម និងវិមជ្ឈការ សម្របសម្រួលឱ្យមានការពិភាក្សាជាមួយសហគមន៍ និងក្រុមដទៃ ទៀត និងធ្វើការផ្លាស់ប្តូរអាកប្បកិរិយា ។
- ដើម្បីបង្កើនការអប់រំ និងការយល់ដឹងឱ្យមានប្រសិទ្ធិភាព ត្រូវផ្សព្វផ្សាយព័ត៌មានទៅដល់សហគមន៍ តាមរបៀបដែលពួកគាត់ងាយយល់ និងអាចប្រើប្រាស់បាន ។
- មានការងារជាច្រើនទៀតដែលចាំបាច់ត្រូវធ្វើនៅពេលអនាគត ដើម្បីបង្កើតស្ថាប័នតាមមូលដ្ឋាន និងបង្កើនតម្លាភាព ការយល់ដឹង និងការបញ្ជាក់ច្បាស់លាស់អំពីតួនាទីរបស់ស្ថាប័នទាំងនេះនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពី CBNRM ។
- ការបង្កើតយន្តការដោះស្រាយទំនាស់នានាឱ្យមានភាពរលូន ដែលជាផ្នែកមួយនៃការពង្រឹងស្ថាប័ននៅមូលដ្ឋាន និង យន្តការដោះស្រាយដែលមានស្រាប់ អាចបង្កើនការបើកទូលាយ និងការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពសហគមន៍ ដូចជា ការគ្រប់គ្រងសហគមន៍ព្រៃឈើ ។
- អាជ្ញាធររដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់ជាតិត្រូវកំណត់អាណត្តិច្បាស់លាស់ និងមានច្បាប់ដែលចែងអំពីអំណាច ដើម្បីជួយគាំទ្រការគ្រប់គ្រង និងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានា កាត់បន្ថយសកម្មភាពល្មើសច្បាប់ ផ្តល់សិទ្ធិស្របច្បាប់ (ជាពិសេស ដល់សហគមន៍ជនជាតិដើម និងការលើកទឹកចិត្តឱ្យមានការធ្វើវិមជ្ឈការ ។
- ត្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតអំពីចំណងមិត្តភាព និងសំទុះការងារសង្គមក្នុងសហគមន៍ (ឧទាហរណ៍ រវាងក្រុមមនុស្សដែលមានស្ថានភាពខុសគ្នាខាង សេដ្ឋកិច្ច យេនឌ័រ អាយុ ជនជាតិ វណ្ណៈ ឥទ្ធិពល និងលទ្ធភាព ដើម្បីធ្វើឱ្យ CBNRM កាន់តែឆ្លុះបញ្ចាំងអំពីស្ថានភាពពិតនៅមូលដ្ឋាន ។
- ជាទូទៅ អ្នកពាក់ព័ន្ធទាំងឡាយក្នុងប្រទេសកម្ពុជា បានយល់ដឹងត្រឹមតិចតួចប៉ុណ្ណោះអំពីចំណេះដឹង និងទំលាប់ជាលក្ខណៈប្រពៃណី ហេតុនេះគេចាំបាច់ត្រូវធ្វើការស្វែងយល់បន្ថែមអំពីកត្តាទាំងនេះ ដើម្បីឱ្យឃើញថាតើចំណេះដឹង និងទំលាប់ទាំងនោះអាចរួមចំណែកបែបណាក្នុងការថែរក្សា ឬកែលំអប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ ។
- ដើម្បីឱ្យ CBNRM មានប្រសិទ្ធិភាពមានលក្ខណៈឆ្លុះបញ្ចាំងអាចពង្រីកទៅកន្លែងផ្សេងទៀតបាន និងមាននិរន្តរភាពក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវមានសម្ព័ន្ធភាពដែលគាំទ្រការងារនេះ ។
- PLUP ជួយជម្រុញ CBNRM ដោយរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ទៅក្នុងដំណើរការរៀបចំកសាងផែនការគ្រប់គ្រងធនធាននៅមូលដ្ឋាន និងដោះស្រាយទំនាស់នានាដែលអាចកើតមានឡើង ។ បន្ទាប់មក លទ្ធផលទាំងនេះអាចយកទៅបញ្ចូលទៅក្នុងការកសាងផែនការ និងគោលនយោបាយជាតិ ។
- ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើការសម្រុះសម្រួលទំនាស់នានា ទទ្ទឹមនឹងជម្រុញយ៉ាងសកម្ម និងសម្របសម្រួលយន្តការសម្រាប់ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន សង្គមស៊ីវិល អង្គការនានា និងក្រុមសហគមន៍ផងដែរ ។
- ចាំបាច់ត្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីទស្សនទាន និងវិធីសាស្ត្រនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលអាចជួយជម្រុញ CBNRM តាមរយៈការដោះស្រាយបញ្ហានៃភាពងាយរងគ្រោះក្នុងការចិញ្ចឹមជីវិត ។

## REFERENCES

Cheam, M, Him, S, Cheam, S , Nun, V, and Sun, V. 2001. *Liquid Resin conflict in Teurn Commune, Konmum Destrict, Ratanakiri Province.* WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Chiy, P, Soum, C, Leng, S, and Suy, T. 2002. *Comparisons on Community Fisheries Management in Ream National Park, Sihanoukvill, and Peam Krasaop Wildlife Sanctuary, Koh Kong Province.* Coordinated by Ouk Lykhim and So Srey Mom. WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Em D, Khim, W. 2003. *Seasonal factors effect on fishers' livelihood. Koh Sralao village, Peam Krasob Wildlfe Sanctuary, Koh Kong Province, Cambodia.* WWF/CBNRM Case Study and Networking Initiative. (Phnom Penh, Cambodia).

Heng, P, Sung, S, Chheun S, Yim, L. 2003. *Village community Planning Is successful due to Active involvement of the community.* Boeung Chunlen Village, Russey Chroy Commune, Mokampool District, Kandal Province, Cambodia. WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Im, M, Sok, M, Heng, S. 2003.*Role and Responsibility of Commune Councils and Local Communities in Natural Resource Management.* Chhumkiri District, Kampot Province, Cambodia. WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Ken, S, Ros, C, Horn, H, Tit, P, Nouv, B. 2003. T*he Establishment of Community Fisheries in Anlong Raing Village Helps Improve the Livelihoods of Local People.* Anlong Raing village, Kampong Por Commune, Krar Kor District, Pursat Province, Cambodia. WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Khai, S, and Thai, K. 2002. *Local Communities Participating in Managing Fisheries-Resources in Tboung Khlaa and O Mreah, Stung Treng.* Coordinated by Oul Kim Sear. WWF/CBNRM Case study and Networking Initiative. Phnom Penh, Cambodia.

Khim, W, and Eam, D. 2004. *Seasonal Factors Affect Fisher' Livelihoods.* WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Kim, S, and Real, S. 2002. *Implementation of Community Forest By-Laws. Som Thom Commune, O Yadao District, Ratanakiri Province. Coordinated by Son Bora.* WWF/CBNRM, IDRC, OXFAM America, PLG<RECOFTC. Phnom Penh, Cambodia.

Marchke, M J. 2002. *Sustainable Livelihoods in Context: Learning with Cambodian Fishers.* PhD draft proposal.

Marschke, M, and Kim, N. 2001. *Community Based Coastal Resource Management: Lessons and Responses.* Presented at: Southeast Asian Studies Conference, University of Victoria, B.C. October 25th-26th 2001.

Ouk, T, Ou, S. 2003. *Integrated participatory Land Use Planning Tools in Community Forestry Establishment Process. Tuol Sambo Vllage, Trapeang Pring Commune, Damber District, Kompong Cham Province, Cambodia.* WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

PMMR Team. 2002. *Finding Sustainable Livelihoods. From Peam Krasaop Wildlife Sanctuary, Koh Kong Province.* WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

Sun, V and Kouk, T. 2002. *Gender in Community Forestry Management. Snam Phrah Commune, Bakan District, Pursat Province.* Coordinated by: Samrang Dy Vicheth. WWF/CBNRM, IDRC, OXFAM America, CONCERN Worldwide, RECOFTC. Phnom Penh, Cambodia.

Tong S, Meas S V, Meas S, Puth S. 2003. *Conflict Management within the Process of Community Forestry Management. Sre Ambel Koh Kong Provice.* WWF/CBNRM Case Study and Networking Initiative. Phnom Penh, Cambodia.

## ឧបសម្ព័ន្ធ ១: យុទ្ធសាស្ត្រនៃការសរសេរករណីសិក្សា និងសកម្មភាពចម្បងៗ (២០០១-២០០៤)

| ឈ្មោះសិក្ខាសាលា និងប្រធានបទនៃការបណ្តុះបណ្តាល | ទីតាំង | ចំនួនអ្នកចូលរួម | កាលបរិច្ឆេទ | លទ្ធផលនៃការរៀនសូត្រ និងឥទ្ធិពលចម្បងៗ |
|---|---|---|---|---|
| ការបណ្តុះបណ្តាលអំពីការសរសេរករណីសិក្សា CBNRM លើកទី១: ប្រវត្តិរឿងស្តីពីបឹងទន្លេសាប | ខេត្តសៀមរាប | ៣០ នាក់ | ខែកក្កដា ឆ្នាំ២០០១ | របាយការណ៍នៃករណីសិក្សា ឧបករណ៍នៃការសរសេរករណីសិក្សា និងរបាយការណ៍ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់កែលំអការបណ្តុះបណ្តាលទៅថ្ងៃអនាគត ។ |
| សិក្ខាសាលាអំពីការឆ្លុះបញ្ចាំង និងការកសាងផែនការបណ្តុះបណ្តាលគ្រូបង្គោល អំពីជំនាញសរសេរករណីសិក្សា និងការសម្របសម្រួល ។ | ក្រុងភ្នំពេញ | ២០ នាក់ | ខែវិច្ឆិកា ឆ្នាំ២០០១ | គឺជាឱកាសល្អដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីសិក្ខាសាលាស្តីពីករណីសិក្សាក្នុងខេត្តសៀមរាប និងរៀនពីរបៀបរៀបចំ និងកែលំអរបៀបវារៈ ។ |
| ការបណ្តុះបណ្តាលអំពីការសរសេរករណីសិក្សាCBNRM លើកទី២: ប្រវត្តិរឿងស្តីពីតំបន់ខ្ពង់រាបរតនគិរី | ខេត្តរតនគិរី | ៣៥ នាក់ | ខែវិច្ឆិកា ឆ្នាំ២០០១ | របាយការណ៍នៃករណីសិក្សា កញ្ចប់ឧបករណ៍សម្រាប់ការសរសេរករណីសិក្សាដែលបានកែសម្រួលជាថ្មី របាយការណ៍ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់វាយតម្លៃពីការរីកចម្រើន និងការកែលំអការបណ្តុះបណ្តាលទៅអនាគត ។ |
| ការបង្កើតសេចក្តីព្រាងករណីសិក្សា ១០ | ទីកន្លែងផ្សេងៗគ្នា | | ខែវិច្ឆិកា ឆ្នាំ២០០១ ដល់ខែឧសភា ២០០២ | យោងទៅលើអត្ថបទនៃករណីសិក្សានានា ។ |
| សិក្ខាសាលាអំពីការធ្វើសំយោគ និងការឆ្លុះបញ្ចាំង | ខេត្ត កោះកុង | ៤៣ នាក់ | ២១-២៥ ខែឧសភា ឆ្នាំ២០០២ | បង្កើតឱ្យមានក្រុមពិនិត្យផ្តល់យោបល់លើករណីសិក្សាក្រោមរូបភាពជាផែនទីអំពីគំនិតការវិភាគ SWOT អំពីដំណើរការសរសេរករណីសិក្សា និងធ្វើផែនការសកម្មភាពសម្រាប់ក្រុម ។ |
| សិក្ខាសាលា CBNRM ថ្នាក់ជាតិ | ក្រុងភ្នំពេញ | ១២៥ នាក់ | ១៣-១៦ ខែវិច្ឆិកា ឆ្នាំ២០០២ | បញ្ចប់របាយការណ៍ជាភាសាខ្មែរ និងភាសាអង់គ្លេស ។ សាកល្បងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីឱ្យយល់ដឹងពីដំណើរការនេះ ។ |
| ការបណ្តុះបណ្តាលអំពីការសរសេរករណីសិក្សា CBNRM លើកទី៣: ប្រធានបទសំខាន់ៗជុំវិញប្រទេសកម្ពុជា | ក្រុងភ្នំពេញ | ៣០ នាក់ | ១៣-២៤ ខែតុលា ឆ្នាំ ២០០៣ | របាយការណ៍បណ្តុះបណ្តាលពីរស្តីពី "ការឆ្លុះបញ្ចាំងអំពីការសរសេរករណីសិក្សា"និង"ការពិចារណាពីការបណ្តុះបណ្តាលសម្រាប់ការសរសេរករណីសិក្សា":មេរៀនទទួលបានពីប្រទេសកម្ពុជា ។ |
| ការបណ្តុះបណ្តាលស្តីពីរបៀបសរសេរអត្ថបទនៅ RECOFTC | ទីក្រុងបាងកក ប្រទេសថៃ | កល្យាណ | ០៧-១៨ ខែតុលា ឆ្នាំ ២០០២ | បង្ហាញពីការសរសេរករណីសិក្សា និងកែលំអចំណេះដឹង និងជំនាញ សម្រាប់ការវិភាគ ។ |
| ការបណ្តុះបណ្តាលពីការសរសេរអត្ថបទនៅ RECOFTC | ទីក្រុងបាងកក ប្រទេសថៃ | ម៉ារ៉ូណា | ១៩ ខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០០៣ | បង្កើតករណីសិក្សា ស្តីពីបញ្ហាដីសម្បទាន ។ បង្ហាញពីការសរសេរករណីសិក្សា និងកែលំអចំណេះដឹង និងជំនាញសម្រាប់ការវិភាគ ។ |
| បង្កើតករណីសិក្សាថ្មីចំនួនប្រាំបី | តំបន់ផ្សេងៗគ្នា | ៣០ នាក់ | ខែតុលា ឆ្នាំ២០០៣ ដល់ ខែកញ្ញា ២០០៤ | យោងទៅលើអត្ថបទនៃករណីសិក្សានានា ។ |

## ឧបសម្ព័ន្ធ ២ :

## ដំណើរការសរសេរករណីសិក្សា

ដោយយល់ឃើញថា អ្នកចូលរួមមាននិន្នាការធ្វើការបកស្រាយអំពីដំណើរការសរសេរករណីសិក្សាទាំងដប់ជំហានថាជាជំហានដែលត្រូវធ្វើបន្តបន្ទាប់ពីមួយតទៅមួយទៀត និងការពង្រីកសេចក្តីក្នុងជំហានទីមួយៗ លំដាប់លំដោយបែបនេះត្រូវបានកែសម្រួល ដើម្បីអោយឆ្លើយតបទៅនឹងតម្រូវការឱ្យមានការសរសេរពង្រីកសេចក្តីបានល្អជាងមុន។ ទោះបីជាយ៉ាងណាក៏ដោយជំហានទាំងនេះនៅតែដូចគ្នាដដែល គំរូក្រោយនេះមានការផ្តុំជំហានទាំងនេះជាបណ្តុំ ដូចជា "ស៊ុតក្នុងកន្ត្រក "មួយចំនួនដូច្នោះដែរ ។កន្ត្រកនេះបង្ហាញអំពីបណ្តុំនៃសកម្មភាពនៅក្នុងដំណើការសរសេរ ។




ចំណុចកណ្តាលនៃរូបភាពនេះគឺ ការវិភាគ ដោយចាត់ទុកថាជំហានផ្សេងៗទៀតទាំងអស់ត្រូវពឹងផ្អែកទៅលើជំនាញនៃការវិភាគនេះ ។ ដំណើរការនេះមាននាទីជាផែនទីសម្រាប់ការចូលរួមក្នុងអំឡុងពេលនៃដំណើរការសរសេរ ។

## ឧបសម្ព័ន្ធ ៣ : ប្រធានបទ និងទីតាំងនៃករណីសិក្សា

| ល.រ | ចំណងជើង | ទីតាំង | អ្នករៀបរៀង | កាលបរិច្ឆេទ | អង្គការជាដៃគូ |
|---|---|---|---|---|---|
| ១ | យេនឌ័រក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ | ពោធិ៍សាត់ | ស៊ុន វណ្ណ ឆ្កូក ធឿន សំរ៉ង ឱ្យវិចិត្រ ជាន ថាយុទ្ធ | ២០០២ | អង្គការខន់សឺន |
| ២ | សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល | ស្ទឹងត្រែង | ខៃ ស៊ីវ៉ាប្ញូ ថៃ គឹម សេង អ៊ុល គីមស៊ា | ២០០២ | អង្គការអុកស្វាម អូស្ត្រាលី (OCAA) |
| ៣ | កំណែទម្រង់គោលនយោបាយវិស័យជលផល និងទស្សនៈថ្មីៗស្តីពីសហគមន៍នេសាទ និងសហគ្រប់គ្រង | សៀមរាប និង បាត់ដំបង | ថាយ សុមុនី | ២០០២ | ការគ្រប់គ្រងធនធានដោយមានការចូលរួម (FAO សៀមរាប និង DoF/CFDO |
| ៤ | ការបំផ្លាញព្រៃកោងកាង និងការស្តារឡើងវិញតាមរយៈយុទ្ធសាស្ត្រសហគ្រប់គ្រង | កំពង់សោម | ឡេង សំអាត ខៀវ ស៊ុនហួ ម៉ែន វុទ្ធី ម៉ាន ឧត សូ ស្រីមុំ អ៊ុក លីឃីម ស៊ុយ ធា | ២០០២ | ឧទ្យានជាតិរាម និង ក្រសួងបរិស្ថាន |
| ៥ | និរន្តរភាពនៃការចិញ្ចឹមជីវិត | កោះកុង | ក្រុមការងារនៃគម្រោង PMMR | ២០០២ | គម្រោង PMMR |
| ៦ | ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍ (CBCRM) | កោះកុង និង កំពង់សោម | ជ័យ ពេជរតនា សោម ជា, ស៊ុយ ធា ឡេង សំអាត សូ ស្រីមុំ អ៊ុក លីឃីម | ២០០២ | គម្រោង PMMRនិង ឧទ្យានជាតិរាម និង ក្រសួងបរិស្ថាន |
| ៧ | ការអនុវត្តលក្ខខន្តិកៈសហគមន៍ព្រៃឈើ | រតនគិរី | វៀល ស៊ីណា គឹម សាត សុន បូរ៉ា | ២០០២ | ភាពជាដៃគូសម្រាប់រដ្ឋាភិបាលមូលដ្ឋាន (PLG) និង CBNRM |
| ៨ | ឥទ្ធិពលនៃការពង្រីកដំណាំស្វាយចន្ទី | រតនគិរី | មាស សុខុម ព្រំ មេត្តា មុំ គន្ធារ៉ី អែម ត្រាយ | ២០០២ | ផលិតផលព្រៃឈើ (NTFP) |
| ៩ | ការថយចុះនូវផ្ទៃដីព្រៃស្រោង និងពាក់កណ្តាលស្រោង | មណ្ឌលគិរី | ឱុន យិមស្រេង ងិន លីណា ស្បាណែត ញ៉ែម សុផល លន់ សម្ផស្ស ជាម មុនី | ២០០២ | នាយកដ្ឋានព្រៃឈើ និង សត្វព្រៃខេត្ត (DoFW) |
| ១០ | សារៈសំខាន់នៃការនេសាទកំពឹស និងការកែច្នៃកំពឹសក្រៀមជាលក្ខណៈគ្រួសារ | សៀមរាប | ថាយ សុមុនី | ២០០២ | ការគ្រប់គ្រងធនធានដោយមានការចូលរួម (FAO សៀមរាប) និង DOF/CFDO |

## ឧបសម្ព័ន្ធ ៤ : ប្រធានបទ និងទីតាំងរបស់ករណីសិក្សា

| ល.រ | ចំណងជើង | ទីតាំង | អ្នករៀបរៀង | កាលបរិច្ឆេទ | អង្គការជាដៃគូ |
|---|---|---|---|---|---|
| ១ | តួនាទី និងទំនាក់ទំនងក្រុមប្រឹក្សាឃុំចំពោះសកម្មភាពសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន | ខេត្តកំពត | អ៊ឹម ម៉ារីឌី សុខ ម៉ារី ហេង សុខឡា | ២០០៤ | គម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) CIDSE |
| ២ | ការគ្រប់គ្រងទំនាស់ក្នុងដំណើរការនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ | ស្រុក ស្រែអំបិល ខេត្តកោះកុង | តួង សុគន្ធាន ពុធ សារ៉ាង មាស សុធនវឌ្ឍនៈ មាស-សមសុជាតិ ផាន់ កំណាព្យ | ២០០៤ | គម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) AFSC |
| ៣ | ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយសហគមន៍ និងនិរន្តរភាពជីវភាពរស់នៅ ។ | ខេត្តកំពង់ធំ | ប៊ី សេងលៀង ពួក ប៊ុនថេត ឌុល វុធ គឹម សារិន | ២០០៤ | គម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) DNCP/MoE |
| ៤ | ការអនុវត្តន៍ផែនការរបស់សហគមន៍នេសាទទឹកបឹងជន្លេន | ខេត្តកណ្តាល | ហេង ពន្លៃ ស៊ឹង សុគន្ធា ឈឹន សារិ យឹម ឡាំ | ២០០៤ | ការិយាល័យអភិវឌ្ឍន៍សហគមន៍ នេសាទ |
| ៥ | ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់ប្រជាជនក្នុងសហគមន៍នេសាទ ភូមិអន្លង់រាំង | ខេត្តពោធិ៍សាត់ | កែន សុភាព រស់ ឆវីវណ្ណ ហឿន ហុន្នី ទិត ភារៈ នៅ ប៊ុនថា | ២០០៤ | ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ |
| ៦ | ការបញ្ចូល PLUP ទៅក្នុងដំណើរការបង្កើតសហគមន៍ព្រៃឈើ | ខេត្តកំពង់ចាម | អ៊ុក ធីរ៉ា អ៊ូ សុភារី | ២០០៤ | អង្គការ Concern |
| ៧ | ឥទ្ធិពលនៃរដូវកាលទៅលើការចិញ្ចឹមជីវិតរបស់ប្រជានេសាទ | ខេត្តកោះកុង | អៀម ឌីណា យឹម វីរិយា | ២០០៤ | PMMR |
| ៨ | ការផ្តល់ដីសម្បទាន ដើម្បីកាត់បន្ថយភាពក្រីក្រ : គោលនយោបាយដែលជាបញ្ហាចោទមួយ ! | កំពង់ធំ | ស្រី ម៉ារ៉ូណា អាជីលីណា ភិសូ ម៉ារីយា ឡាតូម៉ាហ៊ីមា | ២០០៤ | RECOFTC |

# ឧបសម្ព័ន្ធ ៥ : ផែនទី

## ទីតាំងករណីសិក្សាក្នុងប្រទេសកម្ពុជា ( ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម



| លេខកូដ | ចំណងជើង | ស្រុក | ខេត្ត | ឆ្នាំ |
|---|---|---|---|---|
| A | ការអនុវត្តលក្ខន្តិកៈសហគមន៍ព្រៃឈើ | អូយ៉ាដាវ | រតនគិរី | 2002 |
| B | ឥទ្ធិពលនៃការពង្រីកដំណាំស្វាយចន្ទី | កូនមុំ | រតនគិរី | 2002 |
| C | ការថយចុះនូវផ្ទៃដីព្រៃស្រោង និងពាក់កណ្ដាលស្រោង | ពេជ្រាដា | មណ្ឌលគិរី | 2002 |
| D | សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល | សៀមបូក | ស្ទឹងត្រែង | 2002 |
| E | សារៈសំខាន់នៃការនេសាទកំពឹស និងការកែច្នៃកំពឹសជាលក្ខណៈគ្រួសារ | សូត្រនិគម | សៀមរាប | 2002 |
| F | កំណែទម្រង់គោលនយោបាយវិស័យជលផល និងទស្សនៈថ្មីៗស្ដីពីសហគមន៍នេសាទ និងសហគ្រប់គ្រងនេសាទ | ពួក | សៀមរាប | 2002 |
| G | យេនឌ័រក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ | បាកាន | ពោធិ៍សាត់ | 2002 |
| H | វដ្តនៃការរៀនសូត្រៈ ការសរសេរករណីសិក្សាជាវិធីសាស្ត្រសម្រាប់បណ្ដុះបណ្ដាល និងការរៀនសូត្រ | ភ្នំពេញ | ភ្នំពេញ | 2002 |
| I | ការបំផ្លាញព្រៃកោងកាង និងការស្ដារឡើងវិញតាមរយៈយុទ្ធសាស្ត្រសហគ្រប់គ្រង | ព្រៃនប់ | ក្រុងព្រះសីហនុ | 2002 |
| J | ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍ | ព្រៃនប់ | ក្រុងព្រះសីហនុ | 2002 |
| K | កំណែទម្រង់គោលនយោបាយវិស័យជលផល និងទស្សនៈថ្មីៗស្ដីពីសហគមន៍នេសាទ និងសហគ្រប់គ្រងនេសាទ | ឯកភ្នំ | បាត់ដំបង | 2002 |
| L | និរន្តរភាពនៃការចិញ្ចឹមជីវិត | ស្មាច់មានជ័យ | កោះកុង | 2002 |
| M | តួនាទី និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា ឃុំចំពោះសកម្មភាពសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូន | ជុំគិរី | កំពត | 2004 |
| N | ការគ្រប់គ្រងទំនាស់ក្នុងដំណើរការគ្រប់គ្រងសហគមន៍ព្រៃឈើ | ស្រែអំបិល | កោះកុង | 2004 |
| O | ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយសហគមន៍ និងនិរន្តរភាពជីវភាពរស់នៅ | រវៀង | ព្រះវិហារ | 2004 |
| P | ការអនុវត្តន៍ផែនការសកម្មភាពនៃសហគមន៍នេសាទអាងទឹកបឹងជន្លេន | មុខកំពូល | កណ្ដាល | 2004 |
| Q | ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពរបស់ប្រជាជនក្នុងសហគមន៍ជលផលក្នុងអន្លង់រាំង | ក្រគរ | ពោធិ៍សាត់ | 2004 |
| R | ការបញ្ចូលផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម PLUP ក្នុងដំណើរការបង្កើតសហគមន៍ព្រៃឈើ | តំបែរ | កំពង់ចាម | 2004 |
| S | ឥទ្ធិពលនៃរដូវកាលទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជានេសាទ | | កោះកុង | 2004 |
| T | ដីសម្បទាន ដើម្បីកាត់បន្ថយភាពក្រីក្រ ៖ គោលនយោបាយដែលចោទជាបញ្ហាមួយ ! | ទុមរីង | កំពង់ធំ | 2004 |

# ជំពូក ១២

# បទពិសោធន៍នៅមូលដ្ឋានស្តីពីការស្រាវជ្រាវ ដោយអនុវត្តន៍សហគមន៍ព្រៃឈើ

រៀបរៀងដោយ លោក ស៊ី រ៉ាមុនី[១] លោក ផាន់ កំណាព្យ[២] និង លោក គីម សារិន[៣ និង ៤]

## សេចក្តីផ្តើម

ធនធានព្រៃឈើនៅក្នុងប្រទេសកម្ពុជា បានថយចុះជាលំដាប់ក្នុងអំឡុងពេលជាង ២០ឆ្នាំកន្លងមកនេះ ដោយសារតែសង្គ្រាម ការពង្រីកដីកសិកម្ម និងការដកហូតផលិតផលឈើហួសប្រមាណ ។ នយោបាយគ្រប់គ្រងធនធានព្រៃឈើតាមទំលាប់ដើម និងការរីករាលដាលនៃអំពើពុករលួយ គឺជាបុព្វហេតុដែលធ្វើឱ្យបាត់បង់ធនធានជាបន្តបន្ទាប់ ការកើនឡើងខ្ពស់នៃតម្លៃធនធាន និងធ្វើឱ្យកើនឡើងនូវភាពក្រីក្រនៅជនបទ ។ កង្វះខាតសមត្ថភាព និងធនធ្ម បានធ្វើឱ្យការគ្រប់គ្រងធនធានកាន់តែទន់ខ្សោយ និងបាត់បង់ព្រៃឈើជាបន្តបន្ទាប់ ។ អ្នកប្រើប្រាស់ធនធានព្រៃឈើតម្រូវឱ្យមានការផ្តល់សិទ្ធិ និងការចាប់អារម្មណ៍ដើម្បីឱ្យមានការចូលរួមគ្រប់គ្រងធនធានព្រៃឈើ និងការផ្លាស់ប្តូរជាមូលដ្ឋានចំពោះនយោបាយគ្រប់គ្រងព្រៃឈើ ដែលជាសមិទ្ធផលនៃអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ជម្រុញឱ្យមានការផ្គត់ផ្គង់ធនធានដល់ប្រជាពលរដ្ឋមូលដ្ឋាន លើកទឹកចិត្តដល់ការប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើឱ្យមាននិរន្តរភាព ។

អត្ថបទនេះ បង្ហាញពីសេចក្តីសង្ខេបនៃការស្រាវជ្រាវដោយចូលរួមអនុវត្តសហគមន៍ព្រៃឈើ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តសហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ អ្នកអានអាចប្រទះឃើញវិធីសាស្រ្តមួយចំនួនដែលបានប្រើប្រាស់ និងមេរៀនល្អៗដែលអាចយកទៅអនុវត្តបានតាមស្ថានភាពជាក់ស្តែងរបស់ខ្លួន ។

## ហេតុអ្វីចាំបាច់មានការស្រាវជ្រាវដោយអនុវត្តន៍សហគមន៍ព្រៃឈើ ?

សហគមន៍ព្រៃឈើត្រូវបានទទួលស្គាល់ថា ជាយុទ្ធសាស្រ្តយ៉ាងសំខាន់នៃការគ្រប់គ្រងធនធានព្រៃឈើ ប្រកបដោយនិរន្តរភាព និងជាការចូលរួមចំណែកលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាសន្តិសុខផ្នែកបរិស្ថាន ។

---

[១] លោក ស៊ី រ៉ាមុនី ជាប្រធានគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជា និងជាប្រធានការិយាល័យឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ។

[២] លោក ផាន់ កំណាព្យ ជាអនុប្រធានគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជា និងអនុប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលនៃរដ្ឋបាលព្រៃឈើ ។

[៣] លោក គីម សារិន ជាអ្នកសម្របសម្រួលនៅមូលដ្ឋាននៃគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជា និងជាអនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ។

[៤] ការរួមចំណែកពី លោក កែន សេរីរដ្ឋា លោក ញ៉ែម សុវណ្ណា លោក ស្រី ម៉ារ៉ូណា កញ្ញា ហ៊ូ កណ្យាណ លោក Toby Carson និង លោក Doug Henderson ។

សហគមន៍ព្រៃឈើបានពង្រីកតួនាទីនៅកម្ពុជាតាមរូបភាពជាច្រើន :

- ចំនួននៃការផ្តួចផ្តើមសហគមន៍ព្រៃឈើនៅមូលដ្ឋាន បានកើនឡើងជាលំដាប់ក្នុងអំឡុងទសវត្សរ៍កន្លងមកនេះ ដែលកាលពីទសវត្សរ៍មុន មានសហគមន៍ត្រឹមមួយ ឬពីរតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នបានកើនឡើងរហូតដល់ប្រមាណ ៥០សហគមន៍ ។
- ការគាំទ្រខាងស្ថាប័នចំពោះសហគមន៍ព្រៃឈើ បានកើនឡើងនៅថ្នាក់ជាតិ និងជាពិសេសថ្នាក់ខេត្តតាមរយៈការបង្កើតយន្តការអន្តរស្ថាប័នសំរាប់សហគមន៍ព្រៃឈើ ដូចជាបណ្តាញសហគមន៍ព្រៃឈើ ក្រុមការងារផ្សេងៗ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ។
- បរិយាកាសនយោបាយបានបង្កលក្ខណៈអំណោយផលសម្រាប់សហគមន៍ព្រៃឈើ ដូចជាមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ ច្បាប់បរិស្ថាន អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន និងថ្មីៗនេះមានការអនុម័តអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ (សូមអានជំពូក៣ ។

ទស្សនទាននៃការស្រាវជ្រាវដោយអនុវត្តសហគមន៍ព្រៃឈើ គឺជាការរៀនសូត្រពីការអនុវត្ត (រៀនសូត្របណ្តើរ អនុវត្តបណ្តើរ ដែលការរៀនសូត្រត្រូវ បានចាត់ទុកថាជាការដកស្រង់បទពិសោធន៍ និងជាការឆ្លុះបញ្ចាំង បន្ទាប់មកធ្វើឱ្យមានការផ្លាស់ប្តូរ និងរៀនសូត្រជាបន្ថែម ។ ទស្សនទាននេះទទួលស្គាល់ថា បុគ្គលនានារៀនសូត្រតាមរយៈការសម្របសម្រួលសកម្មភាពអនុវត្តន៍ និងចំណេះដឹងរបស់ខ្លួន ដែលមានស្រាប់ឱ្យស្របនឹងកំណើននៃបទពិសោធន៍របស់ខ្លួន និងជាមួយបទពិសោធន៍របស់អ្នកដទៃ ព្រមទាំងជាមួយស្ថានភាពនៃបរិស្ថានដែលពួកគេកំពុងស្ថិតនៅ ។ ដូច្នេះការស្រាវជ្រាវដោយអនុវត្តន៍ គឺជាដំណើរការអនុវត្តន៍សកម្មភាពបន្តបន្ទាប់ មានជាអាទិ៍ ការឆ្លុះបញ្ចាំង ការអនុវត្ត ការរៀនសូត្រ ដែលជាវដ្តប្រព្រឹត្តទៅដដែលៗ (សូមមើលរូបទី ១ ។




*រូបទី១ : ដ្យាក្រាមរបស់វដ្តនៃការស្រាវជ្រាវដោយអនុវត្តន៍*
ប្រភព : យកលំនាំតាម Po' Hara




*រូបភាពទី២ : ការរៀនសូត្រផ្តោតទៅលើទីកន្លែង*

វដ្តនៃការស្រាវជ្រាវដោយអនុវត្តន៍ គឺជាដំណើរការដែលនៅក្នុងនោះ សមាជិកក្រុមដែលមានចំណាប់អារម្មណ៍ និងសហគមន៍មូលដ្ឋានរួមគ្នាកំណត់ពីទិសដៅ និងគោលបំណងរបស់ពួកគេដោយប្រមូល និងវិភាគព័ត៌មាន រៀបចំយុទ្ធសាស្ត្រ និងអនុវត្តទៅតាមផែនការ ដើម្បីឱ្យឆ្លើយតបនឹងតម្រូវការរបស់ខ្លួន ដោយផ្តោតទៅលើទិដ្ឋភាពជាចម្បងៗចំនួនបីគឺ ការរួមបញ្ចូលខាងផ្នែកសង្គម នយោបាយ និងអេកូឡូស៊ី ។

គម្រោង និងកម្មវិធីជាច្រើនបានទទួលស្គាល់ថា ការស្រាវជ្រាវដោយអនុវត្តន៍អាចផ្តល់ព័ត៌មានត្រឹមត្រូវ និងទាន់សភាពការណ៍បំផុតដែលជួយពួកគេក្នុងការធ្វើផែនការ និងធ្វើសេចក្តីសម្រេច ។ ការស្រាវជ្រាវដោយអនុវត្តន៍ជួយបង្កើនសមត្ថភាពក្នុងការកំណត់រឿងរ៉ាវ និងបញ្ហា ព្រមទាំងផ្តល់ឱកាសដល់អ្នកចូលរួមដើម្បីចែករំលែកចំណេះដឹងស្តីពីលទ្ធភាពដែលអាចចូលរួមធ្វើអន្តរាគមន៍ និងរៀបចំយុទ្ធសាស្ត្រសម្រាប់កែលំអស្ថានភាពសង្គមនយោបាយ និងបរិស្ថាន ។ ក្នុងគម្រោងអភិវឌ្ឍន៍សហគមន៍មួយចំនួន អ្នកខាងក្រៅព្យាយាមណែនាំសហគមន៍មូលដ្ឋានអំពីការកំណត់បញ្ហារបស់ពួកគេ ។ នៅក្នុងបរិបទនៃការស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើ សហគមន៍មូលដ្ឋានត្រូវចូលរួមយ៉ាងពេញលេញក្នុងការកំណត់បញ្ហាដើម្បីឱ្យប្រាកដថា ការស្រាវជ្រាវដោយអនុវត្តន៍ឆ្លើយតបនឹងតម្រូវការកែលំអជីវភាពប្រចាំថ្ងៃរបស់ពួកគេ ។

ការអនុវត្តយុទ្ធសាស្ត្រស្រាវជ្រាវដោយអនុវត្តន៍ពីសហគមន៍មូលដ្ឋានអាចបង្កើនការស្វែងយល់ទូលំទូលាយថែមទៀតស្តីពីបញ្ហាសង្គម និងបរិស្ថាន ដូចជាភាពរេចរឹលយ៉ាងរហ័សនៃធនធានធម្មជាតិ ។ ដោយមើលឃើញនូវបុព្វហេតុ និងផលប៉ះពាល់នានា សហគមន៍អាចស្វែងយល់អំពីការប្រើប្រាស់ និងគ្រប់គ្រងធនធានរបស់ពួកគេដើម្បីឱ្យមាននិរន្តរភាព ។

ការស្រាវជ្រាវដោយអនុវត្តន៍ បានក្លាយជាយុទ្ធសាស្ត្រស្នូលនៃគម្រោងសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើនៅកម្ពុជា (CFRP) ដែលទទួលបានការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (RECOFTC) ។ CFRP គឺជាគម្រោងដែលអនុវត្តរួមគ្នាដោយស្ថាប័នជាតិបីគឺនាយកដ្ឋានការពារ អភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមហាវិទ្យាល័យវិទ្យាសាស្ត្ររុក្ខកម្មនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

ការស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើបានធ្វើឡើង ដើម្បីស្វែងយល់ និងកំណត់ពីស្ថានភាពសហគមន៍ព្រៃឈើនៅកម្ពុជា និងដើម្បីកសាងយុទ្ធសាស្ត្រសមស្រប ជម្រុញ និងផ្តល់ឱកាសសម្រាប់ការប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋានប្រកបដោយនិរន្តរភាព និងជម្រុញផងដែរឱ្យមានឱកាសដើម្បីកែលំអកម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទ ។ លទ្ធផល និងរបកគំហើញនៃការស្រាវជ្រាវត្រូវបានយកមកពិនិត្យ និងប្រើប្រាស់ដើម្បីផ្សព្វផ្សាយដល់អ្នករៀបចំគោលនយោបាយនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជម្រុញ និងគាំទ្រឱ្យមានការកសាងគោលនយោបាយ និងកម្មវិធីសមស្របសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើឱ្យមាននិរន្តរភាព ។

## តើការស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើបានធ្វើឱ្យមានការផ្លាស់ប្តូរអ្វីខ្លះ ?

ក. សហគមន៍មូលដ្ឋាន ត្រូវបានជម្រុញឱ្យចូលរួមក្នុងការគ្រប់គ្រងធនធានព្រៃឈើ នៅពេលដែលពួកគាត់បានទទួលការលើកទឹកចិត្តតាមរយៈ ការផ្តល់សិទ្ធិប្រើប្រាស់ធនធានព្រៃឈើ និងចំណេះដឹងជាក់ស្តែង ។ ការស្រាវជ្រាវដោយអនុវត្តន៍បានបង្កើនការយល់ដឹង និងពង្រឹងសមត្ថភាពអំពីសហគមន៍ព្រៃឈើសម្រាប់ស្ថាប័ន និងសហគមន៍គោលដៅដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការនេះ ។ ក្រុមសហគមន៍ព្រៃឈើបានសម្តែងការគាំទ្រ ចំពោះកិច្ចការសហគមន៍ព្រៃឈើ និងក្រុមប្រឹក្សាឃុំ ហើយអ្នកភូមិជិតខាងបានទទូចសុំឱ្យមានការគាំទ្រក្នុងការសម្របសម្រួលបង្កើតសហគមន៍ព្រៃឈើបន្ថែមទៀតនៅតំបន់របស់ពួកគេ ។ ក្រុមនានាដែលមានស្រាប់ក៏បានមើលឃើញពីសារៈសំខាន់នៃការបង្កើតសហគមន៍ព្រៃឈើថាជាយុទ្ធសាស្ត្រសម្រាប់ធានាឱ្យមានការប្រើប្រាស់អនុផលព្រៃឈើខ្លះៗប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលខ្លី និងរយៈពេលវែង និងសម្រាប់ការប្រើប្រាស់ផលិតផលព្រៃឈើសម្រាប់អនាគតយូរអង្វែង ។ សហគមន៍បច្ចុប្បន្នមានភាពក្លាហាន ហ៊ាននិយាយ និងមានភាពជឿជាក់ថា ពួកគេអាចគ្រប់គ្រងធនធានព្រៃឈើប្រកបដោយជោគជ័យ ប្រសិនបើមានការគាំទ្រខាងផ្នែកគោលនយោបាយបន្ថែមទៀតនោះ ។ ពួកគេក៏បានកត់សំគាល់ផងដែរអំពីការលូតលាស់ឡើងវិញតាមបែបធម្មជាតិ នៅពេលដែលព្រៃឈើត្រូវបានការពារពីការប្រើប្រាស់ និងការកាប់បំផ្លាញជាបន្តបន្ទាប់ ។ ការថែរក្សាព្រៃឈើឱ្យដុះ លូតលាស់ជាលក្ខណៈធម្មជាតិ អាចធ្វើឱ្យព្រៃឈើដុះលូតលាស់ដោយមានប្រភេទឈើចម្រុះគ្នា ហើយនេះ គឺជាប្រភេទព្រៃ ដែលសហគមន៍ឱ្យតម្លៃខ្ពស់ជាងព្រៃដែលមានឈើតែមួយប្រភេទ ។ ការបង្កើនការយល់ដឹង និងពង្រីកសមត្ថភាពនៅថ្នាក់មូលដ្ឋានតាមវិធីបែបនេះ គួរតែជាគោលដៅនៃការពង្រឹងសមត្ថភាពនៅថ្នាក់ខេត្តផងដែរ ។ នៅក្នុងជំហានដំបូងនៃដំណើរការស្រាវជ្រាវសហគមន៍ព្រៃឈើសំខាន់គឺការចូលរួម និងគាំទ្រពីសំណាក់សហគមន៍មូលដ្ឋាន និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលផ្តល់នូវការយល់ដឹងអំពីតម្រូវការចំណេះដឹងបន្ថែមឱ្យដល់ក្រុមអ្នកសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធនានា។

ខ. ប្រសិទ្ធិភាពនៃការអនុវត្តសហគមន៍ព្រៃឈើ តម្រូវឱ្យមានកិច្ចសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធនានា ។ ការចែករំលែកបទពិសោធន៍តាមរយៈការស្រាវជ្រាវដោយអនុវត្តន៍ បានផ្តល់នូវកិច្ចសហការប្រកបដោយប្រសិទ្ធិភាព និងភាពជាដៃគូរវាងស្ថាប័នពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន និងស្ថាប័នជាដៃគូនានា។ ការរៀនសូត្រអាចរាប់បញ្ចូលទាំងអំពីកិច្ចសហការ និងភាពជាដៃគូរវាងស្ថាប័ននៅថ្នាក់ជាតិ ខេត្ត មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជន (ក្រុមហ៊ុនព្រៃសម្បទាន ។ ការផ្តួចផ្តើម និងសម្របសម្រួលប្រព័ន្ធប្រាស្រ័យទាក់ទង ការរៀនសូត្រ និងសហការរវាងស្ថាប័ន និងរវាងវិស័យនានា មានសារៈសំខាន់បំផុត ដើម្បីជម្រុញឱ្យមានការចូលរួមទូលំទូលាយនៅក្នុងការគ្រប់គ្រងធនធានរួមទាំង សហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ។

គ. កំណែទម្រង់គោលនយោបាយគ្រប់គ្រងព្រៃឈើ និងរបៀបចាត់ចែងស្ថាប័នមានសារៈសំខាន់ណាស់ ប៉ុន្តែនៅប្រឈមនឹងបញ្ហាលំបាកនៅឡើយ និងទាមទារឱ្យមានទំនាក់ទំនងទៅវិញទៅមកប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍រវាងអ្នកពាក់ព័ន្ធ និងអ្នករៀបចំគោលនយោបាយ ព្រមទាំងដំណើរការផ្លាស់ប្តូរនៅក្នុងស្ថាប័ន ។ ចំណងទាក់ទងរវាងអ្នកពាក់ព័ន្ធនានា និងអន្តរស្ថាប័ន ដូចជានៅក្នុងគម្រោង CFRP គឺជាគន្លឹះនាំមកនូវជោគជ័យជាបន្តបន្ទាប់ក្នុងកំណែទម្រង់គោលនយោបាយ និងការគ្រប់គ្រងស្ថាប័នដែលទាក់ទងទៅនឹងការងារសហគមន៍ព្រៃឈើ ។ ប្រការចាំបាច់គឺត្រូវពង្រឹង និងពង្រីកសមត្ថភាពគ្រប់គ្រងនៅក្នុងស្ថាប័ន ជាពិសេសនៅក្នុងថ្នាក់ខេត្ត និងថ្នាក់សហគមន៍ ពីព្រោះសមត្ថភាពស្ថាប័នមានឥទ្ធិពលខ្លាំងលើសហគមន៍មូលដ្ឋាន និងអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ។

## តើដំណើរនៃការស្រាវជ្រាវដោយអនុវត្តន៍គឺជាអ្វី ?

ការស្រាវជ្រាវដោយអនុវត្តន៍ គឺជាដំណើរការប្រកបដោយគោលបំណងច្បាស់លាស់ មានហេតុផល និងជាលក្ខណៈប្រព័ន្ធដែលផ្សំឡើងដោយសកម្មភាពជាច្រើន មានជាអាទិ៍ ការកសាងផែនការ ការប្រមូល និងវិភាគទិន្នន័យ ការធ្វើសេចក្តីសន្និដ្ឋាន និងការចាត់វិធានការណ៍ (Daniel, 1997:123) ។

ការស្រាវជ្រាវដោយអនុវត្តន៍ត្រូវបានធ្វើឡើង ដើម្បីកែលំអប្រសិទ្ធិភាព និងបង្កើនផលិតភាពក្នុងស្ថាប័ន និងដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតចំណងទាក់ទងជាមួយថ្នាក់នយោបាយ និងអ្នកធ្វើសេចក្តីសម្រេចសំខាន់ៗ។ ការស្រាវជ្រាវបែបនេះជួយផ្តល់ព័ត៌មាន ឬ ដំណឹងថ្មីៗដល់អ្នកធ្វើសេចក្តីសម្រេចស្តីពីស្ថានភាពបច្ចុប្បន្ននៅមូលដ្ឋាន និងសម្រួលឱ្យពួកគេធ្វើសេចក្តីសម្រេច និងកសាងយុទ្ធសាស្ត្រថ្មីដើម្បីដោះស្រាយបញ្ហានានា ដែលនៅពុំទាន់ដោះស្រាយរួចនៅឡើយ ។

### *ការកសាងក្រុមការងារ*

ជាទូទៅ ការកសាងក្រុមស្រាវជ្រាវប្រព្រឹត្តទៅនៅដំណាក់កាលដំបូងនៃគម្រោង និងតម្រូវឱ្យមានការពិចារណា ជាពិសេស ។ សមាជិកក្រុមមួយចំនួនដែលទទួលការតែងតាំងជាផ្លូវការ ជាពិសេសករណីជ្រើសរើសបុគ្គលិករដ្ឋាភិបាលសម្រាប់ជាមន្ត្រីសមភាគី ។ ក្នុងពេលជ្រើសរើសបុគ្គលិកសម្រាប់បំពេញការងារ ត្រូវមានការធ្វើសម្ភាសន៍ដើម្បីវាយតម្លៃអំពីការចាប់អារម្មណ៍ និងសមត្ថភាពរបស់បេក្ខជន ។

សមាជិកក្រុមការងារត្រូវតែត្រួតពិនិត្យឡើងវិញនូវគោលដៅ និងគោលបំណងរបស់គម្រោង និងចូលរួមវគ្គបណ្តុះបណ្តាលអំពីរបៀបអនុវត្តន៍ការងារជាក្រុម និងបច្ចេកទេសនៃការសិក្សាស្រាវជ្រាវ ។ វគ្គបណ្តុះបណ្តាលទាំងនោះ រួមមានទស្សនវិស័យជាមូលដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវ ហេតុផលចាំបាច់នាំឱ្យមានការស្រាវជ្រាវ និងអន្តរាគមន៍ ព្រមទាំងវិធីសាស្ត្រចាំបាច់ខ្លះៗសម្រាប់ការស្រាវជ្រាវ ។ ក្រុមការងារត្រូវធ្វើការក្នុងបរិយាកាសប្រកបដោយកិច្ចសហការ និងយោគយល់គ្នាទៅវិញទៅមក ។ ការកសាងបរិយាកាសស្និទ្ធស្នាល និងរឹងមាំក្នុងក្រុមការងារដែលសមាជិកក្រុមមានជំនាញ និងបទពិសោធន៍ផ្សេងៗគ្នា មិនមែនជាការលំបាកប៉ុន្មានទេ ប៉ុន្តែការរក្សានូវទំនាក់ទំនងទាំងនេះឱ្យបានយូរអង្វែង អាចប្រឈមនឹងការលំបាកច្រើន ។ ប្រធានក្រុមការងារ និងអ្នកសម្របសម្រួលនៅមូលដ្ឋាន ត្រូវតែបង្ហាញពីការតាំងចិត្ត អត់ធ្មត់ និងពោរពេញទៅដោយជំនាញសម្របសម្រួល ។

នៅក្នុងដំណាក់កាលកសាងក្រុមការងារ ក្រុមសិក្សាស្រាវជ្រាវត្រូវតែបង្កើនទំនាក់ទំនងស្និទ្ធស្នាលជាមួយអ្នកដឹកនាំសហគមន៍ ស្ថាប័នមូលដ្ឋាន និងស្ថាប័ននៅថ្នាក់ជាតិ ព្រមទាំងត្រូវកំណត់ក្របខ័ណ្ឌស្ថាប័ន ទស្សនវិស័យ និងវិធីសាស្ត្រនៃគម្រោង ។

សកម្មភាពបន្តទៅនេះ គឺវដ្តនៃការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍សហគមន៍ព្រៃឈើ :

## *ការជ្រើសរើស និងការស្វែងយល់ពីស្ថានភាពតំបន់សិក្សា*

ការវាយតម្លៃតំបន់សិក្សាជំហានដំបូង បានបង្ហាញពីរចនាសម្ព័ន្ធសង្គម និងកំណើនប្រជាពលរដ្ឋដើម្បីបង្ហាញពីភាពផ្សេងៗគ្នារវាងតម្រូវការរបស់ពួកគេ និងបញ្ហាដែលទាក់ទងទៅនឹងការប្រើប្រាស់ធនធានព្រៃឈើ ។ ជាទូទៅក្រុមការងារ និងមនុស្សសំខាន់ៗមួយចំនួនបានជ្រើសរើសយកលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ពីសក្តានុពលភាព ដោយយោងទៅតាមប្រភេទអេកូឡូស៊ី និងលក្ខខណ្ឌនៃព្រៃឈើ ចំណាប់អារម្មណ៍របស់សហគមន៍មូលដ្ឋាន ទំនាស់ និងធនធាននានាដែលមាននៅក្នុងតំបន់ ។

ការជ្រើសរើសតំបន់សិក្សា ក៏ទាក់ទងជាមួយបំណងប្រាថ្នា និងការព្រួយបារម្ភរបស់ស្ថាប័ន ថាតើអ្នកពាក់ព័ន្ធមានការពឹងផ្អែកលើធនធានព្រៃឈើកម្រិតណា ប្រសិនបើសហគមន៍មូលដ្ឋានបានបង្ហាញពីការចាប់អារម្មណ៍ និងការគាំទ្រ ។

**លក្ខណៈវិនិច្ឆ័យសំខាន់ៗ សម្រាប់ការជ្រើសទីតាំង**

- ប្រភេទព្រៃខុសគ្នា និងមានសភាពខុសគ្នា( ព្រៃស្រោង ពាក់កណ្តាលស្រោង ឬព្រៃរេចរឹល និងស្ថិតនៅក្នុង ឬ ក្រៅតំបន់ការពារធម្មជាតិ ឬនៅក្នុងតំបន់ព្រៃសម្បទាន
- ទំនាស់លើការប្រើប្រាស់ធនធាន ( ទំនាស់រវាងសហគមន៍ជិតខាង អ្នកមកពីក្រៅ បុគ្គលមានអំណាច និងផ្នែកឯកជន ។
- សម្ពាធលើធនធានព្រៃឈើ និងភាពរេចរិលនៃបរិស្ថាន
- កម្រិតនៃការពឹងផ្អែកលើធនធានព្រៃឈើសម្រាប់ការរស់នៅ
- អង្គការចាត់តាំងនៅក្នុងមូលដ្ឋាន និងការចាប់អារម្មណ៍ពីសហគមន៍លើ CF&CBNRM ។

តំបន់សិក្សានោះ គួរតែជាតំបន់ដែលអាចងាយស្រួលទៅដល់ និងមានសុវត្ថិភាពចំពោះសមាជិកមកពីទីក្រុងផងដែរ ។

## ***គំណត់ទិធីសាស្ត្រសិក្សាស្រាវជ្រាវ***

ការវាយតំលៃជនបទដោយមានការចូលរួម (PRA) ត្រូវបានទទួលស្គាល់ថា ជាឧបករណ៍មួយសម្រាប់ប្រមូល និងវិភាគព័ត៌មាន ។ PRA រួមផ្សំដោយវិធីសាស្ត្រជាច្រើន រួមមានការគូសផែនទីដោយមានការចូលរួម ការសម្ភាសពាក់កណ្ដាលផ្លូវការ គំនូសកាត់ទទឹង ចំណាត់ថ្នាក់ធនធាន ប្រតិទិនរដូវកាល គំនូសផែនទី រូបថតពីអាកាស និងលំហូរធនធាន ។ ខាងក្រោមនេះជាការសង្ខេបនូវឧបករណ៍ PRA សំខាន់ៗមួយចំនួន ដែលបានប្រើប្រាស់នៅក្នុងដំណើរការសិក្សាស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើនៅស្រុកជុំគីរី ខេត្តកំពត មកបង្ហាញនៅក្នុងប្រអប់ទី១ខាងក្រោម ៖

### **ការប្រមូលព័ត៌មានបន្ទាប់បន្សំ** (Secondary data gathering)

ការប្រមូលព័ត៌មានបន្ទាប់បន្សំនេះ ត្រូវធ្វើឡើងជាដំបូងមុននឹងការសិក្សាស្រាវជ្រាវដោយអនុវត្តន៍នៅមូលដ្ឋាន ។ ព័ត៌មានដែលមានស្រាប់អាចប្រមូលបានរួមមាន ៖ ផែនទី ស្ថិតិមូលដ្ឋាន និងឯកសារដទៃទៀត ដែលទាក់ទងទៅនឹងការសិក្សានៅក្នុងតំបន់ ។

### **ការគូរផែនទីដោយមានការចូលរួម** (Participatory mapping)

ការគូរផែនទីដោយមានការចូលរួម ជាទូទៅគឺ ឧបករណ៍ទី ១ ដែលត្រូវបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើ ។ ជាទូទៅ គេបានចាប់ផ្ដើមដោយជួបប្រជុំជាមួយសហគមន៍មូលដ្ឋាន ប្រធានភូមិ និងមនុស្សសំខាន់ៗមួយចំនួនទៀត ។ ការអនុវត្តវិធីសាស្ត្រនេះ ដំបូងផ្ដើមឡើងដោយកំណត់ពីកិច្ចការនៅក្នុងក្រុម និងគោលបំណងនៃការប្រមូលព័ត៌មាន ។ អ្នកចូលរួម ត្រូវបានស្នើឱ្យគូរ បង្ហាញនៅលើដី ឬក្រដាស ពីទីតាំងសហគមន៍ផ្ដើមចេញពីចំណុចដែលពួកគាត់ស្គាល់ច្បាស់ជាងគេ ដើម្បីឱ្យមានការងាយយល់ដល់អ្នកចូលរួមដទៃទៀត ។ ក្នុងខណៈគូរបង្ហាញនោះ មានសំណួរជាច្រើនសួរបន្តបន្ទាប់ ដើម្បីបញ្ជាក់ និងបង្ហាញទីតាំងដទៃទៀតនៅក្នុងផែនទីនោះ ។ បន្ទាប់ពីបញ្ចប់ការសួរនាំរួចនោះ ក្រុមការងារចំលងរូបភាពផែនទីនោះចូលក្រដាសថ្មី ដើម្បីប្រៀបធៀបជាមួយផែនទីផ្លូវការនៃតំបន់នោះ ។ គោលបំណងនៃការប្រើប្រាស់វិធីសាស្ត្រនេះ គឺចង់ទទួលបាននូវព័ត៌មានដែលទាក់ទងទៅនឹងទីតាំងភូមិសាស្ត្រ និងប្រភពនៃការប្រើប្រាស់ធនធាន ដែលមាននៅក្នុងសហគមន៍ ។

ការជ្រើសរើសបច្ចេកទេស និងឧបករណ៍សម្រាប់ការធ្វើផែនទីនេះ គួរធ្វើឡើងដោយប្រាកដថា ផែនទីដែលទទួលបានអាចមើលយល់ដោយសហគមន៍មូលដ្ឋាន និងអាចទទួលបានដោយស្ថាប័នជំនាញ ។ ផែនទីព្រៃឈើដែលទទួលបានជាដំបូងគួរមានភាពច្បាស់លាស់ និងអាច ពន្យល់បានដោយសហគមន៍មូលដ្ឋាន និងមន្ត្រីបច្ចេកទេស ។

យកផែនទីភូមិសាស្ត្រនៅកម្ពុជាមកពង្រីកបន្ថែម ហើយដាក់ផ្ទឹមនឹងផែនទីថតពីអាកាស អាចផ្ដល់ផែនទីជាមូលដ្ឋានមួយសម្រាប់ការធ្វើសារពើភ័ណ្ឌ ផែនទីប្រើប្រាស់ដីធ្លី និងសកម្មភាពកំណត់តំបន់ប្រើប្រាស់ផ្សេងៗ ។ ផែនទីព្រៃសហគមន៍ធ្វើឡើងដើម្បីបង្ហាញពីតំណាងដែលគួរឱ្យទុកចិត្តបាននៃលក្ខណៈព្រៃឈើ កម្មសិទ្ធិ និងការប្រើប្រាស់ក្នុងគោលបំណងពិភាក្សា និងធ្វើផែនការ ថែមទាំងអាចរក្សាទុកជាឯកសារយោង ។ ផែនទីមាត្រដ្ឋានដែលរួមផ្សំជាមួយផែនទីដែលគូសដោយមានការចូលរួម អាចពិពណ៌នាអំពីព័ត៌មាន និងពន្យល់ខ្លឹមសាររបស់វា ។

ឧបករណ៍ និងបច្ចេកទេសដែលយកទៅអនុវត្ត អាចផ្ដើមចេញពីផែនទីគូសដោយដៃផ្អែកតាមចំណេះដឹងសហគមន៍មូលដ្ឋាន រហូតដល់ការប្រើប្រាស់ផែនទី GIS រួមផ្សំជាមួយព័ត៌មានដែលមានស្រាប់ ព័ត៌មានទទួលបានពីផ្កាយរណប និងផែនទីទាក់ទងទៅនឹងស្ថានភាពទីតាំងភូមិសាស្ត្រ ។ ការប្រើប្រាស់បច្ចេកវិជ្ជាGIS រួមផ្សំជាមួយចំណេះដឹងមូលដ្ឋានបានផ្ដល់ការយល់ដឹងដល់ស្ថានភាពផ្ទាល់ ។

### ការសម្ភាសពាក់កណ្តាលផ្លូវការ

(Semi-structure interview)

ក្រុមអ្នកសិក្សាស្រាវជ្រាវធ្វើការសម្ភាសជាលក្ខណៈគ្រួសារ ឬ បុគ្គល ដើម្បីទទួលបានព័ត៌មានរួម ។ ក្នុងការអនុវត្ត ត្រូវចាប់ផ្តើមដោយបង្កើតសំណួរជាក់លាក់ដែលបានរៀបចំជាមុន ផ្អែកតាមគោល-បំណង និងប្រភពព័ត៌មានដែលត្រូវការ ។

ក្រុមអ្នកសិក្សាស្រាវជ្រាវនឹងបំបែកជាសំណួរតូចៗទៀតចេញពីសំណួរគោលដែលបានបង្កើតឡើង ប្រសិនបើពួកគេចង់បញ្ជាក់ឱ្យច្បាស់ពីទំនាក់ទំនងនៃសំណួរនោះ ។

### គំនូសផែនទី ( គូសដោយដៃ (Sketch map)

គំនូសផែនទីជាជំនួយដល់ការជួបសម្ភាសន៏ពាក់កណ្តាលផ្លូវការជាមួយគ្រួសារ ឬបុគ្គល និងដែលអាចបង្ហាញក្នុងពេលសួរសំនួរ ។ គំនូសផែនទីត្រូវបានកែសម្រួលពីផែនទីដោយមានការចូលរួម ហើយប្រជាជនត្រូវបានលើកទឹកចិត្តឱ្យចូលរួមគូរនៅលើគំនូសផែនទីនេះ ដើម្បីផ្តល់ព័ត៌មានបន្ថែមដែលនៅខ្វះចន្លោះ ។ អ្នកផ្តល់ចម្លើយអាចកំណត់ និងដាក់ឈ្មោះទីតាំង នៃការប្រើប្រាស់ធនធាននៅក្នុងសហគមន៏ ។

### លំហូរធនធាន (Resource flow)

វិធីសាស្ត្រនេះ បានបង្ហាញពីការផ្លាស់ប្តូរនៃធនធានព្រៃឈើនៅក្នុងភូមិ ជាពិសេសទៅតាមរបបនយោបាយពីជំនាន់មួយ ទៅជំនាន់មួយ ។ វិធីនេះអាចកត់ត្រានូវហេតុផលដែលនាំឱ្យមានការផ្លាស់ប្តូរផងដែរ ។ ដោយសារតែមានកំណត់ត្រាសកម្មភាពផ្សេងៗគ្នាទៅតាមពេលវេលានីមួយៗ ការចូលរួមពីមនុស្សនានា ( បុរស ស្រ្តី ចាស់ និងកុមារ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការទទួលបានព័ត៌មានសព្វគ្រប់ និងត្រឹមត្រូវ ។ ជាទូទៅវិធីសាស្ត្រនេះបានជម្រុញឱ្យមានការយល់ដឹងពីប្រវត្តិនៃការបំផ្លិចបំផ្លាញធនធានព្រៃឈើ ។

### គំនូសកាត់ទទឹង (Transect)

ទម្រង់នៃការអនុវត្តគំនូសកាត់ទទឹង ត្រូវកំណត់ដោយប្រើផែនទី ដោយមានការចូលរួមសម្រាប់ទទួលបានព័ត៌មានបន្ថែមទៀតដែលទាក់ទងទៅនឹងការប្រើប្រាស់ធនធាននៅក្នុងតំបន់នីមួយៗ ។ គំនូសកាត់ទទឹង ត្រូវបានធ្វើឡើងដោយធ្វើដំណើរជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើរកាត់តំបន់សិក្សាស្រាវជ្រាវ ដោយផ្តោតលើតំបន់ដែលមានការប្រើប្រាស់ធនធានព្រៃឈើ ការកាប់រានដីព្រៃធ្វើចម្ការ និងទីកន្លែងមានការប្រមូលអនុផលព្រៃឈើ ត្រូវបានបង្ហាញបញ្ហា និងឱកាស ដើម្បីលើកកំពស់ការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់សហគមន៏មូលដ្ឋាន ។

### រូបថតពីលើអាកាស (Arial photo)

ផែនទីថតពីអាកាស ត្រូវបានយកមកប្រើប្រាស់ជំនួសគំនូសផែនទី ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ រូបថតពីលើអាកាសបង្ហាញរូបភាពច្បាស់ជាក់លាក់នៅតាមតំបន់នីមួយៗ។ ប្រការនេះអាចផ្តល់ភាពលំបាក ដល់សហគមន៏ក្នុងការស្វែងយល់ ។ ដូច្នេះគេត្រូវការពេលវេលាច្រើន ដើម្បីសម្របសម្រួល និងបង្ហាញ ពីព្រំប្រទល់ដែលងាយស្គាល់បំផុត ។ គួរឱ្យសោកស្តាយផងដែរ រហូតមកដល់បច្ចុប្បន្នប្រទេសកម្ពុជានៅតែខ្វះខាតរូបថតពីលើអាកាសថ្មីៗនៅឡើយ ។

### ប្រជុំក្រុមគោលដៅ (Target group meeting)

វិធីសាស្ត្រនេះ ត្រូវបានប្រើប្រាស់ ដើម្បីផ្ទៀងផ្ទាត់ជាមួយវិធីសាស្ត្រលំហូរធនធាន និងតម្រូវឱ្យមានការសម្របសម្រួលប្រជាជនដែលមកប្រជុំគ្នាជាក្រុមធំ ។ ការប្រជុំក្រុមគោលដៅធ្វើឡើងក្នុងគោលបំណងផ្ទៀងផ្ទាត់ព័ត៌មានពីប្រភពផ្សេងៗទៀត និងស្វែងរកព័ត៌មានបន្ថែមទៀត ដែលនៅខ្វះចន្លោះ ផ្តល់ឱកាសឱ្យក្រុមអ្នកសិក្សាស្រាវជ្រាវបានស្វែងយល់បន្ថែមទៀតនូវចំណេះដឹង និងទស្សនទានរបស់សហគមន៏មូលដ្ឋាន ដែលទាក់ទងទៅនឹងបញ្ហាព្រៃឈើ ។

**ចំណាត់ថ្នាក់ធនធាន** (Wealth ranking)

ចំណាត់ថ្នាក់ធនធាន ត្រូវបានប្រើប្រាស់ ដើម្បីស្វែងយល់ពីលក្ខខណ្ឌនៃការរស់នៅ និងជីវភាពរបស់ប្រជាជននៅក្នុងសហគមន៍ និងអាចជាមូលដ្ឋាននៃការជ្រើសរើសក្រុមគ្រួសារ ដើម្បីធ្វើការសម្ភាស ។ នេះដោយសារការស្វែងយល់ ពីស្ថានភាព និងលក្ខខណ្ឌនៃជីវភាពរស់នៅ និងការប្រើប្រាស់ ធនធានព្រៃឈើរបស់សហគមន៍មូលដ្ឋានក្នុងចំណោមតំណាងប្រជា-កសិករនានានៅក្នុងតំបន់មានសារៈសំខាន់ណាស់ ។

**ប្រតិទិនរដូវកាល** (Seasonal calendar)

នេះជា វិធីសាស្ត្រ ដើម្បីកំណត់ពីសកម្មភាពរបស់សហគមន៍មូលដ្ឋានក្នុងរយៈពេលមួយឆ្នាំ ជាពិសេសសកម្មភាពទាក់ទងទៅនឹងការប្រើប្រាស់ធនធានព្រៃឈើ ។ វិធីនេះក៏ជួយឱ្យក្រុមសិក្សាស្រាវជ្រាវបានយល់ពីសកម្មភាពអ្វីនឹងកើតឡើងនៅខែណា និងរដូវណា ។ ប្រតិទិនបង្ហាញពីពេលវេលាមិនសូវមមាញឹករបស់សហគមន៍ ហេតុនេះក៏អាចជួយក្នុងការរៀបចំផែនការសម្រាប់អនុវត្តសកម្មភាព ដែលអាចជៀសវាងការប៉ះពាល់ពេលវេលាចិញ្ចឹមជីវិតជាប្រចាំរបស់ពួកគាត់ ព្រោះថាការចូលរួមរបស់សហគមន៍មានសារៈសំខាន់ និងចាំបាច់បំផុតនៅគ្រប់សកម្មភាពអភិវឌ្ឍន៍នានា ។

***ប្រអប់ ១ : វិធីសាស្ត្រវាយតម្លៃជនបទ ដោយមានការចូលរួម (PRA)***

មិនមែនគ្រប់ឧបករណ៍ PRA ដែលបានរៀបរាប់ខាងលើសុទ្ធតែសមស្របសម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវគ្រប់ប្រធានបទទាំងអស់នោះទេ ។ ជាទូទៅវិធីសាស្ត្រមួយចំនួនបានជ្រើសរើសមកប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានជាក់លាក់មួយ ។ ការជ្រើសរើសវិធីសាស្ត្រត្រូវធ្វើឡើងទៅតាមប្រធានបទ និងទីតាំងនៃការសិក្សាស្រាវជ្រាវ ។ សម្រាប់ការសិក្សាស្រាវជ្រាវដោយអនុវត្តអំពីសហគមន៍ព្រៃឈើ ជាទូទៅត្រូវប្រើប្រាស់វិធីគូសផែនទីធនធានដោយមានការចូលរួម ដើម្បីកំណត់ពីទីតាំងធនធាន បន្តដោយគំនូសកាត់ទទឹង និងសម្ភាសន៍ពាក់កណ្តាលផ្លូវការ ។ ទោះជាយ៉ាងណាក៏ដោយ ឧបករណ៍ PRA ត្រូវបានទទួលស្គាល់ថាអាចប្រើប្រាស់សម្រាប់ប្រមូល និងវិភាគព័ត៌មានដ៏មានប្រសិទ្ធិភាព ដោយត្រូវប្រើជំនាញផ្សេងទៀតរួមផ្សំផងដែរ រួមមានចារិកលក្ខណៈសមស្របរបស់អ្នកសិក្សាស្រាវជ្រាវ ដែលមានសារៈសំខាន់ធ្វើឱ្យមានទំនាក់ទំនងល្អជាមួយសហគមន៍មូលដ្ឋាន ។ ទំនាក់ទំនងល្អជាគន្លឹះដ៏សំខាន់ ដែលអាចទទួលបានព័ត៌មានត្រឹមត្រូវ ។

**ការវិភាគព័ត៌មាន**

ជាទូទៅការវិភាគព័ត៌មានត្រូវបានសម្របសម្រួលដោយក្រុមសិក្សាស្រាវជ្រាវ រួមជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត និងសហគមន៍មូលដ្ឋាន ។ ក្រុមសិក្សាស្រាវជ្រាវរួមជាមួយ សហគមន៍មូលដ្ឋាន សហការវិភាគ ផ្តល់យោបល់ និងបង្ហាញបន្ថែមនូវឫសគល់នៃបញ្ហា និងផលវិបាកដែលបានផ្តោតទៅលើប្រភព និងទស្សនៈផ្សេងៗ ស្តីពីបញ្ហាសង្គម នយោបាយ សេដ្ឋកិច្ច និងបរិស្ថាន ។ ការកំណត់ឫសគល់នៃបញ្ហា និងការរៀបចំយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ឃើញទាំងនោះនឹងអាចធ្វើឡើងក្រោយការវិភាគខាងលើនេះ ។ កត្តាសំខាន់នៃការរៀបចំយុទ្ធសាស្ត្រ

***ជំនាញក្នុងការកសាងទំនុកចិត្ត***

- និយាយភាសារបស់ប្រជាពលរដ្ឋមូលដ្ឋាន
- ណែនាំខ្លួន និងអំពីគោលបំណង
- ស្វែងរកពេលវេលាសមស្របដើម្បីជួប និងត្រូវថៃយ៉ាងណាឱ្យការប្រជុំមានរយៈពេលខ្លី
- ជួបប្រជុំទៀងទាត់ និងកំណត់ពីទិសដៅ
- លើកទឹកចិត្ត និងគាំទ្រគំនិតយោបល់ថ្មី
- លើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រី
- លើកទឹកចិត្តស្ថាប័ន និងសហគមន៍មូលដ្ឋានដែលចាប់អារម្មណ៍នឹង CF & CBNRM

នោះ គឺការវិភាគសក្តានុពលភាព ដែលនាំឱ្យការអនុវត្តយុទ្ធសាស្ត្រនោះបានជោគជ័យ ។

## ផែនការសកម្មភាព និងការអនុវត្ត

នៅក្នុងដំណើរការធ្វើផែនការជាដំបូង ក្រុមសិក្សាស្រាវជ្រាវបង្ហាញពីលំដាប់លំដោយនៃរបកគំហើញ ពិពណ៌នាពីលទ្ធភាពដែលអាចដោះស្រាយទំនាស់ ។ របកគំហើញទាំងនោះរួមមានសំណូមពរអំពីសកម្មភាពដែលអាចអនុវត្តទៅបាន ហេតុផលរបស់វា និងតម្រូវការធនធានសម្រាប់ការអនុវត្ត ។ បន្ទាប់ពីបានកំណត់ជម្រើសមួយចំនួនមកក្រុមសិក្សាស្រាវជ្រាវ គួរកំណត់ពីទិសដៅ និងគោលបំណង ។ ទិសដៅ និងគោលបំណងគួរតែកំណត់ក្នុងកម្រិត ដែលប្រាកដថាជាការចាប់អារម្មណ៍របស់ស្ថាប័ន ការតាំងចិត្តកិច្ចខិតខំប្រឹងប្រែង និងការគាំទ្រផ្នែកភស្តុភារ ។

បន្ទាប់ពីក្រុមការងារបានកំណត់ពីទិសដៅ និងគោលបំណងរួមមក បំលែងទិសដៅ និងគោលបំណងរួមនោះទៅជាផែនការសកម្មភាពដែលត្រូវយកទៅអនុវត្ត ដើម្បីឱ្យសម្រេចបានទៅតាមទិសដៅ និងគោលបំណងដែលបានកំណត់ ។ គួររៀបចំបង្កើតផែនការទូទៅមួយ ដោយភ្ជាប់មកជាមួយនូវសកម្មភាពពិស្តារ ព្រមទាំងចែងលំអិតពីសកម្មភាព និងការកំណត់ពេលវេលា និងការទទួលខុសត្រូវរបស់អ្នកស្រាវជ្រាវ ដែលមកពីអង្គការនីមួយៗ ។

## ការវាយតម្លៃ និងការផ្តល់ព័ត៌មានត្រឡប់

ផែនការសកម្មភាពនេះរួមបញ្ចូលទាំងទម្រង់ការសម្រាប់ធ្វើការវាយតម្លៃ ដែលត្រូវអនុវត្តក្នុងពេល និងបន្ទាប់ពីដំណាក់កាលនៃសកម្មភាពនីមួយៗ ។ ត្រូវធ្វើការវាយតម្លៃ ដើម្បីកំណត់ផលប៉ះពាល់នៃសកម្មភាពការងារសិក្សា ដើម្បីប៉ាន់ប្រមាណមើលថា តើគោលបំណងទាំងអស់របស់គម្រោងត្រូវបានបំពេញហើយឬនៅ និងដើម្បីផ្តល់ព័ត៌មានគ្រឹះជាមូលដ្ឋានសំរាប់រៀបចំបង្កើតផែនការសកម្មភាព និងការងារទៅថ្ងៃអនាគត ។ ការវាយតម្លៃគួរមានបញ្ចូលការកំណត់និយមន័យ និងសេចក្តីពិពណ៌នាអំពីដំណើរការដែលនាំឱ្យគម្រោងមួយសំរេចលទ្ធផលរយៈពេលយូរអង្វែងរបស់ខ្លួន ។

## មេរៀនទទួលបាន
## វដ្តនៃការស្រាវជ្រាវដោយអនុវត្តន៍

ការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍ មិនត្រូវធ្វើឡើងក្នុងរយៈពេលកំណត់តែមួយសម្រាប់ការសិក្សាស្រាវជ្រាវទេ ប៉ុន្តែត្រូវតែជាបណ្តុំនៃសកម្មភាព ឬ ក៏ជាករណីសិក្សាក្នុងអំឡុងនៃការអនុវត្តគម្រោង ។ ការសិក្សាស្រាវជ្រាវដោយអនុវត្តន៍ ត្រូវបានពិពណ៌នាថា ជាវដ្តនៃសកម្មភាពដែលរួមមានការឆ្លុះបញ្ចាំង ការកំណត់ពីសំណួរសម្រាប់សិក្សាស្រាវជ្រាវជាគន្លឹះ ការសិក្សា

ស្រាវជ្រាវនៅមូលដ្ឋាន ការអនុវត្ត និងការឆ្លុះបញ្ចាំងត្រឡប់វិញ ។ ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃដើម្បីឱ្យប្រាកដ ថាលទ្ធផលដែលទទួលបានឆ្លើយតបទៅនឹងគោលបំណង និងទិសដៅរបស់គម្រោង (សូមពិនិត្យមើលដ្យាក្រាមទី ៣ ) ។




*រូបទី៣ : ដ្យាក្រាមអំពីវដ្តនៃការសិក្សា និងស្រាវជ្រាវដោយអនុវត្តន៍*

## ផលប៉ះពាល់

តាមរយៈការសិក្សាស្រាវជ្រាវដោយអនុវត្តន៍អំពីសហគមន៍ព្រៃឈើ ប្រជាពលរដ្ឋអាចមើលឃើញពីមូលហេតុដែលសហគមន៍ព្រៃឈើ (CF) និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមមានពីសហគមន៍ (CBNRM) មានសារៈសំខាន់សម្រាប់ពួកគាត់ និងកូនចៅជំនាន់ក្រោយ ។ សហគមន៍ចាប់ផ្តើមយល់ដឹងពីចំណាប់អារម្មណ៍ និងតួនាទីរបស់ពួកគាត់ក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត ។ សហគមន៍មូលដ្ឋានទទួលបានការពេញចិត្តចំពោះសមត្ថភាពរបស់ពួកគាត់ក្នុងការអនុវត្តកិច្ចការ និងផែនការសហគមន៍ ដោះស្រាយបញ្ហា និងទំនាស់ដើម្បីសម្រេចបានគោលបំណង និងការចាប់អារម្មណ៍រួម ។ សមត្ថភាពកសាងផែនការនៅមូលដ្ឋានត្រូវបានពង្រឹង ហើយប្រជាពលរដ្ឋបានទទួលអំណាចដើម្បីដោះស្រាយបញ្ហា និងទំនាស់របស់ពួកគាត់ដែលទាក់ទងនឹងសហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ។

លើសពីនេះទៅទៀត ប្រជាពលរដ្ឋបានយល់ពីតម្រូវការនៃការគាំទ្រ ហើយរដ្ឋាភិបាលបានទទួលស្គាល់តាមរយៈគោលនយោបាយ CF/CBNRM ច្បាប់ និងបទបញ្ញរយៈពេលវែង និងការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព ។ អ្នកធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយអាចប្រើប្រាស់របកគំហើញនៃការសិក្សាស្រាវជ្រាវដើម្បីជួយដល់ការរៀបចំគោលនយោបាយ ច្បាប់ និងបទដ្ឋាននានាទាក់ទងទៅនឹង CF/CBNRM ។ ផលប៉ះពាល់ដ៏ធំធេងនៃការសិក្សាស្រាវជ្រាវ និងអនុវត្តន៍អាចសង្ខេបបានដូចជាការផ្តល់អំណាច និងសេចក្តីសម្រេចដល់សហគមន៍មូលដ្ឋាន ការផ្លាស់ប្តូរខាងស្ថាប័ន និងការគាំទ្រផ្នែកគោលនយោបាយ ។

## ការប្រឈម

ជោគជ័យជាចម្បងនៃការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍ រួមមានការប្តេជ្ញាចិត្ត និងការទទួលបានការគាំទ្រផ្នែកគោលនយោបាយ ។ "ការចូលរួម" ជាពាក្យដែលទទួលបានការនិយមលើវិស័យអភិវឌ្ឍន៍ ប៉ុន្តែមិនមានការងាយស្រួលក្នុងការអនុវត្តនោះទេ ។



អ្នកអនុវត្តនៅមូលដ្ឋានបាន ប្រើប្រាស់ពេលវេលាដ៏សន្ធឹកសន្ធាប់ធ្វើការជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដើម្បីទទួលបានការយល់គ្នាទៅវិញទៅមក ហើយធ្វើការទទួលបានលទ្ធផលល្អ ។ ដើម្បីឱ្យមានកិច្ចសហការល្អទាមទារពេលវេលាច្រើន ប៉ុន្តែវាងាយប្រេះឆាវិញ ដោយសារតែមានកត្តាខាងក្នុង និងខាងក្រៅកើតឡើង ។

ដូចគ្នានេះដែរ ការបញ្ចុះបញ្ចូលឱ្យប្រជាពលរដ្ឋធ្វើការប្ដេជ្ញាលើគោលដៅយូរអង្វែង និងអោយពួកគាត់ជឿថាការធ្វើបែបនេះអាចសម្រេចទៅបាន មិនមែនប្រព្រឹត្តទៅក្នុងរយៈពេលដ៏ខ្លីបាននោះទេ។ ការធ្វើបែបនេះបានទាមទារការប្ដេជ្ញាចិត្ត ខ្លាំងក្លា និងយូរអង្វែងពីអ្នកសម្របសម្រួលក្រុមអ្នកសិក្សាស្រាវជ្រាវ និងតំណាងសហគមន៍ ព្រោះបុគ្គលមួយចំនួនចង់ឃើញលទ្ធផលជាក់ស្ដែងសិនមុននឹងផ្ដល់ភាពជឿជាក់។ លើសពីនេះ ការទទួលបានការគាំទ្រខាងផ្នែកគោលនយោបាយអាចរួម ចំណែកឱ្យដំណើរការសិក្សាស្រាវជ្រាវដោយអនុវត្តន៍បានទទួលជោគជ័យ ប៉ុន្តែមិនអាចធ្វើទៅបានទេប្រសិនបើអ្នកធ្វើសេចក្ដីសម្រេចគោលនយោបាយទាំងនោះមិនទាន់យល់ច្បាស់ពីស្ថានភាព បញ្ហា និងផលលំបាកនានា ដែលបានកើតឡើងនៅមូលដ្ឋាននោះ។ ដូច្នេះ នៅពេលដែលពួកគេបានយល់ពីស្ថានភាពជាក់ស្ដែងនៅមូលដ្ឋាននោះ ការចូលរួមរៀបចំគោលនយោបាយ ក៏បានគិតគូរអំពីការលំបាកទាំងនោះផងដែរ ។ ប៉ុន្តែការពិត ការបញ្ចុះបញ្ចូលអ្នកធ្វើសេចក្ដីសម្រេចខាងគោលនយោបាយឱ្យធ្វើការផ្លាស់ប្ដូរ ក៏ជាការលំបាកខ្លាំងណាស់ដែរ។ ដូច្នេះហើយបានជាអ្នកសិក្សាស្រាវជ្រាវតែងតែលើកជាសំនួរឡើងថា តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យការសិក្សាស្រាវជ្រាវដោយអនុវត្តន៍អាចផ្សារភ្ជាប់ និងជួយអ្នកធ្វើសេចក្ដីសម្រេចគោលនយោបាយ ។

## ស្ថានភាព CF និង CBNRM បច្ចុប្បន្ននៅកម្ពុជា

ទាំងស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលកំពុងធ្វើការរួមគ្នា ដើម្បីគាំទ្រការអភិវឌ្ឍ CF/CBNRM នៅកម្ពុជា ។ យុទ្ធសាស្ត្រមួយចំនួនទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ កំពុងទទួលបានការយល់ដឹង និងគាំទ្រដោយសហគមន៍មូលដ្ឋាននានា ហើយក៏ទទួលបានផងដែរនូវការគាំទ្រដ៏ធំធេងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា (RGC) តាមរយៈការអនុម័តលើអនុក្រឹត្យស្ដីពីសហគមន៍ព្រៃឈើនៅឆ្នាំ២០០៣។ ការកសាងសមត្ថភាពលើការរៀបចំផែនការសម្រាប់ជាតម្រូវការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ត្រូវបានពង្រឹងតាំងពីថ្នាក់ជាតិ ខេត្ត និងកម្រិតមូលដ្ឋាន ដើម្បីធ្វើឱ្យប្រាកដថា ការសម្របសម្រួល និងការអនុវត្តសហគមន៍ព្រៃឈើមានប្រសិទ្ធភាពទូទាំងប្រទេស ។

រដ្ឋបាលព្រៃឈើ និងការិយាល័យថ្នាក់ខេត្តត្រូវផ្សព្វផ្សាយពីទិសដៅ និងការកសាងសមត្ថភាព ដើម្បីបំពេញតួនាទីរបស់ពួកគេក្នុងការគាំទ្រការអភិវឌ្ឍសហគមន៍ព្រៃឈើក្នុងតំបន់ ។ ទោះជាយ៉ាងណាក៏ដោយ ភាពបត់បែននៃយុទ្ធសាស្ត្រតម្រូវឱ្យមានការចូលរួមពីស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីទទួលបានការរៀនសូត្រពីគ្នាទៅវិញទៅមកនូវជំនាញសមស្របសម្រាប់ការចូលរួមគាំទ្រ និងអនុវត្តសហគមន៍ព្រៃឈើ ។

បច្ចុប្បន្នមានការទទួលស្គាល់ និងឱ្យតំលៃអំពីតំរូវការឱ្យមានវិធីសាស្ត្រ ដែលផ្អែកលើការស្រាវជ្រាវ និងការចូលរួមប្រកបដោយប្រសិទ្ធិភាពរបស់សហគមន៍មូលដ្ឋាននៅក្នុងការរៀបចំលក្ខន្តិកៈ សហគមន៍ និងផែនការគ្រប់គ្រង ។

## សន្និដ្ឋាន

ការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍ មានសារៈសំខាន់ក្នុងការរួមចំណែកផ្ដល់អំណាចដល់សហគមន៍មូលដ្ឋាន និងការអភិវឌ្ឍវិធីសាស្ត្រដែលយកមកប្រើប្រាស់ទាំងនេះអាចមានឥទ្ធិពលខ្លាំងក្លាទៅបាន អាស្រ័យលើថាតើអ្នកណាខ្លះមានចំណាប់អារម្មណ៍ក្នុងការចូលរួម និងតើត្រូវចាត់វិធានការអ្វីខ្លះ តាមវិធីណា នៅពេលណា និងនៅទីកន្លែងណាតែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយ  ការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍  គឺធ្វើឡើងក្នុងគោលបំណងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ដែលស្ថិតនៅក្នុងភាពប្រឈម និងភាពស្មុគស្មាញនៃកាតព្វកិច្ចជាច្រើន ។ គោលបំណងដ៏ជាក់លាក់ ត្រូវតែបង្កើតឡើងដែលបានកំណត់ពីគោលដៅសម្រាប់រយៈពេល ៥-១០ ឆ្នាំ និងត្រូវធ្វើឱ្យប្រាកដថា គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលគាំទ្រសកម្មភាពសហគមន៍ព្រៃឈើ បានដឹងពីតួនាទី និងការទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាដ៏ចម្បងៗ ដែលទាក់ទងជាមួយ CF/NRM នៅគ្រប់ជំហានសំខាន់ៗ ។

ទីបំផុត ការចូលរួមសិក្សាស្រាវជ្រាវដោយអនុវត្តន៍ គឺត្រូវបានចងក្រងឡើង ដើម្បីជម្រុញការផ្លាស់ប្តូរសង្គម លើកទឹកចិត្តដល់ប្រជាធិបតេយ្យភាព កិច្ចទំនាក់ទំនង និងការសម្រេច ដែលឈានទៅដល់ការផ្តល់អំណាច និងផលប្រយោជន៍ដល់ប្រជាជន ។

## REFERENCES


Selender, Daniel. 1997. *Participatory Action Research and Social Change*

Technical Report. 2002. *Chumkiri, Kampot Team/CFRP: The Relationship between people and forest resources.*

Annual Report Year II. 2002. *Community Forestry Research Project (IDRC/RECOFTC)*

Final Report Phase I. 2003. *Community Forestry Research Project (IDRC/RECOFTC)*

Annual Report Year I, Phase II. 2004. *Community Forestry Research Project (IDRC)*

IDRC-Case paper. 2004. *Strengthening Local Voices to Inform National Policy: Community Forestry in Cambodia*

CBNRM Case Paper. 2003, *Bhutan Workshop: Case study present on Action Research for Community Forestry: Challenges and lesson in cooperation and learning on the experiences in Cambodia.*

# ជំពូក ១៣ ការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស

រៀបរៀងដោយ លោកបណ្ឌិត Andy Maxwell[១] លោក ជាម មុនី[២] និងក្រុម MOSAIC[៣]

ឯកសារនេះបង្ហាញពីផ្នែកសំខាន់ៗ នៃវិធីសាស្ត្រថ្មីមួយចំពោះការគ្រប់គ្រងធនធាន និងការអភិរក្សជីវៈចម្រុះនៅតំបន់ភាគខាងកើតនៃប្រទេសកម្ពុជា ។

## សេចក្តីផ្តើម

តំបន់ប៉ែកខាងកើតនៃប្រទេសកម្ពុជាកំពុងត្រូវបានទទួលស្គាល់ថាជាតំបន់មួយក្នុងចំណោមតំបន់សំខាន់ៗជាងគេបំផុតជាច្រើននៅអាស៊ីអាគ្នេយ៍ សម្រាប់ការអភិរក្សសត្វព្រៃ និងទីជម្រកនៃរបាយប្រភេទថនិកសត្វ និងសត្វស្លាប ជាច្រើនដែលមិនមាននៅកន្លែងផ្សេងៗទៀតនៅលើផែនដីយើងនេះ (Timmins and Ou, 2001; Maxwell & Pinsonneault, 2001; Goodman, *et al.*, 2003; Tordoff *et al.*, 2004) ។ ប្រភេទសត្វព្រៃសំខាន់ៗជាសកលទាំងអស់នេះរស់នៅក្នុងតំបន់ទេសភាពមួយដែលសម្គាល់ដោយផ្ទៃដីធំទូលាយនៃបណ្តុំជម្រកប្លែកៗ លាតសន្ធឹងចាប់ពីតំបន់ដីសើមតាមរដូវ រហូតដល់តំបន់ព្រៃស្រោងដែលដុះខ្ពស់ៗ ។ តំបន់ទេសភាពទាំងនេះគ្របដណ្តប់ទៅដោយព្រៃល្បោះដ៏ធំល្វឹងល្វើយ ដែលផ្តល់ជាកន្លែងសម្រាប់ ថនិកសត្វស៊ីស្មៅជាអាហារដូចជា: ដំរី ទន្សោង ក្របីព្រៃ ខ្ទីង រួមជាមួយនឹងពពួកសត្វស៊ីសាច់ជាអាហារ ដូចជា ខ្លាធំ ខ្លារខិន ឆ្កែចចក (សត្វឆ្កែព្រៃអាស៊ី និងសត្វផ្សេងៗទៀត។ ការអភិរក្សតំបន់ទេសភាពនេះមានតម្លៃខ្ពស់ ដោយសារវត្តមាននៃសត្វស្លាបទឹកធំៗ ជាអាទិ៍ សត្វក្រៀល ត្រយ៉ងយក្ស ក្រសា។ ដោយសារតម្លៃជីវសាស្ត្រគួរឱ្យកត់សម្គាល់នេះ ព្រមទាំងការគម្រាមកំហែងផ្សេងៗទៀត តាមតំបន់នេះក្នុងប្រទេសកម្ពុជា បានធ្វើឱ្យអង្គការអភិរក្សអន្តរជាតិជាច្រើន (WWF WCS FFI និង CAT) ដៃគូភ្នាក់ងាររដ្ឋាភិបាលដូចជា ក្រសួងបរិស្ថាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រួមជាមួយម្ចាស់ជំនួយ បានធ្វើការវិនិយោគយ៉ាងច្រើន ដើម្បីការពាររបាយសត្វព្រៃដែលនៅសេសសល់ និងទីជម្រករបស់ពួកសត្វទាំងនោះ។

នៅពេលដែលការវិនិយោគដើម្បីអភិរក្សសត្វព្រៃបានធ្វើឡើងក្នុងបំណងថែរក្សាធនធានដ៏មានតម្លៃ ការវិនិយោគដើម្បីដោះស្រាយបញ្ហាជីវភាពរស់នៅជាមូលដ្ឋានរបស់មនុស្សដែលរស់នៅទូទាំងតំបន់ទេសភាពទាំងនោះ ត្រូវបានមើលឃើញថាមានភាពខ្វះចន្លោះ។ ប្រការសំខាន់គឺ ភ្នាក់ងារអភិរក្ស និងអង្គការនានាពុំទាន់មានលទ្ធភាពក្នុងការដោះស្រាយ ដែលចំណោទ

---

[១] លោកបណ្ឌិត Andy Maxwell បច្ចុប្បន្នជាប្រធានគម្រោងប្រភេទព្រៃរបោះ មានការិយាល័យនៅអង្គការ WWF និងជាទីប្រឹក្សាគម្រោង MOSAIC-EP

[២] លោក ជាម មុនី ជាប្រធានក្រុមនៃគម្រោង MOSAIC-EP និងជាបុគ្គលិកការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ ។

[៣] អ្នករួមចំណែក: អ៊ុល គឹមសា សុន បូរ៉ា អែម ត្រាយ ស៊ រ៉ាំង ឌី វិចិត្រ ស្រី ម៉ារ៉ូណា លន់ សម្ផស្ស រ័ត្ន សុវណ្ណ ងិន លីណាស្សាណែត ថូប៊ី ខាស៊ិន សូ ស្រីមុំ ហ៊ូ កល្យាណ Becky Kinakin អ៊ូ រតនៈ ចក់ សុខវិជ្ជបុត្រ លិ វុឌ្ឍី ដួង គង់ ហេង ប៊ុន្នី ក្រុមការពារ PPWS និង Mr. Martin Von Kaschke ។

ថាតើសហគមន៍អាចរក្សាស្ថេរភាពនៃការរស់នៅរបស់ខ្លួនបានទេ នៅពេលដែលការហាមឃាត់ភ្លាមៗ មិនឱ្យជម្រើសនានានៃការបរបាញ់ និងពាណិជ្ជកម្មសត្វព្រៃដោយគ្មាននិរន្តរភាព (ដែលសកម្មភាពបែបនេះបានត្រូវប្រព្រឹត្តដោយគ្មានការត្រួតពិនិត្យអស់រយៈពេលជិតម្ភៃឆ្នាំមកហើយនោះ ។

ទោះបីជាមានភាពចាំបាច់ជាបន្ទាន់ក្នុងកិច្ចការពារយ៉ាងតឹងរ៉ឹងនូវរបាយសត្វព្រៃសំខាន់ៗដែលនៅសេសសល់យ៉ាងណាក៏ដោយ ក៏មានការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅក្នុងប្រទេសកម្ពុជា នៅពេលពិចារណាអំពីកង្វះការចូលរួមពិតប្រាកដពីសហគមន៍មូលដ្ឋានក្នុងការអភិរក្ស និងការសម្រេចចិត្តក្នុងការគ្រប់គ្រងធនធាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅទូទាំងទ្វីបអាស៊ី អាហ្វ្រិក និង អាមេរិកខាងត្បូង ដែលការខ្វះនូវការទំនាក់ទំនងពិតប្រាកដជាមួយសហគមន៍មូលដ្ឋានក្នុងការអភិរក្ស និងការធ្វើសេចក្តីសម្រេចចិត្តគ្រប់គ្រងធនធាន នឹងធ្វើឱ្យសហគមន៍ទាំងនោះមិនទទួលយកការអភិរក្សនោះទៅវិញ ពីព្រោះពួកគាត់យល់ថាវាមានគោលការណ៍ផ្ទុយទៅនឹងតម្រូវការជាមូលដ្ឋានសម្រាប់ការរស់នៅ ។



ហ៊ុយ តារ៉ុង / WWF ២០០៣

***ការធ្វើជំនួញសត្វព្រៃគឺជាការប្រឈមធំបំផុតសម្រាប់ការអភិរក្សនៅប្រទេសកម្ពុជា ។ ក្នុងរូបនេះ គឺស្នែងខ្ទីង និងសត្វត្រកួតដែលត្រូវបានចាប់ និងថតនៅខេត្តក្រចេះ ។ គោលដៅនៃការនាំចេញ : ពុំទាន់ដឹង...***

នៅឆ្នាំ ២០០១ អង្គការ WWF បានផ្តួចផ្តើមបង្កើតគម្រោងមួយដែលហៅថា" MOSAIC-Eastern Plains" (ការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីដាក់បញ្ចូលទៅក្នុងការអភិរក្សតំបន់ខ្ពង់រាបខាងកើត ដើម្បីជួយសម្របសម្រួលដល់ការអភិរក្ស និងការកសាងផែនការប្រើប្រាស់ដីធ្លីនៅកម្រិតតំបន់ទេសភាព ។ គម្រោងនេះបានកើតចេញពីគំនិតផ្តួចផ្តើមធ្វើករណីសិក្សាអំពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដែលបានផ្តល់ឱ្យបុគ្គលិកគម្រោង MOSAIC នូវមូលដ្ឋានរឹងមាំមួយក្នុងការរៀបចំបណ្តាញចូលរួមកសាងផែនការប្រើប្រាស់ដីធ្លី (PLUP) និងការគ្រប់គ្រងធនធានធម្មជាតិ ដោយសហគមន៍ (CBNRM) ។គម្រោងនេះបានទទួលស្គាល់ថា បណ្តាសកម្មភាពបង្កើនការយល់ដឹងអំពីការអភិរក្ស ដែលបានធ្វើកន្លងមកនៅក្នុងខេត្តមណ្ឌលគិរី មានត្រឹមតែការបង្រៀនអំពីច្បាប់ការពារសត្វព្រៃដែលពាក់ព័ន្ធដែលមិនបានចង្អុលបង្ហាញដល់សហគមន៍មូលដ្ឋាន ថាតើតម្រូវការជីវភាពរបស់ពួកគាត់ត្រូវបានដោះស្រាយ ឬក៏ត្រូវបានទទួលស្គាល់ក្នុងគោលនយោបាយអភិរក្សយ៉ាងដូចម្តេច ។

ការស្ទាបស្ទង់ជាមុនរបស់គម្រោង MOSAIC (Pre-MOSAIC Survey) នៅក្នុងខេត្តមណ្ឌលគិរី ជាអាទិ៍ ការអង្កេតសត្វព្រៃដោយអង្គការ WWF និងដៃគូនានាបានបង្ហាញអោយឃើញថា សហគមន៍មួយចំនួនមានតួនាទីសំខាន់ជាយុទ្ធសាស្ត្រក្នុងការអភិរក្សតំបន់ទេសភាព ហើយគម្រោងMOSAIC បានប្រើប្រាស់ព័ត៌មាននេះនៅពេលធ្វើការពិចារណាអំពីសក្តានុពលនៃ

ទីតាំងគម្រោង ។ បណ្ដាទីតាំងគម្រោងទាំងឡាយត្រូវបានជ្រើសរើសដោយផ្អែកលើទីតាំងតំបន់នានា ដែលមានសក្ដានុពលខ្ពស់សម្រាប់ការអភិរក្ស ជាពិសេសនៅក្នុង និងនៅជុំវិញដែនជម្រកសត្វព្រៃភ្នំព្រេច និងព្រៃការពារមណ្ឌលគិរី ។ ទីតាំងទាំងនេះស្ថិតនៅដាច់ស្រយាល ហើយភូមិទាំងនោះភាគច្រើនពុំមានផ្លូវចេញចូលស្រួលឡើយ ដោយត្រូវចំណាយពេលធ្វើដំណើរយ៉ាងតិចមួយថ្ងៃ ដើម្បីធ្វើដំណើរពីទីរួមខេត្ត ។

ដំណាក់កាលទីមួយនៃគម្រោង MOSAIC គឺការផ្សព្វផ្សាយ និងការស្រាវជ្រាវទូលំទូលាយអំពីប្រវត្តិភូមិ ជីវភាពរស់នៅ និងទំនាក់ទំនងរបស់ពួកគេជាមួយជីវៈចម្រុះនៅក្នុងតំបន់ ។ ភាគច្រើននៃភូមិទាំងនេះមិនត្រូវបានរាប់បញ្ចូលនៅក្នុងទិន្នន័យភូមិសាស្ត្រថ្នាក់ជាតិ ហេតុនេះភូមិទាំងនេះមិនត្រូវបានរាប់បញ្ចូលនៅក្នុងស្ថិតិជាតិឆ្នាំ១៩៩៨ នោះឡើយ ។ ភូមិខ្លះមិនបានចូលរួមក្នុងការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០០២ ហើយភូមិខ្លះទៀតមិនត្រូវបានទទួលស្គាល់ដោយអាជ្ញាធរខេត្តឡើយ ។ គម្រោង MOSAIC បានចំណាយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីចូលទៅដល់ភូមិដាច់ស្រយាលទាំងនេះ និងដើម្បីប្រមូលព័ត៌មាន អំពីប្រជាសាស្ត្រ និងភូមិសាស្ត្រ សម្រាប់ជាមូលដ្ឋានទាក់ទងទៅនឹងការកសាងផែនការតំបន់ទេសភាព និងការគ្រប់គ្រងធនធាន ។

## ការបង្កើតភាពជាដៃគូ

កម្មវិធីសិលាបានជួយសម្របសម្រួល និងគាំទ្រដល់ការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន ដែលនេះជាការងារស្នូលនៃគោលបំណងរបស់កម្មវិធីខ្លួន ។ កម្មវិធីថ្នាក់ជាតិនេះបានជួយក្រុមប្រឹក្សាឃុំចំនួន ១៦២៣ដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយសេរី ដើម្បីធ្វើផែនការអភិវឌ្ឍន៍ឃុំ (CDP) ដែលធ្វើឱ្យឃុំមានសិទ្ធិទទួលថវិកាអភិវឌ្ឍន៍តាមកំណត់ ក្រោយពេលអនុម័តផែនការនោះ ។ កម្មវិធីសិលា(សូមអានជំពូកទី ៤) បានចាប់ផ្ដើមនៅខែមិនា ឆ្នាំ២០០៣ ក្នុងខេត្តមណ្ឌលគិរី ដែលជាកន្លែងអាទិភាពទីមួយ ដើម្បីកសាងសមត្ថភាពមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ឃុំ សម្រាប់កសាងផែនការអភិវឌ្ឍន៍ឃុំឱ្យមានលក្ខណៈរលូន ។

យោងតាមអនុសាសន៍របស់កម្មវិធីសិលា គម្រោង MOSAIC កំពុងសហការជាមួយក្រុមកម្មវិធីសិលា ក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលានៅក្នុងឃុំ និងខេត្តរបស់ពួកគេ ដើម្បីធានាថា បញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិត្រូវបានដាក់បញ្ចូលក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំ ។



អែនឌី ម៉ាក់វែល / ១៩៩៥

*ផ្លូវលំក្នុងព្រៃល្បោះនៅភាគខាងត្បូងនៃខេត្តរតនគិរី*

គម្រោង MOSAIC បានស្វែងយល់ពីគម្រោង PLG-Seila នៅក្នុងខេត្តរតនគិរី ដែលជាគំរូដ៏ជោគជ័យនៃការកសាងផែនការដោយមានការចូលរួម និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (CBNRM) និងដែលត្រូវបានអភិវឌ្ឍនៅក្នុងតំបន់សហគមន៍ជនជាតិដើមភាគតិចអស់រយៈពេលជាង ៦ ឆ្នាំមកហើយ ។ អង្គការផ្សេងៗទៀតដែលធ្វើការក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិនៅក្នុងខេត្តរតនៈគិរី មានជាអាទិ៍ NTFP ខេត្តរតនគិរី និង CIDSE ។

បន្ថែមលើកម្មវិធីសិលាក្នុងខេត្តមណ្ឌលគិរី គម្រោង MOSAIC សហការយ៉ាងជិតស្និទ្ធជាមួយអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដែលបានជម្រុញយ៉ាងខ្លាំងលើការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP) នៅថ្នាក់ខេត្ត និងគ្រប់គ្រងគម្រោងសាកល្បងស្តីពីការចុះបញ្ជីកម្មសិទ្ធិដីធ្លីនៅថ្នាក់ឃុំ ។ ជាមួយគ្នាផងដែរ ពេលសកម្មភាពគម្រោង MOSAIC ត្រូវបានពង្រីកចូលទៅក្នុងតំបន់ព្រៃការពារធម្មជាតិមណ្ឌលគិរី គម្រោងនេះនឹងបង្កើតកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយគម្រោងសហគមន៍ការពារសត្វព្រៃ (CWRP) ដែលធ្លាប់ធ្វើការយូរជាងគេលើការកត់ត្រាដានជើងសត្វសម្រាប់សកម្មភាពអភិរក្សនៅក្នុងតំបន់ព្រៃការពារមណ្ឌលគិរី ។ សកម្មភាពទាំងឡាយស្ថិតនៅក្រោមគម្រោង MOSAIC គាំទ្របន្ថែមដល់សកម្មភាពបង្កើនការយល់ដឹងរបស់គម្រោងសហគមន៍ការពារសត្វព្រៃ (CWRP) នៅពេលដែលគម្រោងនេះដំណើរការតាមរយៈតំណាងសហគមន៍ដែលមានស្រាប់ ដើម្បីបង្កើនការគ្រប់គ្រងធនធាន និងការគ្រប់គ្រងដីធ្លីដោយមានការចូលរួម ជាអាទិ៍ការផ្សព្វផ្សាយអំពីប្រការសំខាន់នៅក្នុងច្បាប់ពាក់ព័ន្ធនានា ដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ជលផល ។

ដៃគូសំខាន់ៗផ្សេងទៀត ដូចជា ភ្នាក់ងាររដ្ឋាភិបាល (បុគ្គលិកមកពីមន្ទីរបរិស្ថាន កសិកម្ម គ្រប់គ្រងដែនដី អភិវឌ្ឍន៍ជនបទ និងទេសចរណ៍ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល (WCS, SSP, CIDSE, Nomad) ដែលបានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលពីការចូលរួមកសាងផែនការប្រើប្រាស់ដីធ្លី (PLUP) នៅឆ្នាំ២០០២ និងឆ្នាំ២០០៤ នៅក្នុងខេត្តមណ្ឌលគិរី (ដឹកនាំដោយក្រុមគម្រោងMOSAIC ឬអង្គការដែលប្រើប្រាស់វិធីសាស្ត្រ PLUP ដើម្បីគ្រប់គ្រងដីធ្លី ។

ទស្សនៈយូរអង្វែងរបស់គំរោងMOSAIC :

"កិច្ចសហប្រតិបត្តិការរវាងស្ថាប័នអភិរក្ស (ថ្នាក់អន្តរជាតិ ជាតិ និងថ្នាក់ខេត្ត និង សហគមន៍មូលដ្ឋានបានបង្កលក្ខណៈងាយស្រួលធ្វើឱ្យមានកិច្ចសហប្រតិបត្តិការក្នុងការអភិរក្សនៅថ្នាក់ជាតិ-មូលដ្ឋាន និងគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ រួមទាំងជីវៈចម្រុះ ទន្ទឹមនឹងការជួយសម្របសម្រួល និងការតស៊ូមតិពីសំណាក់ស្ថាប័នថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីធានាសិទ្ធិកាន់កាប់ធនធានរបស់សហគមន៍ និងការគ្រប់គ្រងធនធានដោយសហគមន៍ប្រកបដោយនិរន្តរភាព" ។

ទស្សនៈនេះត្រូវបានសរសេរឡើងដើម្បីគាំទ្រដល់បណ្តាគោលបំណងចម្បងៗនៃកម្មវិធី តំបន់អេកូឡូស៊ីព្រៃល្បោះនៃអាងទន្លេមេគង្គក្រោម (Lower Mekong Dry Forest Ecoregion) និងបានផ្តល់ការណែនាំសម្រាប់ការអភិវឌ្ឍគោលបំណងចំពោះមុខ និងរយៈពេលមធ្យម សម្រាប់គម្រោង MOSAIC (សូមអានប្រអប់ទី១) ។

**ប្រអប់ទី១ : គោលដៅ និងគោលបំណងនៃគម្រោង MOSAIC នៅតំបន់ទំនាបភាគខាងកើតប្រទេសកម្ពុជា**

**គោលដៅពីកម្មវិធីតំបន់អេកូឡូស៊ីព្រៃល្បោះ**

៙ ប្រភេទជាអាទិភាពមានវត្តមាននៅក្នុងក្រុមសត្វជាច្រើននៅទូទាំងតំបន់ទេសភាពអេកូឡូស៊ីព្រៃល្បោះនេះ ។

៙ អភិរក្សតំណាង និងប្រភេទជម្រកធម្មជាតិជាច្រើនបែប និងអភិរក្សដំណើរនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងដំណើរការវិវត្តន៍ ដែលជាកត្តាមានឥទ្ធិពលចំពោះសហគមន៍ធម្មជាតិ ។

៙ ធនធានធម្មជាតិគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ហើយការអភិវឌ្ឍដោយសមស្របធានាបាននូវការអភិរក្សជីវៈចម្រុះ។

៙ កិច្ចខំប្រឹងប្រែងដើម្បីការពារ និងអភិរក្សតំបន់ទេសភាពព្រៃល្បោះត្រូវធានានិរន្តភាពទាំងខាងសង្គម ហិរញ្ញវត្ថុ និងនយោបាយ ។

**គោលបំណងចំពោះមុខ (នៅក្នុងកំឡុងពេល ២ឆ្នាំដំបូងនៃដំណើរការគម្រោង MOSAIC**

៙ សេចក្តីប្រកាសការពារសត្វព្រៃ ច្បាប់តំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល ច្បាប់ផ្សេងៗទៀត និង គោលការណ៍នៃការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះប្រកបដោយនិរន្តរភាព។

៙ កសាងសមត្ថភាព និងគាំទ្រសហគមន៍ទាំងឡាយដើម្បីបង្កើនការអភិរក្ស និង ការព្រមព្រៀងគ្រប់គ្រងធនធានរវាងសហគមន៍ និង អាជ្ញាធរពាក់ពន្ធ័ តាមរយៈការចូលរួមធ្វើផែនការសម្រាប់ការពារ អភិរក្ស និង ប្រើប្រាស់ធនធានជីវៈចម្រុះដោយនិរន្តរភាព ក្នុងគោលបំណងដើម្បីបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ ។

**គោលបំណងរយៈពេលមធ្យម (រយៈពេល ២ ទៅ ៥ ឆ្នាំក្រោយ គឺត្រូវ :**

៙ ដឹកនាំការអនុវត្តនូវការវាយតម្លៃអំពីនិរន្តរភាពនៃការអនុវត្តការចិញ្ចឹមជីវិតដោយមានការចូលរួមដែលមានស្រាប់ ។

៙ លើកស្ទួយ និងគាំទ្រសកម្មភាពចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ជាអាទិ៍ ការស្រាវជ្រាវចុះផ្ទាល់មូលដ្ឋានអំពីសកម្មភាពចិញ្ចឹមជីវិតដែលជាជម្រើស ក្នុងករណីដែលការប្រើប្រាស់ធនធានបច្ចុប្បន្នមិនមាននិរន្តរភាព។

គម្រោង MOSAIC ធ្វើការឆ្ពោះទៅរកគោលដៅ និងគោលបំណងទាំងនេះ តាមរយៈដំណើរជាការយុទ្ធសាស្ត្រទាំងបួនជំហាន ដែលត្រូវបានសង្ខេបនៅរូបទី១។




*រូបទី១: ដំណើរការយុទ្ធសាស្ត្រទាំងបួនជំហាន*

## ការកសាងសមត្ថភាព

ជំហានសំខាន់ៗទាំងបួននៅក្នុងយុទ្ធសាស្ត្ររបស់គម្រោង MOSAIC ទាមទារឱ្យមានការកសាងសមត្ថភាព។ ជាដំបូង បុគ្គលិកថ្នាក់ជាតិបានទទួលការបណ្តុះបណ្តាលតាមរយៈការបង្រៀនជាផ្លូវការ ការចងក្រងជាបណ្តាញ និងការរៀនពីការងារគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ការចូលរួមកសាងផែនការប្រើប្រាស់ដីធ្លី និងកម្មវិធីសហគមន៍ព្រៃឈើ ។ ការបណ្តុះបណ្តាលនេះបានរួមបញ្ចូលការបង្កើនការយល់ដឹងដល់បុគ្គលិកអំពីច្បាប់ និងបទប្បញ្ញត្តិដែលមានឥទ្ធិពលដល់ការអភិរក្សធម្មជាតិ និងភាពសមហេតុផលផ្នែកវិទ្យាសាស្ត្រដែលនៅពីក្រោយច្បាប់ និងបទប្បញ្ញត្តិទាំងនោះ ។ វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាពជាបន្តបន្ទាប់ ត្រូវបានធ្វើឡើងនៅថ្នាក់ខេត្ត ដើម្បីកសាងជំនាញឱ្យដល់កម្រិតប្រហាក់ប្រហែលនឹងបុគ្គលិកថ្នាក់ជាតិដែរ ដើម្បីបំប៉នជំនាញសម្របសម្រួលបន្ថែមសម្រាប់ជួយរៀបចំ និងបណ្តុះបណ្តាលដល់តំណាងសហគមន៍អំពីជំហានយុទ្ធសាស្ត្រជាបន្តបន្ទាប់ ។ នៅទូទាំងដំណើរការនេះ ការចងក្រងជាបណ្តាញ និងការសិក្សាស្វែងយល់ គឺជាផ្នែកដ៏សំខាន់នៃគម្រោងនេះ ។

## ការផ្សព្វផ្សាយ និង ការស្រាវជ្រាវបឋម

ដោយប្រើប្រាស់វិធីសាស្ត្រមួយចំនួននៃការវាយតម្លៃជនបទដោយមានការចូលរួម (PRA) ក្រុមគម្រោងបានរៀបចំធ្វើការវាយតម្លៃទីតាំងភូមិសាស្ត្រតាមលក្ខណៈឆាប់រហ័ស (Rapid Geographic Assessment) សម្រាប់សហគមន៍ទាំងឡាយដែល ស្ថិតនៅជិតតំបន់អភិរក្សដែលមានអាទិភាពខ្ពស់។ ការវាយតម្លៃនេះមានរួមបញ្ចូលការផ្សព្វផ្សាយចំពោះសហគមន៍ផ្សេងៗជាច្រើនទៀតនៅតំបន់ដាច់ស្រយាលព្រមទាំងការស្រាវជ្រាវ និងជំហានដំបូងនៃការបង្កើនការយល់ដឹង ដែលត្រូវបានគេចាត់ទុកថា ជាមូលហេតុដែលគម្រោង MOSAIC រៀបចំធ្វើការផ្សព្វផ្សាយ និងស្រាវជ្រាវនេះ និងមានឥទ្ធិពលលើរបៀបប្រើប្រាស់ព័ត៌មាននេះពីសំណាក់គម្រោង MOSAIC និងបណ្តាដៃគូផ្សេងៗទៀត។ សកម្មភាពនេះរួមមានការពង្រាយសមាជិកក្រុម MOSAIC ដោយមានកិច្ចសហការជាមួយបុគ្គលិកតំបន់ការពារធម្មជាតិ ឬ



ស៊ុន ប៊ុរ៉ា / WWF ២០០៤

*ដំរីក្នុងស្រុកត្រូវបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនក្នុងខេត្តមណ្ឌលគិរី*

បុគ្គលិករដ្ឋបាលព្រៃឈើ ដើម្បីធ្វើការស្ទាបស្ទង់សហគមន៍ចំនួន១៥ នៅភាគពាយព្យនៃខេត្តមណ្ឌលគិរី និងសហគមន៍ដ៏ធំមួយ ក្នុងខេត្តក្រចេះភាគខាងកើត ។ ការវាយតម្លៃទាំងនេះបានបញ្ជាក់ពីស្ថានភាពភូមិសាស្ត្រ និងផលប៉ះពាល់នៃការប្រើប្រាស់ធនធាននៅខាងក្រៅតំបន់ភូមិ ។ ព័ត៌មាននេះ រួមជាមួយការបង្ហាញពីឆន្ទៈរបស់សហគមន៍ក្នុងការចំណាយពេលវេលា ដើម្បីបង្កើតផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ត្រូវបានប្រើប្រាស់ដោយអង្គការ WWF និងដៃគូដើម្បីកំណត់តំបន់អាទិភាពសម្រាប់ការធ្វើអន្តរាគមន៍របស់គម្រោង ។

## ការស្រាវជ្រាវ

គម្រោង MOSAIC បានជ្រើសរើសសហគមន៍ក្នុងតំបន់អាទិភាពខ្ពស់បំផុត ដើម្បីធ្វើការវាយតម្លៃជីវៈចម្រុះដោយមានការចូលរួម (PBA) ។ ភូមិចំនួន២ ដែលត្រូវបានជ្រើសរើសជាតំបន់គោលដៅគឺ ភូមិស្រែធំ ក្នុងឃុំ សុខសាន្ត ស្រុកកោះញែក និងភូមិខ្មែង ក្នុងឃុំចុងផ្លាស់ ក្នុងស្រុកកែវសីម៉ា (សូមមើលរូបទី១ ។ យោងតាមដំណាក់កាលស្រាវជ្រាវ ភូមិទាំង២នេះ ស្ថិតនៅក្នុងការយកចិត្តទុកដាក់នៃសមាសភាគផែនការដោយមានការចូលរួមដែលត្រូវបានផ្តួចផ្តើមនៅក្នុងឆ្នាំ២០០៤ ។




*រូបទី១: ឃុំ និង បណ្តាសហគមន៍គោលដៅនៅតំបន់ទំនាបភាគខាងកើត*

ទោះបីនេះជាដំណាក់កាលស្រាវជ្រាវក៏ដោយ ប្រការសំខាន់គឺត្រូវកសាងទំនុកចិត្ត និងការគោរពរវាងសហគមន៍ ក្រុមការងារគម្រោង MOSAIC និងបណ្តាដៃគូទាំងឡាយ ។

ដំណើរការវាយតម្លៃជីវៈចម្រុះដោយមានការចូលរួម (PBA) រួមមានសមាសភាគស្រាវជ្រាវជាច្រើនផ្នែកដូចជា៖

- ការប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណីដោយសហគមន៍មូលដ្ឋាន ដោយសង្កត់ធ្ងន់លើរបាយ និងភាពសំបូរបែបនៃប្រភេទសត្វព្រៃដែលមានលក្ខណៈសំខាន់ជាសកល ការគូសផែនទីកំណត់ព្រំប្រទល់អំពីរបាយ និងភាពសំបូរបែបនៃប្រភេទសត្វសំខាន់ៗដោយផ្អែកតាមការយល់ឃើញរបស់សហគមន៍ ការចងក្រងជាឯកសារអំពីការគម្រាមកំហែងចំពោះជីវៈចម្រុះ និងធនធានសំខាន់ៗ ។
- ការចាត់ថ្នាក់ទីជម្រកតាមទម្លាប់ពីបុរាណ ការធ្វើចំណាត់ថ្នាក់អំពីសារៈសំខាន់នៃទីជម្រកដែលទ្រទ្រង់ប្រភេទសត្វសំខាន់ៗ ធ្វើអត្តសញ្ញាណកម្រិតនៃការគម្រាមកំហែងនៅក្នុងទីជម្រកទាំងនេះ និងការគូសផែនទីកំណត់របាយនៃទីជម្រកសំខាន់ៗ ។

ព័ត៌មានពីការវាយតម្លៃជីវៈចម្រុះដោយមានការចូលរួម (PBA) ត្រូវបានប្រើប្រាស់ដើម្បីកំណត់សកម្មភាពអាទិភាពសម្រាប់ការអភិរក្ស ដោយរួមមានការស្រាវជ្រាវដោយផ្តោតអំពីអេកូឡូស៊ី/ជីវសាស្ត្រ ការស្រាវជ្រាវចុះផ្ទាល់ដើម្បីអភិវឌ្ឍន៍ ឬជម្រុញឱ្យមានជម្រើសផ្សេងក្នុងការចិញ្ចឹមជីវិត ការតស៊ូមតិសម្រាប់ការពារសិទ្ធិគ្រប់គ្រងធនធានសហគមន៍ ការពង្រឹងការអនុវត្តន៍ច្បាប់ និងការកែលំអលើការត្រួតពិនិត្យ និងរបាយការណ៍ ។

## ការគាំទ្រដល់ការរៀបចំសហគមន៍


ស៊ុង ប៉ាក់ / WWF ២០០៤

គម្រោង MOSAIC ផ្តោតការយកចិត្តទុកដាក់ក្នុងការគាំទ្រដល់សហគមន៍មូលដ្ឋានដើម្បីរៀបចំ និងបង្កើតផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។ ចំពោះការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី គម្រោង MOSAIC បានអនុវត្តដំណើរការដែលបានទទួលស្គាល់ជាផ្លូវការនៅថ្នាក់ជាតិ ដោយយកតាមគំរូបរិបទ នៃសហគមន៍ជនជាតិដើមភាគតិចនៅភាគឦសានក្នុងប្រទេសកម្ពុជា ។ ដំណើរការចូលរួមផែនការប្រើប្រាស់ដីធ្លី បានគាំទ្រដំណាក់កាលដំបូងនៃការគ្រប់គ្រងធនធានធម្មជាតិ ផ្អែកលើសហគមន៍ ហើយដំណើរការនេះនឹងមានបកស្រាយលំអិតនៅក្នុងជំពូកទី៩នៃរបាយការណ៍នេះ ។

## ការគាំទ្រចំពោះការលើកស្ទួយជីវភាពរស់នៅ

នៅពេលរចនាសម្ព័ន្ធ និងការកសាងសមត្ថភាព ត្រូវរៀបចំរួចរាល់ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ បន្ទាប់មកគម្រោងនេះគួរកសាងសមត្ថភាពក្នុងចំណោមសហគមន៍មូលដ្ឋានសម្រាប់ការស្រាវជ្រាវ និងការវិភាគអំពីនិរន្តរភាព ដើម្បីធ្វើឱ្យមានការលើកកម្ពស់ជីវភាពដោយនិរន្តរភាពនៅមូលដ្ឋាន ។ ក្នុងគោលបំណងដើម្បីផ្តល់នូវគោលការណ៍ណែនាំបែបនេះ បុគ្គលិកគម្រោង MOSAIC ផ្ទាល់ត្រូវទទួលការបណ្តុះបណ្តាលបន្ថែមអំពីបច្ចេកទេសស៊ីជម្រៅ និងជាក់លាក់ (រួមទាំងអំពីមីក្រូសេដ្ឋកិច្ច កសិកម្ម ការគ្រប់គ្រងជលផល ការគ្រប់គ្រងសត្វព្រៃ ការស្វែងរកទីផ្សារ និងការកែឆ្នៃអនុផលព្រៃឈើ ។ ដំណើរការនេះ ត្រូវចំណាយពេលយូរ ពីព្រោះនិរន្តរភាពត្រូវបានគេយកមកវាយតម្លៃនៅក្នុងបរិបទនៃការផ្លាស់ប្តូរលក្ខខណ្ឌសង្គម និងបរិស្ថាន ។ ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងនេះគឺដើម្បីលើកស្ទួយ និងគាំទ្រដល់ការរីកចម្រើននៃជីវភាពដោយផ្អែកលើការស្រាវជ្រាវ និងការធ្វើសេចក្តីសម្រេចរបស់សហគមន៍ដោយមានការចូលរួម ។ នៅពេលដែលសហគមន៍ទាំងឡាយ មានសមត្ថភាព និងធនធាន គ្រប់គ្រាន់ដើម្បីអនុវត្តផែនការសកម្មភាព និងប្រើប្រាស់លទ្ធផលដើម្បីធ្វើសេចក្តីសម្រេចប្រកបដោយប្រសិទ្ធភាព តួនាទីនៃដៃគូខាងក្រៅដូចជា គម្រោង MOSAIC ឬភ្នាក់ងាររដ្ឋាភិបាលគួរមានត្រឹមផ្តល់យោបល់បច្ចេកទេសម្តងម្កាលតែប៉ុណ្ណោះ ។

## បទពិសោធន៍ពីទីកន្លែងជាក់ស្តែង

ដំណើរការកសាងផែនការដោយមានការចូលរួមគឺប្រព្រឹត្តិទៅដោយសន្សឹមៗ ហើយគម្រោង MOSAIC មានការតាំងចិត្តដើម្បីធានាថា ដំណើរការនេះប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពនៅក្នុងភូមិ-ឃុំគំរូចំនួនពីរមុនពេលគម្រោងត្រូវ បានពង្រីកយ៉ាងទូលំទូលាយនៅទូទាំងតំបន់ទេសភាព ។ ទោះជាយ៉ាងណាក៏ដោយ ការគម្រាមកំហែងចំពោះជីវៈចម្រុះចេះតែកើនឡើង ដូច្នេះ គម្រោង MOSAIC ឆ្លៀតយកឱកាសនេះ នៅពេលដែលគម្រោងបានពង្រីកដំណើរការទៅសហគមន៍ផ្សេងៗទៀតដែលស្ថិតនៅតាមទីតាំងនានាក្នុងតំបន់នោះ ។

ការគម្រាមកំហែងសំខាន់ថ្មីមួយទៀត គឺការកែលំអផ្លូវថ្នល់រវាងទីរួមខេត្តមណ្ឌលគិរី និងស្រុកកោះញែកដែលនាំឱ្យមានកំណើននៃការចាប់ដីថ្មីៗបន្ថែមទៀត និងរានឆ្ការនៅក្នុងបរិវេណឃុំពូជ្រៃ ស្រុកពេជ្រាដា។ ឃុំពូជ្រៃទាំងមូលមានទីតាំងនៅក្នុងព្រៃការពារមណ្ឌលគិរី ។ ការទន្ទ្រានយកដីនេះ បណ្តាលអោយមានបញ្ហាទាក់ទងគ្នាចម្បងៗ យ៉ាងហោចណាស់ចំនួន៣គឺ :

- ការបាត់បង់ជម្រកព្រៃឈើតាមរយៈការរានឆ្ការយកដី ។
- ការបាត់បង់ធនធានសម្រាប់ជនជាតិដើមភាគតិចនៅក្នុងឃុំពូជ្រៃប្រើប្រាស់ជាលក្ខណៈប្រពៃណី ។
- ទំនាស់កើតឡើងរវាងមនុស្ស និងសត្វព្រៃ រួមបញ្ចូលទាំងការប្រមាញ់ខុសច្បាប់ ការដាក់អន្ទាក់ និងទំនាស់រវាង ដំរី និងមនុស្ស ។

តាមទស្សនៈនៃការអភិរក្សធម្មជាតិ តំបន់នេះមានសារៈសំខាន់បំផុត ដែលមាននាទីជាច្រករបៀងសម្រាប់សត្វដីរីផ្លាស់ទីតាមធម្មជាតិរបស់វា រវាងដែនជម្រកសត្វព្រៃភ្នំព្រេច និងតំបន់ទេសភាពស្រែពកនៅក្នុងតំបន់ព្រៃការពារមណ្ឌលគិរី ។ ការតាំងទីជម្រកថ្មីនៅក្នុងតំបន់នេះបង្កើនគ្រោះថ្នាក់ដែលមនុស្សអាចត្រូវសម្លាប់ដោយសារសត្វដីរី នៅតាមផ្លូវដែលពួកវាធ្លាប់តែផ្លាស់ទី ។ តាមសំណើពីអាជ្ញាធរឃុំ គម្រោង MOSAIC បានសម្រេចផ្ដល់ការគាំទ្រដល់ដំណើរការចូលរួមកសាងផែនការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ ទន្ទឹមនឹងការល្បាត និងពង្រឹងការអនុវត្តបទបញ្ញត្តិដោយរដ្ឋបាលព្រៃឈើ ដើម្បីកាត់បន្ថយអត្រានៃការទន្ទ្រានយកដី ។ យុទ្ធសាស្ត្រនេះមានតួនាទីពីរ ដោយជួយរក្សាដំណើរការអេកូឡូស៊ីធម្មជាតិ ទន្ទឹមនឹងនោះរក្សាមូលដ្ឋានធនធានធម្មជាតិនៃសហគមន៍ជនជាតិភាគតិចតាមមូលដ្ឋាន ។

បន្ថែមលើវត្តមាននៃសហគមន៍ដែលមាននៅក្នុងតំបន់ព្រៃការពារខេត្តមណ្ឌលគិរី ការចូលរួមរបស់សហគមន៍ក្នុងកិច្ចអភិរក្ស មានសារៈសំខាន់ណាស់នៅក្នុងតំបន់ពីរនៃដែនជម្រកសត្វព្រៃភ្នំព្រិច ដែលហៅថា តំបន់ស្រែខ្ទង់-អន្ទ្រង និងតំបន់ស្រែជិះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្សព្វផ្សាយ និងការអង្កេតដំបូងនៅក្នុងតំបន់ទាំងនេះបង្ហាញថា សហគមន៍ទាំងនេះមិនបានទទួលយកដំណើរការចូលរួមកសាងផែនការយ៉ាងពេញលេញទេ ។ ដើម្បីកាត់បន្ថយការគម្រាមកំហែងចំពោះជីវៈចម្រុះ នៅក្នុងតំបន់នេះឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្ដល់ការគាំទ្រដល់អាជ្ញាធរការពារធម្មជាតិដើម្បីពង្រឹងការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹងនៅទីនោះ ទន្ទឹមនឹងការស្វែងរកជម្រើសសមស្របថ្មីៗសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត ជំនួសការបរបាញ់ ការនេសាទ និងការធ្វើជំនួញសត្វព្រៃ ល្មើសច្បាប់ដែលបានកើតឡើងនាពេលថ្មីៗនេះ គឺជាជម្រើសសមស្របជាង ។

## មេរៀនទទួលបាន

### មេរៀនជាក់លាក់តាមតំបន់

កិច្ចខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយ និងការស្រាវជ្រាវបឋមរបស់គម្រោង MOSAIC-EP នាំមកនូវលទ្ធផលដ៏មានសារៈសំខាន់ មួយចំនួនទាក់ទងនឹងស្ថានភាពសហគមន៍មូលដ្ឋាននៅក្នុងតំបន់ខ្ពង់រាបភាគខាងកើត ។

- សហគមន៍ទាំងនេះ មានទីតាំងស្ថិតនៅក្នុងតំបន់ដែលដង់ស៊ីតេប្រជាពលរដ្ឋមានកម្រិតទាប គំរបព្រៃបើកចំហ និងដីរាបស្មើដូច្នេះ សហគមន៍ទាំងនេះមានលទ្ធភាពងាយស្រួលក្នុងការចេញចូលទៅតំបន់ដ៏ធំល្វឹងល្វើយនេះ ។ ប៉ុន្តែដីដែលសមស្របសម្រាប់កសិកម្មពុំសូវសម្បូរឡើយ ថែមទាំងខ្សត់ទឹកទៀតផង ហើយដីច្រើនតែមានគុណភាពទាប ជាពិសេសក្នុងអំឡុងពេលរដូវប្រាំង ។ តំបន់ព្រៃស្រោងដែលអាចរក្សាទុកនូវអនុផលដ៏មានតម្លៃ រួមមានជ័រទឹកក៏ខ្សត់ណាស់ដែរ ។
- ទោះបីជាស្ថានភាពភូមិនៅដាច់ស្រយាលក៏ដោយ ភូមិភាគច្រើនត្រូវបានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីភាពចលាចល ផ្នែកនយោបាយអស់រយៈពេលជាង៣០ឆ្នាំ កន្លងមក ។ ភាគច្រើននៃភូមិទាំងអស់នេះតាំងទីលំនៅជាថ្មីនៅកណ្ដាលស្រុកកោះញែកចន្លោះពីឆ្នាំ ១៩៧០-១៩៧៩ ហើយភូមិជាច្រើនទៀតទើបបានវិលត្រលប់ទៅកាន់ដីដែលបន្សល់ពីដូចតារបស់ពួកគេវិញកាលពី ៥ឆ្នាំមុននេះ នៅពេលដែលរបបខ្មែរក្រហមបញ្ឈប់សកម្មភាពបះបោរប្រឆាំង ។

☜ តំបន់ទេសភាពទាំងមូល សម្បូណ៌ទៅដោយធនធានធម្មជាតិ ប៉ុន្តែរយៈពេល២០ឆ្នាំ (១៩៧០-១៩៩៩) នៃការបរបាញ់សត្វព្រៃដែលមិនអាចគ្រប់គ្រងបាន រួមទាំងការកើនឡើងនាពេលថ្មីៗនៃការនេសាទល្មើសច្បាប់ និងការជីករករ៉ែមាស បានបំផ្លាញមូលដ្ឋានធនធានធម្មជាតិ និងរំខានដល់ជីវភាពរស់នៅជាលក្ខណៈប្រពៃណី ។ ឧទាហរណ៍ វប្បធម៌ផ្អែកលើសត្វដ៏វិមានសភាពទន់ខ្សោយជាងសម័យមុនសង្គ្រាម ការប្រើប្រាស់ថ្នាំពុល និងការប្រើប្រាស់គ្រឿងអគ្គិសនី ក្នុងការនេសាទត្រីកំពុងបំផ្លាញធនធានជលផល ហើយការរុករករ៉ែបាននាំឱ្យមានការបំពុលទឹក និងការផ្លាស់ប្តូរយ៉ាងខ្លាំងខាងវប្បធម៌ និងសេដ្ឋកិច្ចមូលដ្ឋាន ។ ជាសំខាន់ ការផ្លាស់ប្តូរទាំងនេះមិនអាចរកឃើញក្នុងវិធីសាស្ត្រវិភាគអំពីជម្រកតាមបែបបច្ចេកទេស ដូចជាឧបករណ៍ថតពីលើអាកាស (Remote Sensing) បានឡើយ ។

☜ ទោះបីជាទូទៅ សហគមន៍ទាំងឡាយរស់ក្នុងភាពក្រីក្រ និងឱ្យតម្លៃលើការកែលំអ សុវត្ថិភាពទឹក សុខភាព និងការអប់រំក្តីអ្នកភូមិជាច្រើនបានទទួលស្គាល់តម្រូវការជាបន្ទាន់បំផុតក្នុងការត្រួតត្រាសកម្មភាពជកហូតធនធានដែលគ្មាននិរន្តរភាពពីសំណាក់អ្នកមកពីក្រៅ ។ លើសពីនេះ ពួកគាត់ពុំបានកំណត់ជាអាទិភាពឡើយនូវជម្រើសផ្សេងសម្រាប់ការចិញ្ចឹមជីវិត បើប្រៀបធៀបនឹងតម្រូវការឱ្យមានការកសាងផែនការ និងការគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋានដោយមានការដាក់កម្ហិតរួមទាំងការត្រួតពិនិត្យការប្រើប្រាស់ដីព្រៃ និងធនធានជលផលក្នុងមូលដ្ឋាន ។

## មេរៀនពីកម្មវិធី

⊙ **សហប្រតិបត្តិការ** ៖ ដោយសារតំបន់នេះមានវិសាលភាពធំទូលាយ និងស្ថិតនៅដាច់ស្រយាល ប្រការសំខាន់បំផុតគឺត្រូវរៀនសូត្រពីការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី សហគមន៍ព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីសហគមន៍ នៅក្នុងតំបន់ផ្សេងទៀត និងការប្រើប្រាស់វិធីសាស្ត្រដែលបានសាកល្បងរួចមកហើយនៅក្នុងតំបន់ភាគខាងកើត ។ គំរូនៃការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម និងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ដែលបានអភិវឌ្ឍនៅក្នុងខេត្តរតនគិរី និងនៅថ្នាក់ជាតិ បានផ្តល់គោលការណែនាំដ៏មានសារៈសំខាន់សម្រាប់បង្កើនការចូលរួមក្នុងចំណោមសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងតំបន់អភិរក្សអាទិភាពក្នុងខេត្តមណ្ឌលគិរី ។

⊙ **ការរីកចម្រើន** ៖ គម្រោង MOSAIC ដៃគូ និងម្ចាស់ជំនួយបានយល់ និងទទួលយកគោលបំណង និងភាពសមហេតុផលនៃការគ្រប់គ្រង និងការចូលរួមកសាងផែនការ ប៉ុន្តែការកសាងសមត្ថភាពនៅក្នុងសហគមន៍ដើម្បីបង្កើនការធ្វើសេចក្តីសម្រេចនៅតែស្ថិតក្នុងដំណើរការយឺតយ៉ាវនៅឡើយ និងប្រឈមគ្រោះថ្នាក់ច្រើនទាក់ទងនឹងការជម្រុញឱ្យមានការអនុវត្តឆាប់រហ័សពេក ។ សហគមន៍មិនគួរពឹងផ្អែកខ្លាំងពេកទៅលើគោលការណ៍ណែនាំពីខាងក្រៅ ។ គម្រោង MOSAIC ត្រូវធានាថាបណ្តាជំហានជាមូលដ្ឋាននៃការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពសហគមន៍ មិនត្រូវទទួលបង់ខាត ដោយសារតែការបង្ខំឱ្យមានរបាយការណ៍បន្ទាន់ស្តីពីសមិទ្ធិផលជាក់លាក់នោះឡើយ ។

⊙ **ការចូលរួម** : ទោះបីជាដំណើរការកសាងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ការគ្រប់គ្រងធនធានធម្មជាតិ ដោយសហគមន៍ មានការពឹងផ្អែកលើទស្សនទានរលូនក្តី សហគមន៍មួយចំនួនអាចមានហេតុផលត្រឹមត្រូវ ក្នុងការសម្រេចថាមិនចំណាយពេលរបស់ពួកគេដើម្បីចូលរួមក្នុងការគ្រប់គ្រងដោយមានការចូលរួមនេះទេ ។ នៅក្នុងករណីនេះ គម្រោង MOSAIC អាចជូនដំណឹងដល់សហគមន៍ទាំងនេះអំពីជម្រើសរបស់ពួកគេ ហើយអាចចង្អុលបង្ហាញពីឆន្ទៈ ដើម្បីគាំទ្រដល់ដំណើរការ ដែលមានការចូលរួមបែបនេះនៅពេលអនាគត ប្រសិនបើអាកប្បកិរិយារបស់សហគមន៍នេះផ្លាស់ប្តូរ ។

## ជំហានបន្ទាប់

ក្រុម MOSAIC-EP បានសិក្សាស្វែងយល់ និងអនុម័តដំណើរការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី ដែលនាំឆ្ពោះទៅរកការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។ ប៉ុន្តែការអនុវត្តដំណើរការទាំងនេះទើបតែចាប់ផ្តើមនៅលើទីតាំងភូមិសាស្ត្រនាពេលថ្មីៗនេះតែប៉ុណ្ណោះ ។ ក្រុមនេះត្រូវបន្តបង្កើត និងត្រួតពិនិត្យដំណើរការទាំងឡាយនៅក្នុងសហគមន៍គោលដៅ សម្រាប់ឆ្នាំផ្សេងៗទៀត ឬ២ឆ្នាំបន្តទៀត មុនពេលគម្រោងបន្តទៅដំណាក់កាលបន្ទាប់ នៅក្នុងសហគមន៍ដែលមានស្រាប់ទាំងនោះ ឬក៏ពង្រីកទៅកាន់សហគមន៍ថ្មីៗទៀត ។ មកទល់ចុងឆ្នាំ២០០៤ មានសហគមន៍មួយចំនួនតូចប៉ុណ្ណោះនៅតំបន់ភាគខាងកើតអាចចំណាយពេលវេលារបស់ពួកគេក្នុងការកសាងផែនការប្រកបដោយភាពជឿជាក់ ។

នៅពេលដែលកម្មវិធីរីកដុះដាល និងជាពិសេសនៅពេលដែលការកំណត់តំបន់មូលដ្ឋាន និងការចរចារអំពីបទប្បញ្ញត្តិដំបូងស្តីពីការប្រើប្រាស់ធនធាន ប្រការចាំបាច់គឺត្រូវផ្តល់ការណែនាំបច្ចេកទេសត្រឹមត្រូវដែលនាំឆ្ពោះទៅរកការលើកកំពស់ជីវភាពរស់នៅ ។ បុគ្គលិកថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវកសាងសមត្ថភាពជំនាញរបស់ពួកគេទៅតាមបច្ចេកទេសផ្សេងៗ (ដូចជាការគ្រប់គ្រងជលផល កសិកម្ម ការរកទីផ្សារ និងការកែច្នៃអនុផលព្រៃឈើ សម្រាប់សហគមន៍គោលដៅ និងត្រូវធ្វើការស្រាវជ្រាវវិភាគ ត្រួតពិនិត្យ និងវាយតំលៃអំពីឥទ្ធិពលនៃការបណ្តុះបណ្តាលទាំងនោះ ។ វគ្គបណ្តុះបណ្តាលនេះគួរ ផ្តោតលើការកសាងសមត្ថភាពសម្រាប់ការស្រាវជ្រាវសកម្មភាព ការត្រួតពិនិត្យ និងវាយតម្លៃ និងការកសាងជំនាញសម្រាប់ធ្វើការវិភាគតាមបែបគុណវិស័យ ។

## REFERENCES

Goodman, P.S., Conway, A.J., and Timmins, R.J. 2003. *Selection and planning of an intensively managed wildlife recovery zone in the Dry Forest Ecoregion of north eastern Cambodia.* Report to WWF indochina Programme, Cambodia Office, Phnom Penh.

Maxwell, A. and Pinsonneault, Y. (eds.) 2001. *Proceedings of the Conservation Strategy Workshop: Dry Forest Landscapes of northern and northeastern Cambodia.* WWF indochina Programme, Cambodia Office, Phnom Penh.

*Timmins, R.J. and Ou R. 2001. A field survey to assess the feasibility of Tiger conservation in Phnom Penh Wildlife Sancturary and other areas of western and northern Mondulkiri, Cambodia.* WWF Indochina Programme, Cambodia Office, Phnom Penh.

Tordoff, A.W., Timmins, R.J., Maxwell, A, Huy K., Lic V., and Khou E.H. (Eds.). 2004. *Biological Assessment of the Lower Mekong Dry Forest Ecoregion,* Final Report. WWF Indochina Programme, Cambodia Office, Phnom Penh.

# ជំពូក ១៤ ផ្សារភ្ជាប់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ទៅនឹងដំណើរការកសាងផែនការនៅមូលដ្ឋាន

រៀបរៀងដោយ : លោក Ashish John[១]

## សេចក្តីផ្តើម

ឯកសារនេះ[២] គឺជាសេចក្តីសង្ខេបពីបទពិសោធន៍ ដែលផ្តោតលើវិធីសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management - CBNRM) និងដំណើរការកសាងផែនការនៅមូលដ្ឋាន (Local Planning Process)[៣] ក្នុងខេត្តរតនគិរី ក្នុងកិច្ចប្រឹងប្រែងធ្វើឱ្យវិធីសាស្ត្រទាំងនេះកាន់តែជាប់ទាក់ទងជាមួយប្រជាពលរដ្ឋ និងសមស្របជាមួយស្ថានភាពរបស់ប្រជាពលរដ្ឋនៅភាគឦសាននៃប្រទេសកម្ពុជា ។ ឯកសារនេះបង្ហាញពីទិដ្ឋភាពរួមនៃLPP ក្នុងកម្មវិធីសិលា[៤] នៅទូទាំងប្រទេស និងLPP នៅខេត្តរតនគិរី ។

ខេត្តរតនគិរី មានទីតាំងស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ជាប់ជាមួយព្រំប្រទល់ប្រទេសវៀតណាម និងប្រទេសឡាវ (រូបទី១ ។ សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុងខេត្តរតនគិរីមានប្រព័ន្ធជីវភាពរស់នៅពឹងផ្អែកលើធនធានធម្មជាតិ ។ ធនធានធម្មជាតិដែលទ្រទ្រង់តម្រូវការរបស់ពួកគាត់មានដូចជា ស្បៀងអាហារ សម្ភារៈសំណង់ និងប្រាក់ចំណូលសម្រាប់គ្រាខ្វះខាត ។ វប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចក៏មានចំណងទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយធនធានធម្មជាតិផងដែរដោយពួកគាត់ ជឿថាមានព្រលឹងស្ថិតនៅក្នុងតំបន់ព្រៃអារក្សរបស់ពួកគាត់ ។




*រូបទី១ : ផែនទីខេត្តរតនគិរី*

## គម្រោង[៥] CARERE

នៅឆ្នាំ១៩៩៦ គម្រោងCARERE បានដាក់ឱ្យអនុវត្តគម្រោងស្តីពីអភិបាលកិច្ច ការកសាងផែនការ និងហិរញ្ញកិច្ចតាមបែបវិមជ្ឈការក្រោមកម្មវិធីសិលាក្នុងខេត្តរតនគិរី ។ គម្រោងទាំងនេះបានដាក់ឱ្យអនុវត្តដំណើរការអភិវឌ្ឍ "ពីក្រោមទៅលើ" ដែលតម្រូវឱ្យសហគមន៍ចូលរួមក្នុងការ

---

[១] Ashish John គឺជាអ្នកសម្របសម្រួលការស្រាវជ្រាវអន្តរជាតិសម្រាប់គម្រោង NRM ក្នុងខេត្តរតនគិរី ។

[២] ជាដំបូងឯកសារនេះត្រូវបានរៀបរៀងឡើងសម្រាប់ការពិភាក្សាជាមួយក្រុមប្រឹក្សាគ្រប់គ្រងរបស់ CARERE ស្តីពីដំណើរការកសាងផែនការដែលកំពុងអនុវត្តនៅខេត្តរតនគិរី ។ ក្រោយពី ការពិភាក្សានេះ អត្ថបទនេះត្រូវបានកែសម្រួលសម្រាប់អ្នកអានភាគច្រើន ។

[៣] ដំណើរការកសាងផែនការនៅមូលដ្ឋាន គឺជាដំណើរការកសាងផែនការដែលមានប្រើប្រាស់នៅក្នុងកម្មវិធីសិលារបស់រដ្ឋាភិបាលកម្ពុជា ។

[៤] កម្មវិធីសិលារបស់រដ្ឋាភិបាលកម្ពុជាជម្រុញឱ្យមានការកសាងផែនការ ការអនុវត្ត និងការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍបែបវិមជ្ឈការ ។

[៥] CARERE -គម្រោងបង្កើតឡើងវិញ និងស្តារវិស័យនានាក្នុងប្រទេសកម្ពុជា ។ នេះជាគម្រោងដែលទទួលមូលនិធិពី UNDP និងអនុវត្តដោយ UNOPS ។ នៅខែកក្កដា ឆ្នាំ២០០១ គម្រោងនេះត្រូវបានប្តូរឈ្មោះជា "ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន"(PLG) ។

រៀបចំផែនការសម្រាប់ខេត្ត ។ សហគមន៍បានរៀបចំផែនការអភិវឌ្ឍរបស់ខ្លួនផ្អែកលើចក្ខុវិស័យដែលអ្នកភូមិចង់បានទៅអនាគត ។ គណៈកម្មការអភិវឌ្ឍន៍ភូមិ-ឃុំ (VDC, CDC[៦]) រួមជាមួយអ្នកភូមិបានកសាងផែនការទាំងនោះ ។ ក្រុមសម្របសម្រួលថ្នាក់ខេត្ត និងថ្នាក់ស្រុក (PFT, DFT) ដែលជាបុគ្គលិកកម្មវិធីសិលា បានសម្របសម្រួលដំណើរការ ។ ផ្អែកលើផែនការទាំងនេះ មន្ទីរជាច្រើន និងអង្គការមិនមែនរដ្ឋាភិបាល បានគាំទ្រសកម្មភាពនានានៅក្នុងឃុំ ។ គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត (PRDC) គឺជាអ្នកគ្រប់គ្រង និងប្រតិបត្តិដំណើរការអភិវឌ្ឍ ។ សេចក្តីសង្ខេបពីទិដ្ឋភាពរួមនៃជំហានចម្បង៧ ក្នុងដំណើរកសាងផែនការក្នុងមូលដ្ឋាន (LPP) មានបង្ហាញជូនក្នុងតារាងទី ១ ។

| | |
|---|---|
| **ជំហានទី ១ :**<br>ការណែនាំពី LPP | អ្នកសម្របសម្រួលនៅថ្នាក់ឃុំបានបង្ហាញជូនពីរចនាសម្ព័ន្ធកម្មវិធីសិលាដល់ CDC និងអ្នកតំណាងប្រចាំភូមិ ។ ពួកគេធ្វើការផ្ទៀងផ្ទាត់ទិន្នន័យនៅក្នុងកំណត់ត្រាទិន្នន័យប្រចាំឃុំ (CDB)[៧] ។ បន្ទាប់មក ពួកគេបានរៀបចំសេចក្តីព្រាងគោលដៅរបស់ឃុំ និងគំនូសព្រាងផែនទីឃុំ ។ នៅពេលសេចក្តីព្រាងគោលដៅទាំងអស់បានរៀបចំរួចជាស្រេច ពួកគេចាត់គោលដៅទាំងនោះជាអាទិភាពខុសៗគ្នា ។ បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ការណែនាំ ដើម្បីរៀបចំផែនការសកម្មភាពភូមិសម្រាប់រយៈពេល៣ឆ្នាំ ។ |
| **ជំហានទី ២ :**<br>កំណត់អាទិភាពរបស់ភូមិ | លទ្ធផលពីការប្រជុំនៅថ្នាក់ឃុំ ត្រូវបានបង្ហាញជូន និងផ្ទៀងផ្ទាត់ជាមួយអ្នកភូមិ បន្ទាប់មកមានការចាត់ជាអាទិភាពនូវគោលដៅអភិវឌ្ឍន៍ភូមិសម្រាប់រយៈពេល ៣ឆ្នាំ ។ |
| **ជំហានទី ៣ :**<br>កសាងផែនការអភិវឌ្ឍន៍ឃុំ (CDP) | ផ្អែកលើការពិភាក្សានៅថ្នាក់ភូមិ មានការរៀបចំបង្កើយគំនូសព្រាងផែនទី និងគោលដៅអភិវឌ្ឍន៍ឃុំ ។ បន្ទាប់មកបណ្តាអាទិភាពសម្រាប់រយៈពេល ៣ឆ្នាំ ត្រូវបានចាត់ជាអាទិភាពទៅតាមវិស័យ ។ បន្ទាប់ពីនេះ មានការចាត់ភូមិនានាជាក្រុមទៅតាមកម្រិតនៃភាពក្រីក្រ ។ |
| **ជំហានទី ៤ :**<br>សិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក | នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក មានការបង្ហាញជូនពីផែនការអភិវឌ្ឍន៍ឃុំដល់អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរនានា ។ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរធ្វើការពិចារណា ដើម្បីដាក់បញ្ចូលផែនការទាំងនោះ ទៅក្នុងផែនការរបស់ខ្លួនសម្រាប់គ្រោងធ្វើអន្តរាគមន៍ ។ |
| **ជំហានទី ៥:**<br>កសាងផែនការវិនិយោគឃុំ | ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំរៀបចំផែនការវិនិយោគ ។ ក្រុមប្រឹក្សានេះលៃថវិកាសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងរៀបចំផែនការវិនិយោគឃុំ ។ |

*តារាងទី ១ : ជំហាននានា នៃដំណើរការកសាងផែនការនៅមូលដ្ឋាន ។*
*ប្រភព : កែសម្រួលពីដំណើរការ LPP ក្នុងខេត្តបាត់ដំបង ( ខែកញ្ញា ឆ្នាំ១៩៩៩*

## មូលនិធិអភិវឌ្ឍន៍នៅមូលដ្ឋាន (LDP)

ក្រៅពីការគាំទ្រតាមវិស័យដោយមន្ទីរនានា និងដោយអង្គការមិនមែនរដ្ឋាភិបាល ឃុំនីមួយៗបានទទួលមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន (LDF) ។ រដ្ឋាភិបាលថ្នាក់កណ្តាលជាអ្នកចាត់ចែងមូលនិធិទាំងនេះសម្រាប់គណៈកម្មការខេត្ត និងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តន៍គម្រោងរយៈពេលខ្លី ឬមធ្យមដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP) ។ ទោះបីមូលនិធិទាំងនេះអាចយកមក

[៦] សមាជិកសហគមន៍ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសហគមន៍ដើម្បីធ្វើជាតំណាងសហគមន៍ ។ រដ្ឋាភិបាលជាអ្នកបង្កើត VDC និង CDC ។
[៧] ក្រុមកសាងផែនការថ្នាក់ខេត្តបានប្រមូលទិន្នន័យពីភូមិនានា និងបានកសាងជាមូលដ្ឋានទិន្នន័យ (database) ។

ប្រើប្រាស់សម្រាប់គោលបំណងជាច្រើននៅក្នុងដំណាក់កាលចាប់ផ្តើមនៃគម្រោង (១៩៩៦) មូលនិធិទាំងនេះត្រូវបានផ្តល់សម្រាប់គោលដៅអនុវត្តគម្រោង "ជាប្រយោជន៍សាធារណៈ" ( ពោលគឺគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន សាលារៀន ។ល ។ នៅក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយនេះ ។

ក្នុងខេត្តរតនគីរី ដំណើរការកសាងផែនការនៅមូលដ្ឋាន (LPP) ក្នុងកម្មវិធីសិលាទាំងមូល ពុំបានឆ្លើយតបគ្រប់គ្រាន់តាមលក្ខខណ្ឌជាក់លាក់នៅក្នុងមូលដ្ឋានឡើយ ។ អត្ថបទនេះបង្ហាញជូនពីការវិវឌ្ឍនៃដំណើរការកសាងផែនការ ដែលបានកែសម្រួលនៅមូលដ្ឋាន និងដែលបានអនុវត្តនៅក្នុងខេត្តរតនគីរី ។

## ចំណុចខ្វះចន្លោះនៅក្នុងដំណើរការកសាងផែនការនៅមូលដ្ឋាន (LPP)

សហគមន៍នានាក្នុងខេត្តរតនគីរីកំពុងប្រឈមចំពោះសំពាធពីខាងក្រៅជាច្រើនដែលគម្រាមកំហែងដល់ជីវភាពរស់នៅរបស់ពួកគេ ។ ដីធ្លី និងព្រៃឈើ ដែលពួកគាត់ធ្លាប់បានប្រើប្រាស់តាមប្រពៃណីពីបុរាណត្រូវបានបាត់បង់ ដោយសារការប្រែក្លាយជាដីសម្បទាន ឬ ជាព្រៃសម្បទាន ការទន្ទ្រានចាប់យកដី ការកាប់ឈើល្មើសច្បាប់ និងការលក់ដី ។ តារាងទី២ បង្ហាញពីឧទាហរណ៍ដែលកើតមានជាទូទៅនៅក្នុងឃុំសោមធំ ។

តារាងនេះបង្ហាញថា នៅឆ្នាំ ១៩៩៦-១៩៩៧ និងឆ្នាំ១៩៩៨ អ្នកភូមិបានធ្វើការជជែកជាមួយក្រុមហ៊ុនដំណាំដូងប្រេង និងអាជ្ញាធរ អំពីការបាត់បង់ចំណែកដីជាច្រើនដែលសហគមន៍ត្រូវការជាចាំបាច់ដែលក្លាយជាចំណែកដីរបស់ក្រុមហ៊ុនដោយមានការសរសេរញត្តិប្តឹងទៅមន្ទីរបរិស្ថាន (ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៧) ដើម្បីការពារព្រៃរបស់ពួកគេ ។ ប៉ុន្តែនៅក្នុងការវិភាគស្ថានភាពដែលជាផ្នែកមួយការកសាងផែនការនៅមូលដ្ឋានក្នុងឃុំនោះ ពុំបានកត់សម្គាល់ពីបញ្ហានោះឡើយ ហើយក៏មិនបានកត់ត្រាជាអាទិភាពនៅក្នុងដំណើរការរៀបចំផែនការនៅក្នុងមូលដ្ឋានដែរ ។ ផ្ទុយទៅវិញ ឃុំបានចាត់ទុកបញ្ហាផ្សេងៗ ដូចជាសាលារៀន និងមណ្ឌលសុខភាពភូមិថាជាបញ្ហាអាទិភាពទៅវិញ ។

| ឆ្នាំ | ស្ថានភាពនៅឃុំសោមធំ | បញ្ហាដែលបានកំណត់ | | អាទិភាពដែលបានកំណត់ | |
|---|---|---|---|---|---|
| | | LPP | ផ្សេងៗ | LPP | ផ្សេងៗ |
| ១៩៩៥ | គណៈរដ្ឋមន្ត្រីបានផ្តល់ដីសម្បទានទំហំ ២០ ០០០ ហិកតា សម្រាប់ដំណាំដូងប្រេង ដែលលាតសន្ធឹងលើឃុំមួយចំនួន ។ ក្រុមហ៊ុនបានកាប់រានព្រៃ ៣០០ម នៅសងខាងផ្លូវលេខ១៩ ក្នុងឃុំសោមធំ ព្រមទាំងដាំដូងប្រេងលើផ្ទៃដី២៣ ហិកតា និងកាហ្វេ ១០០-២០០ហិកតា ទៀតផង ។ | | សន្តិសុខដីធ្លី [១] ការកាប់ឈើខ្លាំងក្លា [៤] | សហគមន៍ព្រៃឈើ | |
| ១៩៩៦ | បុគ្គលិកក្រុមហ៊ុនបានបំភិតបំភ័យអ្នកភូមិ ។ បុគ្គលិកខ្លះរបស់ក្រុមហ៊ុនបានសំពៀងអាវុធ និងបាញ់សត្វមួយចំនួនរបស់អ្នកភូមិ ។ អ្នកភូមិសំដែងការព្រួយបារម្ភពីការកាន់កាប់ដីដោយក្រុមហ៊ុន និងបានបង្ហាញការព្រួយបារម្ភរបស់ខ្លួននៅសិក្ខាសាលាអន្តរជាតិមួយ ។ អ្នកភូមិឱ្យដឹងថាពួកគាត់បានធ្វើការប្រឆាំងតវ៉ានៅសាលាស្រុក (រវាងឆ្នាំ ១៩៩៥-១៩៩៧) ។ | អត្រាសត្វស្លាប់មានកម្រិតខ្ពស់ ខ្វះស្បៀងអាហារ សត្វល្អិតបំផ្លាញស្រូវ អ្នកភូមិកើតជំងឺ ទិន្នផលស្រូវទាប | ក្រុមហ៊ុនរានឆ្ការដីរបស់ភូមិ[1&4] | សាលារៀនមណ្ឌលសុខភាព ភូមិ អណ្តូងទឹកធនាគារស្រូវ ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម | សន្តិសុខដីធ្លី [1&4] |
| ១៩៩៧ | ការកាប់ឈើបានកើនឡើងនៅអូរយាដាវក្នុងឃុំសោមធំ ។ អ្នកភូមិសោមធំជួបជាមួយមន្ត្រីស្រុក និងសុំឱ្យមានការជួបប្រជុំជាមួយអភិបាលស្រុក ។ អ្នកភូមិក៏បានជួបជាមួយក្រុមហ៊ុនផងដែរដើម្បីជជែកអំពីបញ្ហានេះផងដែរ ។ អភិបាលខេត្តជួបជាមួយអ្នកភូមិនៅខែកុម្ភៈ ឆ្នាំ១៩៩៧ ដើម្បីពិភាក្សាអំពីដីធ្លី ។ អ្នកភូមិសម្តែងការព្រួយបារម្ភអំពីការកាប់ឈើដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងឃុំរបស់ខ្លួន ។ អ្នកភូមិព្រួយបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពនេះ និងបានបញ្ជូនញត្តិប្តឹងទៅមន្ទីរបរិស្ថានខេត្ត នៅខែវិច្ឆិកា ឆ្នាំ១៩៩៧ ។ | ប្រជាពលរដ្ឋមានជំងឺ ពុំមានមណ្ឌលសុខភាពនៅជិត ប្រជាពលរដ្ឋប្រើទឹកមិនស្អាត ។ ទឹកស្ថិតនៅឆ្ងាយពីភូមិ ខ្វះកម្លាំងអូសទាញ ។ | ក្រុមហ៊ុនកាន់កាប់ដី[1] ការកាប់ឈើមានកម្រិតខ្លាំងក្លា[3] | (ខែវិច្ឆិកា ឆ្នាំ ១៩៩៧) ធនាគារស្រូវ សុខភាពសត្វ ភូមិ អណ្តូងទឹក ធនាគារក្របី ការបង្កើនទិន្នផល | សន្តិសុខដីធ្លី [1] ការបាត់បង់ព្រៃឈើ[3] |
| ១៩៩៨ | ការកាប់ឈើខ្លាំងក្លានៅតែបន្តក្នុងឃុំសោមធំ ។ អាជ្ញាធរស្រុក និងក្រុមហ៊ុនអនុញ្ញាតឱ្យអ្នកភូមិ មានចំណែកដីក្នុងភូមិ ៥០-១០០ ម នៅតាមសងខាងផ្លូវធំ ។ អ្នកភូមិដាំដើមឈើក្នុងចំណែកដីនោះតាមសងខាងផ្លូវដើម្បីធ្វើជាកម្មសិទ្ធិ ។ សកម្មភាពគ្រប់គ្រងធនធានធម្មជាតិ ដោយសហគមន៍ចាប់ផ្តើមនៅក្នុងឃុំ ។ មានការកំណត់ថា សន្តិសុខដីធ្លី និងការបាត់ធនធានធម្មជាតិ គឺជាកង្វល់ចម្បងរបស់អ្នកភូមិ ។ អ្នកភូមិ និងក្រុមការងារគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ បានចាប់ផ្តើមរៀបចំផែនទីតំបន់នោះ និងរៀបចំចងក្រងជាវិន័យ ព្រមទាំងបទបញ្ញានានា ។ | ប្រជាពលរដ្ឋមានជំងឺ ពុំមានមណ្ឌលសុខភាពប្រជាជនប្រើទឹកមិនស្អាត ។ ទឹកស្ថិតនៅឆ្ងាយពីភូមិខ្វះកម្លាំងអូសទាញ ។ | ក្រុមហ៊ុនកាន់កាប់ដី[5] ការកាប់ឈើមានកម្រិតខ្លាំងក្លា[5] | | សន្តិសុខដីធ្លី [5] ការបាត់បង់ព្រៃឈើ[5] |
| ១៩៩៩ | អ្នកភូមិ និងមន្ទីរបរិស្ថានធ្វើផែនទីឃុំសោមធំ និងចាប់ផ្តើមបង្ហាញសេចក្តីព្រាង វិន័យ និងបទបញ្ញានានា ទៅអាជ្ញាធរស្រុក និងខេត្ត ។ | ដំណើរ IPP បានសាកល្បងនៅក្នុងឃុំសោមធំ ។ លើកនេះអ្នកភូមិដាក់បញ្ចូល បញ្ហាសហគមព្រៃឈើទៅក្នុងផែនការរយៈពេលវែងរបស់ខ្លួន | | | |

*តារាងទី២ : បញ្ហានិងអាទិភាព ព្រមទាំងស្ថានភាពក្នុងឃុំ សោមធំ នៅខេត្តរតនគិរី*

*ប្រភព : ១. Colm, 1997. ២. CDP សំរាប់ឃុំសោមធំ ៣. Global Witness. ៤. ក្រុមវិភាគ និងកសាងផែនការ. ៥. វិន័យ និងបទបញ្ញាសហគមន៍ព្រៃឈើនៅឃុំសោមធំ ។*

[៨] ការមើលរំលងបែបនេះគួរឱ្យភ្ញាក់ផ្អើលខ្លាំងណាស់ ព្រោះថានៅឆ្នាំ១៩៩៥ ក្រុមវិភាគ និងកសាងផែនការ (AP Team) ដែលជាផ្នែកមួយនៃដំណើរការសាកល្បងបានប្រើប្រាស់ដំណើរការនេះនៅមុន LPP និងពិតជាបានកត់ត្រាកង្វល់របស់ឃុំអំពីប្រការដែលក្រុមហ៊ុនបានយកដីរបស់ពួកគាត់ និងអំពីការដែលពួកគាត់បានស្នើសុំឱ្យបង្កើតជាសហគមន៍ព្រៃឈើ ។ វិធានវិភាគបញ្ហាដែលប្រើប្រាស់ដោយAP Team មិនត្រូវបានប្រើប្រាស់នៅក្នុងដំណើរការ LPP នៅពេលក្រោយមកទេ ។

មានឧទាហរណ៍ជាច្រើនអំពីស្ថានភាពដូចគ្នានេះ ដែលក្នុងនោះដំណើរការកសាងផែនការក្នុងមូលដ្ឋានបានបង្ហាញអំពីចំណុចខ្វះចន្លោះនៃបញ្ហាចម្បង និងកង្វល់ជាច្រើនដែលសហគមន៍បានប្រឈម ។ ឧទាហរណ៍ផ្សេងទៀត គឺនៅឃុំយក្សឡោម ដែលការ រាលដាលនៃទីប្រជុំជននេះ បានរុញច្រានអ្នកស្រុកតំបន់ភ្នំចេញពីដីរបស់ពួកគាត់ ។ នៅអូរជុំ ក្រុមហ៊ុនព្រៃសម្បទានមួយបានចាប់ផ្តើមកាប់ឈើក្នុងព្រៃអារក្សរបស់អ្នកស្រុកតំបន់ភ្នំ និងការជីកយកត្បូងដែលកំពុងគំរាមកំហែងការរស់នៅអ្នកស្រុកតំបន់ភ្នំនៅកាឡែង ។

## បញ្ហាស្នូល

របាយការណ៍នានាស្តីពីសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី គូសបញ្ជាក់ពីសារៈសំខាន់នៃធនធានធម្មជាតិ សម្រាប់សហគមន៍ទាំងនេះ ។ សហគមន៍ ខ្លួនឯងបានដឹងពីប្រការនេះ និងសំដែងការចាប់អារម្មណ៍យ៉ាងសកម្មពីតម្រូវការឱ្យមានកិច្ចការពារធនធានធម្មជាតិរបស់ពួកគេ ព្រមទាំងលើកឡើងពីកង្វល់របស់ខ្លួននៅក្នុងសិក្ខាសាលា និងកិច្ចពិភាក្សានានាស្តីពីធនធានធម្មជាតិ ។ អ្នកតំណាងជនជាតិដើមភាគតិចបានជួបជាមួយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីសម្តែងកង្វល់របស់ខ្លួនអំពីការបាត់បង់ធនធានធម្មជាតិក្នុងខេត្តរតនគិរី ។

ភ្នាក់ងារអភិវឌ្ឍន៍នៅក្នុងខេត្តរតនគិរី បានបន្តប្រឈមនឹងបញ្ហាទាំងនេះ និងពុំអាចព្រងើយកន្តើយបានឡើយ ។

ការធ្វើអាជីវកម្មធនធានធម្មជាតិ ដោយគ្មានការទប់ស្កាត់នៅក្នុងខេត្តរតនគិរី និងភាពងាយរងគ្រោះនៃសហគមន៍ជនជាតិដើមភាគតិចមិនអាចមើលរំលង និងមិនអាចមិនរាប់បញ្ចូលក្នុងកម្មវិធី CARERE/SEILA LPP បានឡើយ ។ ចំពោះក្រុមការងារកសាងផែនការនៅមូលដ្ឋានក្នុងខេត្តរតនគិរី និងក្រុមដទៃទៀត ដែលធ្វើការលើផ្នែកអភិវឌ្ឍន៍ដោយចីរភាពក្នុងតំបន់នេះគ្មានជម្រើសផ្សេងក្រៅពីនៅបន្តយកចិត្តទុកដាក់ចំពោះបញ្ហាទាំងនេះឡើយ ។

## ដំណើរការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM)

ទន្ទឹមនឹងពេលដែល CAREREចាប់ផ្តើមដំណើរការកសាងផែនការនៅមូលដ្ឋាន អង្គការ IDRC[៩] ក៏បានចាប់ផ្តើមអនុវត្តគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM) ក្នុងខេត្តរតនគិរីដែរ ។ វិធីសាស្ត្រ CBNRM ពិនិត្យមើលបញ្ហា និងរឿងរ៉ាវនានាផ្អែកលើទស្សនទាននៃធនធានធម្មជាតិ និងកសាងយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាធនធានដោយឆ្លុះបញ្ចាំងនៅក្នុងផែនការរយៈពេលវែង[១០] ។ វិធីនេះក៏សង្កត់ធ្ងន់ផងដែរលើការគ្រប់គ្រងធនធានធម្មជាតិ (NRM) ដោយមានការចូលរួមពីលើសហគមន៍ ។ នៅឆ្នាំ ១៩៩៧ អង្គការ IDRC និង CARERE ត្រូវបានរួមបញ្ចូលគ្នានៅក្នុងខេត្តរតនគិរី ។ ការធ្វើបែបនេះបានផ្តល់ឱ្យកម្មវិធីរបស់ CARERE នូវកាលានុវត្តន៍ភាពដើម្បីសាកល្បងវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ ដំណើរការគ្រប់គ្រងធនធានធម្មជាតិ[១១] ផ្អែកលើសហគមន៍ក៏បាននាំគំនិតស្តីពីអ្នកសម្រប-សម្រួលឃុំដែលទទួលខុសត្រូវជួយក្នុងការសម្របសម្រួលសហគមន៍ដើម្បីរៀបចំផែនទី ផែនការ វិន័យ និងបទបញ្ជារបស់ខ្លួន ព្រម-

[៩] IDRC- មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា ។

[១០] ផែនការរយៈពេលខ្លី គឺសកម្មភាពដើម្បីឆ្លើយតបដោយផ្ទាល់ចំពោះតម្រូវការជាបន្ទាន់ ។ ផែនការរយៈពេលវែងគឺ សកម្មភាពដើម្បីឆ្លើយតបជាយុទ្ធសាស្ត្រចំពោះហេតុផលជាឫសគល់ដែលជាប្រភពដើមនៃតម្រូវការ/បញ្ហារបស់អ្នកភូមិ (Srey, 1999:5) ។

[១១] សមាជិកសហគមន៍ដែលបានទទួលការជ្រើសតាំងដោយសហគមន៍សម្រាប់ធ្វើការសម្របសម្រួលការគ្រប់គ្រងធនធានធម្មជាតិ ។

ទាំងសម្រាប់បំពេញចន្លោះខ្វះខាត ខាងផ្នែកភាសា និងវប្បធម៌រវាងអ្នក សម្របសម្រួលថ្នាក់ ខេត្ត និងស្រុក ជាមួយសហគមន៍មូលដ្ឋាន ។

វិធាន CBNRM បានសាកល្បងជាលើកដំបូងក្នុងឃុំចំនួន៣ គឺអូរជុំ យក្សឡោម និងសោមធំ ។ ប្រព័ន្ធគ្រប់គ្រងដីធ្លីតាមប្រពៃណីត្រូវបានយកមកប្រើប្រាស់ដើម្បីកសាងផែនទីប្រើប្រាស់ដីធ្លី វិន័យ និងបទបញ្ជានានា ។ ការឆ្លើយតបជាវិជ្ជមានដែលបានទទួលពីដំណើរការបែបនេះនៅក្នុងឃុំទាំងនោះ និងនៅថ្នាក់ខេត្ត បានធ្វើឱ្យ CARERE ក្នុងខេត្តរតនគីរីយល់ថា CBNRM មានសារៈសំខាន់ណាស់ សម្រាប់អនុវត្តសកម្មភាពអភិវឌ្ឍន៍នៅក្នុងខេត្តរតនគីរីទៅអនាគត ។ ជំហានសំខាន់ៗនៃដំណើរការនេះមានបង្ហាញជូនក្នុងតារាងទី៣ ។

| ជំហាន | សកម្មភាព |
|---|---|
| **ជំហានទី ១ :** ការធ្វើសេចក្តីណែនាំ | ការបង្ហាញជូនពីគម្រោងដល់អ្នកតំណាងនានាពីស្រុក និងឃុំទាំងឡាយ និងឯកភាពលើការអនុវត្តគម្រោង ។ ការជ្រើសរើសអ្នកតំណាង ឃុំ និងចាត់ចែងការបណ្តុះបណ្តាល ។ |
| **ជំហានទី ២ :** ការបង្ហាញគម្រោងដល់អ្នកភូមិ | ក្រុមស្នូលថ្នាក់ខេត្តជាមួយអ្នកតំណាងឃុំ បានធ្វើទស្សនកិច្ចក្នុងភូមិនានា ដោយបង្ហាញគម្រោងដល់អ្នកភូមិ និងសុំការអនុញ្ញាតដើម្បីអនុវត្តគម្រោងនៅក្នុងឃុំរបស់ពួកគេ ។ បន្ទាប់មកមានការជ្រើសរើស និងបណ្តុះបណ្តាលសមាជិកគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ ។ សមាជិក ៤ ឬ ៥ រូបត្រូវបានជ្រើសរើសពីក្នុងភូមិនីមួយៗ ដោយមានទាំងសមាជិកជាស្ត្រីផង ។ |
| **ជំហានទី ៣ :** ការប្រមូលព័ត៌មាន | ការប្រមូលផ្តុំព័ត៌មានដែលមានស្រាប់អំពីភូមិនីមួយៗ ។ ការប្រើប្រាស់វិធានប្លែកៗ នៃការចូលរួមវាយតម្លៃជនបទ (PRA) ដើម្បីប្រមូលទិន្នន័យបឋម ឧទាហរណ៍: ការគូសផែនទីធនធាន និងសង្គម គំនូសកាត់ទទឹង (tansect walk) ការវិភាគដើមឈើបញ្ហា (problem tree) ការវិភាគ ការចាត់ជាក្រុម កាលវិភាគប្រចាំរដូវ ។ល ។ បន្ទាប់មក ទិន្នន័យដែលប្រមូលបានត្រូវបានយកទៅបង្ហាញដល់អ្នកភូមិ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងបំភ្លឺបន្ថែម ។ ក្រោយពីនោះព័ត៌មានទាំងនោះត្រូវបានវិភាគដោយអ្នកភូមិ ។ |
| **ជំហានទី ៤ :** កសាងផែនការអភិវឌ្ឍន៍ | មានការសិក្សាពីទម្លាប់ប្រើប្រាស់ដីធ្លីតាមបែបបុរាណ បន្ទាប់មកមានការកសាងផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម ។ ការចូលរួមគូសផែនទី សម្រាប់តំបន់នានាដែលបានកំណត់ និងការកសាងផែនការប្រើប្រាស់ដីទូទៅសម្រាប់តំបន់នីមួយៗ ។ បន្ទាប់មកលទ្ធផលទាំងនេះ ត្រូវបានបង្ហាញជូនអ្នកភូមិ និងប្រជាពលរដ្ឋក្នុងភូមិជិតខាង ដើម្បីស្នើសុំការផ្តល់យោបល់ និងធ្វើការកែតម្រូវ ។ |
| **ជំហានទី ៥ :** ៥ក : ផែនការគ្រប់គ្រងលំអិតសំរាប់តំបន់មួយៗ ៥ខ: សហគមន៍ព្រៃឈើ | អ្នកភូមិរៀបចំផែនការគ្រប់គ្រង វិន័យ និងបទបញ្ជាសហគមន៍ព្រៃឈើ ។ អ្នកភូមិរៀបចំវិន័យ និងបទបញ្ជាលំអិតសម្រាប់តំបន់នីមួយៗ ។ |
| ចំពោះព័ត៌មានលំអិតបន្ថែមសូមអានក្នុង Nhem, 1999 | |

*តារាងទី ៣ : ជំហាននានានៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍*

តាមរយៈសកម្មភាព CBNRM ខេត្តនេះបានកាត់បន្ថយផ្ទៃដីសម្បទានទំហំ ២០ ០០០ហិកតា ដែលគ្រោងសម្រាប់ដំណាំដូងប្រេងនៅស្រុកអូរយ៉ាដាវ អោយមកនៅត្រឹម៥០០ហិកតាតែប៉ុណ្ណោះ ។ ខេត្តក៏ទទួលស្គាល់ផងដែរចំពោះផែនទីគ្រប់គ្រងការប្រើប្រាស់ដីសម្រាប់ឃុំសោមធំ និងព្រៃឈើសហគមន៍ទំហំ ៣,៣៣៤ហិកតា ។ ជាលទ្ធផលអ្នកភូមិបានទទួលការអនុញ្ញាតជាផ្លូវការដើម្បីធ្វើការគ្រប់គ្រង ។ បច្ចុប្បន្ន ឃុំនេះមានសិទ្ធិគ្រប់គ្រងដីធ្លី ដែលពួកគេមានប្រពៃណីរស់នៅជាយូរមកហើយ ។

ដំណើរការ CBNRM បានពង្រឹងអំណាចសហគមន៍ក្នុងការពិភាក្សា និងចរចាជាមួយអាជ្ញាធរខេត្ត ពីសិទ្ធិរបស់ពួកគេលើការប្រើប្រាស់ដីធ្លី ដែលពួកគេធ្លាប់មានប្រពៃណីប្រើប្រាស់ជាច្រើនជំនាន់មកហើយ ។ វិធីសាស្ត្រ CBNRM មានលក្ខណៈសមស្របជាពិសេសសម្រាប់អ្នកស្រុកលើ ព្រោះជាវិធីសាស្ត្រដែលផ្ដោតលើធនធានធម្មជាតិ ។ វិធាននេះមានលក្ខណៈដូចគ្នានឹងការយល់ឃើញរបស់អ្នកស្រុកលើ ពីតំបន់ដែលពួកគេរស់នៅ ពោលគឺទំនាក់ទំនងដ៏ស្មុគស្មាញពាក់ព័ន្ធនឹងធនធានធម្មជាតិ ។ ដំណើរការ CBNRM គូសបញ្ជាក់ពីប្រព័ន្ធជាលក្ខណៈប្រពៃណីរបស់អ្នកស្រុកលើក្នុងការគ្រប់គ្រងដី និងព្រៃឈើ ។ ដំណើរការនេះបង្ហាញពីសារៈសំខាន់នៃធនធានធម្មជាតិសម្រាប់ការរស់នៅរបស់អ្នកស្រុកលើ (សូមអានជំពូកទី១៩) និងតម្រូវការឱ្យមានផែនការរយៈពេលវែង ដើម្បីដោះស្រាយបញ្ហាប្រឈមចម្បងរបស់សហគមន៍ ។ ដូច្នេះ ដំណើរការមួយដែលរួមបញ្ចូល LPP ជាមួយវិធីសាស្ត្រ CBNRM សម្រាប់ខេត្តរតនគិរីបានបង្ហាញឱ្យឃើញថាមានលក្ខណៈសមស្របជាងការអនុវត្តតែឯងនូវវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំងពីរនេះ ។

## ដំណើរការកសាងផែនការដែលមានការកែប្រែ

នៅឆ្នាំ ១៩៩៩ ទីប្រឹក្សាមួយរូប ត្រូវបានជួលឱ្យរៀបចំដំណើរការដែលរួមបញ្ចូលវិធីសាស្ត្រ CBNRM ជាមួយដំណើរការ LPP[១២] ។ ការកសាងផែនការកើតចេញពីដំណើរការនេះត្រូវបានឱ្យឈ្មោះថា ដំណើរកសាងផែនការចម្រុះ និងដំណើរការកសាងផែនការផ្អែកលើធនធានធម្មជាតិ (IPP) ។ ដំណើរការថ្មីនេះត្រូវបានដាក់ឱ្យអនុវត្តក្នុងឃុំ ចំនួន៣ គឺ ទិន្ទចក្រ ឡាមិន និងសោមធំ ។ ការប្រើប្រាស់អ្នកសម្រប សម្រួលក្នុងឃុំ ដូចក្នុងករណីនៃវិធីសាស្ត្រ CBNRM ត្រូវបានបន្តអនុវត្តក្រោមឈ្មោះថ្មីមួយហៅថា អ្នកសម្របសម្រួលតំណាងឃុំ (CRF)[១៣] ។

ដំណើរការ IPP ត្រូវបានរៀបចំឡើងតាមរយៈជំហានជាបន្តបន្ទាប់មួយចំនួន ដែលបានកែប្រែឱ្យមានសភាពស្រដៀងគ្នាជាមួយជំហាននានានៃដំណើរការ LPP ។ ដំណើរការកែប្រែនេះត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃគម្រោងទ្រទ្រង់ដោយ SIDA ស្ដីពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (ដែលហៅថា ដំណើរកសាងផែនការចម្រុះ - I/E-LPP ។ ដំណើរការកែប្រែនេះត្រូវបានដាក់ឱ្យអនុវត្តក្នុងឃុំចំនួន២ ក្នុងស្រុកអូរយ៉ាដាវ ។ ដំណើរការនេះមានបង្ហាញជូនក្នុងតារាងទី ៤ ។

---

[១២] Sritatera, S. 1999. *ដំណើរការកសាងផែនការចម្រុះ និងដំណើរការកសាងផែនការផ្អែកលើធនធានធម្មជាតិ* ( IPP): របាយការណ៍ចុងក្រោយ គម្រោង UNDP/OPS CARERE នៅខេត្តរតនគិរី ។

[១៣] អ្នកសម្របសម្រួលតំណាងឃុំ (CRFs) មាននាទីជា PFT/DFT ក្នុងការសម្របសម្រួលឃុំដើម្បីអភិវឌ្ឍន៍ VDPs និង CDPs ។ល។ និងដើម្បីឱ្យមានការធានាថាមានការដាក់បញ្ចូល NRM ទៅក្នុងការកសាងផែនការ ។ អ្នកសម្របសម្រួលម្នាក់ៗត្រូវជ្រើសរើសដោយ CDC ពីក្នុងសហគមន៍ដែលមានរូបគេជាអ្នកសម្របសម្រួល ។

| ជំហាន | សកម្មភាព |
|---|---|
| **ជំហានទី ១ :** ការណែនាំសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ | ប្រធានភូមិ និងប្រធានឃុំ បានអញ្ជើញចូលរួមក្នុងការប្រជុំមួយនៅថ្នាក់ឃុំ ។ អ្នកសម្របសម្រួលបានណែនាំ ពួកគាត់ឱ្យយល់ពីការអភិវឌ្ឍឃុំ កម្មវិធីសិលា ទស្សនទាននៃ CBNRM និងយេនឌ័រ ព្រមទាំងបង្ហាញជូនពីសេចក្តីសង្ខេបនៃដំណើរការ LPP ផងដែរ ។ |
| **ជំហានទី ២:** ការណែនាំសម្រាប់ភូមិ | ដោយមានការជួយសម្របសម្រួលពី PFT, DFT, CF និងCDC ប្រធានភូមិដែលបានទទួលការបណ្តុះបណ្តាល ត្រូវវិលត្រឡប់ទៅភូមិវិញ និងធ្វើការបង្ហាញដល់អ្នកភូមិពីទស្សនវិស័យខាងលើ ។ |
| **ជំហានទី ៣ :** វាយតម្លៃស្ថានភាពភូមិ និងចក្ខុវិស័យសម្រាប់ភូមិ | ការប្រមូល និងវិភាគទិន្នន័យ ការកំណត់ចក្ខុវិស័យសម្រាប់ភូមិ និងលើកសំណើសម្រាប់ភូមិ ។ |
| **ជំហានទី ៤ :** ការរៀបចំ CDP (មាតិកា) | រៀបចំឯកសារពីស្ថានភាពឃុំ ចក្ខុវិស័យសម្រាប់ឃុំ ក្របខ័ណ្ឌគ្រប់គ្រងធនធានធម្មជាតិ និងរៀបចំគម្រោងសម្រាប់ឃុំ ។ |
| **ជំហានទី ៥ :** ផែនការវិនិយោគឃុំ | រៀបចំសរសេរផែនការអភិវឌ្ឍន៍ឃុំ បង្ហាញផែនការនោះជូនទៅមន្ទីរពាក់ព័ន្ធ និងធ្វើការផ្ទៀងផ្ទាត់ដើម្បីឱ្យមានការឯកភាពគ្នា ។ |
| **ជំហានទី ៦ :** កិច្ចប្រជុំនៅថ្នាក់ស្រុក ដើម្បីសម្របសម្រួល និងទទួលយោបល់ | ជួបជាមួយអ្នកតំណាងភូមិ និងធ្វើការកំណត់ជាចុងក្រោយពីបណ្តាភូមិជាគោលដៅ ។ អ្នកភូមិរៀបចំចាត់ចែងដោយខ្លួនឯង ចំណែកមន្ទីរពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិសម្របសម្រួលឱ្យអ្នកភូមិទាំងនោះធ្វើទស្សនកិច្ចនៅក្នុងភូមិពាក់ព័ន្ធ ដើម្បីជៀសវាង"ភាពទន់ខ្សោយនៃការអភិវឌ្ឍ" ។ |
| **ជំហានទី ៧ :** ការបង្កើត VDC/CDC | ប្រសិនបើនៅពុំទាន់បានបង្កើតគណៈកម្មការទាំងនេះនៅឡើយនៅក្នុងជំហានដំបូង ។ |

*តារាងទី ៤: ដំណើរកសាងផែនការចម្រុះនៅមូលដ្ឋាន*
*ប្រភព : កែសម្រួលពីឯកសារគម្រោងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍*

គោលគំនិតនៃការរួមបញ្ចូលNRMទៅក្នុងសិក្ខាសាលាស្តីពី LPP ត្រូវបានបង្ហាញជូននៅក្នុងសិក្ខាសាលាស្តីពី LPP ក្នុងខេត្តបន្ទាយមានជ័យ (ខែកញ្ញា ឆ្នាំ២០០០) ។ សិក្ខាសាលានោះផ្តោតលើការដាក់បញ្ចូល NRM ទៅក្នុងដំណើរការ LPP ។ ប៉ុន្តែមានការកៀបសង្កត់យ៉ាងខ្លាំងឱ្យបន្តប្រើប្រាស់ដំណើរកសាងផែនការឱ្យមានលក្ខណៈឯកភាពគ្នានៅគ្រប់ខេត្ត-ក្រុងទាំងអស់ ។ ប្រការនេះមិនត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារណែនាំស្តីពីដំណើរការ LPP ដែលកំពុងត្រូវបានរៀបចំនៅពេលនោះឡើយ ។ នៅឆ្នាំ ២០០១ ក្រុម LCB ក្នុងខេត្តរតនគិរី បានប្រើប្រាស់ដំណើរការ LPP ដោយឡែកមួយ ដែលបានកើតចេញពីសិក្ខាសាលានៅខេត្តបន្ទាយមានជ័យ ក្នុងខែកញ្ញា ឆ្នាំ២០០០ ប៉ុន្តែបានបន្ថែមវិធីខ្លះ១ពាក់ព័ន្ធជាមួយធនធានធម្មជាតិ (NR) ទៅក្នុងដំណើរការកសាងផែនការ និងត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងឃុំចំនួន៧ ដែលជាគោលដៅអនុវត្តន៍សំរាប់ឆ្នាំ ២០០១ ។

ឃុំភាគច្រើនដែលបានសាកល្បងដំណើរការនេះ បានដាក់បញ្ចូលការគ្រប់គ្រងព្រៃឈើ និងការកសាងផែនការប្រើប្រាស់ដីធ្លីទៅក្នុងផែនការរយៈពេលវែងរបស់ខ្លួន ។ បួនឆ្នាំក្រោយពីដំណើរការ IPP (ការរួមបញ្ចូលដំណើរ LPP និង CBNRM) ត្រូវបានលើកឡើងជាលើកដំបូង នៅក្នុងការកសាងផែនការដែលធ្វើឡើងដោយក្រុមវិភាគ និងកសាងផែនការរបស់កម្មវិធីសិលា (សូមអានជំពូក៩) និងនៅពេលដាក់ឱ្យអនុវត្ត ដំណើរនេះនៅក្នុងឃុំខាងលើ ឃុំសោមធំមានលទ្ធភាពដាក់បញ្ចូលកិច្ចការពារព្រៃឈើដែលត្រូវបានចាត់ទុកថាជាបញ្ហាអាទិភាពនៅក្នុងការកសាង ផែនការឆ្នាំ ១៩៩៩ (តារាងទី ២) ។ ចាប់ពីឆ្នាំ ១៩៩៥-១៩៩៩មក ដំណើរការ LPP បានបំភ្លេចចោលបញ្ហានេះទាំងអស់ ។

នៅខែមីនា ឆ្នាំ២០០១ ឯកសារណែនាំស្តីពី LPP ត្រូវបានចែកផ្សាយនៅខេត្តជាច្រើន ។ ដំណើរការនៃការចងក្រងនេះត្រូវបានធ្វើឡើងដោយផ្អែកលើដំណើរការ LPP ដែលបានអនុវត្តជាទូទៅក្នុងកម្មវិធីសិលា។ ឯកសារណែនាំនោះសង្កត់ធ្ងន់ពីតម្រូវការឱ្យមានការដាក់បញ្ចូល NRM និងយេនឌ័រ ទៅក្នុងដំណើរការនោះ ទោះបីពុំទាន់មានការដាក់បញ្ចូលប្រការទាំងពីរនេះ នៅក្នុងស្ថានភាពអនុវត្តជាក់ស្តែងនៅឡើយក៏ដោយ ។ ប៉ុន្តែ ក្រុមការងារក្នុងខេត្តរតនគីរី មានការជឿជាក់កាន់តែខ្លាំងឡើងក្នុងការដាក់បញ្ចូលវិធាន NRM ទៅក្នុងដំណើរការនេះឡើងវិញ ។

## ការអភិវឌ្ឍថ្មីៗ

ជំហានបន្ទាប់នៃកម្មវិធីសិលា បានដាក់បញ្ចូល NRM ជាប្រធានបទអន្តរវិស័យនៅក្នុងគ្រប់គម្រោងទាំងអស់របស់ខ្លួន ។ ការធ្វើបែបនេះបានផ្តល់ប្រយោជន៍យ៉ាងច្រើនសម្រាប់ការសាកល្បងនៅក្នុងខេត្តរតនគីរី ដែលបានដាក់បញ្ចូលបញ្ហាធនធានធម្មជាតិទៅក្នុងគម្រោងរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលរបស់អង្គការ CARERE បានធ្វើទស្សនកិច្ចនៅខេត្តរតនគីរីកាន់តែញឹកញាប់ ដោយផ្តោតលើដំណើរកសាងផែនការដែលកំពុងអនុវត្តក្នុងខេត្តរតនគីរី និងពិនិត្យមើលជម្រើសសម្រាប់ទទួលមូលនិធិពី LDF ។ ក្រុមការងារនៅក្នុងខេត្តរតនគីរីត្រូវបានស្នើឱ្យធ្វើការវាយតម្លៃអំពីដំណើរកសាងផែនការខុសគ្នាចំនួនពីរដែលកំពុងអនុវត្តក្នុងខេត្តរតនគីរី (LPP និង LPP ដែលបានកែប្រែ)។ ក្រុមការងារក្នុងខេត្តរតនគីរីត្រូវធ្វើការប្រៀបធៀប ថាតើសហគមន៍ និងអ្នកសម្របសម្រួលពេញចិត្តកម្រិតណាចំពោះដំណើរការទាំងពីរនោះ និងកម្រិតយល់ដឹងអំពី NRM នៅក្នុងដំណើរការទាំងពីរនោះ និង CDP នានា ព្រមទាំងអាទិភាព របស់ឃុំសម្រាប់ដំណើរការទាំងពីរនោះ។ ក្រុមនេះក៏ត្រូវបានស្នើផងដែរឱ្យចាប់ផ្តើមដំណើរការដំបូងរបស់ខ្លួនដើម្បីរៀបចំកិច្ចសន្យា និងបែបបទផ្សេងដែលត្រូវការចាំបាច់ ប្រសិនបើមានការពង្រីកជម្រើសសម្រាប់ទទួលការគាំទ្រពី LDF ។

ជាដំបូងក្រុមការងារក្នុងខេត្តរតនគីរី បានរៀបរាប់អំពីតម្រូវការក្នុងភូមិដាក់បញ្ចូលក្នុង CDP ។ បន្ទាប់មកពួកគេពិភាក្សា អំពីអ្វីដែលអាចទទួលការគាំទ្រពីមូលនិធិ LDF ប្រសិនបើមានការគាំទ្រលើជំរើសជាបន្ថែមពី LDF ។ នៅក្នុងកិច្ចប្រជុំក្រោយមក ជាមួយក្រុមប្រឹក្សានាយករបស់អង្គការ CARERE ចំណុចទាំងអស់នោះត្រូវពង្រីកបន្ថែម ដោយដាក់បញ្ចូលប្រភេទសេវាសាធារណៈ ដែលអាចទទួលការគាំទ្រពីមូលនិធិ LDF ។ លទ្ធផលទាំងនោះមានបង្ហាញជូនក្នុងតារាងទី ៥ ។

| ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ | ប្រភេទសេវាសាធារណៈ | លក្ខណៈវិនិច្ឆ័យសម្រាប់សេវាសាធារណៈ |
|---|---|---|
| ♦ ផ្លូវថ្នល់<br>♦ សាលារៀន<br>♦ ប្រព័ន្ធលូទឹក<br>♦ ទំនប់<br>♦ អណ្តូងទឹក<br>♦ បង្គន់អនាម័យ<br>♦ ស្នាក់ការសុខភាព<br>♦ អាងទឹក<br>♦ ម៉ាស៊ីនកិនស្រូវ<br>♦ ប្រព័ន្ធស្រោចស្រព (រួមទាំងប្រឡាយ<br>♦ មជ្ឈមណ្ឌលធនធានឃុំ<br>♦ សាលប្រជុំភូមិ<br>♦ ម៉ាស៊ីនបូមទឹក<br>♦ ធនាគារស្រូវ<br>♦ កាណូត | ♦ ការបណ្តុះបណ្តាល<br>កសិកម្ម<br>ថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ<br>ការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ<br>VV, VAV<br>បុគ្គលិកសុខាភិបាល<br>ឆ្មប<br>គ្រូ NFE<br>♦ ការផ្សព្វផ្សាយ<br>កសិដ្ឋានបង្ហាញ<br>ថ្នាលបង្ហាញក្នុងភូមិ<br>♦ ជំនួយបច្ចេកទេស<br>មេធាវីជួយក្នុងការដោះស្រាយទំនាស់ដីធ្លី<br>ការគ្រប់គ្រងដីធ្លីសាធារណៈ/សេវានានា<br>ការបង្កើតនិងបណ្តុះបណ្តាលសហគមន៍ ព្រៃឈើ<br>ការកសាងផែនការប្រើប្រាស់ដី (ធ្វើផែនទី<br>ការចុះបញ្ជីដីធ្លី<br>♦ បង្កើនការយល់ដឹង<br>ការថែទាំសុខភាពបន្តពូជ<br>សារៈសំខាន់នៃការបង្កើនការយល់ដឹងដល់មាតាបិតា<br>ឯកសារ និងរូបភាពវីដេអូ<br>សិទ្ធិ និងច្បាប់<br>ការអប់រំអំពីអនាម័យ<br>ការកសាងផែនការប្រើប្រាស់ដីធ្លី<br>វិវាទដីធ្លី<br>ការបង្ហាញរូបភាពតាមទូរទស្សន៍<br>ការចែកចាយព័ត៌មាន<br>♦ មូលនិធិសង្គ្រោះពេលមានគ្រោះមហន្តរាយ<br>♦ ដំណោះស្រាយទំនាស់ (ការបង់ប្រាក់ទៅតុលាការ | ♦ គួរចុះកិច្ចសន្យា<br>♦ ផលប្រយោជន៏សម្រាប់ភូមិ-ឃុំទាំងមូល<br>♦ ក្រុមគោលដៅគួរទទួលផលប្រយោជន៏ (ស្ត្រី អ្នកក្រីក្រ ។ល។<br>♦ កិច្ចព្រមព្រៀងជាមុនពីប្រភេទសេវា និងការបែងចែកផល<br>♦ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសអ្នកម៉ៅការ<br>♦ ពេលវេលា (ជាក់ស្តែង<br>♦ លទ្ធផលច្បាស់លាស់<br>♦ ទាក់ទងជិតស្និទ្ធជាមួយចក្ខុវិស័យ (ផែន-ការអភិវឌ្ឍន៍ឃុំ<br>♦ ការរួមវិភាគទាននៅមូលដ្ឋាន<br>♦ រក្សាទំនាក់ទំនងរវាងអតិថិជន អ្នកម៉ៅការ និងជំនួយបច្ចេកទេស<br>♦ អាចប្រើប្រាស់តែពេលណាដែលរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ មិនអាចផ្តល់សេវា<br>♦ ផ្តល់អាទិភាពទៅស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង ផ្នែកឯកជន |

*តារាងទី៥ : ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ដែលអាចទទួលការគាំទ្រ ក្នុងករណីមានការគាំទ្របន្ថែមពី LDF*

<u>កំណត់សំគាល់</u> : នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០១ ទីប្រឹក្សាមួយរូបពីធនាគារពិភពលោក បានពិនិត្យមើលជម្រើសការគាំទ្រពី LDF និងបានសម្តែងមតិជំទាស់យ៉ាងខ្លាំង ចំពោះការប្រើប្រាស់មូលនិធិ LDF សម្រាប់ការគាំទ្រមន្ទីរនានារបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាទាំងឡាយ [១៤] ។

[១៤] អំណះអំណាងនៅត្រង់ថា ប្រសិនបើប្រើប្រាស់ LDF សម្រាប់គាំទ្រអ្វីដែលជាភារកិច្ចរបស់បណ្តាមន្ទីរជំនាញដែលត្រូវអនុវត្តទៅអនាគតប្រាកដជាមានការលំបាកក្នុងការបញ្ឈប់ការទាមទារឱ្យមានការអនុវត្តទម្លាប់បែបនេះ ពីសំណាក់ការិយាល័យទាំងនោះ ។ ទីប្រឹក្សារូបនោះអះអាងថា គួរប្រើប្រាស់ LDF សម្រាប់គាំទ្រគម្រោងរបស់វិស័យឯកជនតែប៉ុណ្ណោះ ។ ក្នុងតំបន់នានាដូចជាខេត្តរតនគីរី វិស័យឯកជននៅទន់ខ្សោយ ដូច្នេះ គួរតែបង្កើតក្រុម សហគមន៍ និងប្រើប្រាស់ក្រុមនេះជាគម្រោងរបស់វិស័យឯកជន ។ ប៉ុន្តែការប្រមូលចំណូលពីសេវាផ្តល់ដោយមន្ទីរនានាដើម្បីបង្កើនថវិការបស់មន្ទីរទាំងនោះ អាចជួយកែលំអដំណើរការអនុវត្ត របស់មន្ទីរទាំងនោះ និងបង្ខំឱ្យមន្ទីរទាំងនោះធ្វើការកាន់តែមានលក្ខណៈប្រកួតប្រជែងជាងមុន ។

## បញ្ហា

## ដំណើរការកសាងផែនការនៅមូលដ្ឋាន

ដំណើរការកសាងផែនការដែលមានការចូលរួមមានសារៈសំខាន់ណាស់ និងអនុញ្ញាតឱ្យសហគមន៍បង្ហាញពីតម្រូវការ និងការប៉ងប្រាថ្នារបស់ខ្លួនបានច្បាស់លាស់ និងជាក់លាក់ ។ ដំណើរការនេះគួរផ្តល់ឱកាសឱ្យសហគមន៍បង្ហាញពីអ្វីដែលពួកគាត់ចាត់ទុកថាជាតម្រូវការ និងការប៉ងប្រាថ្នារបស់ពួកគាត់ ។ ផែនការនានាដែលបានកសាងឡើងគួរតែផ្តល់លទ្ធភាពដល់សហគមន៍ក្នុងការទាក់ទាញការគាំទ្រពីប្រភពនានាដូចជាពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានាទៅតាមជំនាញជាក់លាក់រៀងៗខ្លួន ។

ចំណុចសំខាន់នៃដំណើរការកសាងផែនការនៅមូលដ្ឋានដោយឡែកមួយ មិនមែនជាយុទ្ធសាស្ត្រ ហើយក៏មិនផ្តោតលើការកសាងផែនការរយៈពេលវែងនោះទេ ប៉ុន្តែផ្តោតលើការរៀបចំឱ្យមានការវិនិយោគក្នុងមូលដ្ឋានសម្រាប់រយៈពេល ខ្លី-មធ្យម ដោយចែងពីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ[១៥] ។ ដំណើរការនេះអាចទាក់ទងតិចតួច ឬពុំទាក់ទងទាល់តែសោះជាមួយចក្ខុវិស័យ និងឧបសគ្គរយៈពេលវែង ដែលសហគមន៍ត្រូវប្រឈមដើម្បីឈានទៅសម្រេចចក្ខុវិស័យ ។ ចំណុចខ្សោយនៃវិធាន LPP មានបង្ហាញជូនយ៉ាងច្បាស់នៅក្នុងឧទាហរណ៍នៃករណីឃុំសោមធំ : នៅពេលដែលដំណើរការLPP កំពុងបង្កើតផែនការរយៈពេលខ្លី ឃុំនោះបានប្រឈមនឹងការគម្រាមកំហែងចម្បងមួយចំពោះជីវភាពរស់នៅរបស់ពួកគេ ។ ប្រការនេះត្រូវបានទទួលស្គាល់នៅក្នុងដំណើរការ LPP ។ ការកសាងផែនការរយៈពេលខ្លីពុំបានឆ្លើយតបនឹងតម្រូវការចាំបាច់ជាបន្ទាន់សំរាប់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានឡើយពោលគឺសន្តិសុខដីធ្លី និងព្រៃឈើ ។

នៅខេត្តរតនគិរី បទពិសោធន៍នេះបង្ហាញថា នៅពេលបំពេញតាមតម្រូវការរយៈពេលខ្លីតែមួយមុខ គេពុំអាចដោះស្រាយឫសគល់នៃបញ្ហាភាពក្រីក្រក្នុងចំណោមអ្នកស្រុកលើបានឡើយ លើកលែងតែមានការពិចារណាពីបញ្ហាគ្រប់ជ្រុងជ្រោយ ដែលជាឫសគល់នៃជីវភាពរស់នៅរបស់ពួកគេ ហើយដែលនៅក្នុងពេលជាមួយគ្នា ទាមទារឱ្យមានវិធីសាស្ត្រដោះស្រាយរយៈពេលវែង ។

## ការកំណត់ចក្ខុវិស័យ ‑ វិធីសាស្ត្រវិភាគស្ថានភាពជីវភាពរស់នៅ

ការកំណត់ចក្ខុវិស័យមានសារៈសំខាន់ណាស់ ដើម្បីឱ្យដំណើរកសាងផែនការមានប្រសិទ្ធិភាព ។ គោលដៅ ឬ ចក្ខុវិស័យបង្ហាញពីទិសដៅនៃសេចក្តីរំពឹងទុក រីឯគោលបំណងគឺជាលទ្ធផលជាក់លាក់ ដែលអាចមើលឃើញនៅក្នុងជំហាននានាចំពោះមុខមុនពេលឈានទៅសម្រេចគោលដៅ និងចក្ខុវិស័យ (Bunch, 1982) ។ ផ្អែកលើគោលបំណង យើងអាចកំណត់ចំណុចដៅសម្រាប់រយៈពេលមួយឆ្នាំ (ដ្យាក្រាម ១ ។ ការកំណត់ចក្ខុវិស័យផ្តោតលើ ការកសាងផែនការរយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី ដោយផ្សារភ្ជាប់គោលបំណងទាំងអស់ជាមួយគ្នា ដើម្បីសម្រេចលទ្ធផលចុងក្រោយ ។

---

[១៥] Leonardo Romeo. ១៩៩៨. កសាងផែនការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ, UNICEF, ១៩៩៨




*ដ្យាក្រាម ១ : ដំណើរការកសាងផែនការដែលបង្ហាញលំដាប់នៃការកសាងផែនការ*
*ប្រភព : កែសម្រួលពី Nooyens (២០០១)*

ផ្អែកលើចក្ខុវិស័យនេះ អ្នកកសាងផែនការគម្រោងត្រូវស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋ និងឧបសគ្គនានាដែលពួកគាត់យល់ថាជាការរាំងស្ទះមិនឱ្យបំពេញតម្រូវការទាំងនោះបាន (Cook, 1991)។ ការធ្វើអត្តសញ្ញាណវត្តមានកាលានុវត្តន៍ភាពក៏មានសារៈសំខាន់ផងដែរ ។ បន្ទាប់មកគេអាចបង្កើតយុទ្ធសាស្ត្រដើម្បីជំនះឧបសគ្គទាំងនោះ និងដើម្បីប្រើប្រាស់កាលានុវត្តន៍ភាពទាំងនោះឱ្យមានប្រសិទ្ធភាព ។

វិធានវិភាគស្ថានភាពជីវភាពរស់នៅ អាចជួយកែលំអការកំណត់ចក្ខុវិស័យឱ្យបានស៊ីជម្រៅ នៅពេលពិភាក្សាជាមួយសហគមន៍ និងនៅពេលផ្តោតលើទិដ្ឋភាពចម្បងបួននៃក្របខ័ណ្ឌវិភាគ[១៦] ។ បន្ទាប់មកសហគមន៍អាចកំណត់ចក្ខុវិស័យរបស់ខ្លួនដោយផ្អែកលើការវិភាគទិដ្ឋភាពទាំងបួននេះនៃស្ថានភាពជីវភាពរស់នៅរបស់ពួកគេ ។ បន្ទាប់ពីនេះ ពួកគេអាចធ្វើអត្តសញ្ញាណកត្តារាំងស្ទះ និងកត្តាជម្រុញ ដែលមានសារៈសំខាន់ក្នុងការសម្រេចគោលដៅរបស់ពួកគេ និងក្នុងការកសាងយុទ្ធសាស្ត្រដើម្បីជំនះកត្តារាំងស្ទះ ព្រមទាំងប្រើប្រាស់កត្តាជម្រុញឱ្យមានប្រសិទ្ធភាព ។ ផ្អែកលើយុទ្ធសាស្ត្រនានា ដើម្បីសម្រេចចក្ខុវិស័យគេអាចពិចារណាពីឧបសគ្គ និងកាលានុវត្តន៍ភាពជាយុទ្ធសាស្ត្រ និងពិចារណាផងដែរពីកាលានុវត្តន៍ភាពក្នុងការទទួលការគាំទ្រពីខាងក្រៅ

[១៦] វប្បធម៌-សង្គម សេដ្ឋកិច្ច ស្ថាប័ន និងធនធានធម្មជាតិ (សូមអានក្នុង Nooyens and Meijers, 2001).

និងកំណត់គោលបំណងគម្រោងសម្រាប់រយៈពេល៣-៥ឆ្នាំ ដែលជាមូលដ្ឋាននៃផែនការ ៣-៥ឆ្នាំ។ ផ្អែកលើផែនការគម្រោងនេះ សហគមន៍អាចកំណត់ចំណុចដៅសម្រាប់រយៈពេលមួយឆ្នាំ ហើយក្រោយពីបានពិចារណាឧបសគ្គ និងកាលានុវត្តន៍ភាពជាក់ស្តែង (រួមទាំងកាលានុវត្តន៍ភាពក្នុងការទទួលបានការគាំទ្រពីខាងក្រៅ ទីបំផុត សហគមន៍អាចកសាងផែនការសកម្មភាពសម្រាប់រយៈពេលមួយឆ្នាំ ។

ចំណុចទាំងអស់នេះអំពាវនាវឱ្យមានដំណើរការវិភាគដែលពិនិត្យមើលបញ្ហាជាមូលដ្ឋានគ្រឹះនានា ប៉ុន្តែមិនពិនិត្យមើលអំពីការកសាងផែនការ ដែលឆ្លើយតបតែនឹងតម្រូវការ និងសកម្មភាពចំពោះមុខនោះឡើយ ដែលចាប់អារម្មណ៍ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ អំពីទំនាក់ទំនងរវាងតម្រូវការ និងសកម្មភាពនានា និងគោលដៅរយៈពេលវែងរបស់សហគមន៍ ។

## មូលនិធិអភិវឌ្ឍន៍មូលដ្ឋាន (LDF)

វត្តមាននៃមូលនិធិ LDF សម្រាប់ទ្រទ្រង់តែគម្រោងមួយចំនួន គឺជាឧបសគ្គចំពោះជម្រើសនៃការអភិវឌ្ឍសម្រាប់សហគមន៍។ សហគមន៍ពុំអាចជ្រើសរើសបញ្ហាដែលពួកគេចាំបាច់ត្រូវដោះស្រាយដូចជា "តម្រូវការជាយុទ្ធសាស្ត្រ" ដែលបានកំណត់ឃើញ ប៉ុន្តែពួកគេមានត្រឹមតែជម្រើសដែលគម្រោងផ្តល់ឱ្យតែប៉ុណ្ណោះ ។

បច្ចុប្បន្នមានការពិភាក្សាដើម្បីបង្កើនប្រភេទការងារសម្រាប់ទទួលការគាំទ្រពី LDF ដែលបង្ហាញឱ្យឃើញថាមានសភាពស្មុគស្មាញ ។ ការប្រើប្រាស់ LDF សម្រាប់គម្រោងដែលអាចបង្កើនអ្នកចំណូលថ្មី ដែលមិនមែនជាជនជាតិដើមភាគតិចមកក្នុងឃុំ និងភូមិរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាកង្វល់ធ្ងន់ធ្ងរមួយដែលគួរតែមានការពិចារណានៅពេលកំណត់គម្រោងដែលមានសក្តានុពលសម្រាប់ទទួលការគាំទ្រពីមូលនិធិ LDF ។

ការពង្រីកប្រភេទការងារដែលអាចគាំទ្រដោយ LDF ដោយរួមបញ្ចូលការផ្តល់ហិរញ្ញប្បទានដល់ស្ថាប័នឯកជនក្នុងការផ្តល់សេវានានា ក៏ជាប្រការទាមទារឱ្យមានការពិចារណាហ្មត់ចត់ផងដែរ នៅពេលអនុវត្តក្នុងខេត្តរតនគីរី ព្រោះថា វិស័យឯកជននៅក្នុងសហគមន៍ជនជាតិដើមភាគតិចនៅទីនោះ មានភាពទន់ខ្សោយណាស់។ ដូច្នេះការធ្វើបែបនេះ អាចនាំឱ្យមានកំណើននៃការហូរចូលនៃសហគ្រាសឯកជនទៅក្នុងតំបន់ទាំងនោះ រួមទាំងប្រជាពលរដ្ឋមិនមែនជាជនជាតិដើមភាគតិចទៅក្នុងសហគមន៍ទាំងនោះផងដែរ ។

សហគមន៍ជនជាតិដើមភាគតិច មានទ្រព្យសម្បត្តិប្រហាក់ប្រហែលគ្នា ហើយដំណើរការធ្វើសេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយផ្អែកលើសហគមន៍ ។ គួរមានការប្រុងប្រយ័ត្នក្នុងការបង្កើតឱ្យមានសហគ្រាសឯកជននៅក្នុងសហគមន៍ទាំងនោះដោយត្រូវពិចារណាអំពីផលប៉ះពាល់ខាង ផ្នែកសង្គម និងវប្បធម៌ដែលបណ្តាលពីទង្វើនេះផងដែរ ។ បើពុំនោះទេយន្តការបែបនោះអាចបំផ្លាញចរិតសមូហភាពនៃសហគមន៍ទាំងនោះ ។

## ការសម្របសម្រួល

ដើម្បីឱ្យដំណើរការចូលរួមមានប្រសិទ្ធភាព ប្រការសំខាន់គឺត្រូវមានជំនាញខាងការសម្របសម្រួលឱ្យបានល្អ ។ ក្នុងខេត្តរតនគិរី ការសម្របសម្រួលដំណើរ LPP ត្រូវធ្វើឡើងក្នុងចំណោមអ្នកមានវប្បធម៌ និងភាសាខុសៗគ្នា ។ ចរិតលំអៀងខាងវប្បធម៌អាចងាយកើតមាននៅក្នុងដំណើរការសម្របសម្រួល និងនៅក្នុងផែនការនានា ។ ត្រូវមានការបកស្រាយឱ្យបានត្រឹមត្រូវបំផុតចំពោះភាពខុសគ្នាខាងភាសា ។ ឧទាហរណ៍ ចំពោះជនជាតិខ្មែរ ការខ្វះស្បៀងមានន័យថា "ខ្វះអង្ករ" ចំណែកអ្នកស្រុកលើពាក្យនេះមានន័យថា គ្មានស្បៀងអាហារជាទូទៅ (គ្មានអង្ករ គ្មានមើមឈើ គ្មានសាច់ សត្វ ។ល ។ ។ អ្នកសម្របសម្រួលជនជាតិខ្មែរអាចធ្វើការសន្និដ្ឋានថា ជាការខ្វះអង្ករតែមួយមុខក្នុងពេលដែលអ្នកភូមិ និយាយថាស្បៀង ជាហេតុនាំឱ្យការសម្របសម្រួលផ្តោតតែលើការពិភាក្សាតែអំពីការផលិតស្រូវ ដោយពុំពិចារណាជម្រើសផ្សេងទៀតឡើយ ។

បញ្ហាមួយផ្សេងទៀតគឺថា អ្នកសម្របសម្រួលភាគច្រើនមានប្រភពពីសង្គមមនុស្ស "ភាគច្រើន" ឬ "វណ្ណៈខ្ពស់" និងព្យាយាមជួយសហគមន៍ ដែលជាផ្នែកមួយនៃក្រុមក្នុងវប្បធម៌ "ជនភាគតិច" ឬ "វណ្ណៈក្រោម" ។ ដូច្នេះ ក្នុងករណីជាច្រើនឥរិយាបទ អរិជ្ជមាន និងវណ្ណៈខ្ពស់របស់អ្នកសម្របសម្រួលពុំផ្តល់ប្រយោជន៍ដល់សមាជិកសហគមន៍ឡើយ ។ មានទិន្នាការក្នុងការយល់ឃើញថា កសិករគឺជា "អ្នកក្រ" "ល្ងង់ខ្លៅ" ឬ "អ្នកធ្វើរឿងផ្តេសផ្តាស" ហើយប្រការនេះនាំឱ្យមានទិន្នាការអាណិតអាសូរការធ្វើ ខ្លួនជាអ្នកឧបត្ថម្ភ ឬជាអ្នកផ្លាស់ទម្លាប់របស់អ្នកស្រុកលើទៅវិញ ។

រចនាសម្ព័ន្ធចាត់តាំងដែលគ្មានការផ្លាស់ប្តូរ ប្រកបដោយយុទ្ធសាស្ត្រអនុវត្តមិនផ្លាស់ប្តូរ គឺជាកត្តាកាត់បន្ថយលក្ខណៈបត់បែនរបស់អ្នកសម្របសម្រួល ។ ក្នុងស្ថានភាពទាំងនេះ អ្នកសម្របសម្រួលមិនបានអនុវត្តមុខនាទីរបស់ខ្លួនទេ ប៉ុន្តែធ្វើសកម្មភាព ដូចជាគ្រឿងយន្តដែលបង្កើតជាបញ្ហាមួយ ដោយសារអ្នកសម្របសម្រួលត្រូវបានណែនាំ ឱ្យប្រកាន់ចរិតដែលមានការចូលរួម និងបត់បែន ចំណែកការបណ្តុះបណ្តាល វិធីសាស្ត្រដែលទទួលបានគ្មានលក្ខណៈបត់បែនឡើយ ។ ជាលទ្ធផលការសម្របសម្រួលបែបនេះពុំសូវមានលក្ខណៈចូលរួមឡើយ ។

## បទពិសោធន៍

### ទំនាក់ទំនងនៃដំណើរការកសាងផែនការនៅមូលដ្ឋាន ដែលយកចិត្តទុកដាក់ចំពោះបញ្ហាធនធាន

ដំណើរការកសាងផែនការនៅមូលដ្ឋានត្រូវបានបង្កើតឡើងដើម្បីជួយប្រជាពលរដ្ឋឱ្យបង្ហាញពីតម្រូវការ បញ្ហា និងបំណងប្រាថ្នារបស់ពួកគាត់ ។ នៅក្នុងខេត្តរតនគិរី បញ្ហាស្ថិតនៅត្រង់ថា តើដំណើរការនេះអនុញ្ញាតឱ្យសហគមន៍បង្ហាញគំនិត និងយោបល់ របស់ពួកគាត់ពីបញ្ហាទាំងនេះ ឬទេ ។

ក្នុងភូមិជាច្រើនដែលមានការសាកល្បងវិធីសាស្ត្រ E/I-LPP អ្នកភូមិបានស្នើឱ្យដាក់បញ្ចូលកិច្ចការពារធនធានធម្មជាតិរបស់ពួកគេទៅក្នុង CDP របស់ពួកគេ ។ ឃុំសោមធំ ភូមិលើងគ្រៀន និងឃុំយក្សលោម បានធ្វើការចរចាដោយជោគជ័យជាមួយអាជ្ញាធរខេត្ត ហើយបច្ចុប្បន្នអាចគ្រប់គ្រងព្រៃឈើសហគមន៍របស់ខ្លួនបាន ។ សហគមន៍ជាច្រើនមានចំណាប់អារម្មណ៍ យ៉ាងខ្លាំង

ក្នុងការចាប់ផ្តើម CBNRM នៅក្នុងបណ្តុំសហគមន៍របស់ពួកគេ ។ អាជ្ញាធរខេត្ត ក៏បានបង្ហាញផងដែរអំពីចំណាប់អារម្មណ៍លើវិធាន CBNRM និងបានស្នើឱ្យមាន CBNRM នៅក្នុងឃុំកាន់តែច្រើនថែមទៀត ។ អ្នកភូមិបានបង្ហាញថា ពួកគេមានចំណូលចិត្តចំពោះ E/I-LPP ជាង LPP ហើយដែលប្រការនេះគួរទទួលពិចារណារដោយម៉ត់ចត់ផងដែរ ។

## ពេលវេលា ប្រាក់កាស និងការសម្របសម្រួល

ធៀបនឹង E/I-LPP ដំណើរការ LPP ដោយឡែក មានលក្ខណៈងាយស្រួលមួយកម្រិត និងធ្វើបានឆាប់រហ័សដោយទាមទារ ពេលវេលាខ្លីជាង និងត្រូវការឱ្យមានការសម្របសម្រួលតិចតួចជាងនៅក្នុងភូមិ-ឃុំ នីមួយៗ ។ វិធីសាស្ត្រ E/I-LPP ត្រូវចំណាយច្រើនជាង ព្រោះត្រូវការឧបករណ៍ច្រើនជាង និងទាមទារឱ្យមានអ្នកជំនាញសម្របសម្រួលល្អ ដែលយល់ដឹងពីបញ្ហាផ្សេងៗ ដែលអ្នកស្រុកលើកំពុងប្រឈម ។ ដោយហេតុថាអ្នកសម្របសម្រួលត្រូវការប្រាក់បៀវត្សរ៍ និងប្រាក់បេសកកម្មភាពខុសគ្នានៃថ្លៃ ចំណាយសម្រាប់ការសម្របសម្រួលរវាងដំណើរការទាំងពីរបែបនេះអាចមានកំរិតខ្ពស់ ។

## អ្នកសម្របសម្រួលសហគមន៍

បទពិសោធន៍បង្ហាញថា ប្រសិនបើអ្នកសម្របសម្រួលត្រូវបានជ្រើសរើស ឬ តែងតាំងពីក្នុងចំណោមសមាជិកសហគមន៍ គេអាចជំនះបាននូវបញ្ហាជាច្រើនខាងវប្បធម៌ និងភាសា។ អ្នកសម្របសម្រួលខាងសហគមន៍ក៏ទំនងជាមានលក្ខណៈមោះមុតជាងបុគ្គលិកដែលពុំទទួលឥទ្ធិពលដោយផ្ទាល់ពីលទ្ធផលនៃគម្រោង ហើយត្រូវចំណាយតិចជាង ដោយពួកគេពុំចាំបាច់ត្រូវធ្វើដំណើរឆ្ងាយដើម្បីធ្វើការក្នុងភូមិទាំងនេះឡើយ ។

## តើអ្នកណាជាអ្នកទទួលផល?

LPP ជាដំណើរការសំខាន់បំផុតនៃកម្មវិធីសិលា ហើយអត្ថបទនេះពុំចោទសំណួរអំពីអត្ថប្រយោជន៍នៃដំណើរការនេះឡើយ។ ប៉ុន្តែអត្ថបទនេះបង្ហាញពីឧបសគ្គខ្លះៗក្នុងខេត្តរតនគិរី ដោយសារស្ថានភាពជាក់លាក់នៅទីនោះ និងព្យាយាមចងក្រងជាឯកសារ ដើម្បីកែសម្រួលដំណើរការនេះឱ្យស្របតាមស្ថានភាពជាក់លាក់នៅកន្លែងនោះ ។ បទពិសោធន៍នានាក្នុងខេត្តរតនគិរី បានបង្ហាញអំពីបញ្ហាជាក់លាក់នានា ទាក់ទងនិងការលើកកំពស់ប្រសិទ្ធិភាពនៃដំណើរការកសាងផែនការនៅមូលដ្ឋាន និងការសម្របសម្រួលនៅមូលដ្ឋាន ទន្ទឹមនិងការព្យាយាមរក្សា និងបង្កើនភាពពាក់ព័ន្ធនៃដំណើរការនោះ ។

សំណួរចម្បងមួយគឺ តើដំណើរការ LPP ដែលអាចត្រូវចំណាយថវិកាតិចជាង និងទាមទារពេលវេលាខ្លីជាង ប៉ុន្តែដោយមានការគាំទ្រតិចជាង អាចផ្តល់អ្វីដែលអ្នកភូមិត្រូវការដែរឬទេ ឬ វាគ្រាន់តែជាតំណាងឱ្យសកម្មភាពដែលអ្នកមកពីខាងក្រៅបង្ខំឱ្យអនុវត្តដោយផ្តល់ផលប្រយោជន៍តិចតួចប៉ុណ្ណោះសម្រាប់អ្នកភូមិឬយ៉ាងណា? ។ តើគម្រោង LPP ដែលផ្តោតលើទិដ្ឋភាពទូលំ

ទូលាយ និងដែលចំណាយថវិកា និងពេលវេលាច្រើនជាងសម្រាប់ការសម្របសម្រួល ដែលអាចវិភាគមូលហេតុនានានៃភាពក្រីក្របានលំអិត អ្នកភូមិអាចកំណត់ផែនការបានត្រឹមត្រូវ និងវិធានជាយុទ្ធសាស្រ្តដែលអាចយកទៅអនុវត្តដោយប្រើប្រាស់ធនធានពីប្រភពច្រើនយ៉ាងមានប្រសិទ្ធិភាពខ្ពស់ជាង ឬយ៉ាងណា ?

## ដំណើរការកសាងផែនការមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ-សង្កាត់

LPP និង LPPដែលកែប្រែ ត្រូវបានអនុវត្តដោយគណៈកម្មការអភិវឌ្ឍន៍ភូមិ និងឃុំ តាមរយៈកម្មវិធីសិលា ។ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅឆ្នាំ២០០២ រចនាសម្ព័ន្ធនិងមុខនាទីអភិបាលកិច្ចបានផ្លាស់ប្តូរ ក្រុមប្រឹក្សាឃុំបានចូលកាន់មុខនាទីជំនួសគណៈកម្មការអភិវឌ្ឍន៍ភូមិ និងឃុំ ហើយដំណើរការកសាងផែនការថ្មីមួយផ្អែកលើ LPP ត្រូវបានរៀបចំឡើងសម្រាប់ក្រុមប្រឹក្សាឃុំ ។ យុទ្ធសាស្រ្តរបស់កម្មវិធីសិលាដែលដាក់បញ្ចូល NREM បានប្រើប្រាស់បទពិសោធន៍ពីខេត្តរតនគីរីដើម្បីរៀបចំដំណើរកសាងផែនការដែលមានការកែប្រែនៅក្នុងបណ្តាខេត្តដែលកំពុងធ្វើការសាកល្បងយុទ្ធសាស្រ្តដាក់បញ្ចូល NREM នេះ ។ ជាលទ្ធផល ខេត្តរតនគីរីអាចបន្តបញ្ចូលការពិចារណាអំពីធនធានធម្មជាតិទៅក្នុងដំណើរកសាងផែនការថ្មីដែលត្រូវប្រើប្រាស់ដោយក្រុមប្រឹក្សាឃុំ ។

## សេចក្តីសន្និដ្ឋាន

ស្ថានភាពស្មុគស្មាញទាមទារឱ្យមានដំណោះស្រាយសាំញ៉ាំ ។ ក្នុងខេត្តរតនគីរី ការផ្តល់ដំណោះស្រាយងាយ (ដែលប្រើប្រាស់ផែនការរយៈពេលខ្លី មិនបានជួយកាត់បន្ថយបញ្ហាជាមូលដ្ឋានគ្រឹះ និងតម្រូវការនៅក្នុងខេត្តនេះទេ ប៉ុន្តែអាចនាំឱ្យមានកំណើនភាពក្រីក្រទៅវិញ ។ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញ ទាមទារអោយមានការវិភាគដែលមានការចូលរួមពីអ្នកពាក់ព័ន្ធមុនពេលកសាងផែនការ ។ ដំណើរការ LPP ក្នុងខេត្តរតនគីរី គឺជាការប្រឹងប្រែងមួយដើម្បីកែលំអការវិភាគមុនពេល កសាងផែនការដោយផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើស្ថានភាពនៃធនធាន ការដោះស្រាយតម្រូវការជាយុទ្ធសាស្រ្ត និង ឧបសគ្គនានា ។ ការបង្កើនទំហំគំរោង LDF អាចផ្តល់ការគាំទ្របន្ថែមទៀតដល់អ្នកភូមិ ។ ការធ្វើបែបនេះ អាចរំពឹងថានឹងនាំឱ្យមានដំណើរការបែងចែកធនធាន អោយមានភាពសមស្របជាងមុន ។

## REFERENCES


Analysis and Planning Team and the Peoples In O'Yadao District. 1996. *Assessment of the Situation in O'Yadao District.*

Bunch, R. 1982. *Two Ears of corn: A guide to people-centered improvement.* World Neighbours.

Colm, S. 1997. Excerpt from: *Options for Land Security Among Indigenous Communities Ratanakiri, Cambodia.*

Cook, C,C. 1991. *Social analysis in Rural Road Projects. Cernea, M.M. (Ed) Putting People first: Sociological variables in rural development.* (Second edition) World Band.

Global Witness. 2000. *Chainsaws speak louder than words. Global Witness Ltd.* United Kingdom.

Kim, S. 1999. *Brief Introduction to Integrated Community and Natural Resource-based Planning Process (IPP).* IDRC/CARERE, Ratanakiri.

Leonard, R. 1998. *Decentralized Development Planning.* UNCDF.

Nhem, S. 1999. *The CBNRM Project. Steps and Processes.* IDRC/CARERE, Ratanakiri

Nooyens, T. 2000. Discussion notes June, 2001.

PRDC. 2000. *Community Natural Resources Management (CNRM) in Ratanakiri.* Project Document.

UNDP/UNOPS/CAERE. 1998. *Local Planning Process (LPP) Manual.*

Interviews:
Mrs. Kim Srey, E/I-LPP Assistant.
Mr. Ream Rin, LCB Assistant.
Miss. Nut Saman, E/I-LPP Field Assistant
Mr. Kong Bunthan, LCB Assistant
Mr. Nhem Sovanna, Senior. CNRM Technical Advisor
Mr. Tonie Nooyens, Management Advisor

# ជំពូក ១៥ សិក្សា និង ធ្វើការជាមួយគណៈកម្មការសហគមន៍

រៀបរៀងដោយលោក គីម ណុង[1] លោក អ៊ុក លីឃីម[2] និងលោក ឃី អាន[3]

ជំពូកនេះឆ្លុះបញ្ចាំងពីការយល់ឃើញយ៉ាងស៊ីជម្រៅពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍របស់គម្រោ មួយនៅក្នុងបរិបទប្រទេសកម្ពុជា និងពីបទពិសោធន៍នៃការគ្រប់គ្រងធនធានធម្មជាតិជាមួយគណៈកម្មាការសហគមន៍ (VMCs) ជាងនេះទៀត ជំពូកនេះបង្ហាញលទ្ធផលនៃការវិភាគពីលទ្ធភាពការងាររបស់គណៈកម្មការសហគមន៍នៅថ្នាក់ភូមិ និងការចែ រំលែកបទពិសោធន៍ទាំងនោះសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅក្នុងប្រទេសកម្ពុជា ។ ជំពូកនេះ ត្រូវបា រៀបរៀងឡើងដោយផ្អែកលើគម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង (PMMR) ដែលជាគម្រោងសិក្សាស្រាវជ្រា មួយ ហើយកំពុងប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួម ដើម្បីជួយសហគមន៍ដោះស្រាយបញ្ហានានា លើការគ្រប់គ្រងធនធា តំបន់ឆ្នេរ ដូចជា ព្រៃកោងកាង និងមច្ឆាជាតិដែលស្ថិតនៅក្នុងតំបន់ការពារដែនជម្រកសត្វព្រៃពាមក្រសោប (PKWS) ។

## តើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មានន័យដូចម្តេចក្នុងបរិបទនៃប្រទេសកម្ពុជា ?

**ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍** គឺសំដៅលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋា ក្រោមការចូលរួម និងជួយជ្រោមជ្រែងពីភាគីពាក់ព័ន្ធផ្សេងៗ ដែលភាគច្រើនជាមន្ត្រីមកពីស្ថាប័នបច្ចេកទេស ថ្នាក់ខេត្ត និងថ្នា ជាតិ ។ ចំណុចជាគន្លឹះនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ គឺថាសហគមន៍ត្រូវបានរៀបចំ (តាមរយៈដំណើរការមួយ មានឈ្មោះថា ការរៀបចំសហគមន៍) អោយទៅជារចនាសម្ព័ន្ធគ្រប់គ្រងមួយ ពោលគឺការបង្កើតក្រុម ការជ្រើសរើសមេដឹកនាំក្រុ និងគណៈកម្មការសហគមន៍ ។ ជាងនេះទៀត សហគមន៍នីមួយៗត្រូវមានលក្ខន្តិកៈសហគមន៍ ដែលបានទទួលឯកភាពពីអាជ្ញាធ មូលដ្ឋាន និងស្ថាប័នជំនាញពាក់ព័ន្ធ ។

ថ្វីបើត្រូវបានហៅថាការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មែន ប៉ុន្តែការអនុវត្តជាក់ស្តែងមានលក្ខណ ជាសហគ្រប់គ្រង ដែលក្នុងនោះមានការរួមចំណែកទទួលខុសត្រូវរវាងស្ថាប័នរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ហើយដែលស្ថាប័ រដ្ឋាភិបាលជាអ្នកមានតួនាទីដ៏រឹងមាំក្នុងដំណើរការនេះ (Marschke និង Nong, 2003) ។ បើពិនិត្យមើលក្នុងគម្រោងមួយចំនួ សហគមន៍មិនអនុវត្តរាល់កិច្ចការគ្រប់គ្រងទាំងអស់ដោយផ្ទាល់ទេ ប៉ុន្តែធ្វើឡើងតាមរយៈការចូលរួមនៃភ្នាក់ងារផ្សេងៗទៀ ដូចជាអង្គភាពជំនាញ និងរដ្ឋអំណាចមូលដ្ឋាន ដែលមានតួនាទីសំខាន់ណាស់ក្នុងការជម្រុញការអនុវត្តច្បាប់ ដោះស្រាយទំនាស និងបញ្ហាផ្សេងៗទៀត ។ នៅក្នុងប្រទេសកម្ពុជា ដំណើរបែបនេះត្រូវបានឱ្យឈ្មោះថាការគ្រប់គ្រងធនធានធម្មជាតិដោយ

---

[1] លោក គីម ណុង ជាអនុប្រធាននាយកដ្ឋានអប់រំបរិស្ថាននៃក្រសួងបរិស្ថាន និងជាប្រធានដឹកនាំគម្រោង PMMR ។

[2] លោក អ៊ុក លីឃីម ជាទីប្រឹក្សាសេដ្ឋកិច្ចសង្គមនៃគម្រោងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ (ក្រសួងបរិស្ថាន និង DANIDA) ។

[3] លោក ឃី អាន ជាទីប្រឹក្សាខាងផ្នែកគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិនៃកម្មវិធីសិលា ខេត្តកោះកុង ។

សហគមន៍ ។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ថែមទៀតអំពីអត្ថន័យនៃ CBNRM ក្នុងបរិបទនៃប្រទេសកម្ពុជា ប្រការចាំបាច់ គឺត្រូវយល់ឱ្យបានច្បាស់លាស់នូវពាក្យថា **សហគមន៍** និង**ការរៀបចំសហគមន៍** ។

## តើសហគមន៍ជាអ្វី ?

តាមវចនានុក្រមកូលីន (Collins) **សហគមន៍** គឺសំដៅ " *ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងតំបន់ ឬ ទីកន្លែងមួយជាក់លាក់* " ។ ដោយសារភាពមិនចុះសម្រុងគ្នាលើសញ្ញាណនៃសហគមន៍ (ចូរមើលឧទាហរណ៍លើកឡើងដោយ Agrawal & Gibson, 1999) ជាញឹកញាប់អ្នកផ្តល់ជំនួយសន្មតថា សហគមន៍គឺសំដៅលើប្រជាពលរដ្ឋក្នុងភូមិទាំងមូល ។ ផ្ទុយទៅវិញនៅក្នុងប្រទេសកម្ពុជានៅពេលមន្ត្រីរដ្ឋាភិបាល ឬអ្នកភូមិប្រើ ឬ ឮពាក្យ **សហគមន៍** ពួកគាត់ភាគច្រើន គិតថានោះគឺជាមនុស្សមួយក្រុម ដែលត្រូវបានរៀបចំឡើង ឬ បានទទួលការឧបត្ថម្ភពីគម្រោង ឬកម្មវិធីអភិវឌ្ឍន៍នានា ។ ចំពោះអ្នកភូមិដែលពុំជាប់ពាក់ព័ន្ធជាមួយគម្រោង ឬកម្មវិធីអភិវឌ្ឍន៍ ពួកគាត់មិនបានចាត់ទុកខ្លួនថាជាសមាជិកសហគមន៍ឡើយ ។ ដូច្នេះ ពាក្យ**សហគមន៍** នៅក្នុងប្រទេសកម្ពុជា មានន័យថាជាមនុស្សពិសេសមួយក្រុម ដែលមានចំណាប់អារម្មណ៍អនុវត្តការងារអ្វីមួយ ដែលមានការចាត់ចែងជាមួយគ្នា និងមានជំនួយគាំទ្រពីគម្រោង ឬកម្មវិធីអង្គការមិនមែនរដ្ឋាភិបាល ឬ ស្ថាប័នរដ្ឋាភិបាល ។ សហគមន៍មួយចំនួនក្នុងប្រទេសកម្ពុជា ដែលបានបង្កើតកន្លងមកមានជាអាទិ៍ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍កសាងផែនការប្រើប្រាស់ដីធ្លី និងសហគមន៍តំបន់ការពារធម្មជាតិ ។ល ។

## តើការរៀបចំសហគមន៍ជាអ្វី ?

ការរៀបចំសហគមន៍ (CO) គឺជាដំណើរការបង្កើត ឬ ពង្រឹងរចនាសម្ព័ន្ធភូមិ ដែលគេហៅថា គណៈកម្មការសហគមន៍ (VMC) [៤]។ គោលបំណងនៃការរៀបចំសហគមន៍គឺ ពង្រឹងរចនាសម្ព័ន្ធសហគមន៍ដែលមានស្រាប់ ឬបង្កើតរចនាសម្ព័ន្ធថ្មីដើម្បីឱ្យប្រជាពលរដ្ឋបានចូលរួមកាន់តែប្រសើរឡើងក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ ជាងនេះទៀត ការរៀបចំសហគមន៍អាចជួយប្រជាពលរដ្ឋអោយមានសិទ្ធិក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដែលខ្លួនពឹងអាស្រ័យ ។

តាមបទពិសោធន៍គម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង ការរៀបចំសហគមន៍មិនត្រឹមតែជាវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហាប៉ុណ្ណោះទេ តែជាមធ្យោបាយមួយសម្រាប់ជួយបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ពង្រឹងការយល់ដឹងនៅមូលដ្ឋាន និងលើកកម្ពស់គុណភាពបរិស្ថានធម្មជាតិទៀតផង ។ សមត្ថភាពសហគមន៍ត្រូវបានពង្រឹងដើម្បីឱ្យចេះគិតគូរពីតម្រូវការសេដ្ឋកិច្ច នយោបាយ និងសង្គម និងចេះផ្តួចផ្តើមដោះស្រាយទំនាស់ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ ។ នៅកន្លែងជាច្រើនក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ការរៀបចំសហគមន៍គឺជាការបង្កើតឱ្យមានភាពជាអ្នកដឹកនាំសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិដោយប្រើប្រាស់ជំនួយគាំទ្រពីស្ថាប័ននានា ។

[៤] ក្រុមគម្រោង PMMR ហៅរចនាសម្ព័ន្ធនៃការរៀបចំសហគមន៍ថាជា គណៈកម្មការគ្រប់គ្រងភូមិ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនក្នុងប្រទេសកម្ពុជាហៅថា គណៈ

## តើចាំបាច់ត្រូវរៀបចំសហគមន៍សម្រាប់ភូមិទាំងអស់ដែរឬទេ ?

ជំពូកនេះផ្តោតលើបទពិសោធន៍រៀបចំសហគមន៍របស់គម្រោង PMMR ដែលគម្រោងនេះកំពុងជួយបង្កើត គណៈកម្មការគ្រប់គ្រងធនធាន ។ មានភូមិមួយចំនួននៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោបមានអារម្មណ៍ថា ភូមិរបស់គេមាន គណៈកម្មការគ្រប់គ្រងសហគមន៍កំពុងដំណើរការយ៉ាងសកម្មរួចទៅហើយ ហេតុនេះពួកគេពុំចាំបាច់រៀបចំសហគមន៍ ឬ បង្កើត គណៈកម្មការថ្មីទៀតទេ ។ ក្នុងស្ថានភាពបែបនេះ គម្រោង PMMR គ្រាន់តែផ្តល់ការគាំទ្រដល់ថ្នាក់ដឹកនាំភូមិ និងឃុំតាមការស្នើ សុំតែប៉ុណ្ណោះ ដោយគម្រោងពុំមានមុខងារចាំបាច់រៀបចំសហគមន៍ថ្មីឡើយ ។

## ការរៀបចំរចនាសម្ព័ន្ធសហគមន៍

### រចនាសម្ព័ន្ធគណៈកម្មការសហគមន៍ដែលសម្របសម្រួលដោយគម្រោង PMMR

រចនាសម្ព័ន្ធគណៈកម្មការសហគមន៍ពុំមែនជាអង្គភាពផ្លូវការមួយរបស់រដ្ឋាភិបាលទេ ហើយរចនាសម្ព័ន្ធនេះ ត្រូវបាន បង្កើតឡើងតាមរយៈការបោះឆ្នោតក្នុងភូមិ ដោយមានកិច្ចសម្របសម្រួលពីបុគ្គលិកគម្រោង ។ បន្ទាប់ពីបានជ្រើសរើសដោយអ្នក ភូមិរួចមក គណៈកម្មការសហគមន៍នេះត្រូវដឹកនាំដំណើរការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនការពាររបស់សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា ក៏បានបង្កើតគណៈកម្មការមួយចំនួនផងដែរ សម្រាប់ធ្វើការតាមវិស័យនានា ដូចជាគណៈកម្មការ សហគមន៍ថែទាំសុខភាព ថែទាំទំនប់ទឹក ឬគណៈកម្មការបង្កើនផលកសិកម្ម ជាដើម ។

### រចនាសម្ព័ន្ធគ្រប់គ្រងផ្សេងៗទៀត

ចាប់តាំងពីគម្រោង PMMR បានអនុវត្តការងារជាមួយគណៈកម្មការសហគមន៍មក រចនាសម្ព័ន្ធអភិបាលកិច្ចមួយ របស់រដ្ឋាភិបាលត្រូវបានបង្កើតឡើងនៅថ្នាក់ឃុំ ក្រោមរូបភាពជាក្រុមប្រឹក្សាឃុំ-សង្កាត់ ។ អង្គភាពរដ្ឋបាលនៅមូលដ្ឋានរបស់ រដ្ឋាភិបាលនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតសេរីដោយប្រជាពលរដ្ឋនៅក្នុងឃុំនីមួយៗក្នុងប្រទេសកម្ពុជា កាលពីខែ កុម្ភៈ ឆ្នាំ២០០២ ។ នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ការសាកល្បងការងារវិមជ្ឈការបានធ្វើឡើងនៅតាមតំបន់ មួយចំនួននៃខេត្ត-ក្រុងក្នុងប្រទេសកម្ពុជា ដែលនៅតាមខេត្ត-ក្រុងទាំងនោះមានការបង្កើតគណៈកម្មការមួយចំនួននៅថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិសម្រាប់ការងារផ្សេងៗ ដោយរួមបញ្ចូលទាំងការគ្រប់គ្រងធនធានធម្មជាតិផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយ កម្មវិធីនោះពុំត្រូវបានអនុវត្តនៅខេត្តកោះកុងឡើយ រហូតដល់ឆ្នាំ ២០០៣ ពោលគឺក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ទើបមានការសាកល្បងអនុវត្តកម្មវិធីវិមជ្ឈការនៅក្នុងខេត្តកោះកុង ។ អាស្រ័យហេតុនេះ សម្រាប់ខេត្តកោះកុង សកម្មភាពនានា នៅក្នុងកម្មវិធីនេះគឺទើបតែចាប់ផ្តើមជំហានរបស់ខ្លួនតែប៉ុណ្ណោះ ។

គម្រោង PMMR បានគាំទ្រគោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ដែលត្រូវបានស្គាល់ថាជា កម្មវិធីសិលា ហើយបានផ្សារភ្ជាប់ការងារសហគមន៍នៅថ្នាក់ភូមិទៅក្នុងរចនាសម្ព័ន្ធផែនការរបស់ក្រុមប្រឹក្សាឃុំ ដើម្បីជៀសវាង

រូបទី ១ : បង្ហាញទិដ្ឋភាពរួមនៃរចនាសម្ព័ន្ធវិមជ្ឈការនៅប្រទេសកម្ពុជា




*រូបទី ១ : រចនាសម្ព័ន្ធវិមជ្ឈការ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅកម្ពុជា*
*កែសម្រួលពីកម្មវិធីសិលាឆ្នាំ ២០០៤*

## សាវតាតំបន់សិក្សា

នៅក្នុងតំបន់ការពារដែនជម្រកសត្វព្រៃពាមក្រសោប មានស្រុក៣ ឃុំ៦ និងភូមិ១២ ដែលមានចំនួនប្រជាពលរដ្ឋច្រើន ជាង ១០ ០០០ នាក់ (PMMR 2000) ។ សហគមន៍តំបន់ឆ្នេរទាំងនោះពឹងផ្អែកលើធនធានដ៏សម្បូណ៌ ក្នុងតំបន់ការពារដែនជម្រ សត្វព្រៃពាមក្រសោបនេះ ។ អ្នកភូមិភាគច្រើននៅក្នុងតំបន់នេះគឺជាអ្នកចំណាកស្រុកមកពីខេត្ត-ក្រុងផ្សេងៗនៃប្រទេសកម្ពុជ ក្នុងអំឡុងពេលជាង២០ឆ្នាំកន្លងទៅនេះ ដោយសារធនធានតំបន់ឆ្នេរដ៏សម្បូរបែប និងភាពទាក់ទាញនៃផលចំណេញកម្រិតខ្ពស់ ទោះជាយ៉ាងនេះក៏ដោយ សកម្មភាពប្រមូលផលពីធនធានទាំងនោះបានបង្កការគម្រាមកំហែងចំពោះនិរន្តរភាពនៃជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ជាអាទិ៍ ការប្រើប្រាស់ឧបករណ៍នេសាទបែបបំផ្លាញ ការកាប់បំផ្លាញព្រៃកោងកាងសម្រាប់ផលិតធ្យូង និង ការរានឆ្ការយកដីធ្វើស្រះចិញ្ចឹមបង្គាជាដើម ។ ជាងនេះទៀត ទីផ្សារនៅប្រទេសថៃ និងវៀតណាម ក៏ជាកត្តាជម្រុញឱ្យមានសម្ពា លើធនធានតំបន់ឆ្នេរទាំងនេះផងដែរ ។ សកម្មភាពទាំងនោះបានគម្រាមកំហែងយ៉ាងខ្លាំងដល់ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កាលពីអតីតកាល ប្រជាពលរដ្ឋពុំបានចាប់អារម្មណ៍លើកិច្ចការពារធនធានឡើយ ដោយសារតែមានការគ្រប់គ្រងយ៉ាង តឹងរឹងពីមន្ទីរជំនាញ និងមានប្រជាពលរដ្ឋរស់នៅតិចតួចក្នុងតំបន់ឆ្នេរ ។ ប៉ុន្តែ នៅពេលដែលធនធានធម្មជាតិកាន់តែរេចរឹល ហើយ ចំនួនប្រជាពលរដ្ឋកាន់តែកើនឡើង កាលានុវត្តន៍ភាពសម្រាប់ពួកគាត់ក្នុងការទាញយកផលចំណេញពីសកម្មភាពអាជីវកម្មល្មើស ច្បាប់កាន់តែកើនឡើង ជាហេតុធ្វើឱ្យប្រជាពលរដ្ឋបានផ្លាស់ប្តូរគំនិត និងចាប់អារម្មណ៍កាន់តែខ្លាំងលើវិធានការនៃគ្រប់គ្រង និងការពារធនធានធម្មជាតិ ។ អ្នកភូមិទទួលស្គាល់ថា បើចង់ឱ្យកូនចៅរបស់គេមានលទ្ធភាពចិញ្ចឹមជីវិតបានដោយធូរធារពួកគេ ត្រូវធ្វើអ្វីមួយ នៅពេលនេះដើម្បីរក្សាស្ថេរភាពធនធានសម្រាប់ការប្រើប្រាស់នៅពេលអនាគត ។

## គម្រោង PMMR និង ការគ្រប់គ្រងធនធានដោយសហគមន៍

ក្នុងអាណត្តិរបស់ខ្លួន ក្រុមស្រាវជ្រាវនៃគម្រោង PMMR បានចាប់ផ្តើមស្វែងយល់ពីការប្រើប្រាស់ធនធានធម្មជាតិ និង ប្រព័ន្ធគ្រប់គ្រងនៅក្នុងតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប ។ ក្រុមស្រាវជ្រាវនេះបានយកចិត្តទុកដាក់ទៅលើការកសាងទំនុក ចិត្ត និងសមត្ថភាពរបស់អ្នកប្រើប្រាស់ធនធាន អាជ្ញាធរមូលដ្ឋាន មន្ត្រីពីមន្ទីរជំនាញ និងភាគីពាក់ព័ន្ធផ្សេងៗទៀត (មើលរូបទី ២) ។




*រូបទី ២ : រចនាសម្ព័ន្ធពាក់ព័ន្ធរបស់គម្រោងចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង*

ប្រភព : *Marschke and Nong 2003*

គម្រោង PMMR បានរៀបចំសិក្ខាសាលា និងទស្សនកិច្ចសិក្សាមួយចំនួនទាំងនៅក្នុង និងក្រៅប្រទេស សម្រាប់មនុស្ស សំខាន់ៗនៅក្នុងភូមិ អាជ្ញាធរមូលដ្ឋាន និងសមាជិកក្រុមនៃគម្រោងPMMR ។ទិសដៅនៃសិក្ខាសាលា និងដំណើរទស្សនកិច្ចសិក្សា

ទាំងនោះគឺការសិក្សារៀនសូត្រអំពីធនធានតំបន់ឆ្នេរ និងទំនាក់ទំនងរវាងសកម្មភាពប្រកបរបរចិញ្ចឹមជីវិត និងការគ្រប់គ្រ ធនធានធម្មជាតិ ។ ឆ្លងតាមទស្សនកិច្ចសិក្សា និងសិក្ខាសាលាជាច្រើន សមាជិកសហគមន៍បានចាប់អារម្មណ៍ និងមានចិត្តចង់ ការងារជាមួយក្រុមស្រាវជ្រាវរបស់គម្រោង PMMR និងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលដើម្បីកសាងយុទ្ធសាស្ត្រគ្រប់គ្រងធ ធានធម្មជាតិដោយមានការចូលរួមក្នុងដែនការពាររបស់សហគមន៍ពួកគេ ។ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ ជំហានដំបូង គឺកា រៀបចំសហគមន៍ និងជំហានបន្ទាប់មកទៀត គឺការកសាង និងអនុវត្តផែនការសកម្មភាពរបស់សហគមន៍ ។

## ការគិតគូរលើការគ្រប់គ្រងធនធានធម្មជាតិនៅថ្នាក់សហគមន៍

## ដំណើរការកសាងផែនការរៀបចំសហគមន៍

នៅពេលដែលគម្រោង PMMR បានចាប់ផ្តើមដំណើរការរៀបចំសហគមន៍ក្នុងតំបន់ការពារដែនជម្រកសត្វព្រៃពា ក្រសោប កិច្ចប្រជុំជាច្រើនត្រូវបានរៀបចំឡើង ដើម្បីពិភាក្សារិះរកវិធីសាស្ត្ររៀបចំសហគមន៍ ដោយហេតុថា ទាំងក្រុមគម្រោ PMMR និងទាំងអ្នកភូមិពុំមានគំនិត និងបទពិសោធន៍លើដំណើរការរៀបចំសហគមន៍ឡើយ ។

**ប្រអប់ ១ៈ សំនួរសំខាន់ៗមួយចំនួនដែលបានពិចារណាក្នុងការកសាងផែនការរៀបចំសហគមន៍**

- តើអ្នកភូមិមានទស្សនវិស័យ និងគំនិតអ្វីខ្លះ អំពីកិច្ចការពារដែននេសាទរបស់ខ្លួន ?
- តើដែននេសាទដែលបានកំណត់សម្រាប់សហាគ្រប់គ្រង អាចរួចផុតពីការរំខានដោយអ្នកខាងក្រៅដែរឬទេ ?
- តើព្រំប្រទល់តំបន់គ្រប់គ្រងដោយសហគមន៍ គួរកំណត់តាមលំនាំនៃព្រំប្រទល់រដ្ឋបាល ឬតាមស្ថានភាពធម្មជាតិនៃទីតាំងភូមិសាស្ត្រ ?
- តើត្រូវមានជំហានអ្វីខ្លះ ក្នុងការបង្កើតដែននេសាទសហគមន៍ ?
- តើនរណាខ្លះត្រូវចូលរួមក្នុងដំណើរការបង្កើតលក្ខន្តិកៈសហគមន៍ ?
- តើធ្វើដូចម្តេចដើម្បីឱ្យរដ្ឋអំណាចមូលដ្ឋាន និងមន្ទីរជំនាញទទួលស្គាល់លក្ខន្តិកៈសហគមន៍ ?
- តើលក្ខន្តិកៈសហគមន៍មានលក្ខណៈដូចម្តេច ? ឧទាហរណ៍ តើលក្ខន្តិកៈនោះមានចែងពីការផាកពិន័យ ដែរ ឬទេ ?

ក្រុមស្រាវជ្រាវរបស់គម្រោង PMMR ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្តបានពិភាក្សាស្វែងរកយុទ្ធសាស្ត្រ ដែលមានសក្តានុពល សម្រាប់ការរៀបចំសហគមន៍ ។ យោងតាមការពិភាក្សា និងសំណូមពរពីអ្នកភូមិចំពោះក្រុមគម្រោង PMMR ដែលជួយសម្របសម្រួលក្នុងដំណើរការរៀបចំសហគមន៍នេះ ភូមិកោះស្រឡៅ និងភូមិកោះកាង ដែលអ្នកភូមិភាគច្រើនជាអ្នកនេសាទ និងប្រើប្រាស់ឧបករណ៍នេសាទខ្នាតតូច ត្រូវបានជ្រើសរើសមុនគេសម្រាប់អនុវត្តការងាររៀបចំសហគមន៍ ។ មានសំនួរជាច្រើនត្រូវបានចោទឡើង ហើយរាល់សំនួរទាំងនេះបញ្ជាក់ថា ក្រុមស្រាវជ្រាវមិនទាន់បានដឹងច្បាស់ថា តើការងាររៀបចំសហគមន៍គួរអនុវត្ត យ៉ាងដូចម្តេចនៅឡើយទេ។ ចូរពិនិត្យក្នុងប្រអប់១ អំពីសំនួរសំខាន់ៗដែលក្រុមបានលើកមក ពិចារណា ។

ដោយមានកិច្ចសម្របសម្រួលដ៏ល្អពីក្រុមស្រាវជ្រាវ

សហគមន៍ចំនួន៤ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងពេញទំហឹង និងទទួលស្គាល់ជាផ្លូវការ ហើយផែនទីដែននេសា សហគមន៍ និងលក្ខន្តិកៈសហគមន៍ក៏ត្រូវបានទទួលស្គាល់ជាផ្លូវការដោយមានការចុះហត្ថលេខាពីអភិបាលខេត្ត និងរដ្ឋមន្ត្រីក្រសួ បរិស្ថានផងដែរ ។

## សេចក្តីសង្ខេបនៃដំណើរការរៀបចំសហគមន៍

ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលមុនៗ ដែលបានរៀបចំឡើងដោយគម្រោង PMMR និងអង្គការដៃគូផ្សេងៗ អ្នកចូ រួមភាគច្រើនបានស្នើឱ្យបង្កើតគំរូមួយនៃការរៀបចំសហគមន៍សម្រាប់ប្រើប្រាស់នៅទូទាំងប្រទេសកម្ពុជា ។ បន្ទាប់ពីកិច្ចពិភាក្ ក្នុងចំណោមអ្នកចូលរួមដែលមានបទពិសោធន៍លើការរៀបចំសហគមន៍ក្នុងប្រទេសកម្ពុជា មានការសន្និដ្ឋានថា ការបង្កើតគំ មួយសម្រាប់ការរៀបចំសហគមន៍នៅទូទាំងប្រទេសគឺជាការលំបាក ដោយហេតុថា ប្រជាពលរដ្ឋនៅក្នុងតំបន់នីមួយៗមានចំណា អារម្មណ៍ និងមានស្ថានភាពខុសៗគ្នា ។ ទោះបីជាយ៉ាងនេះក៏ដោយ ដំណើរការស្រដៀងគ្នានៃការរៀបចំសហគមន៍ត្រូវបានបង្កើ ឡើងនៅក្នុងតំបន់ដែលមានប្រព័ន្ធអេកូឡូស៊ីខុសគ្នាដូចជា ៖ សហគមន៍នេសាទ តំបន់ឆ្នេរសមុទ្រ តំបន់បឹងទន្លេសាប និងតំបន់ទន្ មេគង្គ ។ ម៉្យាងវិញទៀត ទោះបីជាមានការឯកភាពដំបូងទៅលើយុទ្ធសាស្ត្រដែលអាចបត់បែនបានក្នុងការគ្រប់គ្រងសហគម នេសាទក៏ដោយ ក៏នាយកដ្ឋានជលផលមានបំណងអនុវត្តដំណើរការរៀបចំសហគមន៍ជាជំហានៗនៅទូទាំងប្រទេស ។

ក្នុងប្រទេសកម្ពុជា មានការប្រើប្រាស់វិធីសាស្ត្រជាច្រើនខុសៗគ្នានៅក្នុងដំណើរការរៀបចំសហគមន៍ ទាំងសហគម ព្រៃឈើ និងសហគមន៍នេសាទ អាស្រ័យលើស្ថានភាពភូមិសាស្ត្ររបស់តំបន់ គំនិតរបស់សហគមន៍មូលដ្ឋាន ការគាំទ្រពីរដ្ឋអំណា មូលដ្ឋាន[៥] និងមូលដ្ឋានគំនិតនៃការចូលរួមរបស់ស្ថាប័នស្ថាប័ពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស ។ ជាទូទៅ ក្រុមគម្រោង PMMR បានកត់សម្គាល់ពីការប្រើប្រាស់វិធីសាស្ត្រខុសៗគ្នានៃដំណើរការរៀបចំសហគមន៍ រវាងគម្រោងគាំទ្រដោយអង្គការមិនមែ រដ្ឋាភិបាលក្នុងស្រុក ឬដោយម្ចាស់ជំនួយ និងគម្រោងរបស់ស្ថាប័នរដ្ឋាភិបាល ។ មានវិធីសាស្ត្រខុសៗគ្នាជាច្រើនសម្រាប់រៀប សហគមន៍ តែទោះបីជាគេពុំចាំបាច់អនុវត្តជំហានទាំងនោះតាមលំដាប់លំដោយក្តី ប្រការសំខាន់គឺថា ៖ (១) ភ្នាក់ងារម្នាក់ៗ ដែ សម្របសម្រួលការរៀបចំសហគមន៍យល់ឃើញបែបណាអំពីអត្ថន័យនៃការរៀបចំសហគមន៍ និង(២) តើការរៀបចំសហគម អាចផ្តល់ការគាំទ្របែបណាចំពោះចក្ខុវិស័យរបស់សហគមន៍ និងអាចជួយដោះស្រាយទំនាស់នានាក្នុងសហគមន៍របស់គេផ្ទាល់ តា របៀបណា ។ ការកសាងសមត្ថភាពសហគមន៍មាននាទីជាស្នូល និងជាប្រការចាំបាច់បំផុតនៅក្នុងដំណើរការរៀបចំសហគមន៍ ទីភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ឬ អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវតែមានចំណេះដឹងជ្រៅជ្រះអំពីបញ្ហា និងកត្តានានាដែ មានឥទ្ធិពលលើការចូលរួមរបស់អ្នកភូមិនៅក្នុងដំណើរការរៀបចំសហគមន៍ ។ តារាងទី១ ខាងក្រោមបង្ហាញពីដំណើរការរៀប សហគមន៍នេសាទ ដែលគាំទ្រ និងសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងស្ថាប័នរដ្ឋាភិបាល ។

[៥] រដ្ឋអំណាចមូលដ្ឋាន សំដៅលើអង្គភាពចំណុះក្រសួងមហាផ្ទៃ ដូចជាថ្នាក់អាជ្ញាធរខេត្ត-ក្រុង-ស្រុក ឃុំ-សង្កាត់ និងនគរបាលជាដើម ។

| | សកម្មភាពដែលគាំទ្រដោយអ្នកផ្តល់ជំនួយ[៦] | សកម្មភាពដែលគាំទ្រដោយរដ្ឋាភិបាល |
|---|---|---|
| ១ | **កំណត់ច្បាស់លាស់ពីគោលបំណង និងទីតាំង**<br>⋆ យល់ដឹងពីសាវតាតំបន់ដោយប្រើប្រាស់វិធីសាស្ត្រ វាយតម្លៃជនបទដោយមានការចូលរួមពីសហគមន៍ (PRA)<br>⋆ ជ្រើសរើសតំបន់ និងកំណត់ការងារដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ | **កំណត់ច្បាស់លាស់ពីគោលបំណង និងទីតាំង**<br>⋆ ស្វែងយល់ពីសាវតាតំបន់តាមរយៈការប្រមូលទិន្នន័យដែលមានស្រាប់<br>⋆ ជ្រើសរើសទីតាំង |
| ២ | **ចំណាយពេលវេលាសម្រាប់ពិភាក្សាអំពីការគ្រប់គ្រងធនធាន ធម្មជាតិជាមួយបុគ្គលសំខាន់ៗ**<br>⋆ ប្រើប្រាស់វិធាន PRA/RRA<br>⋆ ដោយមានការចូលរួមពីភាគីនានា ធ្វើការសិក្សាអំពីកិច្ចផ្តួចផ្តើមអេកូឡូស៊ី និងបរិស្ថាន (បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា ដំណើរទស្សនកិច្ចសិក្សាស្តីពីCBNRM)<br>⋆ ការធ្វើសេចក្តីសម្រេចដោយមានការចូលរួម | **គ្មានសកម្មភាព** |
| ៣ | **បង្កើតដំណើរការគ្រប់គ្រងសហគមន៍នេសាទ**<br>⋆ កំណត់គោលបំណងទូទៅ<br>⋆ ស្វែងរកការគាំទ្រពីរដ្ឋអំណាចខេត្ត / មន្ទីរជំនាញពាក់ព័ន្ធ<br>⋆ កំណត់មនុស្សសំខាន់ៗនៅក្នុងភូមិគោលដៅ<br>⋆ រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាទូទៅ<br>⋆ កំណត់តំបន់គោលដៅសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ<br>⋆ បង្កើតសហគមន៍ ពោលគឺរៀបចំបោះឆ្នោតបង្កើតគណៈកម្មការសហគមន៍ ។ | **បង្កើតដំណើរការគ្រប់គ្រងសហគមន៍នេសាទ**<br>⋆ កំណត់គោលបំណងទូទៅ<br>⋆ កំណត់បុគ្គលសំខាន់ៗក្នុងភូមិជាគោលដៅ<br>⋆ បង្កើតសហគមន៍ ពោលគឺ រៀបចំបោះឆ្នោតបង្កើតគណៈកម្មការសហគមន៍ |
| ៤ | **បង្កើតលក្ខន្តិកៈសហគមន៍**<br>⋆ បង្កើតលក្ខន្តិកៈសហគមន៍ពោលគឺធ្វើការជាមួយគណៈកម្មការសហគមន៍ដើម្បីកសាង គោលការណ៍ណែនាំអំពីការគ្រប់គ្រង<br>⋆ ទទួលការឯកភាពពីស្ថាប័នរដ្ឋាភិបាល | **បង្កើតលក្ខន្តិកៈសហគមន៍**<br>⋆ បង្កើតលក្ខន្តិកៈសហគមន៍ពោលគឺបង្កើត គោលការណ៍ណែនាំលើការគ្រប់គ្រង<br>⋆ ទទួលការឯកភាពពីស្ថាប័នរដ្ឋាភិបាល |
| ៥ | **អប់រំ និងការអនុវត្ត**<br>⋆ កំណត់ព្រំប្រទល់<br>⋆ គាំទ្រការងារ( ផ្សព្វផ្សាយអំពីបទបញ្ជានានា និងអនុវត្តបទបញ្ជា)<br>⋆ ត្រួតពិនិត្យ និងវាយតម្លៃដោយការចូលរួម (PME) | **អប់រំ និងការអនុវត្ត**<br>⋆ គ្មានសកម្មភាព |

*តារាង ១ : ជំហានសំខាន់ៗនៃដំណើរការគ្រប់គ្រងសហគមន៍នេសាទ*

*ប្រភព: ឯកសារបណ្តុះបណ្តាលសហគមន៍នេសាទ ខេត្តកំពង់ចាម និងភ្នំពេញ ២០០២ (Oxfam GB / America) WWF; IDRC (PMMR,CFDO)*
បទពិសោធន៍គម្រោង *PMMR*

៦

បច្ចុប្បន្នផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា (ជាពិសេស ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ) មន្ទីរជំនាញទាំងអស់បានទទួលការណែនាំថា ការទទួលខុសត្រូវគ្រប់គ្រងធនធានធម្មជាតិត្រូវរួមបញ្ចូលអ្នកភូមិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកផងដែរ ។ រហូតមកដល់ពាក់កណ្តាលឆ្នាំ ២០០៣ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទបានរៀបចំ :

- សហគមន៍នេសាទចំនួន ៣២៩ ក្នុងនោះសហគមន៍ចំនួន ២០ស្ថិតនៅតាមតំបន់ឆ្នេរ (Thouk, 2004) ។
- សហគមន៍ព្រៃឈើចំនួន ២៣៧ (Mckinney and Tola, 2002) ។
- សហគមន៍តំបន់ការពារធម្មជាតិ ១៧ (ទាំងសហគមន៍ព្រៃឈើ និងនេសាទ) ។

នៅក្នុងចំណោមសហគមន៍ទាំងនេះ សហគមន៍មួយចំនួនមានរចនាសម្ព័ន្ធរឹងមាំលើការងារគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសសហគមន៍ដែលបានទទួលការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល ។ អង្គការមិនមែនរដ្ឋាភិបាលខ្លះបានចំណាយពេលវេលាយ៉ាងច្រើន ដើម្បីធ្វើការងារជាមួយគណៈកម្មការសហគមន៍ និងជួយផ្តល់ការគាំទ្រតាមតម្រូវការចាំបាច់លើការគ្រប់គ្រងធនធានធម្មជាតិ ។ ផ្ទុយទៅវិញ សហគមន៍មូលដ្ឋានដែលបានទទួលការគាំទ្រតែពីស្ថាប័នរដ្ឋាភិបាល ច្រើនតែពុំមានរចនាសម្ព័ន្ធរឹងមាំ និងពុំអាចដំណើរការប្រកបដោយប្រសិទ្ធភាពឡើយ ។ តារាងទី ២ សង្ខេបអំពីលក្ខខណ្ឌអំណោយផល និងមិនអំណោយផលក្នុងការរៀបចំសហគមន៍ ។

| លក្ខខណ្ឌអំណោយផល | លក្ខខណ្ឌមិនអំណោយផល |
|---|---|
| បានកសាងសមត្ថភាព (មានជំនាញ/ចំណេះដឹង និងមានចំណាប់អារម្មណ៍លើការកសាងជំនាញ/ចំណេះដឹង) សម្រាប់សហគមន៍មូលដ្ឋាន ។ | កង្វះសមត្ថភាពនៅក្នុងសហគមន៍ |
| បុគ្គលិករៀបចំសហគមន៍មានជំនាញគ្រប់គ្រាន់ និងប្រើវិធីសាស្ត្រសមស្រប ដើម្បីជួយដល់សហគមន៍មូលដ្ឋាន ។ | មន្ត្រីរដ្ឋាភិបាលខ្វះចំណេះដឹង និងជំនាញអំពីវិធីសាស្ត្រនៃការចូលរួម និងប្រើប្រាស់វិធីសាស្ត្របែប មជ្ឈការ ដែលពុំមានលក្ខណៈសមស្របសម្រាប់អនុវត្ត |
| មានកិច្ចសហប្រតិបត្តិការរឹងមាំរវាងបុគ្គលិករៀបចំសហគមន៍ និងតំណាងអ្នកភូមិក្នុងមូលដ្ឋាន ។ មានឱកាសគ្រប់គ្រាន់សម្រាប់សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីចូលរួមក្នុងការសិក្សាស្រាវជ្រាវ ជាពិសេស ការកសាងផែនការ ការធ្វើសេចក្តីសម្រេច ការត្រួតពិនិត្យ និងវាយតម្លៃ ។ | មានថវិកាពុំគ្រប់គ្រាន់សម្រាប់ជួយដំណើរការរៀបចំសហគមន៍ ។ |
| មានផែនការល្អសម្រាប់ជួយសហគមន៍មូលដ្ឋានលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ផ្ទាល់ ។ | ពុំមានបញ្ជាក់ច្បាស់លាស់ពីការងារអភិរក្ស និងការពារធនធានធម្មជាតិឡើយ ។ |
| មានការគាំទ្រគ្រប់គ្រាន់ខាងហិរញ្ញវត្ថុសម្រាប់ដំណើរការកសាងផែនការរៀបចំសហគមន៍ | |
| ការផ្លាស់ប្តូរយោបល់រវាងសហគមន៍មូលដ្ឋាន និងបុគ្គលិកបម្រើការក្នុងសហគមន៍ | |
| ការគាំទ្រខាងគោលនយោបាយពីរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា លើការរៀបចំសហគមន៍ ។ | |

## សាវតាភូមិគោលដៅរបស់គម្រោង PMMR

ក្រុមគម្រោងPMMR បានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការងាររៀបចំសហគមន៍នៅក្នុងភូមិគោលដៅចំនួន៤ គឺភូមិកោះកាង ភូមិកោះស្រឡៅ និងភូមិកោះកាពិ ដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប និងភូមិជ្រោយប្រស់ស្ថិតនៅក្រៅដែនជម្រកសត្វព្រៃពាមក្រសោប ។ ភូមិទាំងនេះសម្បូណ៌ទៅដោយព្រៃកោងកាងនៅព័ទ្ធជុំវិញ ។ ភូមិកោះកាង និងភូមិកោះស្រឡៅ គឺជាគោលដៅដំបូងនៃគម្រោងPMMR សម្រាប់ការងារគ្រប់គ្រងធនធានដោយសហគមន៍ ដោយសារភូមិទាំងពីរ នេះពឹងផ្អែកលើធនធានព្រៃកោងកាងច្រើនជាងគេបើប្រៀបធៀបជាមួយនឹងភូមិដទៃទៀត និងបានបង្ហាញពីបំណងចូលរួមនៅក្នុងការងារគម្រោង (សូមអានជំពូក១៦) ។




*ផែនទី ១: ទីតាំងគម្រោង*

ភូមិទាំងនេះទទួលរងសម្ពាធពីក្រុមចំណាកស្រុកមកពីខេត្តផ្សេងៗ ដែលអ្នកទាំងនោះស្ទើរតែទាំងអស់គឺ ជាអតីតអ្នកកាប់ព្រៃកោងកាងដើម្បីផលិតធ្យូង ឬជាពលករ ។

**ភូមិកោះស្រឡៅ** គឺជាភូមិនេសាទបុរាណមួយ ។ អ្នកភូមិដែលរស់នៅក្នុងភូមិនេះយូរមកហើយបានហៅខ្លួនឯងថាថៃ កោះកុង ដោយហេតុថាអ្នកទាំងនោះដែលមានវ័យចាស់ចេះនិយាយភាសាថៃផងដែរ ។ ក្នុងសម័យខ្មែរក្រហម អ្នកភូមិជាច្រើននាក់បានភៀសខ្លួនទៅរស់នៅក្នុងប្រទេសថៃ ដោយមានអ្នកភូមិដើមមួយចំនួនតូចប៉ុណ្ណោះបានវិលត្រឡប់មករស់នៅក្នុងភូមិនេះវិញនៅទសវត្សរ៍ឆ្នាំ ១៩៨០ ។ ភាគច្រើននៃអ្នកភូមិនេះគឺជាអ្នកចំនូលថ្មីនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងបំណងរកប្រាក់ដោយការកាប់ព្រៃកោងកាង ហើយអ្នកទាំងនោះភាគច្រើនបានបន្តរស់នៅក្នុងភូមិរហូតដល់បច្ចុប្បន្ន និងបានកែប្រែមុខរបរទៅធ្វើនេសាទវិញ ។

**ភូមិកោះកាង** គឺជាភូមិស្ថិតនៅលើកូនកោះតូចមួយដែលគ្មានប្រជាជនរស់នៅឡើយកាលពីមុនទសវត្សរ៍ឆ្នាំ ១៩៨០ តែជាកន្លែងដុតធ្យូង និង ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ មកត្រូវបានប្រែក្លាយជាកន្លែងចិញ្ចឹមបង្គា ។ ឡធ្យូង និងកសិដ្ឋានចិញ្ចឹមបង្គាស្ទើរតែទាំងអស់កាន់កាប់ដោយឈ្មួញកណ្តាលមកពីទីរួមខេត្តកោះកុង ។ ភាគច្រើននៃអ្នកចំណាកស្រុកមកដល់ភូមិនេះដំបូងគឺជាអ្នកលក់កម្លាំងពលកម្មទៅឱ្យម្ចាស់ឡធ្យូង ឬកសិដ្ឋានបង្គា ។ នៅឆ្នាំ១៩៩៨ មន្ទីរបរិស្ថានខេត្តបានបំផ្លាញឡធ្យូងទាំងនោះ ហើយទន្ទឹមនឹងនោះ ការចិញ្ចឹមបង្គាក៏ដួលរលំផងដែរ ។ អ្នកចំណាកស្រុកមួយចំនួនតូចបានវិលត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញ ប៉ុន្តែពួកគេភាគច្រើនបន្តស្នាក់នៅលើកោះនេះ ដោយប្តូរមុខរបរទៅនេសាទវិញ ។

**ភូមិកោះកាពិ** គឺជាកោះមួយដែលអង្គភាពរដ្ឋបាលឃុំតាំងនៅ ។ អ្នកភូមិមួយចំនួនដែលរស់នៅទីនេះ គឺជាមន្ត្រីរដ្ឋាភិបាលថ្នាក់ស្រុក ហើយប្រជាជនមួយចំនួនទៀតគឺជាអ្នកនេសាទប្រើប្រាស់ទូកឌុន និងឈិប (ខ្នាតមធ្យម) ។ ភាពតានតឹងបានកើតឡើងរវាងអ្នកនេសាទទាំងនេះ និងអ្នកនេសាទដែលប្រើប្រាស់ឧបករណ៍ខ្នាតតូចមកពីភូមិកោះស្រឡៅ និងភូមិជ្រោយប្រស់ ជាពិសេស ទំនាស់តំបន់នេសាទក្នុងឈូងជ្រោយប្រស់ ។

**ភូមិជ្រោយប្រស់** គឺជាភូមិស្ថិតនៅក្រៅដែនជម្រកសត្វព្រៃពាមក្រសោប និងជាភូមិនេសាទដ៏សំខាន់មួយដែលស្ថិតនៅជិតភូមិកោះស្រឡៅ ។ ភាគច្រើននៃអ្នកភូមិជ្រោយប្រស់នេសាទក្នុងឈូងជ្រោយប្រស់ ដោយសារឈូងនេះមានមុខងារយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ។ នៅឆ្នាំ ២០០១ បន្ទាប់ពីគម្រោង PMMR បានដំណើរការនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប អ្នកនេសាទក្នុងឃុំជ្រោយប្រស់បានស្នើសុំក្រុមគម្រោង PMMR ជួយរៀបចំសហគមន៍ ដើម្បីគ្រប់គ្រងធនធានជលផលក្នុងឈូងជ្រោយប្រស់ឱ្យមាននិរន្តរភាព ។

## តើគណៈកម្មការគ្រប់គ្រងសហគមន៍ទាំងនេះបានបង្កើតឡើងដូចម្តេច ?

ទោះបីក្រុមគម្រោងបានធ្វើការជាមួយសហគមន៍ទាំងអស់នេះចាប់តាំងពីចុងឆ្នាំ១៩៩៧ក៏ដោយ ដំណើររៀបចំសហគម លើកដំបូងទើបបានចាប់ផ្តើមនៅឆ្នាំ២០០០ នៅក្នុងភូមិកោះស្រឡៅ និងភូមិកោះកាង ។ ដំណើរការនេះបានចាប់ផ្តើមឡើ ដោយមានការប្រជុំ និងការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមួយចំនួន ជាមួយអ្នកភូមិសំខាន់ៗដើម្បីណែនាំអំពីទស្សនវិស័យ ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (CBNRM) បញ្ហានៃការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងដើម្បីពិភាក្សាអំ លទ្ធភាពបង្កើតសហគ្រប់គ្រងជលផលនៅក្នុងតំបន់ ។ បន្ទាប់ពីទទួលការបណ្តុះបណ្តាល អ្នកភូមិសំខាន់ៗបានជ្រើសរើ (១២នាក់ក្នុងភូមិកោះកាង និង២៥នាក់ក្នុងភូមិកោះស្រឡៅ) ហើយបន្ទាប់មក គណៈកម្មការគ្រប់គ្រងភូមិបណ្តោះអាសន្នត្រូវបា ជ្រើសរើសចេញពីចំណោមអ្នកភូមិសំខាន់ៗទាំងនោះ (បីនាក់ក្នុងភូមិនីមួយៗ) ។ គោលបំណងចម្បងនៃការបង្កើតគណៈកម្មការភូ បណ្តោះអាសន្ននេះគឺដើម្បីធ្វើការជាមួយក្រុមគម្រោង PMMR ក្នុងការធ្វើទំនាក់ទំនងជាមួយអ្នកភូមិ និងបង្កើតលក្ខន្តិក សហគមន៍ (អ្នកភូមិបានបង្កើតគោលការណ៍គ្រប់គ្រងធនធាននៅថ្នាក់មូលដ្ឋាន) ។ ដោយមានការចូលរួមសម្របសម្រួលពីក្រុ គម្រោង PMMR ភូមិនីមួយៗបានរៀបចំបង្កើតលក្ខន្តិកៈសហគមន៍ ហើយបន្ទាប់មកអ្នកភូមិបានចូលរួមបោះឆ្នោតជ្រើសរើ គណៈកម្មការសហគមន៍របស់ពួកគេ ។ គណៈកម្មការសហគមន៍កោះកាងមានសមាជិកចំនួន ៣នាក់ និងកោះស្រឡៅមានសមាជិ ៧ នាក់ ។

ការបង្កើតគណៈកម្មការសហគមន៍ក្នុងភូមិជ្រោយប្រស់ និងភូមិកោះកាពិមានលក្ខណៈប្លែកបន្តិច ពោលគឺពុំមា ការបង្កើតគណៈកម្មការភូមិបណ្តោះអាសន្នទេ ។ សេចក្តីព្រាងលក្ខន្តិកៈសហគមន៍បានធ្វើឡើងតាមរយៈសិក្ខាសាលាជាច្រើន និ

## សកម្មភាពចម្បងៗរបស់គណៈកម្មការសហគមន៍

បន្ទាប់ពីបានជ្រើសរើសគណៈកម្មការសហគមន៍រួចហើយ សមាជិកគណៈកម្មការនេះបានកសាងផែនការសក ភាពសម្រាប់គ្រប់គ្រងធនធានជលផល សម្រាប់ដោះស្រាយបញ្ហានៃការចិញ្ចឹមជីវិត ក្រោមការជួយសម្របសម្រួល និងឧបត្ថ គាំទ្រពីក្រុមការងារគម្រោង PMMR ។ ផែនការសកម្មភាពរបស់សហគមន៍រួមមាន:

**ទប់ស្កាត់ និងរារាំងសកម្មភាពខុសច្បាប់ :** កិច្ចការពារធនធានធម្មជាតិត្រូវដោះស្រាយតាមរយៈការបង្កើតឱ្យមានប្រព័ន្ធយាមល្បាត និងប៉ុស្តិ៍ត្រួតពិនិត្យសមស្រប ។ នៅតាមសហគមន៍មួយចំនួន ភារកិច្ចយាមល្បាតត្រូវបានប្តូរវេនគ្នាក្នុងចំណោមសមាជិកទាំងអស់ក្នុងសហគមន៍មូលដ្ឋាន (សហគមន៍កោះកាង) ប៉ុន្តែនៅតាមសហគមន៍ផ្សេងៗទៀត ការយាមល្បាតគឺជាការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍តែប៉ុណ្ណោះ ដោយមានមន្ត្រីការិយាល័យជលផល និងប៉ូលីសជួយជ្រោមជ្រែងក្នុងសកម្មភាពយាមល្បាតទាំងនោះផងដែរ ។

**ការដាំដើមកោងកាងឡើងវិញ :** ការដាំដើមកោងកាងឡើងវិញធ្វើឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៣ ហើយបច្ចុប្បន្ន ផ្ទៃដីរេចរឹលទំហំជាង ៧០ហិកតា ក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ជាដំណុះថ្មីនៃព្រៃកោងកាង ។ គណៈកម្មការសហគមន៍បានដឹកនាំសកម្មភាពដាំដើមកោងកាងឡើងវិញ នៅក្នុងភូមិកោះកាង និងភូមិកោះស្រឡៅ ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកភូមិ ។ ចាប់តាំងពីឆ្នាំ១៩៩៨ ស្ថានភាពព្រៃកោងកាងក្នុងដែនជម្រកសត្វព្រៃពាមក្រសោបមានភាពល្អប្រសើរឡើងវិញ ដោយសារការដុះឡើងវិញតាមធម្មជាតិ និងការដាំរបស់ប្រជាពលរដ្ឋ ។

**សួនបន្លែតាមលំនៅដ្ឋាន :** សួនបន្លែតូចៗជាលក្ខណៈគ្រួសារត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយការចំណាយប្រចាំគ្រួសារលើគ្រឿងទេស និងបន្លែ ។ គម្រោង PMMR បានសហការ និងផ្តល់ការគាំទ្រដល់អ្នកភូមិមួយចំនួនដើម្បីដាំបន្លែជាលក្ខណៈគ្រួសារនេះ ។ គម្រោងខ្នាតតូចសម្រាប់ទ្រទ្រង់ជីវភាពរស់នៅបែបនេះបានជម្រុញសហគមន៍ ឱ្យចេះគិតគូរបន្ថែមទៀតពីការរកប្រាក់ចំណូល និងក្លាយជាគ្រួសារដែលអាចផ្គត់ផ្គង់ខ្លួនឯងបាន ។

**បទបញ្ជាផ្ទៃក្នុងសហគមន៍[៧] :** ដើម្បីកាត់បន្ថយបញ្ហាលួចឧបករណ៍នេសាទ គណៈកម្មការសហគមន៍ កោះកាង និងភូមិកោះស្រឡៅ បានបង្កើតបទបញ្ជាផ្ទៃក្នុងសហគមន៍សម្រាប់អនុវត្តក្នុងសហគមន៍របស់ពួកគេ ។ លបក្តាមត្រូវបានលាបពណ៌ផ្សេងៗ ទៅតាមក្រុមអ្នកនេសាទ ។ ការលាបពណ៌បែបនេះធ្វើឱ្យជនល្មើសមានការ លំបាកប្រើប្រាស់ឧបករណ៍ ដែលគេបានលួច ។

**ការផ្គត់ផ្គង់ទឹកស្អាត:** ភូមិកោះកាងព័ទ្ធជុំវិញដោយទឹកប្រៃ ហើយពេលខ្លះត្រូវលិចដោយទឹកជោរឡើងខ្ពស់ ជាពិសេសចាប់ពីខែវិច្ឆិកា ដល់ខែមករា ។ នៅលើកោះនេះពុំមានប្រភពទឹកសាបទេ ។ ដោយមានការជួយឧបត្ថម្ភពីគម្រោង PMMR និងគម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ (CZM) គណៈកម្មការគ្រប់គ្រងទឹកស្អាតបានបង្កើតឡើង ដែលមានភារកិច្ចគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាត និងបង្កើតបទបញ្ជាសហគមន៍មួយ ដើម្បីបន្ថយថ្លៃទឹក ។

[៧] បទបញ្ជាសហគមន៍គឺជាបទបញ្ញត្តិមួយបែបដែលសហគមន៍បង្កើតឡើងដោយមិនចាំបាច់ស្វែងរកការឯកភាព ប្រកាសលេខាគាំទ្រពីអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋាភិបាល

**ការគ្រប់គ្រងសំណល់ :** ដោយមានការជួយឧបត្ថម្ភពីគម្រោង PMMR និងគណៈកម្មការសហគមន៍ អ្នកភូមិកោះកាង និង កោះស្រឡៅធ្វើការសំអាតភូមិរបស់ពួកគាត់ ក្នុងមួយខែម្តងដោយមានការចូលរួម ពីសិស្សសាលា ។

**តំបន់ការពាររបស់សហគមន៍:** ការពិភាក្សាក្រៅផ្លូវការជាមួយគណៈកម្មការ សហគមន៍ទាំង បីបានបង្ហាញពីតម្រូវការដោះស្រាយទំនាស់រវាងប្រជានេសាទដែលប្រើប្រាស់ឧបករណ៍ នេសាទខុសៗគ្នានៅក្នុងតំបន់នោះ ការពារតំបន់អភិរក្សស្មៅសមុទ្រ កូនត្រីតុកកែតូចៗ និង ដើម្បីលើកកំពស់ជីវភាពរស់នៅរបស់ប្រជានេសាទ ។ នៅខែមិថុនា ឆ្នាំ២០០២ លក្ខខណ្ឌមួយ ចំនួន ត្រូវបានបង្កើតឡើងតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងអង្គសិក្ខាសាលា មួយដើម្បីបង្កើតតំបន់ការពារ ការវាយតម្លៃលទ្ធផលនៃការងារអភិរក្ស និងការពិចារណា ជំហានបន្តបន្ទាប់ទៀត ។ តំបន់ការពារតូចមួយត្រូវបានបង្កើតឡើងនៅឈូងជ្រោយប្រស់ ដើម្បីការពារកូនត្រីតុកកែពីការបំផ្លិចបំផ្លាញដោយការប្រើប្រាស់ឈឺបរុញ អួនហ៊ុំ និងឈឺប យន្ត ។ នៅពេលនោះ សហគមន៍នានាបានយល់ឃើញថា វិធីនេសាទទាំងនេះបានបង្កផលប៉ះ ពាល់យូរអង្វែងចំពោះប្រព័ន្ធអេកូឡូស៊ី និងធនធាននានានៅក្នុងប្រព័ន្ធនោះ ។

## លក្ខណៈខុសគ្នារវាងគណៈកម្មការសហគមន៍ទាំងបួន

ថ្វីបើគណៈកម្មការសហគមន៍នីមួយៗបង្កើតឡើង ក្រោមការសម្របសម្រួលពីគម្រោង PMMR ក៏ដោយប៉ុន្តែរចន សម្ព័ន្ធ និងរបៀបរបបការងាររបស់គណៈកម្មការសហគមន៍ទាំងនោះមានលក្ខណៈខុសៗគ្នា ។ នេះដោយសារភូមិនីមួយៗបានធ្វើ សេចក្តីសម្រេចដោយខ្លួនគេផ្ទាល់ ពីរបៀបចាត់ចែងគណៈកម្មការរបស់ពួកគេ ឱ្យស្របទៅតាមក្របខ័ណ្ឌទូទៅនៃការគ្រប់គ្រង ធនធានធម្មជាតិ ។

## រចនាសម្ព័ន្ធគ្រប់គ្រង

ចំនួនសមាជិកគណៈកម្មការសហគមន៍ខុសគ្នាពីសហគមន៍មួយទៅសហគមន៍មួយទៀត អាស្រ័យទៅតាមការសម្រេច របស់សហគមន៍នីមួយៗពីតម្រូវការចំនួនមនុស្សសម្រាប់ធ្វើការងារគ្រប់គ្រងធនធានធម្មជាតិ ។ ទោះបីអ្នកសម្របសម្រួល ពុំបានផ្តល់ការណែនាំឱ្យមានតំណាងនារីនៅក្នុងសមាសភាពរបស់គណៈកម្មការសហគមន៍ក្តី សហគមន៍នីមួយៗ មានតំណាង នារីមួយរូប ។

ក្នុងអំឡុងពេលមួយឆ្នាំក្រោយមក និងបន្ទាប់ពីមានសំណើពីសមាជិកសហគមន៍ ចំនួនសមាជិកគណៈកម្មការសហគមន៍កោះកាងបានកើនឡើងរហូតដល់៧នាក់ និងកោះស្រឡៅ៩នាក់ ។ រយៈពេលមួយឆ្នាំក្រោយមកគណៈកម្មការសហគមន៍ជ្រោយប្រស់បានបង្កើតឡើង និងមួយឆ្នាំក្រោយមកទៀត គណៈ-កម្មការភូមិកោះកាពិ ក៏ត្រូវបានបង្កើតឡើងផងដែរ ។ អ្នកភូមិទាំងពីរនេះបានសិក្សាស្វែងយល់ពីដំណើរការការងាររបស់គណៈកម្មការសហគមន៍កោះកាង និង កោះស្រឡៅ និងមានបំណងបង្កើតគណៈកម្មការសហគមន៍របស់ខ្លួន ឱ្យមាន

| សហគមន៍ | ចំនួនសមាជិកសហគមន៍ដែលបានជាប់ឆ្នោត |
|---|---|
| កោះកាង | ៣ |
| កោះស្រឡៅ | ៧ |
| ជ្រោយប្រស់ | ៧ |
| កោះកាពិ | ៧ |

## របៀបរបបការងាររបស់គណៈកម្មការសហគមន៍[៨]

□ **កោះកាង :** ប្រធានគណៈកម្មការសហគមន៍ភូមិកោះកាងគឺជាអនុប្រធានភូមិកោះកាង ។ ដូច្នេះ គាត់មានឱកាសបំពេញការងារជាច្រើ
ជាមួយអ្នកភូមិ ហេតុនេះគាត់មានការងាយស្រួលក្នុងការប្រមូលអ្នកភូមិឱ្យចូលរួមក្នុងសកម្មភាពនានារបស់សហគមន៍ ។ ជាងនេះទៀ
សមាជិកគណៈកម្មការ សហគមន៍សាមគ្គីគ្នាបានល្អ ជាក់ស្តែងពួកគាត់បានរួមគ្នាបង្កើតបទបញ្ជាសហគមន៍សម្រាប់គ្រប់គ្រងទឹកស្អាត និងពេលខ្ល
ពួកគាត់ចូលរួមទទួលខុសត្រូវលើការងារយាមល្បាត ។ ចំណុចខ្សោយនៃគណៈកម្មការសហគមន៍នេះ គឺការអនុវត្តវិធីសាស្ត្រការងារតាមបែប
មជ្ឈការ ពីព្រោះប្រធានគណៈកម្មការ មិនចែករំលែកការទទួលខុសត្រូវលើការធ្វើសេចក្តីសម្រេច និងការងារសំខាន់ៗឡើយ ។ ករណីបែបនេ
បានកើតឡើងពាក់ព័ន្ធនឹងការបែងចែកអង្ករទៅឱ្យអ្នកភូមិ ដែលប្រធានគណៈកម្មការសហគមន៍បានស្នើឱ្យសមាជិកគណៈកម្មការសហគមន៍
ពន្យាពេលចែកអង្ករ រហូតដល់ពេលដែលគាត់ត្រលប់មកពីនេសាទវិញ ។

□ **កោះស្រឡៅ :** បើប្រៀបធៀបនឹងភូមិដទៃទៀត គណៈកម្មការគ្រប់គ្រងភូមិកោះស្រឡៅគឺមានភាពរឹងមាំ ។ ពួកគាត់បានធ្វើការប្តេជ្ញាខ្ពស
ហើយ ប្រធានគណៈកម្មការសហគមន៍តែងផ្តល់សិទ្ធិ ដល់សមាជិករបស់គាត់ក្នុងការសម្រេចការងារដោយខ្លួនឯង ។ ជាងនេះទៅទៀត សមាជិ
ពីររូបក្នុងចំណោមសមាជិកសកម្មទាំងអស់ជាស្ត្រី ។ ប្រធានគណៈកម្មការសហគមន៍គឺជាឈ្មួញកណ្តាល ដែលបានមករស់នៅក្នុងភូមិនេះតាំងពី
ដើមទសវត្សរ៍ ឆ្នាំ១៩៩០ ដែលបានប្រែក្លាយខ្លួនពីពលករចំណាកស្រុកទៅជាឈ្មួញកណ្តាល ។ អ្នកភូមិភាគច្រើននិយាយថាគាត់ ជាមនុស្សចិត្តល្
និងចេះជួយយកអាសារអ្នកដទៃ ។ គាត់មិនត្រឹមតែជាប្រធានគណៈកម្មការសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែជាអនុប្រធានក្រុមប្រឹក្សាឃុំ និងជ
ប្រធានគណៈកម្មការវត្ត កោះស្រឡៅទៀតផង ។ គណៈកម្មការសហគមន៍មានសមត្ថភាពដោះស្រាយបញ្ហាផ្ទៃក្នុងរបស់គណៈកម្មការតាមរយ
ការសម្របសម្រួលការប្រាស្រ័យទាក់ទង និងការពិភាក្សា ។ ក្រោមការដឹកនាំរបស់គណៈកម្មការសហគមន៍ ភាគច្រើននៃសកម្មភាពរបស
សហគមន៍បានរីកចម្រើនលូតលាស់គួរជាទីមោទនៈ ។ សមាជិកគណៈកម្មការសហគមន៍បានកំណត់ពេលប្រជុំជាទៀងទាត់ ហើយជាញឹក
ញាប់អ្នកទាំងនោះអាចសម្របសម្រួលកិច្ចពិភាក្សាដោយខ្លួនឯង ។ លើសពីនេះ ការប្រជុំពិសេសខ្លះៗត្រូវបានរៀបចំឡើងទៅតាមការចាំបាច់
គំនិតផ្តួចផ្តើមភាគច្រើនកើតចេញពីគណៈកម្មការគ្រប់គ្រងភូមិ គឺពុំមែនមកពីអ្នកខាងក្រៅឡើយ ។ ឧទាហរណ៍ : គណៈកម្មការបានបង្កើតប
បញ្ជាសហគមន៍ សម្រាប់គ្រប់គ្រងដែនការពារធនធានរបស់សហគមន៍ (តំបន់ការពារស្មៅសមុទ្រ) និងគ្រប់គ្រងសំណល់ក្នុងភូមិរបស់ពួកគេ
ដោយមានការគាំទ្រពីសមាជិកសហគមន៍ ។

□ **ជ្រោយប្រស់ :** គណៈកម្មការសហគមន៍ជ្រោយប្រស់មានភាពខុសប្លែកគ្នាពីគណៈកម្មការសហគមន៍ដទៃទៀត ដោយសារសមាជិកទាំ
ប្រាំពីររូប គឺជាប្រជានេសាទដែលធ្លាប់បំផុសអ្នកនេសាទក្នុងសហគមន៍ឱ្យធ្វើការប្រឆាំងនឹងសកម្មភាពល្មើសច្បាប់ក្នុងតំបន់នេសាទរបស់គេ
គ្មានសមាជិកណាម្នាក់មកពីរដ្ឋអំណាចមូលដ្ឋាន ឬជាឈ្មួញកណ្តាលទេ ។ គណៈកម្មការនេះមិនសូវអនុវត្តការងារបានរលូនឡើយ ពាក់ព័ន្ធនឹងកា
បែងចែកការទទួលខុសត្រូវ ប៉ុន្តែបញ្ហានេះទំនងជាកើតឡើងដោយសារតែគណៈកម្មការនេះទើបតែបង្កើតថ្មី ហើយសមាជិកគណៈកម្មកា
សហគមន៍ពុំមានបទពិសោធន៍ គ្រប់គ្រាន់លើទស្សនវិស័យនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។ សមាជិកគណៈកម្មការសហគមន៍
និងសមាជិកសហគមន៍ស្ទើរតែទាំងអស់ជាអ្នកនេសាទខ្នាតតូច ហើយមានបំណងចង់លុបបំបាត់សកម្មភាពខុសច្បាប់ទាំងឡាយអោយបានឆាប
បំផុត ។ ដោយសារមានបំណងដោះស្រាយ បញ្ហាចម្បងៗឱ្យបានរហ័សតែពុំបានសម្រេចនោះ ជាញឹកញាប់គណៈកម្មការសហគមន៍នេះបានធ្វើឱ
សមាជិករបស់ខ្លួនបាក់ទឹកចិត្ត ។ តែទោះជាយ៉ាងនេះក្តី សមាជិកគណៈកម្មការសហគមន៍ត្រូវការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការងា
ប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាដៃគូរបស់ខ្លួន ជាពិសេសជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញ ។ បន្ទាប់មក
ស្ថានការណ៍នៃការគ្រប់គ្រងមានភាពប្រសើរឡើងដោយសារមានការជួយជ្រោមជ្រែងពីក្រុម PMMR និងពីសមាជិកខ្លះនៃគណៈកម្មកា
សហគមន៍កោះស្រឡៅ ។ នៅពេលបច្ចុប្បន្ន គណៈកម្មការសហគមន៍ជ្រោយប្រស់ទទួលបានការជ្រោមជ្រែងពីមេឃុំជ្រោយប្រស់ និងប៉ូលីស
មូលដ្ឋាននៅពេលពួកគាត់ចុះល្បាតម្តងៗ ។

□ **កោះកាពិ :** គណៈកម្មការគ្រប់គ្រងភូមិកោះកាពិទើបតែត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ ហើយពុំទាន់មានសកម្មភាពខ្លាំងក្លានៅឡើយ
ទេ លើកលែងតែការដាំដើមកោងកាងឡើងវិញ និងការប្រជុំផ្សេងៗ ដែលមានការជួយគាំទ្រពីគម្រោង PMMR ។

## ការលំបាកលើការគ្រប់គ្រងធនធាន

សមាជិកគណៈកម្មការសហគមន៍មួយចំនួនបានក្លាយជាសមាជិកគណបក្សនយោបាយនៅថ្នាក់មូលដ្ឋាន ។ សមាជិកខ្លះ បានចូលរួមយុទ្ធនាការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២ និងសភាជាតិ ឆ្នាំ២០០៣ ។ គណបក្សនយោបាយបានធ្វើឱ្យ គណៈកម្មការគ្រប់គ្រងភូមិ និងអ្នកភូមិបាត់ទំនុកចិត្តលើគ្នាទៅវិញទៅមកក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាព ផ្សេងៗទៀតនៃការអភិវឌ្ឍភូមិ ។

បញ្ហាខ្លះបានកើតឡើងក្នុងសហគមន៍ដោយសារតែកង្វះការប្រាស្រ័យទាក់ទង ។ សកម្មភាពល្មើសច្បាប់នានាដែលគាំទ្រ ដោយអ្នកមានអំណាចអាចនាំមកនូវការលំបាកដល់ការកសាងទំនាក់ទំនងជិតស្និទ្ធរវាងគណៈកម្មការសហគមន៍ និងភាគីពាក់ព័ន្ធ ជាពិសេសកងកម្លាំងប្រដាប់អាវុធ (ប៉ូលីស និងកងនាវាចរ) នៅក្នុងតំបន់ ។

គណៈកម្មការនេះពុំសុទ្ធតែមានជំនាញប្រាស្រ័យទាក់ទង ឬជំនាញចរចាដើម្បីបង្កើតទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធ ដទៃទៀតនៅឡើយទេ ។ សមាជិកគណៈកម្មការភាគច្រើនបានត្អូញត្អែរថា រដ្ឋអំណាចមូលដ្ឋានមិនបានយកចិត្តទុកដាក់ឱ្យបាន ច្រើនលើការគ្រប់គ្រងធនធានឡើយ ផ្ទុយទៅវិញពួកគេគាំទ្រសកម្មភាពល្មើសច្បាប់ ។ ហេតុដូច្នេះ គណៈកម្មការសហគមន៍មិន សូវទទួលបានការគាំទ្រពេញលេញពីអ្នកភូមិឡើយ ដែលអ្នកភូមិមួយចំនួនយល់ឃើញថាជាគណបក្សនយោបាយ ជាងទទួល ស្គាល់ថា ជាការយកចិត្តទុកដាក់របស់ពួកគេលើធនធានធម្មជាតិ ហើយជាញឹកញាប់ គណៈកម្មការសហគមន៍ជួបប្រទះការលំបាក ក្នុងការអនុវត្តសកម្មភាពមួយចំនួន ។

ទោះបីជាសកម្មភាពសំខាន់ៗរបស់គណៈកម្មការសហគមន៍កំពុងមានការរីកចម្រើនក៏ដោយ ការគ្រប់គ្រងធនធានតំបន់ ឆ្នេរពុំមានការចូលរួមឱ្យបានពេញលេញពីអ្នកភូមិ ឬស្ថាប័ននៅមូលដ្ឋានទាំងអស់ឡើយ ។ ភាពក្រីក្ររបស់ប្រជាពលរដ្ឋ មូលដ្ឋាននៅក្នុងតំបន់នេះគឺជាបញ្ហាជាគន្លឹះ ហើយប្រជាពលរដ្ឋភាគច្រើនដែលជាអ្នកនេសាទតូចតាចគឺជាអ្នកទទួលសំពាធ ជាច្រើន ។ អ្នកនេសាទភាគច្រើននៅក្នុងតំបន់នេះមានលទ្ធភាពធ្វើនេសាទនៅតំបន់ទឹករាក់ប៉ុណ្ណោះ ហើយការធ្វើនេសាទរបស់ពួក គេជួបប្រទះនឹងការលំបាកនៅរដូវវស្សា ពោលគឺនៅពេលចរន្តទឹកសាបហូរចូលកាន់តែច្រើន ត្រីភៀសខ្លួនទៅជ្រកក្នុងទឹកជ្រៅ ហើយនៅពេលនោះ ប្រជានេសាទត្រូវតែប្រកួតប្រជែងជាមួយនឹងទូកនេសាទមកពីខាងក្រៅ ។ ដូចនេះ គណៈកម្មការសហគមន៍ និងប្រជានេសាទស្នើក្រុមស្រាវជ្រាវរបស់គម្រោង PMMR ឱ្យបន្តជួយពួកគេរហូតដល់នយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល កម្ពុជាមានភាពរឹងមាំ ។

## ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈកម្មការសហគមន៍ និងមន្ទីរជំនាញដទៃទៀត

ក្រុមប្រឹក្សាឃុំ-សង្កាត់ (CC) ត្រូវបានបង្កើតឡើងកាលពីខែមីនា ឆ្នាំ២០០២ បន្ទាប់ពីមានការបោះឆ្នោតនៅថ្នាក់ មូលដ្ឋាន ។ ក្រុមប្រឹក្សាឃុំមានភារកិច្ចចាត់ចែងការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រនៅក្នុងឃុំ-សង្កាត់ របស់គេឱ្យស្របទៅ តាមយុទ្ធសាស្ត្រអភិវឌ្ឍរបស់រដ្ឋាភិបាល ។

ក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗធ្វើការជាមួយអនុគណៈកម្មការរៀបចំផែនការ និងថវិកា ដើម្បីកសាងផែនការវិនិយោគឃុំប្រចាំឆ្នាំ (CIP) ដែលអាចជួយឃុំ-សង្កាត់កំណត់បញ្ហាជាអាទិភាព និងផ្តល់ឱកាសទទួលជំនួយពីរដ្ឋាភិបាល និងពីអ្នកផ្តល់ជំនួយសម្រាប់ទ្រទ្រង់ការអភិវឌ្ឍក្នុងតំបន់របស់ពួកគេ ។ ការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងដែនជម្រកសត្វព្រៃពាមក្រសោប បង្ហាញថា តម្រូវការរបស់អ្នកភូមិមានជាអាទិ៍ សាលារៀន ទឹកស្អាត មន្ទីរពេទ្យ ផ្លូវថ្នល់ ទំនប់ទឹក និងការស្តារព្រៃកោះកាពិជាដើម ។

ទោះបីការធ្វើផែនការគ្រប់គ្រងធនធានមានជាអាទិ៍ ការដាំដើមកោងកាងឡើងវិញ ជាផ្នែកមួយរបស់ CIP ក៏ដោយក៏កិច្ចការទាំងនោះមិនត្រូវបានគេចាត់ទុកជាការងារអាទិភាពនៅឡើយ ។ ប្រការនេះគ្មានអ្វីដែលគួរអោយភ្ញាក់ផ្អើលឡើយព្រោះថាអ្នកភូមិពុំចាប់អារម្មណ៍ទាំងស្រុងលើប្រព័ន្ធអេកូឡូស៊ី ឬការគ្រប់គ្រងធនធានធម្មជាតិនោះឡើយ ។ ដូចប្រជាជននៅតាមទីកន្លែងដទៃទៀតដែរ អ្នកភូមិនៅតាមតំបន់ឆ្នេរត្រូវការសេវាកម្មជាក់ស្តែង ដូចជា សុខភាព ការអប់រំ ហេដ្ឋារចនាសម្ព័ន្ធជាដើម ។ បើទោះបីជាសមាជិកសហគមន៍កោះស្រឡៅយល់ឃើញថា ការគ្រប់គ្រងធនធានធម្មជាតិគឺជាការងារសំខាន់ក៏ដោយក៏ពួកគេមានតម្រូវការចាំបាច់ជាច្រើនផ្សេងទៀតផងដែរ ។

ក្រុមប្រឹក្សាឃុំ-សង្កាត់គឺជាអ្នកទទួលខុសត្រូវលើកិច្ចការ ជាច្រើនទាក់ទងនឹងការអភិវឌ្ឍឃុំ-សង្កាត់ ចំណែកគណៈកម្មការសហគមន៍យកចិត្តទុកដាក់ជាសំខាន់ លើការគ្រប់គ្រងធនធាន ។ មន្ទីរជំនាញនៅថ្នាក់ខេត្ត ជួយការងារគណៈកម្មការសហគមន៍ ដូចជាការិយាល័យជលផលផ្តោតលើការងារអភិវឌ្ឍន៍វិស័យជលផល ដូចជាការប្រមូលថ្លៃឈ្នួលដែននេសាទ ការត្រួតពិនិត្យប្រភេទឧបករណ៍នេសាទជាដើម ។ ក្នុងពេលជាមួយគ្នានេះ មន្ទីរបរិស្ថានគិតគូរអំពីការងារអភិរក្ស និងកិច្ចការពារធនធានធម្មជាតិ ។

ដោយសារមន្ទីរនីមួយៗមានកម្មវិធីការងាររៀងៗខ្លួន ការបញ្ចូលគ្នានូវសកម្មភាពរួមមួយគឺជាប្រការ

ភាគីពាក់ព័ន្ធ(រួមមានសហគមន៍មូលដ្ឋាន រដ្ឋអំណាចភូមិ ឃុំ និងស្រុក កងកម្លាំងប្រដាប់អាវុធ និងមន្ទីរជំនាញពាក់ព័ន្ធ) ក្នុងខេត្តកោះកុងទទួលស្គាល់ថា ធនធានសមុទ្របានរេចរឹល ដោយសារសកម្មភាពនេសាទល្មើសច្បាប់ ការនេសាទហួសកម្រិត ការបំផ្លាញព្រៃតាមតំបន់ឆ្នេរ ការបំពុល និងសំពាធនៃកំណើនចំនួនប្រជាជន ។ ការបំផ្លិចបំផ្លាញធនធានតំបន់ឆ្នេរបានជះឥទ្ធិពលដល់ជីវភាពរស់នៅរបស់ប្រជាជននៅតាមតំបន់ឆ្នេរ ។ កិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងអស់នៅគ្រប់លំដាប់ថ្នាក់ និងការចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានឆ្នេរសមុទ្រអាចជួយពង្រឹង និងស្តារធនធានតំបន់ឆ្នេរឡើងវិញ ។ ការងារនេះអាចធ្វើទៅបាន លុះត្រាតែលុបបំបាត់ការនេសាទល្មើសច្បាប់ ពង្រឹងការអនុវត្តច្បាប់ បង្កើត និងពង្រឹងសហគមន៍នេសាទ និងធានាឱ្យបាននូវការប្រើប្រាស់ធនធានឆ្នេរប្រកបដោយនិរន្តរភាព ។ ការងារនេះមិនត្រឹមតែបំរើគោលបំណងការពារប្រព័ន្ធអេកូឡូស៊ីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលប្រយោជន៍បរិស្ថានសេដ្ឋកិច្ច-សង្គមរបស់សហគមន៍មូលដ្ឋានទៀតផង ។ អេកូទេសចរណ៍គឺជាកត្តាមួយ ផ្សេងទៀតក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតំបន់ឆ្នេរ ។

*ប្រភព : ចក្ខុវិស័យក្នុងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរខេត្តកោះកុង ថ្ងៃទី ១៤-១៦ ខែមករា ឆ្នាំ២០០៤*

ធម្មជាតិនៅក្នុងសហគមន៍ ។ នាពេលថ្មីៗនេះ គម្រោង PMMR បានរៀបចំសិក្ខាសាលាមួយស្តីពី "ចក្ខុវិស័យក្នុងការចូលរួមគ្រ គ្រងធនធានតំបន់ឆ្នេរ" នៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប និងឈូងជ្រោយប្រស់ ដើម្បីជួយភាគីពាក់ព័ន្ធនៅក្នុងសហគម តំបន់ឆ្នេរធ្វើការរួមគ្នា សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ។

## ឥទ្ធិពលបន្ទាប់ពីវត្តមានរបស់គណៈកម្មការសហគមន៍

ការចងក្រងសហគមន៍គឺជាដំណើរការមួយ ដែលក្នុងនោះសហគមន៍មានអំណាចដើម្បីកំណត់រួមគ្នាពីតម្រូវការរបស់ ខ្លួន និងដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍ (IIRR, 1998) ។ គោលបំណងចម្បងនៃការបង្កើតគណៈកម្មការសហគមន៍ គឺដើម្បី ជួយដល់សមាជិកសហគមន៍លើការងារគ្រប់គ្រងធនធានធម្មជាតិ ។ បើទោះបីជា សហគមន៍ទាំងនេះពុំទាន់មានការគាំទ្រដោយ ច្បាប់ជាផ្លូវការក៏ដោយ (អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទកំពុងត្រូវបានរៀបចំ) ក៏មានគោលនយោបាយក្រៅផ្លូវ ការមួយចំនួនដែលមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញផងដែរ ។

អាជ្ញាធរមូលដ្ឋានទទួលស្គាល់ថា ចាប់តាំងពីមានការបង្កើតគណៈកម្មការសហគមន៍រួចមក មានការផ្លាស់ប្តូរជាវិជ្ជមាន មួយចំនួន ហើយស្ថានភាពធនធានតំបន់ឆ្នេរមានភាពប្រសើរឡើងច្រើន ។ សកម្មភាពនានារបស់គណៈកម្មការសហគមន៍មាន ឥទ្ធិពលវិជ្ជមានទៅលើការងារមួយចំនួនដូចជា ការលើកកម្ពស់ការយល់ដឹងកាន់តែច្រើនឡើងពីគំនិតនៃការគ្រប់គ្រងធនធាន ធម្មជាតិដោយសហគមន៍ ការកែលំអបរិស្ថានឆ្នេរសមុទ្រ និងជីវភាពរបស់ប្រជាជន ការបង្កើនសមត្ថភាពអ្នកប្រើប្រាស់ធនធាន និងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធចាប់ពីថ្នាក់មូលដ្ឋានរហូតដល់អន្តរជាតិ ក្នុងក្តីសង្ឃឹមថានឹង អាចចែករំលែកការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព និងការបង្កើនជីវភាពរស់នៅរបស់សហគមន៍ ។

**ការឈានពីទស្សនទានស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ទៅជាការអនុវត្តជាក់ស្តែង :** មុនពេលអនុវត្តគម្រោង PMMR ក្នុងតំបន់ការពារដែនជម្រកសត្វព្រៃពាមក្រសោប សហគមន៍មូលដ្ឋានបានគិតថា ការគ្រប់គ្រងធនធានតំបន់ឆ្នេរគឺជាការ ទទួលខុសត្រូវរបស់មន្ត្រីរដ្ឋាភិបាល ។ បន្ទាប់ពីបានបញ្ជ្រាបគោលគំនិតនៃការគ្រប់គ្រងធនធានដោយសហគមន៍ តាមរយៈវគ្គ បណ្តុះបណ្តាល សិក្ខាសាលា និងដំណើរទស្សនកិច្ចសិក្សារួចមក សមាជិកសហគមន៍មានបំណងចូលរួមអភិរក្ស និងការពារធនធាន ធម្មជាតិ ។ សមាជិកគណៈកម្មការសហគមន៍បានចាប់ផ្តើម ពិភាក្សាពីប្រសិទ្ធភាពនៃការចូលរួមគ្រប់គ្រងធនធាន និងស្វែងរក មធ្យោបាយលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ។ សកម្មភាពទាំងនេះបានធ្វើអោយអ្នកភូមិ និងភាគី ពាក់ព័ន្ធផ្លាស់ប្តូរអាកប្បកិរិយាទៅលើការគ្រប់គ្រងព្រៃកោងកាង ដូចជា សមាជិកសហគមន៍មួយចំនួនបានចូលរួមល្បាត ដាំកោង កាងឡើងវិញ និងរាយការណ៍ពីសកម្មភាពល្មើសច្បាប់ទៅឱ្យគណៈកម្មការសហគមន៍ និងអជ្ញាធរមូលដ្ឋាន ។

**ការកែលំអប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ:** ធនធានធម្មជាតិក្នុងតំបន់ត្រូវបានទទួលរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដោយសារតែការប្រើប្រាស់មិនសមស្របនិងការគ្រប់គ្រងគ្មានប្រសិទ្ធភាព ។ គណៈកម្មការសហគមន៍បានខិតខំស្វែងរកការគាំទ្រពីសហគមន៍ ផ្សព្វផ្សាយលក្ខន្តិកៈ និងច្បាប់សហគមន៍ រៀបចំផែនការសកម្មភាព ផ្តួចផ្តើមសកម្មភាពល្បាត និងស្វែងរកការគាំទ្រខាងបច្ចេកទេស និងដំណោះស្រាយបញ្ហាពីសំណាក់រដ្ឋអំណាចមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធ ។ នៅក្នុងដែនការពាររបស់សហគមន៍ សមាជិកសហគមន៍បានធ្វើការល្បាតជាមួយឧទ្យានុរក្ស និងប៉ូលិសនៅក្នុង និងក្រៅតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប ។ ជាលទ្ធផលបទល្មើសនេសាទ និងសកម្មភាពល្មើសច្បាប់នានាបានថយចុះ ហើយជនល្មើសបានទទួលការអប់រំ និងធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពល្មើសច្បាប់របស់គេ ។

**ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ:** គណៈកម្មការសហគមន៍ចាប់អារម្មណ៍លើការបង្កើតទំនាក់ទំនង និងស្វែងរកការគាំទ្រ និងកិច្ចសហប្រតិបត្តិការពីអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធនានា ។ បើគ្មានគោលនយោបាយជាផ្លូវការក្នុងការគាំទ្រដល់ការងារគ្រប់គ្រងសហគមន៍នេសាទទេនោះ គណៈកម្មការសហគមន៍ត្រូវប្រឈមមុខនឹងការលំបាកក្នុងការទាក់ទាញអ្នកភូមិ និងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធឱ្យចូលរួមធ្វើការងារផ្សេងៗក្នុងសហគមន៍ ។ ការលំបាកទាំងនេះអាចដោះស្រាយបាន នៅពេលដែលសហគមន៍មូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធយោគយល់គ្នាទៅវិញទៅមក និងមានចំណងមិត្តភាពល្អ ។ ទោះបីជាគណៈកម្មការសហគមន៍មិនមែនស្ថិតនៅចំណុះស្ថាប័នរដ្ឋាភិបាលផ្ទាល់ក៏ដោយ ក៏គណៈកម្មការទាំងនេះបានពិភាក្សាការងារជាមួយមន្ទីរពាក់ព័ន្ធ ហើយកិច្ចពិភាក្សាក្រៅផ្លូវការជាច្រើនត្រូវបានធ្វើឡើងផងដែរ ។ ជាញឹកញាប់ គណៈកម្មការសហគមន៍បានរាយការណ៍ជូនប៉ូលិសឃុំ ក្រុមប្រឹក្សាឃុំ និងមន្ត្រីរដ្ឋាភិបាលនូវសកម្មភាពដែលពួកគាត់បានអនុវត្ត ។ នៅពេលបច្ចុប្បន្ន គណៈកម្មការសហគមន៍បានទទួលការគាំទ្រកាន់តែច្រើនពីភាគីពាក់ព័ន្ធនានា ដោយសារមានកិច្ចខិតខំប្រឹងប្រែងបង្កើតទំនាក់ទំនងល្អ ។ ប៉ូលិសក្នុងសហគមន៍កោះស្រឡៅ និងជ្រោយប្រស់ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនានា ដែលពីពេលមុនពួកគេហាក់ដូចជាចង់គេចវេស មិនចង់ជួយសហគមន៍ឡើយ ។

**ការកែលំអគណៈកម្មការសហគមន៍:** ពីមួយថ្ងៃទៅមួយថ្ងៃ សមត្ថភាពគណៈកម្មការសហគមន៍បានរីកចម្រើនជាលំដាប់ ហើយសមាជិកគណៈកម្មការអាចអនុវត្តការងារជាច្រើនដោយខ្លួនគេផ្ទាល់ដូចជា រៀបចំកិច្ចពិភាក្សារវាងសមាជិកគណៈកម្មការ ឬប្រធានក្រុម រៀបចំវេនល្បាតជាមួយបរិស្ថានុរក្ស ស្វែងរកជំនួយពីប៉ូលិសឃុំក្នុងពេលចាំបាច់ និងផ្តួចផ្តើមគំនិតបង្កើតលក្ខន្តិកៈសហគមន៍ ។ នៅពេលគណៈកម្មការគ្រប់គ្រងភូមិកាន់តែរឹងមាំ ពួកគាត់បានជួយសម្រួលការងាររដ្ឋអំណាចមូលដ្ឋានយ៉ាងច្រើន ។ ប្រធានភូមិកោះស្រឡៅបាននិយាយថា វត្តមានរបស់គណៈកម្មការសហគមន៍បានកាត់បន្ថយជម្លោះ ហើយការចិញ្ចឹមជីវិតរបស់អ្នកភូមិកំពុងកែប្រែទៅជាសកម្មភាពប្រកបដោយនិរន្តរភាព ។

## សក្តានុពលភាពនៃការរៀបចំសហគមន៍

ការយកចិត្តទុកដាក់នៅក្នុងជំពូកនេះគឺការបង្កើត និងសកម្មភាពគណៈកម្មការគ្រប់គ្រងធនធាននៅក្នុងសហគមន៍ទាំង
ដោយមានការជួយសម្របសម្រួលពីក្រុមគម្រោង PMMR ។ គម្រោង PMMR បានប្រើប្រាស់វិធីសាស្ត្រពីរយ៉ាង ដើម្បីជួយដ

- ជួយពង្រឹងប្រព័ន្ធគ្រប់គ្រងមូលដ្ឋាន (ដូចមានបង្ហាញក្នុងរូបទី១) ។ នេះមានន័យថា នៅពេលសមាជិកមានចំណេះដឹងពី មូលដ្ឋានរឹងមាំ ពួកគេបានចូលរួមក្នុងសកម្មភាពគ្រប់គ្រងធនធាន ហើយក្នុងករណីនេះពួកគេពុំចាំបាច់បង្កើតស្ថាប័នថ្មីមួយ ឡើយ ព្រោះថា គេមានការដឹកនាំរឹងមាំរួចទៅហើយសម្រាប់គ្រប់គ្រងធនធានធម្មជាតិ ។ ការជួយអ្នកដឹកនាំដែលមាន ស្រាប់តាមរយៈសិក្ខាសាលា ត្រូវបានចាត់ទុកជាសកម្មភាពសមស្រប ។
- ចំពោះអ្នកភូមិដែលមានបទពិសោធន៍តិចតួចលើការគ្រប់គ្រងធនធានធម្មជាតិបានស្នើឱ្យមានការរៀបចំប្រព័ន្ធគ្រប់គ្រ (ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការសហគមន៍) ដោយមានគោលបំណងបង្កើតក្របខ័ណ្ឌគ្រប់គ្រងធនធាននេសាទ និងធនធានធម្មជាតិក្នុងភូមិរបស់គេនីមួយៗ ។

ជំពូកនេះឆ្លុះបញ្ចាំងដំណើរការមួយប្រភេទនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ក្នុងតំបន់ឆ្នេរនៃប្រទេស កម្ពុជា ។ ទោះបីនៅពេលនេះ ការជួយដល់ការងារគ្រប់គ្រងធនធានដោយសហគមន៍នៅទូទាំងប្រទេសត្រូវឱ្យមានគោលការណ ណែនាំក៏ដោយ ប្រការសំខាន់គឺថា គោលការណ៍នោះត្រូវតែមានលក្ខណៈទូលំទូលាយដើម្បីឱ្យអ្នកភូមិផ្សេងៗទៀតស្វែ រកមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ដោះស្រាយបញ្ហារបស់គេ ដែលប្រការនេះអាច ឬមិនអាចពាក់ព័ន្ធនឹងការបង្កើ គណៈកម្មការសហគមន៍ ។ ក្នុងករណីខ្លះ គេត្រូវផ្តល់ការគាំទ្រដល់ប្រធានភូមិដើម្បីគ្រប់គ្រងធនធានធម្មជាតិ ហើយពេលខ្លះទៀ ចាំបាច់ត្រូវបង្កើតគណៈកម្មការសហគមន៍ផងដែរ ។ ទាំងការគាំទ្រដល់ប្រធានភូមិ ទាំងការបង្កើតគណៈកម្មការសហគមន៍ សុទ្ធតែ មានផលប្រយោជន៍ដូចគ្នា ពោលគឺការបំពេញការងារ តាមរយៈគណៈកម្មការសហគមន៍គឺជាការងារ តំណាងឱ្យអ្នកភូមិភាគច្រើ និងការធ្វើសេចក្តីសម្រេចដោយមានការចូលរួម ។ ចំណែកឯការបំពេញការងារតាមរយៈប្រធានភូមិ និងប្រពៃណីការងារនេ ថ្នាក់ភូមិ ក៏មានគុណសម្បត្តិម្យ៉ាងដែរ ។ ជារួម ប្រព័ន្ធគ្រប់គ្រងនីមួយៗមានចំណុចខ្លាំងផ្ទាល់នីមួយៗរបស់ខ្លួន ។

## សេចក្តីសន្និដ្ឋាន

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍គឺជាទស្សនទានថ្មីសម្រាប់ប្រទេសកម្ពុជា ដោយសារប្រឈមនឹងការធ្លាក់ចុះយ៉ាងលឿននូវធនធានតំបន់ឆ្នេរ និងតំបន់ដីគោក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការខិតខំជម្រុ ឱ្យមានប្រព័ន្ធថ្មីសម្រាប់គ្រប់គ្រងធនធានធម្មជាតិ ។ ការកែទម្រង់គោលនយោបាយរបស់រាជរដ្ឋាភិបាល បានជួយដល់ក្រុ គម្រោង PMMR និងគណៈកម្មការសហគមន៍ ឱ្យឈានឆ្ពោះទៅបំពេញក្តីសង្ឃឹមនានារបស់សហគមន៍មូលដ្ឋា ដែលនៅពេលនេះសមាជិកសហគមន៍រំពឹងថា នៅដំណាក់កាលណាមួយការងាររបស់គណៈកម្មការសហគមន៍នឹងទទួលបានកា គាំទ្រពីគោលនយោបាយផ្លូវការរបស់រាជរដ្ឋាភិបាល ។ គម្រោង PMMR បានចូលរួមសម្របសម្រួលដំណើរការគ្រប់គ្រងធនធា ធម្មជាតិតាមរយៈសហគមន៍ ដោយបញ្ចូលភាគីពាក់ព័ន្ធ ដូចជា សហគមន៍នេសាទ ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានទៅក្នុ

លទ្ធផលនៃការបង្កើតគណៈកម្មការសហគមន៍គឺថា សហគមន៍គោលដៅមានលទ្ធភាពច្រើនក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងធនធានក្នុងដែនការពាររបស់គេ និងចូលរួមលើកកំពស់បរិស្ថានតំបន់ឆ្នេរសមុទ្រ ។ សមាជិកសហគមន៍មានការយល់ដឹង កាន់តែច្រើនឡើងពីសារៈប្រយោជន៍ និងមុខងារនៃព្រៃកោងកាង ដែលជាជម្រកមច្ឆាជាតិ និងជាប្រភពទ្រទ្រង់ជីវភាពរស់នៅ របស់គេ សមាជិកគណៈកម្មការសហគមន៍កំពុងធ្វើការយ៉ាងសកម្មជាមួយសមាជិកសហគមន៍ ហើយក្រុមគម្រោង PMMR ចូលរួមចែករំលែកការទទួលខុសត្រូវលើការគ្រប់គ្រងធនធានឆ្នេរផងដែរ ។ ជាងនេះទៅទៀត សមាជិកទាំងនោះព្យាយាមធ្វើការ ងារជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត លើការងារអភិវឌ្ឍន៍ភូមិ តាមរយៈកិច្ចសម្របសម្រួលដោយប្រយោល និងផ្ទាល់ពីគម្រោង PMMR ។

បទពិសោធន៍នានាកំពុងត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការធ្វើផែនការរបស់ក្រុមប្រឹក្សាឃុំដែលជាគោលនយោបាយ វិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ មេរៀនល្អៗដែលទទួលបានពីការងារនៅមូលដ្ឋាន ក្នុងខេត្តកោះកុង និងតំបន់ផ្សេងៗទៀតក្នុង ប្រទេសកម្ពុជាបាននិងកំពុងចូលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ តាមរយៈកម្មវិធីសិលា និងគម្រោងផ្សេងៗទៀត ជាពិសេស អ្នកធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់ទាំងអស់បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសកម្មភាពគ្រប់គ្រងធនធាន ធម្មជាតិ និងបរិស្ថានរបស់គណៈកម្មការសហគមន៍ ។

ទោះជាយ៉ាងណាក៏ដោយ ការចូលរួមពីសហគមន៍មូលដ្ឋានលើការងារគ្រប់គ្រងធនធានត្រូវការពេលវេលា និងជំនាញ ផ្សេងៗជាច្រើនថែមទៀត ដើម្បីជួយសហគមន៍ឱ្យមានលទ្ធភាពពេញលេញលើការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយ និរន្តភាពនាពេលអនាគត ។ ជាងនេះទៀត សហគមន៍នៅតែត្រូវការចាំបាច់នូវជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីខាងក្រៅ មេរៀនសំខាន់ៗពីក្រុមការងាររបស់គម្រោង PMMR មានជាអាទិ៍ (១) គណៈកម្មការសហគមន៍នីមួយៗមានលក្ខណៈខុសគ្នា ទៅតាមស្ថានភាពសហគមន៍ និង (២)ការសម្របសម្រួលល្អដើម្បីកំណត់ និងដោះស្រាយបញ្ហានានានៃការគ្រប់គ្រងធនធាន ធម្មជាតិពីសំណាក់មន្ត្រីមកពីមន្ទីរ ជំនាញនៅថ្នាក់ខេត្ត ឬបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន គឺជាកត្តាដ៏សំខាន់ និង ចាំបាច់បំផុតដើម្បីជួយគណៈកម្មការសហគមន៍ឱ្យបានរឹងមាំ ។

# REFERENCES


Agrawal, A., and Gibson, C. 1999. *Enchantment and Disenchantment: The Role of Community in Natural Resource Conservation, World Development 27(4): 629-649.*

Chey, P, Som C, Suy,T, and Leng, S. 2002. *Community-based Coastal Resources Management Case Study from Preah Sihanouk "Ream" National Park and Peam Krasaop Wildlife Sanctuary, Kingdom of Cambodia.*

IIRR *(The International Institute of Rural Reconstruction). 1998. Participatory Methods in Community-Based Coastal Resources Management-* Volume 1 Introduction Papers, volume 2 and 3 tools and Methods, IIRR, IDRC, CIDA.

Li, T.M. 2002. Engaging Simplification: Community-Based Resource Management, *Market Processes and State Agendas in Upland Southeast Asia, World Development 30(2): 265-283.*

Marschke, M. 2003. From Planning to Action: What can resources management committees do "on the ground", *Cambodia Development Review, (7)3: 7-10,12.*

Marschke, M. and Nong, K. 2003. Adaptive Co-management: lessons from coastal Cambodia. *Canadian Journal of Development Studies (24) 3: 369-383.*

McKenney, B., and Prom, T. 2002. *Natural Resources and Rural Livelihoods in Cambodia, A baseline assessment.* Working Paper 23. Cambodia Development Resource Institute.

Thouk, N. 2004. Opening Speech for Reviewing CFDO Activities. Phnom Penh, Cambodia Department of Fisheries. January 8th.

# ជំពូក ១៦ ផ្តើមចេញពីការកសាងផែនការ ឈានទៅការអនុវត្តសកម្មភាព : តើគណៈកម្មការគ្រប់គ្រងធនធានអាចធ្វើអ្វីបានខ្លះ "នៅថ្នាក់មូលដ្ឋាន"?[1]

រៀបរៀងដោយ : កញ្ញា Melissa Marschke[2]

*"ខ្ញុំមិនបានគិតទាល់តែសោះថា ការគ្រប់គ្រងធនធានធម្មជាតិ អាចលើកកំពស់ជីវភាពរស់នៅរបស់យើង ។ ប៉ុន្តែបច្ចុប្បន្ន តាមរយៈការងារនេះ យើងអាចដោះស្រាយបញ្ហាខ្លះៗបាន ... យើងមានអារម្មណ៍ថា ធនធានធម្មជាតិមានលក្ខណៈល្អប្រសើរជាងមុនបន្តិចហើយ" ។*

(សំដីរបស់សមាជិកមួយរូបនៃគណៈកម្មការគ្រប់គ្រងធនធានធម្មជាតិ និងអ្នកនេសាទមួយរូបឆ្នាំ ២០០៣) ។

ឆ្លើយតបទៅនឹងការថយចុះនៃលទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ ការគ្រប់គ្រងតាមបែបសហគមន៍ (សហគមន៍នេសាទ សហគមន៍ព្រៃឈើ ឬ សហគ្រប់គ្រង បានកើនឡើងក្នុងប្រទេសកម្ពុជា ។ ទោះបីវិធីសាស្ត្រដែលយកមក ប្រើប្រាស់អាចប្លែកពីគ្នាក៏ដោយ សហគមន៍បានធ្វើការយ៉ាងសកម្មដើម្បីបង្កើតតំបន់គ្រប់គ្រងរបស់ខ្លួន និងរៀបចំផែនការដែលមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ឬ ស្ថាប័នរដ្ឋាភិបាល ។ ជាក់ស្តែង នៅឆ្នាំ២០០២ មានសហគមន៍នេសាទចំនួន ១៦២ កន្លែង និងសហគមន៍ព្រៃឈើចំនួន ២៣៧ កន្លែងត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជា (McKenny & Prom, 2002) ។

លើសពីនេះ ទោះបីបរិយាកាសនយោបាយពុំសូវស៊ីសង្វាក់គ្នាក្តី បរិយាកាសនេះក៏កំពុងត្រូវបានកសាងឡើងដើម្បីគាំទ្រទម្រង់ខ្លះនៃការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ និងសហគមន៍នេសាទត្រូវបានរៀបចំឡើង ហើយបច្ចុប្បន្នកំពុងត្រូវបានពិនិត្យឡើងវិញ ។




*រូបទី១ : តំបន់ការងារពីរកន្លែង*

សហគមន៍ព្រៃឈើ និងសហគមន៍នេសាទនៅក្នុងតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា បានបោះឆ្នោតជ្រើសតាំងគណៈកម្មការគ្រប់គ្រងធនធាន (ដែលត្រូវបានឱ្យឈ្មោះថាជាគណៈកម្មការសហគមន៍នេសាទ ឬ គណៈកម្មការសហគមន៍ព្រៃឈើ ដែលមានភារៈកិច្ចណែនាំអំពីសកម្មភាពគ្រប់គ្រងធនធាន ។ ការរកឃើញនៅក្នុងដំណាក់កាលដំបូង តាមរយៈការសិក្សាមួយដែលកំពុងធ្វើឡើង (ខែសីហា ឆ្នាំ២០០២-ខែកក្កដា ឆ្នាំ ២០០៣) ពីជីវភាពរស់នៅតាម

---

[1] អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយឡើងវិញដោយមានការឯកភាពពី Cambodia Development Review. Marschke, M. "From planning to action: what can resource management committees do 'on the ground'" ? *Cambodia Development Review*. 7(3): 7-10, 12.

[2] កញ្ញា Melissa កំពុងបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត នៅឯសកលវិទ្យាល័យ ម៉ានីតូបា ប្រទេសកាណាដា ។

ជនបទ និងអំពីការគ្រប់គ្រងដោយសហគមន៍នៅភូមិកោះស្រឡៅ ក្នុងខេត្តកោះកុង និងនៅភូមិកំពង់ភ្លុក ក្នុងខេត្តសៀមរាប បានធ្វើការបំភ្លឺអំពីសកម្មភាពចំនួន២បែបនៅលើទីតាំងភូមិសាស្ត្រជាក់ស្តែងរបស់គណៈកម្មការគ្រប់គ្រងធនធាន ។ ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវពីររួមគ្នាគឺ វិធីបរិមាណវិស័យ និងគុណវិស័យរួមទាំងរបៀបស្រាវជ្រាវដែលមានការចូលរួមការពិភាក្សាយ៉ាងស៊ីជម្រៅជាមួយគ្រួសារនានា និង ការអង្កេតតាមគ្រួសារចំនួន ១៤៨ផ្ទះ ។

កំពង់ភ្លុក គឺជាភូមិមួយស្ថិតនៅលើបឹងទន្លេសាប ហើយដែលបានអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍តាំងពីទសវត្សរ៍ឆ្នាំ ១៩៤០មកម្ល៉េះ និងអាចជាកន្លែងមួយដែលមានបទពិសោធន៍ចំណាស់ជាងគេពីការគ្រប់គ្រងធនធាន ( ព្រៃឈើ និងជលផល នៅជុំវិញបឹងទន្លេសាប ។ កោះស្រឡៅគឺជាសហគមន៍មួយក្នុងតំបន់ឆ្នេរនៃខេត្តកោះកុង ដែលបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានដោយសហគមន៍ នៅពេលធនធានរបស់ពួកគេបាននឹងកំពុងបាត់បង់ ។ ទីតាំងទាំងពីរបានទទួលការគាំទ្រពីម្ចាស់ជំនួយ ( ការគាំទ្របច្ចេកទេសច្រើនជាងការគាំទ្រហិរញ្ញវត្ថុ និងត្រូវបានទទួលស្គាល់ថាបានផ្តល់បទពិសោធន៍ជោគជ័យសម្រាប់ការគ្រប់គ្រងដោយសហគមន៍ ។ សហគមន៍ដទៃទៀតពុំសូវរៀបចំចាត់ចែងបានល្អ ឬ ពុំសូវមានចំណាប់អារម្មណ៍ ឬ ចូលរួមយ៉ាងសកម្មឡើយ (Poffenberger 2002; PMMR 2003) ។

ទោះបីការវិភាគពីការគាំទ្រដោយម្ចាស់ជំនួយ និងឥទ្ធិពលនៃការកសាងផែនការគ្រប់គ្រងចំពោះសកម្មភាពនៃការគ្រប់គ្រងដោយសហគមន៍ បានបង្ហាញឱ្យឃើញនូវលទ្ធផលច្រើនក្តី ការផ្តោតសំខាន់នៅទីនេះគឺទៅលើអ្វីដែលកំពុងអនុវត្ត "នៅលើទីតាំងភូមិសាស្ត្រជាក់ស្តែង" នៅពេលដែលសហគមន៍ទាំងនោះត្រូវបានបង្កើតឡើង និងបានអនុម័តផែនការគ្រប់គ្រងរបស់ខ្លួន ។ អត្ថបទនេះបង្ហាញពីការពិនិត្យមើលនូវគណៈកម្មការគ្រប់គ្រងធនធានចំនួនពីរ ដោយគូសបញ្ជាក់អំពីរបៀបការគ្រប់គ្រងដោយសហគមន៍ដែលអាចប្រព្រឹត្តទៅបានល្អនៅថ្នាក់មូលដ្ឋាន និងអំពីមូលហេតុដែលនាំឱ្យអ្នកភូមិចូលរួមនៅក្នុងសកម្មភាពទាំងនោះ ។ ទោះបីគណៈកម្មការគ្រប់គ្រងធនធានទាំងនោះបានអនុវត្តយុទ្ធសាស្ត្រជាការសាកល្បងក្តី ពួកគេអាចបង្កើនសមត្ថភាពក្នុងការដោះស្រាយបញ្ហា និងរឿងរ៉ាវទាំងឡាយនៅថ្នាក់មូលដ្ឋាន ។ បទពិសោធន៍នានាមានជាអាទិ៍ អ្នកភូមិមានឆន្ទៈចូលរួមក្នុងយុទ្ធសាស្ត្រគ្រប់គ្រងធនធានដោយសហគមន៍នៅពេលពួកគេជឿថា ពួកគេអាចលើកកំពស់ជីវភាពរបស់ខ្លួននៅក្នុងសហគមន៍ ។

## ការគ្រប់គ្រងដោយសហគមន៍មូលដ្ឋានៈ ការពិនិត្យមើលនូវគណៈកម្មការគ្រប់គ្រងធនធានចំនួនពីរ

វិធីសាស្ត្រនានានៃការគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ក្នុងប្រទេសកម្ពុជាទំនងជាមានចរិកលក្ខណៈរួមខ្លះៗដូចគ្នាពោលគឺ វិន័យ និងបទបញ្ជា ការបង្កើតគណៈកម្មការគ្រប់គ្រងធនធានដើម្បីតំរង់ទិសគម្រោងគ្រប់គ្រងធនធានដោយសហគមន៍ អ្នកភូមិផ្តិតមេដៃបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះការងារបែបនោះ ការកំណត់ដែនសម្រាប់គ្រប់គ្រង និងការអនុម័តឯកភាពពីអាជ្ញាធររបស់រដ្ឋាភិបាល ( ដូចជាអភិបាលខេត្ត និង ស្ថាប័ននៅថ្នាក់ជាតិ ។

ទោះបីរចនាសម្ព័ន្ធទាំងនេះមានលក្ខណៈស្រដៀងគ្នាក្ដី យោងតាមផែនការគ្រប់គ្រង និងយន្តការអនុម័ត បានបង្ហាញពីបទពិសោធន៍ថាអ្វីៗដែលកើតឡើង "នៅលើទីតាំងភូមិសាស្ត្រជាក់ស្តែង" អាចមានភាពខុសគ្នា ។ ជាក់ស្តែង ទោះបីបានការទទួលស្គាល់ពីសំណាក់ស្ថាប័ននៃរដ្ឋាភិបាលក្ដី គណៈកម្មការគ្រប់គ្រងធនធានខ្លះនៅតែពុំមានសកម្មភាពនៅឡើយ ។ ប៉ុន្តែគណៈកម្មការគ្រប់គ្រងធនធានដោយសហគមន៍នៅភូមិមួយចំនួន បានប្រព្រឹត្តទៅយ៉ាងសកម្ម ទោះបីជាពុំទាន់មានការគាំទ្រ ឬ ការទទួលស្គាល់ជាផ្លូវការក្ដី ។

ការបកស្រាយពីគណៈកម្មការគ្រប់គ្រងធនធានចំនួនពីរនៅទីនេះ បង្ហាញពីភាពខុសគ្នានៃសមាសភាព និងដំណើរការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងធនធាន។ មុនពេលចាត់ចែងបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នៅកោះស្រឡៅ អ្នកភូមិបានបង្កើត និងឯកភាពទទួលយកនូវវិន័យ និងបទបញ្ជាទាក់ទងនឹងការគ្រប់គ្រងធនធាន ។ បន្ទាប់មក អ្នកភូមិបានបោះឆ្នោតជ្រើសរើសគណៈកម្មការមួយដែលសមាសភាព ៧រូប រួមមានស្ត្រី ២រូបផងដែរ ដើម្បីដឹកនាំសកម្មភាពគ្រប់គ្រងធនធាន ។ គណៈកម្មការនេះ ជួបប្រជុំជាទៀងរាល់ខែ ប៉ុន្តែអាចធ្វើការប្រជុំជាបន្ថែមនៅពេលមានបញ្ហាកើតឡើង ។ ផ្ទុយទៅវិញ គណៈកម្មការគ្រប់គ្រងធនធាននៅកំពង់ភ្លុក ត្រូវបានជ្រើសរើសដោយការបោះឆ្នោត ក្រោយការប្រជុំជាច្រើនដង ហើយបន្ទាប់មកបានធ្វើការជាមួយគ្នា ដើម្បីរៀបចំវិន័យ និងបទបញ្ជា ។ គណៈកម្មការនេះមានតំណាង៩រូប (រួមទាំងស្ត្រី ២រូប មក ពីភូមិចំនួន៣នៅក្នុងឃុំនេះ ។ ក្រោយពីមានការកាត់ចំណែកនៃឡូតិ៍នេសាទ មកឱ្យសហគមន៍នៅក្នុងឆ្នាំ ២០០១ តំបន់នៅក្រោមការគ្រប់គ្រងរបស់ភូមិនេះ ក៏ត្រូវបានពង្រីក ។ ហេតុនេះគណៈកម្មការនេះក៏ត្រូវបានពង្រីកផងដែរ ឯតួនាទី និងការទទួលខុសត្រូវក៏ត្រូវបានកែសម្រួលដូចគ្នាដែរ ។ គណៈកម្មការគ្រប់គ្រងធនធាននេះ បានជួបប្រជុំនៅពេលដែលមានបញ្ហាត្រូវពិភាក្សា ឬ នៅពេលមានបញ្ហាកើតឡើង ។

តារាងទី១ គូសបញ្ជាក់អំពីគោលការណ៍គ្រប់គ្រងគណៈកម្មការគ្រប់គ្រងធនធាននៅកោះស្រឡៅ និងកំពង់ភ្លុក រួមទាំងពេលវេលាដែលគណៈកម្មការគ្រប់គ្រងធនធានទាំងនេះត្រូវបានបង្កើតឡើង ស្ថានភាពចំពោះមុខច្បាប់ បញ្ហានៃការគ្រប់គ្រងធនធានដែលត្រូវដោះស្រាយ ។ ចំពោះ ឧទាហរណ៍អំពីយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហា និងហេតុផលដែលនាំឱ្យអ្នកភូមិគាំទ្រគណៈកម្មការគ្រប់គ្រងធនធាននៅក្នុងភូមិ ឬ ឃុំរបស់ពួកគេ (សូមអានជំពូក ១៥ ។ ទោះបីគណៈកម្មការទាំងពីរនោះទើបត្រូវបានបង្កើតក្នុងឆ្នាំ១៩៩៩-២០០០ក៏ដោយ ក៏គណៈកម្មការទាំងពីរនោះអាចធ្វើការសាកល្បងយុទ្ធសាស្ត្រនានានៃការគ្រប់គ្រងធនធាន ដោយបានពិចារណាអំពីអ្វីដែលអាចអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នៅក្នុងស្ថានភាពនៃទីតាំងភូមិសាស្ត្ររៀងៗខ្លួន ។

ឧទាហរណ៍ នៅកោះស្រឡៅ ការគ្រប់គ្រងធនធានជំហានដំបូងផ្តោតលើការអប់រំបរិស្ថាន និងការល្បាតដើម្បីទប់ស្កាត់សកម្មភាពល្មើសច្បាប់ ដូចជាការនេសាទដោយអួនអូស និងដោយគ្រឿងផ្ទុះ ការលួចឧបករណ៍នេសាទ និងការកាប់ព្រៃផលិតធ្យូង ។ ក្រោយមកគណៈកម្មការគ្រប់គ្រងធនធានបានសម្រេចពង្រឹងការងារនេះ តាមរយៈការសម្របសម្រួលយន្តការ

ដោះស្រាយទំនាស់នៅក្នុងកិច្ចប្រឹងប្រែងស្វែងរកដំណោះស្រាយ ដែលអាចឱ្យអ្នកភូមិកាន់តែចូលរួម និងអាចអនុវត្តបានដោយគ្មានជំនួយពីខាងក្រៅ ។ យន្តការមួយបែបនេះ ដែលនឹងត្រូវពង្រីកនៅពេលក្រោយ ហើយត្រូវបានយកទៅប្រើប្រាស់ដើម្បីដោះស្រាយទំនាស់បណ្តាលពីការលួចឧបករណ៍នេសាទ ។

ទោះបីកាលពីដំបូង គណៈកម្មការគ្រប់គ្រងធនធានទាំងពីរនេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងធនធានដោយសហគមន៍ក្តី ពួកគេចាត់ទុកអាណត្តិរបស់ខ្លួនក្រោមរូបភាពទូលំទូលាយ ។ ឧទាហរណ៍: នៅកោះស្រឡៅ គណៈកម្មការគ្រប់គ្រងធនធាន ក៏ស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដទៃទៀតនៅក្នុងសហគន៍ផងដែរ ដូចជាការគាំទ្រគ្រូបឋមសិក្សាឱ្យប្រចាំការនៅក្នុងភូមិ ។ នៅកំពង់ភ្លុក គណៈកម្មការគ្រប់គ្រងធនធានបានជួយគ្រួសារក្រីក្រក្នុង ពេលលំបាក ដូចជាផ្តល់ការគាំទ្រសម្រាប់ពិធីបុណ្យសព ។ ការវិភាគបឋមបានបង្ហាញថាអ្នកភូមិភាគច្រើនចាត់ទុកធនធានទាំងឡាយ (ពោលគឺបញ្ហានេសាទ និងព្រៃឈើ ថាមានទំនាក់ទំនងគ្នា និងយល់ឃើញថា គណៈកម្មការគ្រប់គ្រងធនធានគឺជាអង្គភាពមួយមិនត្រឹមតែគ្រប់គ្រងធនធានប៉ុណ្ណោះទេ តែអាចជួយដោះស្រាយបញ្ហាបាន ។ ក្នុងភូមិនីមួយៗ សមាជិកគណៈកម្មការគ្រប់គ្រងធនធាននិយាយថាអ្នកភូមិបានគាំទ្រការងាររបស់ខ្លួនដោយសារពួកគេមានការជឿទុកចិត្ត និងមានជំនឿថាជីវភាពរស់នៅរបស់ពួកគេបានកែលំអឡើងដោយសារទង្វើរបស់ពួកគេ និងមានអ្នកដឹកនាំល្អ ។

| | កោះស្រឡៅ | កំពង់ភ្លុក |
|---|---|---|
| បានបង្កើតឡើងនៅឆ្នាំ | ២000 | ១៩៩៩ |
| ស្ថានភាពចំពោះមុខច្បាប់ | ទទួលការគាំទ្រក្រៅផ្លូវការដោយកិច្ចព្រមព្រៀងជាមួយអភិបាលខេត្ត និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន (ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិមួយ ។ | បានទទួលការគាំទ្រក្រៅផ្លូវការដោយកិច្ចព្រមព្រៀងជាមួយអភិបាលខេត្ត ។ |
| បញ្ហាគ្រប់គ្រងដែលត្រូវដោះស្រាយ | ការនេសាទល្មើសច្បាប់នៅក្នុង និងក្រៅសហគមន៍របស់ខ្លួន ការផលិតធ្យូង ការលួចឧបករណ៍នេសាទ ការថយចុះនៃធនធាន ការគ្រប់គ្រងសំណល់ និងបញ្ហាផ្សេងទៀតរបស់សហគមន៍ ។ | ការកាប់ព្រៃលិចទឹក ការនេសាទល្មើសច្បាប់ដោយអ្នកនៅខាងក្នុង និងអ្នកមកពីក្រៅសហគមន៍ ការស្រុតចុះនៃធនធាន ការទន្ទ្រានយកដីធ្លីធ្វើចំការ និងបញ្ហាផ្សេងទៀតរបស់សហគមន៍ ។ |
| យុទ្ធសាស្ត្រគ្រប់គ្រង | ដោះស្រាយអំពើលួចតាមរយៈដំណោះស្រាយ ប្រកបដោយការច្នៃប្រឌិត (លាបពណ៌លបក្ដាម ល្បាត គាំទ្រគ្រូបឋមសិក្សាក្នុងមូលដ្ឋាន ។ | បញ្ចុះបញ្ចូលភូមិនីមួយៗឱ្យចូលរួមក្នុងប្រព័ន្ធការពារព្រៃឈើ គាំទ្រអ្នកក្រីក្រក្នុងភូមិនៅពេលមានការលំបាក (បុណ្យសព ។ |
| ហេតុផលដែលនាំឱ្យអ្នកភូមិគាំទ្រ | សមាជិកសំខាន់ៗ នៃសហគមន៍ចូលរួមក្នុងសមាសភាពគណៈកម្មការ ប្រជាពលរដ្ឋជឿទុកចិត្តថាគណៈកម្មការនេះ ធ្វើការដើម្បីប្រជាពលរដ្ឋ និងបានឃើញលទ្ធផលល្អ មេភូមិគាំទ្រគណៈកម្មការនេះដោយចំហ ធ្វើការចែករំលែកការទទួលខុសត្រូវដល់គណៈកម្មការនេះ ។ | អ្នកភូមិទាំងអស់ជឿ និងទុកចិត្តលើការងាររបស់គណៈកម្មការនេះ ឃុំនេះមានទំហំតូច ហេតុនេះមានការងាយស្រួលក្នុងការធ្វើទំនាក់ទំនងគ្នា និងចែករំលែកព័ត៌មានរវាងគ្នា ប្រជាពលរដ្ឋរស់នៅទីនោះជាយូរមកហើយមានភាពវាងវៃនៅក្នុងមូលដ្ឋាន ។ |

*តារាងទី ១ : ការពិនិត្យមើលនូវគណៈកម្មការគ្រប់គ្រងធនធានចំនួនពីរ*

នៅក្នុងទីតាំងនីមួយៗ មានការគាំទ្រនយោបាយសមស្របសម្រាប់ការគ្រប់គ្រងដោយសហគមន៍ ។ ឧទាហរណ៍នៅកោះស្រឡៅអ្នកដឹកនាំគណៈកម្មការគ្រប់គ្រងធនធាន ក៏ជាសមាជិកនៃក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ ។ នៅកំពង់ភ្លុក សមាជិកមួយរូបនៃ ក្រុមប្រឹក្សាឃុំ-សង្កាត់បានដើរតួជាអ្នកផ្តល់យោបល់ដល់គណៈកម្មការគ្រប់គ្រងធនធាន ។ ទោះបីមានការគាំទ្រគោលនយោបាយ ជាលក្ខណៈផ្លូវការ ឬ ក្រៅផ្លូវការក្តី ( មិនទាន់មានការអនុម័តលើអនុក្រឹត្យ វាជាកត្តាមួយដែលនាំឱ្យការគ្រប់គ្រងដោយសហគមន៍បានទទួលជោគជ័យ ។ ការវិភាគបន្ថែមបង្ហាញថា ការគ្រប់គ្រងបែបនេះ ត្រូវទាមទារឱ្យមានការយោគយល់គ្នា និងជំនាញដោះស្រាយបញ្ហាពីសំណាក់គណៈកម្មការគ្រប់គ្រង ធនធានផ្ទាល់ដើម្បី ដឹកនាំការងារនេះ ។ ជាក់ស្តែងនៅកោះស្រឡៅ និងកំពង់ភ្លុក មានការប្រើប្រាស់យុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយ សកម្មភាពល្មើសច្បាប់ និងការថយចុះនៃធនធានរួមទាំងការបង្កើតប្រព័ន្ធគ្រប់គ្រងនៅមូលដ្ឋានដើម្បីធ្វើឱ្យមាន ការគាំទ្រការ បញ្ចុះបញ្ចូលឱ្យនគរបាល និងការិយាល័យបច្ចេកទេសចូលរួមជាមួយអ្នកភូមិនៅក្នុងសកម្មភាពល្បាត និងពង្រឹងការអនុវត្តច្បាប់ ការផ្សព្វផ្សាយវិន័យនិងបទបញ្ជា និងការបង្កើតបណ្តាញទំនាក់ទំនងក្នុងចំណោមអ្នក ភូមិដើម្បីគាំទ្រកិច្ចការរបស់ គណៈកម្មការគ្រប់គ្រងធនធាន ។

## ហេតុអ្វីត្រូវចូលរួមក្នុងការគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ?

អ្នកភូមិសម្រេចចូលរួមក្នុងគម្រោងគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ដោយសារមានហេតុផលជាច្រើន រួមទាំងខាងស្មារតី ( ដូចជា ការពារព្រៃក្បែរវត្ត ខាងនយោបាយ ( ដូចជា ប្រយោជន៍បុគ្គល ឬ កិត្យានុភាព ខាងប្រវត្តិសាស្ត្រ ( ពោលគឺប្រពៃណីគ្រប់គ្រងធនធានក្នុងភូមិ ខាងបរិស្ថាន ( ដូចជា បញ្ឈប់ការថយចុះនៃធនធានធម្មជាតិ ខាងសេដ្ឋកិច្ច ( ពោលគឺគេជឿថាកិច្ចការពារអាចនាំឱ្យមានកំណើនប្រាក់ចំណូលសម្រាប់អភិវឌ្ឍន៍សហគមន៍ និងខាងកសាងទំនាក់ទំនង ( ដូចជាម្ចាស់ជំនួយអាចជួយសម្របសម្រួល និងចរចាដើម្បីធ្វើការស្នើសុំក្នុងនាមអ្នកភូមិ ។ឧទាហរណ៍នៅកំពង់ភ្លុក អ្នកភូមិបានលើកទឹកចិត្តចូលរួមក្នុងការពារធនធានជាប្រពៃណី និងឆ្លើយតបចំពោះការទន្ទ្រានដីធ្វើចំការ និងការថយចុះនៃធនធាន ។

> *"អស់រយៈពេលជាយូរមកហើយ មុនពេលបង្កើតសហគមន៍នេសាទ ប្រជាពលរដ្ឋស្រលាញ់ និងថែរក្សាព្រៃឈើ ។ ប៉ុន្តែសហគមន៍ទាំងនោះ នៅពុំទាន់មានការគ្រប់គ្រងបានល្អឥតខ្ចោះនៅឡើយ ជាពិសេសនាពេលបច្ចុប្បន្ននេះ ។ ហេតុនេះវាជាពេលមួយសមស្របក្នុងការធ្វើការ [ជាមួយអង្គការមិន មែនរដ្ឋាភិបាល] ដើម្បីឱ្យអង្គការទាំងនោះជួយយើង ។ យើងចង់បញ្ឈប់ការរានដីដាំសណ្តែកសៀងនៅជិតឃុំរបស់យើង ហើយយើងត្រូវការឱ្យមានការគាំទ្រពីក្រៅ " (មនុស្សចាស់មួយរូប ២០០៣ ។*

ចំពោះបុរសចំណាស់រូបនេះ ដែលបានរស់នៅភូមិកំពង់ភ្លុកជិតមួយជីវិតហើយនោះ កិច្ចការពារព្រៃលិចទឹកមានន័យខ្លាំងណាស់ តាមប្រវត្តិនៃការគ្រប់គ្រងធនធាននៅកំពង់ភ្លុក ។ ចាស់ទុំមួយចំនួនរំលឹកឡើងវិញ អំពីការប្រឆាំងចំពោះការទន្ទ្រានយកដីភូមិរបស់ពួកគាត់ដើម្បីដាំឪឡឹក នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដោយទុកឱ្យព្រៃលិចទឹកនៅក្បែរភូមិរបស់គាត់អាចដុះលូតលាស់ឡើងវិញដោយខ្លួនឯង (Poffenberger, 2002) ។

ចំណែកឯបទពិសោធន៍នៅកោះស្រឡៅមានសភាពខុសគ្នា ។ អ្នកភូមិភាគច្រើនចូលមករស់នៅកោះស្រឡៅក្រោយសម័យនៃរបបខ្មែរក្រហម ដោយសង្ឃឹមថាអាចរកប្រាក់បានច្រើនពីការធ្វើអាជីវកម្មលើធនធានដ៏សម្បូរបែបនៅទីនោះ ។ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ធនធាននៅទីនោះមានភាពសម្បូរជាបង្គួរ ប៉ុន្តែថ្មីៗនេះ ធនធានបានថយចុះយ៉ាងឆាប់រហ័សនាំឱ្យមានឥទ្ធិពលធ្ងន់ធ្ងរដល់ជីវភាពរស់នៅក្នុងមូលដ្ឋាន ជាហេតុធ្វើឱ្យអ្នកភូមិត្រូវ "ធ្វើអ្វីមួយ" (Marschke, 2000) ។

នេះមិនមែនមានន័យថា អ្នកភូមិទាំងអស់នៅក្នុងឃុំទាំងពីរ គាំទ្រការងាររបស់គណៈកម្មការគ្រប់គ្រងធនធានយ៉ាងសកម្មនោះទេ ការចូលរួមរបស់អ្នកភូមិនៅតែស្ថិតនៅជាបញ្ហានៅឡើយ ។ ក្នុងសហគមន៍មួយមានកត្តាជាច្រើនដែលមានឥទ្ធិពលធ្វើឱ្យបុគ្គលនានាចូលរួមយ៉ាងសកម្ម ។ ឧទាហរណ៍ ស្ត្រីទំនងជាមានឱកាសតិចតួចដើម្បីចូលរួមក្នុងសកម្មភាពគ្រប់គ្រង ។ ក្នុងករណីផ្សេងទៀត អ្នកភូមិមិនអាចចំណាយពេលដោយស្ម័គ្រចិត្តសម្រាប់ការងារគ្រប់គ្រងធនធាន ឬ សកម្មភាពដទៃទៀតសម្រាប់សហគមន៍ឡើយ ។ សូមស្តាប់យោបល់របស់អតីតសមាជិកគណៈកម្មការគ្រប់គ្រងធនធានមួយរូប :

*"ឥឡូវនេះស្ថានភាពជីវភាពរបស់ខ្ញុំមិនសូវល្អឡើយ ។ ខ្ញុំត្រូវយកចិត្តទុកដាក់ថែទាំគ្រួសាររបស់ខ្ញុំជាបឋម ។ នៅពេលខ្ញុំមានការងារធ្វើដែល ខ្ញុំរកប្រាក់ចំណូលបានទៀងទាត់ និងធ្វើផ្ទះសម្រាប់គ្រួសារខ្ញុំរួចរាល់ហើយ ខ្ញុំអាចវិលត្រឡប់ទៅធ្វើការជាមួយគណៈកម្មការគ្រប់គ្រងធនធានវិញ ។ ការងារនោះទាមទារពេលវេលាច្រើន ហើយបច្ចុប្បន្នខ្ញុំបារម្ភអំពីគ្រួសារខ្ញុំណាស់" (អ្នកនេសាទមួយរូប ២០០៣ ។*

ប្រជាពលរដ្ឋពុំចាំបាច់ត្រូវតែចូលរួមយ៉ាងសកម្មក្នុងខណៈពេលដែលជីវភាពរស់នៅរបស់ពួកគេមានសភាពតានតឹងនោះទេ ។ ដោយសារមូលហេតុទាំងនេះ សមាជិកគណៈកម្មការគ្រប់គ្រងធនធាន ច្រើនតែជាអ្នកភូមិដែលមានជីវភាព សមរម្យ និងជាអ្នកមានឥទ្ធិពលនៅក្នុងភូមិ ។ ជាញឹកញាប់សមាជិកគណៈកម្មការមានបណ្តាញ និងទំនាក់ទំនងល្អយ៉ាងល្អដែលអាចគាំទ្រដល់ការងាររបស់ពួកគាត់បាន ។

## យុទ្ធសាស្ត្រគ្រប់គ្រងធនធានរបស់អ្នកភូមិ

*"ដោយសារឃុំរបស់យើងតូច យើងអាចធ្វើការជាមួយគ្នាដោយងាយស្រួល ។ ភូមិនីមួយៗទទួលខុសត្រូវការពារព្រៃឈើតាមផ្នែក ហើយយើងទាំងអស់គ្នាទទួលខុសត្រូវការពារព្រៃនៅជិតភូមិរបស់យើង" (អ្នកនេសាទមួយរូប ២០០៣ ។*

គណៈកម្មការគ្រប់គ្រងធនធាននៅកំពង់ភ្លុក ដឹងថាព្រៃនៅជិតឃុំរបស់ខ្លួនការពារពួកគាត់ពីកំលាំងខ្យល់ និងព្យុះ ។ បញ្ហាដែលគណៈកម្មការនេះព្យាយាមដោះស្រាយមានជាអាទិ៍ កិច្ចការពារព្រៃឈើ សកម្មភាពនេសាទល្មើសច្បាប់ ការថយចុះ

នៃធនធាន ការទន្ទ្រានយកដីធ្វើចំការ និងសកម្មភាពផ្សេងទៀតរបស់សហគមន៍។ យុទ្ធសាស្ត្រជាច្រើនត្រូវបានប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ដែលយុទ្ធសាស្ត្រខ្លះមានប្រសិទ្ធិភាពជាងយុទ្ធសាស្ត្រផ្សេងទៀត ឧទាហរណ៍ សកម្មភាពល្បាតអាចជាដំណោះស្រាយឱ្យឃើញច្បាស់ថា អាចបញ្ឈប់សកម្មភាពល្មើសច្បាប់នៅជិតសហគមន៍ តែសកម្មភាពល្បាតត្រូវចំណាយច្រើន (ដូចជាថ្លៃប្រេងឥន្ធនៈ ដែលសហគមន៍ពុំមានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីធ្វើសកម្មភាពល្បាតជាទៀងទាត់បានឡើយ ប្រថុយគ្រោះថ្នាក់ច្រើន (អាចបណ្ដាលឱ្យមានទំនាស់ និងលំបាកចាត់ចែង (ដូចជាខ្វះការគាំទ្របច្ចេកទេសឱ្យបានទៀងទាត់ ។សមាជិកគណៈកម្មការគ្រប់គ្រងធនធានពិតជាបានចូលរួមក្នុងសកម្មភាពល្បាតជាមួយនគរបាល និងបុគ្គលិកបច្ចេកទេស ហើយពួកគេក៏ផ្ដោតផងដែរលើការបង្កើតបណ្ដាញទាក់ទងនៅក្នុងភូមិ និងនៅក្រៅភូមិ ដើម្បីពង្រឹងការអនុវត្តរបស់ខ្លួន និងការអនុវត្តរបស់ឃុំ ឬស្រុកនៅជុំវិញ។ នៅតំបន់ដទៃទៀត ក្នុងពិភពលោក ការកៀរសង្គត់ពីសាធារណជនមួយក្រុម អាចមានប្រសិទ្ធិភាពដើម្បីឱ្យមានការគោរពវិន័យ និងបទបញ្ញ ។ តារាងទី២ គូសបញ្ជាក់អំពីបញ្ហាខ្លះៗ និងយុទ្ធសាស្ត្រនានា ដែលគណៈកម្មការគ្រប់គ្រងធនធានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាទាំងនោះ ។

| បញ្ហានៃការគ្រប់គ្រង | យុទ្ធសាស្ត្រនៃការគ្រប់គ្រង |
| --- | --- |
| ការកាប់ព្រៃលិចទឹក | គណៈកម្មការដឹកនាំអ្នកភូមិឱ្យគ្រប់គ្រងតំបន់ព្រៃឈើមួយចំនួន ធ្វើសេចក្ដីរាយការណ៍អំពីសកម្មភាពល្មើសច្បាប់នានា ទៅគណៈកម្មការនេះ ហើយបន្ទាប់មកចុះធ្វើការស៊ើបអង្កេត និងព្យាយាមដោះស្រាយបញ្ហានេះ (បើអាចធ្វើបាន ។ |
| ឧបករណ៍នេសាទល្មើសច្បាប់ (ឈិបយន្ត<br>ការនេសាទដោយភ្លើងអគ្គិសនី<br>របាំងព្រួលវែង<br>និងការលួចឧបករណ៍នេសាទ | សកម្មភាពល្បាត និងផាកពិន័យចំពោះការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់<br>ពិភាក្សាជាមួយសហគមន៍ផ្សេងអំពីវិន័យ និងបទបញ្ញារបស់ឃុំកំពង់ភ្លុក<br>សមាជិកសហគមន៍ធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការសហគមន៍<br>ដើម្បីបញ្ឈប់សកម្មភាពល្មើសច្បាប់ និងតាមដានការនេសាទរបស់សហគមន៍ខ្លួន ។ |
| ការស្រុតចុះនៃធនធាន | បង្កើតដែនបម្រុងទំហំ ១គ.ម² អប់រំប្រជាពលរដ្ឋអំពីវិន័យ និងបទបញ្ញា លើកទឹកចិត្តឱ្យអ្នកភូមិស្រង់យកតែអុសអណ្ដែតទឹក និងកាប់អុសនៅព្រៃក្រៅគ្រប់អាយុដែលមានដើមឈើ ធំៗ ។ |
| ការទន្ទ្រានយកដីធ្វើចំការ | ធ្វើការជាមួយអាជ្ញាធរខេត្ត និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដើម្បីបញ្ឈប់ការទន្ទ្រានជាបន្ថែម ។ |
| សកម្មភាពផ្សេងទៀត | គាំទ្រអ្នកក្រីក្រក្នុងភូមិ នៅពេលមានការលំបាក ។ |

*តារាងទី ២ : ឧទាហរណ៍មួយអំពីយុទ្ធសាស្ត្រនានា នៃការគ្រប់គ្រងភូមិនៅកំពង់ភ្លុក*

អ្នកនេសាទខ្នាតតូចភាគច្រើនដែលជាជនជាតិកម្ពុជា បានប្រឈមបញ្ហាដូចគ្នា : ការថយចុះនៃធនធាន និងការលួចឧបករណ៍នេសាទ ។ លើសពីនេះ ការលួច និងការខូចខាតឧបករណ៍នេសាទនាំឱ្យមានទំនាស់ទាំងនៅក្នុងចំណោមអ្នកភូមិ និងជាមួយអ្នកដែលប្រើប្រាស់កន្លែងនេសាទជាមួយគ្នា ។ ឧទាហរណ៍ នៅកោះស្រឡៅ មានការលួចលបក្ដាមជាញឹកញាប់ ភាគច្រើនដោយអ្នកនេសាទមកពីក្រៅសហគមន៍ ប៉ុន្តែជួនកាលក៏កើតមានដោយសារអ្នកភូមិខ្លួនឯងផងដែរ ។ក្រោយពីមានការបំផុសឱ្យមាន

ការពិភាក្សាជាច្រើនលើកមក  គណៈកម្មការគ្រប់គ្រងធនធានបានសម្រេចបង្កើតប្រព័ន្ធមួយដើម្បីឱ្យអ្នកភូមិអាចចំណាំលបក្តាមរបស់ខ្លួនបានងាយស្រួលជាមុន ។ សមាជិកមួយរូបនៃគណៈកម្មការគ្រប់គ្រងធនធានបានពន្យល់បន្ថែមថា :

> *"ក្រោយពិភាក្សាជាច្រើនលើក យើងមានគំនិតមួយ ។ ក្រុមនីមួយៗ (ក្នុងចំណោមក្រុមទាំង៨ នៅក្នុងភូមិ ត្រូវធ្វើសញ្ញាសំគាល់លបក្តាម របស់ខ្លួនឱ្យមានពណ៌ដូចគ្នា ។ ទន្ទឹមនឹងប្រើប្រាស់ពណ៌បែបនេះ បន្ទាប់ម្ចាស់លបក្នុងក្រុមនីមួយៗមានសញ្ញាដោយឡែករៀងខ្លួន ពោលគឺគូសសញ្ញាបន្ទាត់ទ្រេតតាមទិសណាមួយ ដែលបង្ហាញថា លបទាំងនោះជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ ។ មកទល់ពេលនេះ ការលាបពណ៌លើលបក្តាម គឺជាដំណោះស្រាយ ល្អមួយសម្រាប់កាត់បន្ថយករណីលួចលបក្តាម ។ នៅពេលដែលឃើញថា អ្នកណាម្នាក់បានយកលបក្តាមដែលមានពណ៌មិនមែនជារបស់ខ្លួន អ្នកនោះត្រូវ ទទួលការផាកពិន័យ ឬមួយត្រូវសងលបក្តាមថ្មីទៅឱ្យម្ចាស់ដើមវិញ ។ យើងពុំអាចដោះស្រាយបានគ្រប់បញ្ហាទាំងអស់បានទេ ប៉ុន្តែធ្វើបែបនេះ អាចជួយដោះស្រាយបានច្រើន"(២០០៣) ។*

ជាទូទៅអ្នកភូមិរីករាយចំពោះដំណោះស្រាយនេះណាស់ អ្នកនេសាទម្នាក់ឱ្យយោបល់ថា *"ឆ្នាំនេះខ្ញុំបាត់តិចជាងឆ្នាំទៅ ហើយឥឡូវខ្ញុំអាចដេក ផ្ទះនៅពេលយប់ ដោយខ្ញុំពុំបារម្ភអំពីការទុកលបនៅឆ្ងាយពីខ្លួនទេ"*។ដំណោះស្រាយនេះផ្តល់សន្តិសុខខ្លះៗសម្រាប់អ្នកនេសាទ  ហើយអ្នកភូមិធ្វើការជាមួយគ្នា  ដើម្បីសង្កេតមើលទូកនានាដែលពួកគេពុំស្គាល់  ។  ទោះបីកន្លងមកនេះមានករណីបាត់លបក្តាមក៏ដោយ  អ្នកភូមិមានអារម្មណ៍ថា  ករណីលួចលបក្តាមបានថយចុះ  ហើយករណីរកឃើញលបក្តាមដែលលួចមកវិញបានច្រើនជាងមុន  ។  នេះជាឧទាហរណ៍មួយបែបអំពីការផ្តួចផ្តើមដោះស្រាយបញ្ហានៅមូលដ្ឋានដែលចូលរួមដោយគណៈកម្មការគ្រប់គ្រងធនធាន ។

នៅកំពង់ភ្លុក និងកោះស្រឡៅ យុទ្ធសាស្ត្រគ្រប់គ្រងមួយផ្សេងទៀត គឺការបង្កើតដែននេសាទបំរុងទុកនៅក្នុងព្រៃប្រទល់នៃតំបន់គ្រប់គ្រងរបស់សហគន៍ ។ ដែននេសាទធំបង្គួរ ដូចជាកន្លែងត្រីពងកូន ត្រូវបានកំណត់ដើម្បីការពារយ៉ាងតឹងរ៉ឹង ។ ដូចអ្នកនេសាទមួយរូបបានកត់សម្គាល់ថា*"កន្លែងនេសាទបំរុងទុករបស់យើងស្ថិតនៅជិតកន្លែងនេសាទរបស់យើង  ដូច្នេះនេះជាភាពងាយស្រួលសម្រាប់យើងដើម្បីការពារកន្លែងនោះ ។ ឥឡូវនៅកន្លែងនោះមានត្រីច្រើនណាស់ ហើយប្រការនេះធ្វើឱ្យយើងយល់ថា យើងត្រូវការកន្លែងបន្ថែមទៀត ដើម្បីការពារមច្ឆាជាតិ"*  ។  អ្នកនេសាទខ្លួនឯងរួមជាមួយអាជ្ញាធរមូលដ្ឋាន អាចតាមដានពិនិត្យអំពីអ្វីដែលកំពុងកើតមាន ។ ជាការពិតណាស់ ប្រសិនបើអ្នកនេសាទទ្រង់ទ្រាយធំពុំគោរពវិន័យនៅមូលដ្ឋាន ពួកគេត្រូវការឱ្យមានជំនួយ  និងការគាំទ្របច្ចេកទេសពីក្រៅបន្ថែមទៀត  ដើម្បីដោះស្រាយបញ្ហានេះ  ។  គណៈកម្មការគ្រប់គ្រងធនធានទទួលស្គាល់ថា ពួកគេពុំអាចដោះស្រាយបញ្ហាទាំងអស់បានឡើយ ប៉ុន្តែតាមរយៈគំនិតច្នៃប្រឌិត ពួកគេអាចដោះស្រាយបញ្ហាខ្លះៗបាន ។

### បទពិសោធន៍

ការស្រាវជ្រាវដែលបានធ្វើឡើងអំពីគណៈកម្មការគ្រប់គ្រងធនធាននៅកំពង់ភ្លុក  និងកោះស្រឡៅ  បានគូសបញ្ជាក់អំពីដំណើរការដែលការគ្រប់គ្រងដោយសហគមន៍បានវិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន ។ អ្នកភូមិមានការព្រួយបារម្ភអំពីព្រៃឈើ និងដែន

នៃសាទរបស់ខ្លួន ក៏ដូចជាអំពីបញ្ហាផ្សេងទៀតនៅកម្រិតសហគមន៍ផងដែរ ។ គណៈកម្មការធនធាននេះយល់ឃើញថា ការងាររបស់ខ្លួនមានអត្ថប្រយោជន៍ក្នុងការបង្កើនជីវភាពរបស់សហគមន៍ ហើយពួកគេមានឆន្ទៈក្នុងការដកពិសោធន៍តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រនានា ។

អ្នកភូមិក៏យល់ផងដែរថាពួកគេបានទទួលលទ្ធផលជាផ្លែផ្កាពីការងាររបស់ខ្លួន : ចំនួនលបក្តាមដែលត្រូវគេលួចបានថយចុះ ព្រៃឈើកាន់តែដុះក្រាសជាងមុន ការទន្រ្ទានដីធ្វើចំការមានអត្រាទាបជាងមុន ហើយអ្នកភូមិកាន់តែមានកិច្ចសហការជិតស្និទ្ធជាងមុន ។

> *"យើងដឹងថាគណៈកម្មការគ្រប់គ្រងធនធាននឹងជួយយើង ។ ពួកគេបានបង្រៀនយើងអំពីវិធីដាំព្រៃកោងកាងឡើងវិញ និងអំពីកិច្ចការពារធនធានរបស់យើង ។ ឆ្នាំនេះនៅក្បែរព្រៃកោងកាងមានក្តាមច្រើនជាងមុន ហើយឥឡូវយើងយល់ពីទំនាក់ទំនងរវាងព្រៃកោងកាង និងផលនេសាទ" (អ្នកនេសាទមួយរូប ២០០៣ ។*

ទោះបីគ្មានទិន្នន័យគោលដើម្បីផ្ទៀងផ្ទាត់ជាមួយការយល់ឃើញរបស់អ្នកភូមិអំពីកំណើនធនធានក្តី ប៉ុន្តែប្រការសំខាន់គឺអ្នកភូមិជឿជាក់លើការងារបែបនេះ ។

កត្តាសំខាន់មួយផ្សេងទៀតចំពោះជោគជ័យរបស់គណៈកម្មការគ្រប់គ្រងធនធានទាំងពីរនេះ គឺការគាំទ្រពីក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ភាពជាអ្នកដឹកនាំ រួមទាំងឆន្ទៈប្រថុយគ្រោះថ្នាក់ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ណាស់ក្នុងការប្រមូលផ្តុំ និងការគាំទ្រពីសំណាក់សហគមន៍មូលដ្ឋាន ។ អ្នកដឹកនាំនៃគណៈកម្មការគ្រប់គ្រងធនធានទាំងពីរ បានទទួលការគោរពកោតសសើរនៅក្នុងភូមិរបស់ពួកគេ ហើយទំនងជាមានឥទ្ធិពលនៅក្នុងសហគមន៍របស់ពួកគេទៀតផង ។ ប្រសិនបើពុំមានការប្តេជ្ញា និងការគាំទ្រទេ គណៈកម្មការគ្រប់គ្រងធនធានទាំងនេះប្រហែលជាពុំអាចទទួលជោគជ័យបានឡើយ ។

គណៈកម្មការគ្រប់គ្រងធនធានមានវិធានការណ៍ដែលអាចបត់បែនបាន ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងនៅក្នុងសហគមន៍ ។ គ្មានគណៈកម្មការណាមួយដែលអនុវត្តដាច់ខាតតាមអាណត្តិរបស់ខ្លួនឡើយ ដោយទទួលស្គាល់ថាពួកគេមានលទ្ធភាព ដើម្បី ដោះស្រាយជុំវិញបញ្ហានានាក្នុងសហគមន៍ ទោះជាបញ្ហាបរិស្ថាន ឬ សង្គមក្តី ។ ឧទាហរណ៍ៈ ថ្មីៗនេះអ្នកភូមិបានបញ្ជូនស៊ីម៉ងតិ៍ ដើម្បីសង់កុដិមួយនៅក្នុងវត្ត សម្រាប់ប្រើប្រាស់ជាកន្លែងប្រជុំរបស់សហគមន៍នៅចង្កេះភ្នំនៃកោះស្រឡៅតាមសំណើរបស់គណៈកម្មការគ្រប់គ្រងធនធាន ។ ក្នុងន័យនេះការគ្រប់គ្រងធនធាន គឺជាយានចម្លងសម្រាប់គណៈកម្មការទាំងនេះដើម្បីដោះស្រាយបញ្ហានានាក្នុងសហគមន៍ ។

សេចក្តីព្រាងច្បាប់កំពុងត្រូវបានរៀបចំសម្រាប់គាំទ្រកិច្ចផ្តួចផ្តើមនៅកំរិតសហគមន៍ ប៉ុន្តែសំនួរជាគន្លឹះបានចោទថា តើត្រូវអនុវត្តគោលនយោបាយបែបណាទើបបានផលប្រសើរបំផុតសម្រាប់បម្រើផលប្រយោជន៍របស់អ្នកភូមិ ជាពិសេសសម្រាប់អ្នកដែលពុំអាចបែងចែកធនធានរបស់ខ្លួនទៅតាមវិស័យ (ឧទាហរណ៍: ព្រៃឈើ ជលផល ? ប្រការចាំបាច់គឺត្រូវឱ្យមានការសិក្សាវាយតម្លៃបន្ថែមថាតើគោលនយោបាយផ្អែកលើសហគមន៍មូលដ្ឋានត្រូវបានធ្វើកំណត់បែបណា នៅក្នុងច្បាប់ និងកម្មវិធីនានា (ឧទាហរណ៍: អនុក្រឹត្យស្តីពីសហគមន៍នេសាទ អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ច្បាប់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល កម្មវិធីអភិបាលកិច្ចនៅមូលដ្ឋាន ។ល។ ហើយថាតើគោលនយោបាយ អាចគាំទ្រការងារនៅថ្នាក់ភូមិបានយ៉ាងណា ជាជាងការណែនាំឱ្យមានការបែងចែកតាមរយៈការបង្កើតគណៈកម្មការជាច្រើនដើម្បីធ្វើការងារស្រដៀងគ្នាដដែលៗ ។ ដូចដែលបានបង្ហាញតាមរយៈ បទពិសោធន៍នានានៅកំពង់ភ្លុក និងកោះស្រឡៅ ការគ្រប់គ្រងដោយសហគមន៍អាចកើតឡើងតាមរូបភាពជាច្រើនបែប ។ ការបង្កើតវិធីសាស្ត្រដែលអាចបត់បែនបានដែលគាំទ្រការសិក្សាដែលមានលក្ខណៈច្នៃប្រឌិត និងកាលានុវត្តន៍ភាពសម្រាប់ដោះស្រាយបញ្ហា គឺជាការលំបាកមួយសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាននៅមូលដ្ឋាន ។

## REFERENCES


Marschke, M. (Ed). 2000. *Mangrove Meanderings: Life in Peam Krasaop Wildlife Sanctuary.* Phnom Penh: Ministry of Envirnment / International Development Research Centre.

McKenney, B. and Prom, T. 2002. *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment.* Phnom Penh: Cambodia Development Resource Institute. Working Paper No. 23.

PMMR. 2003. *Internal Evaluatin of VMCs in koh Kong.* Phnom Penh: CBNRM LeaRN/ PMMR-Ministry of Environment.

Poffenberger, M. 2002. *Transitions to Community Resource Management around the Great Lake, Tonle Sap, Cambodia.* Draft case study. Siem Reap: Participatory Natural Resource Management in the Tonle Sap Region, FAO-Siem Reap and the Community Forest Management Support Program for Southeast Asia.

# សន្ទានុក្រម

**ជីវៈចម្រុះ :** ជាសារពាង្គកាយដែលមានប្រភពមកពីស្ថានប្រព័ន្ធដែនដីគោក ទឹក សមុទ្រដោយរួមបញ្ចូលប្រព័ន្ធអេកូឡូស៊ី ដែលសារពាង្គកាយទាំងនោះស្ថិតនៅក្នុងនោះរួមមានភាពចម្រុះនៃប្រភេទ (Species) និងរវាងប្រភេទនៃស្ថានប្រព័ន្ធទាំងនោះ ។

**ច្បាប់ :** ជាអត្ថបទផ្លូវការដែលអនុម័តដោយសភាជាតិ ( សភាជាន់ទាប  និងព្រឹទ្ធសភា ( សភាជាន់ខ្ពស់   ។

**សារាចរ :** ជាបរិធានច្បាប់ចេញដោយនាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីសម្រាប់ធ្វើការពន្យល់ ឬ បំភ្លឺវិធានការណ៍ច្បាប់បទ-ប្បញ្ញត្តិជាក់លាក់ ឬ ផ្តល់ការណែនាំ ។

**កិច្ចសហការគ្រប់គ្រងព្រៃឈើ-កិច្ចសហការគ្រប់គ្រងធនធានធម្មជាតិ-សហគ្រប់គ្រង :** សំដៅដល់ភាពជាដៃគូដែលនៅក្នុងនោះអ្នកពាក់ព័ន្ធនានា  ឯកភាពលើការចែករំលែកមុខងារគ្រប់គ្រងសិទ្ធិ  និងកម្មសិទ្ធិផលចំណូល  និងការទទួលខុសត្រូវលើតំបន់មួយនៃព្រៃឈើ  ។ ជាធម្មតាអ្នកពាក់ព័ន្ធទាំងនោះមានជាអាទិ៍ ភ្នាក់ងារដែលមានចំណាប់អារម្មណ៍លើធនធាន និងសមាគមរបស់អ្នករស់នៅក្នុងមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចតាមបែបប្រពៃណី ម្ចាស់ឧស្សាហកម្ម អ្នកជំនួញ វិទ្យាស្ថានស្រាវជ្រាវ និងភ្នាក់ងារផ្សេងទៀត ។

**សហគ្រប់គ្រង :** ជា "ដំណើរការដែលចាត់ចែងឡើងជាផ្លូវការ និងអាចពង្រីកទៅកន្លែងដទៃ នៃការចែករំលែក សមត្ថកិច្ច និងការទទួលខុសត្រូវរវាងរដ្ឋាភិបាល  និងក្រុមអ្នកប្រើប្រាស់ដែលបានបង្កើតឡើងក្នុងការធ្វើសេចក្តីសម្រេចតាមបែបវិមជ្ឈការ សំដៅកែលំអការគ្រប់គ្រងធនធាន" ។

**ក្រុមប្រឹក្សាឃុំ-សង្កាត់ :** ជាសមត្ថកិច្ចរដ្ឋបាលនៅថ្នាក់ទាបបំផុត ដែលកើតឡើងពីការបោះឆ្នោត និងដែលមានអំណាចកសាងផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។  តួនាទីពិតប្រាកដរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាក់ទងនឹង សមត្ថកិច្ចបែបនេះនៅពុំទាន់បញ្ជាក់បានច្បាស់ទាំងស្រុងនៅឡើយទេ ។

**សហគមន៍ :** សំដៅលើក្រុមប្រជាពលរដ្ឋក្នុងឃុំមួយ  ឬ  ច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា  និងជាអ្នកដែលមានផលប្រយោជន៍រួមខាងសង្គម  បរិស្ថាន  វប្បធម៌  ប្រពៃណី  និងសេដ្ឋកិច្ច  និងជាអ្នកប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពក្នុងតំបន់មួយ ( ក្នុងកន្លែង ឬ ក្បែរកន្លែងដែលពួកគេរស់នៅ  សម្រាប់ទ្រទ្រង់ និងលើកកំពស់ជីវភាពរស់នៅរបស់ពួកគេ ។

**សហគមន៍អេកូ-ទេសចរណ៍ (CBET) :** បានអនុវត្តនៅកន្លែងដែលប្រជាពលរដ្ឋមូលដ្ឋាន  មានអំណាចច្រើនក្នុងការត្រួតត្រា និងពាក់ព័ន្ធនៅក្នុងគម្រោងអេកូ-ទេសចរណ៍ ដើម្បីធានាថាផលប្រយោជន៍ភាគច្រើនបានពីគម្រោងត្រូវប្រើប្រាស់នៅក្នុងសហគមន៍ដែលបានអនុវត្តគម្រោងនោះ ។

**ការគ្រប់គ្រងព្រៃឈើដោយសហគមន៍ :** សំដៅលើការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន  ឬ ជាមួយសហគមន៍

មូលដ្ឋានដែលរួមបញ្ចូលទាំងការគ្រប់គ្រងព្រៃឈើតាមបែបប្រពៃណីផងដែរ ។ ការគ្រប់គ្រងបែបនេះមានទាំងកិច្ចផ្តួចផ្តើមគ្រប់គ្រងព្រៃឈើ ដែលចាត់ចែងដោយសហគមន៍ផ្ទាល់នៅក្នុងសហគមន៍ព្រៃឈើ ឬ នៅក្នុងព្រៃឈើក្រោមការគ្រប់គ្រងរបស់សាលាក្រុងដែលអាចមានការចែករំលែកកម្មសិទ្ធិជាមួយរដ្ឋ និងជារបៀបគ្រប់គ្រងតាមរយៈកិច្ចសហការរវាងរដ្ឋ និងអង្គការសហគមន៍ ។

**ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ :** ជាវិធីសាស្ត្រជាច្រើននៃសហគ្រប់គ្រងដែលពង្រឹងអំណាចសហគមន៍មូលដ្ឋានឱ្យចូលរួមយ៉ាងសកម្មភាពក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តភាព តាមរយៈយុទ្ធ-សាស្ត្រនានា រួមមានសហគមន៍ព្រៃឈើ សហគមន៍នេសាទ ការចូលរួមកសាងផែនការប្រើប្រាស់ដីធ្លី និងសហគមន៍គ្រប់គ្រងតំបន់ការពារធម្មជាតិ ។

**សហគមន៍នេសាទ :** សំដៅលើ " ក្រុមមួយនៃប្រជាពលរដ្ឋដែលសហការគ្នាដោយស្ម័គ្រចិត្តដើម្បីគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព" ។ សហគមន៍នេះការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋអនុលោមតាមបទបញ្ជានានាទាក់ទងនឹងវិស័យជលផល ។

**សហគមន៍ព្រៃឈើ :** ជាពាក្យដែលមានន័យទូលំទូលាយដោយរួមបញ្ចូលប្រព័ន្ធនានានៃការគ្រប់ព្រៃឈើដោយសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាកម្មវិធីនានា ដែលផ្តួចផ្តើមដោយសហគមន៍ ឬ រដ្ឋាភិបាល ។ បច្ចុប្បន្នពាក្យ សហគមន៍ព្រៃ-ឈើត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការសំដៅលើទម្រង់ផ្សេងៗនៃការគ្រប់គ្រងព្រៃឈើដែលផ្អែកលើប្រជាពលរដ្ឋ ។

**ការរៀបចំសហគមន៍ :** ជាដំណើរការមួយនៃការពង្រឹងអំណាចសហគមន៍ដោយខ្លួនឯងតាមរយៈការងារជាក់ស្តែងដើម្បីកំណត់តម្រូវការរបស់ខ្លួន និងដោះស្រាយបញ្ហារបស់ខ្លួនជាសមូហភាព ។

**សហគមន៍គ្រប់គ្រងតំបន់ការពារធម្មជាតិ :** ត្រូវបានស្គាល់ថាជាការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួមដែលជាដំណើរការមួយ សំដៅសម្រេចឱ្យបានស្ថានភាពឈ្នះ-ឈ្នះ ដែលផ្តល់ការអនុគ្រោះដល់អ្នកគ្រប់គ្រងធនធានក្នុងការសម្រេចគោលបំណងអភិរក្សជីវៈចម្រុះ និងដល់អ្នកប្រើប្រាស់ធនធានក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងរក្សាតម្លៃវប្បធម៌ និងជំនឿ ។

**ដីកា :** ជាបទបញ្ជាចេញដោយអភិបាលខេត្ត ឬ ក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលមានអំណាចច្បាប់នៅក្នុងព្រំប្រទល់រដ្ឋបាលនៃដែនដីរបស់ខ្លួន ។

**អេកូ-ទេសចរណ៍ :** សំដៅដល់ដំណើរកំសាន្តប្រកបដោយភាពទទួលខុសត្រូវនៅក្នុងតំបន់ធម្មជាតិដែលមានលក្ខណៈអភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

**ព្រៃឈើកសិដ្ឋាន :** សំដៅលើការដាំព្រៃឈើធ្វើឡើងដោយកសិករលើដីឯកជន ដែលច្រើនតែធ្វើឡើងជាក្រុមសហគមន៍

សំដៅរួបរួមគ្នាក្នុងបំណងសម្របសម្រួលការលក់ផលព្រៃឈើ កែច្នៃ និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

**ធនធានហិរញ្ញវត្ថុ :** សំដៅធនធានហិរញ្ញវត្ថុដែលប្រើប្រាស់សម្រាប់សម្រេចគោលបំណងនៃជីវភាពរស់នៅ។ ធនធានទាំងនេះអាចរាប់បញ្ចូល ប្រាក់សន្សំ ប្រាក់ចំណូលទៀងទាត់ ឬ សោធននិវត្តន៍ ឬ ប្រាក់កម្ចី ឬ ឥណទាន និងប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ ដីធ្លី សត្វចិញ្ចឹម ឬ គ្រឿងអលង្ការ ។

**ក្រុមការងារសម្របសម្រួលផ្នែកជលផល :** គោលបំណងចម្បងនៃក្រុមការងារនេះ គឺគាំទ្រ និងសម្របសម្រួល ការរៀបចំច្បាប់ជលផល សេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ គោលការណ៍ណែនាំ និងការរៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹងការអភិវឌ្ឍផ្នែកវិស័យជលផល ។

**កំណែទម្រង់គោលនយោបាយវិស័យជលផល :** ការកាត់ចេញដែនឡូតិ៍នេសាទប្រមាណ ៥៦% ដែលស្ថិតនៅក្រោមការនេសាទជាលក្ខណៈពាណិជ្ជកម្មទៅជាដែននេសាទសហគមន៍ ជាការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះកំណើនភាពតានតឹងរវាងអ្នកកាន់កាប់ឡូតិ៍នេសាទ និងសហគមន៍អ្នកនេសាទក្រីក្រ នៅមូលដ្ឋាន ។

**អភិបាលកិច្ច :** ជាទូទៅសំដៅលើស្ថាប័ននៃសង្គមមនុស្ស ដែលធ្វើការរួមគ្នាដើម្បី "គ្រប់គ្រង" កិច្ចការសាធារណៈ ។ អភិបាលកិច្ចពាក់ព័ន្ធនឹង ដំណើរការមួយ ( ឬច្រើន ដែលតាមរយៈដំណើរការនោះ អង្គភាពដឹកនាំត្រូវបានជ្រើសរើស ដាក់ឱ្យទទួលខុសត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងត្រូវផ្លាស់ប្តូរ និងទទួលការជ្រើសរើស។ សមត្ថភាពរបស់ស្ថាប័នដឹកនាំនៅក្នុងការគ្រប់គ្រងធនធានឱ្យមានប្រសិទ្ធិភាពមានជាអាទិ៍ ការបង្កើត និងអនុវត្តគោលនយោបាយ ( គោលបំណង និងបទបញ្ជា ( លក្ខន្តិកៈ ពង្រឹងការអនុវត្តច្បាប់ និងរក្សាសណ្តាប់ធ្នាប់ ព្រមទាំងការបង្កើតលក្ខខណ្ឌចាំបាច់ សម្រាប់ធានាស្ថេរភាពសង្គម និង សេដ្ឋកិច្ច និងការផ្តល់សុពលភាពជាប្រចាំសម្រាប់ស្ថាប័ននានា នៅក្នុងក្របខ័ណ្ឌនៃសង្គមកិច្ច ។

**គោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល :** កម្មវិធីសិលារបស់រាជរដ្ឋាភិបាល បានជួយកសាងសមត្ថភាពសម្រាប់កសាងផែនការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ ដើម្បីឱ្យការធ្វើសេចក្តីសម្រេចភាគច្រើនបានអនុវត្តនៅថ្នាក់ឃុំ ដែលនៅទីនោះគណៈកម្មការអភិវឌ្ឍន៍ឃុំ-សង្កាត់ ធ្វើសេចក្តីសម្រេចលើ សកម្មភាពនៅមូលដ្ឋាន និងចាត់ចែងថវិកាឱ្យបានសមស្រប ។

**ធនធានមនុស្ស :** រួមមានជំនាញ ចំណេះដឹង និងបទពិសោធន៍ ក៏ដូចជាទេពកោសល្យក្នុងការងារ និងសុខភាពល្អផងដែរ ។

**វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស :** ឈរលើគោលការណ៍គោរពសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិ និងសេរីភាពជាមូលដ្ឋាន។ វិធីសាស្ត្រនេះទទួលស្គាល់ថា អ្នកដែលផលប្រយោជន៍របស់ខ្លួនអាចទទួលរងការខូចខាតត្រូវតែយល់ដឹងអំពីសិទ្ធិមនុស្ស ។

**សហគមន៍ជនជាតិដើមភាគតិច :** ជា "ក្រុមកុលសម្ព័ន្ធដែលមានលក្ខខណ្ឌ សង្គម វប្បធម៌ និងសេដ្ឋកិច្ចផ្សេងពីសហគមន៍ផ្សេងទៀតនៅក្នុងប្រទេស និងមានអត្តសញ្ញាណប្លែកគ្នាទាំងស្រុង ឬ ផ្នែកខ្លះទាក់ទងនឹងទំនៀមទម្លាប់ ឬ ប្រពៃណីរបស់ខ្លួន ឬ មានការកំណត់ក្រោមច្បាប់ ឬ បទប្បញ្ញត្តិពិសេស" ។

**ការគ្រប់គ្រងព្រៃឈើរួមគ្នា ៖** ការចែករំលែកផលិតផល និងការទទួលខុសត្រូវរួមគ្នា រវាងនាយកដ្ឋានរុក្ខា-ប្រមាញ់ និងក្រុមអ្នកប្រើប្រាស់ ។ ការងារនេះ ពាក់ព័ន្ធនឹងកិច្ចសន្យាកំណត់ពីសមត្ថកិច្ច ការទទួលខុសត្រូវ និងការបែងចែកផលរវាងអ្នកភូមិ និង អង្គភាពគ្រប់គ្រងព្រៃឈើរបស់រដ្ឋ។ ការគ្រប់គ្រងបែបនេះមានប្រភពដើមពីចំការព្រៃឈើ នៅលើចំណែកដីរបស់រដ្ឋ នៅប្រទេសឥណ្ឌា ប៉ុន្តែបច្ចុប្បន្នពាក្យនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ។

**ការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន ៖** បណ្តាសកម្មភាពរបស់ប្រជាពលរដ្ឋដែលរស់ក្បែរតំបន់ព្រៃឈើមួយកន្លែងដើម្បីថែរក្សា ឬ បង្កើនគុណភាពព្រៃឈើ និងកែលំអសុខុមាលភាពរបស់ខ្លួន ។ មានការសន្មតថា ប្រជាពលរដ្ឋមូលដ្ឋានជួយបង្កើននិរន្តរភាពព្រៃឈើ បង្កើតឱ្យមានការបែងចែកផល រក្សាអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងធនធាន និងចូលរួមក្នុងការដោះស្រាយតម្រូវការដែលមានលក្ខណៈប្រកួតប្រជែងតាមវិធីដែលកាត់បន្ថយទំនាស់ និងបង្កើនប្រសិទ្ធិភាពជាអតិបរមា ។

**ការចិញ្ចឹមជីវិត ៖** រួមបញ្ចូល សមត្ថភាព ទ្រព្យសម្បត្តិ (រួមទាំងធនធានសង្គម និងសម្ភារៈ និងសកម្មភាពចាំបាច់សម្រាប់ជាមធ្យោបាយ ទ្រទ្រង់ការរស់នៅ ។

**លទ្ធផលនៃការចិញ្ចឹមជីវិត ៖** ជាលទ្ធផលនៃយុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិត និងរួមបញ្ចូលកំណើនសុខុមាលភាព ប្រាក់ចំណូល ភាពមានការងារធ្វើ ចំណងទាក់ទងខាងសេដ្ឋកិច្ច សុខភាពមនុស្ស និងបរិស្ថាន ការបង្កើន និងការផ្លាស់ប្តូរចំណេះដឹង ការថយចុះនៃភាពងាយរងគ្រោះ ហានិយភ័យ និងអស្ថេរភាពព្រមទាំងបទពិសោធន៍ប្រកបដោយផ្លែផ្កាក្នុងជីវិត ។

**ធនធាននៃការចិញ្ចឹមជីវិត ៖** សំដៅដល់វត្តមាននៃទ្រព្យសម្បត្តិ សមត្ថភាព និងសិទ្ធិអំណាច សម្រាប់កសាងជីវភាពរស់នៅ ។

**យុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិត ៖** ជាបណ្តុំនៃអ្វីដែលបុគ្គលអាចប្រើប្រាស់បាន ជាមួយនឹងអ្វីមួយផ្សេងទៀតដែលបុគ្គលអាចត្រួតត្រាបាន ។ " យុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិត គឺជាកិច្ចប្រឹងប្រែងដើម្បីធ្វើការគ្រប់គ្រង និងផ្លាស់ប្តូរស្ថានភាពនៃការចិញ្ចឹមជីវិតសម្រាប់បង្កើតស្ថានភាពថ្មីជំនួស និងជ្រើសរើសយកជម្រើសសមស្របតាមរយៈការប្រើប្រាស់ធនធាននៃការចិញ្ចឹមជីវិត " ។

**ផែនការបរិស្ថានជាតិ ៖** ផែនការនេះផ្តោតលើអាទិភាពចំនួន៦ និងទទួលស្គាល់ទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងបរិស្ថាន សារៈសំខាន់នៃសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ តម្រូវការកសាងសមត្ថភាពស្ថាប័ន និងសារៈសំខាន់នៃវិធីសាស្ត្រចម្រុះសម្រាប់ការកសាងផែនការបរិស្ថាន ។

**គោលនយោបាយជាតិសម្រាប់វិស័យព្រៃឈើ ៖** គោលនយោបាយនេះរួមបញ្ចូលគោលដៅ នៃកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច និងអភិបាលកិច្ចល្អ ។ គោលនយោបាយនេះទទួលស្គាល់កិច្ច

ការពារ "សិទ្ធិជាលក្ខណៈប្រពៃណីតាមផ្លូវច្បាប់របស់សហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ ធនធានព្រៃឈើ ..." និងកិច្ចប្រឹងប្រែង ដើម្បី "បង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន បានពីការប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើ តាមរយៈការអភិរក្ស ព្រៃឈើ និងសត្វព្រៃ ដោយផ្អែកលើសហគមន៍" ។

**យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ** : យុទ្ធសាស្ត្រនេះគូសបញ្ជាក់ពីសកម្មភាពមួយក្នុងចំណោមសកម្មភាពនានា ជាអាទិភាពសម្រាប់កាត់បន្ថយភាពក្រីក្រ គឺដើម្បីពង្រឹងស្ថាប័ន និងលើកកំពស់អភិបាលកិច្ច រួមទាំងកំណែទម្រង់លើការគ្រប់គ្រង ធនធានធម្មជាតិ (ដីធ្លី កសិកម្ម ព្រៃឈើ និងជលផល ។

**បណ្តាញការងារ** គឺក្រុមណាមួយផ្សំឡើងដោយបុគ្គល ឬ អង្គការជាច្រើនដែលរួបរួមគ្នា ដោយស្ម័គ្រចិត្តសម្រាប់ផ្លាស់ប្តូរ ព័ត៌មាន ឬ ធ្វើសកម្មភាពរួមគ្នា និងចាត់ចែងក្រុមរបស់ខ្លួន ដោយរក្សាភាពឯករាជ្យ និងស្វ័យភាពរៀងៗខ្លួន ។

**ធនធានធម្មជាតិ** រួមមានទុនធម្មជាតិ ដែលមានន័យថាជាផលដែលអាចប្រមូលបាន គឺមិនមែនជាលំហូរនៃធនធាននោះ ទេ ។ ផលិតផល និងសេវាអរូបិយរួមមាន បរិយាកាស សោភណភាព និងជីវៈចម្រុះ ហើយផលិតផលព្រមទាំងសេវារូបិយរួមមាន ដើមឈើ ត្រី និងដីធ្លី ។

**ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម** : ជាពាក្យដែលមានន័យ រួមបញ្ចូលទាំងអត្ថន័យ និងទម្រង់នៃការគ្រប់គ្រង ព្រៃឈើនីមួយៗ ដែលមានបកស្រាយនៅក្នុងខ្លឹមសារនៃពាក្យ កិច្ចសហការគ្រប់គ្រងព្រៃឈើ-កិច្ចសហការគ្រប់គ្រងធនធាន ធម្មជាតិសហគ្រប់គ្រង ព្រៃឈើសង្គម សហគមន៍ព្រៃឈើ និងការគ្រប់គ្រងព្រៃឈើរួមគ្នា ។

**ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី** : ជាដំណើរការកសាងផែនការដែលផ្តួចផ្តើមនៅថ្នាក់ភូមិ ដែលនៅក្នុងនោះអ្នកភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត រួមគ្នារៀបចំផែនការសម្រាប់ការប្រើប្រាស់ ការពារ និងបែងចែកចំណែកដី ព្រៃឈើ ផ្ទៃដីកសិកម្ម និងទឹកនៅក្នុងព្រំប្រទល់នៃភូមិរបស់ខ្លួន ។

**ធនធានរូបវ័ន្ត**: សំដៅលើហេដ្ឋារចនាសម្ព័ន្ធដែលជាសេវាសាធារណៈអាចប្រើប្រាស់បាន ដោយពុំចាំបាច់បង់ថ្លៃដោយផ្ទាល់ និង ផលិតផលចាំបាច់សម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត (ឧទាហរណ៍ ឧបករណ៍ និងបរិក្ខារ ។ ធនធានរូបវ័ន្ត មានជាអាទិ៍ មធ្យោបាយ ដឹកជញ្ជូនដែលមានតម្លៃសមរម្យ ទីជម្រក និង អាគារដែលផ្តល់សុវត្ថិភាព ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ថាមពលអគ្គិសនីដែលមានតំលៃសមរម្យ និងលទ្ធភាពទទួលព័ត៌មាន (ទូរគមនាគមន៍ ។

**ប្រកាស** : ជាបទបញ្ជាថ្នាក់ក្រសួង ឬ អន្តរក្រសួងដែលមានការប្រើប្រាស់ដូចអនុក្រឹត្យដែរសម្រាប់អនុវត្តន៍ និងបំភ្លឺ បន្ថែមអំពីបទប្បញ្ញត្តិដែលមាននៅក្នុងឯកសារច្បាប់ផ្សេងៗ ។

**ការចូលរួមជាសាធារណៈលើវិស័យព្រៃឈើ** : ជាពាក្យមួយមានន័យទូលាយ ដែលប្រើប្រាស់សំដៅលើវិធីជាច្រើន

ដែលប្រជាពលរដ្ឋអាចជះឥទ្ធិពលលើវិស័យព្រៃឈើ ប៉ុន្តែមិនសុទ្ធតែនៅក្នុងការធ្វើសេចក្តីសម្រេចរួមគ្នា (ប្រកបដោយកិច្ចសហការ) នោះឡើយ ។

**យុទ្ធសាស្ត្រចតុកោណ :** យុទ្ធសាស្ត្រនេះសំដៅលើ ការបង្កើនកម្រិតលូតលាស់ ភាពមានការងារធ្វើ សមធម៌ និងប្រសិទ្ធិភាពតាមរយៈការអនុវត្តផែនការ អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រចាំឆ្នាំលើកទី២ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ នៅចំណុចស្នូលនៃយុទ្ធសាស្ត្រនេះ គឺអភិបាលកិច្ចល្អដែលផ្តោតលើវិស័យបួនរួមមាន ការប្រឆាំងអំពើពុករលួយ ច្បាប់ និង តុលាការ រដ្ឋបាលសាធារណៈ និងវិមជ្ឈការ ។

**ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមឆ្នាំ ២០០២-២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា :** ជាឯកសារគោលនយោបាយចែងពីមាគ៌ាសម្រាប់រដ្ឋាភិបាលដែលផ្តោតលើទិដ្ឋភាពនានា នៃបញ្ហាអភិវឌ្ឍន៍ ដែលប្រមូលផ្តុំលើបណ្តាសកម្មភាពសម្រាប់អនុវត្តន៍ក្នុងការជម្រុញឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យឯកជន ។

**ធនធានសង្គម :** សំដៅលើទំនាក់ទំនង ឧទាហរណ៍ បណ្តាញទាក់ទងរវាងបុគ្គល និងក្រុម ដើម្បីឱ្យពួកគាត់ធ្វើការរួមគ្នា និងបង្កើនឱកាសចូលរួម (សិទ្ធិ និងអំណាច) ដើម្បីធ្វើការជាមួយស្ថាប័នពាក់ព័ន្ធ ក្លាយជាសមាជិកនៃក្រុមដែលបានបង្កើតជាផ្លូវការដោយមាន វិន័យ លក្ខន្តិកៈ ការផាកពិន័យ និងទំនាក់ទំនងនៃការជឿទុកចិត្ត ភាពមានទៅមានមក និងការផ្លាស់ប្តូរប្រកបដោយកិច្ចសហការគ្នា ដែលបង្កើតបានជាបណ្តាញសុវត្ថិភាពក្រៅផ្លូវការ ។

**ព្រៃឈើសង្គម :** មានការប្រើប្រាស់ពាក្យនេះជាលើកដំបូងដោយរដ្ឋាភិបាលនៃប្រទេសឥណ្ឌា សំដៅលើកម្មសិទ្ធិលើដីព្រៃឈើ ជាចំណែកនៃដីធ្លីរបស់ភូមិមួយ (មិនមែនជាព្រៃឈើបម្រុងនោះទេ) ។ បច្ចុប្បន្នពាក្យនេះន័យថា ជាការគ្រប់គ្រងព្រៃឈើ ប្រកបដោយគោលបំណងខាងសង្គម សំដៅផ្តល់ប្រយោជន៍សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន ។

**ឯកសារគោលនយោបាយដីធ្លី (២០០១) និងយុទ្ធសាស្ត្រនៃក្របខ័ណ្ឌគោលនយោបាយដីធ្លី :** ចែងពីគោលនយោបាយរបស់រដ្ឋាភិបាលអំពីការគ្រប់គ្រងរដ្ឋបាល និងការបែងចែកដីធ្លី ។ ឯកសារនេះចែងថា "ប្រជាពលរដ្ឋដែលប្រើប្រាស់ដីធ្លី គឺជាអ្នកគ្រប់គ្រងដីធ្លីប្រចាំថ្ងៃ ហើយការចូលរួមរបស់ពួកគេ មានសារៈសំខាន់ណាស់នៅក្នុង ការកសាងផែនការប្រើប្រាស់ដីធ្លី" ចំណែកឯ "ទស្សនទានអំពីសហគមន៍ព្រៃឈើ និងសហគមន៍នេសាទ... មានន័យថា ជាការរំពឹងទុកអំពីការកសាងផែនការប្រើប្រាស់ដីធ្លីរបស់សហគមន៍ និងការគ្រប់គ្រងដីធ្លីនៅទូទាំងប្រទេស" ។

**អនុក្រឹត្យ** ជាឯកសារច្បាប់ដែលជាទូទៅត្រូវបានប្រើប្រាស់សម្រាប់អនុវត្តន៍ និងចែងបំភ្លឺបន្ថែមអំពីប្រការជាក់លាក់ដែលមាននៅក្នុងច្បាប់ ។

**ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព :** "ជីវភាពរស់នៅត្រូវបានចាត់ទុកថាមាននិរន្តរភាព នៅពេលមានការដោះ

ស្រោយ និងរួចផុតពីភាពតានតឹង ភាពតក់ស្លុត និងឧបសគ្គផ្សេងទៀត ដោយអាចរក្សាស្ថានភាពដដែល ឬ ពង្រឹងលទ្ធភាព និងទ្រព្យសម្បត្តិរបស់ខ្លួននាពេលបច្ចុប្បន្ន និងអនាគតដោយពុំធ្វើឱ្យខូចខាតមូលដ្ឋានធនធានធម្មជាតិឡើយ " ។

**វិធីសាស្ត្រនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ៖** សំដៅលើវិធីនៃការគិតគូរពីគោលបំណង ទំហំ និងអាទិភាពសំរាប់ការអភិវឌ្ឍ នៅក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីប្រឈមនឹងទ្រឹស្តីនៃការអភិវឌ្ឍធម្មតាដោយ "ចាត់ទុកប្រជាពលរដ្ឋជាកត្តាចម្បងនៃការអភិវឌ្ឍ " ។

**ក្របខ័ណ្ឌនៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ៖** ជាវិធីសាស្ត្រសម្រាប់បង្កើនការយល់ដឹងពីការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ។ ក្របខ័ណ្ឌនេះ បង្ហាញពីកត្តាចម្បងនានា ដែលជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ រួមមានទ្រព្យសម្បត្តិក្រោមរូបភាពជាធនធានមនុស្ស ធនធានសង្គម ធនធានធម្មជាតិ ធនធានរូបវន្ត និងធនធានហិរញ្ញវត្ថុដែលប្រជាពលរដ្ឋអាចមាននៅក្នុងដៃ និងទំនាក់ទំនងក្នុងចំណោមទ្រព្យសម្បត្តិទាំងនេះ ។

**កសិកម្មពនេចរ ៖** ជាប្រព័ន្ធកសិកម្មមួយបែបដែលដីដាំដំណាំបានមកពីការរានឆ្ការ និងដុតព្រៃ និងចន្លោះពេលគ្មានដំណាំ (នៅពេលទុកដីចោលមួយរយៈកាល ដែលជាមធ្យមមានរយៈពេលវែងជាងរយៈពេលដាំដំណាំ នៅពេលប្រើប្រាស់ដីនោះ ។ ជាញឹកញាប់ដីចំការដែលមិនប្រើប្រាស់ ត្រូវបានទុកចោល ដើម្បីឱ្យព្រៃឈើលូតលាស់ឡើងវិញមុនពេលមានការកាប់ឆ្ការ និងដាំដំណាំឡើងវិញ ។

**កម្មសិទ្ធិ ៖** កិច្ចព្រមព្រៀងកំណត់ដោយសង្គម ដែលផ្តល់អំណាចដល់បុគ្គល ឬ ក្រុមនានា និងទទួលស្គាល់ដោយច្បាប់ ឬ ទម្លាប់ជាប្រពៃណី ទាក់ទងជាមួយសិទ្ធិ និងកាតព្វកិច្ចមួយចំនួនអំពីកម្មសិទ្ធិ ការកាន់កាប់ ការចេញចូល និងប្រើប្រាស់ចំណែកដីណាមួយជាក់លាក់ ឬធនធាននានាដែល ពាក់ព័ន្ធនៅក្នុង ចំណែកដីនោះ (ដូចជាដើមឈើ នានា ប្រភេទរុក្ខជាតិ ទឹក រ៉ែ ។ល ។

**ប្រព័ន្ធកម្មសិទ្ធិជាលក្ខណៈប្រពៃណី** របស់ក្រុមជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា គឺជាប្រភេទនៃសិទ្ធិកាន់កាប់លើចំណែកដី និងធនធានធម្មជាតិ ។

**និន្នាការ** រួមមានអត្រាចំនួនកំណើនប្រជាពលរដ្ឋ ប្រជាសាស្ត្រ អភិបាលកិច្ច និងរបបនយោបាយ ។

**សិទ្ធិប្រើប្រាស់ ៖** ជាសិទ្ធិលើការប្រើប្រាស់ ដែលអាចកំណត់ដោយទម្លាប់នៅមូលដ្ឋាន កិច្ចព្រមព្រៀងរវាងគ្នា ឬ ចែងដោយអង្គភាពដទៃដែលមានសិទ្ធិកាន់កាប់ ។ សិទ្ធិបែបនេះ អាចមានដែនកំណត់ត្រឹមប្រើប្រាស់ធនធានជាក់លាក់មួយចំនួន ត្រឹមកម្រិតណាមួយនៃការទាញយកផល ឬ តាមការប្រើប្រាស់ បច្ចេកទេសប្រមូលផលបែបណាមួយតែប៉ុណ្ណោះ ។

**កំណត់សម្គាល់ ៖** និយមន័យនៅក្នុងសន្ទានុក្រមនេះ បានដកស្រង់ចេញពីជំពូកនានា ក្នុងរបាយការណ៍នេះ ។ ចំពោះការបំភ្លឺបន្ថែម និងការធ្វើកំណត់យោង សូមអានជំពូកពាក់ព័ន្ធនីមួយៗ ។

# បញ្ជីឈ្មោះអង្គការពាក់ព័ន្ធ

| ឈ្មោះអង្គការ | សកម្មភាពគោលដៅ | វិស័យ | ព័ត៌មានទាក់ទង |
|---|---|---|---|
| គម្រោងសន្សំសំចៃអុសក្នុងប្រទេសកម្ពុជា (CFSP) | ▪ ការប្រើប្រាស់អុសដោយប្រសិទ្ធភាព និងប្រភពផ្សេងនៃថាមពល | ព្រៃឈើ | 023 986 891; mclequan@cfsp.org.kh |
| សម្ព័ន្ធភាពសហគមន៍ព្រៃឈើសម្រាប់ប្រទេសកម្ពុជា (CFAC) | ▪ សហគមន៍ព្រៃឈើ | ព្រៃឈើ | 023 220 714, 012 909 502<br>Cfac1@online.com.kh<br>cfac2@online.com.kh |
| គម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) | ▪ សហគមន៍ព្រៃឈើ<br>▪ ការស្រាវជ្រាវតាមរយៈសកម្មភាពអនុវត្តជាក់ស្តែង<br>▪ កសាងសមត្ថភាពដើម្បីពង្រឹងសន្តិសុខ និងកាលានុវត្តនភាពក្នុងការចិញ្ចឹមជីវិតក្នុងសហគមន៍ជនបទ | ព្រៃឈើ | 023 211 381<br>012 832 933<br>ramony@online.com.kh |
| មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) | ▪ គម្រោងអប់រំអំពីច្បាប់ ដីធ្លី និងធនធានធម្មជាតិ | គ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី | 023 215 590, 012 695 706<br>usfpp@online.com.kh |
| សមាគមថែរក្សាវប្បធម៌ និងបរិស្ថាន (CEPA) | ▪ គម្រោងសហគមន៍ព្រៃឈើ<br>▪ គម្រោងសហគមន៍ជលផល<br>▪ គម្រោងទន្លេសេសាន | ព្រៃឈើ<br>ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 023 720 062<br>cepa@online.com.kh<br>cepa@forum.org.kh |
| គម្រោងអភិវឌ្ឍន៍ និងបច្ចេកវិទ្យាសមស្រប (DATE) | ▪ ប្រសិទ្ធភាពចង្រ្កានដាំស្ល | ព្រៃឈើ | 012 851 161<br>san_you@online.com.kh |
| អង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍ និងសាមគ្គីភាព (CIDSE) | ▪ កម្មវិធីចម្រុះអភិវឌ្ឍន៍សហគមន៍ | ព្រៃឈើ<br>ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 023 216 369, 023 216 495<br>mam.sambath@everyday.com.kh |
| គម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ (DANIDA/MoE) | ▪ ការគ្រប់គ្រងធនធានតំបន់ឆ្នេរ | គ្រប់គ្រងធនធានធម្មជាតិ | 023 216 510, 034 934 121<br>coastal@online.com.kh<br>coastal@czmcam.com |
| គម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ជនជាតិដើមភាគតិច នៅតំបន់ដាច់ស្រយាល (DRIVE) | ▪ ការអប់រំ និងទេសចរណ៍ធម្មជាតិ<br>▪ សហគមន៍ព្រៃឈើ<br>▪ ការគ្រប់គ្រងធនធានធម្មជាតិ | ទេសចរណ៍ធម្មជាតិ<br>គ្រប់គ្រងធនធានធម្មជាតិ | 012 981 226<br>graemb@camitel.com |
| អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) | ▪ សហគមន៍នេសាទ<br>▪ ការតស៊ូមតិ | ជលផល | 023 213 482, 012 906 279<br>fact@everyday.com.kh |

*បញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងគម្រោង*

| | | | |
|---|---|---|---|
| អង្គការយុវជនខ្មែរ និងអភិវឌ្ឍន៍សង្គម (KYSD) | ▪ ភាពរេចរឹលនៃបរិស្ថាន និងការគ្រប់គ្រងព្រៃឈើ | ព្រៃឈើ | 011 970 868, 012 964 467<br>kysd_org@hotmail.com |
| អង្គការម្លប់បៃតង | ▪ សហគមន៍ព្រៃឈើ<br>▪ ទេសចរណ៍ធម្មជាតិដោយផ្អែកលើសហគមន៍<br>▪ យេនឌ័រ និងបរិស្ថាន<br>▪ ការយល់ដឹងអំពីបរិស្ថាន<br>▪ ការអប់រំ និងបណ្តុះបណ្តាល | ព្រៃឈើ<br>ទេសចរណ៍ធម្មជាតិ<br>យេនឌ័រ | 023 214 409<br>mlup@online.com.kh |
| វេទិកាអង្គការមិនមែនរដ្ឋាភិបាល | ▪ ការសម្របសម្រួល/បណ្តាញអង្គការមិនមែនរដ្ឋាភិបាល<br>▪ ការវិភាគបញ្ហាអភិវឌ្ឍន៍<br>▪ មជ្ឈមណ្ឌលធនធាន | ព្រៃឈើ<br>ជលផល<br>ដីធ្លី | 023 360 119<br>russell@ngo.forum.com.kh |
| គម្រោងអនុផលព្រៃឈើ (NTFP) ខេត្តរតនៈគិរី | ▪ អនុផលព្រៃឈើ<br>▪ បណ្តាញការពារទន្លេសេសាន | ព្រៃឈើ<br>ជលផល<br>ទីជម្រាល | 075 974 039<br>ntfp@camitel.com |
| គម្រោង (PMCR) គ្រប់គ្រងធនធានតំបន់ឆ្នេរ ដោយមានការចូលរួម | ▪ ការស្រាវជ្រាវដោយចូលរួម<br>▪ ការបង្កើតសហគមន៍<br>▪ ការគ្រប់គ្រងធនធានតំបន់ឆ្នេរ/ព្រៃកោងកាង | ជលផល<br>បរិស្ថាន | 023 214 108, 211 406<br>pmmr@online.com.kh<br>kimnongmoe@yahoo.com |
| គម្រោងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមនៅក្នុងតំបន់បឹងទន្លេសាប (FAO ខេត្តសៀមរាប) | ▪ សហគមន៍ព្រៃឈើ<br>▪ សហគមន៍នេសាទ<br>▪ ការពង្រឹងស្ថាប័ន | ព្រៃឈើ<br>ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 063 963 525, 063 963 462<br>pte@online.com.kh<br>faofor@online.com.kh |
| កម្មវិធីអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ (SADP) | ▪ សហគមន៍ព្រៃឈើ<br>▪ សហគមន៍នេសាទ | ព្រៃឈើ<br>ជលផល | 023 217 218<br>sadp@online.com.kh |
| អង្គការសង្គ្រោះសត្វព្រៃកម្ពុជា | ▪ ការអប់រំ និងបណ្តុះបណ្តាល<br>▪ ការផ្សព្វផ្សាយដល់សហគមន៍<br>▪ ការយល់ដឹងអំពីបរិស្ថាន | អភិរក្សបរិស្ថាន | 023 211 263<br>wildlife@online.com.kh |
| អង្គការស្ត្រីដើម្បីសន្តិភាព និងបរិស្ថាន (SSP) | ▪ ការគ្រប់គ្រងព្រៃឈើ | ព្រៃឈើ | 012 670 188<br>ssp_org@yahoo.com |

*បញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងគម្រោង*

| ឈ្មោះអង្គការ | សកម្មភាពគោលដៅ | វិស័យ | ព័ត៌មានទាក់ទង |
|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ▪ ផ្នែកកសិកម្ម បរិស្ថាន និងធនធានធម្មជាតិ | ធនធានធម្មជាតិ<br>ជលផល | www.adb.org |
| ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក់ (DANIDA) | ▪ វិមជ្ឈការផ្តោតលើការគ្រប់គ្រងធនធាន និងបរិស្ថាននៅថ្នាក់ឃុំ<br>▪ ការគ្រប់គ្រងដីធ្លី<br>▪ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក<br>▪ ទីផ្សារគាំទ្រជនក្រីក្រ | គ្រប់គ្រងធនធានធម្មជាតិ<br>ជលផល<br>ព្រៃឈើ<br>ដីធ្លី | 023 987 629, 023 211 484<br>danida@online.com.kh |
| នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (DFID) | ▪ ការចិញ្ចឹមជីវិតនៅជនបទ<br>▪ វិមជ្ឈការផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន<br>▪ ការគ្រប់គ្រងដីធ្លី<br>▪ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក | គ្រប់គ្រងធនធានធម្មជាតិ<br>ជលផល<br>ព្រៃឈើ<br>ដីធ្លី | 023 430 240<br>c-price@dfid.gov.uk |
| អង្គការស្បៀង និងកសិកម្ម (FAO) | ▪ គោលនយោបាយព្រៃឈើ និងការកសាងផែនការ<br>▪ ក្រុមការងារស្តីពីលេខាធិការដ្ឋានគ្រប់គ្រងធនធានធម្មជាតិ | កសិកម្ម<br>ព្រៃឈើ<br>គ្រប់គ្រងធនធានធម្មជាតិ | 023 216 566, 023 211 702<br>www.fao.org |
| ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) | ▪ កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ<br>▪ គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី (LMAP) | ដីធ្លី | 023 726 228 |
| ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) | ▪ កសាងសមត្ថភាពសម្រាប់វិស័យព្រៃឈើ<br>▪ មជ្ឈមណ្ឌលបណ្តុះបណ្តាលអំពីព្រៃឈើ (FA/JICA) | ព្រៃឈើ<br>ជលផល | 023 212 142, 023 211 673<br>jica@online.com.kh<br>023 211 695, 015 851 935<br>www.jica.go.jp |
| ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA) | ▪ វិមជ្ឈការ<br>▪ ការគ្រប់គ្រងដីធ្លី | គ្រប់គ្រងធនធានធម្មជាតិ | 023 212 259<br>claes.sida@online.com.kh |
| កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) | ▪ កិច្ចផ្តួចផ្តើមអំពីភាពក្រីក្រ និងបរិស្ថាន (PEI)<br>▪ កម្មវិធីជំនួយខ្នាតតូចពីមូលនិធិបរិស្ថានពិភពលោក (GEF) | បរិស្ថាន | 023 216 167, 023 216 217<br>douglas.gardner@undp.org<br>www.un.org.kh |
| ភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក (USAID) | ▪ អភិបាលកិច្ច<br>▪ សិទ្ធិមនុស្ស | | |
| ធនាគារពិភពលោក | ▪ ការស្តារ និងអភិវឌ្ឍន៍ | | 023 213 539, 023 217 310<br>www.worldbank |

*បញ្ជីភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគី*

| ឈ្មោះអង្គការ | សកម្មភាពគោលដៅ | វិស័យ | ព័ត៌មានទាក់ទង |
| --- | --- | --- | --- |
| ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO) | ▪ ស្រាវជ្រាវ និងអភិវឌ្ឍន៍<br>▪ ច្បាប់ និងធ្វើជាតំណាង<br>▪ ការឃ្លាំមើល និងវាយតម្លៃ | ជលផល | 023 210 154<br>cfdo@camnet.com.kh |
| ការិយាល័យសហគមន៍ព្រៃឈើ (CFO) នៃរដ្ឋបាលព្រៃឈើ | ▪ កម្មវិធីជាតិសហគមន៍ព្រៃឈើ<br>▪ ការផ្សព្វផ្សាយ និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ | ព្រៃឈើ | sokhhengpiny@yahoo.com |
| ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ(CPADO) នាយកដ្ឋានការពារអភិរក្សធម្មជាតិ  ក្រសួងបរិស្ថាន | ▪ ស្រាវជ្រាវ និងអភិវឌ្ឍន៍សមត្ថភាព<br>▪ គ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម<br>▪ ការអភិវឌ្ឍសហគមន៍ និងបណ្តាញការងារ<br>▪ ការអភិវឌ្ឍគោលនយោបាយ | អភិរក្សបរិស្ថាន | 023 721 462<br>mvathanak@yahoo.com<br>leakhena_san@yahoo.com |
| ការិយាល័យការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីជាបង្គោល ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | ▪ ការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួម | ដីធ្លី | 012 869 377, 012 873 560<br>plup@online.com.kh |
| កម្មវិធីគាំទ្រកម្មវិធីសិលា-PLG នៅខេត្តរតនៈគីរី | ▪ ការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួម<br>▪ LCRT, IFS, CFAR, AAR)<br>▪ ព័ត៌មានសម្រាប់ការអប់រំ<br>▪ ទេសចរណ៍ធម្មជាតិផ្អែកលើសហគមន៍<br>▪ ការស្រាវជ្រាវផ្លូវការ | ព្រៃឈើ<br>ជលផល<br>ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី<br>គ្រប់គ្រងធនធានធម្មជាតិ | 075 974 058, 075 974 016<br>carererat@camitel.com |
| លេខាធិការដ្ឋានក្រុមការងារសិលា | ▪ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន<br>▪ វិមជ្ឈការ | កសិកម្ម ជលផល ព្រៃឈើ ដីធ្លី គ្រប់គ្រងធនធានធម្មជាតិ | 023 362 175, 023 361 900<br>023 723 844<br>scott@seila.gov.kh |
| កម្មវិធីសិលា-ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន | ▪ ធនធានធម្មជាតិ និងបរិស្ថាន<br>▪ វិមជ្ឈការ<br>▪ កាត់បន្ថយភាពក្រីក្រ<br>▪ អភិបាលកិច្ចល្អ | កសិកម្ម ជលផល ព្រៃឈើ ដីធ្លី គ្រប់គ្រងធនធានធម្មជាតិ | 012 812 301, 016 995 501<br>yanara@camnet.com.kh<br>scott@seila.gov.kh<br>sovanna@seila.gov.kh |
| នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម | ▪ គ្រប់គ្រងធនធានទឹក<br>▪ ការស្រោចស្រពគ្រប់គ្រងដោយសហគមន៍ | ទឹក | 012 970 232<br>taratheng@cttnet.com.khs |

| ឈ្មោះអង្គការ | សកម្មភាពគោលដៅ | វិស័យ | ព័ត៌មានទាក់ទង |
|---|---|---|---|
| វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) | ▪ ស្រាវជ្រាវអំពីធនធានធម្មជាតិ និងបរិស្ថាន | គ្រប់គ្រងធនធានធម្មជាតិ | 023 883 603, 023 881 701<br>023 881 384, 023 881 916<br>cdri@camnet.com.kh |
| មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍកសិកម្មកម្ពុជា (CEDAC) | ▪ ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីកសិកម្ម | កសិកម្ម | 023 880 916 |
| មជ្ឈមណ្ឌលជីវៈចម្រុះ និងចំណេះដឹងជនជាតិដើមភាគតិច (CBIK) នៅខេត្តយូណាន ប្រទេសចិន | ▪ ស្រាវជ្រាវដោយមានការចូលរួម<br>▪ ចំណេះដឹងជនជាតិដើម<br>▪ ជីវៈចម្រុះ | គ្រប់គ្រងធនធានធម្មជាតិ<br>អភិរក្សបរិស្ថាន | (+86 871) 4162736<br>wangyu@cbic.ac.cn<br>www.cbik.org |
| មជ្ឈមណ្ឌលស្រាវជ្រាវព្រៃឈើអន្តរជាតិ (CIFOR) នៅប្រទេសឥណ្ឌូណេស៊ី | ▪ ការស្រាវជ្រាវអំពីព្រៃឈើ<br>▪ ព្រៃឈើ និងការចិញ្ចឹមជីវិត | ព្រៃឈើ | (+62 251) 622 622<br>w.sunderlin@cgiar.org<br>www.cifor.cgiar.org |
| វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM LI) | ▪ អភិបាលកិច្ចល្អ និងការចិញ្ចឹមជីវិតដោយនិរន្តរភាព<br>▪ ការអភិវឌ្ឍន៍ធនធានមនុស្ស<br>▪ ការកសាងចំណេះដឹង<br>▪ ភាពជាដៃគូ និងបណ្តាញការងារ<br>▪ ការចាត់ចែងស្ថាប័ន និងការគាំទ្រគោលនយោបាយ | គ្រប់គ្រងធនធានធម្មជាតិ | 023 224 171<br>cbnrmli@everyday.com.kh<br>www.cbnrmLi.org<br>sereyrotha@everyday.com.kh<br>marona@everyday.com.kh<br>toby@everyday.com.kh |
| មជ្ឈមណ្ឌលបណ្តុះបណ្តាលអំពីព្រៃឈើ (FA/JICA) | ▪ កសាងសមត្ថភាពសម្រាប់វិស័យព្រៃឈើ | ព្រៃឈើ | 023 212 142, 023 211 673<br>023 211 695, 015 851 935<br>jica@online.com.kh |
| វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) | ▪ ផ្នែកជីវសាស្ត្រ<br>▪ ផ្នែកសេដ្ឋកិច្ច-សង្គម<br>▪ ស្ថានីយស្រាវជ្រាវកណ្តាលស្ទឹង | ជលផល | (855) 723 275<br>IFRIC@online.com.kh |
| មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិ (IDRC) ការិយាល័យកណ្តាលនៅប្រទេសកាណាដា និងការិយាល័យប្រចាំតំបន់នៅសឹង្ហបុរី | ▪ ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍<br>▪ ការស្រាវជ្រាវដោយសកម្មភាពចូលរួមផ្ទាល់ | គ្រប់គ្រងធនធានធម្មជាតិ | (613) 236 6163<br>hmallee@idrc.org.sg<br>bdavy@idrc.ca<br>www.idrc.ca |
| វិទ្យាស្ថានអន្តរជាតិសម្រាប់ស្តារតំបន់ជនបទ (IIRR) នៅប្រទេសហ្វីលីពីន | ▪ ការសិក្សាដោយសហគមន៍<br>▪ ការអប់រំ និងបណ្តុះបណ្តាល<br>▪ ការបោះពុម្ពផ្សាយ និងទំនាក់ទំនង | គ្រប់គ្រងធនធានធម្មជាតិ | (+63 46) 414 2417<br>information@iirr.org<br>www.iirr.org |

*បញ្ជីឈ្មោះវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាក់ព័ន្ធ (នៅក្នុងថ្នាក់ជាតិ និងថ្នាក់តំបន់*

| | | | |
|---|---|---|---|
| បណ្តាញសិក្សា និងស្រាវជ្រាវ (LeaRN) នៅហ្វីលីពីន | ▪ មជ្ឈមណ្ឌលធនធាន : គ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍<br>▪ បណ្តាញសិក្សា និងស្រាវជ្រាវ | គ្រប់គ្រងធនធានធម្មជាតិ | emferrer@cbcrmlearning.org<br>tatadelacruz@ cbcrmlearning.org |
| គម្រោងសិក្សាស្រាវជ្រាវពីទន្លេមេគង្គ | ▪ ការអភិវឌ្ឍកម្មវិធីសិក្សា : គ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍<br>▪ ការសិក្សា និងការផ្សព្វផ្សាយ<br>▪ អភិបាលកិច្ច និងការចិញ្ចឹមជីវិត<br>▪ ការគាំទ្រគោលនយោបាយ | ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 023 210 357<br>rkinakin@online.com.kh |
| សាលាជាតិកសិកម្មព្រែកលៀប | ▪ កសិកម្ម<br>▪ ជលផល<br>▪ ព្រៃឈើ | កសិកម្ម<br>ជលផល<br>ព្រៃឈើ | 023 219 872, 012 802 890<br>pnsa@mail.com |
| មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើសហគមន៍ប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច(RECOFTC) ប្រទេសថៃ | ▪ ការវិភាគ និងការធ្វើជាតំណាងនៅកម្រិតតំបន់<br>▪ សេវាកសាងសមត្ថភាព<br>▪ ការគាំទ្រកម្មវិធីក្នុងប្រទេស<br>▪ ការកសាងផែនការ និងផ្តល់កម្មវិធី | ព្រៃឈើ | (+66-2) 9405700<br>info@recoftc.org<br>www.recoftc.org |
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) | ▪ កសិកម្ម<br>▪ មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល និងវារីវប្បកម្ម<br>▪ មហាវិទ្យាល័យវិទ្យាសាស្ត្ររុក្ខកម្ម | ជលផល<br>ព្រៃឈើ | 012 807 506, 023 219 612<br>012 868 827, 023 364 138<br>treypra@forum.org.kh<br>vmonin@forum.org.kh |
| សាកលវិទ្យាល័យភ្នំពេញ (RUPP) ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាន | ▪ ដេប៉ាតឺម៉ង់ វិទ្យាសាស្ត្របរិស្ថាន | បរិស្ថាន | 023 882 976, 012 933 089<br>environment.rupp@everyday.com.kh |
| សាកលវិទ្យាល័យភ្នំពេញ (RUPP) ដេប៉ាតឺម៉ង់ទេសចរណ៍ | ▪ ដេប៉ាតឺម៉ង់ទេសចរណ៍ | ទេសចរណ៍ | o16 859 780<br>rupptourism@yahoo.com.au |
| VBNK | ▪ វិទ្យាស្ថានបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងអង្គការដែលធ្វើការដើម្បីអភិវឌ្ឍកម្ពុជា | ការគ្រប់គ្រង | 023 722 115<br>www.vbnk.org |
| មជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក (ICRAF) នៅហ្វីលីពីន | ▪ បំលែងជីវិត និងតំបន់ទេសភាព<br>▪ កសាងសមត្ថភាព | កសិកម្ម<br>ព្រៃឈើ | (+63 49) 5362925<br>(+63 49) 5367341<br>www.icraf.cgiar.org/sea |
| មជ្ឈមណ្ឌលមច្ឆជាតិពិភពលោកនៅប្រទេសម៉ាឡេស៊ី | ▪ មនុស្ស វិទ្យាសាស្ត្រ បរិស្ថាន និងដៃគូ | ជលផល | (+60-4) 626 1606<br>(+60-4) 626 5530<br>www.worldfishcenter.org |

*បញ្ជីឈ្មោះវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាក់ព័ន្ធ ( នៅក្នុងថ្នាក់ជាតិ និងថ្នាក់តំបន់*

| ឈ្មោះអង្គការ | សកម្មភាពគោលដៅ | វិស័យ | ព័ត៌មានទាក់ទង |
|---|---|---|---|
| ភ្នាក់ងារអភិវឌ្ឍ និងជំនួយសង្គ្រោះ (ADRA) | ▪ កសាងសមត្ថភាពសម្រាប់សន្តិសុខស្បៀង | ជលផល | 023 884 365, 023 880 693<br>mark@adracambodia.org |
| អង្គការសេវាមិត្តភាពអាមេរិកាំង (AFSC) | ▪ កម្មវិធីចម្រុះសម្រាប់ការចិញ្ចឹមជីវិតដោយនិរន្តរភាព (ISLP) -ផ្តែកគ្រប់គ្រងធនធានធម្មជាតិ | ព្រៃឈើ<br>ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 012 694 460, 035 940 740<br>012694460@mobitel.com.kh<br>afsc@online.com.kh |
| អង្គការប្រជាជនអូស្ត្រាលីសម្រាប់ការអប់រំនិងអភិវឌ្ឍន៍ឯនាយសមុទ្រ (APHEDA) | ▪ វារីវប្បកម្ម | ជលផល | 023 216 034 |
| អង្គការ CARE កម្ពុជា | ▪ ការអភិវឌ្ឍសហគមន៍ | កសិកម្ម | 023 215 267<br>brian.lund@care-cambodia.org |
| អង្គការអភិរក្សអន្តរជាតិ (CI) | ▪ ការអភិរក្សជីវៈចម្រុះ<br>▪ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ<br>▪ ការអភិរក្ស និងអភិវឌ្ឍន៍ចម្រុះ | ការអភិរក្ស<br>បរិស្ថាន | 023 214 627, 012 974 332<br>ic@everyday.com.kh |
| អង្គការខន់សឺនវ៉ឺលវ៉ាយ | ▪ សហគមន៍ព្រៃឈើ<br>▪ សន្តិសុខនៃការចិញ្ចឹមជីវិត | ព្រៃឈើ | 023 210 314<br>cfppenh@concerncambodia.net<br>piseth@concerncambodia.net |
| អង្គការសេវាពិភពលោករបស់ព្រះគ្រីះ (CWS) | ▪ គម្រោងអភិវឌ្ឍន៍សហគមន៍ | ជលផល<br>ព្រៃឈើ | 012 708 193, 023 217 786<br>kptcws@online.com.kh<br>cws@online.com.kh |
| អង្គការសត្វ និងរុក្ខជាតិអន្តរជាតិ (FFI) | ▪ ការអភិរក្ស<br>▪ តំបន់ការពារធម្មជាតិ<br>▪ ការអប់រំ | ការអភិរក្ស<br>បរិស្ថាន | 023 211 944<br>iucn@forum.com.kh<br>iucn_cambodia@online.com.kh |
| អង្គការសហភាពអភិរក្សពិភពលោក (IUCN) | ▪ អភិវឌ្ឍន៍កម្មវិធីតំបន់ដីសើមដោយនិរន្តរភាពនៅខេត្តស្ទឹងត្រែង<br>▪ ការពិនិត្យអំពីសកម្មភាពអភិរក្សព្រៃកោងកាង<br>▪ ការពិនិត្យអំពីប្រព័ន្ធតំបន់ការពារធម្មជាតិ | ការអភិរក្ស<br>បរិស្ថាន | 023 211 944<br>iucn@forum.com.kh<br>iucn_cambodia@online.com.kh |
| មជ្ឈមណ្ឌលអ្នកស្ម័គ្រចិត្តអន្តរជាតិជប៉ុន (JVC) | ▪ បណ្តាញសហគមន៍នេសាទ | ជលផល | 023 882 841, 016 963 398<br>jvcpp@online.com.kh |

*បញ្ជីឈ្មោះអង្គការអន្តរជាតិ*

| | | | |
|---|---|---|---|
| អង្គការលូថេរ៉ានបម្រើពិភពលោក (LWF) | ▪ គម្រោងអភិវឌ្ឍជនបទចម្រុះ<br>▪ ទឹក និងអនាម័យ<br>▪ ការអប់រំ | ព្រៃឈើ<br>ជលផល<br>ទឹក | 023 881 100, 023 883 254<br>rep@lwfcambodia.org.kh<br>lwf@online.com.kh |
| គណៈកម្មការកណ្តាលមេណូណៃ (MCC) | ▪ សមាគមអភិវឌ្ឍសហគមន៍ព្រៃឈើនៅខេត្តតាកែវ | ព្រៃឈើ | 023 215 994, 023 216 387<br>mcc@online.com.kh |
| អង្គការអុកស្វាមអាមេរិក (Oxfam America) | ▪ ការគ្រប់គ្រងអាងទន្លេមេគង្គ<br>▪ សន្តិសុខស្បៀង និងប្រាក់ចំណូល<br>▪ ហិរញ្ញវត្ថុសហគមន៍ និងពាណិជ្ជកម្ម | ជលផល | 023 210 357<br>info@oxfamamerica.org<br>www.oxfamamerica.org |
| អង្គការអុកស្វាមដើម្បីជួយសហគមន៍ឯនាយសមុទ្រ (OCAA) | ▪ កម្មវិធីអភិវឌ្ឍសហគមន៍ចម្រុះ<br>▪ ការគ្រប់គ្រងជលផលផ្អែកលើសហគមន៍ | ជលផល | 023 720 928<br>ocaast@camintel.com |
| អង្គការអុកស្វាមចក្រភពអង់គ្លេស (Oxfam GB) | ▪ គម្រោងសិក្សាជីវភាពរស់នៅក្នុងប្រទេសកម្ពុជា<br>▪ សហគមន៍ព្រៃឈើ<br>▪ សហគមន៍នេសាទ<br>▪ ដីធ្លី | ព្រៃឈើ<br>ជលផល<br>ដីធ្លី | 023 720 928, 023 720 036<br>mbird@oxfam.org.kh<br>kdinravy@oxfam.org.kh |
| អង្គការសេវាស្ម័គ្រចិត្តឯនាយសមុទ្រ (VSO) | ▪ កម្មវិធីសន្តិសុខជីវភាពរស់នៅ | ព្រៃឈើ<br>ជលផល<br>គ្រប់គ្រងធនធានធម្មជាតិ | 023 216 734, 023 365 380<br>james_whitehead@vsoint.org<br>rob.hartnell@vsoint.org |
| អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) | ▪ ការគ្រប់គ្រងជលផលក្នុងសហគមន៍ជនជាតិដើមតំបន់ភ្នំ<br>▪ គម្រោងអភិរក្សទន្លេមេគង្គលើ ស្ទឹងស្រែអំបិល និងទន្លេសាប<br>▪ ការអភិរក្សជីវៈចម្រុះក្នុងព្រៃសម្បទាន<br>▪ ការគ្រប់គ្រងតំបន់ទេសភាពនៅវាលរាបខាងជើង | ការអភិរក្ស<br>បរិស្ថាន<br>ជលផល<br>ព្រៃឈើ និង ដីធ្លី | 023 217 205, 023 219 443<br>jwalston@wcs.org |
| អង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ (WWF) | ▪ គម្រោងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM LI)<br>▪ ការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលក្នុងការអភិរក្ស (MOSAIC) ក្នុងតំបន់ខ្ពង់រាបភាគ) សាន<br>▪ តំបន់អេកូឡូស៊ីព្រៃល្បោះនៅទន្លេមេគង្គខាងក្រោម<br>▪ ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព | ការអភិរក្ស<br>បរិស្ថាន<br>ជលផល<br>ព្រៃឈើ<br>ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ | 023 218 034<br>teak.seng@everyday.com.kh<br>amaxwell@online.com.kh<br>cheammony@everyday.com.kh<br>toby@everyday.com.kh<br>www.panda.org |

# ប្រវត្តិអ្នកនិពន្ធ

## លោក កែន សេរីរដ្ឋា

លោក កែន សេរីរដ្ឋា ទើបត្រូវបានតម្លើងឋានន្តរសក្តិពីតួនាទីជាប្រធានការិយាល័យសហគមន៍តំបន់ការពារធម្មជាតិ (CPAD )ទៅជាអនុប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ (DNCP) នៃក្រសួងបរិស្ថាន (MoE) កម្ពុជា ហើយលោកក៏ជាទីប្រឹក្សាផ្តល់យោបល់ដល់គម្រោង CBNRM LI ផងដែរ ។



លោក កែន សេរីរដ្ឋា មានសញ្ញាប័ត្រអនុបណ្ឌិតផ្នែក "សិក្សាការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍ" និងបានទទួលវិញ្ញាបនប័ត្រ ក្រោយឧត្តមសិក្សាខាងផ្នែក "គ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍ" ពីសាកលវិទ្យាល័យជាតិ អូស្ត្រាលី នៃប្រទេសអូស្ត្រាលី ការស្រាវជ្រាវរបស់លោកស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងតួនាទីរបស់សហគ្រប់គ្រងនៅភាគនិរតី នៃប្រទេសកម្ពុជា។ លោក រដ្ឋា ក៏មានសញ្ញាប័ត្រវិស្វករខាងផ្នែកផ្គត់ផ្គង់ទឹក និងស្រោចស្រពពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាផងដែរ ។ គាត់បានធ្វើការអស់រយៈពេលច្រើនជាង ១០ឆ្នាំ ជាមួយស្ថាប័ន ផ្តល់ជំនួយទ្វេភាគី ពហុភាគី អង្គការអន្តរជាតិ នឹងអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក ។ គាត់មានជំនាញលើកិច្ចផ្តួចផ្តើម ទាក់ទងនឹងសហគមន៍ រួមទាំងការអភិរក្សជីវៈចម្រុះ ទេសចរណ៍ធម្មជាតិ ការកសាងផែនការបរិស្ថាន ព្រៃឈើ និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ។ លោក កែន សេរីរដ្ឋា មានចំណាប់អារម្មណ៍ជាពិសេស ខាងការអភិវឌ្ឍន៍គោល-នយោបាយ បង្កើនការចូលរួមក្នុង ការគ្រប់គ្រងធនធានធម្មជាតិ និងក្នុងការអភិរក្ស និងកសាងសមត្ថភាពជាតិ ។

អាសយដ្ឋានទាក់ទង :
Sereyrotha@everyday.com.kh

## លោក ថូប៊ី ខាសុិន (Toby Carson)

លោក ថូប៊ី ជាទីប្រឹក្សាផ្តល់យោបល់នៃគម្រោង CBNRM LI (WWF, IDRC, Oxfam, RECOFTC) ដែលផ្តោតលើការកសាងសមត្ថភាព បណ្តាញការងារ ការរៀន-សូត្រពីបទពិសោធន៍ និងការគាំទ្រគោលនយោបាយសម្រាប់ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។



លោក ថូប៊ី មានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែក "ការសិក្សាបរិស្ថាន" ដែលផ្តោតលើការកសាងផែនការបរិស្ថានពីសាកលវិទ្យាល័យយ៉ក(York) នៃប្រទេសកាណាដា និងបរិញ្ញាប័ត្រខាងផ្នែកភូមិសាស្ត្រ និងវិទ្យាសាស្ត្របរិស្ថាន" ពីសាកលវិទ្យាល័យតូរ៉ុនតូ (Toronto) ។ លោក ថូប៊ីបានធ្វើការច្រើនជាង ១០ឆ្នាំមកហើយ ក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា ។ លោកមាន ចំណាប់អារម្មណ៍អំពីផ្នែកនានារួមមាន : វិធីសាស្ត្រ អន្តរជំនាញ និង ការចូលរួមនៅក្នុង ការកសាង ផែនការ បរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធាន ការស្រាវជ្រាវដោយសកម្មភាពអនុវត្តជាក់ស្តែង និងដោយមានការចូលរួម ការអភិវឌ្ឍជីវភាពរស់នៅដោយនិរន្តរភាព ការឃ្លាំមើល និងការវាយតម្លៃដោយមានការចូលរួម ការអប់រំបរិស្ថាន ការដោះស្រាយទំនាស់ ការផ្លាស់ប្តូរខាងសង្គម និងអង្គការចាត់តាំង ។

អាសយដ្ឋានទាក់ទង : toby@everyday.com.kh

## កញ្ញា ហ៊ូ កល្យាណ

កញ្ញា ហ៊ូ កល្យាណ ជាទីប្រឹក្សាផ្តល់យោបល់សម្រាប់គម្រោង CBNRM LI និងជាអនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ (CPAD) នៃនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ។



កញ្ញា កល្យាណ មានបរិញ្ញាប័ត្រវិទ្យាសាស្ត្ររុក្ខកម្ម ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ នៃប្រទេសកម្ពុជា ។ លើសពីនេះ កញ្ញាមានវិញ្ញាបនប័ត្រក្រោយឧត្តមសិក្សាខាងផ្នែកគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍ ពីមជ្ឈមណ្ឌល ជាតិសម្រាប់ការសិក្សាអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យជាតិអូស្ត្រាលី (ANU) នៃប្រទេសអូស្ត្រាលី ។ ជំនាញឯកទេស និង ចំណាប់អារម្មណ៍របស់គាត់រួមមាន : វិធីសាស្ត្រអន្តរជំនាញ និង ការចូលរួមនៅក្នុងការគ្រប់គ្រងជីវៈចម្រុះ តួនាទីរបស់ សហគមន៍ និងអ្នកពាក់ព័ន្ធនានានៅក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការស្រាវជ្រាវដោយសកម្មភាពជាក់ស្តែងការអប់រំបរិស្ថាន បណ្តាញការងារ ការសិក្សាជាក្រុម និងការសម្របសម្រួលការងារជាក្រុម និងភាពជាអ្នកដឹកនាំ ។

អាសយដ្ឋានទាក់ទង :
houkalyan@everyday.com.kh ឬ
houkalyan@yahoo.com

## លោក ស្រី ម៉ារ៉ូណា



លោក ម៉ារ៉ូណា ជាប្រធានក្រុមគម្រោង CBNRM LI និងជាអ្នកផ្តល់យោបល់ថ្នាក់ជាតិសម្រាប់គម្រោងការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការការអភិរក្ស ដែលមានមូលដ្ឋាននៅការិយាល័យអង្គការ WWF ។ លោកទើបត្រូវបានតំឡើងឋានន្តរសក្តិថ្មីៗនេះជាប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន ។

លោក ម៉ារ៉ូណា មានបរិញ្ញាប័ត្រ ខាងផ្នែកបច្ចេកវិទ្យាផលិតអាហារ ពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នៅទីក្រុងភ្នំពេញ ។ លោក បានធ្វើការជាមួយក្រសួងបរិស្ថាន អង្គការ IDRC និង WWF តាំងពីឆ្នាំ១៩៩៥ នឹងបានទទួលការបណ្តុះបណ្តាល ចូលរួមក្នុងសន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សាជាច្រើននៅប្រទេសនានាក្នុងទ្វីបអាស៊ី និងនៅប្រទេសកាណាដា ដែលជាប់ទាក់ទងនឹងសហគមន៍ព្រៃឈើ ការអភិវឌ្ឍន៍គោលនយោបាយ ការអភិវឌ្ឍសហគមន៍ក្នុងទីជនបទ និងការសរសេរករណីសិក្សា ។ លោក ម៉ារ៉ូណា បានចូលរួមនៅក្នុងបណ្តាញសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៩៧ មកម្ល៉េះ ។ ចំណាប់អារម្មណ៍ជាចម្បង នៅក្នុងវិជ្ជាជីវៈរបស់លោក គឺការប្រើប្រាស់វិធីសាស្ត្រPRA ដើម្បីបង្កើនការយល់ដឹងអំពីកត្តានានា និងបញ្ហាអន្តរវិស័យជាច្រើន ដែលមានឥទ្ធិពលលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងការសិក្សាអំពីថាតើ គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងវិធីសាស្ត្រសូចនាករ អាចប្រើប្រាស់យ៉ាងដូចម្តេចដើម្បីធ្វើអោយ CBNRM មាននិរន្តរភាព ។

អាសយដ្ឋានទាក់ទង ៖
marona@everyday.com.kh

## លោក Robert B. Oberndorf, J.D.



បច្ចុប្បន្ន លោក Robert ធ្វើការជាទីប្រឹក្សាច្បាប់ និងគោលនយោបាយសម្រាប់សម្ព័ន្ធភាពសហគមន៍ព្រៃឈើរបស់អង្គការ សហគមន៍ព្រៃឈើអន្តរជាតិសម្រាប់គម្រោងក្នុងប្រទេសកម្ពុជា ។ លោកបានជាប់កិច្ចសន្យាជាអ្នកជំនាញការបច្ចេកទេសច្បាប់សម្រាប់គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងប្រទេសកម្ពុជា ។

លោក Robert បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យកូឡូរ៉ាដូ ដោយទទួលបរិញ្ញាប័ត្រខាងផ្នែកប្រាស្រ័យទាក់ទង និងដោយទទួលសញ្ញាប័ត្រជាបណ្ឌិតនីតិសាស្ត្រពីមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យ Case Western Reserve ។ លោក ត្រូវបានទទួលចូលក្នុងសមាគមអ្នកច្បាប់នៃរដ្ឋអូហាយ៉ូ នៅក្នុងឆ្នាំ១៩៩៣ ។ លោកបានធ្វើការជាអ្នកជំនាញខាងច្បាប់បរិស្ថាន ច្បាប់សាងសង់ ច្បាប់កិច្ចសន្យា និងច្បាប់ទ្រព្យសម្បត្តិអចលនៈ សម្រាប់ការគ្រប់គ្រងការបំពុលទឹកប្រចាំតំបន់នៅសហរដ្ឋអាមេរិកអស់រយៈពេល៧ឆ្នាំ មុនពេល ដែលមកធ្វើការជាទីប្រឹក្សាច្បាប់នៅអាស៊ីអាគ្នេយ៍នៅក្នុងឆ្នាំ២០០១ ។ លោកបានរស់នៅ និងធ្វើការក្នុងប្រទេសកម្ពុជាចាប់តាំងពីពេលនោះមក និងធ្លាប់បានធ្វើការជាមួយធនាគារពិភពលោក អង្គការ FAO, GTZ, ដានីដា និងអង្គការ East/West Management អង្គការសហគមន៍ព្រៃឈើអន្តរជាតិ អង្គការ WWF អង្គការគោលដៅភូមិអន្តរជាតិ (VFI) និងបញ្ហាដទៃទៀតដែលទាក់ទងនឹងច្បាប់ធនធានធម្មជាតិ និងការគ្រប់គ្រងដីធ្លី និងកំណែទម្រង់អភិបាលកិច្ច ។

អាសយដ្ឋានទាក់ទង ៖ oberndorfr@yahoo.com

## លោក ញ៉ែម សុវណ្ណា



លោក សុវណ្ណា ជាទីប្រឹក្សាផ្តល់យោបល់ដល់គម្រោងសមាហរណកម្មការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៃកម្មវិធីសិលា ដោយផ្តោតលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ ។ គាត់បានធ្វើការលើផ្នែក CBNRM និងការធ្វើវិមជ្ឈការបញ្ហាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជាមួយអង្គការ IDRC/CARERE តាំងពីឆ្នាំ ១៩៩៦ មក ។

លោកមានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតខាងវិស្វកម្មកសិកម្មពីសាធារណរដ្ឋអ៊ុយក្រែន អតីតសហភាពសូវៀត ។ លោកបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងទីជម្រាលការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍សហគមន៍ ។

លោក សុវណ្ណា បានចូលរួមនៅក្នុងការជជែកវែកញែកដើម្បីកសាងឯកសារណែនាំអំពី PLUPសម្រាប់ប្រទេសកម្ពុជា និងធ្វើការ តស៊ូមតិដើម្បីឱ្យមានការដាក់បញ្ហាជនជាតិដើមទៅក្នុងច្បាប់ភូមិបាល គោលនយោបាយប្រជាជនតំបន់ភ្នំ និងគោលនយោបាយសហគមន៍ព្រៃឈើ ។ លោកក៏ចូលរួមផងដែរនៅក្នុងការជជែកវែកញែកកម្រិតតំបន់ ស្តីពីការអភិវឌ្ឍន៍យុទ្ធសាស្ត្រដើម្បីការស្រាវជ្រាវ CBNRM ឱ្យមានឥទ្ធិពលទៅលើអ្នកកសាងគោលនយោបាយ ។ ចំណាប់អារម្មណ៍របស់លោក រួមមាន ៖ ការអប់រំបរិស្ថាន ដំណោះស្រាយទំនាស់ បង្កើនការយល់ដឹង យេនឌ័រ និងការតស៊ូមតិ ។

អាសយដ្ឋានទាក់ទង ៖ sovanna@sela.gov.kh

## លោក ស៊ឹម ប៊ុនធឿន



លោក ប៊ុនធឿន ជាមន្ត្រីតស៊ូមតិខាងផ្នែកជលផលនៃការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍របស់អង្គការអុកស្វាមអាមេរិក ដែល មានមូលដ្ឋាននៅទីក្រុងភ្នំពេញ។

ថ្មីៗនេះ លោកប៊ុនធឿន បានសិក្សាអំពីការងារស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការតស៊ូមតិ ដែលចាត់ចែងដោយអង្គការ មូលនិធិយុត្តិធម៌បរិស្ថាននៃចក្រភពអង់គ្លេស។ លោកប៊ុន ធឿនធ្លាប់បានធ្វើការអស់រយៈពេលជាច្រើននៅក្នុងការអភិវឌ្ឍ សហគមន៍ក្នុងប្រទេសកម្ពុជា ជាមួយមជ្ឈមណ្ឌលសម្របសម្រួលការគ្រប់គ្រងសាធារណៈសម្រាប់ប្រតិបត្តិការជំនួយសង្គ្រោះតាមព្រំដែនរបស់សហប្រជាជាតិ ពីឆ្នាំ១៩៨៩-១៩៩៣ និង គម្រោងអភិវឌ្ឍន៍សហគមន៍ជាច្រើននៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ក្នុងចន្លោះឆ្នាំ១៩៩៤-២០០០ លោកបានធ្វើជាប្រធាន ក្រុមគម្រោងអភិរក្សបឹងទន្លេសាបរបស់អង្គការល្មសេណានៃប្រទេសជប៉ុន ដែលមានមូលដ្ឋាននៅក្នុងខេត្ត បាត់ដំបង។ លោកប៊ុនធឿន ក៏បានធ្វើការជាមួយអង្គការ អុកស្វាមអាមេរិក ក្នុងនាមជាអ្នកសម្របសម្រួលក្រុម ការងារផ្នែកច្បាប់ជលផលនៃអង្គការមិនមែនរដ្ឋាភិបាល នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ និងបានចាត់ចែងការបណ្តុះ បណ្តាលអំពីការគ្រប់គ្រងជលផលដោយមានការចូលរួមពី សហគមន៍ និងការកសាងផែនការសម្រាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីជលផល ។ លោកបានធ្វើការជិតស្និទ្ធនៅក្នុងការអភិវឌ្ឍសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍នេសាទ និងបានសម្របសម្រួល សិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់ខេត្ត តំបន់ និងថ្នាក់ជាតិ នៅក្នុងឆ្នាំ២០០២។

អាសយដ្ឋានទាក់ទង៖
sbunthoeun@oxfamamerica.org

## លោក ថាយ សុមុនី



លោក សុមុនី កំពុងធ្វើការជានាយកស្តីទីប្រចាំប្រទេសកម្ពុជា នៃអង្គការមូលនិធិអន្តរជាតិសម្រាប់សត្វក្រៀល ហើយជាអតីតប្រធានស្តីទីនៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។

លោក សុមុនី មានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកគ្រប់គ្រងជំនួញក្នុងឧស្សាហកម្មអាហារ និងកសិកម្ម ពីមហាវិទ្យាល័យកសិកម្ម នៅ Cirencester ប្រទេសអង់គ្លេស សញ្ញាប័ត្រអនុបណ្ឌិតវិទ្យាសាស្ត្រវារីវប្បកម្មនៅសាកលវិទ្យាល័យ Deakin នៅ Warnambool ប្រទេសអូស្ត្រាលី និងមានសញ្ញាប័ត្រវិស្វករជលផលពីសាកលវិទ្យាល័យភូមិន្ទកសិកម្មនៅទីក្រុងភ្នំពេញ ។ លោក បានចូលរួមនៅក្នុងការបណ្តុះបណ្តាលសន្និសីទ និងសិក្ខាសាលាអន្តរជាតិជាច្រើន ។ លោក សុមុនី បានធ្វើការនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីជម្រុញការអភិវឌ្ឍជលផល និងវារីវប្បកម្មនៅក្នុងប្រទេសកម្ពុជា និងធ្លាប់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល/អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ។ លោកក៏បានចូលរួមនៅក្នុងបណ្តាញសហគមន៍នេសាទក្នុងប្រទេសកម្ពុជាតាំងពី ឆ្នាំ២០០១ កន្លងមក ។ ផ្នែកជាចំណាប់អារម្មណ៍របស់លោក គឺកំណែទម្រង់ការគ្រប់គ្រងជលផលដោយនិរន្តរភាព ការប្រែប្រួល និងវាយតម្លៃស្ថាប័នសហគ្រប់គ្រងជលផល ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ការសិក្សានិងវាយតម្លៃជីវភាពរបស់សហគមន៍ ការវាយតម្លៃវារីធនធាន និងឥទ្ធិពលនៃគោលនយោបាយគាំទ្រអ្នកក្រីក្រ និងទំនាក់ទំនងរវាងភាពក្រីក្រ និងវារីធនធាន។

អាសយដ្ឋានទាក់ទង៖
icfcambodia@online.com.kh;
thaysomony@hotmail.com.kh

## អ្នកស្រី សូ ស្រីមុំ



អ្នកស្រី សូ ស្រីមុំ ជាប្រធានក្រុមគម្រោង CBNRM LI (WWF, IDRC, Oxfam, RECOFTC) ដែលផ្តោតលើការកសាងសមត្ថភាព បណ្តាញការងារ ការសិក្សាបទពិសោធន៍ និងការគាំទ្រគោលនយោបាយ។

អ្នកស្រី សូ ស្រីមុំ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងប្រទេសកម្ពុជា។ ប្រធានបទនៃការស្រាវជ្រាវរបស់គាត់ គឺសហគ្រប់គ្រងជលផលក្នុងតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ អ្នកស្រីមានសញ្ញាប័ត្រវិស្វករវិទ្យាសាស្ត្រជលផលពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ដោយសហគមន៍ក្នុងប្រទេសកាណាដា ការវិភាគគោលនយោបាយនៅក្នុងប្រទេសឥណ្ឌូណេស៊ី និងជីវភាពរស់នៅដោយនិរន្តរភាព នៅក្នុងប្រទេសហ្វីលីពីន។ ចំណាប់អារម្មណ៍ និងឯកទេសរបស់អ្នកស្រី គឺវិធីសាស្ត្រនៃការចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្ស រួមទាំង ការវាយតម្លៃ ផលប៉ះពាល់នៃកំណែទម្រង់គោលនយោបាយ។

អាសយដ្ឋានទាក់ទង៖
sreymoms@everyday.com.kh;

## លោក ជាន ថាយុទ្ធ



លោក ថាយុទ្ធ ធ្លាប់បានធ្វើការជាជំនួយការបច្ចេកទេស និងជាទីប្រឹក្សាផ្តល់យោបល់សម្រាប់គម្រោង CBNRM LI ។ គាត់ធ្លាប់ធ្វើការជាមួយអង្គការ Concern Worldwide និងកម្មវិធីប្រាសាក់/សហភាពអឺរ៉ុបតាំងពីឆ្នាំ ១៩៩៥ ។

លោក ថាយុទ្ធ មានបរិញ្ញាប័ត្រខាងផ្នែកវិទ្យាសាស្ត្ររុក្ខកម្មពីសាកលវិទ្យាល័យភូមិន្ទកសិកម្មនៃប្រទេសកម្ពុជា និងបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលសន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សាជាច្រើន ទាក់ទងនឹងការអភិវឌ្ឍសហគមន៍នៅក្នុងប្រទេស វៀតណាម ថៃ ឥណ្ឌូណេស៊ី និង ណេប៉ាល់ ។ លោក ថាយុទ្ធ បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន នាយកដ្ឋានរុក្ខាប្រមាញ់ អង្គការមិនមែន រដ្ឋាភិបាល/អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ជាពិសេសលើផ្នែកអភិវឌ្ឍន៍សហគមន៍ និងសហគមន៍ព្រៃឈើ ។ លោកបានចូលរួមនៅក្នុងបណ្តាញសហគមន៍ព្រៃឈើក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩៩ មក ។

អាសយដ្ឋានទាក់ទង :
thayuth@everyday.com.kh;

## កញ្ញា អ៊ូ សុភារី



កញ្ញា សុភារី ជាជំនួយការកម្មវិធីសហគមន៍ព្រៃឈើជាមួយអង្គការ Concern Worldwide ក្នុងប្រទេសកម្ពុជា ។ តួនាទីជាសំខាន់របស់កញ្ញាគឺ ជំនួយការលេខាធិការសម្រាប់គណៈកម្មការបណ្តាញ CF/CPA ក្នុងការរៀបចំកិច្ចប្រជុំនៃបណ្តាញនេះប្រចាំត្រីមាស និងរៀបចំព្រឹត្តិបត្រព័ត៌មាន CF/CPA ប្រចាំត្រីមាស ។

កញ្ញា សុភារី នឹងបញ្ចប់ការសិក្សាផ្នែកទំនាក់ទំនងអន្តរជាតិនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៃប្រទេសកម្ពុជានៅចុងឆ្នាំ ២០០៥នេះ ។ កញ្ញាសុភារីមានចំណាប់អារម្មណ៍លើ : ទំនាក់ទំនងសាធារណៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការងារសង្គម ការអប់រំ ការអភិវឌ្ឍជីវភាពរស់នៅការពារ និងគ្រប់គ្រងបរិស្ថាន ការស្រាវជ្រាវ និងការសរសេរ ។

អាសយដ្ឋានទាក់ទង :
sopheary.ou@concern.net

## លោកឃី អាន



លោក ឃី អាន បានទទួលបរិញ្ញាប័ត្រវិទ្យាសាស្ត្រជលផលពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៅភ្នំពេញ និងថ្នាក់អនុបណ្ឌិត វិទ្យាសាស្ត្រសមុទ្រ ពីសាកលវិទ្យាល័យ Aarhus ប្រទេសដាណឺម៉ាក់ ។ លោកបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើន ក្នុងផ្នែកវិទ្យាសាស្ត្រជលផល និងវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ឬអំពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ទាំងនៅក្នុង និងក្រៅប្រទេស ។

លោកបានធ្វើការជាមន្ត្រីជលផល និងអនុប្រធានមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ខេត្តកោះកុង ។ កាលណោះ លោកទទួលបន្ទុកផ្នែកជលផលសមុទ្រ និងតំបន់ឆ្នេរ វារីវប្បកម្មតំបន់ឆ្នេរ ការគ្រប់គ្រងព្រៃកោងកាង ការគ្រប់គ្រងតំបន់ឆ្នេរ ក៏ដូចជាក្នុងផ្នែកកសិកម្ម និងការដាំដំណាំទ្រង់ទ្រាយតូចផងដែរ ។ លោក ឃី អាន ដឹកនាំក្រុមការងារប្រចាំមូលដ្ឋាននៅក្នុងគម្រោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង"នៃអង្គការ IDRC នៅក្នុងដែនជំរកសត្វព្រៃពាមក្រសោប ក្នុងខេត្តកោះកុង ។ ចាប់ពីពេលនោះ មក លោកមាននាទីជាអ្នកផ្តល់យោបល់បច្ចេកទេសប្រចាំខេត្តអំពីគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងការគ្រប់គ្រងបរិស្ថានដោយផ្អែកលើសហគមន៍ (CCB-NREM) ក្នុងខេត្តកោះកុង ។ លោកបានជួយ TFT, CCs គណៈកម្មការកសាងផែនការថវិកា (PBC) សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងមន្ទីរនៅក្នុងខេត្ត ដើម្បីឱ្យធ្វើការជាមួយគ្នាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានទាំងសម្រាប់តំបន់ឆ្នេរ និងតំបន់ខាងលើ ។

អាសយដ្ឋានទាក់ទង : an_khy@yahoo.com

## លោក ហ៊ុយ វង់រស្មីតារា

លោក តារា ធ្វើការក្នុងក្រុមបណ្តុះបណ្តាលបណ្តាញការងារទេសចរណ៍ធម្មជាតិផ្អែកលើសហគមន៍ក្នុងប្រទេសកម្ពុជា ដោយផ្តោតលើការធ្វើទំនាក់ទំនងបណ្តាញការងារ ការកសាងសមត្ថភាព និងការរៀបរៀងព្រឹត្តិបត្រព័ត៌មាន។



លោកមានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកគ្រប់គ្រងការអភិវឌ្ឍ និងបរិញ្ញាប័ត្រខាងផ្នែកអប់រំ។ លោក តារា បានទទួលវិញ្ញាបនប័ត្របញ្ជាក់ពីការឆ្លងកាត់វគ្គបណ្តុះបណ្តាលគ្រូបង្គោល (AI & APPA)។ ចំណាប់អារម្មណ៍ជាចម្បងរបស់លោកគឺ ការស្រាវជ្រាវដោយសកម្មភាពអនុវត្ត ជាក់ស្តែង និងដោយមានការចូលរួមការបណ្តុះបណ្តាល ទស្សនទានវិស័យអំពីទេសចរណ៍ធម្មជាតិ និងការអភិវឌ្ឍ ការអប់រំបរិស្ថាន ការរៀបរៀងអត្ថបទ សម្រាប់ព្រឹត្តិបត្រព័ត៌មាន បណ្តាញការងារ ការរៀនសូត្រជាក្រុម និងការសម្របសម្រួលការងារជាក្រុម និងការអភិវឌ្ឍសហគមន៍។

អាសយដ្ឋានទាក់ទង:
hvr_dara@yahoo.com

## កញ្ញា អាម៉ាន់ដា ប្រាដលី (Amanda Bradley)

កញ្ញា អាម៉ាន់ដា ជាអ្នកផ្តល់យោបល់គម្រោងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលធ្វើការខាងផ្នែកបរិស្ថាន ឈ្មោះម្លប់បៃតង និងជាអ្នកសម្របសម្រួលកម្មវិធីសម្រាប់ CFAC ។ គាត់បាន និងកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៦ ឆ្នាំមកហើយ ។កញ្ញា អាម៉ាន់ដា បានចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើត CCBEN និងក៏ជាសមាជិកក្រុមប្រឹក្សានៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយឈ្មោះ CEPA (សមាគមន៍ថែរក្សាវប្បធម៌ និងបរិស្ថាន ។



កញ្ញា អាម៉ាន់ដា មានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកច្បាប់ និងពិធីការដែលផ្តោតលើសេដ្ឋកិច្ចអភិវឌ្ឍន៍ និងគោលនយោបាយ បរិស្ថាន ពីមហាវិទ្យាល័យ Fletcher នៃសាកលវិទ្យាល័យ Tufts នៅសហរដ្ឋអាមេរិក។ បច្ចុប្បន្ន កញ្ញាកំពុងសិក្សាផ្នែកទំនាក់ទំនងដើម្បីការអភិវឌ្ឍន៍ ជាមួយកម្មវិធី Isang Bagsak នៅក្នុងប្រទេសហ្វីលីពីន ។ កញ្ញាអាម៉ាន់ដា បានចូលរួមក្នុងការផ្តល់យោបល់សម្រាប់គម្រោងមួយចំនួនស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ និងទេសចរណ៍ធម្មជាតិផ្អែកលើសហគមន៍ ។ ចំណាប់អារម្មណ៍របស់គាត់មាន : ការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ គោលនយោបាយបរិស្ថាន និងការអប់រំបរិស្ថាន ។

អាសយដ្ឋានទាក់ទង:
cfac1@online.com.kh;
amandamlup@online.com.kh

## លោក យិន សូរិយា

លោក យិន សូរិយា ជាគ្រូឧទ្ទេសន៍ជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់បានបង្រៀនទាំងមុខវិជ្ជាភាសាអង់គ្លេស និង ទេសចរណ៍ នៅសាកលវិទ្យាល័យនេះអស់រយៈពេលបួនឆ្នាំហើយ ។ គាត់បានធ្វើការជាមន្ត្រីទេសចរណ៍ធម្មជាតិសម្រាប់ការអភិវឌ្ឍគម្រោងអប់រំភូមិអ្នកស្រុកជនជាតិដើមភាគតិចនៅតំបន់ដាច់ស្រយាល (DRIVE) អស់រយៈពេលមួយឆ្នាំកន្លះ។ គាត់ក៏ធ្វើការជាទីប្រឹក្សាជាតិខាងផ្នែកទេសចរណ៍ធម្មជាតិផងដែរជាមួយគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្តរតនគិរី (PRDC) អស់រយៈពេល ៩ខែ។ លោកក៏បានជួយកសាងផែនការទេសចរណ៍សម្រាប់ ខេត្តនេះផងដែរ។



លោក យិន សូរិយា មានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកអភិវឌ្ឍន៍ទេសចរណ៍ ផ្តោតលើការកសាងផែនការទេសចរណ៍ធម្មជាតិ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយសហការជាមួយសាកលវិទ្យាល័យបច្ចេកវិទ្យានៃទីក្រុងស៊ីដនី (UTS) ប្រទេសអូស្ត្រាលី និងសាកលវិទ្យាល័យបូឡូញ៉ា ប្រទេសអ៊ីតាលី (UNIBO)។ លោក សូរិយា បានធ្វើការស្រាវជ្រាវ និងបោះពុម្ពអត្ថបទស្រាវជ្រាវ មានដូចជា សក្តានុពល និងការប្រឈមចំពោះការអភិវឌ្ឍទេសចរណ៍ធម្មជាតិផ្អែកលើសហគមន៍ និងការអភិវឌ្ឍគោលការណ៍ណែនាំទេសចរណ៍ធម្មជាតិសម្រាប់តំបន់ការពារធម្មជាតិ ។ ចំណាប់អារម្មណ៍របស់គាត់រួមមាន: ការកសាងផែនការទេសចរណ៍ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិផ្អែកលើសហគមន៍ ការកសាងផែនការ និងគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ និងការអភិវឌ្ឍសហគមន៍។

អាសយដ្ឋានទាក់ទង:
yinsoriya@yahoo.com

## លោក មិន ប៊ុណ្ណារ៉ា



បច្ចុប្បន្ន លោក ប៊ុណ្ណារ៉ា គឺជាមន្ត្រីសម្របសម្រួលប្រចាំប្រទេស សម្រាប់សមាសភាគគ្រប់គ្រងទីជម្រាល នៃកម្មវិធីសហប្រតិបត្តិការ MRC-GTZ ដែលមានមូលដ្ឋាននៅរដ្ឋបាលព្រៃឈើ ។ លោកធ្លាប់ជាមន្ត្រីគម្រោងជាមួយគម្រោងព្រៃឈើកម្ពុជា-អាល្លឺម៉ង់ (GTZ-CGFP) ។

លោក ប៊ុណ្ណារ៉ា បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យបច្ចេកវិទ្យា Dresden ប្រទេសអាល្លឺម៉ង់ ដោយទទួលសញ្ញាប័ត្រ អនុបណ្ឌិតខាងផ្នែកវិទ្យាសាស្ត្ររុក្ខកម្ម មានឯកទេសខាងសេដ្ឋកិច្ច និងគោលនយោបាយព្រៃឈើ ។ លោកក៏សិក្សាខាងផ្នែកគ្រប់គ្រងជំនួញផងដែរ ។ បច្ចុប្បន្ន លោកជាគ្រូបង្ហាត់ផ្នែកកសាងផែនការចម្រុះគ្រប់គ្រងទីជម្រាល ។ លោកធ្លាប់បានធ្វើការសម្របសម្រួលក្រុមការងារសហគមន៍ព្រៃឈើនៅថ្នាក់ជាតិ និងផ្តល់ការបណ្តុះបណ្តាលស្តីពីការកសាងផែនការប្រើប្រាស់ដី ដោយមានការចូលរួមសម្រាប់ជនបទនៅក្នុងប្រទេសកម្ពុជា ។

អាសយដ្ឋានទាក់ទង ៖
bunnara@mrcmekong.org;

## លោកបណ្ឌិត ហារ៉ាល់ គើស (Harald Kirsch)



លោក ហារ៉ាល់ ធ្វើការគាំទ្រ សម្របសម្រួល និងចាត់ចែងរួមគ្នានូវសកម្មភាពស្តីពី PLUP នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ នេះ ។

លោក ហារ៉ាល់ មានសញ្ញាប័ត្រ អនុបណ្ឌិតវិទ្យាសាស្ត្រខាងផ្នែក ភូមិសាស្ត្រ ជលសាស្ត្រ និងរុក្ខវិទ្យា និងសញ្ញាប័ត្របណ្ឌិតខាង ភូមិសាស្ត្ររូបវិទ្យា ពីទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់ ។ នៅមុន ពេលបានធ្វើការនេះនៅក្នុងប្រទេសកម្ពុជា លោក ហារ៉ាល់ បានធ្វើការនៅក្នុងប្រទេសថៃ ពីឆ្នាំ១៩៨៩ ដល់ ២០០១ លើផ្នែកតំបន់ភូមិសាស្ត្រ-អេកូឡូស៊ី កសាងផែនទីប្រើប្រាស់ដី និងការអង្កេតដីធ្លី ។ លោក ហារ៉ាល់ មានចំណាប់អារម្មណ៍លើការវាយតម្លៃតម្រូវការបណ្តុះបណ្តាលអំពី PLUP និងការរៀបចំវគ្គបណ្តុះបណ្តាល និងសេវាក្រោយការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួលសកម្មភាព PLUP ក្នុងខេត្តនានា ។

អាសយដ្ឋានទាក់ទង ៖
HaraldCM@hotmail.com

## លោក អ៊ីកណាស់ ដាមម័រ (Ignas Dümmer)



បច្ចុប្បន្ន លោក អ៊ីកណាស់ ជាអ្នកផ្តល់យោបល់បច្ចេកទេសផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជាមួយលេខាធិការដ្ឋាន ក្រុមការងារសិលា (ផ្តល់មូលនិធិដោយដានីដា ។ លោកធ្លាប់បានធ្វើការជាមួយទីភ្នាក់ងារសេវាអភិវឌ្ឍន៍អាល្លឺម៉ង់ (DED) នៅនាយកដ្ឋាន រុក្ខា-ប្រមាញ់ ក្នុងនាមជាអ្នកសម្របសម្រួលអំពី PLUP និងសហគមន៍ព្រៃឈើ ។

លោក អ៊ីកណាស់ មានសញ្ញាប័ត្រខាងផ្នែកសិក្សាបរិស្ថាន/ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងបច្ចេកវិទ្យាអាហារ បន្ថែមពីលើសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកកសិកម្មតំបន់ត្រូពិក និងតំបន់ក្បែរត្រូពិក ដែលផ្តោតលើវិទ្យាសាស្ត្រដី និងការគ្រប់គ្រងទឹក ។ មុនពេលមកធ្វើការក្នុងប្រទេសកម្ពុជា លោកអ៊ីកណាស់ ធ្លាប់បានធ្វើការខាងផ្នែកកសិ-រុក្ខកម្ម និងសហគមន៍ព្រៃឈើក្នុងប្រទេសថៃ និងបានប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមសម្រាប់តំបន់ទីជម្រាលនៅក្នុងប្រទេសហ្វូឡង់ ។ វិស័យជាចំណាប់អារម្មណ៍របស់លោកគឺ ការគាំទ្រសកម្មភាពស្តីពីការកសាងផែនការប្រើប្រាស់ដី ដោយមានការចូលរួម (PLUP) សម្រាប់ទីជនបទក្នុងប្រទេសកម្ពុជា រួមទាំងការដាក់ឱ្យប្រើប្រព័ន្ធព័ត៌មានភូមិសាស្ត្រក្នុងប្រទេសកម្ពុជា កសាងមូលដ្ឋានទិន្នន័យសហគមន៍ព្រៃឈើ និងស្រាវជ្រាវអំពីគោលនយោបាយ និងការអនុវត្ត ។

អាសយដ្ឋានទាក់ទង ៖ ignas@seila.gov.kh

## លោក មាស សុធនវឌ្ឍនៈ



លោក វឌ្ឍនៈ ជាមន្ត្រីបច្ចេកទេស ដែលធ្វើការជាមួយ ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ (CPAD) នៃនាយកដ្ឋានការពារ អភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ។ លោកក៏ជាប្រធានក្រុមនៅមូលដ្ឋាននៃគម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើផងដែរ ។

លោក វឌ្ឍនៈ មានបរិញ្ញាប័ត្រខាងផ្នែកវិទ្យាសាស្ត្រផលិតកម្ម និងបសុព្យាបាល ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា នៅក្នុងរវាងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ ។ បទពិសោធន៍ និងចំណាប់អារម្មណ៍របស់លោក មានជាអាទិ៍ ការស្រាវជ្រាវនៅតាមទីតាំងភូមិសាស្ត្រជាក់ស្តែង និងការវាយតម្លៃជនបទនៃសហគមន៍មូលដ្ឋាន និងធនធានព្រៃឈើ ធម្មជាតិនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ សកម្មភាពសហគមន៍ព្រៃឈើរួមមាន : ការស្រាវជ្រាវ និងការកៀងគរក្នុងស្រុកស្រែអំបិល និងស្រុកកំពង់សីលា ខេត្តកោះកុង ការស្រាវជ្រាវ អំពីសហគមន៍ តំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា និងរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព នៅក្នុងខេត្តព្រះវិហារ ។

អាសយដ្ឋានទាក់ទង : mvathanak@yahoo.com

## កញ្ញា សាន្ត សុជាតិលក្ខិណា



កញ្ញា លក្ខិណា ជាមន្ត្រីបច្ចេកទេសនៅការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ នៃនាយកដ្ឋានការពារអភិរក្ស ធម្មជាតិ នៃក្រសួងបរិស្ថាន ។

កញ្ញា លក្ខិណា មានបរិញ្ញាប័ត្រខាងផ្នែកអក្សរសាស្ត្រខ្មែរ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបរិញ្ញាប័ត្រខាងផ្នែកគ្រប់គ្រងពីវិទ្យាស្ថានជាតិគ្រប់គ្រង។ កញ្ញាបានធ្វើការខាងផ្នែកអង្កេតនៅតាមទីតាំងភូមិសាស្ត្រជាក់ស្តែង ទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា។ កញ្ញាធ្លាប់ជាមន្ត្រីសមភាគីជាមួយគម្រោង ដានីដា ស្តីពីការអភិវឌ្ឍសមត្ថភាពជាតិ ។

អាសយដ្ឋានទាក់ទង :
leakhena_san@yahoo.com

## កញ្ញា Rebecca Dawn Kinakin



កញ្ញា រីបែកកា គីណាគីន គឺជាអ្នកសម្របសម្រួលគម្រោង MLI ដែលមានមូលដ្ឋាននៅអង្គការអុកស្វាមអាមេរិក (ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍ ។

កញ្ញា មានបរិញ្ញាប័ត្រខាងផ្នែក ភូមិសាស្ត្រ ពីសាកលវិទ្យាល័យ Simon Fraser (Burnaby, ប្រទេសកាណាដា និង សញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកនិរន្តរភាពនៃការចិញ្ចឹមជីវិតនៅជនបទ ពីមហាវិទ្យាល័យសិក្សាបរិស្ថាននៃសាកលវិទ្យាល័យ York (ទីក្រុងតូរ៉ុនតូ ប្រទេសកាណាដា ។ បទពិសោធន៍អតីតភាពការងារមានជាអាទិ៍ កសាងផែនការសេវាគ្រប់គ្រងបរិស្ថាន និងបេតិកភណ្ឌ ជាមួយប្រជាជាតិទីមួយនៅខាគខាងលិចនៃប្រទេសកាណាដា និងជាកម្មសិក្សាការីជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅទីក្រុងឡីគែរ ប្រទេស អេហ្ស៊ីប ដើម្បីជួយអភិវឌ្ឍន៍ផែនការសកម្មភាពបរិស្ថានជាតិ។ នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ កញ្ញា រីបែកកា បានធ្វើការ ជាមួយអង្គការ WWF Cambodia-CBNRM LI លើគម្រោងករណីសិក្សា និងបណ្តុញការងារ ។

ចំណាប់អារម្មណ៍ក្នុងជំនាញវិជ្ជាជីវៈរបស់កញ្ញាមានជាអាទិ៍ ការប្រើប្រាស់វិធាននៃការចិញ្ចឹមជីវិត និងការស្រាវជ្រាវតាមរយៈសកម្មភាពជាក់ស្តែងដោយមានការចូលរួមដើម្បីពង្រីកទស្សនទានអំពីប្រភពនៃភាពងាយរងគ្រោះ និងនិយមន័យ-បទពិសោធន៍របស់សហគមន៍ អំពីនិរន្តរភាព ភាពក្រីក្រ និងសុខុមាលភាព និងធ្វើការស្រាវជ្រាវអំពីថាតើអាចបង្កើត CBNRM តាមលំនាំបែបណា ដើម្បីឆ្លើយតបនឹងតម្រូវការ គោលដៅ និងអាទិភាពរបស់សហគមន៍ ។ កញ្ញាក៏មានចំណាប់អារម្មណ៍ផងដែរក្នុងការស្រាវជ្រាវអំពីការប្រើប្រាស់ និងទំនាស់ក្នុងផ្នែកធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា និងតាមរយៈការប្រើប្រាស់ក្របខណ្ឌ គោលនយោបាយអេកូឡូស៊ី ដើម្បីធ្វើការពិចារណា ថាតើការឆ្លើយតបនៅមូលដ្ឋាន និងតំបន់ទេសភាព មានចំណងទាក់ទងគ្នាបែបណាជាមួយដំណើរការនានានៅថ្នាក់ជាតិ និងពិភពលោក ។

អាសយដ្ឋានទាក់ទង :
bequee@yahoo.com

## លោក ស៊ី រ៉ាមុនី



បច្ចុប្បន្ន លោក ស៊ី រ៉ាមុនី ជាប្រធានក្រុមនៃគម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (ទទួលមូលនិធិពីអង្គការ IDRC នៅក្នុងនាយកដ្ឋានការពារអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។

លោក រ៉ាមុនី មានសញ្ញាប័ត្រអនុបណ្ឌិតវិទ្យាសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ ពីវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី នៅទីក្រុងបាងកក ប្រទេសថៃ និងបរិញ្ញាប័ត្រ វិទ្យាសាស្ត្រកៀ្សត្រសាស្ត្រពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងប្រទេសកម្ពុជា ។ លោកមានចំណាប់អារម្មណ៍ ក្នុងការលើកកម្ពស់ក្រុមការងារពហុជំនាញសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ បណ្តាញការងារ និងការសិក្សាអន្តរ-ស្ថាប័ន ការឃ្លាំមើលនិងការវាយតម្លៃដោយមានការចូលរួម និងការធ្វើអត្តសញ្ញាណលក្ខណៈវិនិច្ឆ័យ និងសូចនាករ សម្រាប់ការគ្រប់គ្រងសហគមន៍ព្រៃឈើ ។ លោកក៏មានចំណាប់អារម្មណ៍ផងដែរលើការគ្រប់គ្រងទំនាស់ ការផ្តល់អំណាចបុគ្គល និងភាពជាអ្នកដឹកនាំ។

អាសយដ្ឋានទាក់ទង:
ramony@online.com.kh

## លោក ផាន់ កំណាព្យ

លោក កំណាព្យ ជាអនុប្រធានក្រុមនៃគម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ (CFRP) និងនាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើ និងសត្វព្រៃនៃរដ្ឋបាលព្រៃឈើ។



លោក កំណាព្យ បានទទួលសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត ខាងផ្នែកគ្រប់គ្រងធនធានធម្មជាតិពីវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ីក្នុងប្រទេសថៃ និងបរិញ្ញាប័ត្រវិទ្យាសាស្ត្ររុក្ខកម្ម ពីសាកលវិទ្យាល័យភូមិន្ទកសិកម្មនៅទីក្រុងភ្នំពេញ។ លោក បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល សន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សា នៅប្រទេស ស៊ុយអែដ ចិន ថៃ វៀតណាម និងហ្វីលីពីន ទាក់ទងនឹងការអភិវឌ្ឍន៍សហគមន៍។ លោក កំណាព្យ បានធ្វើការជាមួយ គម្រោងអនុផលព្រៃឈើ (NTFPs) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅក្នុងគម្រោងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ ចំណាប់អារម្មណ៍របស់លោក មានជាអាទិ៍ ការអភិវឌ្ឍន៍គោលនយោបាយ សហគមន៍ព្រៃឈើ ការអភិវឌ្ឍន៍សហគមន៍នៅក្នុងជនបទ និងការសរសេរករណីសិក្សា។

អាសយដ្ឋានទាក់ទង:
phankamnap@online.com.kh;
phankamnap@hotmail.com

## លោក គឹម សារិន

លោក សារិន ជាអ្នកសម្របសម្រួលការងារគម្រោងស្រាវជ្រាវសហគមន៍ព្រៃឈើ ដែលគាំទ្រដោយ IDRC ហើយលោកក៏បានធ្វើការ យ៉ាងសកម្មក្នុងការផ្តល់កិច្ចគាំទ្របច្ចេកទេសសម្រាប់ទីតាំងស្រាវជ្រាវចំនួនប្រាំ។



លោក សារិន មានសញ្ញាប័ត្រថ្នាក់មធ្យមខាងផ្នែកវប្បធម៌ស៊ីវិល នៅសាលាភូមិន្ទកសិកម្មព្រែកលៀប។ ចំណាប់អារម្មណ៍របស់ លោក សារិន មានជាអាទិ៍ ក្រុមការងារពហុជំនាញ អភិបាលកិច្ចល្អសម្រាប់ការស្រាវជ្រាវតាមរយៈការអនុវត្តជាក់ស្តែង និងដោយមាន ការចូលរួម បណ្តាញការងារ លក្ខណៈវិនិច្ឆ័យ និងសូចនាករសំខាន់ៗសម្រាប់ CBFM និងការពង្រឹងអំណាចបុគ្គល និងភាពជាអ្នកដឹកនាំ។ លោក សារិន បានចូលរួមនៅក្នុងការស្រាវ ជ្រាវផ្នែកលើសកម្មភាពនៅមូលដ្ឋានជាក់ស្តែងអំពីការគ្រប់គ្រងធនធានធម្មជាតិអស់រយៈពេល ៩ ឆ្នាំមកហើយ។

អាសយដ្ឋានទាក់ទង:
CFRP@online.com.kh

## លោក ជាម មុនី



លោក មុនី ជាប្រធានក្រុមគម្រោងការគ្រប់គ្រងតំបន់យុទ្ធសាស្ត្រដើម្បីបញ្ចូលទៅក្នុងការអភិរក្ស (Management of Strategic Areas for Integrat Conservation - MOSAIC) របស់អង្គការ WWF ក្នុងប្រទេសកម្ពុជា។

លោក មុនី មានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកសេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម ពីវិទ្យាស្ថានសេដ្ឋកិច្ចជាន់ខ្ពស់នៅ Sofia ប្រទេសប៊ុលហ្គារី ។ មុនពេលចូលរួមក្នុងគម្រោង MOSAIC លោកបានធ្វើការនៅរដ្ឋបាលព្រៃឈើ នៅក្នុងគម្រោងជាច្រើនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព។ លោក មុនី មានចំណាប់អារម្មណ៍ក្នុងការប្រមូលព័ត៌មានស្តីពីការប្រើប្រាស់ធនធានធម្មជាតិ តាមបែបប្រពៃណីដោយសហគមន៍មូលដ្ឋាន ដោយផ្តោតលើ ប្រភេទសត្វព្រៃដែលមានសារៈសំខាន់ជាសាកល កសាងផែនទីអំពី របាយប្រភេទសត្វសំខាន់ៗ និងភាពសំបូរនៃសត្វប្រភេទទាំងនោះ របាយធនធាន និងភាពសំបូរនៃធនធានទាំងនោះ កសាងផែនទីស្តីពីការគម្រាមកំហែងចម្បងៗ ។ លោក មុនី គឺជាគ្រូបង្ហាត់ដែលមានបទពិសោធន៍ និងបានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកថ្នាក់ខេត្ត និងមន្ត្រីអភិរក្ស អំពីច្បាប់ និងបទបញ្ញត្តិនានា ដែលទាក់ទងនឹងការអភិរក្សធនធាន និងគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ និងការកសាងផែនទីប្រើប្រាស់ដីដោយមានការចូលរួម សម្រាប់ករណីទាក់ទងនឹងការអភិរក្សជីវៈចម្រុះ។ លោកបានលើកទឹកចិត្តឱ្យមានការពិភាក្សារវាងមន្ត្រីអភិរក្ស និងសហគមន៍មូលដ្ឋានអំពីឥទ្ធិពលនៃការទទួល ខុសត្រូវខាងផ្នែកច្បាប់ និងសិទ្ធិលើការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍន៍សហគមន៍ដោយនិរន្តរភាព ។

អាសយដ្ឋានទាក់ទង៖
cheammony@everyday.com.kh

## លោកបណ្ឌិត Andrew L. Maxwell, Ph.D.



បច្ចុប្បន្ន បណ្ឌិត អេនឌ្រូ ជាអ្នកគ្រប់គ្រងគម្រោងប្រភេទព្រៃល្បោះ នៅអង្គការ WWF ក្នុងប្រទេសកម្ពុជា និងធ្វើការជាអ្នកផ្តល់យោបល់សម្រាប់គម្រោងMOSAIC-EP ផងដែរ។

បណ្ឌិត អេនឌ្រូ បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិត នៅឆ្នាំ១៩៩៩ ពីសាកលវិទ្យាល័យ រដ្ឋលូស៊ីយ៉ាណា នៅសហរដ្ឋអាមេរិក។ ការស្រាវជ្រាវរបស់គាត់ស្តីពីការផ្លាស់ប្តូរបរិស្ថាននៅក្នុង ភូមិភាគឦសាននៃប្រទេសកម្ពុជា ដោយផ្អែកលើការវិភាគ អំពីកំណកល្បាប់នៅបាតបឹង ដែលនាំឱ្យគេហៅគាត់ថា "បណ្ឌិត មុដ"។ នៅពេលដែលការងារស្រាវជ្រាវរបស់គាត់កាន់តែឈានទៅមុខ បណ្ឌិត អេនឌ្រូ បានចូលរួមជាមួយកម្មវិធី WWF-កម្ពុជា នៅភាគឦសាន ដែលជាដំបូងក្នុងនាមជាអ្នកផ្តល់យោបល់ឱ្យគម្រោង ឧទ្យានជាតិវីរៈជ័យ បន្ទាប់មកជាអ្នកផ្តល់យោបល់ឱ្យគម្រោងអំពីប្រភេទ និង Mosaic នៅក្នុងតំបន់អេកូឡូស៊ី ។

អាសយដ្ឋានទាក់ទង៖
amaxwell@online.com.kh

## លោក អ៊ុក លីឃីម



បច្ចុប្បន្ន លោក លីឃីម ធ្វើការជាទីប្រឹក្សាជាតិខាងផ្នែកសេដ្ឋកិច្ច-សង្គម (NSE) ឱ្យគម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ (EMCZ) ប្រទេសកម្ពុជា។ លោកធ្វើការសម្របសម្រួលសកម្មភាពគម្រោងនៅតាមខេត្ត-ក្រុងទាំងបួនក្នុងតំបន់ឆ្នេររួមទាំង CBNRM អន្តរាគមន៍ទ្រទ្រង់ជីវភាពរស់នៅ (កែលំអ និងផ្តល់ជម្រើសផ្សេងក្នុងការចិញ្ចឹមជីវិត និងការអប់រំបរិស្ថាននៅតាម សាលារៀន។ ការទទួលខុសត្រូវចម្បងរបស់លោកគឺ លើទិដ្ឋភាពសេដ្ឋកិច្ច-សង្គម។

លោក លីឃីម បានបញ្ចប់ការសិក្សានៅឆ្នាំ ១៩៨៦ ដោយទទួលសញ្ញាប័ត្រខាងផ្នែក គរុកោសល្យ ពីមហាវិទ្យាល័យភ្នំពេញ ហើយនៅក្នុងឆ្នាំ១៩៩៥ លោកបានទទួលបរិញ្ញាប័ត្រវិទ្យាសាស្ត្រជីវវិទ្យាពីសាកលវិទ្យាល័យភ្នំពេញ។

បទពិសោធន៍អតីតភាពការងារមានជាអាទិ៍ មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានការពារអភិរក្សធម្មជាតិ MoE, WWF, NTFP, កម្មវិធីផ្តល់យោបល់បច្ចេកទេស (ETAP)/ UNDP អង្គការតំបន់ដីសើមអន្តរជាតិ (WI) អង្គការសេវាមិត្តភាពអាមេរិកាំង (AFSC) គម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង(PMMR)/IDRC និងEMCZ/DANIDA ។

អាសយដ្ឋានទាក់ទង៖
khim@czmcam.com

## លោក Ashish John



លោក Ashish ជាអ្នកសម្របសម្រួលស្រាវជ្រាវសម្រាប់ គម្រោងស្រាវជ្រាវគ្រប់គ្រងធនធានធម្មជាតិនៅក្នុងខេត្តរតនៈគិរី ដែលផ្តោតលើ CBNRM សម្រាប់ប្រជាពលរដ្ឋជនជាតិដើមភាគតិច ។ គម្រោងនេះជាចំណែកមួយនៃ កម្មវិធីអភិបាលកិច្ច នៃរាជរដ្ឋាភិបាលកម្ពុជា។ លោក បាននិងកំពុងធ្វើការ លើការសាកល្បងផ្នែកលើ បទពិសោធន៍កសិករ PLUP សហគមន៍ព្រៃឈើ CBET ការចុះបញ្ជីដីធ្លី សមូហភាព ។ល ។

ម្តាយរបស់លោក Ashish ជាជនជាតិ Mikir/Karbi ពីភាគឦសាននៃប្រទេសឥណ្ឌា ហើយលោក មានសញ្ញាប័ត្រអនុបណ្ឌិត ខាងផ្នែកសល្យសាស្ត្របសុពេទ្យ ពីសាកលវិទ្យាល័យ Agri នៅរដ្ឋ Assam ។

លោកបានធ្វើការនៅខេត្តរតនៈគិរីអស់រយៈពេលជិត ៧ឆ្នាំមកហើយ និងមានចំណាប់អារម្មណ៍អំពី រឿងព្រេង ភាពជាក់ស្តែង និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងសកម្មភាពអភិវឌ្ឍន៍ ។ ប្រតិកម្មរបស់ប្រជាពលរដ្ឋឆ្លើយតបចំពោះការផ្លាស់ប្តូរទិដ្ឋភាពនយោបាយរដ្ឋបាល និងភូមិសាស្ត្រ ក៏ជាចំណាប់អារម្មណ៍ជាពិសេស របស់លោកផងដែរ ។

អាសយដ្ឋានទាក់ទង :
carat@camitel.com;
ashishingty@yahoo.com

## លោក គឹម ណុង



លោក គឹម ណុង គឺជាអនុប្រធាននាយកដ្ឋានអប់រំបរិស្ថាន និងជាប្រធានក្រុមនៃគម្រោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង ដែលមានមូលដ្ឋាននៅក្រសួងបរិស្ថាន ។

លោក ណុង មានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកការពារបរិស្ថាននៃដែនទឹកក្នុងតំបន់ឆ្នេរពី Bremen ប្រទេសអាល្លឺម៉ង់ និង ការអភិវឌ្ឍ ដោយផ្អែកលើសហគមន៍ Antigonish ប្រទេសកាណាដា ។ លោកក៏បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាជាច្រើន ទាក់ទងនឹងការអភិវឌ្ឍសហគមន៍ ការចិញ្ចឹមជីវិតដោយនិរន្តរភាព និងការអភិរក្ស និងការពារបរិស្ថាន តំបន់ឆ្នេរក្នុងប្រទេសថៃ វៀតណាម ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី ចិន អាល្លឺម៉ង់ និងកាណាដា ។

មុនពេលមកធ្វើការនៅក្នុងផ្នែកបរិស្ថាន និងការអភិវឌ្ឍន៍ លោក ណុង គឺជាវិស្វករគីមី និងបានសិក្សានៅ វិទ្យាស្ថានបច្ចេកវិទ្យានៅប្រទេសកម្ពុជា។ លោក ណុង មានចំណាប់អារម្មណ៍ជាពិសេសអំពី ការកសាងផែនការគម្រោង ការឃ្លាំមើល និងវាយតម្លៃ និងធ្វើឱ្យប្រាកដថា ក្រុមស្រាវជ្រាវ CBNRM និងដៃគូគម្រោងដទៃទៀតមានសមត្ថភាពដើម្បីធ្វើការស្រាវជ្រាវប្រកបដោយ គុណភាពខ្ពស់ ។

អាសយដ្ឋានទាក់ទង :
pmmr@online.com.kh

## អ្នកស្រី កែន សុភាព



អ្នកស្រី សុភាព ជាជំនួយការផ្នែកនិរន្តរភាពនៃការចិញ្ចឹមជីវិតនៃគម្រោង CBNRM LI ដែលមានមូលដ្ឋាននៅអង្គការ WWF ក្នុងប្រទេសកម្ពុជា ។

អ្នកស្រី សុភាព មានបរិញ្ញាប័ត្រខាងផ្នែករដ្ឋបាលជំនួញ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៃកម្ពុជា។ លោកស្រីមានចំណាប់អារម្មណ៍ជាពិសេសអំពី អេកូ-ទេសចរណ៍ ផ្អែកលើសហគមន៍ (CBET) និងការអភិវឌ្ឍជីវភាពរស់នៅដោយនិរន្តរភាព។ អ្នកស្រី ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍន៍ធនធានមនុស្ស ការកសាង និងចែករំលែកចំណេះដឹង ភាពជាដៃគូ និងបណ្តាញការងារ ក៏ដូចជាការចាត់ចែងស្ថាប័ន និងការគាំទ្រគោលនយោបាយ ។

អាសយដ្ឋានទាក់ទង :
sopheap.wwwfcam@evereyday.com.kh

## កញ្ញា Melissa J. Marschke



កញ្ញា មេលីសា ជាបេក្ខជនថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យម៉ានីតូបា ប្រទេសកាណាដា។

កញ្ញាមានបរិញ្ញាប័ត្រខាងផ្នែកសិក្សាធនធានបរិស្ថាន/ ការសិក្សាអភិវឌ្ឍន៍ប្រៀបធៀប នៅសាកលវិទ្យាល័យTrent ប្រទេស កាណាដា។ កញ្ញាក៏មានសញ្ញាប័ត្រអនុបណ្ឌិតវិទ្យាសាស្ត្រខាងផ្នែកគ្រប់គ្រងបរិស្ថាន និងធនធានពីសាកលវិទ្យាល័យ Dalhousie ប្រទេសកាណាដា ផងដែរ។ មេលីសា បានធ្វើការ និងសិក្សានៅអាស៊ីអាគ្នេយ៍ (ថៃ ឡាវ កម្ពុជា និងវៀតណាម តាំងពីឆ្នាំ ១៩៩៥ នៅក្នុងនាមជា: និស្សិតអ្នករៀនសូត្រ និងជាអ្នកស្ម័គ្រចិត្តជាមួយអង្គការជាច្រើនដែលធ្វើការ ខាងបរិស្ថាន ជាអ្នកផ្តល់យោបល់សម្រាប់គម្រោងគ្រប់គ្រងផ្អែកលើសហគមន៍ជាច្រើន ដែលទទួលមូលនិធិពីអង្គការ IDRC និងជាអ្នកសម្របសម្រួលការ សរសេរករណីសិក្សា និងបញ្ហាជីវភាពរស់នៅ (RECOFTC, WWF)។

មេលីសា មានចំណាប់អារម្មណ៍អំពីសហគ្រប់គ្រងជាលក្ខណៈបន្សាំ និងបញ្ហានៅជុំវិញការចិញ្ចឹមជីវិត និងសញ្ញាណអំពីនិរន្តរភាព។ នៅក្នុងការអនុវត្តជាក់ស្តែង មេលីសាមានចំណាប់អារម្មណ៍អំពីរបៀបដែលសហគមន៍/គ្រួសារនានាអនុវត្តបទពិសោធន៍នៅក្នុងទម្រង់នានានៃការចិញ្ចឹមជីវិត និងយុទ្ធសាស្ត្រគ្រប់គ្រងធនធាន និងឥទ្ធិពលនៃការសាកល្បងទាំងនោះសម្រាប់អ្នកកសាងគោលនយោបាយនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។

អាសយដ្ឋានទាក់ទង:
mjmarschkeca@.com.kh

## លោក Doug Henderson



លោក Doug បានធ្វើការផ្តល់យោបល់សម្រាប់គម្រោងជាច្រើនគាំទ្រដោយអង្គការ IDRC តាំងពីឆ្នាំ ១៩៩៦ ហើយបច្ចុប្បន្ន ជាអ្នក ផ្តល់យោបល់សម្រាប់គម្រោងស្រាវជ្រាវ សហគមន៍ព្រៃឈើ ដែលជាក្របខ័ណ្ឌពហុស្ថាប័ន សម្រាប់ការស្រាវជ្រាវដោយសកម្មភាពជាក់ស្តែងអំពីសហគមន៍ព្រៃឈើ ។

លោក Doug មានសញ្ញាប័ត្រអនុបណ្ឌិតវិទ្យាសាស្ត្ររុក្ខកម្ម ពីសាកលវិទ្យាល័យ យេល ក្នុងមហាវិទ្យាល័យរុក្ខកម្ម និងសិក្សាបរិស្ថាន និងបរិញ្ញាប័ត្រវិទ្យាសាស្ត្រគ្រប់គ្រងព្រៃឈើ ពីសាកលវិទ្យាល័យរដ្ឋ Carolina ខាងជើងនៃសហរដ្ឋអាមេរិក។ ចំណាប់អារម្មណ៍ជាពិសេសរបស់គាត់គឺ ការផ្លាស់ប្តូរខាងផ្នែកស្ថាប័ន ដើម្បីពង្រីកការចូលរួមនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

លោកបានធ្វើការនៅក្នុងប្រទេសចំនួន ១០ នៅអាស៊ី និងបានពាក់ព័ន្ធនៅក្នុងស្ថានភាព និងកម្មវិធីប្លែកៗ។ សម្រាប់រយៈពេល៨ឆ្នាំ ក្នុងប្រទេសកម្ពុជា លោកបានផ្តោតលើការពង្រឹងសហសេវិក ពង្រឹងការគាំទ្រ និងកែទម្រង់ស្ថាប័នសហគមន៍ព្រៃឈើ ។

អាសយដ្ឋានទាក់ទង:
dhenderson@zonnet.nl

## លោក Frank van Acker



លោក Frank ធ្វើការជាទីប្រឹក្សាឯករាជ្យ ច្រើនតែនៅក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងវិមជ្ឈការ។ បច្ចុប្បន្ន លោកជា ទីប្រឹក្សា ជាមួយគម្រោង DoLA របស់ GTZ ដែលមានទីតាំងនៅក្រសួងមហាផ្ទៃ ។

លោកមានសញ្ញាប័ត្រអនុបណ្ឌិតខាងផ្នែកសេដ្ឋកិច្ចសាធារណៈ និងអនុបណ្ឌិតខាងផ្នែកសិក្សាការអភិវឌ្ឍ។ លោកបានធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ចម្រុះនៅជនបទជាមួយអាជ្ញាធរមូលដ្ឋាន នៅប្រទេសតង់ហ្សានី អស់រយៈពេលបួនឆ្នាំ បញ្ហាសិទ្ធិចំពោះដីធ្លី និងសិទ្ធិមនុស្សសម្រាប់បណ្តាញ អង្គការមិនមែនរដ្ឋាភិបាលនៅប្រទេសហ្វីលីពីន និងតំបន់អាហ្វ្រិកកណ្តាល (កុងហ្គោ រវ៉ាន់ដា ប៊ូរុនឌី អស់រយៈពេល ៦ឆ្នាំ និងដឹកនាំកម្មវិធីសិទ្ធិមនុស្សរបស់សហភាពអឺរ៉ុបនៅយូហ្គាន់ដា អស់រយៈពេលបួនឆ្នាំ។ ក្នុងនាមជាបេក្ខជន ស្រាវជ្រាវជាមួយសាកលវិទ្យាល័យបែលហ្សិកអស់រយៈពេលបីឆ្នាំ លោកក៏ធ្លាប់បានធ្វើការលើបញ្ហាមូលធនសង្គម សិទ្ធិចំពោះដីធ្លី និងទ្រព្យសម្បត្តិរួម (ជលផលទឹកសាប ក្នុងប្រទេសកម្ពុជាផងដែរ។

អាសយដ្ឋានទាក់ទង:
ackersimons2@hotmail.com

## កញ្ញា Katrin Seidel



នៅក្នុងក្របខ័ណ្ឌនៃជំនួយបច្ចេកទេសផ្តល់ដោយទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ GTZ សម្រាប់គម្រោងគ្រប់គ្រង និងរដ្ឋបាលដីធ្លី (LMAP) កញ្ញា Katrin បានធ្វើការគាំទ្រអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីក្នុងការអភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ ចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមនៅក្នុងប្រទេសកម្ពុជា។

បច្ចុប្បន្ន កញ្ញា Katrin កំពុងបញ្ចប់ថ្នាក់អនុបណ្ឌិតខាងផ្នែកវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ នៅសាកលវិទ្យាល័យ Humboldt ក្នុងទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់។ កញ្ញាបានធ្វើការសិក្សារបស់ខ្លួននៅក្នុងចំណោមសហគមន៍ជនជាតិដើមនៅខេត្តរតនៈគិរី និងមណ្ឌលគិរី ដោយពិនិត្យមើលប្រព័ន្ធសិទ្ធិ និងការគ្រប់គ្រងដីធ្លីតាមបែបប្រពៃណី។

កញ្ញា Katrin មានបរិញ្ញាប័ត្រខាងវិទ្យាសាស្ត្រកសិកម្ម ពីសាកលវិទ្យាល័យ Humboldt ក្នុងទីក្រុងប៊ែរឡាំង ។ កញ្ញា ធ្វើការខាងផ្នែកសេដ្ឋកិច្ចសង្គម និងវប្បធម៌សង្គម របស់សហគមន៍ជនជាតិដើមនៅក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសឥណ្ឌូណេស៊ី ។ កញ្ញា មានចំណាប់អារម្មណ៍ ជាពិសេសអំពីសំណួរទាក់ទងនឹងធនធានជាសម្បត្តិរួម ស្ថាប័ន និងការផ្លាស់ប្តូរខាងផ្នែកស្ថាប័ន។

អាសយដ្ឋានទាក់ទង:
katrin-seidel@camnet.com.kh

## លោកស្រី Steph Cox



លោកស្រី Steph ជាទីប្រឹក្សាឯករាជ្យ ដែលចំណាយពេលវេលារបស់ខ្លួន ធ្វើការលើផ្នែកបរិស្ថាន និងវិចិត្រសិល្បៈ។ លោកស្រី មានសញ្ញាប័ត្រអនុបណ្ឌិតវិទ្យាសាស្ត្រខាងផ្នែកគ្រប់គ្រងតំបន់ការពារទេសភាព និងមានចំណាប់អារម្មណ៍ជាពិសេសអំពីការគ្រប់ គ្រងធនធានធម្មជាតិប្រកបដោយសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មដោយស៊ីសង្វាក់គ្នារវាងការអភិវឌ្ឍ និងការអភិរក្ស។

លោកស្រី គាំទ្រវិធីសាស្ត្រផ្អែកលើទំនាក់ទំនងរវាងគ្នា ទាក់ទងនឹងការអភិវឌ្ឍ និងការអភិរក្ស និងមានបទពិសោធន៍ក្នុងការ សម្របសម្រួលសិក្ខាសាលាតាមបែបច្នៃប្រឌិត និងបណ្តុះបណ្តាលខាងនាដសាស្ត្រ។ លោកស្រីបានធ្វើការនៅក្នុងតំបន់នេះអស់ រយៈពេល៥ ឆ្នាំមកហើយ ហើយថ្មីៗនេះបានចូលពីប្រទេសវៀតណាមមកក្នុងប្រទេសកម្ពុជា។

អាសយដ្ឋានទាក់ទង:
stephjcox@yahoo.co.uk

## លោកស្រី Erika von Kaschke



បច្ចុប្បន្ន លោកស្រី អេរីកា ធ្វើការជាទីប្រឹក្សាឯករាជ្យខាងផ្នែកទំនាក់ទំនង។ លោកស្រីមានឯកទេស ខាងការបោះពុម្ពផ្សាយ យកព័តិមាន និងសំណេរជាលក្ខណៈច្នៃប្រឌិត។

លោកស្រី អេរីកា បានសិក្សាវិទ្យាសាស្ត្រអនុវត្តខាងផ្នែកភាសានៅសាកលវិទ្យាល័យបច្ចេកវិទ្យា Cape Town ប្រទេសអាព្រិក ខាងត្បូង។ ក្រោយបញ្ចប់ការសិក្សានៅឆ្នាំ១៩៩៥ លោកស្រីបានធ្វើការឱ្យរោងពុម្ពជាច្រើន និងសហគមន៍បោះពុម្ពផ្សាយ។ លោកស្រីបានទទួលការសរសើរថាជាអ្នកយកព័ត៌មានម្នាក់ក្នុងចំណោមអ្នកយកព័តិមានពូកែបំផុតក្នុងចំណោមអ្នកយកព័តិមាន ១០រូប នៃទស្សនាវដ្តីខ្នាតតូចនៅក្នុងក្រុង នៅប្រទេសអាព្រិកខាងត្បូង។ ទស្សនាវដ្តីដែលគាត់ធ្វើការជាមួយបានទទួលរង្វាន់សម្រាប់ការសរសេរព័តិមានអំពីការងារឃ្លាំមើល ព័តិមានលើទំព័រក្របមុខល្អ និងទស្សនាវដ្តីខ្នាតតូចល្អជាងគេ នៅក្នុងរយៈពេលពីរឆ្នាំមុននេះ។

នៅក្រោយពេលមកដល់ប្រទេសកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ២០០៤ គាត់បានធ្វើការសម្រាប់ CBNRM LI ។

អាសយដ្ឋានទាក់ទង:
erica@everyday.com.kh

## លោក យ៉ង ភិរម្យ

លោក ភិរម្យ មានតួនាទីជាអ្នកសម្របសម្រួលថ្នាក់ជាតិនៃគម្រោងសម្ព័ន្ធភាពសហគមន៍ព្រៃឈើសម្រាប់កម្ពុជា របស់អង្គការសហគមន៍ព្រៃឈើអន្តរជាតិ (CFAC/CFI) ។ លោក ភិរម្យ ធ្វើការជិតស្និទ្ធជាមួយរដ្ឋបាលព្រៃឈើ (ការិយាល័យសហគមន៍ព្រៃឈើ លើកម្មវិធីសហគមន៍ព្រៃឈើជាតិ (NCFP) គម្រោងគ្រប់គ្រងទិន្នន័យសហគមន៍ព្រៃឈើ (CF Database) បណ្តាញសហគមន៍ព្រៃឈើ និងគោលការណ៍ណែនាំ អនុក្រិត្យសហគមន៍ព្រៃឈើ ។



លោក ភិរម្យ មានបរិញ្ញាប័ត្រ អក្សរសាស្ត្រអង់គ្លេស និងការអប់រំពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោក បានធ្វើការទាក់ទងវិស័យព្រៃឈើតាំងពីឆ្នាំ២000 ជាមួយអង្គការ GTZ ។ លោក ភិរម្យ ចូលរួមក្នុងការរៀបចំសៀវភៅ CBNRM នេះ ក្នុងនាមជាអ្នកគ្រប់គ្រងក្រុមហ៊ុនបកប្រែ DTS ។ លោក បកប្រែជំពូក មួយចំនួនទៅជាភាសាខ្មែរ និងជាអ្នកទទួលខុសត្រូវ ក្នុងការកែសម្រួលរចនារូបភាព និងអត្ថបទ ដោយមានការជួយពីសហសេវិក ដែលបម្រើការនៅDTS ។

អាសយដ្ឋានទាក់ទង :
yangphirom@hotmail.com or
DTScambodia@hotmail.com

## លោក ម៉ម កុសល

លោក កុសល បច្ចុប្បន្នជាប្រធានក្រុមនៃ គម្រោង "ស្វ័យវាយតម្លៃសមត្ថភាពជាតិសម្រាប់ការគ្រប់គ្រងបរិស្ថានពិភពលោក" ដែលផ្តោតលើការពិនិត្យ និងវាយតម្លៃសមត្ថភាព និងតម្រូវការសមត្ថភាពនៅកម្រិត បុគ្គល ស្ថាប័ន និងយថាប្រព័ន្ធ និងកសាងផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពសម្រាប់ឱ្យប្រទេសកម្ពុជាបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះអនុសញ្ញាសហប្រជាជាតិចំនួនបីគឺ អនុសញ្ញាស្តីពីជីវៈចម្រុះ អនុសញ្ញាក្របខ័ណ្ឌ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងរហោស្ថានកម្ម ។



លោក កុសល មានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងសមុទ្រ ដែលផ្តោតលើការកសាងផែនការ និងគ្រប់គ្រងធនធានធម្មជាតិពីសាកលវិទ្យាល័យ Dalhousie ប្រទេសកាណាដា និងមានសញ្ញាប័ត្រវិស្វករ ផ្នែកជលផលពី សាកលវិទ្យាល័យភូមិន្ទកសិកម្មក្នុងប្រទេសកម្ពុជា ។ គាត់ធ្លាប់ បានធ្វើដំណើរទៅប្រទេសជាច្រើននៅអឺរ៉ុប អាមេរិកខាងជើង អាស៊ី និងអូស្ត្រាលី ដើម្បីចូលរួមក្នុងសិក្ខាសាលាសន្និសីទ ការប្រជុំ និងការបណ្តុះបណ្តាល។ លោក កុសល បានធ្វើការ អស់ រយៈពេល១៥ឆ្នាំ ហើយ នៅក្នុងស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ និងក្នុងគម្រោងនានា ដែលផ្តោតជាសំខាន់លើការកសាងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រង តំបន់ដីសើម។ លោក កុសល មានចំណាប់អារម្មណ៍លើវិធាន ដែលមានការចូលរួម និងពហុឯកទេសក្នុងការកសាងផែនការគ្រប់គ្រងធនធាន និងការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការអប់រំបរិស្ថាន និងអភិបាលកិច្ចបរិស្ថាន។ លោក កុសល ចូលរួមក្នុងការរៀបចំសៀវភៅ CBNRM នេះ ក្នុងនាមជាអ្នកបកប្រែ និងកែសម្រួលជំពូកមួយចំនួន ។

អាសយដ្ឋានទាក់ទង : mmksl@yahoo.com

## កញ្ញា ឃឹម វីរិយា

បច្ចុប្បន្ននេះ វីរិយា ជាមន្ត្រីសម្របសម្រួលនៅមូលដ្ឋាននៃគម្រោងកសាងជំនាញ និងចំណេះដឹង (Skills and Awareness Building នៃវិទ្យាស្ថាន CBNRM LI ។ មុននេះ គាត់ជាជំនួយការគម្រោងអភិវឌ្ឍន៍ទំនាក់ទំនងដោយមានការចូលរួម (Participatory Development Communication-PDC ។ នៅឆ្នាំ ២00៤ វីរិយា ជាប្រធានក្រុមបរិស្ថានខ្មែរ ដែលមានសមាជិក៥រូបជានិស្សិតបរិស្ថាននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ក្រុមនិស្សិតនេះ បានចូលរួមក្នុងយុទ្ធនាការឯកអគ្គរាជទូតតំបន់ដីសើមប្រចាំឆ្នាំ២00៤ ដែលរៀបចំដោយអង្គការ WWF MRC Ramsar និងបណ្តាដៃគូរបស់អង្គការ WWF ជាច្រើនទៀត ។ ក្រុមរបស់គាត់ទទួលបានជ័យលាភីលេខមួយក្នុងចំណោមក្រុមនិស្សិតដែលចូលរួមដែលមានចំនួនច្រើនជាង ៦0ក្រុម ប្រចាំតំបន់មេគង្គ ។



វីរិយា មានបរិញ្ញាប័ត្រវិទ្យាសាស្ត្របរិស្ថាន ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់បានធ្វើការស្រាវជ្រាវបញ្ចប់ការសិក្សាស្តីពីបំរែបំរួលធនធានជលផល និងផលប៉ះពាល់ទៅលើការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់បឹងទន្លេសាប ។

ចំណាប់អារម្មណ៍របស់វីរិយា រួមមាន ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព អភិវឌ្ឍន៍ទំនាក់ទំនងដោយមានការចូលរួម យុទ្ធនាការបង្កើនចំណេះដឹង ការអប់រំបរិស្ថាន វិធីសាស្ត្រចូលរួមក្នុងការគ្រប់គ្រង កសាងផែនការ និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

វីរិយា ចូលរួមក្នុងការរៀបចំសៀវភៅ CBNRM ក្នុងនាមជាអ្នកកែសម្រួល ត្រួតពិនិត្យ សម្របសម្រួលដំណើរការនៃការចងក្រង និងបោះពុម្ព ព្រមទាំងរៀបចំ និងសម្របសម្រួល សិក្ខាសាលាបញ្ចប់សៀវភៅនេះជាភាសាខ្មែរ ។

អាសយដ្ឋានទាក់ទង : wirya_k@yahoo.com or
wirya@cbnrmli.org

## លោក សំអឿន សុធីរ៉ូ



សុធីរ៉ូ មានតួនាទីជាមន្ត្រីផ្នែកទំនាក់ទំនង នៃវិទ្យាស្ថាន CBNRM LI ទទួលបន្ទុកគ្រប់គ្រងទិន្នន័យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងចូលរួមក្នុងសកម្មភាពសិក្សាស្រាវជ្រាវខាងផ្នែកការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍។ ពីមុនគាត់ជាសមាជិកនៃក្រុមការងាររបស់គម្រោង អភិវឌ្ឍន៍ទំនាក់ទំនងដោយមានការចូលរួម (Participatory Development Communication–PDC នៃវិទ្យាស្ថាន CBNRM LI ។ ថ្មីៗនេះគាត់បានចូលរួមជាមួយ គម្រោងកសាងជំនាញ និងការយល់ដឹង (Skills and Awareness Building – SAB នៃវិទ្យាស្ថាន CBNRM LI ដើម្បីបង្កើតនូវកម្មវិធី មូលដ្ឋានទិន្នន័យ សំរាប់គ្រប់គ្រងទៅលើព័ត៌មាននៃវគ្គសិក្សានីមួយៗដែលរៀបចំដោយគំរោង SAB នៅតាមសហគមន៍មូលដ្ឋាននៅជុំវិញបឹងទន្លេសាប ។

លោក សុធីរ៉ូ ទទួលបានបរិញ្ញាប័ត្រវិទ្យាសាស្ត្រក្សេត្រកម្មពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម (ចំការដូង, RUA និងវិញ្ញាប័នប័ត្រជំនាញឯកទេសគ្រប់គ្រងទិន្នន័យពីសាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង (UTM ។

ក្រោយពីបញ្ចប់ការសិក្សា សុធីរ៉ូ បានអភិវឌ្ឍកម្មវិធី (Software សំរាប់គ្រប់គ្រងទិន្នន័យរុក្ខជាតិនៃប្រទេសកម្ពុជា តាមប្រព័ន្ធឌីជីថលដំបូងគេបង្អស់ក្នុងប្រទេស ឈ្មោះថា Digital Species ដែលគំរោងនេះគាំទ្រដោយស្ថានទូតចក្រភពអាល្លឺម៉ង់ និងអង្គការ DED/GTZ ។

គោលបំណងរបស់គាត់គឺធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅក្នុងវិស័យនានានៃការគ្រប់គ្រងធនធានធម្មជាតិ ដូចជាវិស័យព្រៃឈើ និងជលផលជាដើម ដែលយន្តការនេះនឹងជួយសំរួលដល់ការគ្រប់គ្រងទិន្នន័យ និងការវិភាគបែបបច្ចេកទេសអោយមានភាពរលូនប្រកបដោយបច្ចេកវិទ្យាខ្ពស់ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបង្កើតនូវប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិច E-Government ។

អាសយដ្ឋានទាក់ទង: sothyro@yahoo.com or sothyro@cbnrmli.org